# ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២

## លោក ហ៊ុន សែន ថ្លែងសុំអភ័យទោសដល់ក្រុមហ៊ុន នៅក្រៅប្រទេស ដែលមានពលករខ្មែរធ្វើការ ហើយបានត្រឡប់ មកកម្ពុជាវិញភ្លាមៗ ព្រោះតែជឿតាមការបំផុសបំផុលបែបអបិយជំនឿ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 31 August 2022 | 11:33 ICT

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី ៣១ ខែសីហា បានថ្លែងដោយសុំអភ័យទោសទៅដល់ក្រុមហ៊ុននៅក្រៅប្រទេស ដែលមានពលករខ្មែរកំពុងធ្វើការនៅទីនោះហើយបានឈប់ និងបានចាកចេញភ្លាមមកកាន់កម្ពុជាវិញ ដែលធ្វើឱ្យប៉ះពាល់ដល់ការផលិត ព្រោះតែជឿតាមការបំផុសបំផុលបែបអបិយជំនឿ ដោយប្រធានគណបក្សសម្ព័ន្ធប្រជាធិបតេយ្យ លោក ខឹម វាសនា។ លោក ហ៊ុន សែន ថ្លែងនៅក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសនៅថ្ងៃទី ៣១ ខែសីហា ថា៖ «សូមរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ជប៉ុន និងថៃ អនុញ្ញាតឱ្យខ្ញុំសុំធ្វើការអភ័យទោសអំពីកង្វះខាតនៃពលករកម្ពុជាដែលត្រូវចាញ់បោកគេ ហើយលះបង់ចោលការងារធ្វើនៅទីនោះ វិលចូលមកស្រុក សូមកុំឱ្យរដ្ឋាភិបាលនៃប្រទេសទាំងអស់ ដែលមានពលករធ្វើការនៅប្រទេសរបស់ខ្លួនដាក់ពាក្យបណ្ដឹង ទាមទារសំណងពីរដ្ឋាភិបាលកម្ពុជា ឬពីបុគ្គលិកដែលរត់ចេញចោលការងារ»។

លោក ថ្លែងថា៖ «សូមកុំផ្សារភ្ជាប់ពលករកម្ពុជាផ្សេងទៀតជាមួយអ្នកដែលប្រព្រឹត្តកំហុស ដោយសារការចាញ់បោក សម្រាប់តាព្រហ្ម (ខឹម វាសនា) នៅប្រទេសកម្ពុជា។ ខ្ញុំកំពុងតែបារម្ភអំពីចំណុចនេះថា ថៅកែមួយចំនួនដែលសង្វាក់ផលិតកម្មកំពុងដើរ ស្រាប់តែពលករចេញផុតមកប៉ះពាល់ដល់ដំណើរផលិតគេ»។ លោក ថ្លែងថាការបំផុសបំផុលនេះ មិនត្រឹមតែធ្វើឱ្យខាតប្រយោជន៍ដល់ពលករក្រៅប្រទេសប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យខាតប្រយោជន៍ដល់ពលរដ្ឋក្នុងស្រុកដែលជឿតាមការឃោសនានោះ ឈានដល់ការលក់ទ្រព្យសម្បត្តិ និងគ្រួសារខ្លះលែងគ្នាទៀតផង។

ការស្នើសុំយោគយល់ពីបណ្ដាប្រទេសទាំងនោះ បន្ទាប់ពលករដែលធ្វើការនៅប្រទេសជប៉ុន ថៃ ជាពិសេសប្រទេសកូរ៉េ បាននាំគ្នាវិលមកកម្ពុជាវិញ ដើម្បីចូលរួមជាមួយលោក ខឹម វាសនា នៅឯចម្ការរបស់លោកនៅស្រុកបន្ទាយស្រី ខេត្តសៀមរាប៕

## នាយឧត្តមសេនីយ៍ នេត សាវឿន និងនាយឧត្តមសេនីយ៍ សៅ សុខា ដឹកនាំកិច្ចប្រជុំអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ

http://freshnewsasia.com/ 2022-08-30 06:55pm

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជាប្រធានក្រុមការងារចាត់តាំងអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ និងនាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការចាត់តាំងអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

កិច្ចប្រជុំនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២នេះ ក៏មានការអញ្ជើញចូលរួមពីលោក លោកស្រី នាយនគរបាល អាវុធហត្ថជាអនុប្រធាន និងជាសមាជិកក្រុមការងារជាច្រើនរូបទៀត។ លោកឧត្តមសេនីយ៍ឯក ឆាយ

គឹមខឿន អគ្គស្នងការរងនគរបាលជាតិ បានឲ្យដឹងថា កិច្ចប្រជុំនេះមានគោលបំណង ដើម្បីពិគ្រោះពិភាក្សាអំពីគោលការណ៍សំខាន់ៗ ជាអាទិភាពសម្រាប់បើកប្រតិបត្តិការអនុវត្តផែនការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់អំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងការជួញដូរផ្លូវភេទ។

ក្នុងអង្គប្រជុំក៏បានឯកភាពគ្នា ទៅលើគោលការណ៍សំខាន់ៗ សម្រាប់បម្រើឲ្យកិច្ចសហប្រតិបត្តិការទាំងការកំណត់គោលដៅ មុខសញ្ញា សម្រាប់ធ្វើការស្រាវជ្រាវ ស៊ើបអង្កេត និងសង្គ្រោះ ជាពិសេស គឺការដាក់ចេញនៅវិធានការសំដៅអនុវត្តឲ្យមានប្រសិទ្ធភាពឆ្លើយតបទៅនឹងគោលបំណង និងសំណូមពរនៃផែនការ។ លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានបញ្ជាក់ថា អង្គប្រជុំក៏ទទួលបានធាតុចូលសំខាន់ៗ ពីសមាជិក សមាជិកា ហើយក៏បានឯកភាពគ្នាការធ្វើការផ្សព្វផ្សាយខ្លឹមសារប្រតិបត្តិការដាក់ស្តែងនៅថ្ងៃសុក្រខាងមុខនេះ៕

## សមត្ថកិច្ច ស្រាវជ្រាវតាមបណ្តឹងចូលប្រព័ន្ធ Hotline រកឃើញជនជាតិម៉ាឡេស៊ី ១៦នាក់ និងឃាត់ជនជាតិចិន១នាក់

https://freshnewsasia.com/ 2022-08-30 06:14pm

**(ព្រះសីហនុ)៖** កម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ នៅរសៀលថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ បានចុះត្រួតពិនិត្យទីតាំងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅភូមិ៦ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ ដោយរកឃើញជនជាតិម៉ាឡេស៊ី ១៦នាក់ ត្រូវគេបង្ខាំងទុកឱ្យធ្វើការ និងឃាត់ជនជាតិចិន ១នាក់។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា ប្រតិបត្តិការនេះ បានធ្វើឡើងបន្ទាប់ពីមានបណ្តឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេង ថាមានការចាប់បង្ខាំងទុកជនជាតិម៉ាឡេស៊ី ១៦នាក់ ដើម្បីឱ្យនៅបម្រើការងារក្នុងក្រុមហ៊ុន នៅក្នុងខេត្តព្រះសីហនុ ចំនួន ០១ករណី។ ក្នុងចំណោមជនរងគ្រោះ ចំនួន ១៦ នាក់ មានស្រី ០៥ នាក់ផងដែរ។

នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា ដោយបានចុះទៅដល់ទីតាំង និងមានការចូលរួមសហការពីម្ចាស់ទីតាំង កម្លាំងសមត្ថកិច្ចបានស្វែងរកឃើញ បុរស ស្ត្រី ជនជាតិម៉ាឡេស៊ី ១៦នាក់ (ដែលក្នុងបណ្តឹងអះអាងថាជាជនរងគ្រោះ) កំពុងធ្វើការនៅក្នុងក្រុមហ៊ុនខាងលើ ទើបកម្លាំងសមត្ថកិច្ចបាននាំអ្នកគ្រប់គ្រងជនជាតិចិន ០១នាក់ មកធ្វើការសាកសួរ បន្តនីតិវិធី៕

## អ្នកនាំពាក្យក្រសួងការងារ៖ ពលរដ្ឋខ្មែរជាង៥០០នាក់ នៅជប៉ុន និងកូរ៉េខាងត្បូង បានឈប់ពីការងារ និងការសិក្សាត្រឡប់មកផ្ទះវិញ ដោយសារជឿលើ លោក ខឹម វាសនា

http://freshnewsasia.com/ 2022-08-31 02:30pm

**(ភ្នំពេញ)៖** យ៉ាងហោចណាស់ មានពលរដ្ឋខ្មែរប្រមាណ៥០០នាក់ ក្នុងនោះមាននៅកូរ៉េខាងត្បូងជាង ៤០០នាក់ និងនៅជប៉ុនជាង១០០នាក់ បានឈប់ពីការងារ និងការសិក្សា ត្រឡប់មកផ្ទះវិញ បន្ទាប់ពីពួកគេជឿលង់នឹងការឃោសនាបែបសាសនារបស់ លោក ខឹម វាសនា ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា ក្នុងចន្លោះថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែសីហា កន្លងទៅនេះ នៅកូរ៉េខាងត្បូងមានពលរដ្ឋខ្មែរចំនួនជាង៤០០នាក់ និងនៅជប៉ុនមានពលរដ្ឋខ្មែរប្រហែល ១០០នាក់ ក្នុងនោះក៏មាននិស្សិតថ្នាក់បណ្ឌិតរៀននៅតំបន់កាន់សៃនៃប្រទេសជប៉ុន ១នាក់ផងដែរ បានឈប់ត្រឡប់មកវិញ។ លោកបានបន្ថែមថា អ្នកខ្លះត្រឡប់មកវិញ ដោយយកហេតុផលថា ឪពុកម្តាយឈឺធ្ងន់ដើម្បីថៅកែអនុញ្ញាតច្បាប់។ អ្នកខ្លះទៀតគឺសុំថៅកែ ប៉ុន្តែថៅកែមិនឲ្យក៏

ឈប់ទាំងអត់ច្បាប់ ក៏បោះបង់ចោលការងារហើយត្រឡប់មកខ្មែរវិញតាមការឃោសនាអកុសល បែបអបិយជំនឿ មិនសមហេតុផលរបស់ លោក ខឹ ម វាសនា តែម្តង។

ទោះជាយ៉ាងណា លោកបានបញ្ជាក់បន្ថែមថា នៅក្រៅប្រទេស ចាប់ពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២មក មិនមានចលនាបោះបង់ចោលការងារត្រឡប់មកខ្មែរទៀតទេ។ លោកបានបន្ថែមថា ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងបានជួបជាមួយតំណាងអង្គភាពអភិវឌ្ឍធនធានមនុស្សកូរ៉េ (HTD Korea) ដើម្បីសុំទោសរដ្ឋាភិបាលកូរ៉េ ជាពិសេសនិយោជកកូរ៉េ ដែលរងផលប៉ះពាល់ដោយការចលាចលនេះ។ ស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ និងជប៉ុន ព្រមទាំងភាគីពាក់ព័ន្ធ ក៏បានចុះជួបបងប្អូនពលករ និងនិយោជកកូរ៉េ និងជប៉ុន ដែលរងផលប៉ះពាល់ផងដែរ។ «ទន្ទឹមនឹងនេះយើងក៏បានសំណូមពរដល់និយោជកកូរ៉េ និងជប៉ុនមេត្តាយោគយល់ជាអតិបរិមាដល់បងប្អូនពលករ និងសិក្ខាកាមយើងកុំប្តឹងបងប្អូនយើង ព្រមទាំងពិចារណាទទួលយកបងប្អូនពលករ និងសិក្ខាកាមយើងវិញតាមលទ្ធភាពជាក់ស្តែង»។ នេះបើតាមការបញ្ជាក់របស់ លោក ហេង សួរ។

សូមបញ្ជាក់ថា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានអាកាស ក្នុងរាជធានីភ្នំពេញចំនួនពីរបន្ថែមទៀត នាព្រឹកថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២នេះ ក៏បានសុំអភ័យទោសរដ្ឋាភិបាលកូរ៉េ ជប៉ុន និងថៃផងដែរ ហើយសុំកុំឱ្យដាក់ពាក្យបណ្តឹងលើពលករ ដែលរត់ចោលការងារ ព្រោះពួកគេបានចាញ់បោកការឃោសនារបស់ លោក ខឹម វាសនា តែប៉ុណ្ណោះ៕

## ជាង១០ថ្ងៃនេះ សម្តេចក្រឡាហោម ស ខេង ទទួលបានបណ្តឹងតាមផេកហ្វេសប៊ុកចំនួន៤០ ពាក់ព័ន្ធករណីបង្ខាំង និងជួញដូរមនុស្ស ហើយរំដោះជនរងគ្រោះបានជាង១០០នាក់

http://freshnewsasia.com/ 2022-08-31 04:46pm

**(ភ្នំពេញ)៖** ជាង១០ថ្ងៃមកនេះ ពោលគឺចាប់ពីថ្ងៃទី១៨ ដល់ទី២៩ ខែសីហា ឆ្នាំ២០២២ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានពាក្យបណ្តឹងចំនួន៤០ តាមទំព័រហ្វេសប៊ុករបស់សម្តេច ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍សង្គ្រោះលើការបង្ខាំង និងជួញដូរ ហើយក្នុងនោះសមត្ថកិច្ចក៏បានបើកប្រតិបត្តិការជាបន្តបន្ទាប់ ដោយជួយរំដោះជនរងគ្រោះជាង១០០នាក់ផងដែរ។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២នេះថា ក្នុងចំណោមពាក្យបណ្តឹងទាំង ៤០នោះ សមត្ថកិច្ចបានជួយជនរងគ្រោះរួមមាន ជនជាតិអាមេរិកចំនួន២នាក់ ឥណ្ឌូនេស៊ីចំនួន១នាក់ ជនជាតិចិនចំ នួន៣៨នាក់ ជនជាតិម៉ាឡេស៊ីចំនួន៥៣នាក់ វៀតណាមចំនួន៥នាក់ ចិនតៃវ៉ាន់ ចំនួន៣នាក់ និងខ្មែរចំនួន១នាក់ផងដែរ។

សូមជម្រាបថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់ សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្តេចក្រឡាហោម បានសម្តែងការសោកស្តាយ និងថ្កោលទោសចំពោះអំពើដ៏អមនុស្សធម៌ទាំងនេះ។ សម្តេចក៏បានថ្លែងអំណរគុណ និងស្វាគមន៍ចំពោះការផ្តល់ព័ត៌មានផ្សេងៗ ពីសំណាក់បុគ្គល និងស្ថានតំណាងបរទេសប្រចាំកម្ពុជា នាពេលកន្លងមកពាក់ព័ន្ធទៅនឹងករណីខាងលើនេះ។

**សូមបញ្ជាក់ថា ការផ្តល់ព័ត៌មានក៏អាចផ្ញើទៅបានតាមរយៈ៖**

១៖ គេហទំព័រ Facebook: Samdech Krolahom Sar Kheng, Cambodian Deputy Prime Minister
២៖ លេខទូរសព្ទHotlineរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ:១១៧ និង (+៨៥៥) ៣១ ២០១ ២៣៤៥
៣៖ គេហទំព័រ Facebook: អគ្គស្នងការដ្ឋាននគរបាលជាតិ-General Commissariat of Natioral Police
៤៖ គេហទំព័រFacebook:អគ្គនាយកដ្ឋានអន្តោប្រវេសន៍-General Department of Immigration-GDI៕

## សមត្ថកិច្ចស្រាវជ្រាវតាមបណ្តឹងចូលប្រព័ន្ធ Hotline ក្រុមការងារ សម្តេចក្រឡាហោម ស ខេង រកឃើញជនជាតិចិន ១នាក់

https://freshnewsasia.com/ 2022-08-31 06:06pm

**(ព្រះសីហនុ)៖** កម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២នេះ បានចុះស្រាវជ្រាវនៅទីតាំងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុងព្រះសីហនុ ដោយស្រាវជ្រាវស្វែងរកឃើញជនរងគ្រោះ ចំនួន០១នាក់។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News ឱ្យដឹងថា ប្រតិបត្តិការនេះ បានធ្វើឡើងបន្ទាប់ពីមាន បណ្ដឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេ ថាត្រូវបានគេចាប់បង្ខាំងទុក ដើម្បីឱ្យនៅបម្រើការងារក្នុងក្រុមហ៊ុន នៅក្នុងខេត្តព្រះសីហនុ ចំនួន ០១ករណី។ នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចុះមកដល់ទីតាំងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ស្រាវជ្រាវស្វែងរកឃើញជនរងគ្រោះចំនួន០១នាក់ ភេទស្រី អាយុ ២៤ ឆ្នាំ ដែលជាជនជាតិចិន។ បន្ទាប់មកកម្លាំងសមត្ថកិច្ចបាននាំអ្នកគ្រប់គ្រងជនជាតិចិន០១នាក់ ភេទប្រុស មកធ្វើការសាកសួរ តាមនីតិវិធីជំនាញនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដើម្បីសួរនាំ បន្តតាមនីតិវិធី៕

## Hotline ១១៧ ត្រូវបានជនបរទេសរាយការណ៍ និងសុំកិច្ចអន្តរាគមន៍ ឲ្យជួយជាបន្ទាន់ ករណីបង្ខាំងមនុស្ស ក្រោយនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ប្រកាសបន្ថែមមន្ត្រីនគរបាល ១១៧ អាចសន្ទនាភាសា ចិន វៀតណាម និងអង់គ្លេស

https://gntimes.com/ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

ភ្នំពេញ៖ នៅរសៀលថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២២ នេះ មជ្ឈមណ្ឌលប្រចាំបញ្ជា នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (Hotline : ១១៧) បានចេញរបាយការណ៍បណ្ដោះអាសន្ន ពាក់ព័ន្ធនឹងករណី បង្ខាំងមនុស្ស ចំនួន ៥ ករណី ស្ថិតក្នុងរាជធានី-ខេត្ត ចំនួន ៤ ផ្សេងគ្នា ដែលទទួលបានប្រភពពីជនជាតិវៀតណាមរាយការណ៍ និងសុំកិច្ចអន្តរាគមន៍ជួយពួកគាត់ ។

ករណីទី ១ នៅវេលាម៉ោង ១០ : ២៥ នាទី ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០២២ ប្រភពពីអ្នកជិះតាក់ស៊ីជាមួយជនរងគ្រោះជាជនជាតិវៀតណាម ដែលបានរត់ចេញរួចពីកន្លែងបង្ខាំង ដោយបញ្ជាក់ទីតាំងនៅ រាជធានីភ្នំពេញ និងសុំអន្តរាគមន៍ ឲ្យជួយពួកគាត់ ។ បន្ទាប់ពីទទួលបានព័ត៌មានខាងលើ មជ្ឈមណ្ឌលប្រចាំបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបញ្ជូនព័ត៏មានជូន លោក ម៉ៅ ពៅ អនុប្រធានសេនាធិការទទួលបន្ទុកមជ្ឈមណ្ឌលប្រចាំបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅម៉ោង ១១:៣០ នាទី ។

ករណីទី ២ នៅវេលាម៉ោង ១០:៣០ នាទី ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០២២ បងប្រុសរបស់ជនរងគ្រោះ ជាជនជាតិវៀតណាម បានរាយការណ៍មកលេខ ១១៧ ដោយបានបញ្ជាក់ពីទីតាំងក្រុងបាវិត ខេត្តស្វាយរៀង និងសុំ

អន្តរាគមន៍ ឲ្យជួយពួកគាត់ ។ ក្រោយទទួលបានព័ត៌មាន មជ្ឈមណ្ឌលប្រចាំបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបញ្ជូនព័ត៌មានជូន លោក ម៉ៅ ពៅ អនុប្រធានសេនាធិការទទួលបន្ទុកមជ្ឈមណ្ឌលប្រចាំបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅម៉ោង ១១:៣៥ នាទី ។

ករណីទី ៣ វេលាម៉ោង ១២:៥៨ នាទី ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២២ ប្រភពពីជនរងគ្រោះ ជាជនជាតិវៀតណាម បានរាយការណ៍មកសមត្ថកិច្ច ១១៧ ដោយបញ្ជាក់ទីតាំង ខេត្តព្រះសីហនុ និងសុំអន្តរាគមន៍ ឲ្យជួយពួកគាត់ ។ មជ្ឈមណ្ឌលប្រចាំបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបញ្ជូនព័ត៌មានជូន លោក ម៉ៅ ពៅ អនុប្រធានសេនាធិការទទួលបន្ទុកមជ្ឈមណ្ឌលប្រចាំបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅម៉ោង១៣:០៥ នាទី ។

និងករណីទី ៤ នៅវេលាម៉ោង ១៣:០០ នាទី ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២២ ប្រភពពីជនរងគ្រោះ ជាជនជាតិវៀតណាម ដោយបានប្រាប់ពីទីតាំងនៅ អូរស្មាច់ ខេត្តឧត្តរមានជ័យ និងសុំអន្តរាគមន៍ ឲ្យជួយពួកគាត់ ។ មជ្ឈមណ្ឌលប្រចាំបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបញ្ជូនព័ត៌មានជូន លោក ម៉ៅ ពៅ អនុប្រធានសេនាធិការទទួលបន្ទុកមជ្ឈមណ្ឌលប្រចាំបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅម៉ោង ១៣:០៨ នាទី ។

ករណីទី ៥ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២២ វេលាម៉ោង ១៥:១៤ នាទី ករណីបង្ខាំងមនុស្ស (ជនជាតិវៀតណាម) ទទួលបានប្រភពពីបងប្រុសជនរងគ្រោះ ដោយបានបញ្ជាក់ពីទីតាំងក្រុងបាវិត ខេត្តស្វាយរៀង និងសុំអន្តរាគមន៍ ឲ្យជួយពួកគាត់ ។ មជ្ឈមណ្ឌលប្រចាំបញ្ជា នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបញ្ជូនព័ត៌មានជូន លោក ម៉ៅ ពៅ អនុប្រធានសេនាធិការទទួលបន្ទុកមជ្ឈមណ្ឌលប្រចាំបញ្ជា នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅម៉ោង ១៧ និង ១៨ នាទី ។

# ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២

## រំដោះជនជាតិវៀតណាម២នាក់ ខណៈរត់គេចចេញពីក្រុមហ៊ុនចិន និងសុំកិច្ចអន្តរាគមន៍ពីសមត្ថកិច្ចឲ្យជួយ

https://www.kampucheathmey.com/ ថ្ងៃពុធ ៣១ សីហា ២០២២ដោយ Kang Tola

ភ្នំពេញ ៖ កុមារានិងយុវជន ជនជាតិវៀតណាម២នាក់ ត្រូវបានកម្លាំងផ្នែកជំនាញ នៃអធិការដ្ឋាននគរបាលខណ្ឌទួលគោក សហការជាមួយកម្លាំងការិយាល័យស៊ើបអង្កេតនិងអនុវត្តនីតិវិធី នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានរំដោះខណៈពួកគេបានរត់គេចចេញពីក្រុមហ៊ុនចិននិងបានសុំកិច្ចអន្តរាគមន៍ពីសមត្ថកិច្ចឲ្យជួយពួកគេ។ ហេតុការណ៍បានកើតឡើងកាលពីវេលាម៉ោងប្រហែល១០និង៥០នាទីព្រឹក ស្ថិតនៅចំណុចមុខមន្ទីរពេទ្យកុមារជាតិ ផ្លូវលេខ២៥៣ ភូមិ១៣ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

មន្ត្រីប៉ូលិសខណ្ឌទួលគោកបានឲ្យដឹងថា នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១០និង៥០នាទីព្រឹក កម្លាំងផ្នែកជំនាញនៃអធិការដ្ឋាននគរបាលខណ្ឌទួលគោក បានសហការជាមួយកម្លាំងការិយាល័យស៊ើបអង្កេតនិងអនុវត្តនីតិវិធី នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានទទួលព័ត៌មានថា មានជនជាតិវៀតណាមចំនួន០២នាក់ស្នើសុំកិច្ចអន្តរាគមន៍ពីសមត្ថកិច្ចយើងឲ្យជួយ ស្ថិតនៅចំណុចមុខមន្ទីរពេទ្យកុមារជាតិ ផ្លូវលេខ ២៥៣ ភូមិ១៣ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ បន្ទាប់ពីទទួលព័ត៌មានកម្លាំងផ្នែកជំនាញនៃអធិការដ្ឋាននគរបាលខណ្ឌទួលគោក បានសហការជាមួយកម្លាំងការិយាល័យស៊ើបអង្កេតនិងអនុវត្តនីតិវិធី នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានអញ្ជើញជនជាតិវៀតណាមទាំងពីរនាក់ខាងលើ មកស្នាក់ការប៉ុស្តិ៍ដើម្បីសាកសួរព័ត៌មានរបស់គាត់ ជនជាតិវៀតណាម២នាក់ ទី១-ឈ្មោះ Pham cong Luu ភេទប្រុស អាយុ១៧ឆ្នាំ ជន

ជាតិវៀតណាម (គ្មានលិខិតឆ្លងដែន) ។ទី២-ឈ្មោះ Nguyen ven hung ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិវៀតណាម (គ្មានលិខិតឆ្លងដែន) ។

ឆ្លងតាមការឆ្លើយបំភ្លឺអះអាងរបស់ជនជាតិវៀតណាមទាំងពីរខាងលើ បានបំភ្លឺអះអាងថា ពួកខ្លួនទាំងពីរនាក់ត្រូវបានមេខ្យល់ជនជាតិវៀតណាមភេទស្រីម្នាក់ អាយុប្រហែល១៨ឆ្នាំ បាននាំយកមកធ្វើការក្រុមហ៊ុនចិនឈ្មោះ Kingcwnao ព្រំដែនបាវិតក្នុងដីកម្ពុជា តាំងតែពីក្នុងខែមិថុនា ឆ្នាំ២០២២ កន្លះខែក្រោយមកក្រុមហ៊ុនចិនខាងលើបានប្តូរទីតាំងការងារពួកខ្លួនទាំងពីរនាក់ឲ្យទៅក្រុមហ៊ុនចិនមួយទៀតនៅក្រុងព្រះសីហនុ រហូតមកដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ក្រុមហ៊ុនចិននៅក្រុងព្រះសីហនុ បាននាំពួកខ្លួន០២នាក់មកភ្នំពេញ មកដល់ភ្នំពេញនៅម៉ោងប្រហែល១០និង៣៥នាទី ពួកខ្លួន០២នាក់បានលួចរត់គេចខ្លួនមកឈរនៅមុខពេទ្យកុមារជាតិរួចហើយពួកខ្លួន០២នាក់បានសុំទូរស័ព្ទរបស់ប្រជាពលរដ្ឋជនជាតិខ្មែរ ខលទៅប្តឹងសមត្ថកិច្ចកម្ពុជាដើម្បីឲ្យជួយអន្តរាគមន៍ពួកខ្លួន និងសំណូមពរឲ្យសមត្ថកិច្ចជួយបញ្ជូនពួកខ្លួនទាំងពីរនាក់ទៅស្រុកកំណើតវិញ នៅប្រទេសវៀតណាមវិញ។ ចំពោះមុខកម្លាំងសហការបានកំពុងសាកសួរជនជាតិវៀតណាមខាងលើដើម្បីបន្តអនុវត្តតាមនីតិវិធី៕*ដោយ ស្រីរ័ត្ន*

## នាយឧត្តមសេនីយ៍ នេត សាវឿន ដាក់ចេញការងារទិសដៅអាទិភាពមួយចំនួន សំដៅទប់ស្កាត់ និងបង្ការបទល្មើសក្នុងសង្គម

http://freshnewsasia.com/ 2022-08-31 07:35pm

**(ភ្នំពេញ)៖** ក្នុងឱកាសអញ្ជើញប្រកាសចូលកាន់តំណែង អគ្គស្នងការរងនគរបាលជាតិ និងប្រធាននាយកដ្ឋានជំនាញ នៅរសៀលថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២នេះ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានដាក់ចេញនូវទិសដៅការងារអាទិភាពមួយចំនួន សំដៅបន្តទប់ស្កាត់ បង្ការ និងបង្ក្រាបបទល្មើសផ្សេងៗ នៅក្នុងសង្គម។

**លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរង និងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ បានឲ្យដឹងថា ទិសដៅសំខាន់ ដែលត្រូវបានដាក់ចេញ ដោយនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន សម្រាប់ទប់ស្កាត់ និងបង្ការបទល្មើសផ្សេងៗ ក្នុងនោះរួមមាន៖**

**ទី១៖** អនុវត្តភារកិច្ចសំខាន់បំផុតត្រូវការពារឲ្យបាននូវសន្តិភាព ធានាបាននូវស្ថេរភាពសន្តិសុខ សណ្តាប់ធ្នាប់សង្គម សុវត្ថិភាពសាធារណៈ ការពារឲ្យបាននូវបាវចនាជាតិ សាសនា ព្រះមហាក្សត្រ ការពាររដ្ឋធម្មនុញ្ញ ការពាររាជរដ្ឋាភិបាលស្របច្បាប់ និងបន្តបញ្ចៀសឲ្យបាននូវអំពើភេរវកម្មមិនឲ្យកើតមាននៅលើប្រទេសកម្ពុជា រួមទាំងឧបាយកល សកម្មភាពផ្សេងទៀត ដែលប៉ុនប៉ងធ្វើសកម្មភាពនៅកម្ពុជា គឺត្រូវការពារឲ្យបានដាច់ខាត។

**ទី២៖** បន្តកាត់បន្ថយឲ្យបាននូវបទល្មើស ដើម្បីបង្កើនភាពកក់ក្តៅជូនប្រជាពលរដ្ឋ ជាពិសេសជំរុញការអនុវត្តផែនការយុទ្ធនាការសំខាន់ៗរបស់រាជរដ្ឋាភិបាល របស់ក្រសួងមហាផ្ទៃ និងរបស់អគ្គស្នងការនគរបាលជាតិ ពិសេសផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន ផែនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំសង្កាត់ មានសុវត្ថិភាព ដើម្បីធានាឲ្យបាននូវនិរន្តភាព ស្ថេរភាពសង្គមរបស់យើង។

**ទី៣៖** ការបន្តពង្រឹងឲ្យបានរឹងមាំ នូវការដោះស្រាយសណ្តាប់ធ្នាប់ ចរាចរណ៍ទូទៅ ដោយត្រូវបន្តពង្រឹងអនុវត្តច្បាប់ បន្តធ្វើការត្រួតពិនិត្យ និងដោះស្រាយបញ្ហាកកស្ទះចរាចរណ៍ ព្រមទាំងផ្សព្វផ្សាយលើកកម្ពស់ការអនុវត្តច្បាប់ឲ្យបានកាន់តែល្អប្រសើរ កាត់បន្ថយគ្រោះថ្នាក់ ហានិភ័យ ដោយសារគ្រោះថ្នាក់ចរាចរណ៍។

បន្ថែមពីនេះ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានផ្តាំផ្ញើដល់នាយនគរបាលជាន់ខ្ពស់ ដែលទើបប្រកាសចូលកាន់តំណែងត្រូវសហការជាមួយថ្នាក់ដឹកនាំក្នុងក្របខ័ណ្ឌអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ដូចជា

ស្ថាប័នខាងក្រៅ និងអង្គភាពនគរបាលគ្រប់ថ្នាក់ ដើម្បីបន្តកិច្ចសម្រេចគោលដៅសំខាន់ គឺការស្ថិរភាពសន្តិសុខ សណ្តាប់ធ្នាប់សង្គម។

ពាក់ព័ន្ធការវាយតម្លៃសភាពការណ៍ប៉ុន្មានខែចុងក្រោយ ឆ្នាំ២០២២ ជារួមមានស្ថានភាពល្អប្រសើរ បើប្រៀបធៀបរយៈពេលដូចគ្នាឆ្នាំកន្លងទៅ ជាពិសេសក្នុងពេលដែលពិភពលោកកំពុងតែប្រឈមនឹងបញ្ហាជាច្រើន រួមទាំងសង្គ្រាម នុយក្លេអ៊ែរ វិវាទតាមដែនកោះ ដែនសមុទ្រ បញ្ហាជំងឺឆ្លងជាដើម។

ប៉ុន្តែកម្ពុជាមិនមានអ្វីជាបញ្ហានោះទេ ពោលស្ថានភាពសន្តិសុខ សណ្តាប់ធ្នាប់មានលក្ខណៈល្អប្រសើរ ដោយរក្សាបានព្រំដែនសន្តិភាព ស្ថេរភាព សហប្រតិបត្តិការ ធានាបាននូវប្រក្រតីភាពសង្គម ការពារបាននូវគ្រប់កិច្ចការងារសំខាន់ៗ ពិសេសពាក់ព័ន្ធការងារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន។ បន្ថែមពីនេះ ក៏ទទួលបានជោគជ័យក្នុងការថែរក្សាសុវត្ថិភាព សន្តិសុខ ក្នុងដំណើរការបោះឆ្នោតឃុំសង្កាត់ កន្លងមកនេះ៕

## នាយឧត្តមសេនីយ៍ ខៀវ សុភ័គ៖ ប្រតិបត្តិការពាកន្លែងទៀត នៅខេត្តព្រះសីហនុ រកឃើញជនរងគ្រោះ៥នាក់

https://freshnewsasia.com/ 2022-09-01 11:07am

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា នៅរសៀល ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ម្សិលមិញនេះ សមត្ថកិច្ចខេត្តព្រះសីហនុ បានបើកប្រតិបត្តិការពាកន្លែងទៀត ដោយសង្គ្រោះជនរងគ្រោះចំនួន៥នាក់។

ប្រតិបត្តិការទី១ បានធ្វើឡើងវេលាម៉ោង១៖៣០នាទីរសៀល នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២ កម្លាំងនគរបាលការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី ផែនការងារអន្តោប្រវេសន៍ បានចុះទៅទីតាំងសួនឧស្សាហកម្មអូស្លា ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ដោយមានការសហការពីម្ចាស់ទីតាំង កម្លាំងនគរបាលបានជួយសង្គ្រោះបុរសជនជាតិចិន២នាក់ ក្នុងនោះទី១ ឈ្មោះ KANG JIANJUN អាយុ២៣ឆ្នាំ និងទី២ឈ្មោះ LIU JUNKAI អាយុ២៨ឆ្នាំ។

ប្រតិបត្តិការមួយទៀត ធ្វើឡើងចាប់ពីវេលាម៉ោង៥ល្ងាច ដោយកម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចុះទៅដល់ក្រុមហ៊ុនមួយកន្លែង ស្ថិតនៅ ភូមិ៣ សង្កាត់១ ក្រុងព្រះសីហនុ ដើម្បីស្វែងរកនារីរងគ្រោះ តាមបណ្តឹង Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេង។ ករណីនេះម្ចាស់ទីតាំង បាននាំសមត្ថកិច្ចទៅបន្ទប់នារីរងគ្រោះធ្វើការ តែមិនឃើញនារីរងគ្រោះនៅទីនោះទេ បន្ទាប់មក សមត្ថកិច្ចបានសួរនាំមេក្រុមរបស់នារីរងគ្រោះ បានឱ្យដឹងថា នារីរងគ្រោះត្រូវបានក្រុមហ៊ុនដឹកទៅទីតាំងក្រុមហ៊ុនមួយកន្លែងទៀត បន្ទាប់មកសមត្ថកិច្ចបានធ្វើការតាមជំនាញ ហើយបានឱ្យមេការរបស់នារីរងគ្រោះនាំនាងមកវិញ លុះដល់វេលាម៉ោង ៨៖៣០នាទីយប់ ទើបមេការរបស់នារីរងគ្រោះដឹកនាង និងមិត្តប្រុសរបស់នាងមកក្រុមហ៊ុនវិញ បន្ទាប់មកទៀត កម្លាំងសមត្ថកិច្ចបានធ្វើការឆែកឆេរបន្ទប់ការិយាល័យនៅជាន់ទី៧ ជាលទ្ធផលរកឃើញដំបង់ឆក់ ១ដើម និងខ្នោះដៃ២គូ មានកូនសោរខ្នោះ២ ក្រោយមកកម្លាំងសមត្ថកិច្ចបាននាំជនរងគ្រោះទាំង២នាក់ និងធ្វើការឃាត់ខ្លួនមនុស្សចំនួន៤នាក់ ភេទប្រុស មកធ្វើការសាកសួរ។

ចំណែកករណីទី៣ បានប្រតិបត្តិការ នៅវេលាម៉ោង៥៖៥០នាទីល្ងាច ដោយកម្លាំងនគរបាលការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី ផែនការងារអន្តោប្រវេសន៍ បានចុះទៅទីតាំងក្រុមហ៊ុន ជីងឆាយអ៊ូ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ដោយមានការសហការពីម្ចាស់ទីតាំងខាងលើ កម្លាំងនគរបាលបានជួយសង្គ្រោះបុរសជនជាតិម៉ាឡេស៊ី១នាក់ ឈ្មោះ BONG JUNE SIN អាយុ៣៨ឆ្នាំ។ បច្ចុប្បន្នកម្លាំងនគរបាលការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី កំពុងធ្វើការសាកសួរដើម្បីបន្តនីតិវិធី។

សូមជម្រាបថា ជាង១០ថ្ងៃមកនេះ ពេលគឺចាប់ពីថ្ងៃទី១៨ ដល់ទី២៩ ខែសីហា ឆ្នាំ២០២២ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានពាក្យបណ្តឹងចំនួន៤០ តាមទំព័រហ្វេសប៊ុករបស់សម្តេច ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍សង្គ្រោះលើការបង្ខាំង និងជួញដូរ ហើយក្នុងនោះសមត្ថកិច្ចក៏បានបើកប្រតិបត្តិការជាបន្តបន្ទាប់ ដោយជួយរំដោះជនរងគ្រោះជាង១០០នាក់ផងដែរ៕

## មន្ត្រីនគរបាលជំនាញឯកភាពគ្នាទៅលើគោលការណ៍សហប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស

https://www.postkhmer.com/ វ៉ែន ដារ៉ា | Publication date 31 August 2022 | 17:22 ICT

**ភ្នំពេញៈ** អគ្គស្នងការនគរបាលជាតិ និងក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឯកភាពគ្នាទៅលើគោលការណ៍សំខាន់ៗ លើកិច្ចសហប្រតិបត្តិការ ក្នុងការកំណត់គោលដៅ មុខសញ្ញា សម្រាប់ធ្វើការស្រាវជ្រាវ ស៊ើបអង្កេត និងសង្គ្រោះក្នុងការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទនៅកម្ពុជា។ នេះបើតាមលោក ឆាយ គឹមខឿន អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិ។

ការឯកភាពគ្នានេះតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការចាត់តាំងអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដែលដឹកនាំដោយលោក នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងមានការចូលរួមពីក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក) កាលពីថ្ងៃទី ៣០ ខែសីហា នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

លោក កត្តា អ៊ន អ្នកនាំពាក្យ គ.ស.ម.ក. បានថ្លែងកាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២២ ថា តាមរយៈកិច្ចប្រជុំនេះ ក្រុមការងារបានឯកភាពលើការពង្រឹងកិច្ចសហការ និងចែករំលែកព័ត៌មានគ្នាក្នុងការបំពេញភារកិច្ចរវាងស្ថាប័នពាក់ព័ន្ធក្នុងសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្មការងារ និងអាជីវកម្មផ្លូវភេទ។ លោកថ្លែងថាៈ «ក្នុងកិច្ចប្រជុំនេះ ក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បានឯកភាពគ្នាប្រឹងប្រែងពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព លុបបំបាត់ភាពអសកម្ម និងអំពើខុសច្បាប់របស់មន្ត្រីមួយចំនួនផងដែរ»។ លោក កត្តា អ៊ន បានឱ្យដឹងថា ក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឯកភាពពង្រឹងផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនានា ជាពិសេសច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្ស ច្បាប់អន្តោប្រវេសន៍ ច្បាប់ការងារ និងលិខិតបទដ្ឋានគតិយុត្តនានាជាដើម។

លោកបន្តថា ក្រៅពីនេះក្រុមការងារ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឯកភាពពង្រឹងការគ្រប់គ្រងជនអន្តោប្រវេសន៍ និងជនបរទេសចេញចូល និងស្នាក់នៅកម្ពុជា។ អន្តរាគមន៍ឱ្យទាន់ពេលវេលា និងចាត់វិធានការផ្លូវច្បាប់ ក្នុងការងារបង្ក្រាប និងស៊ើបអង្កេតចាប់ខ្លួនជនល្មើស និងជនពាក់ព័ន្ធយកមកផ្តន្ទាទោសតាមច្បាប់។ លោកបញ្ជាក់ថា ក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឯកភាពថែមទៀតលើកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងវិធានការបង្ក្រាបបទល្មើស និងបង្កើនសមត្ថភាពមន្ត្រីជំនាញក្នុងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនេះ។

លោក ឆាយ គឹមខឿន បានថ្លែងក្រោយកិច្ចប្រជុំថា កិច្ចប្រជុំនេះមានគោលបំណង ដើម្បីពិគ្រោះពិភាក្សាអំពីគោលការណ៍សំខាន់ៗជាអាទិភាព សម្រាប់បើកប្រតិបត្តិការអនុវត្តផែនការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់អំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងការជួញដូរផ្លូវភេទ។ លោកបញ្ជាក់ថាៈ «អង្គប្រជុំក៏ទទួលបានធាតុចូលសំខាន់ៗពីសមាជិក សមាជិកាហើយក៏បានឯកភាពគ្នាធ្វើការផ្សព្វផ្សាយខ្លឹមសារប្រតិបត្តិការជាក់ស្តែងនៅថ្ងៃសុក្រខាង

មុខនេះ»។ លោកបញ្ជាក់ថា ក្នុងអង្គប្រជុំក៏បានឯកភាពគ្នាទៅលើគោលការណ៍សំខាន់ៗសម្រាប់បម្រើឱ្យ កិច្ចសហប្រតិបត្តិការទាំងការកំណត់គោលដៅ មុខសញ្ញា សម្រាប់ធ្វើការស្រាវជ្រាវ ស៊ើបអង្កេត និងសង្គ្រោះជាពិសេស គឺការដាក់ចេញនូវវិធានការសំដៅអនុវត្តឱ្យមានប្រសិទ្ធភាពឆ្លើយតបទៅនឹងគោលបំណង និងសំណូមពរនៃផែនការ។

ទាក់ទងនឹងនឹងការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទនៅកម្ពុជាកម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ កាលពីថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០២២ បានចុះត្រួតពិនិត្យទីតាំងក្រុមហ៊ុន ១ កន្លែង ស្ថិតនៅភូមិ ៦ សង្កាត់ ៤ ក្រុង-ខេត្តព្រះសីហនុ ដោយរកឃើញជនជាតិម៉ាឡេស៊ី ១៦ នាក់ ត្រូវគេបង្ខាំងទុកឱ្យធ្វើការ និងបានឃាត់ជនជាតិចិន ១ នាក់។ នេះបើតាមលោក ខៀវ អ្នកនាំពាក្យក្រសួងមហាផ្ទៃ។ លោកបញ្ជាក់ថា ប្រតិបត្តិការនេះបានធ្វើឡើងបន្ទាប់ពីមានបណ្ដឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង ថា មានការចាប់បង្ខាំងទុកជនជាតិម៉ាឡេស៊ី ១៦ នាក់ ដើម្បីឱ្យនៅបម្រើការងារក្នុងក្រុមហ៊ុន នៅក្នុងខេត្តព្រះសីហនុ ចំនួន ១ ករណី។ ក្នុងចំណោមជនរងគ្រោះ ចំនួន ១៦ នាក់មានស្រី ៥ នាក់ផងដែរ។ លោកបន្តថា ដោយបានចុះទៅដល់ទីតាំង និងមានការចូលរួមសហការពីម្ចាស់ទីតាំង កម្លាំងសមត្ថកិច្ចបានស្វែងរកឃើញ បុរស និងស្ត្រី ជនជាតិម៉ាឡេស៊ី ១៦ នាក់ (ដែលក្នុងបណ្ដឹងអះអាងថាជាជនរងគ្រោះ) កំពុងធ្វើការនៅក្នុងក្រុមហ៊ុនខាងលើ ទើបកម្លាំងសមត្ថកិច្ចបាននាំអ្នកគ្រប់គ្រងជនជាតិចិន ១ នាក់ មកធ្វើការសាកសួរ បន្តនីតិវិធី។

បើយោងតាមរបាយការណ៍ដែលចុះផ្សាយនៅលើហ្វេសប៊ុករបស់លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឱ្យដឹងថា គិតពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០២២ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជាបានរកឃើញ និងជួយសង្គ្រោះជនបរទេសចំនួន ៨៧ ករណីស្មើនឹងប្រមាណ ៨៦៥ នាក់ ព្រមទាំងបានកសាងសំណុំរឿងបញ្ជូនទៅតុលាការចំនួន ១៧ ករណី ជនសង្ស័យសរុបចំនួន ៦០ នាក់»។ ដោយឡែកនាសប្ដាហ៍ទី៤ ខែសីហាអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាបានបើកកិច្ចប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះសរុបចំនួន ៧ ករណី ដោយបានសង្គ្រោះជនរងគ្រោះសរុបចំនួន ២៥ នាក់ (មាន ៦ សញ្ជាតិ) និងឃាត់ខ្លួនជនសង្ស័យសរុបចំនួន ២៣ នាក់ (មាន ៤ សញ្ជាតិ) នៅក្នុងខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តឧត្តរមានជ័យ៕

## មន្ត្រីស្ថានទូតកម្ពុជាបង្ហាញអារម្មណ៍សោកស្ដាយពលករខ្មែរមួយចំនួនបោះបង់ចោលការងារត្រលប់ទៅមាតុប្រទេសជឿលើការឃោសនារបស់គេ

https://kohsantepheapdaily.com.kh/ ភ្នំពេញ០១ ខែ កញ្ញា ឆ្នាំ ២០២២ ម៉ោង ១៣:៥៣

រាជធានីភ្នំពេញ ៖ មន្ត្រីស្ថានទូតកម្ពុជាបានបង្ហាញអារម្មណ៍សោកស្ដាយ ចំពោះពលករខ្មែរមួយចំនួនដែលសម្រេចចិត្តបោះបង់ចោលការងាររបស់ខ្លួន ដែលមកបម្រើការងារនៅសាធារណរដ្ឋកូរ៉េលត្រឡប់ទៅមាតុប្រទេសវិញ ។ នេះបើយោងតាមស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ បានផ្សាយនាព្រឹកថ្ងៃទី០១ ខែកញ្ញានេះ ។

ជាក់ស្ដែង នៅថ្ងៃទី១ ខែកញ្ញានេះ អ្នកនាង ជ្រឹង បុទុមរង្សី មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ បានលើកឡើងថា« ខ្ញុំពិតជាមានការសោកស្ដាយយ៉ាងខ្លាំង ចំពោះបងប្អូនពលករខ្មែរមួយចំនួន ដែលមកបម្រើការងារនៅសាធារណរដ្ឋកូរ៉េ បានសម្រេចចិត្តបោះបង់ចោលការងាររបស់ខ្លួន និងត្រឡប់ទៅកាន់មាតុប្រទេសវិញ បន្ទាប់ពីជឿតាមបុគ្គលមួយចំនួនដែលបានប្រើប្រាស់រូបភាពអបិយជំនឿ ធ្វើការឃោសនាតាមបែបប្រជាភិថុតិ បោកបញ្ឆោតបងប្អូនប្រជាពលរដ្ឋដោយមិនសមហេតុផល គ្មានមូលដ្ឋាន និងប្រភពច្បាស់លាស់ ។» មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ បានបន្តថា «បើទោះបីកន្លងមកស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ បានខិតខំសម្របសម្រួល និងពន្យល់ណែនាំដល់បងប្អូនពលករអំពីករណីនេះក៏បងប្អូនយើងមួយចំនួននៅតែមានៈ ទទូចចង់វិលត្រឡប់ទៅកម្ពុជាវិញយ៉ាងតក់ក្រហល់ ដែលធ្វើឱ្យបាត់បង់ការងារ ប៉ះពាល់ដល់សេដ្ឋកិច្ចផ្ទាល់ខ្លួន និងផលប្រយោជន៍នានាសម្រាប់

គ្រួសាររបស់ខ្លួន ជាពិសេសប៉ះពាល់ដល់ផលប្រយោជន៍ជាតិ និងសង្គមទៀតផង ។ «ឥឡូវមកដល់ពេលនេះ យើងទាំងអស់គ្នាបានឃើញជាក់ស្តែងថា ការឃោសនានេះ គឺជារឿងបោកបញ្ឆោតទាំងស្រុងដោយពុំមែនជាការពិតនោះឡើយ ។ ដូចនេះ សូមបងប្អូនទាំងអស់សិក្សាឈ្វេងយល់ពីបទពិសោធន៍មួយនេះ និងមានការប្រុងប្រយ័ត្នខ្ពស់មុននឹងសម្រេចចិត្តជឿតាមការឃោសនាណាមួយ ដែលអាចនឹងនាំមកនូវការខាតបង់ទាំងផលប្រយោជន៍ផ្ទាល់ខ្លួន និងក្រុមគ្រួសារនាពេលអនាគត ។

» អ្នកនាង ជ្រឹង បុទុមរង្សី បន្ថែមថា «តាំងនាមឱ្យស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ នាងខ្ញុំសូមប្រកាសគាំទ្រទាំងស្រុងនូវប្រសាសន៍របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ដែលតែងតែយកចិត្តទុកដាក់លើការថែរក្សាសុវត្ថិភាព និងសុខភាព របស់បងប្អូនពលករខ្មែរនៅបរទេស ជាពិសេសនៅកូរ៉េ ជប៉ុន និងថៃ និងសូមគាំទ្ររាល់ចំណាត់ការរបស់រាជរដ្ឋាភិបាលក្នុងការចាត់វិធានការដើម្បីធានាសុវត្ថិភាព សុខមាលភាពរបស់បងប្អូនខ្មែរដែលបានប្រមូលផ្តុំនៅខេត្តសៀមរាប។» ជាចុងក្រោយ នាងខ្ញុំសូមអំពាវនាវឱ្យបងប្អូនប្រជាពលរដ្ឋខ្មែរ និងបងប្អូនពលករ ដែលរស់នៅ និងកំពុងធ្វើការនៅសាធារណរដ្ឋកូរ៉េ សូមរក្សាភាពស្ងប់ស្ងាត់ និងបន្តអនុវត្តន៍កិច្ចការងាររបស់ខ្លួន ដោយឈរលើស្មារតីសាមគ្គីភាព និងការអធ្យាស្រ័យគ្នាទៅវិញទៅមក ដើម្បីសុខសន្តិភាព និងការអភិវឌ្ឍរបស់ប្រទេសជាតិយើង៕

## បុរសវៀតណាមម្នាក់ត្រូវបានចាប់ខ្លួនក្រោយរត់ពន្ធមនុស្ស៥០នាក់មកកម្ពុជា

https://www.khmertimeskh.com/ Khmer Times September 1, 2022

Cao Sy Huy អាយុ៤០ឆ្នាំ បច្ចុប្បន្នកំពុងត្រូវបានឃុំខ្លួននៅខេត្ត Dong Nai ដែលជិតនឹងទីក្រុងហូជីមិញ។ ប៉ូលីសបាននិយាយថា Huy បានឆ្លងដែន វៀតណាម-កម្ពុជា មកធ្វើការនៅកាស៊ីណូនៅកម្ពុជាកាលពីចុងឆ្នាំមុនមុននឹងត្រលប់ធ្វើការអោយក្រុមហ៊ុនដែលគ្រប់គ្រងដោយជនជាតិចិននៅកម្ពុជា។ បុរសជនជាតិចិនបានអោយ Huy ទាក់ទងទៅរកអ្នកអត់ការងារធ្វើនៅប្រទេសវៀតណាមតាមរយៈបណ្តាញសង្គម និងនិយាយបញ្ចុះបញ្ចូលពួកគេអោយមកប្រទេសកម្ពុជា។ បន្ទាប់មក Huyបានផ្សព្វផ្សាយការងារក្នុងប្រទេសកម្ពុជាដោយសន្យាផ្តល់ប្រាក់ចំណូលជាមធ្យមចំនួន៨៥០ដុល្លារក្នុងមួយខែ។ ក្នុងខែឧសភា និងមិថុនា Huy បានត្រឡប់ទៅប្រទេសវៀតណាមវិញ ហើយបានសហការជាមួយជនសមគំនិតមួយចំនួននៅDong Nai ដើម្បីនាំជនជាតិវៀតណាមប្រមាណ ៥០នាក់ មកកម្ពុជាតាមច្រករបៀងខុសច្បាប់។ កាលពីខែកក្កដា ជនសមគំនិតមួយចំនួនត្រូវបានប៉ូលីស Dong Nai ចាប់ខ្លួន បន្ទាប់មក Huy បានត្រឡប់ទៅប្រទេសវៀតណាមវិញ និងបានប្រគល់ខ្លួនទៅអោយប៉ូលីស។

ករណីជនជាតិវៀតណាមជាច្រើននាក់ត្រូវបានបោកបញ្ឆោត និងរត់ពន្ធចូលមកប្រទេសកម្ពុជា បានធ្វើឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងអន្តរជាតិនាពេលថ្មីៗនេះ។ កាលពីដើមខែនេះ ជនជាតិវៀតណាមមួយក្រុមមានគ្នា ៤២នាក់ បានរត់គេចពីកាស៊ីណូកម្ពុជាក្នុងខេត្តកណ្តាលកាលពីពាក់កណ្តាលខែសីហា ហើយព្យាយាមហែលឆ្លងស្ទឹងដើម្បីទៅប្រទេសវៀតណាមវិញ។ ខណៈដែល៤០នាក់បានរត់គេចដោយជោគជ័យ ក្មេងជំទង់ម្នាក់បានលង់ទឹកស្លាប់និងបុរសម្នាក់ផ្សេងទៀតត្រូវបានឆ្មាំកាស៊ីណូចាប់យកទៅវិញ។ ជនដែលរត់គេចខ្លួនបាននិយាយថា ពួកគេត្រូវបានបង្ខំឱ្យធ្វើការក្រោមលក្ខខណ្ឌធ្ងន់ធ្ងរ ហើយត្រូវបានគេវាយដំជាញឹកញាប់។

នៅក្នុងសន្និសីទសារព័ត៌មានកាលពីថ្ងៃទី២២ ខែសីហានៅទីក្រុងហាណូយ លោកវរសេនីយ៍ឯក Khong Ngoc Oanh មកពីក្រសួងសន្តិសុខសាធារណៈបាននិយាយថា មនុស្សរាប់ពាន់នាក់អាចត្រូវបានរត់ពន្ធមកកម្ពុជាដើម្បីកេងប្រវ័ញ្ច ហើយការជួយសង្គ្រោះពួកគេគឺមានការលំបាក។ លោកបាននិយាយថា កម្មករភាគច្រើនដែលត្រូវ

បានជួញដូរត្រូវបានសន្យាថា "ដោយផ្តល់ការងារងាយស្រួលជាមួយនឹងប្រាក់ឈ្នួលខ្ពស់" តែទីបញ្ចប់ពួកគេត្រូវបាននាំយកទៅកាស៊ីណូ និងត្រូវបានបង្ខាំងនៅកន្លែងផ្សេងទៀតដូចជាអ្នកទោស។ ក្នុងឆមាសទី១ឆ្នាំនេះ ប៉ូលិសវៀតណាមដែលសហការជាមួយអាជ្ញាធរកម្ពុជាបានជួយសង្គ្រោះមនុស្សបានជាង២៥០នាក់។ *VNExpress*

## ជនជាតិវៀតណាមត្រូវបានកាត់ទោសពីបទជួញដូរក្មេងជំទង់វៀតណាម៤នាក់មកកម្ពុជា

https://www.khmertimeskh.com/ Khmer Times September 1, 2022

ប៉ូលីសនៅទីក្រុង Hai Phong ភាគខាងជើងប្រទេសវៀតណាមបានចាប់ផ្តើមនីតិវិធីព្រហ្មទណ្ឌលើបុរសក្នុងស្រុកម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទជួញដូរក្មេងជំទង់៤នាក់អោយធ្វើការនៅកាស៊ីណូក្នុងប្រទេសកម្ពុជា។ ប៉ូលិសក្នុងតំបន់បានរាយការណ៍កាលពីពេលថ្មីៗនេះថា ជនសង្ស័យឈ្មោះ Nguyen Van Anh អាយុ ៤៥ ឆ្នាំ មានឈ្មោះហៅក្រៅថា "ក្បាលទំពែក Anh" ដែលមានដើមកំណើតនៅស្រុក Hong Bang ត្រូវបានកាត់ទោសពីបទជួញដូរមនុស្ស។ ប៉ូលីសបាននិយាយថា Anh ត្រូវបានជាប់ពន្ធនាគារចំនួន ៤ ដងពីបទឧក្រិដ្ឋកម្មផ្សេងៗ ហើយត្រូវបានដោះលែងនៅឆ្នាំ២០២០ ហើយថ្មីៗនេះបានធ្វើការឱ្យក្រុមឆបោករត់ពន្ធមនុស្សដែលមានអាយុពី ១៨-៤០ ឆ្នាំមកកម្ពុជាដើម្បីធ្វើការ ហើយបានផ្តល់ប្រាក់កម្រៃជើងសារដល់ក្រុមអ្នកជួញដូរមនុស្ស។

នៅដើមឆ្នាំ២០២២ Anh បានទៅជួបក្មេងជំទង់៤នាក់ ដែលជាមិត្តរបស់កូនប្រុសគាត់ ពួកគេបានបង្កើតទំនាក់ទំនងជិតស្និទ្ធ ហើយបន្ទាប់មកបានហៅពួកគេថាជាកូនចិញ្ចឹមរបស់គាត់។ ក្រោយមក Anh បានបញ្ចុះបញ្ចូលពួកគេបីនាក់ដែលមានអាយុ ១៦ ឆ្នាំ និងម្នាក់ទៀតអាយុ១៧ ឆ្នាំឱ្យទៅប្រទេសកម្ពុជាដើម្បី "ធ្វើការងារដែលមានប្រាក់ខែល្អ" ហើយក្រុមក្មេងជំទង់បានយល់ព្រមតាមការណែនាំរបស់គាត់។

កាលពីថ្ងៃទី៣១ ខែមីនា គាត់បាននាំក្មេងជំទង់ទៅកាន់ទីក្រុងហូជីមិញ បន្ទាប់មកទៅកាន់តំបន់ក្បែរច្រកព្រំដែន Moc Bai ក្នុងខេត្ត Tay Ninh ជាកន្លែងដែលគាត់បានប្រគល់ក្មេងជំទង់ទាំង៤នាក់ទៅឱ្យសមាជិកក្រុមឆបោករបស់គាត់ ដែលបានឆ្លងព្រំដែននាំជនរងគ្រោះមកប្រទេសកម្ពុជា។ ក្មេងជំទង់ទាំងនោះក្រោយមកត្រូវបានគេលក់ទៅឱ្យកាស៊ីណូ Yong Yuan ដែលតាមពិតបានបើកហ្គេមអនឡាញបោកប្រាស់ ដែលមានទីតាំងនៅស្រុកកោះធំ ខេត្តកណ្តាល។ នៅទីនោះ ក្រុមក្មេងជំទង់ទាំង៤នាក់ត្រូវបានបង្ខំឱ្យបោកប្រាស់មនុស្សខ្ចីប្រាក់តាមរយៈកម្មវិធីអនឡាញ ជាមួយនឹងប្រាក់ឈ្នួលប្រចាំថ្ងៃ ២០ ដុល្លារ។

ជនរងគ្រោះបានរំលឹកឡើងវិញថា ពួកគេត្រូវបានធ្វើបាប ប្រសិនបើមិនបំពេញតាមគោលដៅប្រចាំថ្ងៃដែលបានកំណត់ដោយកាស៊ីណូ ឬបំពានច្បាប់ផ្ទៃក្នុងរបស់កាស៊ីណូ ជនរងគ្រោះបានរៀបរាប់បន្ថែមថា ពួកគេមិនត្រូវបានអនុញ្ញាតឱ្យចេញពីកន្លែងធ្វើការទៅខាងក្រៅនោះទេ។ ដោយមានការភ័យខ្លាចចំពោះការងារបែបនេះ ក្មេងជំទង់ទាំង៤បានស្នើសុំឱ្យអ្នកគ្រប់គ្រងកាស៊ីណូអនុញ្ញាតឱ្យពួកគេត្រឡប់ទៅប្រទេសវៀតណាមវិញ ប៉ុន្តែពួកគេត្រូវបង់ប្រាក់យ៉ាងហោចណាស់ ២,៤០០ ដុល្លារក្នុងម្នាក់ជាថ្នូរដោះលែងពួកគេ។ បន្ទាប់ពីក្រុមក្មេងជំទង់បានរាយការណ៍ពីស្ថានភាពរបស់ពួកគេនៅលើបណ្តាញសង្គម ឪពុកម្តាយរបស់ពួកគេបានទាក់ទងទៅអ្នកគ្រប់គ្រងកាស៊ីណូពាក់ព័ន្ធនឹងបង់ប្រាក់លោះ ហើយបានទៅកម្ពុជាដើម្បីយកកូនរបស់ពួកគេមកវិញ។

នៅថ្ងៃទី២២ ខែមេសា គ្រួសារមួយក្នុងចំនោមគ្រួសារផ្សេងទៀតបានយល់ព្រមបង់ប្រាក់ចំនួន ២,៦០០ ដុល្លារទៅក្នុងគណនីធនាគារដែលបានផ្តល់ជូនដើម្បីជួយសង្គ្រោះក្មេងម្នាក់ចេញពីកាស៊ីណូ។ ជាមួយគ្នានេះ ក្មេងបីនាក់ដែលនៅសេសសល់ ត្រូវបានកាស៊ីណូនិយាយថា បានទៅធ្វើការកន្លែងលេងល្បែងស៊ីសងមួយទៀត ដែលទាមទារថ្លៃលោះខ្ពស់ជាងនេះ។ ប៉ូលិសបាននិយាយថា មួយថ្ងៃក្រោយមក ក្រុមគ្រួសាររបស់ក្មេងជំទង់ទាំងបីនាក់

បានបង់ប្រាក់សរុបចំនួន ១០,០០០ ដុល្លារផងដែរ ដោយផ្ទេរប្រាក់តាមធនាគារសម្រាប់ជាថ្លៃរដោះលែងពួកគេ។ គ្រប់ជំហាននៃការទំនាក់ទំនង ការចរចា និងការជួយសង្គ្រោះក្មេងទាំងបួននៅក្នុងប្រទេសកម្ពុជាត្រូវបានជួយសម្របសម្រួលដោយ Le Day បុរសជនជាតិវៀតណាមម្នាក់រស់នៅទីក្រុងភ្នំពេញ រួមទាំងអ្នកសារព័ត៌មាន Tuoi Tre ក្នុងអំឡុងពេលនោះ។ បន្ទាប់ពីក្មេងជំទង់ទាំងនេះត្រលប់មកផ្ទះវិញ ឪពុកម្តាយរបស់ពួកគេបានរាយការណ៍ពីឧក្រិដ្ឋកម្មជួញដូរមនុស្សរបស់ Anh ទៅកាន់ប៉ូលីស បន្ទាប់មកបានស៊ើបអង្កេតបុរសនេះពីបទ "ជួញដូរមនុស្សអាយុក្រោម ១៦ ឆ្នាំ"។ ទោះបីជាយ៉ាងណាក៏ដោយ ខណៈដែលការស៊ើបអង្កេតកំពុងដំណើរការ Anh ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៦ ខែមិថុនា បន្ទាប់ពីត្រូវបានចាប់ខ្លួនពីបទជួញដូរថ្នាំញៀន ៤០០ ក្រាម និងថ្នាំ ecstasy ១,០០០គ្រាប់ នៅក្នុងខេត្ត Quang Ninh ចម្ងាយប្រហែល៨៧ គីឡូម៉ែត្រភាគឦសាននៃទីក្រុង Hai Phong ។

លោកវរសេនីយ៍ទោ Khong Ngoc Oanh មកពីនាយកដ្ឋាននគរបាលព្រហ្មទណ្ឌនៃក្រសួងសន្តិសុខសាធារណៈបានប្រាប់ Tuoi Tre កាលពីពេលថ្មីៗនេះថា ជនជាតិវៀតណាមរាប់ពាន់នាក់អាចត្រូវបានគេរត់ពន្ធចូលមកប្រទេសកម្ពុជា បន្ទាប់ពីពួកគេត្រូវបានបោកប្រាស់ដោយសន្យាផ្តល់ការងារសាមញ្ញដែលមានប្រាក់ខែខ្ពស់នៅទីនោះ។ លោក Oanh បាននិយាយថា តាមពិត ពួកគេត្រូវបានបង្ខំអោយធ្វើការងារខុសច្បាប់ ឬក្លាយជាជនរងគ្រោះនៃពលកម្មដោយបង្ខំ ឬកេងប្រវ័ញ្ចកម្លាំងពលកម្ម។

កាលពីថ្ងៃទី១៨ ខែសីហា កម្មករវៀតណាមមួយក្រុមមានគ្នា ៤២នាក់ បានរត់ចេញពីកាស៊ីណូ Rich World ក្នុងខេត្តកណ្តាល ហើយព្យាយាមហែលឆ្លងស្ទឹងBinh Di ក្នុងខេត្ត An Giang របស់វៀតណាម ដើម្បីត្រឡប់ទៅស្រុកកំណើតវិញ ដោយសារគេបង្ខំអោយធ្វើការងារហួសកម្លាំង និងមិនទទួលបានប្រាក់ខែ។ ក្នុងចំណោមអ្នករត់គេចខ្លួនទាំងនេះ ៤០នាក់បានទៅដល់ប្រទេសវៀតណាម ម្នាក់បានស្លាប់ក្នុងអំឡុងពេលឆ្លងទន្លេ ហើយអ្នកដែលនៅសល់ត្រូវបានចាប់ខ្លួនដោយឆ្មាំកាស៊ីណូ។

ប្រព័ន្ធផ្សព្វផ្សាយកម្ពុជាបានរាយការណ៍ថា កាលពីសប្តាហ៍មុន នាយកដ្ឋានអន្តោប្រវេសន៍កម្ពុជាបាននិយាយថា ពួកគេកំពុងអនុវត្តនីតិវិធីបញ្ជូនអ្នកដែលត្រូវបានជួយសង្គ្រោះ រួមជាមួយនឹងជនជាតិវៀតណាម ១០ នាក់ផ្សេងទៀត ពីកាស៊ីណូនេះផងដែរ។ នៅក្នុងឆមាសទីមួយនៃឆ្នាំនេះ ប៉ូលីសវៀតណាមបានសម្របសម្រួលជាមួយសមភាគីកម្ពុជាដើម្បីកំណត់អត្តសញ្ញាណ និងជួយសង្គ្រោះជនជាតិវៀតណាមជាង២៥០ នាក់ដែលបានរត់ពន្ធមកកម្ពុជាជាមួយនឹងប្រាក់លោះសម្រាប់ពួកគេម្នាក់ៗចាប់ពី ៣,០០០ ដុល្លារដល់ ៣០,០០០ ដុល្លារ នេះបើយោងតាមក្រសួងសាធារណៈនិងសន្តិសុខវៀតណាម។ *Tuoi Tre*

## អ្នកនាំពាក្យក្រសួងការងារ ៖ បើថៅកែមិនអនុញ្ញាតច្បាប់ហើយយើងចេញមក គឺមិនអាចត្រឡប់ទៅវិញបានទេ

https://kohsantepheapdaily.com.kh/ ភ្នំពេញ ០១ ខែ កញ្ញា ឆ្នាំ ២០២២ ម៉ោង ១៥:០៣

រាជធានីភ្នំពេញ ៖ ថ្នាក់ដឹកនាំក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែងឱ្យដឹងថា ជុំវិញរឿងរ៉ាវបងប្អូនពលករខ្មែរនៅក្រៅប្រទេស ដែលតក់ក្រហល់វិលត្រឡប់មកស្រុកខ្មែរវិញកាលពីពេលថ្មីៗកន្លងទៅនេះ ដោយសារជឿការឃោសនារបស់លោក ខឹម វាសនា គណបក្សសម្ព័ន្ធ ដើម្បីប្រជាធិបតេយ្យ (LDP) ថា នឹងមានទឹកលិចពិភពលោកនេះ គឺមិនអាចវិលត្រឡប់ទៅវិញបានទេ បើការវិលមកស្រុកខ្មែរគ្មានការអនុញ្ញាតច្បាប់ពីថៅកែនោះ ។

ឆ្លើយតបទៅនឹងសំណួរដែលបានចោទសួរថា តើពលករដែលមកពីកូរ៉េ និងជប៉ុន ដែលបានចោលការងារមកស្រុកខ្មែរវិញ តើពេលត្រឡប់ទៅវិញ តើខាងក្រុមហ៊ុននៅទទួលដែរទេ? ឯកឧត្តម ហេង សួរ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់យ៉ាងខ្លី និងច្បាស់ៗថា «បើថៅកែមិន

អនុញ្ញាតច្បាប់ ហើយយើងចេញមក គឺមិនអាចត្រឡប់ទៅវិញបានទេ» ។ សូមបញ្ជាក់ ឯកឧត្តម ហេង សួរ ដែលកំពុងស្ថិតនៅក្រៅប្រទេស បានថ្លែងប្រាប់សារព័ត៌មានកោះសន្តិភាព តាមប្រព័ន្ធតេឡេក្រាម នៅថ្ងៃទី៣១ សីហា ម្សិលមិញថា មានពលរដ្ឋខ្មែរប្រមាណ៥០០នាក់ បានត្រឡប់មកស្រុក តាមការឃោសនាអកុសលរបស់លោក ខឹម វាសនា ក្នុងចន្លោះថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែសីហា ។ ក្នុងនោះ ឯកឧត្តមបានប្រាប់លម្អិតថា នៅកូរ៉េខាងត្បូងមានពលរដ្ឋខ្មែរចំនួនជាង៤០០នាក់ និងនៅជប៉ុនមានពលរដ្ឋខ្មែរប្រហែល១០០នាក់ ក្នុងនោះក៏មាននិស្សិតថ្នាក់បណ្ឌិតរៀននៅតំបន់កាន់សៃនៃប្រទេសជប៉ុន១នាក់ផងដែរ បានឈប់ត្រឡប់មកស្រុកវិញ ដោយសារការជឿពាក្យឃោសនាអកុសលរបស់លោក ខឹម វាសនា ឯកឧត្តមលើកឡើងថា អ្នកខ្លះត្រឡប់មកវិញ ដោយយកហេតុផលថាឪពុកម្តាយឈឺធ្ងន់ ដើម្បីថៅកែអនុញ្ញាតច្បាប់ ។ អ្នកខ្លះទៀត គឺសុំថៅកែ ប៉ុន្តែថៅកែមិនឲ្យក៏ឈប់ទាំងអត់ច្បាប់ក៏បោះបង់ចោលការងារហើយត្រឡប់មកខ្មែរវិញ តាមការឃោសនាអកុសលបែបអបិយជំនឿមិនសមហេតុផលរបស់លោក ខឹម វាសនា តែម្តង ។

ទោះជាយ៉ាងណា អ្នកនាំពាក្យក្រសួងការងារបានបញ្ជាក់បន្ថែមថា នៅក្រៅប្រទេសចាប់ពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២មកមិនមានចលនាបោះបង់ចោលការងារត្រឡប់មកខ្មែរទៀតទេ ។ ឯកឧត្តមបានបន្ថែមថា ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងបានជួបជាមួយតំណាង អង្គភាពអភិវឌ្ឍធនធានមនុស្សកូរ៉េ (HTD Korea) ដើម្បីសុំទោសរដ្ឋាភិបាលកូរ៉េ ជាពិសេស និយោជកកូរ៉េ ដែលរងផលប៉ះពាល់ដោយការចលាចលនេះ ។ ស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ និងជប៉ុន ព្រមទាំងភាគីពាក់ព័ន្ធក៏បានចុះជួបបងប្អូនពលករ និងនិយោជកកូរ៉េ និងជប៉ុន ដែលរងផលប៉ះពាល់ផងដែរ ។ ឯកឧត្តមបញ្ជាក់ថា ៖«ទន្ទឹមនឹងនេះយើងក៏បានសំណូមពរដល់និយោជកកូរ៉េ និងជប៉ុនមេត្តាយោគយល់ជាអតិបរមាដល់បងប្អូនពលករ និងសិក្ខាកាមយើងកុំប្តឹងបងប្អូនយើង ព្រមទាំងពិចារណាទទួលយកបងប្អូនពលករ និងសិក្ខាកាមយើងវិញតាមលទ្ធភាពជាក់ស្តែង» ។

កាលពីថ្ងៃទី ៣១ ខែសីហា ម្សិលមិញនេះផងដែរ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជានាឱកាសបើកការដ្ឋានសាងសង់ស្ពានអាកាសក្នុងរាជធានីភ្នំពេញចំនួន០២ ដែលមានតម្លៃសរុបជាង ៤៦លានដុល្លារអាមេរិក ក៏បានលើកឡើងផងដែរថា រឿង លោក ខឹម វាសនា ដែលបានតាំងខ្លួនជា ព្រហ្មបានចុះមក ដើម្បីជួយរំដោះមនុស្សលោក នៅក្នុងតំបន់ភ្នំគូលេន រហូតមានពលករខ្មែរនៅក្រៅប្រទេស ក៏បានរត់ចោលការងារ មកស្រុកខ្មែរវិញ ដែលនាំឱ្យប៉ះពាល់សង្វាក់ផលិតកម្មនៅរោងចក្រ សហគ្រាស នៅប្រទេសថៃ ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង ជាដើម។ សម្តេចតេជោ បានមានប្រសាសន៍ថា «រឿងពលករបាត់បង់ការងារធ្វើ ជារឿងកង្វល់មួយហើយ ដែលយើងសោកស្តាយជាមួយពួកគាត់ ប៉ុន្តែខ្ញុំនៅមានកង្វល់មួយទៀត គឺកង្វល់នៃពាក្យបណ្តឹងនៃបណ្តាក្រុមហ៊ុនដែលពលករបានធ្វើឲ្យខូចខាត រត់ចោលការងារពេលដែលគេកំពុងតែដំណើរការ»។

សម្តេចបន្ថែមថា ដែលខ្ញុំសុំយកឱកាសនេះសុំអង្វររដ្ឋាភិបាលដែលទទួលពលករកម្ពុជា បើនិយាយឲ្យត្រូវបោះបង់ចោលការងារដោយខ្វះការទទួលខុសត្រូវ និងខុសកិច្ចសន្យាការងារ សុំមេត្តាកុំប្តឹង ទាំងប្តឹងចំពោះរដ្ឋាភិបាល និងរដ្ឋាភិបាល ទាំងចំពោះពលករដែលបានចាកចេញនោះ ដែលវានាំជម្លោះផ្លូវច្បាប់ កម្ពុជាទទួលកំហុសនេះ។ សូមជម្រាបថា លោក ខឹម វាសនាបានរៀបចំការប្រមូលផ្តុំមនុស្សរាប់ម៉ឺននាក់ នៅជើងភ្នំគូលែនក្នុងដីចម្ការម្រេចខ្លួន ដែលមានទំហំ១២ហិកតាស្ថិតស្រុកបន្ទាយស្រី ខេត្តសៀមរាប ក្រោមហេតុផលស្តាប់ធម៌ និងគេចចេញពីគ្រោះមហន្តរាយធម្មជាតិមានរញ្ជួយដី និងទឹកជំនន់លិចពិភពលោកជាដើម ។

អាជ្ញាធរខេត្តសៀមរាបបញ្ជាឱ្យរំសាយការជួបជុំ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ(LDP)នៅក្នុងខេត្តសៀមរាប បានការពារខ្លួនថា ការជួបជុំនេះមិនខុសច្បាប់ឡើយ ។ ប្រជាពលរដ្ឋរាប់ពាន់នាក់បានទៅស្នាក់នៅ បោះតង់នៅដីចម្ការម្រេចរបស់ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគឺ លោក ខឹម វាសនា នៅក្បែរជើងភ្នំគូលែន

ដោយសារភ័យខ្លាចរឿងទឹកជំនន់លិចពិភពលោក តាមការថ្លែងរបស់លោក ។ការសម្រុកទៅខេត្តសៀមរាបនេះក៏នាំឱ្យមានការរិះគន់ផងដែរថា ហេតុអ្វីបានជាប្រជាពលរដ្ឋជឿលើពាក្យសម្ដីរបស់លោក ខឹម វាសនា។

ចាប់តាំងពីថ្ងៃទី២៦ ខែសីហា ប្រជាពលរដ្ឋជាង១ម៉ឺន៥ពាន់នាក់បាននាំគ្នាជិះឡាន ម៉ូតូយ៉ាងច្រើនកុះករ ដោយបាននាំយកកូនចៅ និងរបស់របរប្រើប្រាស់មួយចំនួនទៅជាមួយ ដូចជាចាន ឆ្នាំង ត្រីងៀត ត្រីឆ្អើរ ជាដើម ដើម្បីភៀសខ្លួន និងមកស្នាក់នៅរួមគ្នាក្នុងចម្ការម្រេចមួយកន្លែងរបស់ លោក ខឹម វាសនា ដែលស្ថិតនៅខាងជើងភ្នំគូលែន ក្នុងឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ គិតត្រឹមថ្ងៃទី១ ខែកញ្ញានេះ អាជ្ញាធរមានសមត្ថកិច្ចនៅតែឈរជើងនីជិតដីចំការលោក ខឹម វាសនា ដើម្បីបន្តជូនដំណើរបងប្អូនដែលសម្រេចចាកចេញពីដីចំការលោកខឹម វាសនា ។ ខណៈអាជ្ញាធរអំពាវនាវជាបន្តបន្ទាប់ឱ្យអ្នកដែលបានទៅចំការលោក ខឹម វាសនា ចាកចេញទៅស្រុកកំណើតវិញនោះ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យប្រចាំខេត្តសៀមរាបបានចេញសេចក្ដីថ្លែងការណ៍មួយ ចុះថ្ងៃទី៣០ ខែសីហា ការពារខ្លួនថា «ការជួបជុំនេះគឺមិនខុសច្បាប់នោះទេ ហើយគណបក្សបានធ្វើលិខិតជូនដំណឹងទៅអាជ្ញាធរឃុំរួចហើយ»៕

## ជនជាតិចិន៤នាក់ ត្រូវបានសមត្ថកិច្ចជួយសង្គ្រោះ ក្រោយប្ដឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង ថាមានការបង្ខាំង

https://freshnewsasia.com/ 2022-09-01 04:13pm

**(ភ្នំពេញ)៖** នាយឧត្ដមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News ឲ្យដឹងថា នៅវេលាថ្ងៃត្រង់ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២នេះ មានជនជាតិចំនួន ៤នាក់ទៀត ត្រូវបានសង្គ្រោះ ក្រោយមានការប្ដឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង ដែលអះអាងថា ត្រូវបានគេចាប់បង្ខាំងទុក ដើម្បីឲ្យបម្រើការងារក្នុងក្រុមហ៊ុន នៅក្នុងខេត្តព្រះសីហនុ។ ដោយទទួលបានបទបញ្ជាពីលោកឧត្ដមសេនីយ៍ស្នងការ និងដោយមានការសម្របសម្រួលនីតិវិធីពីលោកព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១២៖៣០នាទី កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចុះមកដល់ទីតាំងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅភូមិ៦ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ។

**សមត្ថកិច្ចបានស្រាវជ្រាវស្វែងរកឃើញជនរងគ្រោះ ចំនួន ០៤នាក់ រួមមាន៖**

**១៖** ឈ្មោះ YUAN WENJIE ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិចិន។

**២៖** ឈ្មោះ YANG WANG ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិចិន។

**៣៖** ឈ្មោះ CHEN QINGFENG ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិចិន។

**៤៖** ឈ្មោះ YI KECHENG ភេទប្រុស អាយុ ៣៣ ឆ្នាំ ជនជាតិចិន។

បន្ទាប់មក កម្លាំងសមត្ថកិច្ចបាននាំអ្នកគ្រប់គ្រងជនជាតិចិន ០២នាក់ ភេទប្រុស មកធ្វើការសាកសួរ តាមនីតិវិធីជំនាញ នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ៕

# បញ្ជូនខ្លួនជនសង្ស័យចិននិងខ្មែរ៦នាក់ ទៅតុលាការខេត្តព្រះសីហនុ ពីបទជួញដូរមនុស្សឆ្លងដែន

http://nokorwatnews.com/ 01/09/2022

ខេត្តព្រះសីហនុ ៖ បើតាមការបញ្ជាក់របស់នាយឧត្តមសេនីយ៍ ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានថ្លែងឱ្យដឹងនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២នេះថា៖ ជនសង្ស័យចំនួន ៦នាក់ ក្នុងនោះមានជនជាតិចិន៤នាក់ និងខ្មែរ២នាក់ ត្រូវបានសមត្ថកិច្ចខេត្តព្រះសីហនុបញ្ជូនទៅតុលាការខេត្ត ដើម្បីបន្តនីតិវិធីពាក់ព័ន្ធនឹងករណីជួញដូរមនុស្សឆ្លងដែន។ អ្នកនាំពាក្យរូបនេះ បានឱ្យដឹងទៀតថា ជនសង្ស័យទាំងនេះ ត្រូវបានចាប់ខ្លួនកាលពីរសៀលថ្ងៃទី២៦ ខែសីហាឆ្នាំ២០២២ បន្ទាប់ពីមាន បណ្តឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេង ថាមានករណីរត់ពន្ធមនុស្សឆ្លងដែនខុសច្បាប់ តាមរយៈផ្លូវទឹកពីប្រទេសចិនមកខេត្តព្រះសីហនុ ដោយអនុវត្តតាមបទបញ្ជារបស់ សម្តេចក្រឡាហោម ស ខេង, ឧត្តមសេនីយ៍ស្នងការនគរបាលខេត្តព្រះសីហនុ បានដឹកកម្លាំងជំនាញ ធ្វើការស្រាវជ្រាវករណីខាងលើ ហើយ រហូតដល់ ម៉ោង៣រសៀលថ្ងៃដដែល កម្លាំងជំនាញបានធ្វើការស្រាវជ្រាវដឹងថា មានជនជាតិចិន៣៥នាក់ បានលួចឆ្លងដែនដោយខុសច្បាប់តាមផ្លូវទឹក ពីប្រទេសចិន មកខេត្តព្រះសីហនុ ហើយត្រូវបានមេខ្យល់នាំយកទៅលាក់ទុកនៅក្នុងអគារក្រុមហ៊ុនលិស៊ឹង ស្ថិតនៅភូមិ៤ សង្កាត់៤ ក្រុងខេត្តព្រះសីហនុ។

ក្នុងប្រតិបត្តិការខាងលើនេះ ដោយទទួលបានបទបញ្ជាពីអភិបាលខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលព្រះសីហនុ និងដោយមានការសម្របសម្រួលនីតិវិធីផ្ទាល់ពីលោក ឡុង ដាប និងលោក ច័ន្ទ ដារិទ្ធ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។ កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលព្រះសីហនុ បានចុះទៅធ្វើរដ្ឋបាលឆែកឆេរអគារក្រុមហ៊ុន លិស៊ឹង ដើម្បីស្វែងរកជនជាតិចិនលួចឆ្លងដែនដោយខុសច្បាប់។ ជាលទ្ធផលសមត្ថកិច្ចបានស្វែងរកឃើញជនជាតិចិនលួចឆ្លងដែនដោយខុសច្បាប់ទាំង ៣៥នាក់ (ស្រី២) កំពុងស្នាក់នៅក្នុងបន្ទប់ជាន់ទី៤ នៃអគារក្រុមហ៊ុន លិស៊ឹង។ ក៏មានការចូលរួមសហការពីម្ចាស់ទីតាំង កម្លាំងសមត្ថកិច្ចបានធ្វើការស្រាវជ្រាវឃាត់ខ្លួនបានមនុស្សចំនួន១៧នាក់ ជាបន្តបន្ទាប់យកមកធ្វើការសាកសួរនៅការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល។ បន្ទាប់ពីធ្វើការសាកសួរ និងស្រាវជ្រាវយ៉ាងហ្មត់ចត់ក្នុងករណីនេះ ឃើញថាជនសង្ស័យដែលជាប់ពាក់ព័ន្ធក្នុងករណីនេះមានចំនួន ០៦នាក់ ភេទប្រុស (ចិន៤នាក់ ,ខ្មែរ ២នាក់)។

ជនសង្ស័យទាំង ០៦នាក់ មានឈ្មោះដូចខាងក្រោម៖

*ទី១៖ ឈ្មោះ XIA JUNHAO ហៅ SONG TAN ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែន (មិននៅជាប់ខ្លួន) មុខរបរ អ្នកគ្រប់គ្រង ស្នាក់នៅភូមិ៦ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ។ (មេក្លោង លក់-ដូរមនុស្សដោយមានគោលដៅ)

*ទី២៖ ឈ្មោះ សន ពិសិដ្ឋ ភេទប្រុស អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ មុខរបរជាអ្នកបើកបរ និងជាអង្គរក្សការពារថៅកែចិន ស្នាក់នៅភូមិ២ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ។ (សមគំនិត លក់-ដូរមនុស្សដោយមានគោលដៅ)

*ទី៣៖ ឈ្មោះ LU XINYOU ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែន (មិននៅជាប់ខ្លួន) មុខរបរ អ្នកគ្រប់គ្រងនៅជាន់ទី៧ នៃអគារ លិស៊ឹង ស្នាក់នៅ ភូមិ៤ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ ។ (អ្នករៀបចំចាត់ចែង លក់-ដូរមនុស្សដោយមានគោលដៅ)

*ទី៤៖ ឈ្មោះ ZHANG YONG ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែន (មិនជាប់ខ្លួន) មុខរបរអ្នកគ្រប់គ្រងនៅជាន់ទី១០ នៃអគារ លិស៊ឹង ស្នាក់នៅ ភូមិ៤ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ។ (អ្នករៀបចំ ចាត់ចែង លក់-ដូរមនុស្សដោយមានគោលដៅ)

*ទី៥៖ ឈ្មោះ MO ZHENGYUN ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែន (មិនទៅជាប់ខ្លួន) មុខរបរចុងភៅ ស្នាក់នៅ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ។ (សហចារី លក់-ដូរមនុស្សដោយមានគោលដៅ)

និងទី៦៖ ឈ្មោះ គី វង្ស ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកបររថយន្ត ស្នាក់នៅភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ។ (សមគំនិត លក់-ដូរមនុស្សដោយមានគោលដៅ)

ចំណែកវត្ថុតាងដែលចាប់យកបានក្នុងប្រតិបត្តិការនេះ រួមមាន អាវុធខ្លី ០១ដើម ពណ៌ទឹកប្រាក់ ម៉ាក K54 លេខៈ 1611 , បង់១មានគ្រាប់ចំនួន ០៦គ្រាប់, ទូរស័ព្ទដៃ ០៩គ្រឿង, ខ្សែក លោហៈធាតុ ពណ៌លឿង ០១ខ្សែ មានបន្តោងរូបគ័នកុង, ខ្សែដៃ លោហៈធាតុ ពណ៌លឿង ០១ខ្សែ, ចិញ្ចៀន១វង់ រថយន្ត ០២គ្រឿង៕

## ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២

### ពលករខ្មែរនៅប្រទេសថៃត្រូវថៅកែបង្ខំឱ្យធ្វើប័ណ្ណការងារច្រើនទម្រង់ ដើម្បីធ្វើការស្របច្បាប់

https://www.rfa.org/ ដោយ យ៉ង ចាន់តារា 2022.08.31

ពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃក្នុងទីក្រុងបាងកក អះអាងថា ថៅកែរបស់ពួកគាត់បានបង្ខំឲ្យធ្វើឯកសារការងារជាច្រើនសណ្ឋាន ទើបថៅកែអនុញ្ញាតឲ្យធ្វើការ ព្រោះក្រសួងការងារថៃ តម្រូវឱ្យថៅកែធ្វើដូច្នោះ។ ពួកគាត់ត្អូញត្អែរថា ត្រូវការធ្វើប័ណ្ណការងារពី ៣ទៅ៤ដំណាក់កាល គឺត្រូវចំណាយប្រាក់ច្រើន ដើម្បីទទួលបានការងារធ្វើស្របច្បាប់នៅប្រទេសថៃ។ ពលករខ្មែរដែលធ្វើការនៅប្រទេសថៃ កំពុងជួបការលំបាកក្នុងការទទួលបានការងារ ប្រសិនបើពួកគាត់មិនព្រមធ្វើឯកសារ តាមតម្រូវការរបស់ថៅកែថៃទេនោះ។ ពួកគាត់ថាកាលពីមុនពលករកាន់ត្រឹមតែប័ត្រស៊ីជម្ពូ ដែលចេញដោយក្រសួងការងារថៃ គឺអាចធ្វើការងារបានដោយមិនមានបញ្ហាអ្វីឡើយ តែឥឡូវថៅកែបានបង្ខំឲ្យពលករខ្មែរទៅធ្វើសៀវភៅអនុញ្ញាតធ្វើការទៀត (Work Permits) ទើបអាចធ្វើការងារបានដូចមុន។ ពួកគាត់ថា ការធ្វើឯកសារច្រើនដំណាក់កាលបានធ្វើឲ្យពលករមិនមានលទ្ធភាពចំណាយលើថ្លៃឯកសារទាំងនោះទេ។

ពលការិនីធ្វើការផ្នែកអនាម័យតាមផ្ទះក្នុងទីក្រុងបាងកក មានស្រុកកំណើតនៅខេត្តបាត់ដំបង លោកស្រី សាត សៀប អាយុ៣៧ឆ្នាំ ប្រាប់វិទ្យុអាស៊ីសេរីនៅព្រឹកថ្ងៃទី៣០ ខែសីហាថា លោកស្រីបានចំណាយប្រាក់ថ្លៃធ្វើទិដ្ឋាការការងារ ប័ណ្ណធ្វើការ និងសៀវភៅអនុញ្ញាតការងារ ដោយឯកសារនីមួយៗត្រូវបង់ថវិកាពីប្រាំបីពាន់(៨.០០០)ទៅប្រាំបួនពាន់(៩.០០០)បាត ឬជាង ២០០ដុល្លារអាមេរិក។ លោកស្រីបន្តថាបើគ្មានឯកសារទាំងនេះទេ ថៅកែមិនព្រមទទួលឲ្យចូលធ្វើការ និងរស់នៅក្នុងប្រទេសថៃដោយខុសច្បាប់។ លោកស្រីឱ្យដឹងថា ពលករក្នុងតំបន់ដែលលោកស្រី ស្នាក់នៅថៅកែថៃបានបង្ខំឲ្យធ្វើប័ណ្ណការងារច្រើនប្រភេទដូចៗគ្នា ដោយពលករខ្លះត្រូវចំណាយប្រាក់ពីមួយម៉ឺនប្រាំពាន់(១៥.០០០) ទៅដល់មួយម៉ឺនប្រាំមួយពាន់(១៦.០០០)បាត ស្មើនឹងជាង ៤០០ដុល្លារ ឬចំណាយច្រើនជាងនេះ។ លោកស្រីស្នើដល់ ក្រសួងការងារកម្ពុជាជួយអន្តរាគមន៍រឿងនេះ ព្រោះពលករខ្មែរកំពុងជួបការលំបាកជាខ្លាំងលើការបង់ថ្លៃសេវាឯកសារច្រើន៖ «បើសិនជាក្រសួងអត់យកចិត្តទុកដាក់ត្រង់ចំណុចនេះទេ គឺពលករយើងដែលរស់នៅប្រទេសថៃនេះ គឺគាត់អត់ទទួលបានអត្ថប្រយោជន៍ច្រើនទេ។ គាត់ធ្វើការឲ្យដូច

ដែលលុយ គឺហៅថាធ្វើការឲ្យតែគេ ប៉ុន្តែអាចំណាយទៅលើរឿងប័ត្រ រឿងប៉ាស្ព័រហ្នឹងក៏ច្រើន ហើយដល់ពេលគាត់ទទួលបានថវិកាមកវិញ ពេលដែលគាត់ឈឺ ពេលដែលគាត់អីហ្នឹង គឺគាត់ចំណាយលុយដោយខ្លួនឯង។ អីចឹងតើគាត់មានលុយឯណា ពេលដែលគាត់ត្រឡប់ទៅប្រទេសវិញ តើគាត់បានលុយពីណាទៅជួយប្រទេស»។

វិទ្យុអាស៊ីសេរី មិនអាចទាក់ទងសុំការអត្ថាធិប្បាយជុំវិញបញ្ហានេះ ពីអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ និងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃបានទេ នៅថ្ងៃទី៣០ ខែសីហា ដោយទូរស័ព្ទហៅចូលជាច្រើនដង តែពុំមានអ្នកទទួល។

ពាក់ព័ន្ធរឿងនេះដែរ មន្ត្រីគម្រោងនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្សអង្គការសង់ត្រាល់ លោក លឹង សុផុន លើកឡើងថា ច្បាប់ការងារបច្ចុប្បន្ននៅប្រទេសថៃតម្រូវឲ្យពលករធ្វើឯកសារច្រើនដំណាក់កាល ព្រោះប្រព័ន្ធលក្ខខណ្ឌការងារត្រូវបានផ្លាស់ប្ដូរ។ លោកបន្តថា កន្លងមកពលករខ្មែរអាចធ្វើប័ណ្ណការងារម្ដងប្រើបានពីរឆ្នាំ ប៉ុន្តែបច្ចុប្បន្នប័ណ្ណនេះមានសុពលភាពបានតែមួយឆ្នាំទេ ដែលធ្វើឱ្យកម្មករត្រូវចំណាយប្រាក់ច្រើនជាងមុន។ លោកយល់ថាបញ្ហានេះ ពួកគាត់នឹងប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃ និងធ្វើឲ្យពលករកាន់តែលំបាកលើសដើម ព្រោះឥឡូវការងាររបស់ពួកគាត់មិនសូវមានការងារ ខណៈតម្លៃពលកម្មទទួលបានប្រាក់ចំណូលតិចតួច ដែលធ្វើឲ្យពួកគាត់ចំណាយដោយត្បិតត្បៀត និងគ្មានប្រាក់សម្រាប់ផ្ញើទៅផ្ទះចិញ្ចឹមកូននៅស្រុកកំណើត។ លោកស្នើដល់ក្រសួងការងារកម្ពុជា ជួយអន្តរាគមន៍ទៅក្រសួងការងារថៃ ឲ្យជួយសម្រួលថ្លៃធ្វើឯកសារការងារក្នុងតម្លៃសមរម្យដល់ពលករខ្មែរ ដើម្បីឲ្យពួកគាត់មានសេដ្ឋកិច្ចគ្រាន់បើជាងសព្វថ្ងៃ៖ «ព្រោះអីកន្លងមកឃើញថា ដំណាក់កាលឲ្យតក៏វាឆាប់ផុតកំណត់ពេកទៅ ជួនកាលទៅគាត់ចំណាយលុយបង់ឲ្យគេមិនទាន់អស់ផងដល់ដំណាក់កាលធ្វើតទៀតអីចឹងណា។ មួយឆ្នាំម្ដងអីចឹងទៅ ហើយបងប្អូនពលករខ្លះគាត់លក្ខណៈធ្វើការមិនពេញម៉ោងអីចឹងទៅ អ្នកខ្លះទៅធ្វើការលក្ខណៈនៅថៃគេថារ៉ាប់ចបណា ការងារបណ្ដោះអាសន្នអីចឹងទៅ នៅពេលដែលធ្វើប័ណ្ណធ្វើអី ធ្វើឯកសារដើម្បីឲ្យរស់នៅស្របច្បាប់»។

របាយការណ៍របស់ក្រសួងការងារកម្ពុជា ឱ្យដឹងថា បច្ចុប្បន្ន មានពលករខ្មែរជាង ១លាន ២សែននាក់កំពុងធ្វើការនៅប្រទេសថៃ។ ប៉ុន្តែរបាយការណ៍របស់អង្គការ (Central) បង្ហាញថា មានពលករខ្មែរកំពុង ធ្វើការដោយស្របច្បាប់ និងមិនស្របច្បាប់នៅប្រទេសថៃប្រមាណ ២លាននាក់ ដោយភាគច្រើនពួកគាត់កំពុងជួបបញ្ហាផ្នែកសេដ្ឋកិច្ច៕

## សមត្ថកិច្ច ស្រាវជ្រាវតាមបណ្ដឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង រកឃើញស្ត្រីជនជាតិចិនតៃវ៉ាន់១នាក់

http://freshnewsasia.com/ 2022-09-01 09:41pm

**(ព្រះសីហនុ)៖** កម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ បានចុះត្រួតពិនិត្យទីតាំងក្រុមហ៊ុនមួយកន្លែងទៀត ស្ថិតនៅអគារក្រុមហ៊ុនហ៊ូក៣ ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុងព្រះសីហនុ ដោយរកឃើញជនជាតិចិនតៃវ៉ាន់១នាក់ ក្នុងករណីបង្ខាំងដើម្បីបម្រើការងារ។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News ឱ្យដឹងថា ប្រតិបត្តិការនេះ បានធ្វើឡើងបន្ទាប់ពីមានបណ្ដឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង ថា មានការចាប់បង្ខាំងទុកជនជាតិចិ នតៃវ៉ាន់ ១នាក់ ដើម្បីឱ្យនៅបម្រើការងារក្នុងក្រុមហ៊ុន នៅក្នុងខេត្តព្រះសីហនុ។ សូមបញ្ជាក់ដែរថា នារីជនរងគ្រោះមានឈ្មោះ Keng Ching Ling អាយុ ២៤ឆ្នាំ ជនជាតិចិនតៃវ៉ាន់ ស្នាក់នៅបន្ទប់លេខ៣២០ ជាន់ទី៣ និងបន្ទប់ធ្វើការ បន្ទប់លេខ 3A08 ជាន់ទី៤។ នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា កំឡុងពេលនៅតៃវ៉ាន់ នាងត្រូវបុរសជនជាតិចិនឈ្មោះ Wang Yi Wen ទំនាក់

ទំនងតាមហ្វេសប៊ុកឱ្យមកធ្វើការនៅខេត្តព្រះសីហនុ ថាទទួលប្រាក់ខែចាប់ពី ៥០០០ដុល្លាឡើងទៅ។ លុះនៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២២ នាងជិះយន្តហោះពីតៃវ៉ាន់ មកចុះនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ពេលមកដល់ ក៏មានគេចាំទទួលដឹកមកធ្វើការក្នុងក្រុមហ៊ុន ហ៊ូក នៅភូមិ១ សង្កាត់១ ក្រុងព្រះសីហនុ ដោយរាល់ការចាយវាយធ្វើដំណើរ និងធ្វើឯកសាផ្សេងៗ ខាងក្រុមហ៊ុនជាអ្នករាប់រងទាំងអស់។ អំឡុងខែឧសភា ឆ្នាំ២០២២ ក្រុមហ៊ុនបានប្តូរឱ្យទៅធ្វើការនៅក្រុមហ៊ុនហ៊ូក៣ ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុងព្រះសីហនុ ធ្វើការរយៈពេល ១៥ម៉ោង ទទួលបាន ៨០០ដុល្លា ក្នុង១ខែ ដោយបើកបានទៀតទាត់ មិនមានការបង្ខាំង និងធ្វើទារុណកម្មទេ។

អ្នកនាំពាក្យបានបញ្ជាក់បន្ថែមថា នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ នាងបានទាក់ទងទៅក្រុមគ្រួសារ ដើម្បីប្តឹង រហូតដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ក៏មានសមត្ថកិច្ច ចុះមកដល់ទីតាំងក្រុមហ៊ុន សង្គ្រោះនាងទៅកាន់ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។ បើតាមលទ្ធផលសាកសួរអ្នកគ្រប់គ្រង ឈ្មោះ រិត សាំង បានឲ្យដឹងថា អំឡុងខែឧសភា ឆ្នាំ២០២២ ខ្លួនបានចូលធ្វើការជាអ្នកគ្រប់គ្រងទូទៅ (តំណាងទីតាំង) ក្នុងក្រុមហ៊ុន ហ៊ូក៣ ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុងព្រះសីហនុ ហើយកំឡុងខែឧសភា ឆ្នាំ២០២២ ស្ត្រីខាងលើបានប្តូរពីក្រុមហ៊ុន ហ៊ូក១ មកធ្វើការផ្នែកបុគ្គលិកកុំព្យូទ័រ នៅក្រុមហ៊ុន ហ៊ូក៣ ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុងព្រះសីហនុ ធ្វើការរយៈពេល ១២ ម៉ោង ក្នុង ០១ថ្ងៃ ទទួលបានប្រាក់ខែ ៨០០ដុល្លា ក្នុង១ខែ បើកបានទៀតទាត់ និងស្នាក់នៅដូចបុគ្គលិកដទៃទៀតដែរ ហើយមិនមានការបង្ខាំង ឬធ្វើទារុណកម្មអ្វីឡើយ៕

## ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានអាជ្ញាធរខេត្តកណ្តាលចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅក្រុងតាខ្មៅ

https://gntimes.com/ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២

ខេត្តកណ្តាល៖ លោកស្រី ហ៊ុន កុសនី អភិបាលរងខេត្តកណ្តាល និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងថា ច្បាប់ទាក់ទងនឹងការបង្រ្កាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ គឺពិតជាមានសារៈសំខាន់ណាស់ សម្រាប់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស បានយល់ជ្រួតជ្រាបអំពីទោសទ័ន្ឌ សិទ្ធិ និងចូលរួមសហការបង្រ្កាប អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដើម្បីការពារ លើកកម្ពស់ទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិ។ លោកស្រីបានថ្លែងដូច្នេះ នៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលបានរៀបចំឡើងក្នុងបរិវេន សាលាបឋមសិក្សាដើមអង្កោល ស្ថិតក្នុងសង្កាត់ស្វាយរលំ ក្រុងតាខ្មៅ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ដោយមានការចូលរួមពី អាជ្ញាធរក្រុង មន្ទីរពាក់ព័ន្ធ ប្រជាពលរដ្ឋ និងសិស្សានុសិស្សជាច្រើនរូប។

លោកស្រី ក៏បានលើកទឹកចិត្តដល់ អ្នកចូលរួមទាំងអស់ ត្រូវខិតខំត្រងត្រាប់ស្តាប់ ដើម្បីទុកជាមេរៀន បទពិសោធន៍ សម្រាប់អប់រំ កូនចៅ កុំឱ្យធ្លាក់ក្នុងការលួងលោម បោកបញ្ឆោត ជឿតាមការសន្យារបស់ជនខិលខូចមួយចំនួន ដែលជាមូលហេតុធ្វើឱ្យងាយធ្លាក់ទៅក្នុងស្ថានភាពនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។ ជាមួយគ្នានេះ លោកស្រី ហ៊ុន កុសនី នៅបានបញ្ជាក់ថា អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាបរិបទសកលប្អី ដែលនៅតែបន្តកើតមានអាស្រ័យកត្តា ៣គឺ ការអប់រំសង្គម ការអនុវត្តច្បាប់ និងការឆក់ឱកាសពីជនល្មើស ។ រូបភាពនៃអំពើជួញដូរមនុស្សមិន ត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេ តែក៏មានលេចចេញនូវបាតុភាពមួយចំនួន ដែលមានទំនោរទៅរកអំពើ ជួញដូរសេរីរាង្គ និងបទល្មើសរត់ពន្ធ ឬជួញ

ដូរទារកឆ្លងដែនដែលហៅថា បទអន្តរការីនៃអំពើពពោះជំនួស ដែលបញ្ហានេះគឺជាកង្វល់របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ ខេត្ត ដើម្បីឆ្លើយតបនឹងបញ្ហានេះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ មានតួនាទីសំខាន់ណាស់ ក្នុងការដាក់វិធានការស៊ើបអង្កេតស្រាវជ្រាវ និងបង្ក្រាបឱ្យបានទាន់ពេលវេលា ជៀសវាងការរីករាលដាលនៃបទល្មើស និងបង្កគ្រោះថ្នាក់កាន់តែច្រើនឡើងៗ ។ លោកស្រីបានបញ្ជាក់បន្ថែមថា ចំពោះករណីអំពើហិង្សាក្នុងគ្រួសារ ក៏ជាបញ្ហាប្រឈមមួយដែល នៅតែបន្តកើតមានគ្រប់រូបភាពទាំងអស់នៅក្នុងសហគមន៍ ដែលជះឥទ្ធិពល ដល់សង្គមយ៉ាងខ្លាំង ជាដើមហេតុនៃការបាត់បង់ធនធានមនុស្ស សេដ្ឋកិច្ចគ្រួសារធ្លាក់ចុះ មានបញ្ហាផ្លូវចិត្ត ធ្វើឱ្យក្រុមគ្រួសារគ្មានសុភមង្គល សង្គមគ្មានការអភិវឌ្ឍដែលត្រូវទាមទារឱ្យយើងទាំងអស់គ្នាធ្វើការអប់រំផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

ក្នុងវេទិកានេះ លោកស្រីឧត្តមសេនីយ៍ត្រី ឈឹម វណ្ណនី ស្នងការរងនគរបាលខេត្តកណ្ដាល បានធ្វើការផ្សព្វផ្សាយច្បាប់ ជូនដល់អ្នកចូលរួមទាំងអស់ ដោយបញ្ជាក់ជូននូវមាត្រាសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តរបស់ជនល្មើស ទោសទណ្ឌដែលត្រូវទទួល តាមច្បាប់បានកំណត់ និងជាតុផ្សំដែលនាំឱ្យមានកើតបទល្មើសដោយចេតនាផងដែរ ៕

## សមត្ថកិច្ច ស្រាវជ្រាវតាមបណ្ដឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង រកឃើញជនជាតិម៉ាឡេស៊ី១នាក់

https://freshnewsasia.com/ 2022-09-02 09:33am

**(ព្រះសីហនុ)៖** កម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ នៅល្ងាចថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ បានចុះត្រួតពិនិត្យទីតាំងក្រុមហ៊ុនមួយកន្លែងស្ថិតនៅភូមិ៦ សង្កាត់៤ ក្រុងព្រះសីហនុ ដោយបានរកឃើញជនរងគ្រោះជាជនជាតិម៉ាឡេស៊ីចំនួន ០១នាក់ ដែលមានការប្ដឹងថាត្រូវបានបង្ខាំង។
នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News ឱ្យដឹងថា ប្រតិបត្តិការនេះ បានធ្វើឡើងបន្ទាប់ពីមានបណ្ដឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេ ថាត្រូវបានគេចាប់បង្ខាំងទុក ដើម្បីឱ្យនៅបម្រើការងារក្នុងក្រុមហ៊ុន នៅក្នុងខេត្តព្រះសីហនុ ចំនួន ០១ករណី។

នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចុះមកដល់ទីតាំងក្រុមហ៊ុនខាងលើនេះ បានស្រាវជ្រាវស្វែងរក ឃើញជនរងគ្រោះចំនួន០១នាក់ មានឈ្មោះ OOI BOO WEN ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិម៉ាឡេស៊ី។ បន្ទាប់មកកម្លាំងសមត្ថកិច្ចក៏បាននាំអ្នកគ្រប់គ្រងជនជាតិចិន ០១នាក់ ភេទប្រុស មកធ្វើការសាកសួរតាមនីតិវិធីជំនាញ នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដើម្បីសួរនាំ ដើម្បីបន្តតាមនីតិវិធី៕

## អាជ្ញាធរធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋជាង ៦០០នាក់ ដែលត្រូវបានគេល្បួងឱ្យមកធ្វើការដោយខុសច្បាប់នៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times September 2, 2022

ក្រសួងការបរទេស និងភ្នាក់ងារតំណាងរបស់វៀតណាមប្រចាំនៅកម្ពុជា បានសម្របសម្រួលជាមួយអាជ្ញាធរនៃប្រទេសទាំងពីរ ដើម្បីធ្វើមាតុភូមិនិវត្តន៍ដោយសុវត្ថិភាព នូវពលរដ្ឋជាង ៦០០នាក់ ដែលត្រូវបានបោកបញ្ឆោត ឬល្បួងឱ្យមកកម្ពុជាពីការងារខុសច្បាប់។ ភ្នាក់ងារក៏កំពុងផ្ទៀងផ្ទាត់ព័ត៌មានផ្ទាល់ខ្លួនរបស់មនុស្សមួយចំនួនដែលត្រូវបានជួយសង្គ្រោះដោយភាគីកម្ពុជា ហើយនឹងជួយពួកគេឱ្យត្រឡប់ទៅផ្ទះវិញក្នុងពេលឆាប់ៗនេះ។

ក្រោមការដឹកនាំរបស់ក្រសួងការបរទេស ភ្នាក់ងារតំណាងវៀតណាមប្រចាំនៅកម្ពុជា បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជួយសង្គ្រោះជនជាតិវៀតណាមដែលត្រូវបានបោកបញ្ឆោត ឬល្បួងឱ្យទៅធ្វើការដោយខុសច្បាប់នៅទីនោះ ហើយបានស្នើឱ្យកម្ពុជាកុំដាក់ពិន័យរដ្ឋបាលលើជនទាំងនេះ។ នាយកដ្ឋានកុងស៊ុលរបស់ក្រសួងក៏បានស្នើឱ្យភ្នាក់ងារក្នុងស្រុក និងតំបន់ដែលជាប់ព្រំដែនកម្ពុជាអនុវត្តយន្តការសម្រាប់ការផ្ទៀងផ្ទាត់រហ័ស និងការទទួលពលរដ្ឋដែលត្រូវបានជួយសង្គ្រោះ។

ក្រសួងការបរទេស និងទីភ្នាក់ងារតំណាងកំពុងឃ្លាំមើលយ៉ាងជិតដល់អំពីស្ថានភាពពលករវៀតណាមនៅកម្ពុជា។ ពួកគេក៏កំពុងសម្របសម្រួលជាមួយអាជ្ញាធរនៃប្រទេសនានា ដើម្បីទទួលបានព័ត៌មានរហ័ស ជួយសង្គ្រោះ អនុវត្តវិធានការការពារប្រជាពលរដ្ឋ និងធ្វើមាតុភូមិនិវត្តន៍ជនដែលត្រូវបានបោកបញ្ឆោត ឬល្បួងឱ្យទៅធ្វើការដោយខុសច្បាប់នៅបរទេស។

នាថ្ងៃទី ១ ខែកញ្ញា ឆ្មាំព្រំដែនខេត្ត An Giang នៃខេត្តតាមដងទន្លេមេគង្គនិងកងកម្លាំងពាក់ព័ន្ធបានទទួលពលរដ្ឋវៀតណាមចំនួន ២៦ នាក់ ដែលអាជ្ញាធរកម្ពុជាប្រគល់ជូននៅច្រកទ្វារព្រំដែនអន្តរជាតិ Tinh Bien ។ លោកវរសេនីយ៍ទោ Tran Hoa Hiep ប្រធានប៉ុស្តិ៍ការពារព្រំដែននៅច្រកទ្វារព្រំដែនអន្តរជាតិ Tinh Bien បាននិយាយថា ក្រុមនេះមានស្ត្រី ៣នាក់ និងបុរស ២៣ នាក់ ក្នុងនោះមាន ១១ នាក់ពាក់ព័ន្ធនឹងកាស៊ីណូ Rich World ដែលកម្មករជាច្រើនបានព្យាយាមរត់ចេញទៅប្រទេសវៀតណាមកាលពីថ្ងៃទី១៨ សីហា ។

កាលពីថ្ងៃទី១៨ ខែសីហា មនុស្សចំនួន៤០នាក់ រួមមានប្រុស៣៥នាក់ ស្រី៥នាក់ បានរត់គេចខ្លួនចេញពីកាស៊ីណូ Rich World ស្ថិតក្នុងឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ហើយបានហែលឆ្លងទន្លេ Binh Ghi ត្រឡប់ទៅប្រទេសវៀតណាមវិញដោយខុសច្បាប់។ ក្រៅពីពួកគេមានម្នាក់ស្លាប់ដោយសារលង់ទឹកទន្លេ និងម្នាក់ទៀតត្រូវឆ្មាំកាស៊ីណូចាប់។ ពួកគេបាននិយាយថា ពួកគេត្រូវបានបង្ខំឱ្យធ្វើការ ហើយមិនបានបើកប្រាក់ខែ ទើបពួកគេសម្រេចចិត្តរត់ចេញទៅប្រទេសវៀតណាម។ ការស៊ើបអង្កេតករណីនេះ នគរបាលបានរកឃើញបណ្តាញ ៤ ដែលបង្ហាញពីសញ្ញានៃការជួញដូរមនុស្សនៅក្នុងមូលដ្ឋានមួយចំនួន។ នគរបាលខេត្ត An Giang បានឃាត់ខ្លួន និងចាប់ផ្តើមដំណើរការនីតិវិធីផ្លូវច្បាប់លើស្ត្រីម្នាក់ និងបុរសម្នាក់ ក្រោមបទចោទប្រកាន់នៃការរៀបចំច្រកចេញខុសច្បាប់សម្រាប់មនុស្សផ្សេងទៀត។ *VNA*

## អ្នកនាំពាក្យអគ្គស្នងការ៖ កម្ពុជាគ្មានតំបន់ងាយរងគ្រោះដោយអំពើជួញដូរមនុស្សទេ ខណៈរាជរដ្ឋាភិបាលបន្តខិតខំទប់ស្កាត់ និងបង្ក្រាបជានិច្ច

http://freshnewsasia.com/ 2022-09-02 02:11pm

**(ភ្នំពេញ)៖** កម្ពុជា គ្មានតំបន់ដែលងាយរងគ្រោះ ដោយសារអំពើជួញដូរមនុស្សឡើយ ហើយរាជរដ្ឋាភិបាល មិនដែលប្រងើយកន្តើយលើការងារនេះទេ ពោលតាំងពីដើមរហូតមកដល់ពេលនេះ កម្ពុជាបន្តខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាបន្តបន្ទាប់ និងប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ក្នុងការបង្ការ ទប់ស្កាត់ និងឈានដល់ការបង្ក្រាប។ នេះជាការប្រកាសរបស់ លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរង និងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រោយបញ្ចប់កិច្ចប្រជុំផ្សព្វផ្សាយផែនការស្តីពីការចាត់តាំងអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រោមអធិបតីភាព នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជាប្រធានគណៈបញ្ជាការដឹកនាំប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំង

គ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ។ ការប្រកាសនេះ ក៏ជាការឆ្លើយតបនឹងសារព័ត៌មានបរទេសមួយចំនួន ដែលបានបំភ្លៃពីកម្ពុជាផងដែរ។

កិច្ចប្រជុំនៅព្រឹកថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២នេះ ធ្វើឡើងនៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយមានការចូលរួមពី នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរង មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងថ្នាក់ដឹកនាំ មន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត ដែលជាសមាជិកគណៈបញ្ជាការដឹកនាំប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ។ ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានថ្លែងយ៉ាងដូច្នេះថា «**កម្ពុជាគ្មានតំបន់ណាដែលងាយរងគ្រោះ ដោយអំពើជួញដូរមនុស្សនោះទេ ប៉ុន្តែមុខសញ្ញាដែលងាយរងគ្រោះមាន។ ដោយសារប្រជាពលរដ្ឋមូលដ្ឋានខ្វះការអប់រំ ខ្វះការជួយផ្សព្វផ្សាយ និងមិនសូវយល់ដឹងអំពីល្បិចកលជនល្មើស ដែលលួងលោមជួញដូរកុមារ ស្ត្រីនេះ គឺជាមុខសញ្ញាដែលងាយរងគ្រោះ ប៉ុន្តែបើឲ្យវាយតម្លៃថាកន្លែងណាដែលងាយជួញដូរ គឺអត់មាន**»។

បើតាមលោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន, ក្នុងកិច្ចប្រជុំនេះ នាយឧត្តមសេនីយ៍ នេត សាវឿន បានណែនាំឲ្យពង្រឹងវិធានការក្នុងការតស៊ូប្រយុទ្ធប្រឆាំងជាមួយឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ជាពិសេសពាក់ព័ន្ធអំពើជួញដូរមនុស្ស ហើយដាក់ចេញវិធានការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈទូទៅ សំដៅធានាបរិយាកាសសន្តិសុខនៅក្នុងប្រទេសកម្ពុជា ហើយក៏បានដាក់ចេញវិធានការដើម្បីស្រាវជ្រាវរកមូលហេតុ រកដើមចមដាក់ស្តែងនៃសារព័ត៌មានមួយចំនួនដែលមានបំពុល ធ្វើឲ្យប៉ះពាល់ដល់កិត្តិយសកម្ពុជា។

នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានកំណត់នូវទិសដៅផែនការ ចំនួន២សំខាន់ៗ ដើម្បីរួមគ្នាអនុវត្ត គឺទី១៖ កំណត់គោលដៅដែលត្រូវត្រួតពិនិត្យ ស្រាវជ្រាវ និងបង្ក្រាប និងទី២៖ កំណត់គោលការណ៍ដែលត្រូវអនុវត្ត។ នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ក៏បានដាក់ចេញនូវគោលការណ៍ត្រួតពិនិត្យគោលដៅជនបរទេស ត្រួតពិនិត្យលិខិតស្នាម ភាពស្របច្បាប់របស់ជនបរទេសដែលស្នាក់នៅ និងបម្រើការងារនៅក្នុងប្រទេសកម្ពុជា ក្នុងនោះត្រូវធ្វើការស្រាវជ្រាវដើម្បីរកឲ្យឃើញនូវបទល្មើស និងឈានទៅបើកប្រតិបត្តិការបង្ក្រាប។

**សម្រាប់គោលការណ៍ប្រតិបត្តិការ ដែលដាក់ចេញនៅក្នុងកិច្ចប្តជុំនេះ ក៏មានដែរនូវ៖**

**ទី១៖** ផ្តល់ក្នុងការផ្សព្វផ្សាយអប់រំទៅដល់គោលដៅអាជីវកម្ម សេវាកម្មពាក់ព័ន្ធជនបរទេស ធ្វើឲ្យបានទូលំទូលាយ និងឆ្លើយតបព័ត៌មានបំពុលនានា។

**ទី២៖** ម្ចាស់អាជីវកម្មទីតាំងទាំងអស់នោះ ត្រូវធ្វើស្វ័យរបាយការណ៍ជូនគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ដោយផ្អែកតាមច្បាប់អន្តោប្រវេសន្ត និងច្បាប់ការងារ ប៉ុន្តែត្រូវភាពទន់ភ្លន់ ដោយម្ចាស់អាជីវកម្មអាចមកបំពេញនៅកន្លែងនគរបាល ឬបំពេញតាមប្រព័ន្ធអនឡាញ ឬសមត្ថកិច្ចចុះទៅដល់ទីតាំងផ្ទាល់តែម្តង។

បន្ថែមពីនេះ ត្រូវអនុវត្តវិធានការជំនាញ ដោយផ្តោតលើការងារពង្រឹងគ្រប់គ្រងធ្វើរដ្ឋបាល ប៉ុន្តែមិនមែនត្រូវធ្វើរដ្ឋបាលទាំងអស់នោះទេ ចៀសវាងនូវការបង្កភាពភិតភ័យដល់ប្រជាពលរដ្ឋ មានន័យថា ត្រូវចុះទៅកន្លែងណាដែលជាគោលដៅសង្ស័យ និងពង្រឹងការអនុវត្តច្បាប់ផ្ទាល់តែម្តង នៅពេលរកឃើញបទល្មើសកើតឡើង។ ដោយឡែក សម្រាប់ជនបរទេសណាដែលចូលមកកម្ពុជា ដោយមិនមានច្បាប់ទម្លាប់ ឬលិខិតស្នាមត្រូវចាប់បណ្តេញចេញ ខណៈជនណាដែលពាក់ព័ន្ធការអូសទាញក្រោយពិនិត្យឃើញមានធាតុផ្សំបទល្មើសច្បាស់លាស់ ករណីជួញដូរ ធ្វើទារុណកម្ម ត្រូវតែអនុវត្តច្បាប់ជាធរមាន។

សូមរំលឹកថា ពាក់ព័ន្ធអំពើជួញដូរមនុស្សជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ធ្លាប់បានចេញសេចក្តីអំពាវនាវឲ្យសាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និង

អាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសជាមិត្ត បន្តសហការផ្តល់ព័ត៌មាន ឬតម្រុយនានាពាក់ព័ន្ធអំពើជួញដូរមនុស្ស ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះ នៅក្នុងប្រទេសកម្ពុជា។

**ការផ្តល់ព័ត៌មានអាចធ្វើទៅបានតាមរយៈ៖**

១៖ គេហទំព័រ Facebook: Samdech Krolahom Sar Kheng, Cambodian Deputy Prime Minister

២៖ លេខទូរសព្ទ Hotline របស់អគ្គស្នងការដ្ឋាននគរបាលជាតិ: ១១៧ និង (+៨៥៥) ៣១ ២០១ ២៣៤៥

៣៖ គេហទំព័រ Facebook: អគ្គស្នងការដ្ឋាននគរបាលជាតិ-General Commissariat of Natioral Police

៤៖ គេហទំព័រ Facebook: អគ្គនាយកដ្ឋានអន្តោប្រវេសន៍-General Department of Immigration-GDI៕

## នាយឧត្តមសេនីយ៍ នេត សាវឿន ផ្សព្វផ្សាយផែនការ ស្តីពីការចាត់តាំងអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ

https://cen.com.kh/ Posted ByPen Srey NeatSeptember 2, 2022

ភ្នំពេញ ៖ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជាប្រធានគណៈបញ្ជាការដឹកនាំប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បានអញ្ជើញដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយផែនការ ស្តីពីការចាត់តាំងអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ នៅព្រឹកថ្ងៃសុក្រ ទី២ ខែកញ្ញា ឆ្នាំ២០២២។

ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មានក្រោយបញ្ចប់កិច្ចប្រជុំ ឯកឧត្តម ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងនគរបាលជាតិ បានឲ្យដឹងថា កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងពង្រឹងវិធានការក្នុងការតស៊ូប្រយុទ្ធប្រឆាំងជាមួយឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ជាពិសេសពាក់ព័ន្ធអំពើជួញដូរមនុស្ស ដោយដាក់ចេញវិធានការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈទូទៅ សំដៅធានាបរិយាកាសសន្តិសុខនៅក្នុងប្រទេសកម្ពុជា ហើយក៏បានដាក់ចេញវិធានការដើម្បីស្រាវជ្រាវរកមូលហេតុ រកដើមចមដាក់ស្តែង នៃសារព័ត៌មានមួយចំនួនដែលមានបំពុល ធ្វើឲ្យប៉ះពាល់ដល់កិត្តិយសកម្ពុជា។ ឯកឧត្តម បន្តថា ជារួមសមាសភាពក្រុមការងារជំនាញថ្នាក់ជាតិ ជាកម្លាំងគាំទ្រផ្នែកបច្ចេកទេស ដោយឡែកអ្នកអនុវត្តជាក់ស្តែងនៅគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ជាអ្នកចាត់តាំងអនុវត្តនូវគោលការណ៍ ផែនការប្រតិបត្តិការនេះ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានបញ្ជាក់ថា ក្នុងកិច្ចប្រជុំ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានអះអាងថា នៅក្នុងប្រទេសកម្ពុជា គ្មានកន្លែងណាមួយដែលងាយរងគ្រោះដោយអំពើជួញដូរមនុស្សនោះទេ ប៉ុន្តែយើងមានមុខសញ្ញាដែលងាយរងគ្រោះ ដូចជាស្ត្រី និងកុមារដែលពួកគាត់នៅតាមមូលដ្ឋានខ្វះការអប់រំ និងមិនសូវយល់ដឹងអំពីល្បិចកលរបស់ជនល្មើស ដែលលួងលោមពួកគាត់ឲ្យធ្លាក់ចូលក្នុងអន្ទាក់នៃអំពើជួញដូរនេះ។ ទន្ទឹមនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ក៏បានណែនាំកិច្ចការមួយចំនួនដូចខាងក្រោម៖

ទី១៖ កំណត់គោលដៅដែលត្រូវត្រួតពិនិត្យ ស្រាវជ្រាវ និងបង្ក្រាប

ទី២៖ កំណត់គោលការណ៍ដែលត្រូវអនុវត្ត។

ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ក៏បានដាក់ចេញនូវគោលការណ៍ត្រួតពិនិត្យគោលដៅជនបរទេស ត្រួតពិនិត្យលិខិតស្នាម ភាពស្របច្បាប់របស់ជនបរទេសដែលស្នាក់នៅ និងបម្រើការ

ងានៅក្នុងប្រទេសកម្ពុជា ក្នុងនោះត្រូវធ្វើការស្រាវជ្រាវដើម្បីរកឲ្យឃើញនូវបទល្មើស និងឈានទៅបើកប្រតិបត្តិការបង្ក្រាប។

សម្រាប់គោលការណ៍ប្រតិបត្តិការរួមមាន៖

១៖ ផ្សព្វផ្សាយអប់រំ

២៖ ការធ្វើស្វ័យរបាយការណ៍របស់ម្ចាស់អាជីវកម្មជូនគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត

៣៖ការត្រួតពិនិត្យ រដ្ឋបាល

៤៖ ការអនុវត្តច្បាប់

បន្ថែមពីនេះ ត្រូវផ្តល់ការផ្សព្វផ្សាយអប់រំទៅដល់គោលដៅអាជីវកម្ម សេវាកម្មពាក់ព័ន្ធជនបរទេស ធ្វើឲ្យបានទូលំទូលាយ និងឆ្លើយតបព័ត៌មានបំពុលនានា។ ត្រូវអនុវត្តវិធានការជំនាញ ដោយផ្តោតលើការងារពង្រឹងគ្រប់គ្រងធ្វើរដ្ឋបាលដោយ ត្រូវចុះទៅកន្លែងណាដែលជាគោលដៅសង្ស័យ និងពង្រឹងការអនុវត្តច្បាប់ផ្ទាល់តែម្តង នៅពេលរកឃើញបទល្មើសកើតឡើង។ ដោយឡែក សម្រាប់ជនបរទេសណាដែលចូលមកប្រទេសកម្ពុជា ដោយមិនមានច្បាប់ទម្លាប់ ឬលិខិតស្នាមត្រូវចាប់បណ្តេញចេញ ខណៈជនណាដែលពាក់ព័ន្ធការអូសទាញក្រោយពិនិត្យឃើញមានជាតុផ្សំបទល្មើសច្បាស់លាស់ ករណីជួញដូរ ធ្វើទារុណកម្ម ត្រូវតែអនុវត្តច្បាប់ជាធរមាន៕ រក្សាសិទ្ធិដោយ ៖សុទ្ធលី

# ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២

## នាយឧត្តមសេនីយ៍ នេត សាវឿន ជំរុញឱ្យបង្កើនសកម្មបន្ថែមទៀត ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

https://btv.com.kh/ 2022/09/02 02:39:28 pm

ភ្នំពេញ៖ នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានធ្វើការជំរុញដល់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវតែបង្កើនសកម្មភាពបន្ថែមទៀតក្នុងកិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយបញ្ចប់កិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដែលដឹកនាំដោយនាយឧត្តមសេនីយ៍ នេត សាវឿន នាព្រឹកថ្ងៃទី២ ខែ កញ្ញា ឆ្នាំ២០២២នេះ ឯកឧត្តមឧត្តមសេនីយ៍ឯក ឆាយ គឹមឃឿន អគ្គស្នងការរង និងជាអ្នកនាំពាក្យរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ បានលើកឡើងថា នៅក្នុងកិច្ចប្រនេះឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន បានជំរុញឲ្យភាគីទាំងអស់ គប្បីយកចិត្តទុកដាក់បន្ថែមទៀត លើកិច្ចការទប់ស្កាត់បទល្មើសឆ្លងដែន ការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងបញ្ហាជាច្រើនទៀត៕ អត្ថបទ៖ បាន ចក់

## ប្រតិបត្តិការពិសេស រំដោះនារីរងគ្រោះ ៧នាក់ ចេញពីទីតាំង KTV ផ្តល់ឱ្យបម្រ សេវាសញ្ញារកម្ម

https://cen.com.kh/ Posted ByPen Srey NeatSeptember 3, 2022

កំពង់ស្ពឺ៖ កាលពីថ្ងៃសុក្រ ទី២ ខែកញ្ញា ឆ្នាំ២០២២ ក្រោមកិច្ចចង្អុលការណែនាំដ៏ខ្ពង់ខ្ពស់ ពីលោកឧត្តមសេនីយ៍ទោ សម សាមួន ស្នងការ នគរបាលខេត្តកំពង់ស្ពឺ កម្លាំងជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺបានការសេម្របសម្រួលនីតិវិធី ពីលោកចក់ សម្បត្តិ ព្រះរាជអាជ្ញារង នៃ

អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានដំណើរការ ចុះបង្ក្រាបករណីសញ្ជារកម្ម នៅទីតាំង KTV និងបើកផ្ទះសំណាក់គ្មានឈ្មោះ ស្ថិតនៅភូមិទី៤ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

ប្រតិបត្តិការខាងលើសមត្ថកិច្ចបានទទួលព័ត៌មានពី ប្រភពច្បាស់ការថាទីតាំង KTV នេះបើកបម្រើសេវាច្រៀងលេងកំសាន្តផង និងលួចលាក់ឲ្យមានការផ្តល់សេវាផ្លូវភេទ ពាក្យច្បាប់សញ្ជារកម្ម ״ ជាក់ស្តែងសមត្ថកិច្ចបានឃាត់មនុស្ស ០៣នាក់ដែលជាអ្នកទទួលខុសត្រូវលើទីតាំងខាងលើ ដើម្បីយកមកសាកសួរ នៅស្នងការដ្ឋាននគរបាលខេត្ត។ តាមការបញ្ជាក់ពីលោកស្រី វរសេនីយ៍ ទោ មួនមល្លិកា នាយការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនថា ជនសង្ស័យក្នុងការទទួល ខុសត្រូវចំពោះទីតាំងខាងលើ ៣នាក់មានឈ្មោះ÷

១.ឈ្មោះ សួង ស្រីអូន ភេទស្រី អាយុ ៣៣ ឆ្នាំ តួនាទី ជាថៅកែហាង

២.ឈ្មោះ ទាវ ស្រីមុំ ភេទស្រី អាយុ ១៨ ឆ្នាំ តួនាទី ជាមេការ

៣.ឈ្មោះ អាន ស្រីមុំ ភេទស្រី អាយុ ៣៣ឆ្នាំ តួនាទី ជាមេការ

ប្រតិបត្តិការ បានសង្គ្រោះនារីចំនួន៧នាក់ ក្នុងនោះមានក្មេងស្រី មិនទាន់គ្រប់អាយុ(ជាអនីតិជន ក្រោម១៨ឆ្នាំ ) ៤នាក់ ។ ក្រោយនីតិវិធីសាកសួរលើជនសង្ស័យទាំង៣នាក់ សមត្ថកិច្ចរកឃើញ តម្រុយពីការប្រព្រឹត្តិឲ្យមានអំពើសញ្ជាកម្ម បម្រើសេវាផ្លូវភេទ នៅទីតាំង ខាងលើ សមត្ថកិច្ចនគរបាលបានបំពេញនីតិវិធី កសាងសំណុំរឿងបញ្ជូនទៅអយ្យការចាត់ការបន្ត៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## មន្ត្រីក្រសួងការងារ៖ ក្រុមហ៊ុនកូរ៉េស្នើឱ្យកាត់បន្ថយចំនួនពលករខ្មែរ បន្ទាប់ពីពួកគេសម្រុកចេញពីប្រទេស

https://khmer.voanews.com/ 31 សីហា 2022លាស់ លីបលីប

ភ្នំពេញ៖ អ្នកនាំពាក្យក្រសួងការងារបានឱ្យដឹងថា ក្រុមហ៊ុនកូរ៉េបានប្តឹងទៅក្រសួងការងារកូរ៉េ ដោយស្នើឱ្យកាត់បន្ថយចំនួនពលករកម្ពុជា បន្ទាប់ពីពួកគេជាង៤០០នាក់ ដែលធ្វើការនៅកូរ៉េ បានសម្រុកចាកចេញមកកម្ពុជា និងបោះបង់ការងារយ៉ាងតក់ក្រហល់។ ការចាកចេញនេះពាក់ព័ន្ធនឹងការអំពាវនាវរបស់ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ លោក ខឹម វាសនា ដែលថា ទឹកនឹងជន់លិចពិភពលោកទាំងមូល។ មិនមែនមានតែពលករខ្មែរធ្វើការនៅប្រទេសកូរ៉េទេ ពលករខ្មែរធ្វើការនៅប្រទេសជប៉ុន ប្រមាណ១០០នាក់ក៏បានត្រឡប់មកកម្ពុជាយ៉ាងតក់ក្រហល់ផងដែរ។ នេះបើតាមលោក ហេង សួរ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការងារ។

លោក ហេង សួរ ប្រាប់វីអូអេនៅថ្ងៃពុធនេះថា ចាប់ពីថ្ងៃទី២៣ដល់២៥ ខែសីហានេះ ពលករខ្មែរធ្វើការនៅកូរ៉េបានសម្រុកចេញមកកម្ពុជា ចំនួនជាង៤០០នាក់ និងពលករខ្មែរចាកចេញពីប្រទេសជប៉ុនមកកម្ពុជាមានប្រហែល១០០នាក់។ លោកបន្ថែមថា ក្នុងនោះក៏មាននិស្សិតថ្នាក់បណ្ឌិត រៀននៅតំបន់កាន់សៃរបស់ប្រទេសជប៉ុន១នាក់ផងដែរ។ អ្នកនាំពាក្យក្រសួងការងាររូបនេះបន្ថែមថា ពលករខ្មែរទាំងនោះ ខ្លះសុំច្បាប់ថៅកែថា ឪពុកម្តាយឈឺធ្ងន់ និងខ្លះទៀតសុំច្បាប់ថៅកែឈប់មិនបាន ក៏ពួកគេសម្រេចចិត្តបោះបង់ការងារចោល និងត្រឡប់មកកម្ពុជាវិញ។ លោកបញ្ជាក់ថា ការចាកចេញរបស់ពួកគេគឺដោយសារជឿលើ«ការឃោសនាអកុសលបែបអបិយជំនឿ និងមិនសមហេតុផល» របស់លោក ខឹម វាសនា។ លោក ហេង សួរ បន្តថា ករណីនេះធ្វើឱ្យក្រុមហ៊ុនកូរ៉េមួយចំនួនបានប្តឹងទៅក្រសួងការងារកូរ៉េ ដោយស្នើឱ្យកាត់បន្ថយពលកររបស់កម្ពុជា ដែលលោកមិនអាចបញ្ជាក់ថា តើមានចំនួនក្រុមហ៊ុនប៉ុន្មានទេ ដែលបានប្តឹងទៅក្រសួងការងារកូរ៉េ។

អ្នកនាំពាក្យក្រសួងការងារថា ក្រសួងការងារបានជួបដោះស្រាយបញ្ហានេះជាមួយតំណាងអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សកូរ៉េ (HTD Korea) ដោយបានសុំទោសរដ្ឋាភិបាលកូរ៉េ ជាពិសេសនិយោជកកូរ៉េ ដែលរងផលប៉ះ

ពាល់ដោយការចលាចលនេះ។ ក្រសួងក៏សំណូមពរដល់និយោជកកូរ៉េ និងជប៉ុនមេត្តាយោគយល់ដល់ពលករ និងសិក្ខាកាមរបស់កម្ពុជា ដោយកុំប្តឹង និងពិចារណាទទួលយកពួកគេវិញតាមលទ្ធភាពជាក់ស្តែង។ លោក ហេង សួរ បញ្ជាក់សារជាអក្សរតាមប្រព័ន្ធតេឡេក្រាមថា៖ «គេ [ក្រុមហ៊ុនកូរ៉េ] បានប្តឹងទៅក្រសួងការងារកូរ៉េ និងបានសំណូមពរឲ្យក្រសួងការងារកូរ៉េកាត់បន្ថយចំនួនពលករយើង។ យើងបានខិតខំសុំការយោគយល់ពីនិយោជកកូរ៉េ ហើយសន្យាថា នឹងអប់រំបងប្អូនយើងបន្ថែម»។ លោក ហេង សួរ ក៏ស្នើទៅពលករដែលធ្វើការនៅក្រៅប្រទេសឱ្យរក្សាភាពស្ងៀមស្ងាត់ និងកុំជឿលើការឃោសនាណាមួយ។ បើតាមលោក ហេង សួរ បច្ចុប្បន្នពលករខ្មែរដែលធ្វើការនៅប្រទេសកូរ៉េ មានជាង៥ម៉ឺននាក់ និងក្នុងប្រទេសជប៉ុនមានជាង១ម៉ឺន៦ពាន់នាក់។

ទាក់ទងបញ្ហានេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃពុធនេះ បានស្នើទៅក្រុមហ៊ុនកូរ៉េ ជប៉ុន និងថៃ កុំប្តឹងតាមផ្លូវច្បាប់លើរដ្ឋាភិបាលកម្ពុជា និងពលករដែលរត់ចោលការងារនាពេលថ្មីៗនេះ។ លោកបន្ថែមថាពលករទាំងនោះចាញ់បោកការឃោសនារបស់ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ លោក ខឹម វាសនា។ លោក ហ៊ុន សែន បានស្នើបែបនេះនៅក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសថ្មីចំនួន២ ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី៣១ ខែសីហានេះ។ លោក ហ៊ុន សែន ថ្លែងថា៖ «សូមកុំឱ្យរដ្ឋាភិបាលនៃប្រទេសទាំងអស់ ដែលមានពលករធ្វើការនៅក្នុងប្រទេសរបស់ខ្លួន ដាក់ពាក្យបណ្តឹង ទាមទារសំណងពីរដ្ឋាភិបាលកម្ពុជា ឬពីបុគ្គលិកដែលរត់ចោលការងារ។ ហើយសូមកុំផ្សារភ្ជាប់ពលករកម្ពុជាដទៃទៀតជាមួយពលករដែលធ្វើកំហុស ដោយសារការចាញ់បោកសម្រាប់ព្រះព្រហ្ម [លោក ខឹម វាសនា តាំងខ្លួនជាព្រះព្រហ្ម] នៅប្រទេសកម្ពុជា»។

វីអូអេមិនទាន់អាចសុំការអត្ថាធិប្បាយពីអ្នកនាំពាក្យរបស់ក្រសួងការងារសាធារណៈរដ្ឋកូរ៉េ លោក Park Jihye តាមសារអ៊ីម៉ែលបាននៅឡើយទេ នាថ្ងៃពុធនេះ។

គួរបញ្ជាក់ថា កាលពីពេលថ្មីៗនេះ លោក ខឹម វាសនា ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានតាំងខ្លួនថា ជា«ព្រហ្មរក្សាលោក» និងបានទស្សន៍ទាយថា មានទឹកជំនន់លិចពិភពលោក ដោយថា មានតែដីចម្ការម្រេចរបស់លោកនៅជិតក្បែរជើងភ្នំគូលែន ខេត្តសៀមរាបប៉ុណ្ណោះ ដែលមិនជន់លិច។ អ្នកនយោបាយរូបនោះបានហៅសមាជិករបស់ខ្លួនឱ្យមកផ្តុំគ្នានៅចម្ការនោះដើម្បីរួចផុតពីការជន់លិច ដែលជាហេតុធ្វើឱ្យអ្នកគាំទ្រលោក ទាំងក្នុងស្រុកនិងក្រៅស្រុកនាំគ្នាសម្រុកទៅ និងខ្លះទៀតដែលជាពលករនៅក្រៅប្រទេសបង្ខំចិត្តបោះបង់ចោលការងារនៅក្រៅប្រទេស និងមកប្រទេសកម្ពុជាវិញយ៉ាងតក់ក្រហល់ ដោយសារភ័យខ្លាច។ ការជឿលើការឃោសនារបស់លោក ខឹម វាសនា ក៏នាំឱ្យមានការរិះគន់ផងដែរថា ហេតុអ្វីបានជាប្រជាពលរដ្ឋជឿលើពាក្យសម្តីរបស់អ្នកនយោបាយរូបនោះ។ អ្នកតាមដានសង្គមបានលើកឡើងថា ប្រជាពលរដ្ឋគួរតែពិចារណា មុនជឿស្លុងលើអ្វីមួយ៕

## នាយឧត្តមសេនីយ៍ ខៀវ សុភ័គ៖ ៨ខែនេះ សមត្ថកិច្ចអន្តរាគមន៍១០៤ករណី សង្គ្រោះ៩៦៨នាក់ ឃាត់ខ្លួន៨២នាក់ ក្នុងនោះមានតែ១៩ករណីប៉ុណ្ណោះ ជាករណីបង្ខាំង និងជំរិតទារប្រាក់

http://freshnewsasia.com/ 2022-09-03 09:52am

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា រយៈពេល៨ខែ ក្នុងឆ្នាំ២០២២នេះ ពោលពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជា បានបើកប្រតិបត្តិការចុះត្រួតពិនិត្យលើបណ្តឹងចំនួន១០៤ករណី ដោយសង្គ្រោះមនុស្ស៩៦៨នាក់ និងឃាត់ខ្លួនជនសង្ស័យ៨២នាក់ ប៉ុន្តែក្នុងនោះមានតែ១៩ករណីប៉ុណ្ណោះ ដែលជាករណីបង្ខាំង និងជំរិតទារប្រាក់។ នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា រយៈពេល៨ខែមកនេះ សមត្ថកិច្ចកម្ពុជា បានទទួលពាក្យបណ្តឹងសរុបចំនួន១២៨ករណី ក្នុងនោះបណ្តឹងតាមរយៈស្ថានទូតចំនួន១០៥ករណី បណ្តឹងតាមរ

យៈ Hotline ជនបរទេស ១៩ករណី និងបណ្តឹងពីនគរបាលអន្តរជាតិ៤ករណី ដោយឡែកតាមហ្វេសប៊ុករបស់ សម្តេចក្រឡាហោម ស ខេង មានចំនួន៤០ករណីទៀត។

បើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ, ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ សមត្ថកិច្ចបានើអន្តរាគមន៍ ចំនួន១០៤ករណី សង្គ្រោះជនរងគ្រោះចំនួន៩៦៨នាក់ ក្នុងនោះមានជនជាតិឥណ្ឌូនេស៊ី ៣៦៥នាក់ វៀតណាម ៣៥៣នាក់ ថៃ១១៩នាក់ ម៉ាឡេស៊ី៤២នាក់ ចិន៣៥នាក់ ប៉ាគីស្ថាន១៤នាក់ ឥណ្ឌា ១២នាក់ មីយ៉ាន់ម៉ា១២នាក់ ហ្វីលីពីន១១នាក់ តួកគី២នាក់ អាមេរិក១នាក់ អង់គ្លេស១នាក់ និងកូរ៉េខាងត្បូង១នាក់។ លោកបានបញ្ជាក់ថា ក្នុងចំណោម១០៤ករណី ដែលសមត្ថកិច្ចបានអន្តរាគមន៍ នេះ មានតែ១៩ករណីប៉ុណ្ណោះដែលជាករណីបង្ខាំង និងជំរិតទាប្រាក់ ឯក្រៅពីនោះ សមត្ថកិច្ចរកឃើញថាជាករណីប្រឌិដ្ឋដោយសារ វិវាទការងារ ទំនាស់កិច្ចសន្យា, ការរិតត្បិតសេរីភាព, ផ្លាស់ប្តូរកន្លែងធ្វើការងារផ្ទុយពីឆន្ទៈ, ជំពាក់ប្រាក់ក្រុមហ៊ុន ឬគេចវេសមិនសង, មិនពេញចិត្តស្ថានភាពរស់នៅ ស្ថានភាពការងារ និងសាច់ញាតិព្រួយបារម្ភ ហើយប្តឹងសមត្ថកិច្ចឱ្យតាមរកជាដើម។ លោកបានបញ្ជាក់បន្ថែមទៀតថា សម្រាប់ជនសង្ស័យដែលសមត្ថកិច្ចឃាត់ខ្លួនចំនួន៨២នាក់វិញ មានជនជាតិចិន៣នាក់ វៀតណាម៤នាក់ ម៉ាឡេស៊ី៣នាក់ និងខ្មែរ២នាក់ផងដែរ។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) កាលពីពេលថ្មីៗនេះ បានចេញសេចក្តីអំពាវនាវឲ្យសាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសជាមិត្ត បន្តសហការផ្តល់ព័ត៌មាន ឬតម្រុយនានាពាក់ព័ន្ធអំពើជួញដូរមនុស្ស ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះ នៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះផងដែរ។

ពាក់ព័ន្ធនឹងករណីនេះ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ ក្នុងនាមសមត្ថកិច្ចកម្ពុជា បានស្នើដល់ស្ថាប័នតុលាការ ចាត់វិធានការតាមច្បាប់ឱ្យបានតឹងរ៉ឹង និងម៉ឺងម៉ាត់ចំពោះជនដែលបានប្រព្រឹត្តល្មើស ហើយសមត្ថកិច្ចបានត្រៀមឯកសារ និងភស្តុតាងដាក់បន្ទុកនានា ដើម្បីផ្តល់ជូនតុលាការ ធ្វើយ៉ាងណាមិនឱ្យជនល្មើសរួចខ្លួនពីសំណាញ់ច្បាប់នោះឡើយ៕

## ព្រះរាជអាជ្ញាក្រុងតៃប៉ិ ចោទប្រកាន់ជនសង្ស័យ៩នាក់ ពីបទជួញដូរជនជាតិតៃប៉ិ ៨៨នាក់ មកកម្ពុជា

https://www.khmertimeskh.com/ Khmer Times September 3, 2022

ព្រះរាជអាជ្ញាក្រុងតៃប៉ិកាលពីថ្ងៃសុក្របានចោទប្រកាន់ជនសង្ស័យចំនួន ៩ នាក់ពីការចំណាយលើការជួញដូរមនុស្ស ពីបទល្បួងមនុស្សចំនួន ៨៨ នាក់មកប្រទេសកម្ពុជាឱ្យធ្វើការនៅក្នុងក្រុមបោកប្រាស់តាមបណ្តាញអ៊ីនធឺណែត ដែលបានវិវត្តទៅជាបញ្ហាក្តៅក្នុងតំបន់។ ក្រុមបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិត មានវត្តមានយូរមកហើយនៅទូទាំងអាស៊ីអាគ្នេយ៍ ប៉ុន្តែនៅក្នុងខែចុងក្រោយនេះ លក្ខណៈពិសេសបន្ថែមបានលេចឡើងនៃបុគ្គលដែលត្រូវបានជួញដូរ និងបង្ខំឱ្យធ្វើការ។ ជនរងគ្រោះបានរាយការណ៍ថាបានធ្វើដំណើរទៅប្រទេសមីយ៉ាន់ម៉ា កម្ពុជា ថៃ និងឡាវ លើការជានាក្លែងក្លាយពាក់ព័ន្ធនឹងរឿងស្នេហា ឬការងារដែលមានប្រាក់ខែខ្ពស់។

ការិយាល័យព្រះរាជអាជ្ញាក្រុងតៃប៉ិបានលើកឡើងនៅក្នុងសេចក្ដីប្រកាសព័ត៌មានមួយថា ជនជាប់ចោទទាំងនេះនៅទីក្រុងតៃប៉ិ បានរៀបចំបណ្ដាញរត់ពន្ធមនុស្សចំនួនពីរដែលដំណើរការការផ្សាយពាណិជ្ជកម្មការងារនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមជាមួយនឹងការធានានៃ "ប្រាក់ខែច្រើនលើលលប់និងប្រាក់កម្ចីភ្លាមៗ" ។ ព្រះរាជអាជ្ញាបានបន្ថែមថា ការផ្សាយពាណិជ្ជកម្មបានបោកបញ្ឆោតបុគ្គលវ័យក្មេងដែលគ្មានការងារធ្វើ និងអ្នកដែលមានការលំបាកផ្នែករូបិយវត្ថុឱ្យចូលមកប្រទេសកម្ពុជា។ នៅពេលនោះ ពួកគេត្រូវបានប្រគល់ទៅឱ្យបណ្ដាញទូរគមនាគមន៍ និងក្លែងបន្លំតាមអ៊ីនធឺណិត ដែលបង្ខំពួកគេឱ្យធ្វើការ។ អ្នកខ្លះត្រូវបានគេធ្វើការឆក់ខ្សែភ្លើង ឬត្រូវបានបង្ខាំងខ្លួនដើម្បីជំរិតទារប្រាក់ ក្នុងករណីដែលពួកគេបដិសេធមិនគោរពតាមបញ្ជា ឬអនុវត្តមិនបានល្អ តាមតម្រូវការ។ ព្រះរាជអាជ្ញាបានរៀបរាប់ថា "ជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយមិនគិតពីអាយុជីវិតដែលរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ហើយបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់មុខមាត់ប្រទេសជាតិ។ ក្នុងចំណោមជនរងគ្រោះទាំង៨៨នាក់នោះ មាន១៨នាក់ត្រូវបានជួយសង្គ្រោះពីកម្ពុជា និងបានត្រឡប់ទៅតៃវ៉ាន់វិញ។

ខែចុងក្រោយ តៃវ៉ាន់រៀបចំឱ្យមានសកម្មភាពអន្តរក្រសួងមួយដើម្បីតាមដាន និងជួយជនរងគ្រោះដែលត្រូវបានជួញដូរដោយការបោកប្រាស់តាមអ៊ីនធឺណិត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ជាការឆ្លើយតបទៅនឹងការិយាល័យស៊ើបអង្កេតឧក្រិដ្ឋកម្មរបស់តៃវ៉ាន់ ជនជាតិតៃវ៉ាន់ច្រើនជាង ៤,៦០០ នាក់ ដែលបានធ្វើដំណើរមកប្រទេសកម្ពុជាកាលពីឆ្នាំមុន មិនបានត្រឡប់ទៅលំនៅដ្ឋានរបស់ពួកគេវិញទេ។ អ្នកស៊ើបអង្កេតចាត់ទុកថាប្រហែល ៣០០ នាក់ ក្នុងចំណោមនោះ អាចជាជនរងគ្រោះនៃបណ្ដាញបោកប្រាស់ និងការជួញដូរមនុស្ស។ ជនរងគ្រោះនៃក្រុមឧក្រិដ្ឋទាំងនោះ រួមមានអ្នករស់នៅហុងកុង និងអ្នកនិយាយភាសាចិន បន្ថែមលើជនជាតិថៃ និងជនជាតិវៀតណាម៕ Universalverge.com

## លោក នេត សាវឿន ណែនាំដល់មន្ត្រីឱ្យកំណត់គោលដៅ និងគោលការណ៍ដែលត្រូវអនុវត្តក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://www.postkhmer.com/ ភ្នំពេញ ប៉ុស្តិ៍ | Publication date 03 September 2022 | 09:46 ICT

**ភ្នំពេញ:** នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ជាអនុប្រធានគណៈ កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជាប្រធានគណៈបញ្ជាការដឹកនាំប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បានណែនាំដល់មន្ត្រីពាក់ព័ន្ធឱ្យកំណត់គោលដៅដែលត្រូវត្រួតពិនិត្យ ស្រាវជ្រាវ បង្ក្រាប និងត្រូវកំណត់គោលការណ៍ដែលត្រូវអនុវត្តក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ លោក នេត សាវឿន បានធ្វើការណែនាំបែបនេះ ក្នុងពេលដែលលោកអញ្ជើញដឹកនាំកិច្ចប្រជុំ ផ្សព្វផ្សាយផែនការស្ដីពីការចាត់តាំងអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ នៅថ្ងៃទី ២ ខែកញ្ញា នេះ។ ហ្វេសប៊ុកអគ្គស្នងការដ្ឋាននគរបាលជាតិ បានចុះផ្សាយថា កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីអនុប្រធាន និងសមាជិក សមាជិកា នៃគណៈបញ្ជាការដឹកនាំប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ អភិបាលខេត្តកណ្ដាល អភិបាលខេត្តព្រះសីហនុ និងអភិបាលរាជធានី-ខេត្តទាំង ២៥ ផងដែរ។

លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងនគរបាលជាតិ បានឱ្យដឹងថា កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីពង្រឹងវិធានការក្នុងការតស៊ូប្រយុទ្ធប្រឆាំងជាមួយឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ជាពិសេសពាក់ព័ន្ធអំពើជួញដូរមនុស្ស ដោយដាក់ចេញនូវវិធានការពង្រឹងសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈទូទៅ

សំដៅធានាបរិយាកាសសន្តិសុខនៅក្នុងប្រទេស។ កិច្ចប្រជុំនេះ ក៏ដើម្បីដាក់ចេញនូវវិធានការដើម្បីស្រាវជ្រាវរកមូលហេតុ រកដើមចមដាក់ស្តែង នៃសារព័ត៌មានមួយចំនួន ដែលបានបំពុល ធ្វើឱ្យប៉ះពាល់ដល់កិត្តិយសកម្ពុជាផងដែរ។ លោកបន្តថា ជារួមសមាសភាពក្រុមការងារជំនាញថ្នាក់ជាតិ ជាកម្លាំងគាំទ្រផ្នែកបច្ចេកទេស ដោយឡែកអ្នកអនុវត្តជាក់ស្តែងនៅគណៈបញ្ជាការឯកភាពរាជធានី-ខេត្តជាអ្នកចាត់តាំងអនុវត្តនូវគោលការណ៍ផែនការប្រតិបត្តិការនេះ។ លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានបញ្ជាក់ថា ក្នុងកិច្ចប្រជុំ នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានអះអាងថា នៅក្នុងប្រទេសកម្ពុជា គ្មានកន្លែងណាមួយដែលងាយរងគ្រោះ ដោយអំពើជួញដូរមនុស្សនោះទេ ប៉ុន្តែយើងមានមុខសញ្ញាដែលងាយរងគ្រោះ ដូចជាស្ត្រី និងកុមារ ដែលពួកគាត់នៅតាមមូលដ្ឋានខ្វះការអប់រំ និងមិនសូវយល់ដឹងអំពីល្បិចកលរបស់ជនល្មើស ដែលលួងលោមពួកគាត់ឱ្យធ្លាក់ចូលក្នុងអន្ទាក់ នៃអំពើជួញដូរនេះ។

ហ្វេសប៊ុកដដែលបញ្ជាក់ថា ទន្ទឹមនោះ នាយឧត្តមសេនីយ៍ នេត សាវឿន ក៏បានណែនាំកិច្ចការមួយចំនួនដោយត្រូវទី១ កំណត់គោលដៅដែលត្រូវត្រួតពិនិត្យ ស្រាវជ្រាវ និងបង្ក្រាបនិងទី២ កំណត់គោលការណ៍ដែលត្រូវអនុវត្ត។ លោកអគ្គស្នងការនគរបាលជាតិ ក៏បានដាក់ចេញនូវគោលការណ៍ត្រួតពិនិត្យគោលដៅជនបរទេស ត្រួតពិនិត្យលិខិតស្នាម ភាពស្របច្បាប់របស់ជនបរទេសដែលស្នាក់នៅ និងបម្រើការងារនៅក្នុងប្រទេសកម្ពុជា ក្នុងនោះត្រូវធ្វើការស្រាវជ្រាវដើម្បីរកឱ្យឃើញនូវបទល្មើស និងឈានទៅបើកប្រតិបត្តិការបង្ក្រាប។ សម្រាប់គោលការណ៍ប្រតិបត្តិការរួមមាន គឺត្រូវផ្សព្វផ្សាយអប់រំ ការធ្វើស្ទ័យបាយការណ៍របស់ម្ចាស់អាជីវកម្ម ជូនគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ការត្រួតពិនិត្យ រដ្ឋបាលនិងការអនុវត្តច្បាប់។ បន្ថែមពីនេះ ត្រូវផ្តល់ការផ្សព្វផ្សាយអប់រំទៅដល់គោលដៅអាជីវកម្ម សេវាកម្មពាក់ព័ន្ធជនបរទេស ធ្វើឱ្យបានទូលំទូលាយ និងឆ្លើយតបព័ត៌មានបំពុលនានា។ ត្រូវអនុវត្តវិធានការជំនាញ ដោយផ្តោតលើការងារពង្រឹងគ្រប់គ្រងធ្វើរដ្ឋបាលដោយត្រូវចុះទៅកន្លែងណាដែលជាគោលដៅសង្ស័យ និងពង្រឹងការអនុវត្តច្បាប់ផ្ទាល់តែម្តង នៅពេលរកឃើញបទល្មើសកើតឡើង។ ដោយឡែក សម្រាប់ជនបរទេសណាដែលចូលមកប្រទេសកម្ពុជា ដោយមិនមានច្បាប់ទម្លាប់ ឬលិខិតស្នាមត្រូវចាប់បណ្តេញចេញ ខណៈជនណាដែលពាក់ព័ន្ធការអូសទាញក្រោយពិនិត្យឃើញមាន ជាតុផ្សំបទល្មើស ច្បាស់លាស់ ករណីជួញដូរ ធ្វើទារុណកម្ម ត្រូវតែអនុវត្តច្បាប់ជាធរមាន៕

## សមត្ថកិច្ច ស្រាវជ្រាវតាមបណ្តឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេង មួយករណីទៀត រកឃើញជនជាតិមីយ៉ាន់ម៉ា២នាក់

http://freshnewsasia.com/ 2022-09-03 06:00pm

**(ព្រះសីហនុ)៖** កម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ នៅរសៀលថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២២ នេះ បានចុះត្រួតពិនិត្យទីតាំងក្រុមហ៊ុន ហ័ង ឡឺ ដែលមានទីតាំងស្ថិតនៅ ក្រុមទី៩ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ដោយបានរកឃើញជនរងគ្រោះជាជនជាតិមីយ៉ាន់ម៉ា២នាក់ ដែលមានការប្តឹងថាត្រូវបានបង្ខាំង។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា ប្រតិបត្តិការនេះ បានធ្វើឡើងបន្ទាប់ពីមានបណ្តឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេ ថាត្រូវបានគេចាប់បង្ខាំងទុក ដើម្បីឱ្យនៅបម្រើការងារក្នុងក្រុមហ៊ុន នៅក្នុងខេត្តព្រះសីហនុ ចំនួន ០១ករណី។ នាយឧត្តមសេនីយ៍ បានបញ្ជាក់ថាកម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចុះមកដល់ទីតាំងក្រុមហ៊ុនខាងលើនេះ បានស្រាវជ្រាវស្វែងរក ឃើញជនរងគ្រោះចំនួន០២នាក់ មាន ១៖ ឈ្មោះ AUNG MYINT THU ភេទប្រុស ជនជាតិមីយ៉ាន់ម៉ា អាយុ២៧ឆ្នាំ និង២៖ ឈ្មោះ SAI SI THU SHEIN ភេទប្រុស ជនជាតិមីយ៉ាន់ម៉ា អាយុ២៨ឆ្នាំ។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានបន្ថែមថា ក្រោយការសាកសួរ ជា

លទ្ធផលបឋមពុំមានការបង្ខាំង និងធ្វើទារុណកម្មឡើយ បន្ទាប់មកកម្លាំងសមត្ថកិច្ច ក៏បានឃាត់អ្នកគ្រប់គ្រងឈ្មោះ OOI SEE CHOON ភេទប្រុស ជនជាតិម៉ាឡេស៊ី អាយុ ៤៧ឆ្នាំ មកធ្វើការសាកសួរ ដើម្បីបន្តតាមនីតិវិធី៕

## ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២

## ស្ត្រីថៃវ័យក្មេងម្នាក់ ត្រូវបានប៉ូលីសឃាត់ខ្លួន ខណៈធ្វើដំណើរបម្រុងឆ្លងដែនចូលកម្ពុជា ដើម្បីធ្វើការឱ្យអេនបោកម្ដងនេះ

https://cen.com.kh/archives/524170.html Posted ByLeng KhunSeptember 3, 2022

ស្ត្រីជនជាតិថៃម្នាក់ត្រូវបានចាប់ខ្លួន ពាក់ព័ន្ធជាសមាជិកនៃក្រុមឆបោកតាមទូរស័ព្ទ (Call Center) ខណៈត្រូវបានរកឃើញពេលកំពុងធ្វើដំណើរត្រឡប់មកកាន់ប្រទេសកម្ពុជា។ មជ្ឈមណ្ឌលបោកប្រាស់ Call Center ត្រូវបានដឹងថា កំពុងដំណើរការយ៉ាងច្រើននៅក្នុងប្រទេសកម្ពុជា។ ក្នុងនោះ ពលករថៃទាំងអ្នកមានចេតនា និងខ្លះមិនមាន ត្រូវបង្ខំឲ្យធ្វើការនៅមជ្ឈមណ្ឌលនេះ ដើម្បីបោកប្រាស់ជនជាតិថៃផ្សេងទៀតក្នុងប្រទេស។

ប៉ូលីស PCT បានចាប់ខ្លួនស្ត្រីនោះ ដែលមានឈ្មោះ Jennisa Muangjam អាយុ ២៣ ឆ្នាំ ជាមួយនឹងភស្តុតាងដែលបង្ហាញពីតួនាទីរបស់នាង ធ្វើការនៅក្នុងមជ្ឈមណ្ឌល Call Center។ ព័ត៌មានបង្ហាញថា នាងគឺជាមិត្តស្រីរបស់មនុស្សសំខាន់ម្នាក់ នៅក្នុងមជ្ឈមណ្ឌល Call Center។ Jennisa ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២ ដែលធ្វើឡើងតាមដីកាចាប់ខ្លួន ពីបទចោទប្រកាន់ពាក់ព័ន្ធនឹងការក្លែងបន្លំ និងករណីជាច្រើនទៀត។ ស្ត្រីជាជនសង្ស័យរូបនេះ មានចំណែកក្នុងក្រុមឧក្រិដ្ឋកម្មអន្តរជាតិដែលមានអំពើក្លែងបន្លំដោយប្រើអ៊ីនធឺណិត។ នាងក៏ជាប់ពាក់ព័ន្ធនឹងការលាងលុយដែរ ហើយជាដីកាចាប់ខ្លួន១ក្នុងចំណោម ៥៨ ដីកា សម្រាប់ជាសមាជិកមជ្ឈមណ្ឌល Call Center។ បន្ទាប់ត្រូវបានចាប់ខ្លួន ជនសង្ស័យបានបដិសេធរាល់ការចោទប្រកាន់ ហើយមិននិយាយជាមួយប៉ូលិសទេ។ ប៉ុន្តែ ការស៊ើបអង្កេតបង្ហាញថា នាងកំពុងធ្វើដំណើរត្រឡប់មកកម្ពុជាវិញ។ ស្ត្រីរូបនេះធ្វើការក្រៅផ្ទះ មានន័យថា នាងមិននិយាយផ្ទាល់ជាមួយជនរងគ្រោះដែលត្រូវគេបោកប្រាស់នោះទេ។ នាងក៏ជាមិត្តស្រីកូនប្រុសថៅកែរបស់នាងផងដែរ។ ទាក់ទងរឿងនេះ នោះបានបង្ហាញថា នាងមិនមែនគ្រាន់តែជាជនរងគ្រោះម្នាក់នោះទេ ដែលត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងមជ្ឈមណ្ឌល Call Center។

តែទោះជាយ៉ាងណា ប៉ូលីសនៅខេត្ត Samut Prakan បានចេញដីកាចាប់ខ្លួន ហើយបញ្ជាក់ថា មានភស្តុតាងរឹងមាំប្រឆាំងនឹងស្ត្រីនោះ។ ព្រោះមានជនរងគ្រោះបានផ្ដល់ព័ត៌មានដល់មន្ត្រីដែលបង្ហាញថា ស្ត្រីរូបនេះកំពុងជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការហៅទូរស័ព្ទ។ រីឯអ្នកផ្សេងទៀតក៏បានបង្ហាញភស្តុតាងនៃការទំនាក់ទំនងតាមអ៊ីនធឺណិតជាមួយជនសង្ស័យផងដែរ។ ក្រុមឆបោកតាមទូរស័ព្ទ(Call Center) ត្រូវបានដឹងថា នៅតែបន្តកើតមាន និងរីកចម្រើនក្នុងប្រទេសកម្ពុជា។ ពួកគេតែងតែផ្លាស់ប្ដូរយុទ្ធសាស្ត្រ ឬផ្លាស់ទី នៅពេលដែលព័ត៌មានអំពីទីតាំង ឬព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ត្រូវបានលេចធ្លាយ។ ជនជាតិថៃជាច្រើននាក់ ដែលទៅធ្វើការនៅមជ្ឈមណ្ឌល (ប៉ូលីសនៅខេត្ត Samut Prakan បានចេញដីកាចាប់ខ្លួន ហើយបញ្ជាក់ថា ភស្តុតាងរឹងមាំប្រឆាំងនឹងស្ត្រីនោះ។ ជនរងគ្រោះបានផ្ដល់ព័ត៌មានដល់មន្ត្រីដែលបង្ហាញថាស្ត្រីរូបនេះកំពុងជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការហៅទូរស័ព្ទ។ អ្នកផ្សេងទៀត ដែលមានដីកាចាប់ខ្លួនដែលចេញជាឈ្មោះក៏បង្ហាញភស្តុតាង នៃការទំនាក់ទំនងតាមអ៊ីនធឺណិតជាមួយជនសង្ស័យផងដែរ។ ក្រុមក្មេងទំនើង Call Center នៅតែបន្តកើតមាន និងរីកចម្រើនក្នុងប្រទេសកម្ពុជា។ ពួកគេតែងតែផ្លាស់ប្ដូរយុទ្ធសាស្ត្រ ឬផ្លាស់ទីនៅពេលដែលព័ត៌មានអំពីទីតាំង ឬព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានបែកធ្លាយ។ ជនជាតិថៃជាច្រើននាក់ទៅធ្វើការនៅមជ្ឈមណ្ឌល Call Center ទាំងនោះក្នុងប្រទេសកម្ពុជា។ អ្នកខ្លះត្រូវបង្ខំ ហើយខ្លះទៀតទៅដោយស្ម័គ្រចិត្តដោយសង្ឃឹមរកលុយបាន៕ រក្សាសិទ្ធិដោយ៖ លឹម ហុង

## ចិនឃាត់ខ្លួនមនុស្ស ២០,០០០ នាក់ ដែលមានបំណងលួចទៅក្រៅប្រទេសដោយខុសច្បាប់ ដើម្បីប្រព្រឹត្តការក្លែងបន្លំទូរគមនាគមន៍ និងតាមអ៊ីនធឺណិត

https://www.khmertimeskh.com/501144447/p=1144447 Khmer Times September 4, 2022

ដោយសារការបោកប្រាស់តាមទូរគមនាគមន៍ឆ្លងព្រំដែន និងតាមអ៊ីនធឺណិតនៅតែជាបញ្ហា សមាជិកសភាចិនកំពុងអំពាវនាវឱ្យពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព ដោយបង្កើតសេចក្តីព្រាងច្បាប់ដោះស្រាយបញ្ហានេះឱ្យកាន់តែជាក់លាក់។

លោក Wang Jiaocheng សមាជិកម្នាក់នៃគណៈកម្មការអចិន្ត្រៃយ៍នៃសភាប្រជាជាតិដែលជាអង្គនីតិប្បញ្ញត្តិកំពូលរបស់ប្រទេសចិន បានមានប្រសាសន៍ថា "វាចាំបាច់ណាស់ក្នុងការបញ្ជាក់ពីរបៀបដែលអាជ្ញាធរ ដូចជាក្រសួងសន្តិសុខសាធារណៈ និងក្រសួងការបរទេសអាចរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងការបោកប្រាស់តាមទូរគមនាគមន៍ និងតាមអ៊ីនធឺណិត ដើម្បីធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងរួមគ្នាកាន់តែមានការអនុវត្តជាក់ស្តែង" ។ លោកបានចូលរួមជាមួយសមាជិកសភាជាតិដទៃទៀតក្នុងការពិនិត្យសេចក្តីព្រាងច្បាប់នេះកាលពីថ្ងៃពុធ។ សេចក្តីព្រាងច្បាប់នេះត្រូវបានដាក់ជូនសម្រាប់ការពិនិត្យជាលើកទីបីទៅកាន់សម័យប្រជុំបន្តនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រជាជាតិ នៅថ្ងៃអង្គារ។ នៅក្នុងប្រទេសចិន សេចក្តីព្រាងច្បាប់ជាទូទៅនឹងក្លាយទៅជាច្បាប់មួយ បន្ទាប់ពីវាត្រូវបានពិនិត្យចំនួនបីលើក។ សេចក្តីព្រាងច្បាប់នេះចែងថា ទីភ្នាក់ងាររដ្ឋាភិបាលចិនគួរតែបង្កើនកិច្ចសហប្រតិបត្តិការផ្នែកតុលាការជាមួយប្រទេស និងតំបន់ពាក់ព័ន្ធ ដោយបង្កើតយន្តការដ៏មានប្រសិទ្ធភាពដើម្បីរួមគ្នាលើកកម្ពស់ការប្រយុទ្ធប្រឆាំងនឹងការបោកប្រាស់តាមទូរគមនាគមន៍និងតាមអ៊ីនធឺណិត។

លោក Wang បានឯកភាពក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ "ដោយសារតែអ្នកបោកប្រាស់ជាច្រើនមកពីប្រទេសផ្សេងទៀត រួមទាំងហ្វីលីពីន កម្ពុជា និងតួកគី ត្រូវបានគេរកឃើញថាបានបោកប្រាស់ប្រជាជនចិន"។ ប៉ុន្តែបទប្បញ្ញត្តិនេះគឺមានលក្ខណៈទូទៅពេក ដែលមានន័យថា វានឹងមិនដើរតួនាទីខ្លាំងក្នុងកិច្ចសហប្រតិបត្តិការនាពេលអនាគតទេ ខណៈលោកបានអំពាវនាវឱ្យសភាជាន់ខ្ពស់បញ្ជាក់បន្ថែមនូវភារកិច្ចរបស់នាយកដ្ឋានរដ្ឋាភិបាលនៅក្នុងសេចក្តីព្រាងច្បាប់នេះ។ លោកបានស្នើថា ជាឧទាហរណ៍ "វានឹងជាការប្រសើរក្នុងការនិយាយនៅក្នុងសេចក្តីព្រាងច្បាប់ថា មន្ត្រីនគរបាល និងអ្នកដែលធ្វើការឱ្យក្រសួងការបរទេសគួរតែរៀបចំយន្តការការងារឱ្យទាន់ពេលវេលាជាមួយប្រទេស និងតំបន់ពាក់ព័ន្ធ ដោយបង្កើត និងកែលម្អគោលនយោបាយជំនួយទៅវិញទៅមក និងវិធានការណ៍ក្នុងការអនុវត្តច្បាប់» ។

លោក Li Wei សមាជិកម្នាក់ទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍សភាប្រជាជាតិ បានលើកឡើងពីសារៈសំខាន់នៃការធ្វើការជាមួយប្រទេសផ្សេងទៀត ដើម្បីដោះស្រាយការបោកប្រាស់ ដោយបានបន្ថែមថា "កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិគួរតែត្រូវបានបន្ថែមនៅក្នុងសេចក្តីព្រាងច្បាប់នេះផងដែរ" ។

បន្ថែមពីលើភ្នាក់ងាររដ្ឋាភិបាល លោក Chen Fuli ដែលជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍សភាប្រជាជាតិ បានមានប្រសាសន៍ថា ព្រះរាជអាជ្ញា និងតុលាការគួរតែត្រូវបានបញ្ចូលទៅក្នុងក្រុមសហប្រតិបត្តិការអន្តរជាតិប្រឆាំងនឹងការបោកប្រាស់។ ប្រទេសចិនបានបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងនឹងការបោកប្រាស់តាមទូរគមនាគមន៍ និងតាមអ៊ីនធឺណិតក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ជាពិសេសករណីឆ្លងព្រំដែន។ ក្រសួងសន្តិសុខសាធារណៈបាននិយាយកាលពីខែមិថុនាថា នៅមានក្រុមឧក្រិដ្ឋជនមួយចំនួនធំនៅក្នុងប្រទេសកម្ពុជា ហ្វីលីពីន អេមីរ៉ាត់អារ៉ាប់រួម ភាគខាងជើងមីយ៉ាន់ម៉ា តួគី និងប្រទេស និងតំបន់ផ្សេងទៀត កំពុងប្រព្រឹត្តការបោកប្រាស់ សំដៅលើប្រជាជនចិន។ ក្រសួងបានបន្ថែមថា មនុស្សប្រហែល ២០,០០០ នាក់ ដែលមានបំណងលួចទៅក្រៅប្រទេសដោយខុស

ច្បាប់ ដើម្បីធ្វើសកម្មភាពបោកប្រាស់តាមទូរគមនាគមន៍ និងតាមអ៊ីនធឺណិត ត្រូវបានបញ្ឈប់ដោយនគរបាលចិន ចាប់ពីខែឧសភាដល់ខែតុលាឆ្នាំមុន។ *China Daily*

## ជនរងគ្រោះវៀតណាមចំនួន ៨៩នាក់ ដែលត្រូវបានគេឆបោកពីការទទួលបានការងារស្រួលប្រាក់ខែខ្ពស់ ត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីកម្ពុជា

https://www.khmertimeskh.com/501144454//?p=1144454 Khmer Times September 4, 2022

ក្រសួងការបរទេសវៀតណាមបាននិយាយថា ជនជាតិវៀតណាមចំនួន ៨៩ នាក់ត្រូវបានជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ពីប្រទេសកម្ពុជា បន្ទាប់ពីត្រូវបានគេបោកបញ្ឆោតឱ្យទទួលយក "ការងារងាយស្រួលដែលមានប្រាក់ខែខ្ពស់" ដោយក្រុមជួញដូរមនុស្ស។ ក្រសួងបានរាយការណ៍ថា ក្នុងចំណោមបុគ្គលដែលត្រូវបានជួយសង្គ្រោះមាន ៦៣នាក់ បានចូលប្រទេសវៀតណាមកាលពីថ្ងៃទី ២៩ ខែសីហា តាមរយៈប៉ុស្តិ៍ការពារព្រំដែន Ha Tien ក្នុងខេត្ត Kien Giang ភាគនិរតីនៃប្រទេសវៀតណាម ដោយសារកិច្ចសហប្រតិបត្តិការរវាងអគ្គកុងស៊ុលវៀតណាមប្រចាំក្រុងព្រះសីហនុ និងអាជ្ញាធរពាក់ព័ន្ធកម្ពុជា។ ក្រសួងបាននិយាយថា បីថ្ងៃក្រោយមក ក្នុងកិច្ចខិតខំប្រឹងប្រែងចុងក្រោយរបស់ខ្លួនក្នុងការជួយសង្គ្រោះជនរងគ្រោះដោយការជួញដូរមនុស្សពីប្រទេសកម្ពុជា ស្ថានទូតវៀតណាមនៅទីក្រុងភ្នំពេញបានធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋវៀតណាមចំនួន ២៦ នាក់បន្ថែមទៀតតាមរយៈច្រកព្រំដែន Tinh Bien ក្នុងខេត្ត An Giang របស់វៀតណាម។

បុគ្គលទាំងនេះរួមមានជនជាតិវៀតណាម ១១នាក់ ដែលត្រូវបានជួយសង្គ្រោះពីកាស៊ីណូ Rich World ដែលមានមូលដ្ឋាននៅខេត្តកណ្តាល ជាទីដែលជនជាតិវៀតណាមចំនួន ៤២នាក់ បានរត់ចេញ និងព្យាយាមហែលឆ្លងទន្លេ Binh Di ចូលទៅក្នុងខេត្ត An Giang កាលពីថ្ងៃទី ១៨ ខែសីហា។ ក្នុងចំណោមអ្នករត់គេចខ្លួនទាំងនេះ ៤០នាក់បានទៅដល់ប្រទេសវៀតណាម ម្នាក់បានស្លាប់ក្នុងអំឡុងពេលឆ្លងទន្លេ ហើយអ្នកដែលនៅសល់ត្រូវបានចាប់ខ្លួនដោយឆ្មាំកាស៊ីណូ ទោះបីជាយ៉ាងណា ក្រោយមកគាត់ត្រូវបានជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍។ ដូច្នេះ ជនជាតិវៀតណាមសរុបចំនួន ៨៩នាក់ ត្រូវបានជួយសង្គ្រោះ និងនាំយកពីកម្ពុជាមកប្រទេសវិញក្នុងរយៈពេលមួយសប្តាហ៍កន្លងមកនេះ។

ក្រសួងបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយកាលពីថ្ងៃព្រហស្បតិ៍ថា "ភ្នាក់ងារតំណាងវៀតណាមនៅកម្ពុជាកំពុងផ្ទៀងផ្ទាត់អត្តសញ្ញាណពលរដ្ឋវៀតណាមផ្សេងទៀត ដែលត្រូវបានជួយសង្គ្រោះដោយអាជ្ញាធរកម្ពុជា ប៉ុន្តែមិនមានឯកសារអត្តសញ្ញាណផ្ទាល់ខ្លួន ដើម្បីធានាថាបុគ្គលទាំងនេះត្រូវបានធ្វើមាតុភូមិនិវត្តន៍ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន" ។ តាមរយៈការសហការជាមួយអាជ្ញាធរកម្ពុជា ទីភ្នាក់ងារនេះបានធ្វើមាតុភូមិនិវត្តន៍ប្រជាពលរដ្ឋជាង ៦០០ នាក់ មកទល់ពេលនេះ ដែលត្រូវបានបោកបញ្ឆោតដោយក្រុមជួញដូរមនុស្សឱ្យមកធ្វើការក្នុងប្រទេសកម្ពុជាក្នុងស្ថានភាពវេទនា។

លោកវរសេនីយ៍ទោ Khong Ngoc Oanh ពីនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃក្រសួងសន្តិសុខសាធារណៈ បានប្រាប់កាសែត Tuoi Tre (យុវជន) ថា ជនជាតិវៀតណាមរាប់ពាន់នាក់ប្រហែលជាត្រូវបានរត់ពន្ធចូលមកកម្ពុជាក្នុងការបោកប្រាស់បែបនេះ។ លោក Oanh បាននិយាយថា ជនជាតិវៀតណាមដែលត្រូវបានជួយសង្គ្រោះទាំងអស់បានចូលរួមក្នុងការងារខុសច្បាប់ ឬក្លាយជាជនរងគ្រោះនៃពលកម្មដោយបង្ខំ ឬការកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយលោកបន្ថែមថា វាមានការលំបាកសម្រាប់អាជ្ញាធរក្នុងការផ្ទៀងផ្ទាត់ករណី ការពារ និងសង្គ្រោះជនរងគ្រោះទាំងនោះ។

ក្រសួងការបរទេសបាននិយាយថា ខ្លួន និងភ្នាក់ងារតំណាងវៀតណាមផ្សេងទៀតនៅក្នុងប្រទេសកម្ពុជានឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីកំណត់អត្តសញ្ញាណ ជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ពលករវៀតណាមដែលត្រូវបានបោកបញ្ឆោតចូលមកកម្ពុជាដើម្បីធ្វើការជាកម្មករខុសច្បាប់ ឬដោយបង្ខំ។ យោងតាមក្រសួងបានឲ្យដឹងថា មនុស្សដែលត្រូវបានគេបោកប្រាស់និងបញ្ជូនមកប្រទេសកម្ពុជាក្នុងករណីបោកប្រាស់ការងារបែបនេះមកពីប្រទេសជាច្រើនផ្សេងគ្នានេះ។ ក្រសួងបញ្ជាក់ថា អាជ្ញាធរកម្ពុជាបានបើកការចុះត្រួតពិនិត្យ និងឆ្មក់ចូលជាច្រើនកន្លែងលើគ្រឹះស្ថានដែលជួលពលករបរទេស ដើម្បីជួយសង្គ្រោះជនរងគ្រោះពីការជួញដូរមនុស្ស ខណៈដែលប្រទេសពាក់ព័ន្ធបាននិងកំពុងព្យាយាមបង្ក្រាបសកម្មភាពដែលទាក់ទាញ និងបញ្ជូនមនុស្សមកកម្ពុជាដោយការឆ្លងព្រំដែនខុសច្បាប់។ *Tuoi Tre News*

## ជនបរទេសត្រូវបានល្បួងដោយសន្យាអោយការងារដែលមានប្រាក់ខែខ្ពស់ ប៉ុន្តែការជួញដូរសេរីភាពហាក់ដូចជាមិនមាននោះទេ

https://www.khmertimeskh.com/501144534//?p=114453 Khmer Times September 4, 2022

អាជ្ញាធរកម្ពុជាបានចាប់ខ្លួនជនសង្ស័យចំនួន ៦០ នាក់ និងបានជួយសង្គ្រោះជនរងគ្រោះចំនួន ៨៦៥ នាក់ពីក្រុមជួញដូរមនុស្សដែលជាជនបរទេស។ កាលពីសប្តាហ៍មុន បុរសជនជាតិចិន៩នាក់ និងបុរសខ្មែរ២នាក់ ត្រូវបានចាប់ខ្លួនពីបទប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ការជួញដូរមនុស្ស ការបង្ខំឱ្យធ្វើការ និងលក់ស្ត្រីជាជនរងគ្រោះឱ្យអ្នកទិញផ្សេងៗគ្នា។ ក្រៅពីនេះ ជនជាតិវៀតណាម ៦០០នាក់ ក៏ត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញដែរ។ ប្រទេសថៃបានបញ្ជូនមនុស្សជិត ២,០០០នាក់ទៅប្រទេសវិញ ខណៈដែលប្រទេសឥណ្ឌូនេស៊ីបានបញ្ជូនជនជាតិរបស់ពួកគេជាង ២០០ នាក់ទៅប្រទេសវិញ ហើយការបង្ក្រាបយ៉ាងខ្លាំងក្លារបស់ពួកគេលើទីកន្លែងជ្រើសរើសបុគ្គលិកសម្រាប់ក្រុមអ្នកបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណេតបានជួយទប់ស្កាត់ជនជាតិរបស់ពួកគេជាង៦០០ នាក់មកកម្ពុជាតាមជើងហោះហើរដោយគិតថានឹងទទួលបានការងារដែលមានប្រាក់ខែច្រើន។ ការងារដែលមានប្រាក់ខែខ្ពស់ទាំងនេះ គ្មានអ្វីក្រៅពីការបោកប្រាស់ ឬការងារដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យា ការបោកប្រាស់តាមអ៊ីនធឺណិតដែលខុសច្បាប់នៅក្នុងប្រទេសកម្ពុជា។

នគរបាលហុងកុងបានចាប់ខ្លួនមនុស្សប្រុសស្រី៥នាក់ដែលត្រូវបានគេសង្ស័យថាជាសមាជិកសំខាន់នៃក្រុមជួញដូរមនុស្សនៅហុងកុងកាលពីថ្ងៃទី២៥ សីហា។ នៅក្នុងកិច្ចប្រជុំជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មកាលពីថ្ងៃទី២៦ ខែសីហា លេខាធិការសន្តិសុខលោក Chris Tang Ping-keung បានការពារការចោទប្រកាន់របស់អ្នកជំនាញដែលគិតថា កងកម្លាំងនគរបាលហុងកុងមិនបានសហការឲ្យបានជិតដល់ជាមួយអ្នកអនុវត្តច្បាប់កម្ពុជា ឬទប់ស្កាត់ការជួញដូរមនុស្សនៅហុងកុង។ លោក Tang បាននិយាយថា "ហុងកុងមិនដែលជាទីកន្លែងចាប់ផ្តើម ឬជាកន្លែងឆ្លងកាត់ ឬជាគោលដៅសម្រាប់ការជួញដូរមនុស្សនោះទេ។ យើងមានបទប្បញ្ញត្តិផ្លូវច្បាប់ជាង៥០ ផ្សេងៗគ្នា ដែលអាចដោះស្រាយស្ថានការណ៍ទាក់ទងនឹងការជួញដូរមនុស្ស»។ លោក Tang បានអះអាងថា ទីក្រុងហុងកុងមានប្រព័ន្ធដ៏រឹងមាំមួយ ដើម្បីត្រួតពិនិត្យរាល់ការជួញដូរមនុស្សនៅក្នុង ឬក្រៅទីក្រុង។ ជាការឆ្លើយតបទៅនឹងការសហការជាមួយនឹងការអនុវត្តច្បាប់នៅបរទេស លោក Tang បានឆ្លើយថា "តាមពិតទៅ យើងក៏មានកិច្ចសហប្រតិបត្តិការដ៏រឹងមាំជាមួយភ្នាក់ងារអនុវត្តច្បាប់នៅក្រៅប្រទេស ទាំងនៅលើមូលដ្ឋានទ្វេភាគី ឬតាមរយៈបណ្តាញនគរបាលអន្តរជាតិ ដើម្បីចាប់អ្នកដែលបង្កបទល្មើសឆ្លងដែន។"

ក្រុមឧក្រិដ្ឋកម្មទាំងនេះដែលជ្រៀតចូលប្រទេសកម្ពុជា វៀតណាម និងហ្វីលីពីន តែងតែចាប់ជំរិតជនរងគ្រោះរបស់ពួកគេ ហើយចាប់ពួកគេធ្វើជាចំណាប់ខ្មាំង មុនពេលធ្វើទារុណកម្មពួកគេដោយបង្ខំអោយធ្វើកិច្ចការខុស

ច្បាប់ ឬកេងប្រវ័ញ្ចផ្លូវភេទ។ ជនល្មើសទាំងនេះក៏ប្រមូលផលសរីរាង្គ និងលក់ផ្នែករាងកាយរបស់មនុស្សទៅឱ្យអ្នកមាន និងនៅលើទីផ្សារងងឹតផងដែរ។

កម្ពុជា និងថៃបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនីតិវិធីប្រតិបត្តិការស្តង់ដារ (SOPs) ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស។ កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃកម្ពុជា និងនិងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) លោកស្រី ជូ ប៊ុនអេង និងលោកស្រី Ramrung Worawat អនុលេខាអចិន្ត្រៃយ៍នៃក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សរបស់ប្រទេសថៃ នៅចុងបញ្ចប់នៃកិច្ចប្រជុំនៅទីក្រុងបាងកក ប្រទេសថៃ។ សេចក្តីថ្លែងការណ៍បាននិយាយថា កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងដោយអង្គការអន្តរជាតិសម្រាប់ការធ្វើចំណាកស្រុក (IOM) ដោយបន្ថែមថា SOPs នឹងធ្វើជាគោលការណ៍ណែនាំសម្រាប់កិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធរវាងប្រទេសទាំងពីរក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ សេចក្តីថ្លែងការណ៍បានបន្តថា "ការពិភាក្សាដំណើរការបានយ៉ាងល្អ ដោយមានគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះ ហើយភាគីទាំងពីរបានឈានដល់ការចុះកិច្ចព្រមព្រៀងស្តីពី SOPs ដោយមានលោកស្រី ជូ ប៊ុនអេង តំណាងឱ្យភាគីកម្ពុជា និងលោកស្រី Ramrung Worawat តំណាងឱ្យភាគីថៃ" ។

រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី លោកស្រី Retno Marsudi ក៏បានជួបជាមួយអគ្គស្នងការនគរបាលជាតិកម្ពុជា នាយឧត្តមសេនីយ៍ នេត សាវឿន នៅរាជធានីភ្នំពេញ នៅថ្ងៃទី២ ខែសីហា ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ការជួញដូរមនុស្ស។ នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសឥណ្ឌូណេស៊ីនៅថ្ងៃដដែលនោះ លោកស្រី Marsudi បានសង្កត់ធ្ងន់ថា កិច្ចសហប្រតិបត្តិការរវាងប្រទេសឥណ្ឌូនេស៊ី និងកម្ពុជា ក្នុងការទប់ស្កាត់ការជួញដូរមនុស្សត្រូវតែពង្រឹងអោយបានកាន់តែច្រើន។ ក្នុងជំនួបនោះ មន្ត្រីទាំងពីរក៏បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ និងវិធានការទប់ស្កាត់ករណីបែបនេះមិនឱ្យកើតឡើងវិញម្តងទៀត។ ពួកគេក៏បានឯកភាពថា ក្រុមបច្ចេកទេសនៃកងកម្លាំងនគរបាលនៃប្រទេសទាំងពីរនឹងបើកកិច្ចប្រជុំនាពេលឆាប់ៗនេះ ដើម្បីពិភាក្សាលើបញ្ហាជាច្រើន រួមទាំងកិច្ចសហប្រតិបត្តិការក្នុងការស៊ើបអង្កេតរួមគ្នា ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MoU) រវាងប្រទេសទាំងពីរស្តីពីកម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្សនៃប្រទេសទាំងពីរ។

ក្នុងពេលជាមួយគ្នានេះ កងកម្លាំងនគរបាលហុងកុង បាននិយាយថា ខ្លួនបានទទួលសំណើសង្គ្រោះចំនួន ៣៦ មកទល់ពេលនេះ។ ក្នុងចំណោម៣៦ករណី មាន៣២នាក់ជាបុរស និង៤នាក់ជាស្ត្រីអាយុចន្លោះពី១៩ឆ្នាំដល់ ៥០ឆ្នាំ ។ កាលពីថ្ងៃទី២២ ខែសីហា នគរបាលហុងកុងគ្រាន់តែបញ្ជាក់អំពីសុវត្ថិភាព និងកន្លែងរបស់ជនរងគ្រោះ ២២ នាក់ប៉ុណ្ណោះ ប៉ុន្តែសង្ស័យថាពួកគេស្ថិតនៅក្នុងការបង្ខាំងទុក។ អ្នករួចផុតពីការឆបោក១១នាក់បានត្រឡប់ទៅហុងកុងវិញដោយគ្មានគ្រោះថ្នាក់។ ទោះបីជាយ៉ាងណា អាជ្ញាធរបានបាត់បង់ទំនាក់ទំនងជាមួយជនរងគ្រោះចំនួន ៩នាក់ទៀត។

អ្នកសារព័ត៌មានសង្គមជាន់ខ្ពស់របស់តៃវ៉ាន់ Dai Zhiyang បានធ្វើបទសម្ភាសន៍ផ្ទាល់មុខជាមួយ Info Times ដើម្បីបង្ហាញពីអាថ៌កំបាំងដ៏ខ្មៅងងឹតមួយចំនួនរបស់កន្លែងបោកប្រាស់ទាំងនេះនៅកម្ពុជា។ គាត់ក៏បានវិភាគពីរបៀបនៃការជួញដូរមនុស្ស និងការប្រមូលផលសរីរាង្គដែលកំពុងរីករាលដាល។ យ៉ាងណាក៏ដោយ កាសែតខ្មែរថាមស៍ ដែលបានទម្លាយរឿងរ៉ាវនៃការជួញដូរមនុស្ស និងល្បែងស៊ីសងតាមប្រព័ន្ធអ៊ីនធឺណេតកាលពីជាងមួយឆ្នាំមុននោះ មិនបានរកឃើញភស្តុតាងជាក់ស្តែងណាមួយដែលបង្ហាញថាការប្រមូលឈាម ឬសរីរាង្គកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជា ទោះបីជាមានការចោទប្រកាន់ម្តងហើយម្តងទៀតក៏ដោយ។ រឿងដំបូងដែលត្រូវបានគេ

ទម្លាយនោះ គឺស្ត្រីជនជាតិថៃម្នាក់ដែលអះអាងថានាងនឹងត្រូវបានគេ វះកាត់យកសរីរាង្គទៅលក់ ហើយត្រូវបាន កាសែតខ្មែរថាមស៍លាតត្រដាង។ ក្នុងខែមីនា នគរបាលថៃ បានបញ្ជាក់ថា ការចោទប្រកាន់របស់ស្ត្រីនោះមិនពិត ហើយបានចាប់នាងដាក់គុក។ គេបានដឹងផងដែរថា ការប្រមូលផលសរីរាង្គអាចនឹងធ្វើឡើងនៅក្នុងប្រទេសអាស៊ាន មួយទៀត ដែលជាប់ពាក់ព័ន្ធនឹងក្រុមជួញដូរមនុស្ស។

ឧក្រិដ្ឋជនកំពុងផ្លាស់ប្តូរទម្លាប់បន្ទាប់ពីប្រព័ន្ធផ្សព្វផ្សាយបានលាតត្រដាងព័ត៌មានអំពីការជួញដូរជនជាតិតៃវ៉ាន់ និងហុងកុងរបស់ក្រុមឧក្រិដ្ឋកម្មនៅកម្ពុជា ក្រុមឧក្រិដ្ឋកម្មបានផ្លាស់ប្តូរយុទ្ធសាស្ត្រដើម្បីព្យាយាមគេចចេញពីការតាមដាន។ សមាជិកអង្គការប្រឆាំងការបោកប្រាស់អន្តរជាតិ (GASO) បាននិយាយថា ប្រទេសថៃបានក្លាយជាកន្លែងសម្រាប់ឧក្រិដ្ឋជនធ្វើការជួញដូរមនុស្ស និងប្រមូលផលសរីរាង្គដែលត្រូវបានគេចោទប្រកាន់។ ជាធម្មតា ជនរងគ្រោះត្រូវបានបញ្ជូនទៅក្នុងអគារដូចជាពន្ធនាគារ និងត្រូវបានបង្ខាំងទុក។ លួសបន្លាអគ្គិសនីត្រូវបានព័ទ្ធជុំវិញគ្រប់ជញ្ជាំង ដើម្បីកុំអោយរត់ចេញរួច។

Jason សមាជិក GASO បាននិយាយថា ក្រុមឧក្រិដ្ឋកម្មភាគច្រើនត្រូវបានរៀបចំឡើងដោយជនជាតិចិន។ ឧក្រិដ្ឋជនបានរត់ពន្ធជនរងគ្រោះរបស់ពួកគេពីខេត្តយូណានរហូតដល់ជំងឺរាតត្បាតបានកើតឡើង។ គោលនយោបាយ Zero-COVID របស់ចិនមានន័យថា គ្មាននរណាម្នាក់អាចចូល ឬចេញពីប្រទេសបានទេ។ ឧក្រិដ្ឋជនមិនអាចស្វែងរកជនរងគ្រោះរបស់ពួកគេនៅក្នុងប្រទេសចិនបានទៀតទេ។ ដូច្នេះ ពួកគេបានផ្លាស់ប្តូរកន្លែងដែលពួកគេបានរកឃើញជនរងគ្រោះបន្ទាប់របស់ពួកគេ៖ តៃវ៉ាន់ ម៉ាឡេស៊ី ហុងកុង ឥណ្ឌូនេស៊ី ឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដែស និងហ្វីលីពីន។

តើអ្វីជាការជួញដូរមនុស្ស? យោងតាម United Against Human Trafficking ជនរងគ្រោះនៃការជួញដូរមនុស្សត្រូវទទួលរងនូវការបង្ខំ ការក្លែងបន្លំ ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និង/ឬពលកម្មដោយបង្ខំ។ មានជនរងគ្រោះនៃការជួញដូរមនុស្សប្រហែល ២៤.៩ លាននាក់នៅទូទាំងពិភពលោករហូតមកដល់បច្ចុប្បន្ន។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២២ មក អាជ្ញាធរតៃវ៉ាន់បានទទួលសំណើសុំជួយពីជនរងគ្រោះនៃការចាប់ជំរិត និងការជួញដូរមនុស្ស។ កន្លែងជួញដូរមនុស្សមួយបានធ្វើអាជីវកម្មល្បែងស៊ីសង និងបានលួងជនជាតិតៃវ៉ាន់ ៥នាក់មកកម្ពុជា មុននឹងត្រូវបង្ខំឲ្យធ្វើការនៅមជ្ឈមណ្ឌលហៅទូរស័ព្ទបោករបស់ខ្លួន។ ខណៈដែលតៃវ៉ាន់បានធ្វើសកម្មភាពយ៉ាងសកម្មក្នុងការជួយសង្គ្រោះពលរដ្ឋរបស់ខ្លួនពីឧក្រិដ្ឋជននៅកម្ពុជា នគរបាលហុងកុងកំពុងចាត់វិធានការមួយផ្សេងទៀត។ តំណាងការិយាល័យសន្តិសុខបាននិយាយនៅក្នុងសន្និសីទសារព័ត៌មានមួយថា "យើងលើកទឹកចិត្តជនរងគ្រោះដែលត្រូវបានចាប់ពង្រត់ឱ្យស្វែងរកជំនួយតាមរយៈកម្មវិធី WhatsApp របស់យើង ឬដោយការបំពេញទម្រង់បែបបទ" ។ សាធារណៈជនបានសួរថា "តើជនរងគ្រោះដែលត្រូវបានចាប់ជំរិតនឹងមានពេលវេលាដើម្បីបំពេញទម្រង់ ឬទាញយកកម្មវិធីដោយរបៀបណា ដើម្បីឱ្យនរណាម្នាក់អាចសង្គ្រោះពួកគេបាន?"

អ្នកស្រី Anna ក៏មិនពេញចិត្តចំពោះវិធានការរបស់អាជ្ញាធរហុងកុងដែរថា « បំពេញទម្រង់បែបបទយ៉ាងមេច? គ្មានផ្លូវទេ។ ជនរងគ្រោះអាចនឹងស្លាប់ ប្រសិនបើក្រុមឧក្រិដ្ឋជនរកឃើញថាពួកគេព្យាយាមរត់គេចខ្លួន ឬសុំជំនួយ»។ អ្នកស្រី Anna ក៏បាននិយាយផងដែរថា GASO បានព្យាយាមទាក់ទងប៉ូលីសហុងកុងអស់រយៈពេលប្រាំមួយខែ ប៉ុន្តែមិនមានសកម្មភាពណាមួយត្រូវបានធ្វើឡើងរហូតមកដល់ពេលថ្មីៗនេះ។

យោងតាមមន្ត្រីអនុវត្តច្បាប់បរទេសដែលសុំមិនបញ្ចេញឈ្មោះ ប៉ុន្តែបានផ្តល់ព័ត៌មានជាក់លាក់ដល់ ខ្មែរថាមស៍ បាននិយាយថា ចំណុចសំខាន់មួយគឺត្រូវបញ្ឈប់ការជ្រើសរើសជនជាតិនៃបណ្តាប្រទេសកុំអោយធ្លាក់ទៅក្នុងការបោកប្រាស់ទាំងនេះ។

"ឥណ្ឌូនេស៊ី តៃវ៉ាន់ ហុងកុង និងថៃ គឺជាគំរូដ៏ល្អនៃការព្យាយាមបំបាត់បញ្ហាឫសគល់របស់វា។ វាប្រហែលជាមិនមានប្រសិទ្ធភាព ១០០ ភាគរយទេ ប៉ុន្តែអាចនិយាយបានថា យ៉ាងហោចណាស់៥០ ភាគរយទទួលបានជោគជ័យក្នុងការកាត់បន្ថយចំនួនមនុស្សដែលត្រូវបានបោកបញ្ឆោតឱ្យទទួលយកការងារនេះ ដោយសន្យាផ្តល់ការងារដែលមានប្រាក់ខែខ្ពស់។ *ដកស្រង់ពី The Epoch Times និងការស៊ើបអង្កេតដោយ ការសែតខ្មែរថាមស៍*

## ហ្វេសប៊ុកសម្តេចក្រឡាហោម ស ខេង ទទួលបានពាក្យបណ្តឹងចំនួន៩៩ ទាក់ទងនឹងការស្នើអន្តរាគមន៍លើករណីបង្ខាំង និងជួញដូរពលកម្ម

http://freshnewsasia.com/index.php/en/localnews/256046-2022-09- 2022-09-04 05:13pm

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា រហូតមកដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានទទួលពាក់បណ្តឹងសរុបចំនួន៩៩បណ្តឹង ហើយ តាមរយៈទំព័រហ្វេសប៊ុករបស់សម្តេច។ លោកបានបញ្ជាក់ថា បណ្តឹងទាំង៩៩នោះ គឺពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ជួយសង្គ្រោះជនបរទេស ដែលត្រូវបានអះអាងថាបង្ខាំង និងជួញដូរកម្លាំងពលកម្ម នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីសម្តេចបានអំពាវនាវឱ្យភាគីទាំងអស់ រួមទាំងបរទេសផងដែរ សហការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងករណីទាំងនេះ។

សូមបញ្ជាក់ថា រយៈពេល៨ខែ ក្នុងឆ្នាំ២០២២នេះ ពោលពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជា បានបើកប្រតិបត្តិការចុះត្រួតពិនិត្យលើបណ្តឹងចំនួន១០៤ករណី ដោយសង្គ្រោះមនុស្ស៩៦៨នាក់ និងឃាត់ខ្លួនជនសង្ស័យ៨២នាក់ ប៉ុន្តែក្នុងនោះមានតែ១៩ករណីប៉ុណ្ណោះ ដែលជាករណីបង្ខាំង និងជំរិតទារប្រាក់។ ឯករណីក្រៅពីនោះ សមត្ថកិច្ចរកឃើញថា ជាករណីប្រឌិដ្ឋដោយសារវិវាទការងារ ទំនាស់កិច្ចសន្យា, ការរិតត្បិតសេរីភាព, ផ្លាស់ប្តូរកន្លែងធ្វើការងារផ្ទុយពីឆន្ទៈ, ជំពាក់ប្រាក់ក្រុមហ៊ុន ឬគេចវេសមិនសង, មិនពេញចិត្តស្ថានភាពរស់នៅ ស្ថានភាពការងារ និងសាច់ញាតិព្រួយបារម្ភ ហើយប្តឹងសមត្ថកិច្ចឱ្យតាមរកជាដើម។

ទោះជាយ៉ាងណា រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះផងដែរ៕

## សមត្ថកិច្ចការពារព្រំដែនកម្ពុជា ជួបប្រជុំគ្នាជាមួយសមត្ថកិច្ចការពារព្រំដែនថៃ រួមគ្នាទប់ស្កាត់បទល្មើសឆ្លងដែនដោយខុសច្បាប់

https://gdlf-kh.com/2022/09/04/2/ Noun Vanny បន្ទាយមានជ័យ

បន្ទាយមានជ័យ ៖ នៅថ្ងៃអាទិត្យ ៩ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០២២ សមត្ថកិច្ចការពារព្រំដែនកម្ពុជា សរុបចំនួន១៤នាក់ កងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៩១១ ចំនួន០៤នាក់ យោធាការពារព្រំដែនគោកចំនួន០៨នាក់ និងសមត្ថកិច្ចការពារព្រំដែនថៃ សរុបចំនួន០៧នាក់ នៅវេលាម៉ោង០៨និង៤០នាទីព្រឹក បានជួបប្រជុំគ្នា នៅទីបញ្ជាការដ្ឋានកងអនុសេនាតូចទី២ នៃកងអនុសេនាធំល្បាតទី២ ស្ថិតក្នុងភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ទល់មុខភូមិណងយ៉ាកែវ ឃុំ – ស្រុកឃោគស៊ូង ខេត្តស្រះកែវ ប្រទេសថៃ ។

តាមរបាយការណ៍របស់នគរបាលវរសេនាតូចការពារព្រំដែនលេខ៩១១ បង្ហាញឲ្យដឹងនៅថ្ងៃនេះថា ៖ ដោយអង្គភាពចាត់តាំងនៅព្រឹកថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០២២ កម្លាំងប៉ុស្តិ៍ការពារព្រំដែនរិទ្ធិសែននិងប៉ុស្តិ៍ការពារព្រំដែនថ្នល់បែក សរុប០៤នាក់ដឹកនាំដោយលោកវរសេនីយ៍ត្រី ពុត វុណ និងលោក វរសេនីយ៍ត្រី រាជ្យ ម៉ូ ជានាយប៉ុស្តិ៍ បានចូលរួមជាមួយយោធា កងការពារព្រំដែន៥០៣ ចំនួន០៨នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី អ៊ិន ថុល មេបញ្ជាការកងអនុសេនាធំល្បាតទី២ បានជួបប្រជុំពិភាក្សាជាមួយទាហ៊ានឈុតខ្មៅថៃកងអនុសេនាធំ១,២០២ ចំនួន០៧នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី សាន់យ៉ា គៀតធុំ មេបញ្ជាការ កងអនុសេនាធំ១,២០២ ។

របាយការណ៍បានបញ្ជាក់ថា ៖ ក្នុងជំនួបនេះ គឺដើម្បីបង្កើនរឹតចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ រួមគ្នាទប់ស្កាត់ការលួចឆ្លងដែនដោយខុសច្បាប់ ។ រួមគ្នាទប់ស្កាត់ការជួញដូរគ្រឿងញៀន ទំនិញគេចពន្ធ ចោរកម្មឆ្លងដែន ឧក្រិដ្ឋកម្មឆ្លងដែន និងទបល្មើសឆ្លងដែនផ្សេងៗទៀត រាល់ហេតុការណ៍កើតឡើងនៅតាមព្រំដែន ត្រូវផ្តល់ព័ត៌មានឲ្យគ្នាបានដឹងទៅវិញទៅមក ៕

## បញ្ជូនជនជាតិចិនម្នាក់ ទៅតុលាការ ពាក់ព័ន្ធករណីបង្ខាំងមនុស្សខុសច្បាប់

https://cen.com.kh/archives/524568.html Posted ByPen Srey NeatSeptember 5, 2022

ព្រះសីហនុ៖ កងរាជអាវុធហត្ថខេត្តព្រះសីហនុ នៅថ្ងៃទី៥ខែកញ្ញា បានបញ្ជូនជនជាតិចិនម្នាក់ ទៅតុលាការ ពាក់ព័ន្ធករណីប.ង្ខាំងមនុស្សខុសច្បាប់ ក្រោយពេល កម្លាំងមន្ទីស្រាវជ្រាវ និង បង្ក្រាបបទល្មើស កងរាជអាវុធហត្ថខេត្ត បានចុះស្រាវជ្រាវដល់ទីតាំងអគារចំនួន២ បានរកឃើញជនរងគ្រោះ ចំនួន ០៤នាក់ ក្នុងនោះជនជាតិម៉ាឡេស៊ី៣នាក់ និងជនជាតិចិនតៃវ៉ាន់ម្នាក់ ។ ដោយមានការសម្របសម្រួលនីតិវិធីពីព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ នៅវេលាម៉ោង១៤:៣០នាទីរសៀល ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២ កម្លាំងមន្ទីរស្រាវជ្រាវ និង បង្ក្រាបបទល្មើស កងរាជអាវុធហត្ថខេត្ត បានចុះស្រាវជ្រាវដល់ទីតាំងអគារលេខ ៨ និងអគារលេខ ១៣ ស្ថិតក្នុងភូមិ៦ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ពាក់ព័ន្ធករណីបង្ខាំងមនុស្សខុសច្បាប់ ដោយមានការសហការពីម្ចាស់ទីតាំង បានរកឃើញជនរងគ្រោះ ចំនួន ០៤នាក់ រួមមាន៖

១/ ឈ្មោះ LIM HUI GUAN ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិម៉ាឡេស៊ី

២/ ឈ្មោះ FONG CHUN HUI ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិម៉ាឡេស៊ី

៣/ ឈ្មោះ LIM KEE GUAN ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិម៉ាឡេស៊ី

៤/ ឈ្មោះ TSAI CHIH PING ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិចិនតៃវ៉ាន់

នៅវេលាម៉ោង១១:១០នាទី ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២២ សមត្ថកិច្ចជំនាញ បានឃាត់ខ្លួនជនសង្ស័យចំនួន ០១នាក់ ឈ្មោះ WONG ZHi YUAN ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិចិន នៅចំណុចអគារលេខ ១៣ (ខែប៉) ពាក់ព័ន្ធករណីធ្វើទារុណកម្ម តាមការចង្អុលបង្ហាញ ពីជនរងគ្រោះ ឈ្មោះ TSAI CHIH PING។ជំនាញបានដកហូតវត្ថុតាងដែកបំពង់ទីប ចំនួន ០១ ដើម។ បច្ចុប្បន្នកម្លាំងការិយាល័យជំនាញ កងរាជអាវុធហត្ថខេត្ត បានចាត់ការតាមនីតិវិធី៕រក្សាសិទ្ធិដោយ ៖ សុទ្ធលី

# ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២

## ជនរងគ្រោះម៉ាឡេស៊ីជិត ១៥០នាក់ដោយសារការឆបោកការងារត្រូវបានគេជឿថានៅកម្ពុជា

https://www.khmertimeskh.com/501145105//?p=1145105K hmer Times September 5, 2022

រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី លោក Datuk Seri Saifuddin Abdullah បាននិយាយថា ជនជាតិម៉ាឡេស៊ីសរុបចំនួន ១៤៨ នាក់ ដែលត្រូវបានគេជឿថា ជាជនរងគ្រោះនៃការឆបោកការងារ ត្រូវបានគេគិតថា នៅក្នុងប្រទេសកម្ពុជាគិតត្រឹមថ្ងៃសុក្រ (ថ្ងៃទី ២ ខែកញ្ញា) ។ ពួកគេស្ថិតក្នុងចំណោមជនរងគ្រោះ នៃការឆបោកការងាររបស់ជនជាតិម៉ាឡេស៊ីចំនួន ១៩៥ នាក់ដែលនៅបរទេស។ ក្រៅពីជនរងគ្រោះនៅប្រទេសកម្ពុជាចំនួន១៤៨នាក់ មាន២៣នាក់ត្រូវបានគេជឿថា នៅប្រទេសថៃ ២២នាក់នៅឡាវ និងមានតែពីរនាក់នៅមីយ៉ាន់ម៉ា។

លោក Saifuddin បាននិយាយថា ជនជាតិម៉ាឡេស៊ីសរុបចំនួន ៦៥នាក់ នៅក្នុងប្រទេសកម្ពុជា ១០នាក់នៅប្រទេសថៃ និងឡាវ និងពីរនាក់នៅមីយ៉ាន់ម៉ា ត្រូវបានជួយសង្គ្រោះដោយជោគជ័យ។ «ក្រសួងការបរទេស សូមណែអ្នកដែលរងគ្រោះពីការឆបោកការងារនៅក្រៅប្រទេស សូមមកដាក់ពាក្យបណ្តឹង និងរាយការណ៍ជូនសមត្ថកិច្ចដើម្បីចាត់វិធានការបន្ត។ រាល់របាយការណ៍ ឬឯកសារដែលទទួលបាននឹងត្រូវធ្វើដោយផ្ទាល់ទៅកាន់តំណាងម៉ាឡេស៊ីនៅក្នុងប្រទេសដែលពាក់ព័ន្ធ។ លោកបាននិយាយនៅក្នុងសន្និសីទកាសែត កាលពីថ្ងៃអាទិត្យនៅក្នុងក្រុង Kuantan រដ្ឋ Pahang ថា "សកម្មភាពតាមដាននឹងត្រូវបានអនុវត្តដោយសហការជាមួយអាជ្ញាធរនៃប្រទេសដែលពាក់ព័ន្ធ ស្របតាមនីតិវិធី និងច្បាប់នៃប្រទេសដែលពាក់ព័ន្ធនឹងការស៊ើបអង្កេត ចារកម្ម កិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះ ឯកសារពាក់ព័ន្ធ ដែលអាចត្រូវការពេលវេលាច្រើន"។

យោងតាមលោក Saifuddin អាជ្ញាធរមូលដ្ឋាននៃប្រទេសពាក់ព័ន្ធតែងតែផ្តល់កិច្ចសហការ និងជំនួយដើម្បីតាមរកជនជាតិម៉ាឡេស៊ីណាម្នាក់ដែលស្ថិតនៅក្នុងប្រទេសរបស់ពួកគេ។ លោកក៏បានណែនាំដល់ប្រជាជនម៉ាឡេស៊ីកុំឱ្យងាយចាញ់បោកគេ ហើយត្រូវប្រុងប្រយ័ត្នជានិច្ចចំពោះការផ្តល់ឱកាសការងារធ្វើការនៅបរទេស ក៏ដូចជាពិនិត្យមើលសុពលភាពនៃការផ្តល់ជូននេះជាមួយការិយាល័យតំណាងនៅក្នុងប្រទេសដែលពាក់ព័ន្ធ ឬនៅ Wisma Putra ។ លើសពីនេះ ពួកគេក៏ត្រូវបានណែនាំឲ្យសុំទិដ្ឋាការអោយបានត្រឹមត្រូវ (ទិដ្ឋាការការងារ) មុនពេលចាប់ផ្តើមការធ្វើដំណើរ ត្រូវប្រាកដថាលិខិតផ្តល់ជូន និងកិច្ចសន្យាការងារត្រូវបានយល់ និងវ៉ៃត្រាជាលាយលក្ខណ៍អក្សរ និងធ្វើដំណើរតាមផ្លូវច្បាប់។ លោកបានបន្ថែមថា "អ្នកដែលជារឿយៗក្លាយជាជនរងគ្រោះនៃការឆបោករួមមានក្មេងវ័យជំទង់ អាយុ ប្រហែល២០ ឆ្នាំ ដែលត្រូវបានសន្យាផ្តល់ជូនដូចជា ប្រាក់កម្រៃជាង ២០០០ ដុល្លារអាមេរិក ប្រាក់ឧបត្ថម្ភខ្ពស់ នឹងផ្តល់សម្ភារៈបរិក្ខារផ្សេងៗ រួមទាំងប្រាក់សម្រាប់វិស្សមកាលជាដើម។

លោក Saifuddin បាននិយាយថាជនរងគ្រោះអាចទាក់ទងអង្គភាពជំនួយកុងស៊ុលសម្រាប់ប្រជាជនម៉ាឡេស៊ីនៅក្រៅប្រទេសតាមរយៈ bkrm@kln.gov.my ហើយប្រជាពលរដ្ឋទាំងអស់នៅបរទេសត្រូវបានណែនាំឱ្យចុះឈ្មោះជាមួយបេសកកម្មម៉ាឡេស៊ីដែលនៅជិតបំផុតឬតាមរយៈគេហទំព័រhttps://ekonsular.kln.gov.my/login។ ទន្ទឹមនឹងនេះ ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Datuk Eldeen Husaini Mohd Hashim ត្រូវបានសារព័ត៌មានម៉ាឡេស៊ីដកស្រង់សម្តីថា "យើងបានជួយសង្គ្រោះមនុស្សជាច្រើន ប៉ុន្តែមនុស្សជាច្រើនមិនចង់ត្រឡប់ទៅម៉ាឡេស៊ីវិញទេ។ ខ្លះរត់ចេញពីផ្ទះ ខ្លះរត់គេចពីម្ចាស់បំណុល។

Datuk Eldeen បាននិយាយថា "ពេលខ្លះ ពួកគេមិនចង់ប្រាប់ការពិតដល់ឪពុកម្តាយរបស់ពួកគេទេ។ នៅពេលដែលឪពុកម្តាយមិនដឹងថាត្រូវធ្វើអ្វី ពួកគេបង្កើតរឿងដែលកូនរបស់ពួកគេត្រូវបានចាប់ពង្រត់ ហើយត្រូវបានបង្ខំឱ្យធ្វើការ ប៉ុន្តែនៅពេលដែលយើងទៅជួយពួកគេ ពួកគេបាននិយាយថា ពួកគេមិនចង់ត្រឡប់ទៅវិញទេ"។ បន្ទាប់ពីការវាយឆ្មក់លើកន្លែងក្រុមឆបោក អាជ្ញាធរកម្ពុជាបញ្ជូនជនជាតិម៉ាឡេស៊ីដែលត្រូវបានជួយសង្គ្រោះទៅ

កាន់បុស្តិ៍អន្តោប្រវេសន៍ ដើម្បីធ្វើការស៊ើបអង្កេត និងរៀបចំឯកសាររបស់ពួកគេ។ លោកបានបន្ថែមថា៖ «នៅពេលដែលរៀបចំឯកសាររួច ពួកគេនឹងត្រូវបញ្ជូនទៅស្ថានទូតសម្រាប់ដំណើរការបញ្ជូនទៅវិញ ដែលនៅពេលនោះយើងនឹងចេញវិញ្ញាបនបត្រសង្គ្រោះបន្ទាន់ និងអោយដំណឹងដល់នគរបាលរបស់យើង និង Wisma Putra»។

បញ្ហានៃការជួញដូរមនុស្សដោយសន្យាអោយការងារ ដែលបានប្រាក់ខែខ្ពស់ត្រូវបានកំរើកឡើងវិញជាថ្មីដូចព្យុះកំបុតត្បូងក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះ ដោយប្រព័ន្ធផ្សព្វផ្សាយបរទេសស្ទើរតែមិនឈប់ឈរពាយការណ៍អំពីរឿងនេះ ដូចជាហុងកុង តៃវ៉ាន់ ឥណ្ឌូណេស៊ី ហ្វីលីពីន និងម៉ាឡេស៊ី ក្នុងចំណោមប្រទេសដទៃទៀត។ អាជ្ញាធរត្រូវបានគេជឿថាកំពុងពិនិត្យនូវការកើនឡើងនៃការរាយការណ៍បែបនេះ ហើយជឿថាកំពុងមានជនខិលខូចមួយចំនួនព្យាយាមបំពុលប្រទេសកម្ពុជា ជាពិសេសនៅក្នុងស្ថានការណ៍នៃការបើកប្រទេសឡើងវិញ ដោយព្យាយាមជំរុញលំហូរនៃទេសចរណ៍ និងការរៀបចំសម្រាប់ការប្រកួតកីឡាស៊ីហ្គេមខែឧសភាឆ្នាំ២០២៣ និង ការបោះឆ្នោតថ្នាក់ជាតិនាខែកក្កដា។ *Malaysian Media/Khmer Times*

## ទូតម៉ាឡេស៊ី៖ ជនជាតិម៉ាឡេស៊ីមួយចំនួនបដិសេធការជួយសង្គ្រោះ ឬមិនចង់ចាកចេញពីកម្ពុជា

https://www.rfi.fr/km//20220905-ref=tgi ចុះផ្សាយនៅថ្ងៃ៖ 05/09/2022 - 08:08

ជនជាតិម៉ាឡេស៊ីច្រើនជាង ១០០នាក់ ដែលរងគ្រោះដោយក្រុមឆបោកការងារ នៅកម្ពុជានោះ ត្រូវបានជួយសង្គ្រោះដោយស្ថានទូតម៉ាឡេស៊ី ចាប់តាំងពីឆ្នាំ២០១៨មក។ នេះបើតាមការបញ្ជាក់ពីឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា និងត្រូវបានចុះផ្សាយ ដោយសារព័ត៌មានម៉ាឡេស៊ី កាលពីថ្ងៃទី០៤ ខែកញ្ញា។ ក៏មានជនជាតិម៉ាឡេស៊ីមួយចំនួនបដិសេធការជួយសង្គ្រោះ និងមិនចង់ចាកចេញពីកម្ពុជា។

ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Eldeen Husaini Mohd Hashim បានលើកឡើងថាជនជាតិម៉ាឡេស៊ីច្រើនជាង ១០០នាក់ ដែលរងគ្រោះដោយសារក្រុមឆបោក នៅកម្ពុជានោះ ត្រូវបានជួយសង្គ្រោះដោយស្ថានទូតម៉ាឡេស៊ី ចាប់តាំងពីឆ្នាំ២០១៨មក។ នេះបើតាមការចុះផ្សាយរបស់សារព័ត៌មាន The Star កាលនៅថ្ងៃទី០៤ ខែកញ្ញា។ ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីលើកឡើងថា ក៏មានជនជាតិម៉ាឡេស៊ីមួយចំនួនបានបដិសេធមិនទទួលយកការជួយសង្គ្រោះ ឬចាកចេញពីប្រទេសកម្ពុជាទៅម៉ាឡេស៊ីទេ ដោយសារពួកគេទាំងនោះបានរត់គេចពីផ្ទះ។ លោកបន្តថា ពួកគេទាំងនោះមិនចង់ប្រាប់គ្រួសារពីរឿងពិត ដែលពួកគេបានជួបទេ។ នៅពេលដែលឳពុកម្តាយរបស់ពួកគេមិនដឹងថាត្រូវធ្វើដូចម្តេច នោះក៏ឈានដល់ការប្រឌិតរឿងដែលថា កូនរបស់ពួកគាត់ត្រូវបានចាប់ពង្រត់ទៅធ្វើការ ប៉ុន្តែនៅពេលស្ថានទូតទៅជួយ ជនជាតិម៉ាឡេស៊ីទាំងនោះប្រាប់ថាមិនចង់ត្រឡប់ទៅវិញទេ។ នេះបើតាមលោក Eldeen។ លោកបានសង្កត់ធ្ងន់ថា ស្ថានទូតមិនអាចគ្រាន់តែបញ្ជូនជនជាតិម៉ាឡេស៊ីចេញភ្លាមៗ ក្រោយពីការជួយសង្គ្រោះនោះទេ ព្រោះមាននីតិវិធីដែលត្រូវអនុវត្ត។ អ្នកដែលបានបំពានច្បាប់អន្តោប្រវេសន៍កម្ពុជា តម្រូវឱ្យជាប់ទោស មុនពេលពួកគេអាចចាកចេញពីប្រទេស ប៉ុន្តែស្ថានទូតម៉ាឡេស៊ីនឹងធ្វើអន្តរាគមន៍នៅពេលករណីនេះកើតឡើង។ នេះបើតាមអគ្គរដ្ឋទូតម៉ាឡេស៊ី។

គិតពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២នេះ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា បានរកឃើញ និងជួយសង្គ្រោះជនបរទេសដែលប្រកាសថា ជនរងគ្រោះ ចំនួន ៨៧ករណី ស្មើនឹងប្រមាណ ៨៦៥នាក់ ព្រមទាំងបានកសាងសំណុំរឿងបញ្ជូនទៅតុលាការចំនួន ១៧ករណី ជនសង្ស័យសរុបចំនួន ៦០នាក់។ នេះបើតាមលិខិតមួយរបស់លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា កាលពីថ្ងៃទី២៦ ខែសីហា។ ក្រសួងមហាផ្ទៃកម្ពុជាក៏រកឃើញថា ពលរដ្ឋបរទេសទាំងនោះ មួយចំនួនធំត្រូវបានក្រុមឧក្រិដ្ឋជនដែលមានមេក្លោងនៅក្នុងប្រទេសរបស់

ខ្លួន និងមានបក្សពួកនៅកម្ពុជាប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ធ្វើការឆបោកឲ្យឆ្លងដែនដោយខុសច្បាប់ក្រោមការសន្យាផ្តល់ការងារដែលទទួលបានប្រាក់ឈ្នួលខ្ពស់។

លោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាបានថ្លែងប្រាប់វិទ្យុបារាំងតាមរយៈសារតេឡេក្រាមនៅថ្ងៃទី០៥ ខែសីហា ថាកន្លងមក ក្រសួងការបរទេសទទួលបានសំណើសុំកិច្ចអន្តរាគមន៍របស់ស្ថានតំណាងបរទេសមួយចំនួន ហើយតែងតែសម្របសម្រួល បញ្ជូនសំណើទាំងនោះទៅកាន់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បានយ៉ាងឆាប់រហ័ស ដើម្បីពិនិត្យ និងធ្វើកិច្ចអន្តរាគមន៍។ លោកបន្តថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធកម្ពុជា ដើម្បីលើកកម្ពស់យន្តការទទួលបណ្តឹង សំណើសុំអន្តរាគមន៍ និងចាត់ការពាក្យបណ្តឹងជួយសង្គ្រោះពលរដ្ឋដែលជាជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស៕

## សមត្ថកិច្ចខេត្តព្រះសីហនុបញ្ជូនជនជាតិចិនម្នាក់ទៅតុលាការ និងរំដោះជនរងគ្រោះ៤នាក់ចេញពីកន្លែងបង្ខាំង

https://www.rfa.org/khmer/news/social-economy/authorities-in-sihanoukville-send-a-chinese-man-to-court-and-release-four-victims-from-detention-09052022114531.html ដោយ មាន ឫទ្ធិ 2022.09.05

សមត្ថកិច្ចខេត្តព្រះសីហនុ អះអាងថា បានបញ្ជូនជនសង្ស័យជនជាតិចិនម្នាក់ទៅតុលាការពាក់ព័ន្ធនឹងករណីប្រើអំពើហិង្សាដោយចេតនា។ ទន្ទឹមគ្នានេះ សមត្ថកិច្ចបានជួយសង្គ្រោះជនជាតិម៉ាឡេស៊ីចំនួន ៣នាក់ និងជនជាតិតៃវ៉ាន់ម្នាក់ ចេញពីកន្លែងបង្ខាំងធ្វើទារុណកម្មនៅក្នុងក្រុមហ៊ុនឯកជនមួយកន្លែងក្នុងខេត្តព្រះសីហនុ។ មន្ត្រីសង្គមស៊ីវិល ព្រួយបារម្ភ អំពីកំណើនបទល្មើសជួញដូរមនុស្ស ឬបង្ខាំងមនុស្សនៅកម្ពុជា ព្រោះបានធ្វើឱ្យប៉ះពាល់កេរ្តិ៍ឈ្មោះប្រទេសជាតិនៅលើឆាកអន្តរជាតិ។ សមត្ថកិច្ចខេត្តព្រះសីហនុ ឱ្យដឹងថា ជនជាតិម៉ាឡេស៊ីចំនួន ៣នាក់ និងជនជាតិតៃវ៉ាន់ម្នាក់ ដែលត្រូវគេបង្ខាំងធ្វើទារុណកម្ម សមត្ថកិច្ចបានបញ្ជូនទៅប្រទេសកំណើតពួកគេវិញរួចរាល់ហើយ។

គេហទំព័របញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រះសីហនុនៅថ្ងៃទី៥ កញ្ញាថា សមត្ថកិច្ចបានកសាងសំណុំរឿងលើជនសង្ស័យម្នាក់ជាជនជាតិចិនឈ្មោះ វង្ស ហ្ស៊ី យ៉ាន់ (WONG ZHI YUAN) ទៅតុលាការជាប់ពាក់ព័ន្ធករណីប្រើអំពើហិង្សាដោយចេតនា។ កាលពីថ្ងៃទី០២ ខែកញ្ញា កម្លាំងសមត្ថកិច្ចស្រាវជ្រាវទីតាំងអគារលេខ ៨ និងអគារលេខ ១៣ ស្ថិតក្នុងភូមិ៦ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ និងបានជួយសង្គ្រោះជនរងគ្រោះចំនួន ០៤នាក់។ ជនរងគ្រោះទាំងនោះ មាន៣នាក់ជាជនជាតិម៉ាឡេស៊ី (Malaysia) ដែលមានឈ្មោះ លឹម ហៃ ក្វាន់ (LIM HUI GUAN) ហ្វុង ជួន ហៃ (FONG CHUN HUI) លីម កៃ ក្វាន់ (LIM KEE GUAN) និងជនរងគ្រោះម្នាក់ទៀតគឺ ឈ្មោះ សាយ ឈី ពីង (TSAI CHIH PING) ដែលជនជាតិចិនតៃវ៉ាន់។ រហូតដល់ថ្ងៃទី៣ កញ្ញា ជនរងគ្រោះឈ្មោះ សាយ ឈី ពីង (TSAI CHIH PING) អះអាងថា ជនសង្ស័យឈ្មោះ វង្ស ហ្ស៊ី យ៉ាន់ (WONG ZHI YUAN) បានធ្វើទារុណកម្មមកលើខ្លួននៅក្នុងអគារលេខ១៣។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទង មេបញ្ជាការកងរាជអាវុធហត្ថខេត្តព្រះសីហនុ លោក ហេង ប៊ុនទី និងស្នងការនគរបាលខេត្តព្រះសីហនុ លោក ជួន ណារិន្ទ ដើម្បីសាកសួរបន្ថែមពីបញ្ហានេះបានទេនៅថ្ងៃទី០៥ កញ្ញា។ ប៉ុន្តែ លោក ជួន ណារិន្ទ ធ្លាប់ប្រាប់វិទ្យុអាស៊ីសេរីថា សមត្ថកិច្ចនឹងស្រាវជ្រាវជាបន្តបន្ទាប់លើទីតាំងដែលមានករណីបង្ខាំង មនុស្សក្នុងខេត្តព្រះសីហនុ។ ទាក់ទងនឹងរឿងជនបរទេសចាញ់បោកមេខ្យល់ជនជាតិចិននេះដែរ កាលពីថ្ងៃទី២ កញ្ញា សារព័ត៌មានវៀតណាម (VietNam News) បានចុះផ្សាយថា មនុស្សជាង ៦០០នាក់នេះ ត្រូវបាន

ចាញ់បោក តាមរយៈការល្បួងផ្សព្វផ្សាយពាណិជ្ជកម្មមិនពិត ដោយឱ្យចូលមកធ្វើការងារនៅកម្ពុជាខុសច្បាប់។ អាជ្ញាធរកម្ពុជា និងទីភ្នាក់ងារតំណាងរបស់វៀតណាមបានសហការជាមួយក្រសួងការបរទេសកម្ពុជា នឹងបញ្ជូនពួកគេទៅប្រទេសវៀតណាមវិញ។

ក្រសួងមហាផ្ទៃ រកឃើញថា រយៈពេល ៨ខែ ក្នុងឆ្នាំ២០២២ សមត្ថកិច្ច ចុះត្រួតពិនិត្យលើបណ្តឹងចំនួនជាង ១រយករណី (១០៤ករណី) និងសង្គ្រោះមនុស្ស ជិត ១ពាន់ (៩៦៨) នាក់ និងឃាត់ខ្លួនជនសង្ស័យ ជិត ១រយនាក់ (៨២) ដោយក្នុងនោះមាន ១៩ករណី គឺជាអំពើបង្ខាំង និងជំរិតទារប្រាក់។ ជនរងគ្រោះដែលសមត្ថកិច្ចជួយសង្គ្រោះរួមមានជនជាតិឥណ្ឌូនេស៊ី (Indonesia) វៀតណាម (Vietnam) ថៃ (Thailand) ម៉ាឡេស៊ី (Malaysia) ចិន (China) ប៉ាគីស្ថាន (Pakistan) ឥណ្ឌា (India) មីយ៉ាន់ម៉ា (Myanmar) ហ្វីលីពីន (Philippines) តួកគី (Turkey) អាមេរិក (USA) អង់គ្លេស (UK) និងជនជាតិកូរ៉េខាងត្បូង (South Korea) ជាដើម។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័គ បាននៅឡើយទេនៅថ្ងៃទី០៥ ខែកញ្ញា ដើម្បីសុំព័ត៌មានបន្ថែមជុំវិញតួលេខចុងក្រោយនៃយុទ្ធនាការបង្ក្រាបរបស់អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ការបង្ខាំងមនុស្សខុសច្បាប់ និងអំពើឆបោកអនឡាញនៅកម្ពុជា។ ក៏ប៉ុន្តែ លោក ខៀវ សុភ័គ បានប្រាប់សារព័ត៌មានក្នុងស្រុក VOD ឱ្យដឹងថា គិតត្រឹមថ្ងៃទី០២ ខែកញ្ញា សមត្ថកិច្ចបានចោទប្រកាន់ជាបណ្តោះអាសន្នលើជនជាតិចិន និងខ្មែរចំនួន៦នាក់ពីបទជួញដូរមនុស្ស ហើយបានសង្គ្រោះជនរងគ្រោះជាង១០០នាក់ ក្នុងរយៈពេល១២ថ្ងៃ។ លោកថា អាជ្ញាធរបានចាត់វិធានការលើបណ្តឹងចំនួន៤០ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៩ ខែសីហា ហើយសង្គ្រោះបានជនរងគ្រោះជាង១០០នាក់ ក្នុងនោះមានជនជាតិអាមេរិកម្នាក់ ខ្មែរអាមេរិកាំងម្នាក់ ឥណ្ឌូនេស៊ី២នាក់ ចិន៣៨នាក់ ម៉ាឡេស៊ី៥៣នាក់ វៀតណាម៥នាក់ និងតៃវ៉ាន់៣នាក់។

ជុំវិញរឿងនេះ សម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (ADHOC) ប្រចាំខេត្តព្រះសីហនុ អ្នកស្រី ជៀប សុធារី សោកស្តាយដែលកម្ពុជាកំពុងក្លាយជាទីកន្លែង សម្រាប់ក្រុមឧក្រិដ្ឋជនប្រតិបត្តិការចាប់បង្ខាំង ឬជួញដូរមនុស្ស។ អ្នកស្រី មើលឃើញថា ការណ៍ដែលខេត្តព្រះសីហនុសម្បូរដោយបទល្មើសបែបឧក្រិដ្ឋ ជាពិសេសមានករណីជួញដូរមនុស្សជាបន្តបន្ទាប់មកនេះ គឺដោយសារលំហូរជនបរទេស ជាពិសេសជនជាតិចិន បានពង្រីកវិសាលភាពក្នុងការបើកបនល្បែងកាស៊ីណូខុសច្បាប់ ហើយអាជ្ញាធរគ្មានវិធានការទប់ស្កាត់នៅឡើយ៖ *«ខ្ញុំថារាជរដ្ឋាភិបាល លោកមានវិធីច្រើនណាស់ ក្នុងការកៀងគរអ្នកវិនិយោគ មករកស៊ីនៅកម្ពុជា។ បើសិនជាអាច យើងមិនចង់ឱ្យមានការបើកល្បែងកាស៊ីណូទេព្រោះ រឿងល្បែងស៊ីសងនេះសុភាសិតខ្មែរ យើងក៏បានលើកឡើងផ្តាំផ្ញើដល់កូនចៅជំនាន់ក្រោយថា ល្បែងតែងវិនាស។ វាជាការព្រួយបារម្ភ ជាពិសេស ស្នើសុំឱ្យអាជ្ញាធរយកចិត្តទុកដាក់ ក្នុងការធ្វើការពិនិត្យ សិក្សាស្រាវជ្រាវ អំពីការស្នាក់នៅនៃជនបរទេសបញ្ហាដែលមានការកើតឡើងដូចជា ការបង្ខាំងមនុស្ស ការប្រព្រឹត្តមុខរបរខុសច្បាប់ដូចជា មានការជួញដូរគ្រឿងញៀនអ៊ីចឹង»*។

យុទ្ធនាការបង្ក្រាបអំពើជួញដូរ និងឃុំឃាំងមនុស្សជាប់ៗនេះ ធ្វើឡើង ក្រោយពីក្រសួងការបរទេសអាមេរិក បានចេញរបាយការណ៍កាលពីខែកក្កដា ស្តីពីការជួញដូរមនុស្សឆ្នាំ២០២២ ដោយបានទម្លាក់ចំណាត់ថ្នាក់កម្ពុជាចុះមកលំដាប់ទី៣ ដែលមានន័យថា អាក្រក់បំផុត និងពុំធ្លាប់មានទេ ចាប់តាំងពីឆ្នាំ២០១៥ មក។ ក្រៅពីនេះ ក៏មានស្ថាប័នសារព័ត៌មានអន្តរជាតិបានរាយការណ៍យ៉ាងផុសផុលជាបន្តបន្ទាប់នារយៈពេលចុងក្រោយនេះ អំពីកំណើនឧក្រិដ្ឋកម្មចាប់បង្ខាំងជួញដូរមនុស្សនៅកម្ពុជា។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលស្គាល់អំពីស្ថានភាពជួញដូរមនុស្សធ្ងន់ធ្ងរនៅកម្ពុជា និងអំពាវនាវឱ្យស្ថាប័នតំណាងបរទេស និងភាគីពាក់ព័ន្ធនានាសហការផ្តល់ព័ត៌មាន និងចូលរួមបង្ការ ទប់ស្កាត់ និងបង្ក្រាប អំពើជួញដូរមនុស្សក្នុងប្រទេសកម្ពុជា៕

# មន្ត្រីសង្គមស៊ីវិលអំពាវនាវដល់ប្រជាពលរដ្ឋស្វែងយល់ព័ត៌មាន និងប្រុងប្រយ័ត្នករណីជួញដូរមនុស្សនៅកម្ពុជា

https://www.rfa.org/khmer/news/social-economy/civil-society-officials-call-on-citizens-to-find-out-information-and-vigilant-human-trafficking-in-cambodia-09052022 ដោយ មាន ឫទ្ធិ2022.09.05

មន្ត្រីសង្គមស៊ីវិល អំពាវនាវដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ឱ្យប្រុងប្រយ័ត្នខ្ពស់ចំពោះការល្បួងលួងលោមពីសំណាក់ក្រុមហ៊ុនចិនមួយចំនួន ដែលកំពុងប្រតិបត្តិការចាប់ជំរិតមនុស្សនៅលើទឹកដីខ្មែរ។ ជាមួយគ្នានេះ ពួកគាត់ថា រដ្ឋាភិបាល ក៏គួរបង្ហាញព័ត៌មានឱ្យបានទូលំទូលាយ និងប្រកបដោយតម្លាភាព អំពីករណីបង្ខាំងមនុស្ស ឬជួញដូរមនុស្សនេះ ដើម្បីជាប្រយោជន៍សម្រាប់មហាជនទូទៅ។ មន្ត្រីអង្គការសង្គមស៊ីវិល ជំរុញដល់ប្រជាពលរដ្ឋទូទៅដែលចង់ធ្វើការនៅក្រុមហ៊ុនឯកជន ជាពិសេសក្នុងវិស័យបនល្បែងណាមួយនោះ គួរតែមានការសិក្សាអំពីក្រុមហ៊ុននោះឱ្យបានច្បាស់លាស់ជាមុនសិន ដើម្បីបញ្ចៀសរាល់បញ្ហាប្រឈមនានា ដូចជាការកេងប្រវ័ញ្ចកម្លាំងពលកម្មពីថៅកែ ការបំបិទសិទ្ធិសេរីភាព ឬរហូតដល់មានការបង្ខាំងខ្លួនដោយខុសច្បាប់ ដែលអាចឈានទៅដល់ករណីអំពើជួញដូរមនុស្ស។

នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការសិទ្ធិមនុស្សលីកាដូ (LICADHO) លោក អំ សំអាត ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី០៤ ខែកញ្ញាថា ថ្វីដ្បិតករណីជួញដូរមនុស្សដែលភាគច្រើនបង្កឡើងដោយជនបរទេស និងជនបរទេសយ៉ាងណាក្តី ក៏បទល្មើសឧក្រិដ្ឋកម្មនេះបានកើតមានលើទឹកដីខ្មែរ ដែលធ្វើឱ្យប៉ះពាល់ដល់មុខមាត់ប្រទេសជាតិ និងជាការគំរាមកំហែងដល់ពលរដ្ឋជាម្ចាស់ស្រុក។ ទន្ទឹមគ្នានេះ លោកថា ប្រជាពលរដ្ឋជាម្ចាស់ប្រទេស ក៏ត្រូវស្វែងរកព័ត៌មាន អំពីករណីបង្ខាំងមនុស្ស ឬអំពើជួញដូរមនុស្ស ប្រសិនបើពួកគេចង់ធ្វើការក្នុងក្រុមហ៊ុនណាមួយ ដើម្បីធ្វើជាដើមទុនការពារខ្លួនពីសំណាក់ក្រុមហ៊ុនឆបោកនៃក្រុមឧក្រិដ្ឋជននៅកម្ពុជា៖ *«ទោះបីវាកើតឡើង ភាគច្រើនតែជនបរទេស និងជនបរទេស ក៏ដោយត្រូវតែមានការបង្ហាញព័ត៌មានជាតម្លាភាព ដើម្បីឱ្យបងប្អូន ប្រជាពលរដ្ឋហ្នឹងបានយល់ បានដឹង ហើយត្រៀម ខ្លួនក្នុងការ ការពារខ្លួន កុំឱ្យចាញ់បោកជនទុច្ចរិត ឬឧក្រិដ្ឋជន ក្នុងការអូសទាញទៅជាកម្មវត្ថុ នៃការជួញដូរមនុស្ស ជួញដូរពលកម្ម ឬជាការចាប់ជម្រិតជាដើម»*។

ចំណែកអ្នកសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (ADHOC) ប្រចាំខេត្តព្រះសីហនុ អ្នកស្រី ជៀប សុធារី ជឿជាក់ថា ក្នុងតំបន់អគារមួយចំនួនស្ថិតក្នុងខេត្តព្រះសីហនុ ដែលមានជនបរទេសត្រូវគេបង្ខាំងក្នុងក្រុមហ៊ុនចិននោះ ក៏អាចមានបុគ្គលជាជនជាតិខ្មែរដែរ។ អ្នកស្រី ឱ្យវិទ្យុអាស៊ីសេរីដឹងថា នៅអំឡុងឆ្នាំ២០១៩ អ្នកស្រីទទួលបានព័ត៌មានពីប្រជាពលរដ្ឋខ្មែរ ដែលត្រូវបានថៅកែជនជាតិចិននៃបនល្បែងកាស៊ីណូ បង្ខំឱ្យធ្វើការ និងមិនឱ្យចាកចេញពីកន្លែងការងារឡើយ។ ចំណែក ប្រាក់ខែសម្រាប់ទូទាត់ជូនបុគ្គលិក ក្រុមហ៊ុនក៏មិនបានគោរពតាមកិច្ចសន្យាឡើយ។ អ្នកស្រី អំពាវនាវដល់ប្រជាពលរដ្ឋខ្មែរ ឱ្យប្រុងប្រយ័ត្នខ្ពស់ចំពោះការផ្សាយពាណិជ្ជកម្មការងារពីសំណាក់ក្រុមហ៊ុនមួយចំនួនដែលអះអាងថា អាចផ្តល់ចំណូលបានពីជាង ១ពាន់ (១.០០០) ដុល្លារក្នុងមួយខែ។ អ្នកស្រីថា ពលរដ្ឋគួរតែសិក្សាស្រាវជ្រាវអំពីក្រុមហ៊ុនដែលខ្លួនចង់ដាក់ពាក្យធ្វើការងារ ដើម្បីបញ្ចៀសការប្រឈមបញ្ហា និងការរំលោភសិទ្ធិពីសំណាក់ថៅកែ៖ *«បង្ខាំងការបង្ខំ ភាគច្រើនតែជនបរទេស ហើយខ្មែរយើងគាត់ធ្វើទៅ ប្រសិនជាគាត់មិនពេញចិត្តនឹងធ្វើការនៅកន្លែងហ្នឹងទេ គឺគាត់អាចសុំមេការ របស់គាត់ ហើយមេការ នឹងផ្ញើព័ត៌មានទៅឱ្យ អ្នកគ្រប់គ្រងទៅគាត់អាចចាកចេញបាន។ គ្រាន់ថា នៅពេលដែលយើងចង់ចាកចេញហ្នឹង គេមានការតឹងតែងតិច ទល់តែមានការអនុញ្ញាតពីថៅកែធំៗហ្នឹងបានយើងអាចចាកចេញបាន»*។

ការអំពាវនាវនេះ ធ្វើឡើងក្រោយពីជនបរទេសមួយចំនួន ដូចជា ជនជាតិថៃ វៀតណាម ហ្វីលីពីន ចិន ម៉ាឡេស៊ី និងជនជាតិឥណ្ឌូនេស៊ីជាដើម ត្រូវក្រុមហ៊ុនឆបោករបស់ចិនបោកបញ្ឆោត ដោយផ្សព្វផ្សាយពាណិជ្ជកម្ម

ការងារក្លែងក្លាយថា មានការងារនៅកម្ពុជាអាចរកប្រាក់ចំណូលបានចន្លោះពី១ពាន់ (១.០០០) ទៅ ១ពាន់ ៥រយ ដុល្លារ១.៥០០ ក្នុងមួយខែ។ ប៉ុន្តែជនបរទេសទាំងនោះពេលមកដល់កម្ពុជាបែរជាត្រូវបានគេបង្ខាំងក្នុងអគារខ្ពស់ៗ និងត្រូវបានថៅកែជនជាតិចិនធ្វើទារុណកម្ម ដើម្បីបង្ខំឱ្យធ្វើការឆបោកជម្រិតមនុស្សតាមប្រព័ន្ធអ៊ីធឺណែត ទៅវិញ។

ទាក់ទងនឹងរឿងនេះ ស្នងការនគរបាលខេត្តព្រះសីហនុ លោក ជួន ណារិន្ទ ប្រាប់វិទ្យុអាស៊ីសេរីថ្មីៗនេះថា រដ្ឋាភិបាលតែងផ្សព្វផ្សាយព័ត៌មានអំពីករណីជួញដូរមនុស្សទៅកាន់សាធារណជនជាបន្តបន្ទាប់។ ទោះយ៉ាងណា លោកនិយាយថា ក្នុងខេត្តព្រះសីហនុ មានករណីបង្ខាំង និងករណីចាប់ជម្រិតតិចតួចបំផុត។ លោកថា ជនបរទេស ដែលអះអាងថា ត្រូវគេបង្ខាំងគឺពួកគេតែងតែចង់ចាកចេញពីកម្ពុជា វិលទៅស្រុកកំណើតវិញតែប៉ុណ្ណោះ។

ផ្ទុយពីការអះអាងនេះ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (UN) លោក វិទិត មុនតាប៊ន (Vitit Muntarbhorn) ថ្លែងកាលពីពេលថ្មីៗនេះថា កម្ពុជាជាប្រទេសគោលដៅនៃការជួញដូរ និងបង្ខាំងមនុស្សឱ្យធ្វើការខុសច្បាប់។ លោក ជំរុញទៅអាជ្ញាធរ និងរដ្ឋាភិបាល ត្រូវចាត់វិធានការឱ្យប្រសិទ្ធភាព និងបើកកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធ និងប្រទេសអាស៊ាន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលស្គាល់អំពីស្ថានភាពជួញដូរមនុស្សធ្ងន់ធ្ងរនៅកម្ពុជា និងអំពាវនាវឲ្យស្ថាប័នតំណាងបរទេស និងភាគីពាក់ព័ន្ធនានាសហការផ្តល់ព័ត៌មាន និងចូលរួមបង្ការ ទប់ស្កាត់ និងបង្ក្រាប អំពើជួញដូរមនុស្សក្នុងប្រទេសកម្ពុជា។

កន្លងទៅក្រសួងការបរទេសបញ្ជាក់ថា មានស្ថានទូតចំនួន០៩រួមមាន បង់ក្លាដែស (Bangladesh) ឥណ្ឌា (India) ឥណ្ឌូនេស៊ី (Indonesia) ម៉ាឡេស៊ី Malaysia ម៉ុងហ្គោលី (Mongolia) នេប៉ាល់ (Nepal) ប៉ាគីស្ថាន (Pakistan) ហ្វីលីពីន (Philippines) និងប្រទេសថៃ (Thailand) ស្នើអាជ្ញាធរកម្ពុជាជួយសង្គ្រោះពលរដ្ឋរបស់ពួកគេ ដែលត្រូវបានក្រុមឧក្រិដ្ឋជនចាប់បង្ខាំងឱ្យធ្វើការងារទាំងបង្ខំនៅកម្ពុជា៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/2022/09/05/-27-2/ 05/09/2022 Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង ១១ និង០០នាទី ថ្ងៃចន្ទ ១០កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន(មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន៨០នាក់ ស្រី៣៤នាក់ ក្មេងស្រី១នាក់ ។

ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើការពិនិត្យ និងស្តែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## លោក ហេង សួរ ៖ មិនមានពលករខ្មែរណាម្នាក់វិលត្រឡប់មកស្រុក តាមការឃោសនារបស់លោក ខឹម វាសនា ទៀតទេ

https://www.kampucheathmey.com/local-news/368508 ថ្ងៃអង្គារ ៦ កញ្ញា ២០២២ Sokhom Khon

លោក ហេង សួរ រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងថា រហូតមកដល់ពេលនេះមិនមានពលករខ្មែរនៅក្រៅប្រទេសណាម្នាក់បានវិលត្រឡប់មកស្រុកកំណត់វិញតាមការឃោសនា របស់លោក ខឹម វាសនា ជាបន្តទៀតនោះទេ។ ថ្លែងប្រាប់អ្នកសារព័ត៌មាននៅព្រឹកថ្ងៃទី០៦ ខែកញ្ញា ក្នុងឱកាសចូលរួមក្នុងពិធីបើកយុទ្ធនាការជិះដើម្បីមិត្តយើងរបស់សមាគមមិត្តយើងនៅកោះពេជ្រ លោកបានបន្តថា «មកដល់ពេលនេះពាក់ព័ន្ធទៅនឹងការឃោសនាអបិយជំនឿហួសហេតុរបស់លោក ខឹម វាសនា មិនមានពលករខ្មែរធ្វើការនៅប្រទេសថៃ នៅកូរ៉េ និងនៅជប៉ុនបានឆ្លងដែន និងធ្វើដំណើរមកស្រុកទៀតទេ មានតែនៅចន្លោះថ្ងៃទី២៣ដល់ថ្ងៃទី២៦ ខែសីហា ប៉ុណ្ណោះ ហើយចាប់ពីថ្ងៃទី២៧ ខែសីហា មក មិនមានទៀតទេ»។ លោកបានបន្តទៀតថា ការដែលមិនមានពលករមកស្រុកនេះ បន្ទាប់ពីអ្នកលេងតាមហ្វេសប៊ុកបានធ្វើការអំពាវនាវ និង ចែកចាយព័ត៌មាន និងរូបភាពផ្សេងៗនិងពន្យល់ណែនាំទៅឃើញថា បងប្អូនពលករខ្មែរយើងបានយល់ និងភ្ញាក់ខ្លួនមិនបានបន្តវិលត្រឡប់មកស្រុកវិញតាមការអំពាវនាវរបស់លោក ខឹម វាសនា ជាបន្តទៀត។ លោក ហេង សួរ បានឱ្យដឹងទៀតថា មានពលករខ្មែរធ្វើការនៅក្រៅប្រទេសប្រមាណជាង៥០០នាក់បានវិលត្រឡប់មកស្រុកវិញ តាមការឃោសនារបស់លោក ខឹម វាសនា ក្នុងនោះមានពលករធ្វើការនៅកូរ៉េប្រមាណជាង៤០០នាក់ និងប្រមាណ១០០នាក់ទៀតធ្វើការនៅជប៉ុនពាក់ព័ន្ធនឹងការអំពាវនាវរបស់ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ លោក ខឹម វាសនា ដែលថាទឹកនឹងជន់លិចពិភពលោកទាំងមូល។ លោកបានបន្ថែមថា ពលករខ្មែរទាំងនោះ ខ្លះសុំច្បាប់ថៅកែថា ឪពុកម្តាយឈឺធ្ងន់ និងខ្លះទៀតសុំច្បាប់ថៅកែឈប់មិនបានក៏ពួកគេសម្រេចចិត្តបោះបង់ការងារចោល និងត្រឡប់មកកម្ពុជាវិញ។

លោក ហេង សួរ បានបញ្ជាក់ថា ករណីនេះធ្វើឱ្យក្រុមហ៊ុនកូរ៉េមួយចំនួនបានប្តឹងទៅក្រសួងការងារកូរ៉េដោយស្នើឱ្យកាត់បន្ថយពលកររបស់កម្ពុជាដែលលោកមិនអាចបញ្ជាក់ថា តើមានចំនួនក្រុមហ៊ុនប៉ុន្មានទេដែលបានប្តឹងទៅក្រសួងការងារកូរ៉េ។ លោកបានបន្ថែមទៀតថា ក្រសួងការងារបានជួបដោះស្រាយបញ្ហានេះជាមួយតំណាងអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សកូរ៉េ (HTD Korea) ដោយបានសុំទោសរដ្ឋាភិបាលកូរ៉េជាពិសេសនិយោជកកូរ៉េដែលរងផលប៉ះពាល់ដោយការចលាចលនេះ។ ក្រសួងក៏សំណូមពរដល់និយោជកកូរ៉េ និងជប៉ុនមេត្តាយោគយល់ដល់ពលករ និងសិក្ខាកាមរបស់កម្ពុជា ដោយកុំប្តឹង និងពិចារណាទទួលយកពួកគេវិញតាមលទ្ធភាពជាក់ស្តែង។

ទាក់ទងបញ្ហានេះ ក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសថ្មីចំនួន២ក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែសីហាឆ្នាំ២០២២ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើទៅក្រុមហ៊ុនកូរ៉េ ជប៉ុន និងថៃ កុំប្តឹងតាមផ្លូវច្បាប់លើរដ្ឋាភិបាលកម្ពុជា និងពលករដែលរត់ចោលការងារនាពេលថ្មីៗនេះ ព្រោះពលករទាំងនោះចាញ់បោកការឃោសនារបស់ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ លោក ខឹម វាសនា។ សម្តេចបានថ្លែងថា «សូមកុំឱ្យរដ្ឋាភិបាលនៃប្រទេសទាំងអស់ ដែលមានពលករធ្វើការនៅក្នុងប្រទេសរបស់ខ្លួន ដាក់ពាក្យបណ្តឹងទាមទារសំណងពីរដ្ឋាភិបាលកម្ពុជា ឬពីបុគ្គលិកដែលរត់ចោលការងារ។ ហើយសូមកុំផ្សារភ្ជាប់ពលករកម្ពុជាដទៃទៀតជាមួយពលករ

ដែលធ្វើកំហុស ដោយសារការចាញ់បោកសម្រាប់ព្រះព្រហ្ម [លោក ខឹម វាសនា តាំងខ្លួនជាព្រះព្រហ្ម] នៅប្រទេសកម្ពុជា»។

បើតាមលោក ហេង សួរ បច្ចុប្បន្នមានពលករខ្មែរដែលធ្វើការនៅប្រទេសកូរ៉េមានជាង៥ម៉ឺននាក់ និងក្នុងប្រទេសជប៉ុនមានជាង១ម៉ឺន៦ពាន់នាក់៕ អត្ថបទ៖ សំអឿន

## ៥ថ្ងៃនេះ សម្ដេចក្រឡាហោម ស ខេង ទទួលបណ្ដឹងតាម Hotline ១៧ករណី ពាក់ព័ន្ធការស្នើអន្តរាគមន៍ជួយសង្គ្រោះករណីបង្ខាំង និងជួញដូរពលកម្ម, រំដោះជនរងគ្រោះ២៣នាក់

http://freshnewsasia.com/index.php/en/localnews 2022-09-06 02:43pm

**(ភ្នំពេញ)៖** រយៈពេល៥ថ្ងៃមកនេះ គិតចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ សម្ដេចក្រឡាហោម ស ខេង បានទទួលពាក្យបណ្ដឹងសរុបចំនួន ១៧ករណី ពាក់ព័ន្ធនឹងការស្នើអន្តរាគន៍ជួយសង្គ្រោះពីការបង្ខាំង និងជួញដូរពលកម្ម ក្នុងនោះក៏មានការជួយសង្គ្រោះជនបរទេស២៣នាក់ផងដែរ។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។

នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ សមត្ថកិច្ចបានបើកប្រតិបត្តិការរំដោះជនរងគោះចំនួន២៣នាក់ (ស្រី៣នាក់) មានជនជាតិចិន ១៥នាក់ ជនជាតិចិនតៃវ៉ាន់ ៧នាក់ និងជនជាតិវៀតណាម ៧នាក់ និងឥណ្ឌូនេស៊ី១នាក់ផងដែរ។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្ដេជ្ញាចិត្តប្រកបដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្ដល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះផងដែរ៕

## គិតត្រឹមថ្ងៃទី៥ កញ្ញា ហ្វេសប៊ុកសម្តេចក្រឡាហោម ស ខេង ទទួលបានពាក្យបណ្តឹងសរុប ១១៧ ទាក់ទងនឹងការស្នើអន្តរាគមន៍លើករណីបង្ខាំង និងជួញដូរពលកម្ម

http://freshnewsasia.com/index.php/en/localnews/256363-2022-09-06-10-22-01.html 2022-09-06 05:22pm

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News ឱ្យដឹងថា រហូតមកដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានទទួលពាក់បណ្ដឹងសរុបចំនួន ១១៧ បណ្ដឹងហើយ តាមរយៈទំព័រហ្វេសប៊ុករបស់សម្ដេច។ លោកបានបញ្ជាក់ថា បណ្ដឹងទាំង១១៧នោះ គឺពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ជួយសង្គ្រោះជនបរទេស ដែលត្រូវបានអះអាងថាបង្ខាំង និងជួញដូរកម្លាំងពលកម្ម នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីសម្ដេចបានអំពាវនាវឱ្យភាគីទាំងអស់ រួមទាំងបរទេសផងដែរ សហការផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងករណីទាំងនេះ។ បើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ សរុបពាក្យបណ្ដឹងទាំង ១១៧នេះ គឺចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្ដេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់ សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធ បន្តសហការ

ផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបាន ទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស សម្តេចក្រឡាហោម បានសម្តែងការសោកស្តាយ និងថ្កោលទោសចំពោះអំពើដ៏អមនុស្សធម៌ ទាំងនេះ។ សម្តេចក៏បានថ្លែងអំណរគុណ និងស្វាគមន៍ចំពោះការផ្តល់ព័ត៌មានផ្សេងៗ ពីសំណាក់បុគ្គល និងស្ថាន តំណាងបរទេសប្រចាំកម្ពុជា នាពេលកន្លងមកពាក់ព័ន្ធទៅនឹងករណីខាងលើនេះ។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះ ដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះផងដែរ៕

## ឯកអគ្គរដ្ឋទូតម៉ាឡេស៊ី ថាការជួយសង្គ្រោះពលរដ្ឋមួយចំនួនចេញពីការងារឆបោកមានខ្លះ បដិសេធ មិនចង់ចេញពីកម្ពុជា

https://www.postkhmer.com/international/2022-09-06-1500-240618.html សេក ប្រាក់ | Publication date 06 September 2022 | 15:00 ICT

ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជាលោក EldeenHusainiMohd Hashim បានអះអាងថា ជនជាតិម៉ាឡេ ស៊ីជាង ១០០ នាក់ ដែលរងគ្រោះដោយសារក្រុមឆបោក នៅកម្ពុជា ត្រូវបានជួយសង្គ្រោះដោយស្ថានទូតម៉ាឡេស៊ី ចាប់តាំងពីឆ្នាំ ២០១៨ មក។ នេះបើតាមការចុះផ្សាយរបស់សារព័ត៌មាន The Star កាលនៅថ្ងៃទី ០៤ ខែកញ្ញា។ ក៏ប៉ុន្តែការជួយសង្គ្រោះជាង ៤ ឆ្នាំមកនេះ មានជនជាតិម៉ាឡេស៊ីខ្លះ បានបដិសេធ មិនចង់បានការអន្តរាគមន៍ពីរដ្ឋា ភិបាល។ លោក EldeenHusainiMohd Hashim លើកឡើងថា «យើងបានជួយសង្គ្រោះមនុស្សជាច្រើននាក់ ហើយ ប៉ុន្តែមនុស្សជាច្រើនក៏មិនចង់ត្រឡប់ទៅម៉ាឡេស៊ីដែរ ព្រោះពួកគេខ្លះរត់ចេញពីផ្ទះ»។ តាមឯកអគ្គរដ្ឋទូតម៉ា ឡេស៊ីការបដិសេធនេះ ក៏ព្រោះតែជនជាតិម៉ាឡេស៊ីទាំងនោះ មិនចង់ប្រាប់គ្រួសាររបស់គេពីរឿងពិត។ ទោះយ៉ាង ណា ចាប់តាំងពីឆ្នាំ ២០១៨ មក ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីបានអះអាងថា ស្ថានទូតមិនអាចគ្រាន់តែបញ្ជូនជនជាតិម៉ា ឡេស៊ីចេញភ្លាមៗ ក្រោយពីការជួយសង្គ្រោះនោះទេ តែត្រូវអនុវត្តតាមច្បាប់របស់កម្ពុជា។ ច្បាប់កម្ពុជាស្តីពីអន្តោ ប្រវេសន៍ បញ្ជាក់ថា ប្រសិនបើជនបរទេសចូលមកកម្ពុជាដោយខុសច្បាប់ នោះនឹងត្រូវមានទោស មុនពេលចាក ចេញពីកម្ពុជា។ បើតាមលោក EldeenHusainiMohd Hashim គឺជនជាតិម៉ាឡេស៊ីមួយចំនួន បានចូលមកកម្ពុជា ដោយខុសច្បាប់តាមរយៈការរត់ការសម្ងាត់ ហើយមិនមានឯកសារបញ្ជាក់គ្រប់គ្រាន់។

ជាមួយគ្នានេះ លោកជុំ សុន្ទរីអ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា បញ្ជាក់ថា «ក្រសួងការបរទេសទទួល បានសំណើសុំកិច្ចអន្តរាគមន៍របស់ស្ថានតំណាងបរទេសមួយចំនួន ហើយតែងតែសម្របសម្រួល បញ្ជូនសំណើទាំង នោះទៅកាន់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បានយ៉ាងឆាប់រហ័ស ដើម្បីពិនិត្យ និងធ្វើកិច្ចអន្តរាគមន៍»។ លោកថា «ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធកម្ពុជា ដើម្បី លើកកម្ពស់យន្តការទទួលបណ្តឹង សំណើសុំអន្តរាគមន៍ និងចាត់ការពាក្យបណ្តឹងជួយសង្គ្រោះពលរដ្ឋដែលជាជន សង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស»។ សម្រាប់អ្នកនាំពាក្យក្រសួងការបរទេស បទល្មើសជួញដូរមនុស្សគឺ ជាឧក្រិដ្ឋកម្មឆ្លងដែន ដែលបាននិងកំពុងកើតមានឡើងនៅគ្រប់តំបន់ និងបានរីកសាយភាយ ប្រទាក់ក្រឡាគ្នា យ៉ាងស្មុគស្មាញ។ ដូចនេះការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ទាមទារ នូវកិច្ចសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធ រវាងបណ្តាប្រទេសពាក់ព័ន្ធ។ នេះបើតាមលោក ជុំ សុន្ទរី។

សូមបញ្ជាក់ថា បទល្មើសឆបោកតាមប្រព័ន្ធអ៊ីនធឺណិត បានក្លាយជាបញ្ហាចោទមួយថ្មីនៅកម្ពុជា ដែលសារព័ត៌មានអន្តរជាតិមួយចំនួន បានលើកយកមកចុះផ្សាយជាហូរហែ។ កាលពីពាក់កណ្ដាលខែកក្កដា សារព័ត៌មាន Al Jazzera បានចុះផ្សាយវីដេអូស៊ើបអង្កេតមួយដោយបង្ហាញថា កម្ពុជាកំពុងមានបទល្មើសឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ដែលឈានទៅដល់រូបភាពនៃការជួញដូរមនុស្ស។ សម្រាប់ការជួញដូរមនុស្ស របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសអាមេរិក ក៏បានទាញសញ្ញាអាសន្នសម្រាប់កម្ពុជា។ ការទាញសញ្ញាអាសន្ននោះដោយសារ ឆ្នាំ ២០២២ កម្ពុជាបានធ្លាក់ទៅក្នុងបញ្ជីខ្មៅនៃអំពើជួញដូរមនុស្ស ដែលទាមទារឱ្យ រដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ដោយហ្មត់ចត់ និងប្រសិទ្ធភាព៕

## ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២

### សម្ដេច ស ខេង ៖ មិនគ្រាន់តែជួយជនរងគ្រោះហើយ ចប់ភារកិច្ចទេ ត្រូវពន្លាតការស្រាវជ្រាវ និងបង្ក្រាបជនល្មើសជួញដូរមនុស្ស

https://dap-news.com/national/2022/09/07/276985/ ByPH104Posted on September 7, 2022

**ភ្នំពេញ ៖** ក្នុងនាមជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)សម្ដេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាដាច់ណាត់ ដល់សមត្ថកិច្ចមានជំនាញគ្រប់ជាន់ថ្នាក់ ត្រូវបង្ក្រាបករណីជួញដូរមនុស្ស នៅកម្ពុជាឲ្យបាន ព្រោះមិនអាចគ្រាន់ តែជួយជនរងគ្រោះហើយ ចប់ភារកិច្ចនោះទេ ត្រូវចាប់ខ្លួនជនល្មើស និងបង្ក្រាបទីតាំងពាក់ព័ន្ធ អំពើជួញដូរមនុស្ស។

ក្នុងពិធីប្រកាសផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងអគារធិការ នៃអគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២ សម្ដេច ស ខេង បានឲ្យដឹងថា រហូតមក ដល់ពេលនេះ ក្រសួងទទួលពាក្យបណ្ដឹង ពាក់ព័ន្ធអំពើជួញដូរមនុស្សចំនួន១១៧ករណីហើយ ក្រោយបើកការបង្ក្រាប ជាលក្ខណៈទ្រង់ទ្រាយធំកាលពីពេលថ្មីៗនេះ។ សម្ដេចបន្តថា ក្នុងចំណោមបណ្ដឹង សុំកិច្ចអន្តរាគមន៍ជួយសង្គ្រោះនោះ ក៏មានជនរង គ្រោះជាបន្តបន្ទាប់ ត្រូវបានសមត្ថកិច្ចជួយសម្រួល ឲ្យបានចាកចេញពីទីកន្លែងការងារ បន្ទាប់ពីពួកគេ និង សាច់ញាតិ បានស្នើសុំកិច្ចអន្តរាគមន៍មក សម្ដេចផ្ទាល់តាមរយៈទំព័រហ្វេសប៊ុក ឬតាមរយៈអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ។

សម្ដេចបញ្ជាក់ថា «មិនអាចគ្រាន់តែយកជនរងគ្រោះ ហើយក៏ចប់ភារកិច្ច មិនមែនទេ ត្រូវតែពន្លាតការស្រាវជ្រាវ របស់យើងឲ្យវាច្បាស់លាស់ ចប់ចុងចប់ដើម។ រាយការណ៍មកថា អត់មានការបង្ខាំងទេ អត់មានការធ្វើទារុណកម្មទេ គ្រាន់តែអត់ឲ្យមានសិទ្ធិដើរទៅនេះ ដើរទៅនោះ អាហ្នឹងហើយឃុំខ្លួនគេ។ តាមពិតយើងមានសិទ្ធិអីទៅបិទគេ។ អាហ្នឹងយ៉ាងណាក៏មានទំនួលខុសត្រូវ ធ្ងន់ឬស្រាលអាហ្នឹងតាមច្បាប់កំណត់ទៅ។ ប៉ុន្តែបើថាទៅហាមឃាត់សិទ្ធិសេរីភាពគេ ហើយថាវាអត់មានអីទេ វាអត់ត្រូវ តាមខ្ញុំយល់ ក្រែងខ្ញុំយល់វាមិនដល់ តែយើងទៅមានសិទ្ធិអីហាមឃាត់គេ?»។ សម្ដេច បន្ថែមថា រាល់កិច្ចប្រតិបត្តិការបង្ក្រាបអំពើជួញដូរមនុស្ស ត្រូវតែប្រកាន់យកគោលការណ៍ ចំនួន៣ រួមមាន៖ គឺសង្គ្រោះជនរងគ្រោះ បង្ក្រាបទីតាំងខុសច្បាប់ និងផ្តន្ទាទោសជនល្មើស ។ សម្ដេចថា បញ្ហាជួញដូរមនុស្សជាបញ្ហាដែលអន្តរជាតិយកចិត្តទុកដាក់ហើយកម្ពុជាក៏ត្រូវ យកចិត្តទុកដាក់ឲ្យបានខ្លាំងក្លាដែរ។

កាលពីថ្ងៃ១៩ សីហា សម្ដេច ស ខេង បានប្រកាសចាប់ផ្តើមបើកប្រតិបត្តិការត្រួតពិនិត្យ ការរស់នៅជនបរទេសនៅកម្ពុជា លើកលែងតែមន្ត្រីទូត ហើយឃាត់ខ្លួនមេក្លោងជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះមួយចំនួនទៀតផងដែរ ។ ដោយជំហានដំបូងធ្វើនៅខេត្តកណ្ដាល និងព្រះសីហនុ និងបន្តត្រួតពិនិត្យនៅខេត្តផ្សេងៗទៀត ។ បន្ទាប់ពីបើកប្រតិបត្តិការរួចមក ឃើញថា មានជនរងគ្រោះជាច្រើនរយនាក់ដែលជាជនបរទេស ត្រូវបានជួយសង្គ្រោះដែលភាគច្រើនពួកគេធ្វើការតាមអនឡាញ។

សូមរំលឹកថា ក្រសួងការបរទេសអាមេរិក បានទំលាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជាដល់លេខ៣ ជាចំណាត់ថ្នាក់ទាបបំផុត និងបង្ហាញថាកម្ពុជា ជារដ្ឋគ្មានឆន្ទៈបង្ក្រាបអំពើជួញដូរមនុស្ស។ ជុំវិញបញ្ហានទាំងនេះ សម្តេច ស ខេង ក៏បានបង្កើតក្រុមការងារ ដើម្បីបង្កើនប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

គួរឲ្យដឹងថា ក្នុងរយៈពេល៨ខែ ឆ្នាំ២០២២ សមត្ថកិច្ចអះអាងថា បានចុះត្រួតពិនិត្យបណ្តឹងជាង១០០ករណី ដោយសង្គ្រោះមនុស្សចំនួន៩៦៨នាក់ និងឃាត់ខ្លួនជនសង្ស័យ៨២នាក់ ក្នុងនោះ១៩ករណី គឺជាអំពើបង្ខាំង និងជំរិតទារប្រាក់៕

## តៃវ៉ាន់អះអាងថា ពលរដ្ឋខ្លួន ១១នាក់ផ្សេងទៀតដែលជាប់នៅក្នុងប្រទេសកម្ពុជាបានធ្វើមាតុភូមិនិវត្តន៍មកប្រទេសវិញ

https://www.khmertimeskh.com/501146609//?p=1146609 Khmer Times September 7, 2022

ការិយាល័យស៊ើបអង្កេតឧក្រិដ្ឋកម្ម (CIB) បាននិយាយកាលពីថ្ងៃចន្ទថា ជនជាតិតៃវ៉ាន់ ១១នាក់ ដែលស្ថិតក្នុងចំណោមរាប់រយនាក់ផ្សេងទៀតដែលត្រូវបានជួញដូរមកកម្ពុជា អោយធ្វើការឆបោកបានត្រឡប់ទៅទីក្រុងតៃប៉ិវិញហើយ។ ការិយាល័យបានបន្តថា ការវិលត្រឡប់របស់ជនជាតិតៃវ៉ាន់២នាក់នៅថ្ងៃអាទិត្យនិង៩នាក់ទៀតនៅថ្ងៃចន្ទត្រូវបានធ្វើឡើង ដោយជោគជ័យក្រោមជំនួយពីឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង។ រដ្ឋាភិបាលបាននិយាយថា មនុស្ស១១ នាក់ ស្ថិតក្នុងចំណោមជនជាតិតៃវ៉ាន់ប្រហែល៣៧៣ នាក់ដែលគេដឹងថា ជាប់នៅកម្ពុជាបន្ទាប់ពីត្រូវបានល្បួងអោយទៅទីនោះដោយសន្យាផ្តល់ការងារ ដែលរកកម្រៃបានច្រើនដែលទីបញ្ចប់ប្រែក្លាយទៅជាការបោកប្រាស់ដោយក្រុមឆបោក។

អ្នកនាំពាក្យលោក Lo Ping-cheng បាននិយាយកាលពីថ្ងៃទី១៨ ខែសីហាថា ជនជាតិតៃវ៉ាន់ប្រមាណ១៤៤នាក់កំពុងត្រូវបានបង្ខាំងខ្លួនប្រឆាំងនឹងឆន្ទៈរបស់ពួកគេ ហើយលិខិតឆ្លងដែនរបស់ពួកគេត្រូវបានរឹបអូស។ ចាប់តាំងពីពេលនោះមក រដ្ឋាភិបាលបានបញ្ជូនមន្ត្រីទំនាក់ទំនងពិសេសនៃបេសកកម្ម CIB លោក Chan Li-tse ទៅកាន់ប្រទេសវៀតណាម ដើម្បីធ្វើការជាមួយមន្ត្រី CIB ដែលឈរជើងនៅទីនោះ ដើម្បីជួយនាំជនជាតិតៃវ៉ាន់ដែលជាប់នៅក្នុងប្រទេសកម្ពុជា។

លោក Chan បាននិយាយថា កិច្ចខិតខំប្រឹងប្រែងនាំយកជនជាតិតៃវ៉ាន់ទាំង ១១នាក់ មកផ្ទះវិញ បានចាប់ផ្តើមនៅពេលដែលគាត់ទាក់ទង លោក ស ខេង តាមរយៈហ្វេសប៊ុក ដោយផ្តល់ឈ្មោះ លេខលិខិតឆ្លងដែន និងទីតាំងរបស់ជនរងគ្រោះដល់លោក។ លោក Chan បាននិយាយថា ព័ត៌មាននេះត្រូវបានទទួលក្នុងអំឡុងពេលស៊ើបអង្កេតលើការជាប់ពាក់ព័ន្ធរបស់សហជីពឫស្សី(Bamboo Union) ដែលជាក្រុមឧក្រិដ្ឋជននៅតៃវ៉ាន់ ជួញដូរជនជាតិតៃវ៉ាន់មកកម្ពុជា។ លោកបានបន្ថែមថា ក្នុងអំឡុងពេលស៊ើបអង្កេត មន្ត្រីអនុវត្តច្បាប់បានរកឃើញសៀវភៅកត់ត្រាដែលមានទិន្នន័យផ្ទាល់ខ្លួន និងទីតាំងរបស់ជនជាតិតៃវ៉ាន់ទាំង ១១ នាក់ ដែលនៅកន្លែងផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា រួមទាំងខេត្តព្រះសីហនុ និងខេត្តកណ្តាល។ Chan បាននិយាយថា អ្នកខ្លះដែលបានត្រលប់មកវិញបាននិយាយថា ខណៈដែលពួកគេដឹងពីការកើនឡើងនៃការបោកប្រាស់ការងារ ពួកគេគិតថាការងារនេះគឺស្របច្បាប់ដោយសារពួកគេត្រូវបានសម្ភាសន៍តាមប្រព័ន្ធវីដេអូ។ លោក Chan បានបន្តថា នៅពេលទៅដល់ប្រទេសកម្ពុជា លិខិតឆ្លងដែនរបស់ពួកគេត្រូវបានសមាជិកក្រុមឆបោករឹបអូសដោយជនរងគ្រោះម្នាក់និយាយបានថា អ្នកណាបំពានវិន័យត្រូវបានគេវាយធ្វើបាប។

លោក ស ខេង ដែលជាប្រធានគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សផងដែរ កាលពីខែមុន បានសន្យាបង្ក្រាបការជួញដូរមនុស្សនៅក្នុងប្រទេស។ *Taipei Times*

# មន្ត្រីរដ្ឋាភិបាលៈ ការស៊ើបអង្កេតលើការជួញដូរមនុស្សមកកម្ពុជានៅតែបន្ត

https://www.khmertimeskh.com/501146629//?p=1146629 Khmer Times September 7, 2022

មន្ត្រីរដ្ឋាភិបាលបានរាយការណ៍អំពីបញ្ហាជនជាតិវៀតណាម ដែលត្រូវបានបោកបញ្ឆោតឱ្យមកធ្វើការដោយខុសច្បាប់នៅក្នុងប្រទេសកម្ពុជានៅក្នុងសន្និសីទសារព័ត៌មានជាប្រចាំរបស់រដ្ឋាភិបាលនៅទីក្រុងហាណូយកាលពីថ្ងៃទី៦ ខែកញ្ញា។ ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម លោក Nguyen Minh Vu មានប្រសាសន៍ថា ក្រសួងការបរទេស និងទីភ្នាក់ងារតំណាងវៀតណាមប្រចាំនៅកម្ពុជាបានសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយក្រសួងសន្តិសុខសាធារណៈ ក្រសួងការពារជាតិ និងតាមមូលដ្ឋាន ជាពិសេសនៅតាមព្រំដែនកម្ពុជា ក៏ដូចជាអាជ្ញាធរកម្ពុជា ដើម្បី ផ្ទៀងផ្ទាត់ព័ត៌មាន និងអនុវត្តវិធានការការពារប្រជាពលរដ្ឋ។ លោកបន្តថា កម្លាំងជំនាញ និងបណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ ត្រូវបានបង្កើតឡើង ដើម្បីត្រៀមទទួលសំណើសុំជំនួយ និងជួយប្រជាពលរដ្ឋ ខណៈការព្រមានពាក់ព័ន្ធ ត្រូវបានបង្ហោះតាមគេហទំព័រ និងបណ្ដាញសង្គមផងដែរ។

លោកថាមិនទាន់មានចំនួនពិតប្រាកដនៃជនជាតិវៀតណាមដែលត្រូវបានបោកប្រាស់មកធ្វើការនៅកម្ពុជានោះទេ ដោយលោកបានបន្ថែមថា ភ្នាក់ងារតំណាងវៀតណាមបានសម្របសម្រួលក្នុងការជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តជនវៀតណាមប្រមាណ ៦០០ នាក់ ក៏ដូចជាផ្ដល់ជំនួយទាក់ទងនឹងនីតិវិធីច្បាប់សម្រាប់មនុស្សជាច្រើនទៀត។ លោក Vu បានសង្កត់ធ្ងន់ថា នាពេលខាងមុខ ភ្នាក់ងារតំណាងរបស់វៀតណាមប្រចាំនៅកម្ពុជានឹងបង្កើនការសម្របសម្រួលជាមួយក្រសួង ផ្នែកនានា និងអាជ្ញាធរមូលដ្ឋាន ដើម្បីបន្តការពារប្រជាពលរដ្ឋ និងកម្មករវៀតណាម។

លោកឧត្តមសេនីយ៍ទោ To An Xo ប្រធានការិយាល័យ និងជាអ្នកនាំពាក្យក្រសួងសន្តិសុខសាធារណៈបានមានប្រសាសន៍ថា ក្រសួងបានដឹកនាំនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នាយកដ្ឋាននគរបាលគ្រប់គ្រងរដ្ឋបាលសណ្ដាប់ធ្នាប់សង្គម និងនាយកដ្ឋានសន្តិសុខតាមអ៊ីនធឺណិត និងនគរបាលតាមមូលដ្ឋាន ជាពិសេសអ្នកជាប់ព្រំដែនកម្ពុជា ដើម្បីសម្របសម្រួលជាមួយកម្លាំងការពារព្រំដែន ដើម្បីស៊ើបអង្កេត និងផ្ទៀងផ្ទាត់បណ្ដាញជួញដូរមនុស្សពីវៀតណាមមកកម្ពុជា។លោកកត់សម្គាល់ថា ការស៊ើបអង្កេតដំបូងបានទទួលលទ្ធផលល្អ។ *VNA*

# ម្សិលមិញ សមត្ថកិច្ចបន្តសង្គ្រោះ២ករណីទៀត ទាក់ទងនឹងការស្នើអន្តរាគមន៍លើករណីបង្ខាំង និងជួញដូរពលកម្ម នៅខេត្តព្រះសីហនុ

http://freshnewsasia.com/index.php/en/localnews/256440-2022-09-07-06-15-25.html 2022-09-07 01:15pm

**(ភ្នំពេញ)៖** នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញនេះ សមត្ថកិច្ចចុះត្រួតពិនិត្យតាមពាក្យបណ្ដឹងចំនួន២ករណីទៀត ដែលអះអាងថា មានការបង្ខាំង និងជួញដូរពលកម្ម នៅខេត្តព្រះសីហនុ ដោយក្នុងនោះរកឃើញជនបរទេស៣នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃបានបញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២។ ការចុះស្រាវជ្រាវនេះ បានធ្វើឡើងបន្ទាប់ពីមានបណ្ដឹង តាមទំព័រទំព័រហ្វេសបុក សម្ដេចក្រឡាហោម ដើម្បីសុំឲ្យមានការអន្តរាគមន៍សុំឲ្យជួយសង្គ្រោះជនបរទេស ដោយអះអាងថា បានក្រុមហ៊ុនចាប់បង្ខាំង ដើម្បីឲ្យនៅបំរើការងារនៅខេត្តព្រះសីហនុ។

* **ករណីទី១** បានប្រតិបត្តិការ វេលាម៉ោង ១០៖៥០នាទី ដោយសមត្ថកិច្ចបានចុះមកដល់ទីតាំងក្រុមហ៊ុនមួយកន្លែង ឈ្មោះ ខៃ ប៉ (ឆាយណាថោន) ស្ថិតនៅ ភូមិ៦ សង្កាត់៤ ក្រុងព្រះសីហនុ។ ដោយមានការសហការពីម្ចាស់ទីតាំង សមត្ថកិច្ចបានរកឃើញបុរសជនជាតិចិនតៃវ៉ាន់ម្នាក់ ឈ្មោះ LEE CHIEN HUI អាយុ ៣៤ឆ្នាំ។

ក្នុងការសាកសួរ ឈ្មោះ LEE CHIEN HUI បានឲ្យដឹងថា គាត់បានចូលមកប្រទេសកម្ពុជា នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២ តាមជើងយន្តហោះចុះនៅព្រលានអន្តរជាតិភ្នំពេញ ហើយក្រុមហ៊ុនបានដឹកមកធ្វើការនៅក្រុមហ៊ុនជីនស៊ួយ ផ្នែកទំនាក់ទំនងភ្ញៀវនិងរកបុគ្គលយកមកធ្វើការ។ គាត់ទទួលបានប្រាក់ខែ ១៥០០ដុល្លាក្នុង១ខែ រហូតដល់ខែមិថុនា ឆ្នាំ២០២២ ក្រុមហ៊ុនដដែលបានដូរទីតាំងមកជួលអាគារ G២ ក្នុងក្រុមហ៊ុន ខៃប៉ ធ្វើការវិញ។

នៅកន្លែងធ្វើការក្នុងក្រុមហ៊ុន ពុំមានអ្នកណាបង្ខាំង ឬធ្វើទារុណកម្មអ្វីមកលើរូបកាយគាត់ទេ គ្រាន់តែបិទសិទ្ធិមិនឲ្យចេញក្រៅបរិវេណអាគារ ក៏ប៉ុន្តែក្រុមហ៊ុនបានអនុញ្ញាតឲ្យដើរសេរីក្នុងបរិវេណក្រុមហ៊ុន។ តាមការបញ្ជាក់ពី ឈ្មោះ LEE CHIEN HUI ខាងលើ ថាគាត់ពុំបានប្ដឹងសមត្ថកិច្ចទេ ហើយក៏ពុំបានដឹងថាអ្នកណាជាអ្នកប្ដឹងដែរ ដោយគាត់ធ្វើការក្នុងក្រុមហ៊ុននេះស្រួលមិនបញ្ហាអ្វីសម្រាប់គាត់ទេ និងទទួលបានប្រាក់ខែខ្ពស់ទៀត។ គាត់មានលិខិតឆ្លងដែន និងទិដ្ឋាការត្រឹមត្រូវ។

* **ករណីទី២** គឺសមត្ថកិច្ចបានចុះពិនិត្យនៅក្រុមហ៊ុន ស៊ីនហ័រខឺ ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុងព្រះសីហនុ រកឃើញជនជាតិចិន២នាក់ ហើយពុំឃើញមានសម្ភារណាមួយពាក់ព័ន្ធបទល្មើស បង្ខាំង និងទារុណកម្មឡើយ និងហៅអ្នកគ្រប់គ្រង មកសួរបំភ្លឺនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដើម្បីបន្តនីតិវិធី។

បើតាមលទ្ធផលនៃការសាកសួរ ឈ្មោះ LI CHUNXIA ភេទស្រី និងឈ្មោះ ZHANG YUNKAI ភេទប្រុស បានឲ្យដឹងថា នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ ពួកគាត់ជិះយន្តហោះពីខេត្តគ័ងចូវ ប្រទេសចិន មកកាន់ព្រលានយន្តហោះអន្តរជាតិភ្នំពេញធ្វើចត្តាឡីស័ក១៤ថ្ងៃ ហើយបានចូលធ្វើការងារនៅក្រុមហ៊ុនមួយកន្លែងមិនចាំនៅខេត្តកំពត។ បន្ទាប់មកក្រុមហ៊ុនបានផ្លាស់ប្ដូរឲ្យពួកគាត់ធ្វើការជាច្រើនកន្លែង រហូតដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ បានប្ដូរពួកគាត់មកក្រុមហ៊ុន ស៊ីហ័រខឺ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ជាបុគ្គលិកកុំព្យូទ័រ ធ្វើការរយៈពេល ១៣ម៉ោងក្នុងមួយថ្ងៃ ទទួលប្រាក់ចំនួន ១,៣០០ដុល្លារ បើកទៀងទាត់ មិនការបង្ខាំងនិងធ្វើទារុណកម្មឡើយ។

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ ដោយទ្រាំធ្វើការងារច្រើនម៉ោងមិនបាន និងចង់ត្រលប់ទៅស្រុកកំណើតវិញ ពួកគាត់បានទាក់ទងសមាគមន៍ចិន ហើយគេឲ្យពួកគាត់ទាក់ទងបន្តទៅតេលេក្រាមលេខៈ 011546677 ជនជាតិខ្មែរចេះភាសាចិន ដើម្បីប្ដឹង លុះដល់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ មានសមត្ថកិច្ចមកដល់ជួយពួកគាត់តែម្ដង៕

## រដ្ឋមន្ត្រី វង សូត ស្នើឲ្យក្រុមការងារពន្លឿនការសាងសង់មជ្ឈមណ្ឌលសំចត និងស្ថានីតិសម្បទាជនរងគ្រោះ ប៉ោយប៉ែត ឲ្យបានឆាប់តាមការកំណត់

https://freshnewsasia.com/index.php/en/localnews/256447-2022-09-07-07-25-16.html 2022-09-07 02:25pm

**(បន្ទាយមានជ័យ)៖** លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានស្នើមន្ត្រីពាក់ព័ន្ធបន្តសហការគ្នានិងពន្លឿនការសាងសង់ឲ្យបានឆាប់រហ័សតាមកិច្ចព្រមព្រៀង ដែលបានកំណត់ ដើម្បីផ្តល់សេវាដល់ជូនជនរងគ្រោះ និងមានទីកន្លែងស្នាក់នៅបណ្ដោះអាសន្នសមរម្យ មុនបញ្ជូនទៅសហគមន៍វិញ។ ការស្នើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច បានធ្វើឡើងខណៈលោក អញ្ជើញចុះពិនិត្យដំណើរការសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះ ប៉ោយប៉ែត ដែលស្ថិតក្នុងភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២។ លោក វង សូត បានបន្ថែមថា នេះសមិទ្ធផលថ្មីមួយទៀត ដែលបានបង្ហាញពីកិច្ចសហប្រតិបត្តិការដ៏ល្អ រវាងប្រទេសទាំងពីរកម្ពុជា-ថៃ ដែលផ្តោតសំខាន់លើសុខុមាលភាពជនរងគ្រោះ និងងាយរងគ្រោះ។ លើសពីនេះ ក្រោមកិច្ចសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ មជ្ឈមណ្ឌលនេះ នឹងទទួលជនរងគ្រោះដែលធ្វើចំណាកស្រុកដោយប្រថុយប្រថានត្រលប់មកពីប្រទេសថៃ ផ្តល់ការហូបចុក ការស្នាក់នៅ បណ្ដុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅសហគមន៍វិញ ។

សូមបញ្ជាក់ថា មជ្ឈមណ្ឌលសំចត និងស្ថានីតិសម្បទាជនរងគ្រោះ ប៉ោយប៉ែត ចាប់ផ្តើមកសាងនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ នឹងគ្រោងបញ្ចប់នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ លើផ្ទៃដីទំហំ ៩,៧៦៨ ម៉ែត្រការ៉េ ដែលក្នុងនោះរួមមាន៖ អគារសម្រាប់ទទួលជនរងគ្រោះចំនួន ២ខ្នង (អគារសម្រាប់បុរស១ខ្នង និងនារី១ខ្នង), អគាររដ្ឋបាល ១ខ្នង, អគារអាហារដ្ឋាន ១ខ្នង និងអគារសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈរួមចំនួន ១ខ្នង ដែលថវិកានេះបានមកពីជំនួយរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់សរុបចំនួន ១,៤៥៩,៥៥៣ ដុល្លារសហរដ្ឋអាមេរិច ហើយគ្រោងនឹងដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការនាចុងឆ្នាំ២០២៣ ខាងមុខនេះ៕

## ហ្វេសប៊ុកសម្តេចក្រឡាហោម ស ខេង ទទួលបានពាក្យបណ្តឹងចំនួន១២៥ ទាក់ទងនឹងការស្នើអន្តរាគមន៍លើករណីបង្ខាំង និងជួញដូរពលកម្ម

http://freshnewsasia.com/index.php/en/localnews/256500-2022-09-07-10-46-02.html 2022-09-07 05:46pm

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា រហូតមកដល់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញនេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានទទួលពាក់បណ្តឹងសរុបចំនួន ១២៥បណ្តឹង ហើយ តាមរយៈទំព័រហ្វេសប៊ុករបស់សម្តេច។ លោកបានបញ្ជាក់ថា បណ្តឹងទាំង ១២៥នោះ គឺពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ជួយសង្គ្រោះជនបរទេស ដែលត្រូវបានអះអាងថាបង្ខាំង និងជួញដូរកម្លាំងពលកម្ម នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីសម្តេចបានអំពាវនាវឱ្យភាគីទាំងអស់ រួមទាំងបរទេសផងដែរ សហការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងករណីទាំងនេះ។ បើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ សរុបពាក្យបណ្តឹងទាំង ១២៥នេះ គឺចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់ សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្តេចក្រឡាហោម បានសម្តែងការសោកស្តាយ និងថ្កោលទោសចំពោះអំពើដ៏អមនុស្សធម៌ទាំងនេះ។ សម្តេចក៏បានថ្លែងអំណរគុណ និងស្វាគមន៍ចំពោះការផ្តល់ព័ត៌មានផ្សេងៗ ពីសំណាក់បុគ្គល និងស្ថានតំណាងបរទេសប្រចាំកម្ពុជា នាពេលកន្លងមកពាក់ព័ន្ធទៅនឹងករណីខាងលើនេះ។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះផងដែរ៕

# បុរស២នាក់ចោទក្រុមហ៊ុននាំពលករស្របច្បាប់មួយថា «សន្យាហើយមិនទទួលខុសត្រូវ»

https://kohsantepheapdaily.com.kh/article/1594892.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ០៨ ខែ កញ្ញា ឆ្នាំ ២០២២ ម៉ោង ១០:២៧

ខេត្តបន្ទាយមានជ័យ ៖ បុរស២នាក់បានស្គាត់រកអ្នកយកព័ត៌មានតាមដងផ្លូវដោយរៀបរាប់ថាពួកខ្លួនបានចំណាយប្រាក់ម្នាក់អស់២០០ដុល្លារ ព្រោះចង់ទៅធ្វើការស្របច្បាប់លើទឹកដីថៃដឹងអីក្រុមហ៊ុននាំពលករស្របច្បាប់មួយបានត្រឹមតែសន្យា និងយកប្រាក់ហើយបែរជាមិនទទួលខុសត្រូវទៅវិញ។

បុរសទាំង២នាក់ខាងលើ ម្នាក់ឈ្មោះសម ឌីណែត អាយុ៣២ឆ្នាំ រស់នៅក្នុងភូមិចាន់គិរី សង្កាត់ប៉ោយប៉ែត និងម្នាក់ឈ្មោះតាំង ពៅ អាយុ៤០ឆ្នាំ រស់នៅក្នុងភូមិព្រៃព្រិច សង្កាត់អូរជ្រៅ ក្រុងប៉ោយប៉ែត។ បុរសទាំង២នាក់ប្រាប់កោះសន្តិភាពថា ក្នុងអំឡុងខែឧសភា ២០២២ ពួកខ្លួនត្រូវបានស្ត្រីម្នាក់ឈ្មោះភា ជាបុគ្គលិកក្រុមហ៊ុននាំពលករស្របច្បាប់ «ក្រុមហ៊ុនព្រីមៀមមេនផៅវ័រសឺវីសឯ.ក» មានការិយាល័យនៅខាងជើងឈាងខាងលិចសាលាក្រុងប៉ោយប៉ែត ជាប់ផ្លូវជាតិលេខ៥ ស្ថិតក្នុងភូមិគីឡូម៉ែត្រលេខ៤ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ណែនាំឲ្យធ្វើលិខិតឆ្លងដែនដើម្បីបានចេញទៅធ្វើការនៅប្រទេសថៃ ផ្នែកអេឡិចត្រូនិច។ បុរសទាំង២នាក់បន្តថា លុះស្ដាប់កាណែនាំពីរបៀបបំពេញឯកសារ និងពីច្បាប់ការងារនៅក្នុងប្រទេសថៃនៅសាខាក្រុមហ៊ុនខាងលើរួច ឈ្មោះផាន ភេទប្រុស ជាបុគ្គលិកក្រុមហ៊ុនក៏នាំពួកខ្លួនទៅកាន់ការិយាល័យធ្វើលិខិតឆ្លងដែន ក្នុងភូមិនិងសង្កាត់ផ្សារកណ្ដាល។

ពួកគាត់បន្តថា ក្រោយធ្វើលិខិតឆ្លងដែនរួចខាងក្រុមហ៊ុនប្រាប់ឲ្យរងចាំរយៈពេលយ៉ាងយូរ២ខែទើបបានចេញដំណើរតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតទៅធ្វើការនៅប្រទេសថៃ។ បុរសទាំង២នាក់បន្តទៀតថា លុះដល់រយៈពេលកំណត់ពួកខ្លួនទៅសួរនាំរឿងចេញដំណើរទៅប្រទេសថៃបែរជាខាងក្រុមហ៊ុននិយាយថា ឥឡូវក្រុមហ៊ុនប្ដូរគោលការណ៍ហើយ គឺមិនទៅកាត់ប្រាក់ធ្វើការម្នាក់១៨.០០០បាតនៅប្រទេសថៃ ដូចគម្រោងពីមុនឡើយពេល គឺបើចង់ទៅត្រូវបង់ប្រាក់ម្នាក់១៨០០០បាតនៅដីខ្មែរជាមុនសិន។ បុរសទាំង២នាក់បន្តថា បើខាងក្រុមហ៊ុនណែនាំឲ្យច្បាស់លាស់ពួកខ្លួន ក៏មិនចំណាយប្រាក់ម្នាក់២០០ដុល្លារដែរ ។ មិនតែប៉ុណ្ណោះខាងក្រុមហ៊ុនឲ្យពួកខ្លួនឡើងទៅដកលិខិតឆ្លងដែនវិញបើមិនព្រមបង់ប្រាក់ម្នាក់១៨០០០បាត ដើម្បីចង់បន្តដំណើរទៅធ្វើការលើទឹកដីថៃ ។ ហើយពេលពួកខ្លួនទារប្រាក់ម្នាក់២០០ដុល្លារវិញ បែរជាខាងក្រុមមិនទទួលខុសត្រូវ និងរុញដាក់គ្នាពីម្នាក់ទៅម្នាក់និងនិយាយថាបុគ្គលឹកចាស់ៗទៅអស់ហើយនៅតែពួកខ្លួនជាអ្នកថ្មីមិនដឹងអីទេ។ឈ្មោះសម ឌីណែត និយាយថា ព្រោះតែចង់បំពេញបំណងកូនម្ដាយខ្លួនសុខចិត្តដោះក្រវិលពីត្រចៀកយកទៅលក់ ដើម្បីបានប្រាក់ឲ្យខ្លួនធ្វើលិខិតឆ្លងដែននិងទៅធ្វើការដោយស្របច្បាប់លើទឹកដីគេ ។

ជុំវិញករណីខាងលើលោក ស៊ន សារិន ប្រធានក្រុមហ៊ុនព្រីមៀមមេនផៅវ័រសឺវីសឯ.កបានបដិសេធថា លោកមិនបានដឹងរឿងរ៉ាវខាងលើទេ ដោយនិយាយថា ដរាបណាបុរសទាំង២នាក់ ហៅអ្នកពាក់ព័ន្ធទទួលឯកសារ ឬប្រាក់កន្លងមកជួបទើបដឹង។ ពេលសាកសួរបន្តថា តើក្រុមហ៊ុនរបស់លោកមានការិយាល័យនៅភូមិគីឡូម៉ែត្រលេខ៤ សង្កាត់កណ្ដាលក្រុងប៉ោយប៉ែត និងមានបុគ្គលិកប្រុសស្រីឈ្មោះភា ឬឈ្មោះផានដែរឬទេ? លោកទទួលស្គាល់ថាមានមែនហើយថា បុគ្គលិកប្រុសឈ្មោះផាន បានឈប់យូរហើយ ខណៈបុគ្គលិកស្រីឈ្មោះភា ត្រូវបានលោកដាក់ពាក្យបណ្ដឹងនៅប៉ុស្ដិ៍រដ្ឋបាលសង្កាត់ផ្សារកណ្ដាលដើម្បីស្រាវជ្រាវហៅសួរនាំ ព្រោះធ្វើការខុសលក្ខ័ណ្ឌរបស់ក្រុមហ៊ុនធ្វើឲ្យកើតមានបញ្ហា ៕

## រដ្ឋមន្ត្រីមហាផ្ទៃ ចាត់ទុកការជួញដូរមនុស្ស នៅកម្ពុជា មានអង្គការចាត់តាំង ព្រោះមេខ្លោងសុទ្ធតែបរទេស

https://dap-news.com/national/2022/09/08/277285/ ByDR103Posted on September 8, 2022

**ភ្នំពេញ៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចាត់ទុកករណីជួញដូរមនុស្សកើតមានឡើង នៅប្រទេសកម្ពុជា នារយៈពេលចុងក្រោយនេះ មានអង្គការចាត់តាំង ព្រោះមេខ្លោង និងអ្នកប្រព្រឹត្តបទល្មើសនេះ ស្ទើរតែសុទ្ធសឹង ជាជនបរទេសទាំងអស់។

ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវសមិទ្ធផលស្នងការដ្ឋាន នគរបាលរាជធានីភ្នំពេញ ស្ថិតនៅលើទីតាំងចាស់ នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ សម្តេច ស ខេង បានបញ្ជាក់ថា ប្រទេសកម្ពុជា បានក្លាយជាប្រទេសរងគ្រោះ ដោយសារតែការជួញដូរមនុស្ស ហើយករណីនេះ ត្រូវបានគេចាត់ទុកកម្ពុជា ចូលក្នុងបញ្ជីខ្មៅ និងប្រទេសជាប់លេខបី ដែលមានភាពប្រងើយកន្តើយ ក្នុងការទប់ស្កាត់បទល្មើសមួយនេះ។ សម្តេច បញ្ជាក់ថា «កម្ពុជាជាកន្លែងរងគ្រោះ ពីព្រោះអ្នកប្រព្រឹត្តិបទល្មើស ដែលជាមេខ្លោងនោះ ៩៩.៩៩ភាគរយ គឺមិនមែនខ្មែរ ហើយការរៀបចំមនុស្សចេញមកពី ប្រទេសខ្លួននោះ ក៏មិនមែនជាជនជាតិខ្មែរផងដែរ»។ សម្តេច បានបញ្ជាក់បន្ថែមទៀតថា មេខ្លោងនៃការជួញដូរមនុស្សនេះ គឺជាជនជាតិវៀតណាម ជនជាតិចិនតៃវ៉ាន់ ជនជាតិចិន ជនជាតិឥណ្ឌូនេស៊ី ជនជាតិម៉ាឡេស៊ី និងជនជាតិថៃដើម។

យ៉ាងណាក៏ដោយ សម្តេច ស ខេង បានធ្វើការអំពាវនាវ ដល់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវខិតខំរួមគ្នាឲ្យបានសកម្មបន្ថែមទៀត ក្នុងកិច្ចការទប់ស្កាត់នូវបទល្មើស នៃការជួញដូរមនុស្សនេះ ខណៈបទល្មើសនេះបានកំពុងកើតឡើង នៅលើទឹកដីកម្ពុជា គួរឲ្យព្រួយបារម្ភយ៉ាងខ្លាំងនោះ។ សម្តេច ស ខេង បន្ថែមថា មានបទល្មើសថ្មីមួយ លិចឡើងយ៉ាងសាហាវចុងក្រោយ នៅកម្ពុជា វាមិនមែនជាបទល្មើសប្រពៃណីទេ គឺបទល្មើសឆបោកតាមប្រព័ន្ធទូរគមនាគមន៍។ សម្តេច បញ្ជាក់ថា «ឥឡូវនេះមានបទល្មើសថ្មីមួយ ដែលលិចឡើងយ៉ាងសាហាវចុងក្រោយ នៅកម្ពុជារបស់យើងនេះ ដើម្បីខ្ញុំ យកឱកាសនេះបញ្ជាក់ វាមិនមែនជាបទល្មើសប្រព្រៃណីទេ បទល្មើសមុនប្រពៃណី នោះគឺបទល្មើសឆបោតាមប្រព័ន្ធទូរគមនាគមន៍ នេះហើយជាបញ្ហា កំពុងកើតមានសព្វថ្ងៃនេះ»។

សូមរំលឹកថា ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា បានរកឃើញ និងជួយសង្គ្រោះជនបរទេស បានចំនួន៨៧ករណី ស្មើនឹងប្រមាណ ៨៦៥នាក់ ព្រមទាំងបានកសាងសំណុំរឿងបញ្ជូនទៅ តុលាការចំនួន១៧ករណី ជនសង្ស័យសរុបចំនួន ៦០នាក់។ ដោយឡែក នាសប្តាហ៍ទី៤ ខែសីហា ឆ្នាំ២០២២ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា បានបើកកិច្ចប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះ សរុបចំនួន ០៧ករណី ដោយបានសង្គ្រោះជនរងគ្រោះ សរុបចំនួន ២៥នាក់ (មាន ៦ សញ្ជាតិ) និងឃាត់ខ្លួនជនសង្ស័យ សរុបចំនួន ២៣នាក់ (មាន ៤ សញ្ជាតិ) នៅក្នុងខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តឧត្តរមានជ័យ៕

## សម្តេចក្រឡាហោម ស ខេង ៖ កម្ពុជាជាប្រទេសរងគ្រោះ ក្រោយពីមេខ្លោងជួញដូរមនុស្ស យកកម្ពុជា ធ្វើជាទីកន្លែងប្រព្រឹត្តិបទល្មើស

https://www.information.gov.kh/articles/85766 ចេញផ្សាយ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២២

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងឱ្យដឹងថា កម្ពុជា ជាប្រទេសរងគ្រោះ ក្រោយពីមេខ្លោងជួញដូរមនុស្សតាមប្រព័ន្ធទូរគមនាគមន៍ កំពុងយកកម្ពុជាធ្វើជាទីកន្លែងប្រព្រឹត្តិបទល្មើសជួញដូរមនុស្ស។ ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវសមិទ្ធផលស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ស្ថិតនៅលើទីតាំងចាស់ ក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ សម្តេចក្រឡាហោម ស ខេង

មានប្រសាសន៍ថា «ជនល្មើសជាមេខ្លោងជួញដូរមនុស្ស តាមប្រព័ន្ធទូរគមនាគមន៍នេះ កំពុងយកកម្ពុជា ដើម្បីទីកន្លែងប្រព្រឹត្តិបទល្មើសនោះ ចឹងកម្ពុជាយើង ជាទីកន្លែងរងគ្រោះ ពីព្រោះអ្នកប្រព្រឹត្តិបទល្មើសដែលជាមេខ្លោងនោះ ៩៩.៩៩ភាគរយ គឺមិនមែនខ្មែរ ហើយមេខ្យល់ ដែលរៀបចំបញ្ជូនមនុស្សចេញពីប្រទេសរបស់ខ្លួននោះ ក៏មិនមែនជាជនជាតិខ្មែរដែរ។ សម្ដេចក្រឡាហោម បន្តថា ចំពោះបទល្មើសឆបោកតាមប្រព័ន្ធទូរគមនាគមន៍ នៅរាជធានីភ្នំពេញ សម្ដេច ក៏បានទទួលពាក្យបណ្ដឹងចំនួន២ ហើយសមត្ថកិច្ចបានធ្វើការស្រាវជ្រាវ ហើយបញ្ជូលជនរងគ្រោះទាំងនោះត្រឡប់ទៅប្រទេសដើមវិញផងដែរ។

សម្ដេចក្រឡាហោម បញ្ជាក់បន្ថែមថា «ឥឡូវនេះ មានបទល្មើសថ្មីមួយ ដែលលិចឡើងយ៉ាងសាហាវចុងក្រោយ នៅកម្ពុជារបស់យើងនេះ។ ខ្ញុំ យកឱកាសនេះបញ្ជាក់ថា វាមិនមែនជាបទល្មើសប្រពៃណីទេ ជាបទល្មើសមុនប្រពៃណី នោះគឺបទល្មើសឆបោកតាមប្រព័ន្ធទូរគមនាគមន៍ ហើយជាបញ្ហាកំពុងកើតមានសព្វថ្ងៃនេះ»។ លើសពីនេះ សម្ដេចក្រឡាហោម ស ខេង ក៏បានរៀបរាប់ថា មេខ្លោង នៃការជួញដូរមនុស្សនេះ គឺជាជនជាតិវៀតណាម ជនជាតិចិនតៃវ៉ាន់ ជនជាតិចិន ជនជាតិឥណ្ឌូនេស៊ី ជនជាតិម៉ាឡេស៊ី និងជនជាតិថៃ ជាដើម។ យ៉ាងណាក៏ដោយ សម្ដេច ក៏បានធ្វើការអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវខិតខំរួមគ្នាឱ្យបានសកម្មបន្ថែមទៀត ក្នុងកិច្ចការទប់ស្កាត់នូវបទល្មើស នៃការជួញដូរមនុស្សនេះ ខណៈបទល្មើសនេះបានកំពុងកើតឡើងនៅលើទឹកដីកម្ពុជា គួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងនោះ៕ សម្រួលផ្សាយ៖ កន ចំណាន, ប្រផព ៖ នាយកដ្ឋានព័ត៌មានវិទ្យានៃក្រសួងមហាផ្ទៃ

## ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២

### រាជរដ្ឋាភិបាល ដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ឱ្យរដ្ឋបាលរាជធានី-ខេត្ត បើកយុទ្ធនាការបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន និងការជួញដូរមនុស្ស

https://cen.com.kh/archives/528264.html Posted ByPen Srey NeatSeptember 10, 2022

ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ឱ្យគ្រប់រដ្ឋបាលរាជធានី ខេត្ត និងមូលដ្ឋានទាំងអស់ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការ ប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរ និងរត់ពន្ធមនុស្ស ពលកម្ម បង្ខិតបង្ខំ និងអាជីវកម្មផ្លូវភេទ ឱ្យមានប្រសិទ្ធភាព។ បទបញ្ជានេះត្រូវបានដាក់ចេញនៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពរបស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា នាព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២នេះ។ រាជរដ្ឋាភិបាលដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ឱ្យគ្រប់រដ្ឋបាលរាជធានី ខេត្ត និងមូលដ្ឋាន ទាំងអស់ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការប្រយុទ្ធប្រឆាំងនិងបង្ក្រាប ឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរនិងរត់ពន្ធមនុស្ស ពលកម្មបង្ខិតបង្ខំ និងអាជីវកម្មផ្លូវភេទ ដែលបាន និងកំពុងកើតឡើងលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឱ្យមានប្រសិទ្ធភាព។

ការដាក់បទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា បានធ្វើចំពេលដែលគេសង្កេតឃើញថា ឧក្រិដ្ឋកម្មគ្រឿងញៀនហាក់បានកម្រើកឡើងនៅក្នុងប្រទេសកម្ពុជា។ ក្នុងនោះការជួញដូរធំៗ ព្រមទាំងកន្លែងផលិតគ្រឿងញៀនជាច្រើនកន្លែងត្រូវបានអាជ្ញាធរបង្ក្រាបបានជាបន្តបន្ទាប់។ការជួញដូរ ការរត់ពន្ធមនុស្ស ពលកម្មបង្ខិតបង្ខំជាដើម ក៏ត្រូវបានរកឃើញថា ក្លាយជាបញ្ហាក្ដៅនៅកម្ពុជាផងដែរ រហូតដល់សហរដ្ឋអាមេរិកទម្លាក់ចំណាត់ថ្នាក់របស់កម្ពុជាថែមទៀតផង។ ក្នុងមួយរយៈពេលចុងក្រោយនេះ ក្រសួងមហាផ្ទៃ ក៏បានបើកយុទ្ធនាការបោសសំអាតការជួយញដូរមនុស្ស ការបង្ខាំងមនុស្សបង្ខំឱ្យធ្វើការបានជាច្រើនករណីផងដែរ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

# សម្តេច ស ខេង៖ ការដាក់កម្ពុជាចូល «បញ្ជីប្រផេះ» និងការទម្លាក់ចំណាត់ថ្នាក់ទី៣ នៃការជួញដូរមនុស្ស ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់មុខមាត់កម្ពុជា ដែលទាមទារឱ្យចូលរួមទប់ស្កាត់ទាន់ពេលវេលា

http://freshnewsasia.com/index.php/en/localnews/256592-2022-09-08-08-43-46.html 2022-09-08 03:43pm

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ថា បញ្ហាចំនួន២ គឺការដាក់កម្ពុជា ឱ្យស្ថិតក្នុង «បញ្ជីប្រផេះ» នៃក្រុមប្រទេស ដែលមានហានិភ័យខាងលាងលុយកខ្វក់ និងការទម្លាក់កម្ពុជាទៅក្នុងចំណាត់ថ្នាក់ទី៣ ឬបញ្ជីខ្មៅ នៃការជួញដូរមនុស្សឆ្នាំ២០២២ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងលើមុខមាត់កម្ពុជា។ ការបញ្ជាក់បែបនេះរបស់សម្តេចក្រឡាហោម ស ខេង បានធ្វើឡើងនៅក្នុងឱកាសដែលសម្តេចអញ្ជើញជាអធិបតីភាពសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគាររដ្ឋបាលកម្ពស់១០ជាន់ និងអគារសាលប្រជុំកម្ពស់៣ជាន់ របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២នេះ។

សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់យ៉ាងដូច្នេះថា៖ «**មានបញ្ហា២ របស់យើងសព្វថ្ងៃនេះ សម្រាប់មុខមាត់មុខមាត់ប្រទេសជាតិ ទី១៖ ការចាត់កម្ពុជាទៅក្នុងបញ្ជីប្រផេះ នៅក្នុងវិស័យធនាគារ ដោយគេចាត់ទុកថា ការចរាចរណ៍លុយនៅស្រុកខ្មែរ វាខ្មៅ យើងមិនមែនគាំទ្រការវាយតម្លៃនោះទេ តែយើងក៏មិនអាចបដិសេធ យើងត្រូវតែមើលឱ្យបានច្បាស់ថា មានករណីនេះអត់? ទី២៖ ការទម្លាក់កម្ពុជា ទៅក្នុងចំណាត់ថ្នាក់ទី៣ ឬបញ្ជីខ្មៅ នៃការជួញដូរមនុស្ស**»។ សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា ប្រសិនបើមិនខិតខំប្រឹងប្រែងរំដោះកម្ពុជា ឱ្យចេញពីបញ្ជីប្រផេះនោះទេ វាអាចនឹងថ្ងៃណាមួយត្រូវបានទម្លាក់ចូលក្នុងបញ្ជីខ្មៅ នៃការចរាចរណ៍លុយបន្ថែមទៀត ដែលអាចធ្វើការប្រើថវិកាទាំងរដ្ឋ និងឯកជនមានការលំបាក។

ជាមួយគ្នានេះសម្តេចក្រឡាហោម ស ខេង ក៏បានបញ្ជាក់ថា រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន បានបង្កើតគណៈកម្មាធិការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម បាននឹងកំពុងខិតខំប្រឹងដើម្បីដោះស្រាយបញ្ហាទាំងនេះជាដើម។ សម្តេចក្រឡាហោម ស ខេង បានសង្កត់ធ្ងន់ថា៖ «**កាល២សប្តាហ៍មុន សមត្ថកិច្ចកម្ពុជាចាប់ជនជាតិចិនជាង៣០នាក់ ដែលធ្វើដំណើរតាមទូកពីប្រទេសចិន ឆ្លងកាត់តាមប្រទេសវៀតណាម ចូលមកកំពង់សោម ខេត្តព្រះសីហនុ ដែលគ្មានឯកសារអ្វីបន្តិចជាប់នឹងខ្លួន**»។ ជុំវិញបញ្ហាទាំង២ ចំណុចនេះ សម្តេចក្រឡាហោម ស ខេង បានអំពាវនាវឱ្យមានចូលរួមគាំទ្រឱ្យកាន់ខ្លាំងក្លាយបន្ថែមទៀត ពីសំណាក់ក្រសួង ស្ថាប័នពាក់នានា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំង២ ខាងលើនេះ ឱ្យកាន់តែមានប្រសិទ្ធខ្ពស់។

សូមជម្រាបថា ក្រុមការងារហិរញ្ញវត្ថុ ហៅកាត់ថា (FATF) ដែលមានមូលដ្ឋាននៅទីក្រុងប៉ារីស កាលពីថ្ងៃទី៤ ខែមីនា បានសម្រេចបន្តដាក់កម្ពុជាឱ្យស្ថិតក្នុង «បញ្ជីប្រផេះ» នៃក្រុមប្រទេសដែលមានហានិភ័យខាងលាងលុយកខ្វក់ដែលពិភពលោកត្រូវបង្កើនការតាមដានក្នុងឆ្នាំនេះ។

កាលពីឆ្នាំ២០២០ សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬការលាងលុយកខ្វក់ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីកម្ពុជា។ វិស័យដែលរងហានិភ័យខ្ពស់ខាងអំពើលាងលុយកខ្វក់នៅកម្ពុជា រួមមាន៖ វិស័យធនាគារ ហិរញ្ញវត្ថុ វិស័យសំណង់ អចលនទ្រព្យ និងវិស័យកាស៊ីណូ។ បើយោងតាមរបាយការណ៍ចុងក្រោយរបស់ក្រសួងមហាផ្ទៃ បង្ហាញថា ក្នុងរយៈ៦ខែដើមឆ្នាំ២០២២នេះ អាត្រាជួញដូរមនុស្សនៅកម្ពុជាមានការថយចុះច្រើនបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំទៅ៕

## សម្តេចក្រឡាហោមៈ
## កម្ពុជាក្លាយជាប្រទេសរងគ្រោះក្នុងអំពើជួញដូរមនុស្សតាមប្រព័ន្ធទូរគមនាគមន៍

https://www.kampucheathmey.com/local-news/370209 ថ្ងៃព្រហស្បតិ៍ ៨ កញ្ញា ២០២២ដោយ Sokhom Khon

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានឱ្យដឹងថា កម្ពុជា ជាប្រទេសរងគ្រោះ ក្រោយពីមេខ្លោងជួញដូរមនុស្សតាមប្រព័ន្ធទូរគមនាគមន៍ យកកម្ពុជាធ្វើជាទីកន្លែងប្រព្រឹត្តិបទល្មើសជួញដូរមនុស្ស។ សម្តេចក្រឡាហោម បានមានប្រសាសន៍បែបនេះ ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសមិទ្ធផលស្នងការដ្ឋាន នគរបាលរាជធានីភ្នំពេញ ស្ថិតនៅលើទីតាំងចាស់ ក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២។ សម្តេចក្រឡាហោម បានបន្តថា «ជនល្មើសជាមេខ្លោងជួញដូរមនុស្សតាមប្រព័ន្ធទូរគមនាគមន៍នេះ កំពុងយកកម្ពុជា ដើម្បីទីកន្លែងប្រព្រឹត្តិបទល្មើសនោះ ចឹងកម្ពុជាយើង ជាទីកន្លែងរងគ្រោះ ពីព្រោះអ្នកប្រព្រឹត្តិបទល្មើសដែលជាមេខ្លោងនោះ ៩៩.៩៩ភាគរយ គឺមិនមែនខ្មែរ ហើយមេខ្យល់ដែលរៀបចំបញ្ជូនមនុស្សចេញពីប្រទេសរបស់ខ្លួននោះក៏មិនមែនជាជនជាតិខ្មែរដែរ»។

សម្តេចក្រឡាហោម បានបន្តថា មេខ្លោងនៃការជួញដូរមនុស្សនេះ គឺជាជនជាតិវៀតណាម ជនជាតិចិនតៃវ៉ាន់ ជនជាតិ ចិន ជនជាតិឥណ្ឌូនេស៊ី ជនជាតិម៉ាឡេស៊ី និងជនជាតិថៃ ជាដើម។ សម្តេចក្រឡាហោម បានបន្តទៀតថា ថ្មីៗនេះសម្តេច ក៏បានទទួលពាក្យបណ្តឹងចំនួន២បទល្មើសឆបោកតាមប្រព័ន្ធទូរគមនាគមន៍ នៅរាជធានីភ្នំពេញ ហើយសមត្ថកិច្ចបានធ្វើការស្រាវជ្រាវ ហើយបញ្ជូនជនរងគ្រោះទាំងនោះត្រឡប់ទៅប្រទេសដើមវិញផងដែរ។ សម្តេចក្រឡាហោម បានបន្តទៀតថា «ឥឡូវនេះ មានបទល្មើសថ្មីមួយដែលលិចឡើងយ៉ាងសាហាវចុងក្រោយនៅកម្ពុជារបស់យើងនេះ។ ខ្ញុំយកឱកាសនេះបញ្ជាក់ថា វាមិនមែនជាបទល្មើសប្រពៃណីទេ ជាបទល្មើសមុនប្រពៃណី នោះគឺបទល្មើសឆបោកតាមប្រព័ន្ធទូរគមនាគមន៍ ហើយជាបញ្ហាកំពុងកើតមានសព្វថ្ងៃនេះ»។ សម្តេចក្រឡាហោមបានធ្វើការអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ត្រូវខិតខំរួមគ្នាឱ្យបានសកម្មបន្ថែមទៀត ក្នុងកិច្ចការទប់ស្កាត់នូវបទល្មើសនៃការជួញដូរមនុស្សនេះ ខណៈបទល្មើសនេះបានកំពុងកើតឡើងនៅលើទឹកដីកម្ពុជាគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងនោះ៕ អត្ថបទ៖ សំអឿន

## អ្នកនាំពាក្យមហាផ្ទៃៈ
## បទល្មើសជួញដូរមនុស្ស ភាគច្រើនកើតនៅតាមកាស៊ីណូ និងទីតាំងល្បែងអនឡាញ

https://btv.com.kh/article/15164 2022/09/09 12:13:51 pm

ភ្នំពេញ៖ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ ថ្លែងថា ក្នុងយុទ្ធនាការប្រឆាំងបទល្មើសការជួញដូរមនុស្ស ភាគច្រើនធ្វើឡើងនៅតាមកាស៊ីណូ និងទីតាំងល្បែងអនឡាញ។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានថ្លែងប្រាប់ BTV នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២នេះ ថា អនុវត្តតាមប្រសាសន៍របស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ថាប័នពាក់ព័ន្ធកំពុងបន្តកិច្ចការយ៉ាងសកម្ម ក្នុងយុទ្ធនាការប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមរយៈក្រុមប្រតិបត្តិការត្រួតពិនិត្យការស្នាក់នៅរបស់ជនបរទេស។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បន្តថា ក្នុងប្រតិបត្តិការត្រួតពិនិត្យជនបរទេស មានគោលដៅចំនួន៣ រួមមាន ទី១ប្រតិបត្តិការត្រួតពិនិត្យដើម្បីជួយជនរងគ្រោះ ពីការជួញដូរមនុស្ស ទី២ ផ្តន្ទាទោសជនល្មើសដែលពាក់ព័ន្ធករណីជួញដូរមនុស្ស និងទី៣ ស្រាវជ្រាវករណីបង្ខាំងមនុស្សដែលឈានទៅទប់ស្កាត់ការលាងសម្អាតប្រាក់។

យ៉ាងណាមិញ ក្នុងយុទ្ធនាការប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បញ្ជាក់ថា អំឡុងយុទ្ធនាការប្រឆាំងការជួញដូរមនុស្ស និងតាមរយៈបណ្ដឹងរបស់គ្រួសារ ឬសាច់ញាតិជនរងគ្រោះ ភាគច្រើនករណីជួញដូរមនុស្សកើតមាននៅតាមកាស៊ីណូ និងទីតាំងបទល្មើសអនឡាញ។ ជាមួយគ្នានេះ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បញ្ជាក់ទៀថា តាមរយៈបណ្ដឹងពីគ្រួសារ និងសាច់ញាតិដែលបានប្ដឹងមកក្រសួងមហាផ្ទៃកន្លងមកពាក់ព័ន្ធនឹងការបង្ខាំងមនុស្ស ដូចនេះក្រុមប្រតិបត្តិការត្រួតពិនិត្យជនបរទេសពាក់ព័ន្ធការជួញដូរមនុស្ស បន្តត្រួតពិនិត្យរាល់ការស្នាក់នៅរបស់ជនបរទេស សំដៅស្វែងរកឯកសារដូចជា លិខិតឆ្លងដែន ទិដ្ឋាការ សៀវភៅការងារជាដើម។ គិតមកទល់ពេលនេះ បន្ទាប់ពីមានបទបញ្ជាក្រុមប្រតិបត្តិការចុះឆែកឆេរជនបរទេសនៅតាមសណ្ឋាគារ កាស៊ីណូ និងកន្លែងមួយចំនួនទៀត សមត្ថកិច្ចបានឃាត់ខ្លួនមេការ និងមេខ្លោងជួញដូរមនុស្សបានមួយចំនួន ដើម្បីយកមកផ្ដន្ទាទោសទៅតាមច្បាប់ផងដែរ៕អត្ថបទ សេក ឧត្តម

## កម្ពុជាធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះវៀតណាម ១២នាក់ពីក្រុមឆបោក

https://www.khmertimeskh.com/501148102//?p=1148102 Khmer Times September 9, 2022

ក្រសួងការបរទេសកម្ពុជាបានឲ្យដឹងកាលពីថ្ងៃព្រហស្បតិ៍ថា ថ្មីៗនេះ កម្ពុជាបានធ្វើមាតុភូមិនិវត្តន៍ពលករវៀតណាមចំនួន ១២ នាក់ដែលត្រូវបានគេបោកបញ្ឆោតទៅធ្វើការនៅប្រទេសជិតខាង។ អ្នកនាំពាក្យរងក្រសួងការបរទេស លោក Doan Khac Viet មិនបានបង្ហាញព័ត៌មានលម្អិតបន្ថែមអំពីការធ្វើមាតុភូមិនិវត្តន៍នៅក្នុងកិច្ចប្រជុំសារព័ត៌មាននោះទេ។ វៀតណាមបានឆ្លើយតបនឹងសំណួរអំពីវិធានការការពារពលរដ្ឋចំពោះពលករវៀតណាមដែលបោកបញ្ឆោតឲ្យក្លាយជាពលករខុសច្បាប់នៅកម្ពុជា។ លោកថា វៀតណាមបានសហការជាមួយកម្ពុជាដើម្បីនាំយកមនុស្សជាង ៦០០ នាក់មកវិញដោយសុវត្ថិភាព។ នៅក្នុងកិច្ចប្រជុំសារព័ត៌មានមួយទៀតកាលពីចុងខែមុនក្រសួងការបរទេសបាននិយាយថា កម្ពុជាបានបញ្ចប់នីតិវិធីធ្វើមាតុភូមិនិវត្តន៍សម្រាប់ពលករវៀតណាមចំនួន២៥នាក់ក្នុងនោះមាន ១១ នាក់ដែលត្រូវបានសង្គ្រោះពីកាស៊ីណូមួយក្នុងខេត្តកណ្ដាលដែលបានចុះផ្សាយក្នុងសារព័ត៌មានកាលពីខែមុន នៅពេលដែលពួកគេចំនួន ៤២ នាក់បានរត់គេចខ្លួន ហើយមានតែ៤០នាក់ប៉ុណ្ណោះ ដែលរត់រួចដោយហែលទឹកឆ្លងទន្លេចូលទឹកដីវៀតណាម។

លោក Viet បាននិយាយថា អាជ្ញាធរកម្ពុជាក៏កំពុងបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ការជួញដូរមនុស្សនៅក្នុងប្រទេសផងដែរ ដោយបន្ថែមថា ជនរងគ្រោះជាញឹកញាប់ត្រូវបានទាក់ទាញដោយការសន្យានៃការងារងាយស្រួលជាមួយនឹងប្រាក់ខែខ្ពស់។ អាជ្ញាធរវៀតណាមបានឱ្យដឹងកាលពីពេលថ្មីៗនេះថា ជនជាតិវៀតណាមរាប់ពាន់នាក់ប្រហែលជាត្រូវបានជួញដូរមកកម្ពុជា ដើម្បីកេងប្រវ័ញ្ច បង្ខំឱ្យធ្វើការក្នុងលក្ខខណ្ឌដ៏លំបាកសម្រាប់សំណងតិចតួច ដោយបន្ថែមថា ការជួយសង្គ្រោះអាចនឹងមានការលំបាក។

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជាបានថ្លែងកាលពីចុងខែមុនថា អាជ្ញាធរកម្ពុជាបានផ្ទៀងផ្ទាត់ករណីជួញដូរមនុស្សចំនួន ៨៧ ករណីចាប់តាំងពីដើមឆ្នាំនេះរហូតដល់ថ្ងៃទី ២០ ខែសីហា ហើយ ១៧ ករណីត្រូវបានបញ្ជូនទៅតុលាការ។ លោក ស ខេង ថ្លែងថា ជនរងគ្រោះដោយការជួញដូរមនុស្សចំនួន ៨៦៥ នាក់ ត្រូវបានអាជ្ញាធរកម្ពុជាជួយសង្គ្រោះតាំងពីដើមឆ្នាំនេះមក។ *VNExpress*

## អាជ្ញាធរខេត្តព្រះសីហនុ ឲ្យម្ចាស់គ្រប់គ្រងទីតាំងមានជនបរទេសស្នាក់នៅ និងបម្រើការ ធ្វើរបាយការណ៍ មកនគរបាលឃុំ-សង្កាត់ មុនថ្ងៃ២៤កញ្ញា

https://dap-news.com/national/2022/09/09/277777/ ByPH104Posted on September 9, 2022

**ភ្នំពេញ ៖ រដ្ឋបាលខេត្តព្រះសីហនុ ស្នើម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំង ដែលមានជនបរទេសស្នាក់នៅ និងបម្រើការងារធ្វើរបាយការណ៍ ស្តីពីវត្តមានជនបរទេស បានមកស្នាក់នៅ និងបម្រើការងារ នៅក្នុងទីតាំងអគារខ្លួនគ្រប់គ្រង** ។ ក្រោយធ្វើរបាយការណ៍រួច ត្រូវផ្ញើមកប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ឲ្យបានមុនថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២២ ជាកំណត់។

ការឲ្យធ្វើរបាយការណ៍ របស់រដ្ឋបាលខេត្ត នាថ្ងៃ៩ កញ្ញានេះ ស្របពេលកម្ពុជាកំពុងបើកប្រតិបត្តិការបង្ក្រាបការជួញដូរមនុស្ស ជាជនបរទេសនៅកម្ពុជា ។ ប្រតិបត្តិការនេះ បានចាប់ផ្ដើមពីខេត្តព្រះសីហនុ ភ្នំពេញ កណ្ដាល និងបណ្ដាខេត្តមួយចំនួនទៀត ។ ក្រោយបើកប្រតិបត្តិការ តាមបទបញ្ជាសម្តេច ស ខេង ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បង្ក្រាបបានជាបន្តបន្ទាប់ ហើយក៏បានជួយសង្គ្រោះជនរងគ្រោះជាជនបរទេសច្រើន នាក់ផងដែរ៕

## ស្ថានភាពគឺមិនធម្មតា៖ អ្នកជួយសង្គ្រោះជនជាតិវៀតណាមដែលត្រូវបានជួញដូរមកកម្ពុជា

https://www.khmertimeskh.com/501148231//?p=1148231 Khmer Times September 9, 2022

បុរសជនជាតិវៀតណាមម្នាក់នៅប្រទេសកម្ពុជាបានចំណាយពេលបីឆ្នាំចុងក្រោយ ដើម្បីជួយជនជាតិវៀតណាមដែលត្រូវបានគេកេងប្រវ័ញ្ចក្នុងប្រទេស។ កាលពីបីឆ្នាំមុន លោក ជា សុខ មកពីសមាគមខ្មែរ-វៀតណាម ក្នុងខេត្តព្រះសីហនុ ត្រូវបានស្ត្រីពីរនាក់មកពីតំបន់ខ្ពង់រាបភាគកណ្តាលនៃប្រទេសវៀតណាម ទាក់ទងមកសុំអង្វរលោកឱ្យជួយសង្គ្រោះពួកគេពីកាស៊ីណូនៅខេត្តព្រះសីហនុ។ ពួកគេបាននិយាយថាប្រាក់លោះនឹងត្រូវបានបង់ដោយក្រុមគ្រួសាររបស់ពួកគេនៅវៀតណាម។ សុខ ជា ជនជាតិវៀតណាម ប៉ុន្តែមករស់នៅខេត្តព្រះសីហនុអស់៣៥ឆ្នាំបានគិតថា៖ «ដំបូងខ្ញុំគិតថាវាជាការលោះធម្មតា៖ ខ្ញុំនឹងឲ្យលុយទៅកាស៊ីណូ ហើយយកពួកគេមកវិញ។ ប៉ុន្តែពេលដែលខ្ញុំបានជួបពួកគេទល់មុខគ្នាទើបខ្ញុំដឹងថាស្ថានភាពគឺមិនធម្មតាទេ»។ គាត់បានធ្វើដំណើរទៅកាន់ទីតាំងដាច់ស្រយាលដែលបង្ហាញដោយ GPS ប្រហែល១០ គីឡូម៉ែត្រពីទីក្រុង។ វាជាផ្ទះមួយនៅកណ្តាលកន្លែងដាច់ស្រយាលគ្មានបង្អួច និងជញ្ជាំងកម្ពស់បីម៉ែត្រ។ មនុស្សដប់នាក់បានកំពុងរង់ចាំគាត់ និងដៃគូរបស់គាត់ សុទ្ធតែមានកាន់អាវុធ។

ទោះបីជាមានការព្រមព្រៀងគ្នាពីមុនក៏ដោយ ក៏ក្រុមនេះបាននិយាយថា សុខ អាចយកតែម្នាក់ក្នុងចំណោមស្ត្រីពីរនាក់ ហើយគាត់ត្រូវបង់ប្រាក់បន្ថែមសម្រាប់ម្នាក់ទៀតដើម្បីត្រូវបានដោះលែង។ គាត់បានបត់យានជំនិះរបស់គាត់ ធ្វើពុតជាចាកចេញ។ ដោយសំអាងលើការខិតខំជំរិតទារប្រាក់ច្រើនជាងការព្រមព្រៀង គាត់បាននិយាយទៅកាន់អ្នកយាមថា៖ «អ្នកមានគ្នាច្រើន តែយើងមានតែពីរនាក់តើអ្នកខ្លាចអ្វី? ពួកគេហាក់ដូចជាជាប់នុយ ហើយបន្ទាប់ពីការចរចាបន្ថែមទៀតបានអនុញ្ញាតឱ្យស្ត្រីទាំងពីរទៅដោយមិនទាមទារប្រាក់បន្ថែម។ សុខ និងដៃគូត្រូវធ្វើឱ្យប្រាកដថាគ្មានអ្នកណាតាមគេមុនពេលពួកគេត្រូវបានដោះលែង។ វាជាលើកទីមួយហើយ ដែលគាត់បានជួយសង្គ្រោះមនុស្សពីកាស៊ីណូនៅកម្ពុជា។ ចាប់តាំងពីពេលនោះមក គាត់ និងមិត្តភក្តិរបស់គាត់នៅក្នុងសមាគមបានជួយជនជាតិវៀតណាមរាប់មិនអស់ឱ្យរួចផុតពីការជួញដូរមនុស្ស ហើយរក្សាសុវត្ថិភាពរហូតដល់ពួកគេអាចត្រឡប់ទៅផ្ទះវិញបាន។

ស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា បានឲ្យដឹងថា អាជ្ញាធរវៀតណាមបានធ្វើការជាមួយសមភាគីកម្ពុជា ដើម្បីនាំយកពលរដ្ឋជាង ៦០០នាក់ ដែលត្រូវបានបោកបញ្ឆោតឲ្យមកធ្វើជាពលករខុសច្បាប់នៅកម្ពុជាអោយត្រឡប់ទៅប្រទេសវិញ។ ប៉ុន្តែ សុខ បាននិយាយថា ជនរងគ្រោះជាច្រើនក៏រកផ្លូវគេចខ្លួនដោយមិនទាក់ទងតំណាងការទូតវៀតណាមប្រចាំកម្ពុជា។ ជាឧទាហរណ៍ កាលពីមួយខែមុន គាត់បានជួយជនជាតិវៀតណាមម្នាក់ចេញពីក្រុមហ៊ុនមួយ ដោយបង់ប្រាក់លោះចំនួន ៤,៥០០ ដុល្លារ។ សាច់ញាតិជនរងគ្រោះនៅទីក្រុងហូជីមិញបានប្រើទំនាក់ទំនងផ្ទាល់ខ្លួនដើម្បីជួយសង្គ្រោះមនុស្សជាទីស្រឡាញ់របស់ពួកគេពីទីក្រុងភ្នំពេញ។ ពួកគេបានសុំឲ្យលោក សុខ យកប្រាក់ទៅលោះហើយយកជនរងគ្រោះមកវិញ។ លោក សុខ និយាយថា លោកបានរៀនមេរៀនជាច្រើនពីការខិតខំរបស់លោកក្នុងការជួយសង្គ្រោះពួកគេពីក្រុមជួញដូរមនុស្ស។

ជាឧទាហរណ៍ រាល់ពេលដែលគាត់ធ្វើដំណើរទៅកន្លែងសង្គ្រោះ គាត់ប្រាប់ពីទីតាំងដល់អាជ្ញាធរវៀតណាម និងកម្ពុជា ដើម្បីផ្តល់ជំនួយក្នុងករណីមានអ្វីមួយខុសប្រក្រតី។ លោកនិយាយថា ការចរចាដើម្បីធានាដោះលែងជនរងគ្រោះមិនមែនជារឿងងាយស្រួលនោះទេ ហើយ«លុយតែមួយមុខមិនគ្រប់គ្រាន់ដើម្បីធានាសេរីភាពនោះទេ»។ តម្លៃលោះជាធម្មតានៅចន្លោះ $៣,០០០-៥,០០០។ មានករណីជនរងគ្រោះទាក់ទងទៅក្រុមគ្រួសារ និងប្រគល់លុយទាំងអស់តាមការទាមទារ ហើយត្រូវបានដោះលែង ប៉ុន្តែជាក់ស្តែងពួកគេត្រូវបាន "លក់" ទៅឱ្យអ្នកផ្សេង។ សុខ និយាយថា៖ «មានករណីជនរត់គេចខ្លួនដោយខ្លួនឯង ហើយសំណាងល្អត្រូវបានអ្នកស្រុកជួយ។ ពួកគេដឹងថាពួកគេជាជនជាតិវៀតណាមព្យាយាមរត់គេចពីការជួញដូរហើយតែងតែទាក់ទងមកយើងដើម្បីសុំអោយយើងជួយ។ លោកថា សមាគមជួយជនរងគ្រោះរកកន្លែងស្នាក់នៅ បំពេញនីតិវិធីច្បាប់ និងជូនដំណឹងដល់អាជ្ញាធរពាក់ព័ន្ធ។ សមាគមក៏ផ្តល់ការព្យាបាលសម្រាប់អ្នកដែលត្រូវបានគេវាយដំ ឬរងរបួសអំឡុងពេលរត់គេចខ្លួនផងដែរ។

យោងតាមស្ថានទូតវៀតណាម អង្គភាពការពារពលរដ្ឋរបស់ខ្លួនទទួលបានសំបុត្រ និងទូរស័ព្ទជាច្រើន ដើម្បីស្វែងរកជំនួយសង្គ្រោះជនជាតិវៀតណាមដែលត្រូវបានបោកបញ្ឆោតឱ្យធ្វើជាពលករខុសច្បាប់។ លោក ស៊ឹម ជី ប្រធានសមាគមបាននិយាយថា ក្រុមឆបោកជួញដូរមនុស្សភាគច្រើនធ្វើសកម្មភាពក្នុងខេត្តមួយចំនួនដូចជា ស្វាយរៀង ព្រះសីហនុ និងកំពង់ស្ពឺ។ ជនជាតិវៀតណាមរាប់ពាន់នាក់ត្រូវបានគេគិតថាត្រូវបាននាំមកកាន់ប្រទេសកម្ពុជានាពេលថ្មីៗនេះ ដើម្បីបង្ខាំង និងបង្ខំឱ្យធ្វើការក្នុងលក្ខខណ្ឌដ៏លំបាក និងដោយគ្មានសំណងដូចដែលពួកគេបានសន្យា។ លោក សុខ បានបន្តថា ជនរងគ្រោះភាគច្រើនគឺមិនទាន់គ្រប់អាយុ ហើយពួកគេត្រូវបាននាំមកកម្ពុជាដោយគ្មានឯកសារត្រឹមត្រូវ។ «អ្នកខ្លះយកលិខិតឆ្លងដែនក្នុងនាមជាភ្ញៀវទេសចរដោយមានសុពលភាពតែមួយខែ។ «ក៏មានអ្នកដែលមិនមានឯកសារអត្តសញ្ញាណផ្ទាល់ខ្លួនដែរ»។ ក្នុងករណីបែបនេះ អាជ្ញាធរវៀតណាម និងកម្ពុជា ត្រូវទាក់ទងអាជ្ញាធរមូលដ្ឋាននៅកន្លែងរស់នៅរបស់ជនរងគ្រោះ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណ និងប្រាប់ពួកគេឲ្យផ្តល់ឯកសារចាំបាច់។ បន្ទាប់មក ទើបអាចរៀបចំការធ្វើមាតុភូមិនិវត្តន៍បាន។ សុខ បន្ថែមថា៖ «ខ្ញុំសង្ឃឹមថាប្រជាជននៅវៀតណាមយល់ពីការជួញដូរមនុស្សទាំងនេះថាមានគ្រោះថ្នាក់ប៉ុណ្ណា។ «ពេលណាម្នាក់ធ្វើដំណើរទៅក្រៅប្រទេស រួមទាំងកម្ពុជាផង ត្រូវស្រាវជ្រាវព័ត៌មានឲ្យបានហ្មត់ចត់ បើមានសញ្ញាគួរឲ្យសង្ស័យ អ្នកមិនគួរទៅទេ ព្រោះគ្មានការងារណាដែលងាយស្រួល និងមានប្រាក់ខែខ្ពស់នោះទេ។ *VNExpress*

# រដ្ឋមន្ត្រីការបរទេសកម្ពុជា និងម៉ាឡេស៊ី
# ពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆបោក

https://cen.com.kh/archives/528204.html Posted ByPen Srey NeatSeptember 9, 2022

ភ្នំពេញៈ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បាន ជួបសន្ទនាតាមទូរស័ព្ទជាមួយ ឯកឧត្តម ដាតុ ស្រ៊ី សៃហ្វូឌីន អាប់ឌុលឡា (Dato' Sri Saifuddin Abdullah) រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី ដែលបានមកបំពេញទស្សនកិច្ចការងាររយៈពេលខ្លីនៅ រាជធានីភ្នំពេញ នាថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២២ នេះ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងសមភាគីម៉ាឡេស៊ី បានពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆបោក។ ឯកឧត្តមរដ្ឋមន្ត្រីការបរទេស ដាតុ ស្រ៊ី សៃហ្វូឌីន អាប់ឌុលឡា បានសម្តែងនូវអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ ដែលបានផ្តល់ «ជំនួយជាច្រើន» និងបានបំពេញ «ការងារដ៏ល្អ» ក្នុងការជួយសង្គ្រោះជនរងគ្រោះ។ ឯកឧត្តមក៏បានគូសបញ្ជាក់ផងដែរថា មានជនជាតិ ម៉ាឡេស៊ីជាច្រើននាក់ដែលចូលមកកម្ពុជា ដើម្បីធ្វើជំនួញ និងធ្វើការយ៉ាងជោគជ័យ ហើយមានតែមួយចំនួនតូចប៉ុណ្ណោះដែលរងគ្រោះដោយសារការបោកប្រាស់ការងារ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីការបរទេស ដាតុ ស្រ៊ី សៃហ្វូឌីន អាប់ឌុលឡា ថា ឧក្រិដ្ឋកម្មទាំងនេះកើតឡើងនៅគ្រប់ប្រទេស មិនថាជាប្រទេសតូច ឬធំនោះទេ ហើយយើងទាំងអស់គ្នាត្រូវតែប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនេះ ដោយគូសបញ្ជាក់ថាមធ្យោបាយដ៏ល្អបំផុតដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវរួមដៃគ្នា និងមានកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានធានាចំពោះសមភាគីរបស់ឯកឧត្តម អំពីការត្រៀមខ្លួនរួចជាស្រេចរបស់កម្ពុជា ក្នុងការធ្វើការជាមួយស្ថានទូតម៉ាឡេស៊ីនៅភ្នំពេញ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនេះ៕ ដោយៈចេស្តារ

# ថ្ងៃទី០៨ ខែកញ្ញា ម្សិលមិញនេះ សម្តេចក្រឡាហោម ស ខេង ទទួលពាក្យបណ្តឹងចំនួន១៧ ទៀត ពាក់ព័ន្ធនឹងករណីបង្ខាំង និងជួញដូរ

https://freshnewsasia.com/index.php/en/localnews/256743-2022-09-09-13-00-57.html 2022-09-09 08:00pm

**(ភ្នំពេញ)៖** សម្រាប់ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញនេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជ.ប.ជ) បានទទួលពាក្យបណ្តឹងចំនួន ១៧ទៀត ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍លើករណីបង្ខាំង និងជួញដូរ។ នេះបើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។

នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា ក្នុងបណ្តឹងនោះ មានការស្នើឱ្យអន្តរាគមន៍ស្វែងរកជនជាតិចិន ១៥នាក់, ជនជាតិម៉ាឡេស៊ី ០៤នាក់, ជនជាតិវៀតណាម ០៤នាក់, ជនជាតិចិនតៃវ៉ាន់ ០១នាក់ និងជនជាតិខ្មែរ ០១នាក់។ បើតាមអ្នកនាំពាក្យក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ សម្តេចក្រឡាហោម បានទទួលពាក្យបណ្តឹងសរុបចំនួន១៥៤បណ្តឹង ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ជួយសង្គ្រោះជនបរទេស ដែលត្រូវបានអះអាងថាបង្ខាំង និងជួញដូរកម្លាំងពលកម្ម។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់ សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការ

ផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបាន ទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ។

នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅព្រឹកថ្ងៃទី០៩ ខែកញ្ញានេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ឱ្យគ្រប់រដ្ឋបាលរាជធានី ខេត្ត និងមូលដ្ឋានទាំងអស់ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការ ប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរ និងរត់ពន្ធមនុស្ស ពលកម្ម បង្ខិតបង្ខំ និងអាជីវកម្មផ្លូវភេទ ឱ្យមានប្រសិទ្ធភាពផងដែរ៕

## ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ
## ជំរុញដល់អាជ្ញាធរខេត្ត និងសមត្ថកិច្ចតាមបន្ទាត់ព្រំដែន ត្រូវពង្រឹងតួនាទីភារកិច្ចរបស់ខ្លួន ឲ្យបានល្អ ពិសេស ពង្រឹងការទប់ស្កាត់ការជួញដូរមនុស្ស និងករណីគ្រឿងញៀន ឆ្លងដែន

https://gntimes.com/news/6266 ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២

ប៉ៃលិន៖ លោក អ៊ុត សំអន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា ការរត់ពន្ធមនុស្ស (ជួញដូរមនុស្ស) បទល្មើសគ្រឿងញៀន ឆ្លងដែន តែងតែកើតមានជាបន្តបន្ទាប់ នៅតាមបណ្តាខេត្តជាប់ព្រំដែន ប៉ុន្តែសមត្ថកិច្ច ក៏បានបង្ក្រាបជាច្រើនករណីដែរ ដូច្នេះ សូមឲ្យអាជ្ញាធរខេត្ត និងសមត្ថកិច្ចតាមបន្ទាត់ព្រំដែន ត្រូវពង្រឹងការទប់ស្កាត់ ករណីជួញដូរមនុស្ស និងបទល្មើសគ្រឿងញៀន ឆ្លងដែន ជាបន្តទៀត ។ លោក អ៊ុត សំអន មានប្រសាសន៍បែបនេះ នៅក្នុងពិធីប្រកាសចូលកាន់តំណែងអភិបាលរងខេត្តប៉ៃលិន កាលពីល្ងាចថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០២២ នៅសាលាខេត្តប៉ៃលិន ដោយមានការអញ្ជើញចូលរួមពីលោកស្រី បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន ។

លោក អ៊ុត សំអន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា៖ គណៈអភិបាលខេត្ត និងមន្ត្រីរាជការទាំងអស់ក្នុងខេត្ត ត្រូវរួមគ្នាពង្រឹងការងារផ្តល់សេវាជូនប្រជាពលរដ្ឋ ឱ្យបានល្អប្រសើរប្រកបដោយគុណភាព ប្រសិទ្ធភាព និងស្នាមញញឹម ត្រូវរួមគ្នារក្សាស្ថេរភាពប្រទេសជាតិ ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ច ដោយអនុវត្តវិធានការច្បាប់ចំពោះជនទាំងឡាយណាដែលបង្កអស្ថេរភាពសង្គម ប៉ះពាល់ដល់សន្តិសុខជាតិ ។ ជាមួយគ្នានេះដែរ លោករដ្ឋលេខាធិការក្រសួងមហាផ្ទៃ ក៏បានក្រើនរំឭកបន្ថែមដល់អាជ្ញាធរខេត្ត ពង្រឹងការគ្រប់គ្រងបញ្ហាគ្រឿងញៀន ទាំងវិធានការអប់រំ វិធានការរដ្ឋបាល និងវិធានការត្រួតពិនិត្យ ត្រូវអនុវត្តឱ្យបានជាប់ជាប្រចាំ ពង្រឹងការងារគ្រប់គ្រងនៅតាមខ្សែបន្ទាត់ព្រំដែន និងជំរុញការអនុវត្តគោលនយោបាយកំណែទម្រង់ ដែលរដ្ឋាភិបាលដាក់ចេញ ជាពិសេសបង្កើនការចូលរួមទប់ស្កាត់ នូវការរីករាលដាលជំងឺកូវីដ-១៩ ផងដែរ ។

សូមបញ្ជាក់ថា អភិបាលរងខេត្តប៉ៃលិន ដែលត្រូវប្រកាសចូលកាន់តំណែងនោះ រួមមាន៖ ទី១. លោក ម៉ើង លីដា ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ឲ្យកាន់មុខតំណែងជាអភិបាលរងខេត្តប៉ៃលិន, ទី២. លោក អ៊ុន ប៊ុនលី ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ពីនាយករដ្ឋបាលខេត្ត ឲ្យកាន់តំណែងជាអភិបាលរងខេត្តប៉ៃលិន, ទី៣. លោក រស់ នឿន ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ពីនាយករងរដ្ឋបាលខេត្ត ឲ្យកាន់តំណែងជាអភិបាលរងខេត្តប៉ៃលិន,

ទី៤. លោក សោ សុវណ្ណ ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ពីនាយករងរដ្ឋបាលខេត្ត ឲ្យកាន់តំណែងជាអភិបាលរងខេត្តប៉ៃលិន, ទី៥. លោក ងួន លីណា ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ឲ្យកាន់តំណែងជាអភិបាលរងខេត្តប៉ៃលិន និងទី៦. លោក សុខ ពិសី ឋានន្តរស័ក្តិវរអភិបាល ថ្នាក់លេខ៣ ឲ្យកាន់តំណែងជាអភិបាលរងខេត្តប៉ៃលិនផងដែរ ៕ អត្ថបទ សុវណ្ណារិទ្ធ

## ក្រសួងយុត្តិធម៌បង្កើតក្រុមការងារចំពោះកិច្ចប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://nokorwatnews.com/archives/895663 10/09/2022

ភ្នំពេញ៖ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២ ក្រសួងយុត្តិធម៌បានចេញសេចក្តីសម្រេច បង្កើតក្រុមការងារចំពោះកិច្ចមួយរបស់ក្រសួង ដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ។ ជាការកត់សម្គាល់ការបង្កើតក្រុម ការងារប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្សនេះ គឺបន្ទាប់ពីសហរដ្ឋអាមេរិក បានដាក់កម្ពុជាចូលក្នុងបញ្ជីខ្មៅ ជាប្រទេសជាប់ចំណាត់ថ្នាក់លេខ៣នៃការជួញដូរមនុស្ស។ ក្រុមការងារចំពោះកិច្ចនេះមានប្រធានមួយរូប អនុ ប្រធានមួយរូប សមាជិក៩រូប និងលេខាធិការចំនួន ៧រូប។ តាមរយៈសេចក្តីសម្រេចចេញនៅថ្ងៃ០៩កញ្ញា ក្រុមការងារចំពោះកិច្ចគឺជាសេនាធិការរបស់ក្រសួងយុត្តិធម៌ ដែលមានតួនាទីនិងភារកិច្ចដូចជា៖

-សម្របសម្រួលនីតិវិធីក្នុងការស៊ើបអង្កេត ស្រាវជ្រាវ និងត្រួតពិនិត្យជនបរទេសតាមបណ្តាគោលដៅសង្ស័យ ដើម្បីឈានទៅដល់ការឃាត់ខ្លួនជនល្មើស និងសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា។

-ជំរុញ និងពង្រឹងការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និងការផ្តន្ទាទោសពីបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ឱ្យបានតឹងរ៉ឹងស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

-ប្រមូល ចងក្រង និងរៀបចំតារាងស្ថិតិទិន្នន័យ អំពីការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និងការផ្តន្ទាទោស ពីបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ។

-ជំរុញការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និងការផ្តន្ទាទោស ពីបទល្មើសសម្អាតប្រាក់ស្របច្បាប់ និងនីតិវិធីប្រតិបត្តិស្តង់ដា (SOP) ជាធរមាន ដោយសហការជាមួយក្រុមការងាររបស់ក្រសួងយុត្តិធម៌ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្នុងករណីដែលក្រុមការងារពិនិត្យឃើញនូវតម្រុយនៃបទល្មើសសម្អាតប្រាក់ ដែលកើតចេញពីបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ។

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជាប្រចាំ ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

-បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កាលពីពេលកន្លងទៅសហរដ្ឋអាមេរិក បានដាក់កម្ពុជាចូលក្នុងបញ្ជីខ្មៅ ជាប្រទេសជាប់ចំណាត់ថ្នាក់លេខ៣ នៃការជួញដូរមនុស្ស។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានសម្តែងការខកចិត្តយ៉ាងខ្លាំងចំពោះការសម្រេចរបស់ក្រសួងការបរទេសអាមេរិក ដាក់កម្ពុជាចូលក្នុងបញ្ជីខ្មៅនេះ ត្បិតកម្ពុជាបានខិតខំយ៉ាងសកម្មក្នុងការសហការទប់ស្កាត់នូវអំពើជួញដូរមនុស្សនេះ៕

# អាជ្ញាធរកម្ពុជា
# ឃាត់ខ្លួនជនបរទេសសរុបជាង៦០នាក់ ក្នុងប្រតិបត្តិការបង្ក្រាបការបង្ខាំងមនុស្ស

https://khmer.voanews.com/a/cambodia-official-says-more-than-60-foreigners-arrested-related-to-human-trafficking-linked-with-scams/6737967.html 09 កញ្ញា 2022លាស់ លីបលីបហាន ណូយ

ភ្នំពេញ៖ អាជ្ញាធរកម្ពុជាបានឃាត់ខ្លួនជនសង្ស័យដែលជាជនបរទេសសរុបជាង៦០នាក់ នៅក្នុងប្រត្តិបត្តិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការបង្ខាំងមនុស្ស ដែលប្រទេសនានាបានស្នើកម្ពុជាឱ្យជួយសង្គ្រោះប្រជាជនរបស់ខ្លួន ដែលត្រូវបានធ្វើបាបនៅលើទឹកដីកម្ពុជា។ នេះបើតាមមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកការជួញដូរមនុស្ស។ ក្នុងចំណោមជនសង្ស័យទាំងនោះ អ្នកខ្លះត្រូវបានបញ្ជូនចេញទៅក្រៅប្រទេស និងខ្លះទៀតត្រូវបានបញ្ជូនទៅតុលាការ។

អ្នកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រាប់វីអូអេនៅថ្ងៃសុក្រនេះថា អាជ្ញាធរបានទទួលពាក្យបណ្តឹង តាមបណ្តាញសង្គមហ្វេសប៊ុករបស់អាជ្ញាធរពាក់ព័ន្ធ និងហ្វេសប៊ុករបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមស្ថានទូតនៃបណ្តាប្រទេសនានា និងខ្លះទទួលបានពាក្យបណ្តឹងពីសាច់ញាតិ។ អ្នកស្រីបន្តថាអាជ្ញាធរបានឃាត់ខ្លួនជនសង្ស័យជាជនបរទេសបានជាង ៦០ នាក់ ដោយពួកគេខ្លះត្រូវបញ្ជូនទៅតុលាការ និងអ្នកខ្លះទៀតត្រូវបានបញ្ជូនចេញទៅក្រៅប្រទេស តាមការស្នើសុំរបស់ប្រទេសសាមី។ អ្នកស្រី ជូ ប៊ុនអេង មិនបានបញ្ជាក់ថាតើជនសង្ស័យទាំងនោះជាជនជាតិអ្វីឡើយ ដោយត្រឹមតែលើកឡើងថាអ្នកដែលត្រូវឃាត់ខ្លួនមានចម្រុះជាតិសាសន៍។ អ្នកស្រីថ្លែងថា៖ «យើងក៏បានរកឃើញជនដែលសង្ស័យ ឬមួយមេការ ឬមួយស្អីដែលនៅកន្លែងធ្វើការងារដែលពាក់ព័ន្ធហ្នឹងដូចជាបានជាង ៦០ នាក់។ ហើយក៏បានធ្វើបែបបទបញ្ជូនទៅតុលាការ ហើយករណីខ្លះ គឺសាមីប្រទេស គាត់ស្នើសុំយកទៅប្រទេសគាត់អ៊ីចឹងទៅ»។

ចំណែកជនរងគ្រោះដែលអាជ្ញាធរជួយសង្គ្រោះបាន មានជាង១២០នាក់ ក្នុងប្រតិបត្តិការស្រាវជ្រាវ ចំនួន ៥៧ ក្រោយពីទទួលបានបណ្តឹងប្រមាណ ១១៣។ នេះបើតាមអ្នកស្រី ជូ ប៊ុនអេង។ ជនរងគ្រោះទាំងនោះ រួមមានជនជាតិចិនច្រើនជាងគេ និងជនជនផ្សេងៗទៀត ដូចជាតៃវ៉ាន់ម្នាក់ អាមេរិកម្នាក់ ហ្វីលីពីន វៀតណាម និងបណ្តាប្រទេសមួយចំនួនទៀត។ បើតាមអ្នកស្រី ជូ ប៊ុនអេង ករណីជួញដូរមនុស្សមានមិនដល់១០ករណីនោះទេ ដោយភាគច្រើន គឺជាករណីចម្រូងចម្រាសកិច្ចសន្យាការងារតែប៉ុណ្ណោះ។

កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាឱ្យអាជ្ញាធរពាក់ព័ន្ធនានាត្រៀមចុះពិនិត្យអគារនានានៅទូទាំងប្រទេស ខណៈមានសេចក្តីរាយការណ៍ថា កម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងជួញដូរមនុស្សតាមរយៈការប្រើប្រាស់កម្លាំងបរទេសឱ្យធ្វើការជាអ្នកឆបោកតាមបច្ចេកវិទ្យា ឬហៅថា Scam។

លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ ប្រាប់វីអូអេកាលពីចុងខែសីហាថា ជនរងគ្រោះមួយចំនួនដែលជាជនជាតិចិន បានចាញ់បោកមេខ្យល់ឱ្យបម្រើការងារអនឡាញនៅក្រុមហ៊ុនកាស៊ីណូ ក្នុងខេត្តព្រះសីហនុ ដោយក្រុមហ៊ុនបានដកយកលិខិតឆ្លងដែននិងដកទូរស័ព្ទដៃទុក ហើយបានបង្ខំឱ្យធ្វើការរហូតដល់១៧ទៅ១៨ម៉ោងក្នុងមួយថ្ងៃ។

វីអូអេមិនទាន់អាចសុំការបញ្ជាក់ពីលោក ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុបាននៅឡើយទេ។ ចំណែកលោក ឡុង ឌីម៉ង់ អ្នកនាំពាក្យសាលាខេត្តព្រះសីហនុ បានប្រាប់ឱ្យអ្នកសារព័ត៌មានរបស់វីអូអេទៅសួរខាងអគ្គស្នងការនគរបាលជាតិជំនួសវិញ។

វីអូអេមិនទាន់អាចសុំការបញ្ជាក់ពីលោក ឆាយ គឹមខឿន អ្នកនាំពាក្យរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងលោក កែវ វណ្ណថន អ្នកនាំពាក្យនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃបាននៅឡើយទេ។

កាលពីថ្ងៃព្រហស្បតិ៍ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានថ្លែងថា កម្ពុជាត្រូវបានជនបរទេសប្រើប្រាស់ ជាកន្លែងប្រព្រឹត្តបទល្មើសឆបោកតាមបច្ចេកវិទ្យា ដែលនេះនាំឲ្យកម្ពុជាក្លាយជាប្រទេសរងគ្រោះនៃអំពើខុសច្បាប់ទាំងនេះ។ លោកបន្ថែមថាប្រជាជនកម្ពុជាមិនមែនជាមេខ្លោងប្រព្រឹត្តបទល្មើសទេ ដែលបទល្មើសនេះ កើតឡើងពិសេសនៅក្នុងខេត្តព្រះសីហនុ។ លោកថ្លែងថា៖ «ជនល្មើស មេក្លោង ជួញដូរមនុស្សតាមប្រព័ន្ធទូរគមនាគមន៍នេះ កំពុងយកកម្ពុជាជាកន្លែងប្រព្រឹត្តបទល្មើសនោះ អ៊ីចឹងកម្ពុជាយើងជាកន្លែងរងគ្រោះ ពីព្រោះអ្នកប្រព្រឹត្តបទល្មើស ជាមេក្លោង។ ៩៩,៩% មិនមែនខ្មែរ»។

លោក អំ សំអាត នាយករងទទួលបន្ទុកកម្មវិធីឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ ប្រាប់វីអូអេថា អង្គការសង្គមស៊ីវិលនៅតែមានការព្រួយបារម្ភពាក់ព័ន្ធជាមួយការជួញដូរមនុស្សនៅកម្ពុជា ខណៈកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ទាបក្នុងការបង្ក្រាបការជួញដូរមនុស្សនៅឡើយ។ លោកបន្ថែមថា រដ្ឋាភិបាលត្រូវតែមានឆន្ទៈពិតប្រាកដ និងការតាំងចិត្តខ្ពស់នៅក្នុងការដោះបញ្ហានេះ ដើម្បី កុំឲ្យប៉ះពាល់មុខមាត់កម្ពុជា ជាពិសេសជះផលអាក្រក់ដល់ការវិនិយោគនៅក្នុងប្រទេស។ លោកបញ្ជាក់ថា៖ «កម្ពុជាយើងត្រូវតែមានការខិតខំនិងការប្រឹងប្រែងទៅលើការបង្ក្រាបនិងការទប់ស្កាត់ការជួញដូរមនុស្ស ពីព្រោះបញ្ហាទាំងអស់នេះវាជះឥទ្ធិពល ប៉ះពាល់ដល់កម្ពុជា មុខមាត់កម្ពុជាយើង»។

គួរបញ្ជាក់ថាកម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធឺណិត (Scam) ដោយប្រើប្រាស់កម្លាំងពលកម្មបរទេស ធ្វើការនៅតាមអគារខ្ពស់ៗនៅក្នុងប្រទេសកម្ពុជា រហូតមានសេចក្តីរាយការណ៍អំពីការបង្ខាំងទុកពួកគេ មិនឱ្យមានសេរីភាព ធ្វើទារុណកម្ម និងជំរិតទារប្រាក់ជាដើម៕

## ជនរងគ្រោះម៉ាឡេស៊ីដោយសារការបោកប្រាស់ការងារ ចំនួន២៤នាក់ក្នុងចំណោម៩៣នាក់នៅកម្ពុជាត្រឡប់មកមាតុប្រទេសវិញជាមួយរដ្ឋមន្ត្រីការបរទេស

https://www.khmertimeskh.com/501148477//?p=1148477 September 10, 2022

Bernama នៃប្រទេសម៉ាឡេស៊ីបានរាយការណ៍ថា ក្រុមជនជាតិម៉ាឡេស៊ីចំនួន២៤ នាក់ ដែលត្រូវបានចោទថាជាជនរងគ្រោះ នៃការចាញ់បោកការងារនៅក្នុងប្រទេសកម្ពុជាត្រូវបានត្រឡប់មកប្រទេសវិញ ដោយជោគជ័យពីទីក្រុងភ្នំពេញកាលពីម្សិលមិញ។ ជនរងគ្រោះមានអាយុចន្លោះពី២០ឆ្នាំទៅ៣០ឆ្នាំ បានត្រឡប់មកវិញជាមួយរដ្ឋមន្ត្រីការបរទេស Saifuddin Abdullah ដែលបានកំពុងបំពេញទស្សនកិច្ចនៅទីក្រុងភ្នំពេញ។ Saifuddin បាននិយាយថា ជនជាតិម៉ាឡេស៊ី២៩ នាក់ផ្សេងទៀតកំពុងស្ថិតនៅមន្ទីរអន្តោប្រវេសន៍ក្នុងប្រទេសកម្ពុជា ដោយសារពួកគេមិនមានឯកសារធ្វើដំណើរត្រឹមត្រូវនៅពេលពួកគេចូលប្រទេស។ ទោះជាយ៉ាងណា ពួកគេទាំងអស់មានសុវត្ថិភាព។ លោក Saifuddin បាននិយាយថា លោកបានទៅសួរសុខទុក្ខជនជាតិម៉ាឡេស៊ីចំនួន ៧ នាក់ ដែលនៅមន្ទីរអន្តោប្រវេសន៍រាជធានីភ្នំពេញខណៈ២២នាក់ទៀត ត្រូវបានគេរាយការណ៍ថាត្រូវបានឃុំខ្លួននៅខេត្តព្រះសីហនុ។ លោកបានប្រាប់អ្នកយកព័ត៌មាននៅពេលមកដល់ថា "ពួកគេនឹងត្រូវធ្វើមាតុភូមិនិវត្តន៍តាមដំណាក់កាលអាស្រ័យលើនាយកដ្ឋានអន្តោប្រវេសន៍កម្ពុជា ពីព្រោះខ្លះមិនមានឯកសារធ្វើដំណើរត្រឹមត្រូវ ហើយករណីពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ភាគីកម្ពុជា"។

Saifuddin បានបន្តថា ក្នុងចំណោមករណីដែលបានរាយការណ៍ចំនួន១៤៨ ករណី មានជនជាតិម៉ាឡេស៊ីចំនួន ១១៨ នាក់ដែលបានធ្លាក់ខ្លួនរងគ្រោះដោយសារការចាញ់បោកការងារ និងការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា ត្រូវបានជួយសង្គ្រោះរហូតមកដល់ពេលនេះ។ លោកបានថ្លែងថា៖ «សូមអរគុណរដ្ឋាភិបាលកម្ពុជា និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានផ្តល់ការណែនាំជាក់លាក់ក្នុងប្រតិបត្តិការសង្គ្រោះជនជាតិម៉ាឡេស៊ីមួយចំនួននៅទីនោះ»។ Saifuddin ជាថ្មីម្តងទៀតបានក្រើនរំលឹកប្រជាជនម៉ាឡេស៊ីឱ្យប្រុងប្រយ័ត្នចំពោះការផ្តល់ជូន

ការងារដែលមានប្រាក់ខែខ្ពស់នៅបរទេស។ លោកបានបន្តថា "ប្រសិនបើអ្នកទទួលបានការផ្តល់ជូនណាមួយ សូមទាក់ទងទៅស្ថានទូតរបស់យើងនៅភ្នំពេញ ដើម្បីឲ្យពួកគេជួយពិនិត្យមើលថាតើក្រុមហ៊ុននេះស្របច្បាប់ឬអត់ ជាជាងទៅទីនោះដោយគ្មានព័ត៌មានត្រឹមត្រូវ"។ លោកបានបន្ថែមថា មានក្រុមហ៊ុនម៉ាឡេស៊ីប្រហែល ៥០០ ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ហើយមានជនជាតិម៉ាឡេស៊ី ៥,០០០ ដែលកំពុងធ្វើការ និងធ្វើអាជីវកម្មនៅក្នុងប្រទេស ហើយសុទ្ធតែកំពុងដំណើរការបានល្អ។

មុននេះ ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Datuk Eldeen Husaini បាននិយាយថា មិនមែនជនជាតិម៉ាឡេស៊ីទាំងអស់ ដែលត្រូវបានចោទប្រកាន់ថា ត្រូវបានជួញដូរមកកម្ពុជា គឺជាជនរងគ្រោះនៃការជួញដូរមនុស្សនោះទេ។ តាមពិត ពួកគេបានភៀសខ្លួនចេញពីប្រទេសម៉ាឡេស៊ី និងក្រុមគ្រួសាររបស់ពួកគេដោយសារជាប់បំណុលផ្សេងៗ ដូចជាបញ្ហាប្រាក់កម្ចី ការរត់ចេញពីគ្រួសារ និងបញ្ហាពាក់ព័ន្ធផ្សេងទៀត។ កម្ពុជាបានបង្កើនការបង្ក្រាបលើករណីជួញដូរមនុស្សដែលគេស្គាល់ថាជាជនរងគ្រោះដោយសារការចាញ់បោក និងបានជួយសង្គ្រោះមនុស្សរាប់រយនាក់ដែលមានសញ្ជាតិផ្សេងៗគ្នា។ *Free Malaysia Today/Khmer Times*

## កម្ពុជាត្រៀមខ្លួនរួចជាស្រេចក្នុងការធ្វើការជាមួយស្ថានទូតម៉ាឡេស៊ីនៅរាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆបោក

https://www.information.gov.kh/articles/85903 វិទ្យុជាតិកម្ពុជា ៖ យី វិច្ឆិកា ១០ ០៩ ២០២២

ភ្នំពេញ ៖ កម្ពុជាបានត្រៀមខ្លួនរួចជាស្រេចហើយ ក្នុងការធ្វើការជាមួយស្ថានទូតម៉ាឡេស៊ី នៅរាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆបោក ខណៈដែល ឧក្រិដ្ឋកម្មទាំងនេះកើតឡើងនៅគ្រប់ប្រទេស មិនថាជាប្រទេសតូច ឬធំនោះឡើយ។

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានជួបសន្ទនា តាមទូរស័ព្ទជាមួយ ឯកឧត្តម ដាតុ ស្រ៊ី សៃហ្វូឌីន អាប់ឌុលឡា (Dato' Sri Saifuddin Abdullah) រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី ដែលបានមកបំពេញទស្សនកិច្ចការងាររយៈពេលខ្លីនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២២ ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងសមភាគីម៉ាឡេស៊ី បានពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការរវាងប្រទេស ទាំងពីរ លើកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆបោក។ ឯកឧត្តមរដ្ឋមន្ត្រីការបរទេស ដាតុ ស្រ៊ី សៃហ្វូឌីន អាប់ឌុលឡា បានសម្តែងនូវអំណរគុណចំពោះ រាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ ដែលបានផ្តល់ «ជំនួយជាច្រើន» និងបានបំពេញ «ការងារដ៏ល្អ» ក្នុងការជួយសង្គ្រោះជនរងគ្រោះ។

ឯកឧត្តមក៏បានគូសបញ្ជាក់ផងដែរថា មានជនជាតិ ម៉ាឡេស៊ីជាច្រើននាក់ ដែលចូលមកកម្ពុជា ដើម្បីធ្វើជំនួញនិងធ្វើការយ៉ាងជោគជ័យ ហើយមានតែមួយចំនួនតូចប៉ុណ្ណោះ ដែល រងគ្រោះ ដោយសារការបោកប្រាស់ការងារ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីការបរទេស ដាតុ ស្រ៊ី សៃហ្វូឌីន អាប់ឌុលឡា ថា ឧក្រិដ្ឋកម្មទាំងនេះកើតឡើងនៅគ្រប់ប្រទេស មិនថាជាប្រទេសតូច ឬធំនោះទេ ហើយយើង ទាំងអស់គ្នាត្រូវតែប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនេះ ដោយគូសបញ្ជាក់ថា មធ្យោបាយដ៏ល្អបំផុតដើម្បី ដោះស្រាយបញ្ហានេះ គឺត្រូវរួមដៃគ្នា និងមានកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានធានាចំពោះសមភាគីរបស់ឯកឧត្តម អំពីការត្រៀមខ្លួនរួចជាស្រេចរបស់ កម្ពុជា ក្នុងការធ្វើការជាមួយស្ថានទូតម៉ាឡេស៊ីនៅភ្នំពេញ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម ទាំងនេះ៕

## ថ្ងៃទី០៩ ខែកញ្ញា ម្សិលមិញនេះ សម្តេចក្រឡាហោម ស ខេង ទទួលពាក្យបណ្តឹងចំនួន២១ ទៀត ពាក់ព័ន្ធនឹងករណីបង្ខាំង និងជួញដូរ

http://freshnewsasia.com/index.php/en/localnews/256824-2022-09-10-08-53-05.html 2022-09-10 03:53pm

**(ភ្នំពេញ)៖** សម្រាប់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញនេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជ.ប.ជ) បានទទួលពាក្យបណ្តឹងចំនួន ២១ទៀត ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍លើករណីបង្ខាំង និងជួញដូរ។ នេះបើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។

នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា ក្នុងបណ្តឹងនោះមានការស្នើឱ្យអន្តរាគមន៍ស្វែងរកជនជាតិចិន ១៣នាក់, ជនជាតិម៉ាឡេស៊ី០១នាក់, ជនជាតិវៀតណាម០៤នាក់, ជនជាតិចិនតៃវ៉ាន់ ០៨នាក់ និងជនជាតិឥណ្ឌា ១៤នាក់។ បើតាមអ្នកនាំពាក្យក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ សម្តេចក្រឡាហោម បានទទួលពាក្យបណ្តឹងសរុបចំនួន១៧៥បណ្តឹង ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ជួយសង្គ្រោះជនបរទេស ដែលត្រូវបានអះអាងថាបង្ខាំង និងជួញដូរកម្លាំងពលកម្ម។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ។

នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅព្រឹកថ្ងៃទី០៩ ខែកញ្ញា រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ឱ្យគ្រប់រដ្ឋបាលរាជធានី ខេត្ត និងមូលដ្ឋានទាំងអស់ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការ ប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរ និងរត់ពន្ធមនុស្ស ពលកម្ម បង្ខិតបង្ខំ និងអាជីវកម្មផ្លូវភេទ ឱ្យមានប្រសិទ្ធភាពផងដែរ៕

# ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២

## សម្តេចក្រឡាហោម ស ខេង អញ្ជើញដឹកនាំកិច្ចប្រជុំ ត្រួតពិនិត្យការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ

https://www.information.gov.kh/articles/85996 ខេត្តព្រះសីហនុ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២

នាព្រឹកថ្ងៃចន្ទ ២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំ ត្រួតពិនិត្យការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅខេត្តព្រះសីហនុ។

កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត ឯកឧត្តមនាយឧត្តមសេនីយ៍ ឧត្តមសេនីយ៍ ថ្នាក់ដឹកនាំរដ្ឋបាលខេត្តព្រះសីហនុ និងមន្ត្រីជាន់ខ្ពស់មួយចំនួនទៀត។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថាកិច្ចប្រជុំនាថ្ងៃនេះជាផ្នែកមួយនៃការជួយគាំទ្របន្ថែមទៀតដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងខេត្តព្រះសីហនុដែលមានការប្រឈមទៅនឹងបទល្មើសប្រភេទនេះ។ សម្តេចក៏បានរម្លឹកជាថ្មីទៀតអំពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា។ សម្តេចក្រឡាហោម បានបន្តថាកាលពីពេលថ្មីៗនេះ ក្រសួងបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការកិច្ចប្រតិបត្តិការលើការងារនេះ ហើយក្នុងឋានៈជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្តេចក៏បានអំពាវនាវឱ្យមានការគាំទ្រនិងចូលរួមក្នុងការងារនេះ ដោយបានផ្តល់បណ្តាញនិងលេខទូរសព្ទទំនាក់ទំនងរាយការណ៍អំពីករណីនេះ។ សម្តេចឱ្យដឹងទៀតថារហូតមកដល់ពេលនេះ ក្រសួងបានទទួលបណ្តឹង និងការរាយការណ៍ចំនួន១៨៦ករណី។

ក្នុងឱកាសនោះដែរ ឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ បានរាយការណ៍ជូនសម្តេចក្រឡាហោម និងអង្គប្រជុំអំពីវឌ្ឍនភាពនៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅខេត្តព្រះសីហនុក្រោមកិច្ចប្រតិបត្តិការរបស់កម្លាំងនគរបាលជាតិ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងនោះរួមទាំងលទ្ធផលនៃកិច្ចប្រតិបត្តិការក្រោយពីមានការដាក់ចេញផែនការដោយសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិ។

ក្នុងកិច្ចប្រជុំនោះ សម្តេចក្រឡាហោម ស ខេង បានជំរុញរដ្ឋបាលខេត្ត និងគ្រប់ភាគីពាក់ព័ន្ធក្នុងខេត្តព្រះសីហនុ បន្តការខិតខំប្រឹងប្រែងបង្ក្រាបគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ដោយប្រកាន់យកគោលការណ៍៣ក្នុងកិច្ចប្រតិបត្តិការ គឺសង្គ្រោះជនរងគ្រោះ បង្ក្រាបទីតាំងប្រព្រឹត្តបទល្មើស និងចាប់ខ្លួនជនល្មើស បណ្តាញ និងមេក្លោងពាក់ព័ន្ធមកផ្តន្ទាទោសទៅតាមច្បាប់ ដើម្បីពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ព្រមទាំងកិត្តិយសជាតិ៕

## ថ្ងៃទី១០ ខែកញ្ញា ម្សិលមិញនេះ សម្ដេចក្រឡាហោម ស ខេង ទទួលពាក្យបណ្ដឹងចំនួន១១ ទៀត ពាក់ព័ន្ធនឹងករណីបង្ខាំង និងជួញដូរ

https://freshnewsasia.com/index.php/en/localnews/256906-2022-09-11-11-20-28.html 2022-09-11 06:20pm

**(ភ្នំពេញ)៖** សម្រាប់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញនេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជ.ប.ដ) បានទទួលពាក្យបណ្តឹងចំនួន ១១ទៀត ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍លើករណីបង្ខាំង និងជួញដូរ។ នេះបើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ បើតាមអ្នកនាំពាក្យក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២ សម្តេចក្រឡាហោម បានទទួលពាក្យបណ្តឹងសរុបចំនួន១៨៦បណ្តឹង ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ជួយសង្គ្រោះជនបរទេស ដែលត្រូវបានអះអាងថាបង្ខាំង និងជួញដូរកម្លាំងពលកម្ម ៣៧៥នាក់ ក្នុងនោះមាន ១០សញ្ជាតិ រួមមានជនជាតិអាមេរិក ០២នាក់, ឥណ្ឌូណេស៊ី ០៣នាក់, ចិន ១៤៣នាក់, ម៉ាឡេស៊ី ៩៧នាក់, វៀតណាម ៤០នាក់, ចិនតៃវ៉ាន់ ៤២នាក់, ខ្មែរ ០៣នាក់, មីយ៉ាន់ម៉ា ០២នាក់, ឥណ្ឌា ១៦នាក់ និង បង់ក្លាដេស ០៩នាក់។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ។ នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅព្រឹកថ្ងៃទី០៩ ខែកញ្ញា រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ឱ្យគ្រប់រដ្ឋបាលរាជធានី ខេត្ត និងមូលដ្ឋានទាំងអស់ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរ និងរត់ពន្ធមនុស្ស ពលកម្ម បង្ខិតបង្ខំ និងអាជីវកម្មផ្លូវភេទ ឱ្យមានប្រសិទ្ធភាពផងដែរ៕

## សម្តេចក្រឡាហោម ស ខេង អំពាវនាវឲ្យគ្រប់មជ្ឈដ្ឋានគាំទ្រ និងចូលរួមរាយការណ៍អំពីអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ

http://freshnewsasia.com/index.php/en/localnews/257003-2022-09-12-09-59-10.html 2022-09-12 04:59pm

**(ព្រះសីហនុ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២នេះ បានអំពាវនាវឲ្យគ្រប់មជ្ឈដ្ឋានទាំងអស់គាំទ្រ និងចូលរួមក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដោយត្រូវរាយការណ៍មកកាន់បណ្តាញសង្គម និងលេខទូរស័ព្ទទំនាក់ទំនងរបស់ក្រុមការងារសម្តេច ដែលធ្លាប់ផ្តល់ជូន។ សម្តេចក្រឡាហោម ស ខេង ក្នុងឱកាសដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅខេត្តព្រះសីហនុ នាព្រឹកមិញនេះ បានឲ្យដឹងថា រហូតមកដល់ពេលនេះ ក្រសួងបានទទួលបណ្តឹង និងការរាយការណ៍ចំនួន ១៨៦ករណី។

កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីលោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ, លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ, នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ, នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស, ថ្នាក់ដឹកនាំរដ្ឋបាលខេត្តព្រះសីហនុ និងមន្ត្រីជាន់ខ្ពស់មួយចំនួនទៀត។ សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា កិច្ចប្រជុំនាថ្ងៃនេះជាផ្នែកមួយ នៃការជួយគាំទ្របន្ថែមទៀត ដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងខេត្តព្រះសីហនុ ដែលមានការប្រឈមទៅនឹងបទល្មើសប្រភេទនេះ។ សម្តេចក៏បានរំលឹកជាថ្មីទៀត អំពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសអនុសាសន៍ជំរុញណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា។

ក្នុងឱកាសនោះ លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ បានរាយការណ៍ជូនសម្តេចក្រឡាហោម និងអង្គប្រជុំអំពីវឌ្ឍនភាព នៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុសន្សនៅខេត្តព្រះសីហនុ ក្រោមកិច្ចប្រតិបត្តិការរបស់កម្លាំងនគរបាលជាតិ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងនោះរួមទាំងលទ្ធផល នៃកិច្ចប្រតិបត្តិការក្រោយ

ពីមានការដាក់ចេញផែនការដោយសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិ។

សម្ដេចក្រឡាហោម ស ខេង បានជំរុញរដ្ឋបាលខេត្ត និងគ្រប់ភាគីពាក់ព័ន្ធក្នុងខេត្តព្រះសីហនុ បន្តការខិតខំប្រឹងប្រែងបង្ក្រាបគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ដោយប្រកាន់យកគោលការណ៍៣ក្នុងកិច្ចប្រតិបត្តិការ គឺសង្គ្រោះជនរងគ្រោះ បង្ក្រាបទីតាំងប្រព្រឹត្តបទល្មើស និងចាប់ខ្លួនជនល្មើស បណ្ដាញ និងមេក្លោងពាក់ព័ន្ធមកផ្ដន្ទាទោសទៅតាមច្បាប់ ដើម្បីពង្រឹងសន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាពសង្គម ព្រមទាំងកិត្តិយសជាតិ។

**សូមជម្រាបថា ការផ្ដល់ព័ត៌មានអាចធ្វើទៅបានតាមរយៈ៖**

១៖ គេហទំព័រ Facebook: Samdech Krolahom Sar Kheng, Cambodian Deputy Prime Minister

២៖ លេខទូរសព្ទ Hotline របស់អគ្គស្នងការដ្ឋាននគរបាលជាតិ: ១១៧ និង (+៨៥៥) ៣១ ២០១ ២៣៤៥

៣៖ គេហទំព័រ Facebook: អគ្គស្នងការដ្ឋាននគរបាលជាតិ-General Commissariat of Natioral Police

៤៖ គេហទំព័រ Facebook: អគ្គនាយកដ្ឋានអន្តោប្រវេសន៍-General Department of Immigration-GDI៕

## សម្ដេច ស ខេង ឲ្យអាជ្ញាធរខេត្តព្រះសីហនុ បន្តខិតខំប្រឹងប្រែង បង្ក្រាបគ្រប់ទម្រង់ អំពើជួញដូរមនុស្ស

https://dap-news.com/national/2022/09/12/278362/ ByPH104Posted on September 12, 2022

**ភ្នំពេញ សម្ដេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំឲ្យអាជ្ញាធរខេត្តព្រះសីហនុ ត្រូវបន្តខិតខំប្រឹងប្រែងបង្ក្រាបគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ដោយប្រកាន់យកគោលការណ៍៣ ក្នុងកិច្ចប្រតិបត្តិការ ដើម្បីពង្រឹងសន្តិសុខសណ្ដាប់ធ្នាប់សង្គម។**

ក្នុងកិច្ចប្រជុំ ត្រួតពិនិត្យការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅខេត្តព្រះសីហនុ នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ សម្ដេច ស ខេង បានថ្លែងថា កិច្ចប្រជុំនាថ្ងៃនេះ ជាផ្នែកមួយនៃការជួយគាំទ្របន្ថែមទៀត ដល់ការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សក្នុងខេត្តព្រះសីហនុ ដែលមានការប្រឈម ទៅនឹងបទល្មើសប្រភេទនេះ។ សម្ដេច ក៏បានរំលឹកជាថ្មីទៀត អំពីការប្ដេជ្ញាចិត្តរបស់កម្ពុជា ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសអនុសាសន៍ជំរុញ ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា ។ សម្ដេចបន្តថា កាលពីពេលថ្មីៗនេះ ក្រសួងបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ផែនការកិច្ចប្រតិបត្តិការ លើការងារនេះ ហើយក្នុងឋានៈជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួរមនុស្ស សម្ដេចក៏បានអំពាវនាវឱ្យមានការគាំទ្រ និងចូលរួមក្នុងការងារនេះ ដោយបានផ្ដល់បណ្ដាញ និងលេខទូរសព្ទទំនាក់ទំនងរាយការណ៍អំពីករណីនេះ។

សម្ដេច ស ខេង មានប្រសាសន៍ថា «ជំរុញរដ្ឋបាលខេត្ត និងគ្រប់ភាគីពាក់ព័ន្ធក្នុងខេត្តព្រះសីហនុ បន្តការខិតខំប្រឹងប្រែងបង្ក្រាបគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ដោយប្រកាន់យកគោលការណ៍៣ ក្នុងកិច្ចប្រតិបត្តិការ គឺសង្គ្រោះជនរងគ្រោះ បង្ក្រាបទីតាំងប្រព្រឹត្តបទល្មើស និងចាប់ខ្លួនជនល្មើស បណ្ដាញ និងមេក្លោងពាក់ព័ន្ធមកផ្ដន្ទាទោសទៅតាមច្បាប់ ដើម្បីពង្រឹងសន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាពសង្គម ព្រមទាំងកិត្តិយសជាតិ»។

សូមរំលឹកថា ចាប់ពីថ្ងៃទី១៨ សីហា ដល់ថ្ងៃទី១០ កញ្ញា ហ្វេសប៊ុក សម្ដេច ស ខេង បានទទួលពាក្យបណ្ដឹង ចំនួន ១៨៦បណ្ដឹង ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ ជួយសង្គ្រោះជនបរទេស ដែលត្រូវបានអះអាងថាបង្ខាំង និងជួញដូរកម្លាំងពលកម្ម ៣៧៥នាក់៕

# ក្រុមគាំទ្រជនរងគ្រោះម៉ាឡេស៊ីនិយាយថា
# អាស៊ានត្រូវតែដោះស្រាយបញ្ហានៃការបោកប្រាស់ការងារ

https://www.khmertimeskh.com/501148713//?p=1148713 September 11, 2022

ក្រុមគាំទ្រម៉ាឡេស៊ីជាច្រើន បានជំរុញឱ្យក្រសួងការបរទេសម៉ាឡេស៊ីឱ្យអាស៊ានដោះស្រាយបញ្ហា នៃក្រុមដែលប្រើការទាក់ទាញការងារនៅបរទេសដើម្បីចាប់ និងជួញដូរអ្នកស្វែងរកការងារ។ ក្នុងអនុស្សរណៈដែលប្រគល់ឲ្យក្រសួងការបរទេស ក្រុមទាំងនោះក៏ទាមទារឲ្យប្រមុខរដ្ឋាភិបាលធ្វើអន្តរាគមន៍ ជាពិសេសនៅក្នុងប្រទេសដូចជាកម្ពុជា មីយ៉ាន់ម៉ា និងឡាវ។ សមាជិកក្រុមគ្រួសារជនរងគ្រោះមានវត្តមាននៅពេលប្រគល់អនុស្សរណៈ។

Bernama បានរាយការណ៍ថាលោក Hishamuddin Hashim អគ្គលេខាធិការនៃអង្គការមនុស្សធម៌អន្តរជាតិម៉ាឡេស៊ីបានមានប្រសាសន៍ថាសកម្មភាព "វិសាមញ្ញ" មួយគឺត្រូវការជាបន្ទាន់។ លោកបាននិយាយទៅកាន់អ្នកសារព័ត៌មានបន្ទាប់ពីប្រគល់អនុស្សរណៈនេះថា "ក្រសួងការបរទេស និងរដ្ឋាភិបាលម៉ាឡេស៊ីត្រូវប្រើវេទិកាថ្នាក់ខ្ពស់បំផុតដែលមាន" ដោយជំរុញឱ្យរដ្ឋាភិបាលចាត់វិធានការអោយបានខ្លាំងក្លាដើម្បីយកឈ្នះលើបញ្ហានេះ។ លោកបានមានប្រសាសន៍ថា "យើងត្រូវដាក់សម្ពាធដោយប្រើវេទិកាអាស៊ាន និងនាយករដ្ឋមន្ត្រី (នៃប្រទេសអាស៊ានីមួយៗ) ពីព្រោះប្រសិនបើយើងបន្តប្រើប្រាស់បណ្ដាញធម្មតា ករណីនេះនឹងមិនអាចដោះស្រាយបានទេ" ដោយយោងទៅកាន់ស្ថានទូត និងអាជ្ញាធរពាក់ព័ន្ធរបស់ប្រទេសនានាថាជាបណ្ដាញធម្មតា។

អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតដែលពាក់ព័ន្ធគឺ Persatuan Pengguna Semboyan Malaysia, Pertubuhan Penggerak Ekonomi Islam Malaysia និង Pertubuhan Ekonomi Negeri Sembilan ។ លោក Hishamuddin បានមានប្រសាសន៍ថាជនរងគ្រោះនៃក្រុមនេះក៏ត្រូវបានលក់ពីភ្នាក់ងារមួយទៅភ្នាក់ងារមួយទៀត ឬផ្លាស់ទីទៅប្រទេសផ្សេងទៀតដោយប្រើផ្លូវខុសច្បាប់។ លេខាធិការនៃកងកម្លាំងនគរបាលលោក Noorsiah Mohd Saaduddin បាននិយាយកាលពីខែមុនថា ជនជាតិម៉ាឡេស៊ីចំនួន ២៣៨ នាក់បានធ្លាក់ខ្លួនជាជនរងគ្រោះនៃក្រុមការងារដោយមនុស្ស ១៦៨នាក់នៅតែជាប់គាំងនៅបរទេស។ ជនរងគ្រោះភាគច្រើនត្រូវបានបោកបញ្ឆោតដោយការផ្សាយពាណិជ្ជកម្មដែលបង្ហោះនៅលើ Facebook ដែលបានសន្យាថាពួកគេផ្តល់ឱកាសការងារជាមន្ត្រីបម្រើអតិថិជននៅបរទេសជាមួយនឹងប្រាក់ខែល្អ។ ពួកគេត្រូវបានទាក់ទាញឱ្យទាក់ទងភ្នាក់ងារតាមរយៈសារដេដែក ហើយនឹងត្រូវបានប្រាប់ថាការចំណាយលើការធ្វើដំណើររបស់ពួកគេនឹងត្រូវបានគេរ៉ាប់រង។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលទៅដល់គោលដៅ ឯកសារធ្វើដំណើរ និងទូរស័ព្ទរបស់ពួកគេត្រូវបានរឹបអូស និងបំផ្លាញចោល ហើយពួកគេនឹងត្រូវចាក់សោរ ហើយនៅទីបំផុតត្រូវបង្ខំឱ្យធ្វើការឱ្យក្រុមដែលពាក់ព័ន្ធនឹងការលេងល្បែងអនឡាញ ការវិនិយោគ និងការបោកប្រាស់ស្នេហា ក្នុងចំណោមបញ្ហាដទៃទៀត។

កាលពីថ្ងៃសុក្រ ក្រុមជនជាតិម៉ាឡេស៊ីចំនួន ២៤ នាក់ ដែលបានធ្លាក់ខ្លួនរងគ្រោះដោយសារការបោកប្រាស់ការងារនៅកម្ពុជា ត្រូវបានត្រឡប់ទៅផ្ទះវិញជាមួយរដ្ឋមន្ត្រីការបរទេស Saifuddin Abdullah ដែលនៅរាជធានីភ្នំពេញក្នុងដំណើរទស្សនកិច្ចការងារ។ ២៩នាក់ទៀតនៅរង់ចាំនិរទេសនៅភ្នំពេញ និងមណ្ឌលឃុំខ្លួនអន្តោប្រវេសន៍ខេត្តព្រះសីហនុនៅកម្ពុជា។ Free Malaysia Today

# ស្ថានទូតចិនប្រចាំកម្ពុជា អំពាវនាវជាថ្មីកុំឱ្យពលរដ្ឋរបស់ខ្លួនជឿការឆបោករបស់ឧក្រិដ្ឋជន ថា មកធ្វើការនៅកម្ពុជាបានប្រាក់ខែខ្ពស់

https://www.postkhmer.com/national/2022-09-11-1552-240852.html សេក ប្រាក់ and ឡាយ សាមាន | Publication date 11 September 2022 | 15:52 ICT

**ភ្នំពេញ:** ស្ថានទូតចិនប្រចាំនៅកម្ពុជា បានអំពាវនាវជាថ្មី កុំឱ្យប្រជាពលរដ្ឋរបស់ខ្លួនចាញ់បោកការឃោសនាពីក្រុមឆបោកមួយចំនួន ដែលអះអាងថា ការមកធ្វើការនៅកម្ពុជានឹងទទួលបានប្រាក់ខែខ្ពស់ ខណៈកន្លងមកកម្ពុជា មានកិច្ចសហការល្អជាមួយស្ថានទូតក៏ដូចជារដ្ឋាភិបាលនៃប្រទេសចិន ចំពោះបញ្ហានេះ។ តាមរយៈគេហទំព័ររបស់ខ្លួននៅថ្ងៃទី ៧ ខែកញ្ញា ស្ថានទូតចិនប្រចាំកម្ពុជា បានរំឭកពលរដ្ឋកុំឱ្យចាញ់បោកក្រុមឧក្រិដ្ឋជន ខណៈបទល្មើសឆបោកតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា កំពុងកើនឡើង។ ស្ថានទូតចិនប្រចាំកម្ពុជា បានកត់សម្គាល់ថា ពលរដ្ឋចិនត្រូវបានចាប់ជំរិត និងរឹតត្បិតសេរីភាពផ្ទាល់ខ្លួន ដោយក្រុមបោកប្រាស់ល្បែងស៊ីសងតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា បានកើតឡើងជាបន្តបន្ទាប់ នៅមួយរយៈចុងក្រោយនេះ។ ភាគច្រើននៃការចាប់ជំរិត គឺដោយសារពលរដ្ឋចិនបានចាញ់បោកការឃោសនាអំពីឱកាសការងារនៅកម្ពុជាថានឹងទទួលបានកម្រៃខ្ពស់។ បញ្ហានេះ ស្ថានទូតចិនបានរំឭកពលរដ្ឋខ្លួនជាថ្មីថា៖ «កុំឱ្យជឿលើការឃោសនាក្លែងក្លាយ នៃក្រុមល្បែងស៊ីសង និងក្រុមបោកប្រាស់ ហើយរត់មកកម្ពុជាខុសច្បាប់»។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គជបជ) មានប្រសាសន៍ថា ការអំពាវនាវរបស់ស្ថានទូតចិនប្រចាំកម្ពុជានាពេលនេះ គឺជាសារក្រើនរំឭកដល់ពលរដ្ឋខ្លួន កុំឱ្យបន្តចាញ់បោកមេខ្យល់បន្តទៀត។ លោកស្រីបញ្ជាក់ថា៖ «កន្លងកម្ពុជា មានកិច្ចសហការល្អជាមួយស្ថានទូតក៏ដូចជារដ្ឋាភិបាលនៃប្រទេសចិន ដោយសារកន្លងមកនៅពេលណាយើងមានការបង្ក្រាបបទល្មើសគឺពួកគាត់ស្ម័គ្រចិត្ត មកយកប្រជាពលរដ្ឋគាត់ទៅដោយខ្លួនឯង បើនិយាយពីជនល្មើសវិញគឺគាត់ស្នើសុំទៅកាត់ទោសឬដំណើរការនីតិវិធីនៅប្រទេសគាត់ ព្រោះខាងគាត់ក៏តឹងតែងដែរមិនធូរប៉ុន្មានទេ»។ ជាមួយគ្នានេះដែរ លោកស្រីអំពាវនាវសុំឱ្យប្រទេសនីមួយៗ គួរមានវិធានការទប់ស្កាត់ ហាមឃាត់ពលរដ្ឋខ្លួនឯងកុំចេះតែចាញ់បោកគេ ពីព្រោះមេខ្យល់មាននៅតាមប្រទេសរៀងៗខ្លួន។ ប្រឈមនឹងបញ្ហាដូច្នេះ រដ្ឋាភិបាលកម្ពុជានិងចិន បានសហការគ្នា បន្ថែមសេវាកម្មពិសេសសម្រាប់បណ្ដាញជនជាតិចិន ដើម្បីរាយការណ៍ដល់អាជ្ញាធរស្នើសុំការអន្តរាគមន៍ជាបន្ទាន់។

បើតាមក្រសួងមហាផ្ទៃ បច្ចុប្បន្នអាជ្ញាធរបានបង្កើតប្រព័ន្ធ Hotline ពិសេស ដើម្បីទទួលការរាយការណ៍ពីករណីឆបោក និងជួញដូរមនុស្សនៅកម្ពុជា។ ត្រឹមថ្ងៃទី ៥ កញ្ញា ឆ្នាំ ២០២២ គណនីហ្វេសប៊ុកមួយ ក្នុងចំណោមគណនី និងប្រព័ន្ធ Hotline ចំនួន ៤ ដែលបើកទទួលពាក្យបណ្ដឹងពីពលរដ្ឋ ហើយទទួលបានបណ្ដឹងសុំអន្តរាគមន៍ចំនួន ១១៧ បណ្ដឹង ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។ បណ្ដឹងទាំង ១១៧ នោះ គឺពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ជួយសង្គ្រោះជនបរទេស ដែលបានអះអាងថាត្រូវបានបង្ខាំង និងជួញដូរកម្លាំងពលកម្មក្នុងប្រទេសកម្ពុជា។ បើតាមក្រសួងមហាផ្ទៃ អំពើបង្ខាំង និងជួញដូរកម្លាំងពលកម្ម ភាគច្រើនកើតមាននៅតាមក្រុមហ៊ុនល្បែងស៊ីសង ឬកាស៊ីណូ ខណៈជនរងគ្រោះភាគច្រើន ជាជនជាតិ ចិន វៀតណាម និងម៉ាឡេស៊ី។ ក្រសួងមហាផ្ទៃបញ្ជាក់ថា ជនបរទេសមួយចំនួនធំ បានចូលមកកម្ពុជាដោយខុសច្បាប់ តាមរយៈមេខ្លោងនៅប្រទេសរបស់គេ និងបក្ខពួកនៅកម្ពុជា ដោយសន្យាផ្ដល់ការងារប្រាក់ខែខ្ពស់។ ករណីនេះ គឺពួកគេត្រូវបានចាញ់បោក និងគំរាមកំហែងក្រោមរូបភាពផ្សេងៗ ដូចជា ការធ្វើការលើសកម្លាំងពលកម្មដោយមិនទទួលបានប្រាក់ខែនិងត្រូវបានផ្ទេរពីក្រុមហ៊ុន ១ ទៅក្រុមហ៊ុន១ទៀត។

គួរបញ្ជាក់ថា ក្នុងរយៈពេល ៨ ខែ ឆ្នាំ ២០២២ នេះ អាជ្ញាធរកម្ពុជាបានជួយសង្គ្រោះជនរងគ្រោះចំនួន ៨៦៥ នាក់ ពីបទល្មើសជួញដូរមនុស្ស ខណៈជនសង្ស័យ ៦០ នាក់ ត្រូវបានឃាត់ខ្លួន។ នេះបើតាមការបញ្ជាក់របស់លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ២៦ សីហា។ ទោះបីកំពុងប្រឈមខ្លាំងនឹងបទល្មើសជួញដូរមនុស្សក្តី តែលោក ស ខេង បានបញ្ជាក់ថា កម្ពុជានៅតែបន្តប្តេជ្ញាចិត្ត ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើឆបោកជំរិតទារប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន និងសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងជួយការពារជនរងគ្រោះទាំងពលរដ្ឋកម្ពុជា និងជនបរទេស៕

## អ.ស.ប. ៖ ទាសករបែបថ្មី ឡើងដល់ជិត៥០លាននាក់ នៅឆ្នាំ២០២១

https://www.rfi.fr/km//20220912?ref=tg_i ចុះផ្សាយនៅថ្ងៃ៖ 12/09/2022 - 13:09ដោយ៖អៀង សុខម៉ិញ

ចំនួនមនុស្សរងគ្រោះធ្វើពលកម្មដោយបង្ខំ និងរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានកើនឡើងជាលំដាប់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយមកនេះ។ ពន្លឿនបន្ថែមដោយវិបត្តិកូវីដ នៅក្នុងឆ្នាំ២០២១ មានមនុស្សជិត៥០លាននាក់ បានធ្លាក់ខ្លួនជាទាសករបែបថ្មី។ នេះបើតាមរបាយការណ៍របស់អង្គការសហប្រជាជាតិ ចេញផ្សាយនៅថ្ងៃចន្ទទី ១២ កញ្ញា ២០២២។ អង្គការសហប្រជាជាតិមានផែនការលុបបំបាត់ទាសភាពបែបថ្មី នៅឆ្នាំ២០៣០ ប៉ុន្តែបើតាមរបាយការណ៍ចុងក្រោយរបស់អង្គការពលកម្មអន្តរជាតិ និងអង្គការដើម្បីអន្តោប្រវេសន៍អន្តរជាតិ សហការជាមួយអង្គការក្រៅរដ្ឋាភិបាល Walk Free Foundation នៅឆ្នាំ២០២១ ចំនួនជនរងគ្រោះ ធ្វើពលកម្មដោយបង្ខំ និងរៀបការដោយបង្ខំ បានកើនឡើង១០លាននាក់បើប្រៀបទៅនឹងឆ្នាំ២០១៦។ ក្នុងចំណោមទាសករបែបថ្មី ទាំងជិត៥០លាននាក់ ជិត២៧,៦លាននាក់ជាជនរងគ្រោះដោយពលកម្មដោយបង្ខំ និង២២លាននាក់ បានរៀបការដោយបង្ខំ។ ជាងពីរភាគបីនៃជនរងគ្រោះរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជានារីនិងកុមារី ហើយបួនលើប្រាំនាក់ ស្ថិតក្នុងស្ថានភាពរកស៊ីផ្លូវភេទ។

ជាសរុបស្ត្រីតំណាងឱ្យ ៥៤%នៃទាសភាពបែបថ្មី។ ឯពលករអន្តោប្រវេសន៍ងាយរងគ្រោះដោយពលកម្មដោយបង្ខំ ជាងបីដងលើសពលករពេញវ័យមិនមែនជាជនអន្តោប្រវេសន៍។ នេះបើតាមរបាយការណ៍ដដែលរបាយការណ៍បានលម្អិតទៀតថា ទាសភាពបែបថ្មី មាននៅក្នុងគ្រប់ប្រទេសទាំងអស់លើពិភពលោក តែជាងពាក់កណ្តាល (៥២%) នៃជនរគ្រោះធ្វើពលកម្មដោយបង្ខំ និង១/៤នៃការរៀបការដោយបង្ខំ ស្ថិតនៅក្នុងប្រទេសមានចំណូលទាបនិងមធ្យម នៅតំបន់ អាស៊ី និងប៉ាស៊ីហ្វិក។ ក្រៅពីជំងឺរាតត្បាតសកលកូវីដ ដែលបានធ្វើឱ្យលក្ខខណ្ឌការងារធ្លាក់ចុះ និងឡើងបំណុល របាយការណ៍បានពន្យល់ថាមានជាមូលហេតុរួមផ្សំជាច្រើនផ្សេងទៀតដែលជំរុញឱ្យមានកំណើនទាសភាពបែបថ្មី។ ជម្លោះប្រដាប់អាវុធ និងវិបត្តិអាកាសធាតុប្រែប្រួល បានរំខានវិស័យការងារនិងអប់រំ បានធ្វើឱ្យមានភាពក្រីក្រកាន់តែធ្ងន់ធ្ងរ បានបង្ខំឱ្យមនុស្សធ្វើអន្តោប្រវេសន៍ ប្រថុយនឹងគ្រោះថ្នាក់។

កាន់តែគួរឱ្យព្រួយបារម្ភ ស្ថានភាពទាសភាពបែបថ្មីមិនមែនជាហេតុការណ៍មួយសំណើទេ តែជាបញ្ហាត្រាំត្រែងយូរ។ ហេតុដូច្នេះហើយបានជានៅក្នុងសេចក្តីថ្លែងការណ៍ អគ្គនាយកអង្គការពលកម្មអន្តរជាតិ បានសម្តែងភាពតក់ស្លុតនឹងស្ថានភាពទាសភាពបែបថ្មីដែលមិនប្រសើរឡើងសោះ ដោយបានអំពាវនាវឱ្យរដ្ឋាភិបាល សហជីព អង្គការនិយោជក សង្គមស៊ីវិល និងពលរដ្ឋទូទៅ នាំគ្នាប្រយុទ្ធប្រឆាំងនឹងការរំលោភសិទ្ធិជាមូលដ្ឋានរបស់មនុស្ស។ របាយការណ៍បានស្នើឱ្យបញ្ចេញសកម្មភាពមួយចំនួនដូចជា ធ្វើ -អនុវត្តច្បាប់ត្រួតពិនិត្យការងារឱ្យបានល្អជាងមុន រដ្ឋត្រូវបញ្ចប់ពលកម្មដោយបង្ខំ ពង្រីកកិច្ចការពារសង្គម ពង្រឹងកិច្ចការពារតាមផ្លូវច្បាប់ ដោយកំណត់ឱ្យរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ចាប់ពីអាយុ១៨ឆ្នាំឡើងទៅដោយគ្មានករណីលើកលែង៕

# នៅថ្ងៃទី១១ ខែកញ្ញា ម្សិលមិញ សម្តេចក្រឡាហោម ស ខេង បានទទួលសំណើចំនួន ០៧ ករណី ពាក់ព័ន្ធនឹងករណីបង្ខាំង និងជួញដូរ

http://freshnewsasia.com/index.php/en/localnews/257042-2022-09-12-14-34-46.html 2022-09-12 09:34pm

(ភ្នំពេញ)៖ សម្រាប់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញនេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជ.ប.ដ) បានទទួលពាក្យបណ្តឹងចំនួន ០៧ទៀត ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍លើករណីបង្ខាំង និងជួញដូរ។ នេះបើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។

នាយឧត្តមសេនីយ៍ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់បន្ថែមថា ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២ សម្តេចក្រឡាហោម បានទទួលពាក្យបណ្តឹងសរុបចំនួន១៩៣បណ្តឹង ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ជួយសង្គ្រោះជនបរទេស ដែលត្រូវបានអះអាងថាបង្ខាំង និងជួញដូរកម្លាំងពលកម្ម ក្នុងនោះមានករណីមួយចំនួនត្រូវបានសមត្ថកិច្ចកម្ពុជា ស្វែងរកឃើញហើយ និងចាត់វិធានការផ្សេងៗ។ ចំណែកករណីមួយចំនួនទៀត នៅមិនទាន់រកឃើញនៅឡើយ ខណៈសមត្ថកិច្ចកំពុងតាមស៊ើបអង្កេត។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ។ នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅព្រឹកថ្ងៃទី០៩ ខែកញ្ញា រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ ឱ្យគ្រប់រដ្ឋបាលរាជធានី ខេត្ត និងមូលដ្ឋានទាំងអស់ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរ និងរត់ពន្ធមនុស្ស ពលកម្ម បង្ខិតបង្ខំ និងអាជីវកម្មផ្លូវភេទ ឱ្យមានប្រសិទ្ធភាពផងដែរ៕

# ក្រសួងមហាផ្ទៃ ទទួលបានបណ្តឹងអំពីការជួញដូរមនុស្សជិត២០០ករណី

https://thmeythmey.com/?page=detail&id=119107 12, Sep 2022 , 5:09 pm ដោយ: សារព័ត៌មានថ្មីៗ

មួយរយៈពេលចុងក្រោយនេះ ក្រសួងមហាផ្ទៃ ទទួលបានជាង១៨០បណ្តឹង អំពីការជួញដូរមនុស្ស និងការជួញដូរកម្លាំងពលកម្មនៅកម្ពុជា។ សម្តេច ស ខេង បានបញ្ចេញតួលេខនេះ ក្នុងកិច្ចប្រជុំ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការប្រយុទ្ធប្រឆាំងបទល្មើសទាំងនេះ ក្នុងខេត្តព្រះសីហនុ។

សម្តេចរដ្ឋមន្ត្រីមហាផ្ទៃ បានណែនាំឲ្យសមត្ថកិច្ច បន្តប្រឹងប្រែងបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដោយប្រកាន់យកគោលការណ៍៣ គឺសង្គ្រោះជនរងគ្រោះ បង្ក្រាបទីតាំងប្រព្រឹត្តបទល្មើស និងចាប់ខ្លួនជនល្មើស។ សម្តេចសង្កត់ថា សមត្ថកិច្ច ត្រូវចាប់បណ្តាញ និងមេខ្លោងពាក់ព័ន្ធ យកទៅផ្តន្ទាទោសទៅតាមច្បាប់ ដើម្បីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ព្រមទាំងកិត្តិយសជាតិ។ សម្តេច មានប្រសាសន៍ថា ការបើកកិច្ចប្រជុំនេះ គឺដើម្បី

គាំទ្រដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងខេត្តព្រះសីហនុ ដែលកំពុងប្រឈមទៅនឹងបទល្មើសប្រភេទនេះ។ ជាថ្មីម្តងទៀត សម្តេច នអំពាវនាវឲ្យមានការគាំទ្រនិងការចូលរួមពីភាគីនានា ក្នុងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ កាលពីអំឡុងខែកក្កដា ឆ្នាំ២០២២ សហរដ្ឋអាមេរិក បានដាក់កម្ពុជា ចូលទៅក្នុងបញ្ជីខ្មៅនៃក្រុមប្រទេស ដែលមានការលួញជួញដូរមនុស្សធ្ងន់ធ្ងរ៕

## ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

### រាជរដ្ឋាភិបាល នឹងបង្កើនការស្រាវជ្រាវ បង្ក្រាប និងអនុវត្តតាមច្បាប់យ៉ាងម៉ឺងម៉ាត់ដោយគ្មានការលើកលែងចំពោះទីតាំង និងបុគ្គល ពាក់ព័ន្ធនឹងអំពើជួញដូរ និងរត់ពន្ធមនុស្សគ្រប់ទម្រង់

http://freshnewsasia.com/index.php/en/localnews/257109-2022-09-13-06-43-34.html 2022-09-13 01:43pm

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើនការស្រាវជ្រាវ បង្ក្រាប ហើយអនុវត្តច្បាប់ ដោយស្មើភាព និងម៉ឺងម៉ាត់ ដោយគ្មានការលើកលែងចំពោះទីតាំង និងបុគ្គល ពាក់ព័ន្ធនឹងអំពើជួញដូរ និងរត់ពន្ធមនុស្សគ្រប់ទម្រង់នៅក្នុងប្រទេសកម្ពុជា។

ការសម្រេចរបស់រាជរដ្ឋាភិបាល បានធ្វើឡើងតាមរយៈចំណាររបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា លើរបាយការណ៍របស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីស្ថានភាព និងកិច្ចប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង រត់ពន្ធមនុស្ស។ **យោងតាមលិខិត របស់ទីស្តីការ គណៈរដ្ឋមន្ត្រីដែលបណ្តាញព័ត៌មាន Fresh New ទទួលបាននៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២នេះ បានឱ្យដឹងថា រាជរដ្ឋាភិបាលបានឃើញរបាយការណ៍របស់ សម្តេចក្រឡាហោម និងឯកភាពដូចខាងក្រោម៖**

**១៖** បង្កើនកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីសង្គ្រោះជនរងគ្រោះ ស្រាវជ្រាវរកជនល្មើសមកផ្តន្ទាទោសតាមច្បាប់ និងបង្ក្រាបល្បែងស៊ីសងខុសច្បាប់ដែលមានការពាក់ព័ន្ធ។

**២៖** ចំពោះករណីដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពិតប្រាកដ ឬការជួញដូរកម្លាំងពលកម្ម ឬការឆបោកតាមប្រព័ន្ធអនឡាញ ត្រូវពន្លាតការស្រាវជ្រាវនោះសំដៅទៅរក បទល្មើសសម្អាតប្រាក់ថែមទៀត។

**៣៖** អនុវត្តដោយស្មើភាពស្របតាមច្បាប់ជាធរមាន និងប្រកបដោយការទទួលខុសត្រូវខ្ពស់នៅគ្រប់ទីតាំងដែលសង្ស័យថាពាក់ព័ន្ធនឹងអំពើជួញដូរ និងរត់ពន្ធមនុស្សគ្រប់ទម្រង់ ដោយអនុវត្តវិធានការច្បាប់ ម៉ឺងម៉ាត់លើទីតាំង និងបុគ្គលដែលត្រូវបានរកឃើញថា ជាប់ពាក់ព័ន្ធនឹងបទល្មើសនេះ ហើយត្រូវទទួលរងទណ្ឌកម្មស្របតាមការកំណត់នៃច្បាប់ដោយគ្មានការលើកលែង។

**៤៖** ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការវាយបក និងឆ្លើយតបទាន់ពេលវេលារាល់ការផ្សព្វផ្សាយព័ត៌មានដែលមានចរិតញុះញង់ និងស្នើឱ្យកែតម្រូវចំណុចដែលផ្ទុយពីការពិត ដើម្បីបន្សាបឥទ្ធិពលវាយប្រហារ អវិជ្ជមានពីមជ្ឈដ្ឋាននានា ទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងបញ្ចៀសផលប៉ះពាល់មកលើបរិយាកាស នយោបាយ និងសន្តិសុខសង្គម។

**៥៖** បង្កើនកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ សំដៅត្រួតពិនិត្យ និងរៀបចំរបៀបរៀបរយនៅតាមបណ្តាទីតាំងដែលមានការប្រមូលផ្តុំការស្នាក់នៅ ការធ្វើអាជីវកម្ម និងការប្រើប្រាស់កម្លាំងពលកម្មជនបរទេស សំដៅគ្រប់គ្រងជនបរទេសឱ្យបានហ្មត់ចត់ និងទប់ស្កាត់ការជ្រៀតចូលដោយខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែន៕

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ៧៧.២៨.សជណ

ថ្ងៃសុក្រ ១៤ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមជម្រាបជូន**

**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**កម្មវត្ថុ ៖** ករណីរបាយការណ៍ស្តីពីស្ថានភាព និងកិច្ចប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរត់ពន្ធមនុស្ស។

**យោង ៖** - លិខិតលេខ១២៥ របក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ

- លិខិតលេខ៤៧៥ ខន/០២២ សជណ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនសម្តេចក្រឡាហោម មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានឃើញនិងឯកភាពដូចខាងក្រោម៖

១-បង្កើនកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីសង្គ្រោះជនរងគ្រោះ ស្រាវជ្រាវរកជនល្មើសមកផ្តន្ទាទោសតាមច្បាប់ និងបង្ក្រាបល្បែងស៊ីសងខុសច្បាប់ដែលមានការពាក់ព័ន្ធ។

២-ចំពោះករណីដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពិតប្រាកដ ឬការជួញដូរកម្លាំងពលកម្ម ឬការឆបោកតាមប្រព័ន្ធអនឡាញ ត្រូវពន្លាតការស្រាវជ្រាវនោះសំដៅទៅរកបទល្មើសសម្អាតប្រាក់ថែមទៀត។

៣-អនុវត្តដោយស្មើភាពស្របតាមច្បាប់ជាធរមាន និងប្រកបដោយការទទួលខុសត្រូវខ្ពស់នៅគ្រប់ទីតាំងដែលសង្ស័យថាពាក់ព័ន្ធនឹងអំពើជួញដូរ និងរត់ពន្ធមនុស្សគ្រប់ទម្រង់ ដោយអនុវត្តវិធានការច្បាប់មឺងម៉ាត់លើទីតាំង និងបុគ្គលដែលត្រូវបានរកឃើញថាជាប់ពាក់ព័ន្ធនឹងបទល្មើសនេះ ហើយត្រូវទទួលរងទណ្ឌកម្មស្របតាមការកំណត់នៃច្បាប់ដោយគ្មានការលើកលែង។ទ.

៤-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការវាយបក និងឆ្លើយតបទាន់ពេលវេលារាល់ការផ្សព្វផ្សាយព័ត៌មានដែលមានចរិតញុះញង់ និងស្នើឱ្យកែតម្រូវចំណុចដែលផ្ទុយពីការពិត ដើម្បីបន្សាបឥទ្ធិពលវាយប្រហារអវិជ្ជមានពីមជ្ឈដ្ឋាននានា ទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងបញ្ចៀសផលប៉ះពាល់មកលើបរិយាកាសនយោបាយ និងសន្តិសុខសង្គម។

៥-បង្កើនកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ សំដៅត្រួតពិនិត្យ និងរៀបចំរបៀបរៀបរយនៅតាមបណ្ដាទីតាំងដែលមានការប្រមូលផ្ដុំការស្នាក់នៅ ការធ្វើអាជីវកម្ម និងការប្រើប្រាស់កម្លាំងពលកម្មជនបរទេស សំដៅគ្រប់គ្រងជនបរទេសឱ្យបានហ្មត់ចត់ និងទប់ស្កាត់ការជ្រៀតចូលដោយខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែន។

សេចក្ដីដូចបានជម្រាបជូនខាងលើសូមសម្ដេចក្រឡាហោម មេត្តាជ្រាបនិងចាត់ចែងអនុវត្ត។ទ.Lpk

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

Thyxy

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

**ចម្លងជូន៖**
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងកិច្ចការនារី
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

## សម្តេចក្រឡាហោមជំរុញរដ្ឋបាលខេត្តនិងគ្រប់ភាគីពាក់ព័ន្ធក្នុងខេត្តព្រះសីហនុបង្កើនការប ង្រ្កាបគ្រប់ទម្រង់នៃអំពើជួញដូរមនុស្សឱ្យមានប្រសិទ្ធភាពខ្ពស់

https://www.information.gov.kh/articles/86044 ចេញផ្សាយ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២២

MC៖ សម្តេចក្រឡាហោមជំរុញរដ្ឋបាលខេត្ត និងគ្រប់ភាគីពាក់ព័ន្ធក្នុងខេត្តព្រះសីហនុ បន្តការខិតខំប្រឹងប្រែងបង្រ្កាបគ្រប់ទម្រង់នៃអំពើជួញដូរមនុស្សដោយប្រកាន់យកគោលការណ៍ ៣ ក្នុងកិច្ចប្រតិបត្តិការ ដើម្បីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមព្រមទាំងកិត្តិយសជាតិ។ ថ្លែងក្នុងកិច្ចកិច្ចប្រជុំត្រួត ពិនិត្យការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្សជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទនៅខេត្តព្រះសីហនុនាថ្ងៃ ទី១២ ខែកញ្ញា ឆ្នាំ ២០២២ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានមាន ប្រសាសន៍ថា ហូតមកដល់ពេលនេះ ក្រសួងបានទទួលបណ្តឹង និងការរាយការណ៍ចំនួន១៨៦ករណី។ ដូច្នេះកិច្ចប្រជុំនាថ្ងៃនេះ ជាផ្នែកមួយនៃការជួយគាំទ្របន្ថែមទៀត ដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងខេត្តព្រះសីហនុ ដែលមានការប្រឈម ទៅនឹងបទល្មើសប្រភេទនេះ។

សម្តេចក្រឡាហោមបានរំលឹកជាថ្មីទៀត អំពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ពិសេសអនុសាសន៍ជំរុញណែនាំដ៏ខ្ពង់ខ្ពស់ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា។ សម្តេចក្រឡាហោម ជំរុញរដ្ឋបាលខេត្ត និងគ្រប់ភាគី ពាក់ព័ន្ធក្នុងខេត្ត ព្រះសីហនុបន្តការខិតខំប្រឹងប្រែងបង្រ្កាបគ្រប់ទម្រង់នៃអំពើជួញដូរ មនុស្ស ដោយប្រកាន់យកគោលការណ៍៣ក្នុងកិច្ចប្រតិបត្តិការ គឺសង្រ្គោះជនរងគ្រោះ បង្រ្កាបទីតាំងប្រព្រឹត្ត បទល្មើស និងចាប់ខ្លួនជនល្មើសបណ្តាញ និងមេខ្លោងពាក់ព័ន្ធមកផ្តន្ទាទោសទៅតាមច្បាប់ ដើម្បីពង្រឹង សន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ព្រមទាំងកិត្តិយសជាតិ៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូល ខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/2022/09/12/26/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង ១៥ និង១០នាទី ថ្ងៃចន្ទ ២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស .២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុ៉ឹង–ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១៧នាក់ ស្រី១០នាក់ក្មេង២នាក់ ក្មេងស្រី១នាក់ ។ ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ថ្ងៃទី១២ ខែកញ្ញា ម្សិលមិញ សមត្ថកិច្ចបើកប្រតិបត្តិការចុះស្រាវជ្រាវ និងត្រួតពិនិត្យចំនួន៦ករណី សង្គ្រោះជនបរទេសចំនួន ៨នាក់

http://freshnewsasia.com/index.php/en/localnews/257170-2022-09-13-13-22-59.html 2022-09-13 08:22pm

**(ភ្នំពេញ)៖** គិតត្រឹមវេលាម៉ោង៣៖០០នាថ្ងៃទី១២ ដល់វេលាម៉ោង៣៖០០ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជា បានទទួលសំណើចំនួន១៧ករណី ដើម្បីស្វែងរកជនបរទេស៧០នាក់។ នេះបើតាមនេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ ក្នុងចំណោមទាំង ១៧ករណីនេះមានតាមរយៈ Facebook សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជ.ប.ជ) ៨ករណី តាមអគ្គស្នងការដ្ឋាននគរបាលជាតិ០៦ករណី និងតាម Hotline ជនបរទេសចំនួន២ករណី ផងដែរ។ នាយឧត្តមសេនីយ៍ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបន្ថែមថា សម្រាប់នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ សមត្ថកិច្ចក៏បានបើកប្រតិបត្តិការស្រាវជ្រាវ និងត្រួតពិនិត្យបានចំនួន០៦ករណី ដោយជួយសង្គ្រោះជនបរទេសចំនួន៨នាក់ ក្នុងនោះមានជនជាតិចិន៤នាក់ និងវៀតណាម៤នាក់ ផងដែរ។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្ដេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្ដល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ។ នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅព្រឹកថ្ងៃទី០៩ ខែកញ្ញា រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ឱ្យគ្រប់រដ្ឋបាលរាជធានី ខេត្ត និងមូលដ្ឋានទាំងអស់ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរ និងរត់ពន្ធមនុស្ស ពលកម្ម បង្ខិតបង្ខំ និងអាជីវកម្មផ្លូវភេទ ឱ្យមានប្រសិទ្ធភាពផងដែរ៕

## ពលរដ្ឋម៉ាឡេស៊ីចំនួន ២៩នាក់ ដែលត្រូវបានជឿថាជាជនរងគ្រោះនៃការបោកប្រាស់ឲ្យមកធ្វើការងារក្លែងក្លាយនៅកម្ពុជា នឹងត្រូវធ្វើមាតុភូមិនិវត្តន៍ចាប់ពីចុងខែកញ្ញា

https://www.khmertimeskh.com/501150546//?p=1150546 Khmer Times September 14, 2022

ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា Datuk Eldeen Mohd Hasshin បានប្រាប់ទីភ្នាក់ងារសារព័ត៌មានជាតិរបស់ម៉ាឡេស៊ី Bernama ថា ជនជាតិម៉ាឡេស៊ី ២៩នាក់ ក្នុងចំណោម ៥៣នាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណ និងជឿថា ត្រូវបានរត់ពន្ធ ឬល្បួងឲ្យមកធ្វើការងារឲ្យក្រុមឆបោកតាមអ៊ីនធឺណិតនៅកម្ពុជា នឹងត្រូវធ្វើមាតុភូមិនិវត្តន៍ចាប់ពីចុងខែកញ្ញា។ Datuk Eldeen បាននិយាយថា ក្រុមចុងក្រោយក្នុងចំណោម២៩ នាក់ គឺស្ថិតក្នុងចំណោមជនរងគ្រោះដែលត្រូវគេបោកប្រាស់ចំនួន ៥៣នាក់ដែលត្រូវបានជួយសង្គ្រោះ ប៉ុន្តែត្រូវឃុំខ្លួនដោយសារតែពួកគេមិនមានឯកសារធ្វើដំណើរត្រឹមត្រូវ។ កាលពីព្រឹកថ្ងៃសុក្រសប្ដាហ៍មុន ពលរដ្ឋម៉ាឡេស៊ី ២៤នាក់ត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីកម្ពុជា អមដោយរដ្ឋមន្ត្រីការបរទេសលោក Datuk Seri Saifuddin Abdullah ដែលបានមកបំពេញទស្សនកិច្ចការងារនៅកម្ពុជា។ Datuk Seri Saifuddin ក៏បានទៅសួរសុខទុក្ខជនជាតិម៉ាឡេស៊ីមួយចំនួនដែលត្រូវបានឃុំខ្លួននៅឯមន្ទីរឃុំឃាំងកម្ពុជាផងដែរ មុនពេលជិះយន្តហោះត្រឡប់ទៅវិញជាមួយនឹងអ្នកទាំង ២៤ ដែលមានអាយុចន្លោះពី២០ ទៅ៣០ ឆ្នាំ។

"អ្នកទាំង ២៩ នាក់នេះ អត់មានលិខិតឆ្លងដែន បើពួកគេមានលិខិតឆ្លងដែន លិខិតទាំងនោះមិនមានសុពលភាពទៀតទេ ឬពួកគេអាចលួចចូលក្នុងប្រទេស។ ពួកគេកំពុងត្រូវបានស៊ើបអង្កេត ហើយដំណើរការត្រូវការពេលវេលា ព្រោះជនរងគ្រោះមិនត្រឹមតែជាជនជាតិម៉ាឡេស៊ីទេ ក៏មានជនរងគ្រោះមកពីប្រទេសថៃ វៀតណាម ឥណ្ឌូនេស៊ី ជាដើម ដូច្នេះយើងនឹងត្រូវរង់ចាំសិន។ លោកបានបន្ថែមថា "យើងបានទទួលព័ត៌មានថាការស៊ើបអង្កេតជិតរួចរាល់ហើយ ហើយយើងនឹងព្យាយាមនាំពួកគេមកវិញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប៉ុន្តែយើងមិនអាចនាំពួកគេទាំងអស់គ្នាបានទេ ដោយសារករណីកំពុងត្រូវបានដោះស្រាយជាលក្ខណៈបុគ្គល" ។

Eldeen បាននិយាយថា ជនជាតិម៉ាឡេស៊ីចំនួន៣០ នាក់ទៀតត្រូវបានគេរាយការណ៍ថាជាជនរងគ្រោះនៃក្រុមបោកប្រាស់ឲ្យធ្វើការងារក្លែងក្លាយនៅក្នុងប្រទេសកម្ពុជា ហើយកិច្ចខិតខំប្រឹងប្រែងកំពុងដំណើរការដើម្បីតាមដានកន្លែងលាក់ខ្លួនរបស់ពួកគេ។ លោកបានសង្កត់ធ្ងន់ថា "សរុបមក យើងបានទទួលរបាយការណ៍ចំនួន១៤៨ នៅស្ថានទូតរបស់យើង ហើយយើងបានជួយសង្គ្រោះមនុស្សចំនួន១១៨ នាក់មកទល់ពេលនេះ" ។

ការសែតខ្មែរថាមស៍ បានទទួលព័ត៌មានដ៏គួរឱ្យទុកចិត្តថា សម្រាប់ពលរដ្ឋម៉ាឡេស៊ី ១០នាក់ ដែលអង្វរឱ្យធ្វើមាតុភូមិនិវត្តន៍ ឬជួយសង្គ្រោះ មានចំនួនស្មើគ្នាទៅនឹងអ្នកដែលមិនព្រមវិលត្រឡប់មកវិញខណៈពួកគេពេញចិត្តធ្វើការនៅមជ្ឈមណ្ឌលហៅទូរស័ព្ទដែលអាចរកប្រាក់ចំណូលបានច្រើនតាមដែលពួកគេអាចបំពេញតាមគោលដៅរបស់ពួកគេ។ ករណីបែបនេះមានចំពោះជាតិសាសន៍ផ្សេងទៀតដែរ៕ *Bernama/Khmer Times*

## ការជួយសង្គ្រោះមិនបានលឿនគ្រប់គ្រាន់សម្រាប់ជនជាតិវៀតណាម ដែលត្រូវគេជួញដូរមកកម្ពុជា

https://www.khmertimeskh.com/501150719//?p=1150719 Khmer Times September 14, 2022

ខណៈពួកគេកំពុងរង់ចាំអាជ្ញាធរវៀតណាម និងកម្ពុជាជួយសង្គ្រោះកុមារដែលត្រូវបានជួញដូរនោះ ឪពុកម្តាយជាច្រើននៅប្រទេសវៀតណាមកំពុងតែអន្ទះសារ។ អ្នកខ្លះថែមទាំងបានបញ្ចាំផ្ទះរបស់ពួកគេដើម្បីរៃអង្គាសប្រាក់គ្រប់គ្រាន់ដើម្បីបង់ "ថ្លៃលោះ" ដោយភ័យខ្លាចថាកូនរបស់ពួកគេអាចត្រូវបានសម្លាប់។ រៀងរាល់យប់ក្នុងរយៈពេលបីខែកន្លងមកនេះ Tran Thi Nhung និងប្តីរបស់គាត់ Phan Van Hanh នៅឃុំ Hoa My Dong ស្រុក Tay Hoa ខេត្ត Phu Yen ភាគខាងត្បូងបានរង់ចាំទូរស័ព្ទកូនប្រុសរបស់គាត់។ ចាប់តាំងពីដើមខែមិថុនា កូនប្រុសច្បងរបស់ពួកគេ Phan Van Duc អាយុ ២៦ឆ្នាំ ត្រូវបានអនុញ្ញាតឱ្យរាយការណ៍អំពីស្ថានភាពរបស់គាត់ និងអង្វរសុំជំនួយ។ លើកចុងក្រោយគាត់បានទូរស័ព្ទប្រាប់គេថា គាត់ត្រូវបានគេវាយដំយ៉ាងធ្ងន់ធ្ងរ ដកដង្ហើមមិនរួច ក្អួតចេញបបរដែលគាត់បានញ៉ាំ ហើយត្រូវបង្ខំឱ្យធ្វើការរហូតដល់ម៉ោង៣ទៀបភ្លឺជារៀងរាល់ថ្ងៃ។

ដូចយុវជនវៀតណាមដែលងាយរងគ្រោះរាប់ពាន់នាក់ផ្សេងទៀត Duc ត្រូវបានបោកបញ្ឆោត និងជួញដូរមកកម្ពុជា ដើម្បីធ្វើជាទាសករសម្រាប់ក្រុមឧក្រិដ្ឋជនមិនស្គាល់អត្តសញ្ញាណមួយផ្សេងទៀត។ គាត់ត្រូវបានគេបញ្ជាឱ្យជួយរត់ពន្ធជនជាតិវៀតណាម ៥ នាក់នៅទីនោះជារៀងរាល់ខែ ដោយបានបដិសេធ ហើយត្រូវបានគំរាមកំហែងថាគាត់នឹងត្រូវសម្លាប់ប្រសិនបើគ្រួសាររបស់គាត់មិនបង់ប្រាក់លោះចំនួន ២៤០ លានដុង (១០,១៩០ ដុល្លារ) ។ នៅពេលដែល Nhung បានឃើញរូបភាពកូនប្រុសរបស់នាងត្រូវបានវាយដំជាលើកដំបូង នាងកើតជំងឺគាំងបេះដូង ហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យ។ ពេលគាត់ជាសះស្បើយ គាត់ និងប្តីបានរត់ទៅខ្ចីលុយគេ ដើម្បីទិញពេលវេលាឱ្យកូនប្រុសរបស់នាង ហើយថែមទាំងបញ្ចាំផ្ទះរបស់ពួកគេ ដើម្បីខ្ចីប្រាក់ចំនួន ១០០ លានដុង (៤,២៥០ ដុល្លារ) ដោយសង្ឃឹមថានឹងអាចជួយសង្គ្រោះគាត់បាននៅទីបំផុត។ Nhung បានរាយការណ៍ករណីកូនប្រុសរបស់គាត់ទៅនគរបាល Phu Yen ដែលបាននិយាយថាពួកគេកំពុងធ្វើការជាមួយអាជ្ញាធរកម្ពុជាលើបញ្ហានេះ។

តាមការប៉ាន់ប្រមាណរបស់នគរបាល Phu Yen មនុស្សចំនួន ១១ នាក់មកពីខេត្តនេះត្រូវបានលក់ទៅធ្វើការដោយបង្ខំនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីខែមករា ឆ្នាំ ២០២២ មក។ ជនរងគ្រោះទាំងអស់សុទ្ធតែមានវ័យក្មេងមកពីគ្រួសារក្រីក្រ ហើយឈប់រៀនមុនពេល។ ក្រុមឈ្មួញបានបោកបញ្ឆោតពួកគេតាមមធ្យោបាយមួយ ឬមធ្យោបាយផ្សេងទៀត ហើយបានចំណាយសម្រាប់ការដឹកជញ្ជូន ដើម្បីនាំពួកគេទៅកាន់ទីក្រុងហូជីមិញ និងបន្តមកកម្ពុជា។ ក្នុងចំណោមមនុស្សទាំង ១១នាក់ នគរបាល Phu Yen បានជួយសង្គ្រោះមនុស្សចំនួន ៧ នាក់ និងកំពុងស៊ើបអង្កេតអ្នកនៅសល់។

កាលពីខែកក្កដា ក្រសួងសន្តិសុខសាធារណៈបានចេញការព្រមានអំពីការជួញដូរពលករវៀតណាមអាយុពី១៨ដល់៣៥ឆ្នាំមកកម្ពុជា។ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម មនុស្សទាំងនេះត្រូវបានសន្យាថា "ការងារងាយស្រួល រកប្រាក់បានច្រើន" តែទើបដឹងខ្លួនថាត្រូវបានគេបង្ខាំងខ្លួន បង្ខំឱ្យធ្វើការច្រើនម៉ោង និងត្រូវបានលក់ក្នុងចំណោមក្រុមខុសច្បាប់ដែលចូលរួមក្នុងសកម្មភាពដូចជាការក្លែងបន្លំល្បែងអនឡាញ និងការជួញដូរគ្រឿងញៀន។

ជនរងគ្រោះក៏ត្រូវបានសន្យាថា ពួកគេនឹងត្រូវបានដោះលែង ឬផ្តល់ប្រាក់រង្វាន់ ប្រសិនបើពួកគេរកបានមនុស្ស បោកប្រាស់ និងនាំជនជាតិវៀតណាមបន្ថែមទៀតមកកម្ពុជា។ ជារឿយៗ គ្រួសារត្រូវបង់ថ្លៃលោះរហូតដល់ ៣០,០០០ ដុល្លារ ដើម្បីឱ្យកូនរបស់ពួកគេនៅមានជីវិត។ ក្រុមឧក្រិដ្ឋជនទាំងនេះប្រមូលផ្តុំនៅតាមទីតាំងតាមបណ្តោយព្រំដែនប្រទេសកម្ពុជាដូចជា ក្រុងបាវិត ក្នុងខេត្តស្វាយរៀង និងក្រុងជ្រៃធំ ខេត្តកណ្តាល នៅភាគអាគ្នេយ៍ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងក្រុងព្រះសីហនុ ក្នុងខេត្តព្រះសីហនុ ភាគខាងលិចជាប់ព្រំដែនប្រទេសថៃ និងរាជធានីភ្នំពេញ។ ចាប់តាំងពីឆ្នាំ២០១៧ មក នៅតាមតំបន់ទេសចរណ៍ដែលរីកចម្រើន និងតំបន់សេដ្ឋកិច្ចពិសេសផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា និងទូទាំងអាស៊ីអាគ្នេយ៍ និងអាស៊ី កាស៊ីណូបាននិងកំពុងរីកដុះដាលដូចផ្សិត ក្លាយជាឧស្សាហកម្មរកប្រាក់បានរាប់ពាន់លានដុល្លារ ជាពិសេសតាមរយៈល្បែងអនឡាញ។ ពួកគេបានបង្កើតការងាររាប់រយរាប់ពាន់នាក់ និងទាក់ទាញអ្នកវិនិយោគកាន់តែច្រើនឡើងៗ ដែលចូលមកសាងសង់មិនត្រឹមតែកាស៊ីណូប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានកន្លែងពាក់ព័ន្ធដូចជា សណ្ឋាគារ រមណីយដ្ឋាន ភោជនីយដ្ឋាន បារ ផ្សារទំនើប និងអាផាតមិន។

ទោះជាយ៉ាងណាក៏ដោយ ទន្ទឹមនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច ហានិភ័យនៃឧក្រិដ្ឋកម្មដូចជាការលាងលុយកខ្វក់ ការក្លែងបន្លំហិរញ្ញវត្ថុតាមអ៊ីនធឺណិត ពេស្យាកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចរបស់កម្មករ។ Covid-19 ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អាជីវកម្ម បណ្តាលឱ្យមានការកើនឡើងនៃសកម្មភាពខុសច្បាប់ ដើម្បីទូទាត់សងសម្រាប់ការធ្លាក់ចុះនៃប្រាក់ចំណូលស្របច្បាប់។ ពាសពេញតំបន់ មនុស្សបាត់បង់ការងារដោយសារជំងឺរាតត្បាត ហើយងាយធ្លាក់ចូលទៅក្នុងការលួចបន្លំតាមអ៊ីនធឺណិត និងការជួញដូរមនុស្ស។ ឧក្រិដ្ឋកម្មទាក់ទងនឹងកាស៊ីណូបានក្លាយទៅជារឿងធ្ងន់ធ្ងរ ដែលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អាជ្ញាធរចិនបានធ្វើការជាមួយសមភាគីអាស៊ីអាគ្នេយ៍របស់ពួកគេ ដើម្បីបង្ក្រាបល្បែងអនឡាញខុសច្បាប់។ កម្ពុជាបានហាមប្រាមល្បែងអនឡាញនៅខែសីហា ឆ្នាំ២០១៩។ទោះបីជាមានការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងតំបន់ក៏ដោយ ក៏ការក្លែងបន្លំតាមអ៊ីនធឺណិត និងការជួញដូរមនុស្សដែលពាក់ព័ន្ធ និងការបង្ខំឱ្យធ្វើការនៅមានកម្រិតនៅឡើយ។

នាពេលថ្មីៗនេះ ដូចជានៅក្នុងឆមាសទីមួយនៃឆ្នាំនេះ ប្រទេសចំនួនប្រាំបួនត្រូវបានស្នើឱ្យធ្វើការជាមួយកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស រួមមាន បង់ក្លាដែស ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ម៉ុងហ្គោលី នេប៉ាល់ ប៉ាគីស្ថាន ថៃ និងហ្វីលីពីន។ កម្ពុជា និងវៀតណាម បានសហការជាច្រើនឆ្នាំដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សក្រោមកិច្ចព្រមព្រៀងទ្វេភាគី។ **ការងារជួយសង្គ្រោះត្រូវការពេលវេលា** យោងតាមក្រសួងសន្តិសុខសាធារណៈ

វៀតណាម វាមិនងាយស្រួលទេក្នុងការជួយសង្គ្រោះមនុស្សដែលត្រូវបានជួញដូរ និងលក់ជាពលកម្មដោយបង្ខំនៅកម្ពុជានោះទេ។

លោកវរសេនីយ៍ឯក Khong Ngoc Oanh នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌនៃក្រសួងបានប្រាប់សារព័ត៌មានកាលពីពេលថ្មីៗនេះថា នៅកម្ពុជា មានក្រុមជួញដូរមនុស្សជាច្រើន ធ្វើសកម្មភាពយ៉ាងជ្រៅក្នុងព្រៃក្រោមរូបភាពជាក្រុមហ៊ុនស្របច្បាប់ ដែលធ្វើឲ្យអ្នកខាងក្រៅពិបាកដឹងពីអ្វីដែលកំពុងកើតឡើងនៅខាងក្នុង។ លោកបន្តថា នៅពេលណាដែលអាជ្ញាធរវៀតណាមទទួលបានដំណឹងអំពីករណីជួញដូរមនុស្ស ពួកគេបន្តតាមកិច្ចព្រមព្រៀង ប៉ុន្តែត្រូវរង់ចាំភាគីកម្ពុជាស៊ើបអង្កេត និងផ្ទៀងផ្ទាត់ព័ត៌មាន ហើយនេះក៏ជាដំណើរការដ៏លំបាកមួយផងដែរ។ លោកបានមានប្រសាសន៍ថា អាជ្ញាធរពិបាកក្នុងការតាមដាន ពលករចំណាកស្រុកវ័យក្មេងដែលធ្លាក់ក្នុងកណ្តាប់ដៃនៃក្រុមឧក្រិដ្ឋជន ដោយសារពួកគេភាគច្រើនមិនបានជូនដំណឹងដល់គ្រួសាររបស់ពួកគេអំពីកន្លែងដែលពួកគេទៅជាមួយ ឬពេលណាដែលពួកគេគ្រោងនឹងត្រលប់មកវិញ ដោយសារខ្លាចឪពុកម្តាយជំទាស់។

កាលពីថ្ងៃទី១៨ ខែសីហា បញ្ហានេះបានផ្ទុះឡើងដល់ថ្នាក់ជាតិក្នុងប្រទេសវៀតណាម នៅពេលដែលមនុស្សចំនួន ៤២នាក់ ដែលត្រូវបានលក់ទៅឱ្យកាស៊ីណូ Golden Phoenix Entertainment ស្រុកកោះធំ ខេត្តកណ្តាល បានលោតចូលទៅក្នុងទន្លេ Binh Di ដើម្បីហែលឆ្លងទៅប្រទេសវៀតណាមដោយអស់សង្ឃឹមដើម្បីរត់គេចពីកន្លែងធ្វើការដ៏អាក្រក់របស់ពួកគេ។ ៤០នាក់យកមកផ្ទះវិញ ម្នាក់លង់ទឹក ហើយម្នាក់ទៀតត្រូវបានគេចាប់យកមកវិញ។ ក្រោយមកប៉ូលិសវៀតណាម និងកម្ពុជាបានចាប់ខ្លួនក្រុមជួញដូរមនុស្សចំនួនបួននាក់ដែលពាក់ព័ន្ធនឹងករណីនេះ ព្រមទាំងអ្នកគ្រប់គ្រងជនជាតិចិនរបស់ Golden Phoenix ដែលបានសារភាពថាបានប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ។ មិនយូរប៉ុន្មាន ពលករវៀតណាម ១១ នាក់ផ្សេងទៀតក៏ត្រូវបានជួយសង្គ្រោះពី Golden Phoenix រួមទាំងម្នាក់ដែលត្រូវបានចាប់ខ្លួនផងដែរ ដែលនាំឱ្យចំនួនមនុស្សសរុបដែលត្រូវបានជួយសង្គ្រោះនៅឆ្នាំ ២០២២ ឡើងដល់ជាង ៦០០ នាក់។

យោងតាមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ដែលជាប្រធានគណៈកម្មាធិការជាតិ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស បានឱ្យដឹងថា គិតត្រឹមចុងខែសីហានេះ កម្ពុជាបានស៊ើបអង្កេតករណីជួញដូរមនុស្សចំនួន ៨៧ ករណី កាត់ទោសចំនួន ១៧ ករណី ពាក់ព័ន្ធនឹងមនុស្សសរុប ៦០ នាក់ និងបានជួយសង្គ្រោះជនបរទេស ៨៦៥នាក់។ អាជ្ញាធរកម្ពុជាក៏បានបង្កើតបណ្តាញទូរស័ព្ទបន្ទាន់ជាតិលេខ ១១៧ និងបានចាប់ផ្តើមយុទ្ធនាការទូទាំងប្រទេស ដើម្បីតាមដានអ្នកជួញដូរ និងជនរងគ្រោះ ដោយត្រួតពិនិត្យជនបរទេសទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា លើកលែងតែបុគ្គលិកស្ថានទូត។

បើតាមលោក ស៊ឹម ជី ប្រធានសមាគមខ្មែរ-វៀតណាម ដែលបាននិងកំពុងជួយអាជ្ញាធរយ៉ាងសកម្មក្នុងការលុបបំបាត់ការជួញដូរមនុស្សនៅកម្ពុជា អាជីវកម្មគួរឱ្យសង្ស័យជាច្រើនបានជួលជនជាតិវៀតណាមរហូតដល់ ៣០០ នាក់ដោយខុសច្បាប់។ **ទាល់តែអ្នកទាំងអស់គ្នាអាចត្រឡប់មកវិញ** ចាប់តាំងពីកូនប្រុសរបស់គាត់ត្រូវបានគេជួញដូរ Nhung មិនអាចគេងនៅពេលយប់បានទេ។ សព្វថ្ងៃនេះ គាត់តែងតែយកទូរស័ព្ទទៅជាមួយដោយសង្ឃឹមថានឹងទទួលបានការហៅទូរសព្ទពីគាត់។ គាត់និយាយថា ខណៈគាត់អន្ទះសារចង់ឮពីគាត់ គាត់ក៏ខ្លាចដែរ ។ «ខ្ញុំខ្លាចព្រោះខ្ញុំមិនចង់ឃើញគាត់ត្រូវបានគេធ្វើបាបយ៉ាងឈឺចាប់ ប៉ុន្តែមានអារម្មណ៍ថាគាត់នៅមានជីវិត»។ រហូតមកដល់ពេលនេះ គាត់បានចំណាយប្រាក់លោះជិត ២១០ លានដុង (៨,៩១៥ ដុល្លារ) ហើយនិយាយថាគាត់នឹងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីជួយសង្គ្រោះកូនប្រុសរបស់គាត់ ដរាបណាគាត់នៅមានជីវិត។ ចម្ងាយ ២០ គីឡូម៉ែត្រពីផ្ទះរបស់គាត់ ក្នុងឃុំ Hoa An ស្រុក Phu Hoa លោក Pham Thi Trinh កំពុងរង់ចាំកូនប្រុសរបស់គាត់ឈ្មោះ Nguyen Minh Tri អាយុ ២៦ ឆ្នាំត្រឡប់ទៅផ្ទះវិញ។ នៅរសៀលថ្ងៃមួយនៅចុងខែកក្កដា Tri ដែលពេលនោះធ្វើការជាកម្មករ

សំណង់នៅទីក្រុងហូជីមិញ បានបាត់ខ្លួន។ បីថ្ងៃក្រោយមក Trinh បានដឹងថា កូនប្រុសរបស់គាត់ត្រូវបានលក់ទៅឱ្យប្រទេសកម្ពុជា ហើយប្រសិនបើគាត់ចង់បានកូនគាត់មកវិញ នាងនឹងត្រូវបង់ប្រាក់លោះចំនួន ១០០ លានដុង (៤,២៤៥ ដុល្លារ) ។

អ្នកស្រី និងស្វាមី Nguyen Ngoc Thuc ដែលអ្នកទាំងពីរក៏ជាកម្មករសំណង់ដែលមានប្រាក់ខែទាបផងដែរនោះ បានអែអង្គាសប្រាក់ចំនួន ៥០ លានដុង (២.១២០ ដុល្លារ) ពីសាច់ញាតិ និងអ្នកជិតខាង ហើយសង្ឃឹមថានឹងធ្វើកិច្ចព្រមព្រៀងជាមួយអ្នកចាប់កូនប្រុសរបស់ពួកគេ។ ប៉ុន្តែគេមិនទាន់អាចដោះស្រាយបាននៅឡើយទេ។ Trinh ដែលបានរាយការណ៍ថាកូនប្រុសរបស់គាត់បាត់ខ្លួនទៅនគរបាលក្រុងហូជីមិញ ថា៖ «យើងមិនអាចញ៉ាំអីបានទេ ហើយសង្ឃឹមថាមានអព្ភូតហេតុមួយព្រោះយើងមិនដឹងថាត្រូវធ្វើយ៉ាងណា»។ សម្រាប់យុវជនដែលបានលោះហើយអាចត្រឡប់មកវិញ ត្រូវការពេលវេលាដើម្បីសង្គ្រោះ និងព្យាបាល ក្រៅពីត្រូវប្រឹងប្រែងធ្វើការដើម្បីសងបំណុលដែលឪពុកម្តាយបានជំពាក់។

Thuc Uyen អាយុ១៩ ឆ្នាំនៅស្រុក Krong Pac ក្នុងខេត្ត Dak Lak ភាគកណ្តាលគឺជាមនុស្សម្នាក់ក្នុងចំណោមនោះ។ កាលពីដើមឆ្នាំនេះ Uyen បានជួបអ្នកជ្រើសរើសម្នាក់ដែលបានសន្យាថានាងនឹងទទួលបានការងារល្អ ប៉ុន្តែបានជួញដូរ និងរត់ពន្ធមកកម្ពុជា។ ប៉ុន្មានខែក្រោយមក ទើបនាងត្រូវបានអនុញ្ញាតឱ្យទូរស័ព្ទទៅប្រាប់ម្តាយរបស់នាងថា នាងត្រូវបានគេបង្ខំឱ្យធ្វើការ ធ្វើទារុណកម្ម អត់ឃ្លាន និងត្រូវបានលក់ក្នុងចំណោមក្រុមក្មេងទំនើងដោយរងទុក្ខជាច្រើនដល់អ្នកដទៃ។ ម្តាយរបស់នាងឈ្មោះ Truong Thi Tam ត្រូវបានគេគំរាមថាកូនស្រីរបស់នាងនឹងត្រូវលក់ទៅប្រទេសថៃ ប្រសិនបើនាងមិនបង់ប្រាក់ចំនួន ២៥០ លានដុង (១០,៦១០ ដុល្លារ) ក្នុងរយៈពេល ២០ ថ្ងៃ។ Tam បានធ្វើអ្វីដែលត្រូវបានគេប្រាប់ គឺខ្ចីលុយគេ។ ម្តាយនិយាយដោយប្រាថ្នាថា "ដរាបណានាងនៅមានជីវិត គ្រួសាររបស់យើងទាំងមូលអាចធ្វើការសងបំណុលយើងវិញបាន"។ VNExpress

## ថ្ងៃទី១៣ ខែកញ្ញា ម្សិលមិញ សម្តេចក្រឡាហោម ស ខេង ទទួលពាក្យបណ្តឹងចំនួន១៤ទៀត ពាក់ព័ន្ធនឹងករណីបង្ខាំង និងជួញដូរ

http://freshnewsasia.com/index.php/en/localnews/257255-2022-09-14-07-43-35.html 2022-09-14 02:43pm

**(ភ្នំពេញ)៖** សម្រាប់ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជ.ប.ជ) បានទទួលពាក្យបណ្តឹងចំនួន ១៤ទៀត ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍លើករណីបង្ខាំង និងជួញដូរ។ នេះបើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា ក្នុងបណ្តឹងនោះមានការស្នើឱ្យអន្តរាគមន៍ស្វែងរកជនជាតិឥណ្ឌូនេស៊ី ៧៩នាក់, ជនជាតិចិន ០១នាក់, ជនជាតិម៉ាឡេស៊ី ០២នាក់, ជនជាតិចិនតៃវ៉ាន់ ០១នាក់ និងជនជាតិឥណ្ឌា ០២នាក់។ បើតាមអ្នកនាំពាក្យក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ សម្តេចក្រឡាហោម បានទទួលពាក្យបណ្តឹងសរុបចំនួន២១៤បណ្តឹង មានមនុស្សចំនួន ៤៦១នាក់ មាន ១០សញ្ជាតិ ពាក់ព័ន្ធនឹងការស្នើអន្តរាគមន៍ជួយសង្គ្រោះជនបរទេស ដែលត្រូវបានអះអាងថាបង្ខាំង និងជួញដូរកម្លាំងពលកម្ម។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការ

ផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ។ នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅព្រឹកថ្ងៃទី០៩ ខែកញ្ញា រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ ឱ្យគ្រប់រដ្ឋបាលរាជធានី ខេត្ត និងមូលដ្ឋានទាំងអស់ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរ និងរត់ពន្ធមនុស្ស ពលកម្ម បង្ខិតបង្ខំ និងអាជីវកម្មផ្លូវភេទ ឱ្យមានប្រសិទ្ធភាពផងដែរ៕

## ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២

## បទសម្ភាសន៍ពិសេស៖
## ស្ថានភាពនៃការជួញដូរមនុស្សនិងវិធានការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែននេះ

https://khmer.voanews.com/a/special-interview-series-cambodia-a-hotspot-for-human-trafficking/6747767.html 15 កញ្ញា 2022ធីតា វិន

*ភ្នំពេញ៖ កំណត់និពន្ធ៖ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធឺណិត (Scam) ដោយប្រើប្រាស់កម្លាំងពលកម្មបរទេស ធ្វើការនៅតាមអគារខ្ពស់ៗនៅក្នុងប្រទេសកម្ពុជា ហេតុមានសេចក្តីរាយការណ៍អំពីការបង្ខាំងទុកពួកគេ មិនឱ្យមានសេរីភាព ធ្វើទារុណកម្ម និងជំរិតទារប្រាក់ជាដើម។ ថ្មីៗនេះ សហរដ្ឋអាមេរិកបានទម្លាក់កម្ពុជាពីចំណាត់ថ្នាក់កម្រិតពីរ (Tier 2) មកកម្រិតបី (Tier 3) ដែលជាចំណាត់ថ្នាក់ទាបបំផុតមួយក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស។ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាឱ្យអាជ្ញាធរពាក់ព័ន្ធនានាត្រៀមចុះពិនិត្យអគារនានានៅទូទាំងប្រទេស ខណៈមានសេចក្តីរាយការណ៍ថា កម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងជួញដូរមនុស្សតាមរយៈការប្រើប្រាស់កម្លាំងបរទេសឱ្យធ្វើការជាអ្នកឆបោកតាមបច្ចេកវិទ្យា ឬហៅថា Scam។ វីអូអេបានសម្ភាសន៍អ្នកជំនាញ លោក មឿន តុលា នាយកប្រតិបត្តិនៃអង្គការសង់ត្រាល់ មន្ត្រីរដ្ឋបាលខេត្ត លោក ឡុង ឌីម៉ង់ អភិបាលរងខេត្តព្រះសីហនុ និងមន្ត្រីជាន់ខ្ពស់នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពីស្ថានភាពនៃការជួញដូរមនុស្ស និងវិធានការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែននេះ៕*

**បទសម្ភាសន៍ VOA៖ អំពើពុករលួយជាកត្តាចម្បងនាំឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសគោលដៅនៃការជួញដូរមនុស្ស៖**

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គេសង្កេតឃើញថា ប្រទេសកម្ពុជាបានក្លាយជាប្រទេសគោលដៅក្នុងការជួញដូរមនុស្ស និងបង្ខាំងមនុស្សខុសច្បាប់ បន្ទាប់ពីមានការកើនឡើងនៃលំហូរជនជាតិចិន មកវិនិយោគក្នុងប្រទេស។ អ្នកស្រី ធីតា វិន បានជួបសម្ភាសន៍ផ្ទាល់ជាមួយលោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ ជុំវិញការជួញដូរមនុស្ស និងបង្ខាំងមនុស្សខុសច្បាប់នៅកម្ពុជា។

លោក មឿន តុលា បានឱ្យដឹងថា ការកើនឡើងនូវការជួញដូរមនុស្ស និងការបង្ខាំងមនុស្សខុសច្បាប់ នៅក្នុងប្រទេសកម្ពុជាមួយផ្នែកដោយសារការអនុវត្តច្បាប់មានភាពធូរលុង ហើយចំណាត់ការធ្វើឡើងតាមការបញ្ជាពី

ថ្នាក់លើតែប៉ុណ្ណោះ។ ទោះបីជាមានការរិះគន់អំពីការប្រានចោលរបស់រដ្ឋាភិបាលអំពីភាពធ្ងន់ធ្ងរ នៃការជួញដូរមនុស្ស និងបង្ខាំងមនុស្សខុសច្បាប់នៅកម្ពុជាក្តី ក៏មន្រ្តីជាន់ខ្ពស់ម្នាក់របស់ខេត្តព្រះសីហនុ បានអះអាងថា អាជ្ញាធរមានសមត្ថកិច្ច មិនដែលព្រងើយកន្តើយក្នុងការបង្រ្កាបការជួញដូរមនុស្សនោះឡើយ៕ EMBED SHARE

**បទសម្ភាសន៍ VOA៖ អាជ្ញាធរខ្មែរខ្នែងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅខេត្តព្រះសីហនុ ទោះមានការរិះគន់ពីចន្លោះប្រហោង៖**

ខេត្តព្រះសីហនុត្រូវបានគេដឹងថា មានជនជាតិចិនទៅធ្វើការវិនិយោគច្រើនជាងបណ្តាខេត្តផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ន ខេត្តមួយនេះ បានក្លាយជាទីតាំងដ៏ធំមួយរបស់ក្រុមជួញដូរមនុស្ស។ អ្នកស្រី ធីតា រីន បានជួបសម្ភាសន៍ផ្ទាល់ជាមួយលោក ឡុង ឌីម៉ង់ អភិបាលរងខេត្តព្រះសីហនុ អំពីការជួញដូរមនុស្ស ឬបង្ខាំងមនុស្សខុសច្បាប់ នៅក្នុងខេត្តជាប់ឆ្នេរសមុទ្រមួយនេះ។

លោក ឡុង ឌីម៉ង់ បានឱ្យដឹងថា ការបង្រ្កាបការជួញដូរមនុស្ស និងបង្ខាំងមនុស្សខុសច្បាប់ គឺជាភារកិច្ចរួមគ្នា ដែលតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទើបមានប្រសិទ្ធភាព។ ស្របពេលជាមួយគ្នានេះដែរ មន្រ្តីជំនាញជាន់ខ្ពស់របស់រដ្ឋាភិបាលក៏បានអះអាងដែរថា រដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តធ្វើការបង្រ្កាបករណីការជួញដូរមនុស្ស និងបង្ខាំងមនុស្សខុសច្បាប់ឱ្យដល់ទីបំផុត «ពីព្រោះគ្មានប្រទេសណាមួយចង់បង្កើតអំពើឧក្រិដ្ឋកម្មឱ្យខ្លួនឯងនោះទេ»៕IMBED SHARE

**បទសម្ភាសន៍ VOA៖ ការបង្រ្កាបដោយមានប្រសិទ្ធភាពលើការជួញដូរមនុស្សសម័យបច្ចេកវិទ្យា ចាំបាច់ការសហការគ្រប់ភាគី៖**

នៅក្នុងអំឡុងពេលមួយរយៈកន្លងមកនេះ មានសារព័ត៌មានក្នុងស្រុកនិងក្រៅស្រុកជាច្រើន បានចុះផ្សាយអំពីការជួញដូរមនុស្សនិងបង្ខាំងមនុស្សខុសច្បាប់នៅក្នុងប្រទេសកម្ពុជា ស្របពេលដែលសហរដ្ឋអាមេរិកបានទម្លាក់កម្ពុជាពីចំណាត់ថ្នាក់កម្រិតពីរ (Tier 2) មកកម្រិតបី (Tier 3) ដែលជាចំណាត់ថ្នាក់ទាបបំផុតមួយក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស។

អ្នកស្រី ធីតា រីន បានជួបសម្ភាសន៍ផ្ទាល់ជាមួយលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្រ្តៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជុំវិញការជួញដូរមនុស្ស និងបង្ខាំងមនុស្សខុសច្បាប់នៅកម្ពុជា។

លោកស្រី ជូ ប៊ុនអេង បានឱ្យដឹងថា ការជួញដូរមនុស្ស និងបង្ខាំងមនុស្សខុសច្បាប់ គឺជាការរួមគ្នា ទទួលខុសត្រូវជាមួយបណ្តាលប្រទេសពាក់ព័ន្ធ ដែលយើងចាំបាច់ត្រូវធ្វើការសហការគ្នា ដោយយើងមិនអាចចង្អុលថា ជាកំហុសរបស់ប្រទេសណាមួយនោះទេ៕

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាត់តាំងមន្ត្រី១៤រូប ចូលរួមប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសជួញដូរមនុស្ស ពលកម្ម និងអាជីវកម្មផ្លូវភេទនៅខេត្តព្រះសីហនុ

https://freshnewsasia.com/index.php/en/localnews/257380-2022-09-15-08-23-34.html 2022-09-15 03:23pm

**(ភ្នំពេញ)៖** លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចេញលិខិតបង្គាប់ឲ្យមន្ត្រីចំនួន១៤រូប ចូលរួមការអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី១៤ ខែកញ្ញា។ នេះបើតាមលិខិតបង្គាប់ការរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលអង្គភាពព័ត៌មាន Fresh News ទទួលបាននៅរសៀលថ្ងៃទី១៥ ខែកញ្ញានេះ។

តាមលិខិតបង្គាប់ការរបស់រដ្ឋមន្ត្រីយុត្តិធម៌ បានបង្ហាញថា មន្ត្រីដែលត្រូវចាត់តាំងចូលរួមការងារប្រយុទ្ធប្រឆាំងបទល្មើសនេះមានរដ្ឋលេខាធិការម្នាក់គឺលោក កេង សុម៉ារិទ្ធ អមដោយមន្ត្រីជំនាញចំនួន១៣រូបផ្សេងទៀត។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ: ១៥ កយ.ស.ក/២២

# លិខិតបង្គាប់ការ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញសេចក្តីសម្រេចលេខ ៤៥ កយ.សសរ/២២ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចរបស់ក្រសួងយុត្តិធម៌ប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ
- យោងតាមការចាំបាច់របស់ក្រសួងយុត្តិធម៌

## បង្គាប់មក

**ឯកឧត្តម លោក លោកស្រី** ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម | **កេង សុម៉ារិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| ២-ឯកឧត្តម | **ប៉ែន ពេជ្រសាលី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ |
| ៣-លោក | **នុប សុធនទិសុទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ |



KR

| | | |
|---|---|---|
| ៤-លោកស្រី | **សុន សុខាលីដា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ |
| ៥-លោក | **សេង ពុទ្ធី** | ប្រធាននាយកដ្ឋានកិច្ចការច្បាប់ព្រហ្មទណ្ឌ |
| ៦-លោកស្រី | **យុន ច័ន្ទសោភា** | ប្រធាននាយកដ្ឋានគ្រប់គ្រងវត្ថុតាង និងផលនៃបទល្មើស |
| ៧-លោក | **លី សុផាណា** | ប្រធាននាយកដ្ឋានស្រាវជ្រាវ និងស៊ើបអង្កេត |
| ៨-កញ្ញា | **សុខ ឆវ័ន្ត** | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ៩-លោក | **សុភ កែវបណ្ឌិត** | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ១០-លោក | **សំម ឫទ្ធីវាសនា** | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ១១-លោក | **ឌី រីដា** | ប្រធានការិយាល័យនៃក្រសួងយុត្តិធម៌ |
| ១២-លោក | **អៀម សំណាង** | មន្ត្រីនៃក្រសួងយុត្តិធម៌ |
| ១៣-លោក | **ជូ ធីឡេង** | មន្ត្រីនៃក្រសួងយុត្តិធម៌ |
| ១៤-លោក | **ហាក់ សុខម៉េង** | មន្ត្រីនៃក្រសួងយុត្តិធម៌ |

ឱ្យទៅប្រចាំការនៅខេត្តព្រះសីហនុ ដើម្បីចូលរួមក្នុងការអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅខេត្តព្រះសីហនុ ចាប់ពី **ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់បញ្ចប់បេសកកម្ម។**

សាមីខ្លួនត្រូវអនុវត្តតាមលិខិតបង្គាប់ការនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ KR

ថ្ងៃ សុក្រ ៦រោច ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០២២
**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- រដ្ឋបាលខេត្តព្រះសីហនុ
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
- សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ
  *"ដើម្បីជូនជ្រាប"*
- សាមីខ្លួន *"ដើម្បីអនុវត្ត"*
- ឯកសារ កាលប្បវត្តិ

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/2022/09/15/-28/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃព្រហស្បតិ៍ ៥រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ឯកឧត្តម ឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ីមេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០២លើក សរុបចំនួន១៤នាក់ ស្រី៧នាក់ក្មេងស្រី១នាក់ ។

ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើការពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ពលករខ្មែរម្នាក់ធ្វើការលើទូកនេសាទថៃ រៀបរាប់ពីភាពជូរចត់ ពេលបានមកធ្វើការលើដីគោកវិញ

https://www.rfa.org/khmer/news/social-economy/a-cambodian-worker-on-thai-fishing-boat-describes-his-bitterness-when-worked-in-middle-of-the-sea-09132022050003.html ដោយ សុជីវី 2022.09.13

ពលករខ្មែរម្នាក់ធ្វើការលើទូកនេសាទនៅកណ្ដាលសមុទ្រប្រទេសថៃ ដែលបានរួចជីវិតពីការធ្វើបាបកំឡុងពេលជាប់លើទូក រៀបរាប់ពីភាពជូរចត់ដែលបានហែលឆ្លងកាត់ ពេលបានមកធ្វើការលើដីគោកវិញ។ ពលករខ្មែររូបនេះថា លោកនៅតែដក់ជាប់ក្នុងអារម្មណ៍ជានិច្ចនូវទង្វើអមនុស្សធម៌ ដែលថៅកែថៃគាបសង្កត់ កេងកម្លាំងពលកម្មប្រើអំពើហិង្សា និងបង្ខំឲ្យធ្វើការ ដោយមិនបើកប្រាក់ឲ្យជាច្រើនឆ្នាំក្នុងពេលធ្វើការនៅកណ្ដាលសមុទ្រ។

អង្គុយមូរថ្នាំជក់ក្នុងបន្ទប់ជួលមួយជាយក្រុងបាងកក ពលករខ្មែរដែលធ្លាប់ចាញ់បោកមេខ្យល់ បញ្ឆោតយកទៅលក់បង្ខំឲ្យធ្វើការលើទូកនេសាទអស់រយៈពេល៣ឆ្នាំ នៅលើសមុទ្រជាប់ព្រំដែនប្រទេសម៉ាឡេស៊ី ទម្លាយពីប្រវត្តិជីវិតជូរចត់នៅពេលធ្វើការលើទូកនេសាទ ដែលថៅកែថៃបានធ្វើបាបលោក និងពលករខ្មែរដទៃទៀតជិត៣០នាក់។

ពលករខ្មែរធ្លាប់ធ្វើការលើទូកនេសាទ ក្នុងខេត្តត្រាត (Trat) ប្រទេសថៃ មានស្រុកកំណើតនៅខេត្តតាកែវ លោក ញឹក គីម ប្រាប់វិទ្យុអាស៊ីសេរី នៅរសៀលថ្ងៃទី១២ ខែកញ្ញា ថា ពេលលោកឈានជើងចូលប្រទេសថៃមុនដំបូង បានទៅធ្វើការតាមមេខ្យល់ណែនាំនៅលើទូកនេសាទមួយ ដោយថៅកែជនជាតិថៃទទួលឱ្យធ្វើការងារជាមួយដោយមិនចាំបាច់មានឯកសារស្របច្បាប់ទេ ។ លោកបន្តថា លោកបានធ្វើការនៅទីនោះប្រមាណ ៤ខែ ដោយថៅកែមិនបានបើកប្រាក់ខែឲ្យឡើយ ទើបលោកដឹងខ្លួនថា គេបោកលោកយកមកលក់ឱ្យជនជាតិថៃ។ លោកបន្តថា លើទូកនេសាទមានមេការ ៥នាក់ប្រដាប់ដោយកាំភ្លើងខ្លីគ្រប់ដៃចាំមើលការខុសត្រូវលើកម្មករនេសាទ ៣០នាក់ និងតែង

តែគំរាមកំហែងបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ ដោយឲ្យសម្រាកតែបន្តិចណាឡើយ ។ លោកប្រាប់ថា ពេលកម្មករឈឺ មេការមិនយកចិត្តទុកដាក់មើលថែនោះទេ ហើយបើកម្មករធ្វើការលែងបានមេការចាប់បោះទៅក្នុងសមុទ្រ។

លោកនិយាយទាំងឈឺចាប់ទៀតថា មេការប្រើកម្មករនេសាទឲ្យធ្វើការដូចសត្វធាតុ ពួកគេមិនបានចាត់ទុកពលករខ្មែរនៅលើទូកនេសាទទាំងនោះជាមនុស្សទេ ពេលដែលគេខឹងម្តងៗ គេគប់ដបអំបែងខ្ទាតមកត្រូវកម្មករជាញឹកញយ រហូតបែកក្បាលចេញឈាមក៏មាន។ លោកបន្តថា កន្លែងដេករបស់កម្មករនេសាទ គឺមិនបានត្រឹមត្រូវទេ គ្រាន់តែចងអង្រឹងដេកជាជួរ ខ្លះក៏ដេកលើក្តារបាតទូកតែម្តង ពេលភ្លៀងធំទឹកសាចទទឹកអស់ ហើយរងាខ្លាំងដោយពុំបានដេកពួនទេ។ លោកអះអាងថា មានកម្មករនេសាទជាច្រើននាក់ ដែលត្រូវមេខ្យល់បោកយកទៅលក់ ឲ្យធ្វើជាទាសករលើទូកនេសាទថៃ កម្មករទាំងនោះមាន លាវ (Lao) ភូមា (Myanmar) និងខ្មែរ។ លោកឲ្យដឹងទៀតថា លោកបានជាប់លើទូកនេសាទអស់៣ឆ្នាំ ក្រោយមកគេបាននាំទូកចូលចត គេក៏បានផ្តល់លុយថ្លៃពលកម្មមួយចំនួន ប៉ុន្តែពេលឡើងមកលើច្រាំងក៏ត្រូវប៉ូលិសមកចាប់ភ្លាមៗ យកទៅសាកសួរ ហើយពិន័យប្រាក់ចំនួនបីម៉ឺន (៣០.០០០)បាត។ «»

ចំណែកប្រពន្ធលោក ញឹក គីម គឺលោកស្រី ភា រុន ធ្វើការជាអ្នកលក់បាយឲ្យថៅកែជនជាតិថៃ ប្រាប់ថា ពេលបាត់ប្តីមិនដឹងដំណឹង លោកស្រីបារម្ភពីប្តីជាខ្លាំងនិងបានដើរសួររកប្តី តែគ្មាននរណាស្គាល់។ លោកស្រីថា លោកស្រីចង់ទៅប្តឹងប៉ូលិសឲ្យជួយតាមរកប្តី តែមិនហ៊ានទៅ ព្រោះលោកស្រីមកធ្វើនៅប្រទេសថៃដោយខុសច្បាប់ ម្យ៉ាងទៀតពេលនោះលោកស្រីមិនទាន់ចេះភាសាថៃ មិនដឹងទៅពឹងនរណាឱ្យជួយនោះទេ។ លោកស្រីឲ្យដឹងទៀតថា ពេលប្តីមិននៅលោកស្រីខំធ្វើការរកលុយមកចិញ្ចឹមកូនទាំងពីរប្រុស១ ស្រី១ ដោយលំបាក ទើបក្រោយមកបានដឹងដំណឹងប្តីថា នៅរស់ និងបានមកជួបលោកស្រីនិងកូន។ «»

ទាក់ទងបញ្ហានេះ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ប្រាប់វិទ្យុអាស៊ីសេរី ថា ករណីប្រើកម្លាំងពលករខ្មែរលើទូកនេសាទថៃ គឺមានច្រើនដូចការរាយការណ៍មែន ហើយអ្នកស្រីថា ខាងរដ្ឋាភិបាលបានចាត់វិធានការលើរឿងនេះហើយ ចំណែកពលករដែលរងគ្រោះពីការប្រើកម្លាំងទាំងបង្ខំ ពួកគេអាចដាក់ពាក្យបណ្តឹងមកអាជ្ញាធរ ដើម្បីងាយស្រួលសមត្ថកិច្ចចុះស៊ើបអង្កេត និងបង្ក្រាបទាន់ពេល។ «»

ជុំវិញរឿងនេះដែរ ប្រធានផ្នែកប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ អង្គការសង់ត្រាល់ លោក ឌី ថេហូយ៉ា យល់ថា ដើម្បីរាំងការជួញដូរមនុស្ស និងការជួញដូរកម្លាំងពលករឆ្លងដែនខុសច្បាប់ រដ្ឋាភិបាលត្រូវផ្សព្វផ្សាយចំណេះដឹងដល់ពលរដ្ឋខ្មែរឲ្យបានទូលំទូលាយជាងនេះ ចៀសវាងពលរដ្ឋខ្មែរធ្វើចំណាកស្រុកដោយខុសច្បាប់ ទៅតាមការបញ្ចុះបញ្ចូលពីមេខ្យល់។ លោកបន្តថា កត្តាដែលបណ្តាលឲ្យពលរដ្ឋធ្វើចំណាកស្រុក ហើយចាញ់បោកមេខ្យល់ គឺភាគច្រើនពលរដ្ឋនៅតាមទីជនបទ ដែលខ្វះព័ត៌មាន ហើយមិនយល់ដឹងអំពីហានិភ័យនៃការធ្វើចំណាកស្រុកដោយខុសច្បាប់។ «»ការស្ទង់មតិបង្ហាញថា ២០ភាគរយនៃកម្មករ និងប្រហែល ៥០ភាគរយនៃជនរងគ្រោះដោយការជួញដូរក្នុងវិស័យនេសាទរបស់ថៃ ទទួលរងគ្រោះថ្នាក់ការងារ ក៏ប៉ុន្តែពួកគេមិនទទួលបានសំណងអ្វីឡើយ។

ធនាគារពិភពលោករាយការណ៍ថា ប្រទេសថៃមានចំនួនកម្មករចំណាកស្រុកខ្ពស់ជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជិត ៤ លាននាក់ (៣.៧៦) នៅក្នុងឆ្នាំ២០១៥ ក្នុងនោះ ៥៣ ភាគរយមកពីប្រទេសភូមា ២៦ ភាគរយមកពីប្រទេសឡាវ និង២១ភាគរយមកពីកម្ពុជា។ ចំណែកទិន្នន័យរបស់រដ្ឋាភិបាលថៃវិញ បង្ហាញថា កម្មករចំណាកស្រុកកម្ពុជា ឡាវ និងភូមា ដែលបានចុះឈ្មោះរួចរាល់គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៧ មានចំនួនជិត ២លាននាក់ (១,៧២៦,៤១៥) ក្នុងនោះជិត ៥ម៉ឺននាក់ ចុះឈ្មោះធ្វើការក្នុងឧស្សាហកម្មនេសាទ។

របាយការណ៍របស់ក្រសួងការងារកម្ពុជា ឱ្យដឹងថា បច្ចុប្បន្ន មានពលករខ្មែរជាង ១លាន ២សែននាក់កំពុងធ្វើការនៅប្រទេសថៃ។ ប៉ុន្តែរបាយការណ៍របស់អង្គការ (Central) បង្ហាញថា មានពលករខ្មែរកំពុង ធ្វើការដោយស្របច្បាប់ និងមិនស្របច្បាប់នៅប្រទេសថៃប្រមាណ ២លាននាក់ធ្វើការ នៅក្នុងប្រទេសថៃ និងភាគច្រើនពួកគាត់កំពុងជួបបញ្ហាផ្នែកសេដ្ឋកិច្ច៕

## រដ្ឋបាលខេត្តព្រះសីហនុ បកស្រាយបំភ្លឺ ពាក់ព័ន្ធនឹងករណីស្ត្រីជនជាតិវៀតណាមម្នាក់ បង្ហោះវីដេអូថាខ្លួនត្រូវបានគេចាប់បង្ខាំងឲ្យបម្រើការងារ

http://freshnewsasia.com/index.php/en/localnews/257446-2022-09-15-14-24-29.html 2022-09-15

**(ព្រះសីហនុ)៖** រដ្ឋបាលខេត្តព្រះសីហនុ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ បានឲ្យដឹងថា រយៈពេលថ្មីៗនេះ មានបណ្តាញសង្គម និងសារព័ត៌មានមួយចំនួន បានធ្វើការចែកចាយបន្តគ្នា នូវវីដេអូឃ្លីបស្ត្រីជនជាតិវៀតណាម (ចេះភាសាខ្មែរ) ម្នាក់ ដែលបានបង្ហោះដោយលើកឡើងថា ខ្លួនត្រូវបានគេចាប់បង្ខាំងទុក ដើម្បីឲ្យនៅបំរើការងារក្នុងក្រុមហ៊ុនមួយ នៅក្នុងខេត្តព្រះសីហនុ។

តាមប្រភពរបាយការណ៍ ស្តីពីលទ្ធផលនៃការស្រាវជ្រាវរបស់សមត្ថកិច្ច បានឲ្យដឹងថា កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង១៣៖០០នាទីរសៀល កម្លាំងជំនាញ នៃស្នងការដ្ឋាន នគរបាលខេត្តព្រះសីហនុ បានចុះទៅទីតាំងដែលស្ត្រីខាងលើបានបង្ហោះវីឌីអូឃ្លីបថា ត្រូវបានគេចាប់បង្ខាំងទុក ដើម្បីឲ្យនៅបំរើការងារក្នុងក្រុមហ៊ុននោះ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ។ ដោយមានការចូលរួមសហការពីម្ចាស់ទីតាំង កម្លាំងសមត្ថកិច្ច បានរកឃើញស្ត្រីជនជាតិវៀតណាមរូបនេះ និងនាំគាត់ និងអ្នកគ្រប់គ្រងជនជាតិចិនម្នាក់ ភេទប្រុស មកធ្វើការសាកសួរ នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។ បន្ទាប់ពីធ្វើការសាកសួរ គឺគាត់បានធ្វើការឲ្យក្រុមហ៊ុនចំនួន៣កន្លែង នៅក្នុងក្រុងព្រះសីហនុ ក្នុងនោះក្រុមហ៊ុន២កន្លែងទៀត មិនមានបញ្ហាអ្វីកើតឡើងចំពោះគាត់ទេ តែនៅក្រុមហ៊ុនទី៣នេះ គឺក្រុមហ៊ុនមានលក្ខខណ្ឌការងារតឹងរឹង ដោយសម្រូវឲ្យគាត់ធ្វើការច្រើនម៉ោងពី១៤ ទៅ១៥ម៉ោង ក្នុងមួយថ្ងៃ។

ដោយក្រុមហ៊ុនទី៣ខាងលើ ពេលគាត់ចូលធ្វើការដំបូង ខាងក្រុមហ៊ុនប្រាប់ថា ត្រូវធ្វើការ០៦ខែ ទើបអាចស្នើសុំឈប់បាន។ លុះពេលគាត់ធ្វើការបានជិត០៣ខែ ស្រាប់តែខាងក្រុមហ៊ុន បានឲ្យគាត់ចុះកុងត្រាថ្មី ជាលាយលក្ខអក្សរជាមួយក្រុមហ៊ុន ដោយធ្វើការរយៈពេល០៦ខែទៀត ជាហេតុធ្វើឲ្យគាត់មិនពេញចិត្ត។ ក្រោយមកទៀតស្ត្រីជនជាតិវៀតណាខាងលើ ទទួលបានដំណឹងថា ម្តាយរបស់គាត់មានជំងឺ គាត់បានស្នើសុំក្រុមហ៊ុនឈប់ធ្វើការតែក្រុមហ៊ុនមិនព្រមទើបគាត់ប្តឹងសមត្ថកិច្ច ឲ្យមកជួយគាត់យកចេញពីក្រុមហ៊ុនតែម្តង។ ហើយចំពោះវីដេអូឃ្លីបដែលគាត់បាននិយាយថា គាត់បានឃើញជនជាតិចិន នៅក្នុងក្រុមហ៊ុនមានអាវុធខ្លីប្រើប្រាស់ គឺជារឿងមិនពិតទេ ហើយគាត់មិនដែលបានឃើញជនជាតិចិន មានអាវុធប្រើប្រាស់ទេ គាត់គ្រាន់តែឮគេនិយាយបន្តគ្នា គ្មានប្រភពច្បាស់លាស់។

នៅពេលដែលគាត់ថតវីដេអូឃ្លីប គាត់មានការភិតភ័យ និងព្រួយបារម្ភណ៍ ទើបគាត់យំ ដោយខាងក្រុមហ៊ុនមិនបានបង្ខាំង និងវាយធ្វើបាបមកលើរូបគាត់ទេ។ ហើយមូលហេតុដែលគាត់ធ្វើបែបនេះ គឺគាត់ចង់ឲ្យសមត្ថកិច្ចមកជួយយកគាត់ចេញពីក្រុមហ៊ុនឲ្យបានលឿន ព្រោះគាត់ចង់ត្រឡប់ទៅប្រទេសកំណើត ដើម្បីមើលម្តាយឈឺ។ ជាមួយគ្នានេះ រដ្ឋបាលខេត្តសូមអំពាវនាវស្ថាប័នសារព័ត៌មាន និងអ្នកប្រើប្រាស់បណ្តាញសង្គម សូមបញ្ឈប់ការផ្សព្វផ្សាយ និងចែករំលែកនូវព័ត៌មានបំភ្លៃដែលខុស ពីហេតុការណ៍បានកើតឡើងពិតប្រាកដ ដែលធ្វើឲ្យសាធារណមតិមានការភាន់ច្រឡំ៕

## ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២

## សម្តេចក្រឡាហោម ស ខេង ដឹកនាំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការ

http://freshnewsasia.com/index.php/en/localnews/257536-2022-09-16-09-39-15.html 2022-09-16 04:39pm

**(ភ្នំពេញ)៖** នៅព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈប្រតិភូកម្ពុជា បានអញ្ជើញធ្វើជាសហដឹកនាំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧ តាមប្រព័ន្ធវីដេអូ តបតាមការអញ្ជើញរបស់នាយឧត្តមសេនីយ៍ អនុកុង ផៅចិន្តា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃ។ ក្រោយបញ្ចប់កិច្ចប្រជុំ ភាគីទាំងពីរបានចេញសេចក្តីប្រកាសព័ត៌មានរួម ឲ្យដឹងថា កិច្ចប្រជុំបានដំណើរការក្នុងបរិយាកាសមិត្តភាព សាមគ្គីភាព ភាតរភាព និងយោគយល់គ្នាទៅវិញទៅមក។ ភាគីទាំងពីរទទួលស្គាល់នូវសារៈសំខាន់នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និងមានឆន្ទៈក្នុងការរក្សាសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍប្រកបដោយចីរភាពរវាងប្រទេសទាំងពីរ។ កិច្ចប្រជុំបានផ្តល់តម្លៃខ្ពស់ ដល់ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកិច្ចសហប្រតិបត្តិការយ៉ាងទូលំទូលាយ ចំនួន១៨ចំណុច។

*__ទី១៖__ កិច្ចសហប្រតិបត្តិការក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីការឆ្លងកាត់ព្រំដែន៖ ភាគីទាំងពីរបានឯកភាពគ្នាបន្តអប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងអាជ្ញាធរមានសមត្ថកិច្ចនៅតាមតំបន់ព្រំដែនដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព និងពេញលេញនូវកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ។

*__ទី២៖__ កិច្ចសហប្រតិបត្តិការគ្រប់គ្រងការឆ្លងកាត់ព្រំដែន អំឡុងពេលឆ្លងរាលដាលជំងឺកូវីដ-១៩៖ ភាគីទាំងពីរលើកទឹកចិត្តដល់ស្ថាប័នពាក់ព័ន្ធ នៃប្រទេសទាំងពីរ បង្កើនការសម្របសម្រួលឲ្យស៊ីសង្វាក់គ្នានូវបែបបទនីតិវិធី និងវិធានការឆ្លងកាត់ព្រំដែន រួមមាន វិធានការសុខភាពសាធារណៈ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងដទៃទៀត សំដៅជួយសម្រួលដល់ការធ្វើដំណើរឆ្លងកាត់ព្រំដែន និងបើកដំណើរការឡើងវិញ នូវច្រកទ្វារព្រំដែនផ្សេងទៀតដែលមិនទាន់បានបើកដំណើរការនៅឡើយ។

*__ទី៣៖__ កិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម និងវិនិយោគនៅតាមព្រំដែន៖ ភាគីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់ នៃការជំរុញ និងសម្របសម្រួលដល់សកម្មភាពពាណិជ្ជកម្ម និងសេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរវាងខេត្តបន្ទាយមានជ័យ-ខេត្តស្រះកែវ និងខេត្តកោះកុង-ខេត្តត្រាត។ បន្ថែមលើនេះ ភាគីទាំងពីរ ឯកភាពសហការ និងសម្របសម្រួលសកម្មភាពជំនួញ និងពាណិជ្ជកម្មនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ ដើម្បីជំរុញចីរភាព និងវិបុលភាពរបស់ប្រជាជនរស់នៅតាមខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ។

*__ទី៤៖__ កិច្ចសហប្រតិបត្តិការលើវិស័យដឹកជញ្ជូន៖ ភាគីទាំងពីរគាំទ្រដល់ស្ថាប័នពាក់ព័ន្ធ នៃប្រទេសទាំងពីរពិចារណាឡើងវិញលើកិច្ចចរចាលើកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនតាមផ្លូវគោករវាងកម្ពុជា និងថៃ ដើម្បីជំរុញការតភ្ជាប់ការដឹកជញ្ជូនរវាងប្រទេសទាំងពីរ។

*__ទី៥៖__ កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្មក្នុងតំបន់ព្រំដែន៖ ភាគីទាំងពីរលើកទឹកចិត្តឲ្យខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ សម្របសម្រួលដល់ការធ្វើជំនួញផលិតផលកសិកម្មឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋរស់នៅតាមតំបន់ព្រំដែន។ ភាគីទាំងពីរបានព្រមព្រៀងបន្តធ្វើសហប្រតិបត្តិការ លើការងារអនាម័យ និងភូតគាមអនាម័

យ ការគ្រប់គ្រងការផ្ទុះឡើងនៃជំងឺសត្វ និងរុក្ខជាតិ សហការលើការកសាងសមត្ថភាព ការផ្លាស់ប្តូរលើព័ត៌មាន និងការស្រាវជ្រាវ និងអភិវឌ្ឍន៍។

***ទី៦៖** កិច្ចសហប្រតិបត្តិការឧស្សាហកម្ម៖ ភាគីទាំងពីរឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្ម ដើម្បីផ្តល់ការគាំទ្រដល់វិនិយោគិនប្រទេសទាំងពីរ ធ្វើការបណ្តាក់ទុនបើកដំណើរ ការរោងចក្រនៅក្នុងខេត្តជាប់ព្រំដែន នៃប្រទេសទាំងពីរ និងលើកទឹកចិត្តឲ្យមានការផ្លាស់ប្តូរទស្សនកិច្ច រវាងមន្ត្រី និងអ្នកជំនាញក្នុងវិស័យឧស្សាហកម្ម ដើម្បីចែករំលែកឧត្តមានុវត្ត និងចំណេះធ្វើ។

***ទី៧៖** កិច្ចសហប្រតិបត្តិការលើវិស័យការងារ៖ ភាគីទាំងពីរបានឯកភាពគ្នាគាំទ្រដល់ក្រសួង ស្ថាប័ន និងមន្ត្រីពាក់ព័ន្ធនៃប្រទេសទាំងពីរ សហការសម្របសម្រួលឲ្យពលករ នៃប្រទេសទាំងពីរប្រើប្រាស់ប័ណ្ណ ព្រំដែនសម្រាប់ធ្វើការងារប្រចាំថ្ងៃ និងប្រចាំរដូវនៅតាមតំបន់ព្រំដែន។

***ទី៨៖** កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងច្រកទ្វារព្រំដែន៖ ភាគីទាំងពីរបានស្វាគមន៍ ការបើកដំណើរការជាផ្លូវការច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី (ខេត្តបាត់ដំបង)-បានខៅឌីន (ខេត្តស្រះកែវ) នៅក្នុងឆ្នាំ២០១៨ និងស្វាគមន៍ការបិទបញ្ចប់ការងារសាងសង់ស្ពានមិត្តភាពកម្ពុជា-ថៃ ស្ទឹងបត់-បានណងអៀន នៅក្នុងឆ្នាំ២០១៩។ ភាគីទាំងពីរក៏បានលើកទឹកចិត្តឲ្យស្ថាប័នពាក់ព័ន្ធ សហការឲ្យបានជិតស្និទ្ធដើម្បីឈានទៅបើកដំណើរការច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ (ខេត្តបន្ទាយមានជ័យ)- បានណងអៀន (ខេត្តស្រះកែវ) ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

**បន្ថែមលើនេះ ភាគីទាំងពីរឯកភាពសហការពន្លឿនការដំឡើង និងការបើកដំណើរការច្រកទ្វារព្រំដែននៅសេសសល់ចំនួនបីទៀតជាច្រកទ្វារព្រំដែនអន្តរជាតិ មានដូចជា៖ ១៖** ច្រកទ្វារព្រំដែន អានសេះ (ខេត្តព្រះវិហារ)-អានម៉ា (ខេត្តឧប៊ុនរាជធានី), **២៖** ច្រកទ្វារព្រំដែនថ្មដា (ខេត្តពោធិ៍សាត់)-បានថាសែន (ខេត្តត្រាត) និង**៣៖** ច្រកទ្វារព្រំដែនជប់គគីរ (ខេត្តឧត្តរមានជ័យ)-សាយតាគូ (ខេត្តបុរីរុំ)។ ភាគីទាំងពីរក៏បានយល់ព្រមពិនិត្យលទ្ធភាព ក្នុងការដំឡើងកម្រិតច្រកទ្វារព្រំដែនធកកា (ខេត្តបាត់ដំបង)-បានម៉ាក់មួង (ខេត្តត្រាត) ទៅជាច្រកទ្វារព្រំដែនអន្តរជាតិ។ ជាងនេះទៅទៀត ភាគីទាំងពីរបានលើកទឹកចិត្តអាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរ ឲ្យធ្វើការវាស់វែងលម្អិតនៅភូមិព្រៃចាន់ ខេត្តបន្ទាយមានជ័យ និងភូមិណានម៉ាក់មូន ខេត្តស្រះកែវ ដើម្បីបង្កើតច្រកទ្វារតំបន់ព្រំដែនថ្មីមួយទៀត។ បន្ថែមលើនេះ ភាគីទាំងពីរឯកភាពថា មិនបិទច្រកទ្វារព្រំដែនជាឯកតោភាគីឡើយ។ ការបិទច្រកទ្វារព្រំដែនណាមួយ គប្បីធ្វើឡើងដោយមានហេតុផលច្បាស់លាស់ និងតាមការចាំបាច់ និងដោយមានការព្រមព្រៀងពីអាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរ។

***ទី៩៖** កិច្ចសហប្រតិបត្តិការលើវិស័យសុខភាពសាធារណៈ និងការអភិវឌ្ឍសហគមន៍៖ ភាគីទាំងពីរឯកភាពជំរុញឲ្យមានការផ្លាស់ប្តូរទស្សនកិច្ចសិក្សា ឬរៀបចំសិក្ខាសាលា ឬសន្និសីទផ្សេងៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ ព្រមទាំងវឌ្ឍនភាពលើការងារសេវាសុខាភិបាល។

***ទី១០៖** កិច្ចសហប្រតិបត្តិការគ្រប់គ្រងគ្រោះមហន្តរាយ៖ ភាគីទាំងពីរឯកភាពពិនិត្យលទ្ធភាពបង្កើតអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការផ្តល់ជំនួយបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយ។

***ទី១១៖** កិច្ចសហប្រតិបត្តិការកាប់ឈើខុសច្បាប់៖ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរ ខេត្ត និងកងកម្លាំងមានសមត្ថកិច្ចតាមបណ្តាខេត្តជាប់ព្រំដែន នៃប្រទេសទាំងពីរ ក្នុងការអប់រំណែនាំប្រជាពលរដ្ឋមិនឲ្យចាញ់ការអូសទាញ ទៅកាប់ឈើខុសច្បាប់តាមតំបន់ព្រំដែន និងក្នុងការអនុវត្ត វិធានការទប់ស្កាត់ និងបង្ក្រាបការកាប់ឈើខុសច្បាប់បានទាន់ពេលវេលា។

***ទី១២៖** កិច្ចសហប្រតិបត្តិការថែរក្សាបរិស្ថានព្រំដែន៖ ភាគីទាំងពីរបានឯកភាពចាត់ឲ្យខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីថែរក្សាបរិស្ថាន រួមបញ្ចូលការធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងសំណល់រឹង និងសំណល់រាវ នៅតាមបណ្តោយព្រំដែន។

***ទី១៣៖** កិច្ចសហប្រតិបត្តិការបង្ការ និងទប់ស្កាត់បទល្មើសឆ្លងដែន៖ ភាគីទាំងពីរវាយតម្លៃខ្ពស់ ចំពោះកងកម្លាំង និងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទាំងពីរ ដែលបានខិតខំប្រឹងប្រែងបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែន ជាពិសេសអំពើភេរវកម្ម ការជួញដូរគ្រឿងញៀនដោយខុសច្បាប់ ការជួញ ដូរមនុស្ស និងការរត់ពន្ធមនុស្ស ការជួញដូរអាវុធ គ្រាប់រំសេវ និងគ្រឿងផ្ទុះ។ បន្ថែមលើនេះ ភាគីទាំងពីរ គាំទ្រការកសាងភូមិសគ្មានគ្រឿងញៀន និងពង្រឹងដំណើរការ នៃការិយាល័យទំនាក់ទំនងព្រំដែន (BLO) និងផែនការសកម្មភាពពាក់ព័ន្ធ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបការជួញ ដូរគ្រឿងញៀន នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

***ទី១៤៖** កិច្ចសហប្រតិបត្តិការបោសសម្អាតមីន៖ ភាគីទាំងពីរឯកភាពបន្តសហការការងារ ដើម្បីសម្របសម្រួលប្រតិបត្តិការដោះមីន ដោយមនុស្សធម៌នៅតំបន់តាមបណ្តោយព្រំដែន ក្នុងគោលបំណងបំពេញកាតព្វកិច្ចស្របតាមតាមមាត្រា៥ នៃអនុសញ្ញាស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស។

***ទី១៥៖** កិច្ចសហប្រតិបត្តិការទេសចរណ៍៖ ភាគីទាំងពីរឯកភាពលើការអភិវឌ្ឍផ្លូវទេសចរណ៍រួម ក្រោមមូលបទ «ព្រះរាជាណាចក្រពីរ គោលដៅតែមួយ» និងគាំទ្រលើការអភិវឌ្ឍការតភ្ជាប់ទេសចរណ៍ រវាងខេត្តឆ្នេរសមុទ្រកម្ពុជា និងខេត្តភាគខាងកើតប្រទេសថៃ។

***ទី១៦៖** កិច្ចសហប្រតិបត្តិការខេត្ត/ក្រុងសម្ព័ន្ធមេត្រី៖ លើកទឹកចិត្តឲ្យមានសកម្មភាពរួមគ្នា ដើម្បីជំរុញភាពជាដៃគូទីក្រុងសម្ព័ន្ធមេត្រី ឲ្យកាន់តែប្រសើរឡើង និងប្រកបដោយចីរភាព។ ក្នុងនាមជាអ្នកជិតខាងល្អ ភាគីទាំងពីរឯកភាព ធ្វើការរួមគ្នាពង្រឹងការប្តេជ្ញាចិត្តរួមគ្នាក្នុងការការពារ និងថែរក្សា សម្បត្តិវប្បធម៌ និងធ្វើការឲ្យកាន់តែជិតស្និទ្ធ ដើម្បីលើកកម្ពស់ការយល់ដឹងសាធារណៈ ការយោគយល់ ទៅវិញទៅមក និងការគោរពទៅវិញទៅមកនៃវប្បធម៌ និងអត្តសញ្ញាណជាតិនីមួយៗ។

***ទី១៧៖** យន្តការកិច្ចសហប្រតិបត្តិការថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន៖ ភាគីទាំងពីរលើកទឹកចិត្ត អភិបាលខេត្តជាប់ព្រំដែន និងថ្នាក់ដឹកនាំ នៃរដ្ឋបាលក្រុង ស្រុកជាប់ព្រំដែន នៃប្រទេសទាំងពីរ ឲ្យសហការរៀបចំកិច្ចប្រជុំជាប្រចាំ ដោយប្តូរវេនគ្នាជាម្ចាស់ផ្ទះ ទៅតាមការព្រមព្រៀងគ្នារវាងអភិបាលខេត្ត ជាប់ព្រំដែននៃប្រទេសទាំងពីរ។

***ទី១៨៖** កិច្ចការផ្សេងៗ៖ ភាគីទាំងពីសម្តែងនូវក្តីសោមនស្សរីករាយចំពោះខួបអនុស្សាវរីយ៍លើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរក្នុងឆ្នាំ២០២០ ដែលបានរៀបចំព្រឹត្តិការណ៍ អបអរសាទរជាច្រើនពេញមួយឆ្នាំ។

កិច្ចប្រជុំលើកទឹកចិត្តឲ្យមានសកម្មភាព ឬព្រឹត្តការណ៍បន្ថែមទៀត ដើម្បីពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ នៅចុងបញ្ចប់នៃសេចក្តីព័ត៌មានរួមស្តីពីកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៧ ភាគីកម្ពុជាបានបញ្ជាក់ពីយល់ព្រមទទួលធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៨ ដោយកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងរៀបចំកិច្ចប្រជុំលើកទី៨ នឹងត្រូវពិភាក្សាគ្នាតាមផ្លូវទូត៕

## ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ណែនាំអំពីចំណាត់ការលើសំណុំរឿង ជួញដូរមនុស្ស សំណុំរឿងសម្អាតប្រាក់ និងសំណុំរឿងរំលោភសេពសន្ថវៈ

https://cen.com.kh/archives/533051.html Posted ByPen Srey NeatSeptember 17, 2022

ភ្នំពេញ ៖ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដឹកនាំកិច្ចប្រជុំ ស្តីពីការណែនាំអំពីចំណាត់ការលើសំណុំរឿងជួញដូរមនុស្ស សំណុំរឿងសម្អាតប្រាក់ និងសំណុំរឿងរំលោភសេពសន្ថវៈ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងពន្លឿនចំណាត់ការនីតិវិធីពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌទាំងនេះ នារសៀលថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០២២ នេះ,។នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានប្រសាសន៍ណែនាំ និងផ្តាំផ្ញើដល់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីនូវចំណុចសំខាន់ៗមួយចំនួនរួមមាន៖

(១)-ស្ថាប័នអយ្យការត្រូវផ្តល់កិច្ចសហការពេញលេញ និងគ្រប់ជ្រុងជ្រោយជាមួយមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ ក្នុងការអនុវត្តប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ។

(២)-ស្ថាប័នអយ្យការត្រូវយកចិត្តទុកដាក់ពន្លាតការស្រាវជ្រាវពាក់ព័ន្ធនឹងបទល្មើសសម្អាតប្រាក់ ចំពោះករណីបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ ឱ្យបានទាន់ពេលវេលា និងឱ្យមានប្រសិទ្ធភាព។

(៣)-សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ត្រូវពន្លឿនចំណាត់ការឱ្យបានឆាប់រហ័ស ចំពោះសំណុំរឿងជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម អាជីវកម្មផ្លូវភេទ និងសំណុំរឿងរំលោភសេពសន្ថវៈ ព្រមទាំងសំណុំរឿងពាក់ព័ន្ធផ្សេងទៀត។

(៤)-ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ទាំងអស់ ត្រូវយកចិត្តទុកដាក់ពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមទៀត លើជំនាញផ្នែកប្រយុទ្ធប្រឆាំងនឹងការសម្អាតប្រាក់ ក៏ដូចជាបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ ដើម្បីធានាប្រសិទ្ធភាពការងារក្នុងការប្រយុទ្ធប្រឆាំងបទល្មើសទាំងនេះ សំដៅឆ្លើយតបទៅនឹងសភាការណ៍ជាក់ស្តែងនៃការវិវត្តផ្នែកសង្គម និងសេដ្ឋកិច្ច។រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## ប្រេសិតវៀតណាមប្រចាំកម្ពុជានិយាយថា មានការស្វែងរកជំនួយទាំងថ្ងៃទាំងយប់ពីមនុស្ស ដែលលក់ទៅធ្វើជាទាសករ

https://www.khmertimeskh.com/501151709//?p=1151709 September 16, 2022

ចំនួនមនុស្សយ៉ាងច្រើនដែលធ្វើដំណើរពីប្រទេសវៀតណាមមកខេត្តព្រះសីហនុ ប្រទេសកម្ពុជា ហើយត្រូវបានធ្លាក់ទៅក្នុងទាសភាពសម័យទំនើប គឺជាបញ្ហាប្រឈមដ៏សំខាន់មួយក្នុងកិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះ។ ចាប់តាំងពីដើមឆ្នាំនេះ ស្ថានកុងស៊ុលវៀតណាមប្រចាំក្រុងព្រះសីហនុ បានសហការជាមួយអាជ្ញាធរកម្ពុជា ធ្វើការស្វែងរក៥០-៦០ដង និងជួយសង្គ្រោះមនុស្សជាង៦០០នាក់ ពីពលកម្មដោយបង្ខំ។ ចាប់តាំងពីឆ្នាំមុន ជនជាតិវៀតណាមជាង ៨០០ នាក់ ត្រូវបានគេជួយសង្គ្រោះពីខេត្តព្រះសីហនុ។ ប៉ុន្តែអគ្គកុងស៊ុលលោក Vu Ngoc Ly បាននិយាយថា ចំនួនពិតប្រាកដនៃជនរងគ្រោះវៀតណាមដែលធ្វើការអោយក្រុមឆបោកនៅកម្ពុជាគឺធំជាងនេះ ហើយកិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះប្រឈមនឹងបញ្ហាជាច្រើន។ លោកបានបន្តថា បញ្ហាធំបំផុតនោះគឺចំនួនប្រជាជនវៀតណាមយ៉ាងច្រើនបានមកកម្ពុជា ដែលបណ្តាលឱ្យមានជនរងគ្រោះជាច្រើន ហើយជារៀងរាល់ថ្ងៃស្ថានកុងស៊ុលទទួលបានសំណើជាច្រើនដើម្បីជួយសង្គ្រោះ។ "ការហៅទូរសព្ទថ្មីៗមានទាំងយប់ទាំងថ្ងៃឥតឈប់ឈរ យើងមិនហ៊ានបិទទូរសព្ទរបស់យើងទេ"។

លោកនិយាយថា កាលពីខែមេសា ស្ថានកុងស៊ុលបានទទួលការសុំជំនួយពីជនជាតិវៀតណាមមួយចំនួន ដែលនិយាយថាពួកគេត្រូវបានគេឃុំខ្លួនជាកម្មករដោយបង្ខំ។ ស្ថានកុងស៊ុលបានសហការជាមួយប៉ូលីសមូលដ្ឋាន និងបានជួយសង្គ្រោះពលករចំនួន ២៧០ នាក់ដែលជាប់នៅក្នុងកន្លែងពួកគេធ្វើការ។ ពួកគេទាំងអស់សុទ្ធតែជាជនជាតិវៀតណាម ប៉ុន្តែមានតែប្រហែល ៥០ នាក់ប៉ុណ្ណោះដែលមានឯកសារ ហើយអ្នកនៅសេសសល់បានធ្វើដំណើរមកកម្ពុជាដោយខុសច្បាប់។ លោកនិយាយថា អ្នកទាំងអស់បានវិលត្រឡប់ទៅប្រទេសវៀតណាមវិញដោយសុវត្ថិភាព។ បញ្ហាមួយទៀតដែលក្រុមអ្នកជួយសង្គ្រោះប្រឈមនោះគឺថា ព័ត៌មានដែលផ្ញើទៅស្ថានកុងស៊ុល ជារឿយៗមិនមានភាពលម្អិត និងពិបាកក្នុងការផ្ទៀងផ្ទាត់។ "សារជាច្រើនមានតែឈ្មោះ និងអាយុ រួមជាមួយនឹងរូបភាពអត្តសញ្ញាណប័ណ្ណ សមាជិកគ្រួសារគ្រាន់តែដឹងថាពួកគេបានធ្វើដំណើរមកប្រទេសកម្ពុជា ឬកំពុងរស់នៅក្នុងខេត្តព្រះសីហនុ ប៉ុន្តែមិនដឹងថាពួកគេនៅឯណាពិតប្រាកដនោះទេ។ "អ្នកខ្លះផ្ញើទិន្នន័យ GPS ប៉ុន្តែបង្ហាញតែតំបន់ដែលមានអគារមួយចំនួនប៉ុណ្ណោះ យើងមិនដឹងច្បាស់ថាពួកគេស្ថិតនៅអគារណានោះទេ។"លោកបានបន្ថែមថា ប៉ូលីសកម្ពុជាត្រូវការព័ត៌មានច្បាស់លាស់ ដូចជាលេខបន្ទប់ ជាន់ និងអាស័យដ្ឋាន មុនពេលពួកគេបញ្ជូនមន្ត្រី ហើយពួកគេត្រូវធ្វើការងារច្រើន ដោយសារត្រូវដោះស្រាយច្រើនករណីក្នុងពេលតែមួយ។ លោកបន្តថា ពលករខុសច្បាប់កាន់តែច្រើនឡើងៗពីប្រទេសវៀតណាមមកកម្ពុជាហើយចំនួនក៏កើនឡើងយ៉ាងឆាប់រហ័ស។ "រាល់ពេលដែលយើងយកមនុស្សម្នាក់ចេញ ពីរឬបីនាក់ទៀតបានចូល"។

បញ្ហាជនជាតិវៀតណាមលក់ទៅធ្វើជាទាសករនៅតំបន់នានាដូចជាខេត្តព្រះសីហនុ បានកើនឡើងតាំងពីចុងឆ្នាំមុន នៅពេលដែលវិធានការរឹតបន្តឹងកូវីត-១៩ នៅក្នុងប្រទេសទាំងពីរត្រូវបានបន្ធូរបន្ថយ។ ក្រុមឆបោកបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីទាក់ទាញជនជាតិវៀតណាម ដោយសន្យាផ្តល់ការងារងាយស្រួលនិងប្រាក់ខែខ្ពស់។ ជាធម្មតាជនរងគ្រោះគឺជាមនុស្សដែលមានអាយុពី ២០-៣០ ឆ្នាំ ពេលខ្លះក៏មានក្មេងអាយុពី ១៤-១៥ ឆ្នាំ។ លោក Ly បាននិយាយថា ស្ទើរតែគ្រប់គ្នាដែលមកកម្ពុជាដោយខុសច្បាប់នៅទីបំផុតក្លាយជាជនរងគ្រោះនៃការបង្ខំឲ្យធ្វើការងារ។ នៅពេលដែលពួកគេមកដល់ប្រទេសកម្ពុជា ពួកគេត្រូវបានឱ្យចុះហត្ថលេខាលើកិច្ចសន្យាជាភាសាខ្មែរ អង់គ្លេស ឬចិន ហើយពួកគេភាគច្រើនចុះហត្ថលេខាដោយមិនដឹងខ្លឹមសារច្បាស់លាស់។

យោងតាមការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម កន្លែងការងារដោយបង្ខំភាគច្រើនត្រូវបានក្លែងបន្លំជាអាជីវកម្មអនឡាញ ឬកាស៊ីណូ។ ជនរងគ្រោះដឹងថា "ការងារក្នុងក្តីស្រមៃ" របស់ពួកគេ មិនមែនជាអ្វីដែលពួកគេធ្លាប់គិតនោះទេ ហើយត្រូវបានបង្ខំឱ្យធ្វើការជាមួយនឹងប្រាក់កម្រៃទាប និងទទួលរងនូវការផាកពិន័យចំពោះការបំពានកិច្ចសន្យា។ លោក Ly បានពន្យល់ថា "ថៅកែផ្តល់កូតាឱ្យពួកគេ ដូចជាត្រូវរកលុយអោយបានប៉ុន្មានដើម្បីបោកប្រាស់មនុស្សក្នុងមួយថ្ងៃ ឬចំនួនជនជាតិវៀតណាមប៉ុន្មាននាក់ដែលត្រូវល្បួងអោយមកកម្ពុជា។"ប្រសិនបើកូតាមិនត្រូវបានបំពេញទេ ថៅកែធ្វើឱ្យពួកគេធ្វើការ ១៦-១៧ ម៉ោងក្នុងមួយថ្ងៃ កាត់ប្រាក់ខែ ឬលក់ពួកគេឱ្យអ្នកដទៃទៀត"។មានករណីជាច្រើនដែលជនរងគ្រោះត្រូវបានគេវាយដំនិងបញ្ជាឲ្យសងសំណងចំពោះការបំពានកិច្ចសន្យា។

ស្ថានកុងស៊ុលនិយាយថាចំនួនប្រាក់លោះដើម្បីយកជនរងគ្រោះចេញបានកើនឡើងក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះពីប្រហែល១,០០០ដុល្លារក្នុងឆ្នាំ២០២០-២០២១ ដល់២,០០០-៥,០០០ដុល្លារចាប់តាំងពីចុងឆ្នាំមុន។ មានករណីមួយចំនួនទារសំណងរហូតដល់២០.០០០ដុល្លារ។មនុស្សមួយចំនួនហៅក្រុមគ្រួសាររបស់ពួកគេឱ្យស្វែងរកជំនួយ ថែមទាំងគំរាមធ្វើអត្តឃាត ខណៈដែលពួកគេ "ប្រហែលជាស្លាប់ផងដែរ" ជាជាងរស់នៅដោយទទួលបានការធ្វើបាប។ គ្រួសារជាច្រើនលក់អ្វីៗទាំងអស់ដែលពួកគេមាន ឬខ្ចីប្រាក់ដើម្បីបង់ថ្លៃលោះ។ គ្រួសារដែលមិនអាចរកប្រាក់បានស្វែងរកជំនួយពីអាជ្ញាធរវៀតណាម និងកម្ពុជា។

លោក Ly និយាយថា វិធានការសំខាន់មួយដើម្បីបញ្ឈប់បញ្ហានេះ គឺការអប់រំប្រជាជនអំពីការសន្យាដោយ "ការងារងាយស្រួលនិងប្រាក់ខែខ្ពស់"នៅបរទេស ជាពិសេសអ្នកដែលរស់នៅជិតព្រំដែនជាមួយប្រទេសដទៃទៀត។ ស្ថានកុងស៊ុលបានបន្តថា ការអប់រំគួរតែធ្វើឡើងនៅក្នុងគ្រួសារ និងនៅសាលារៀន ហើយត្រូវផ្តោតលើយុវជន និងអ្នកដែលខ្វះលទ្ធភាពទទួលបានព័ត៌មាន។ លោកបានបន្ថែមថា៖ "ចំនួនអ្នកជួយសង្គ្រោះ ហាក់បីដូចជាតិចជាងចំនួនជាក់ស្តែងទៅទៀត។ ប៉ុន្តែខ្ញុំជឿថា ក្នុងរយៈពេលមួយ ឬពីរឆ្នាំទៀត នឹងមិនមានបញ្ហាបែបនេះទេ នៅក្នុងខេត្តព្រះសីហនុ"។ លោកបានចង្អុលបង្ហាញពីយុទ្ធនាការប្រឆាំងឧក្រិដ្ឋកម្មរបស់អាជ្ញាធរកម្ពុជា ដើម្បីបញ្ឈប់ការជួញដូរមនុស្ស និងទាសភាពសម័យទំនើប។ *VNExpress*

## អ្នកនាំពាក្យក្រសួងមហាផ្ទៃ៖ រយៈពេល៣ថ្ងៃនេះ សមត្ថកិច្ចបើកប្រតិបត្តិការជួយសង្គ្រោះជនបរទេស២ករណី រកឃើញជនរងគ្រោះ១០នាក់

http://freshnewsasia.com/index.php/en/localnews/257451-2022-09-15-15-02-45.html 2022-09-15 10:02pm

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃបានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឲ្យដឹងថា រយៈពេល ៣ ថ្ងៃមកនេះ ពោលចាប់ពីថ្ងៃទី១២ ដល់១៥ ខែកញ្ញា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជា បានបើកប្រតិបត្តិការជួយសង្គ្រោះជនបរទេស២ករណី ដោយរកឃើញជនរងគ្រោះចំនួន១០នាក់។ ប្រតិបត្តិការជួយសង្គ្រោះជនបរទេសទាំងពីរករណីនេះ បានធ្វើឡើងនៅរាជធានីភ្នំពេញចំនួន១ករណី កាលពីថ្ងៃទី១២ ខែកញ្ញា ដោយសង្គ្រោះជនបរទេសម្នាក់ និងធ្វើឡើងនៅខេត្តព្រះសីហនុ១ករណី កាលពីថ្ងៃទី១៤ ខែកញ្ញា ដោយសង្គ្រោះបានជនបរទេសចំនួន៩នាក់។

ដោយឡែកគិតចាប់ពីម៉ោង៣រសៀលថ្ងៃទី១៤ ដល់ម៉ោង៣រសៀល ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២នេះ សមត្ថកិច្ចកម្ពុជា បានទទួលសំណើចំនួន២៤ករណី ទាក់ទងទៅនឹងការសុំអន្តរាគមន៍ឲ្យជួយស្វែងរកជនជាតិចិន និងវៀតណាមសរុប ២៩នាក់។ សំណើទាំងនោះមាននៅក្នុងខេត្តព្រះសីហនុស្វាយរៀង ពោធិ៍សាត់ ឧត្តរមានជ័យ កោះកុង និងរាជធានីភ្នំពេញជាដើម។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ។

នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅព្រឹកថ្ងៃទី០៩ ខែកញ្ញា រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ឱ្យគ្រប់រដ្ឋបាលរាជធានី ខេត្ត និងមូលដ្ឋានទាំងអស់ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការ ប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរ និងរត់ពន្ធមនុស្ស ពលកម្ម បង្ខិតបង្ខំ និងអាជីវកម្មផ្លូវភេទ ឱ្យមានប្រសិទ្ធភាពផងដែរ។

# ស្ត្រីឥណ្ឌាម្នាក់រត់គេចពីការងារក្លែងក្លាយនៅកម្ពុជា

https://www.khmertimeskh.com/1151738// September 16, 2022

ស្ត្រីម្នាក់មកពីតំបន់ Puducherry ដែលត្រូវបានសន្យាថានឹងផ្តល់ការងារហៅទូរស័ព្ទ បានមកកម្ពុជា ដោយបង្ខំឱ្យធ្វើការជាអ្នកឆបោក និងបង្ខាំងនៅក្នុងបន្ទប់មួយ ប៉ុន្តែគាត់បានរត់គេចខ្លួនត្រឡប់ទៅស្រុកកំណើតវិញ។ ប៉ូលីសបាននិយាយកាលពីថ្ងៃព្រហស្បតិ៍ថា ក្រោយមក ស្ត្រីនោះបានទៅជួបអគ្គនាយក Puducherry នៅថ្ងៃទី១២ ខែកញ្ញា ហើយក្នុងរយៈពេល២៤ ម៉ោង ជនជាប់ចោទម្នាក់ត្រូវបានចាប់ខ្លួន។ តាមការលើកឡើង ស្ត្រីរូបនេះបានរកឃើញការផ្សាយពាណិជ្ជកម្មតាមបណ្តាញមួយដែលផ្តល់ការងារជាអ្នកហៅទូរស័ព្ទក្នុងប្រទេសកម្ពុជាដោយសន្យាផ្តល់ប្រាក់ខែរហូតដល់ Rs 1 lakh (ប្រហែល១២០០ដុល្លារ) ។ នៅពេលដែលនាងចុចលេខនៅលើអេក្រង់ ស្ត្រីនោះបានទាក់ទងជាមួយ Murugan នៅ Puducherry និង Rajkumar នៅ Chennai ។ អ្នកទាំងពីរបានសុំឱ្យនាងបង់ប្រាក់ Rs 3.25 lakh (ប្រហែល៤០០០ដុល្លារ) ជាថ្លៃរត់ការសម្រាប់ទិដ្ឋាការ ហើយបានប្រាប់នាងថាមួយផ្នែកនៃលុយនេះនឹងជាកម្រៃជើងសារបស់ពួកគេ។ ប៉ូលិសបាននិយាយថា ពេលស្ត្រីរូបនោះមកដល់ប្រទេសកម្ពុជា នាងត្រូវបានជនម្នាក់ឈ្មោះ John មកទទួល។ ពេលទៅដល់កម្ពុជា ស្ត្រីរូបនេះបានដឹងថា នាងបានទៅទីនោះតាមទិដ្ឋាការទេសចរណ៍។ John បានផ្តល់ឱ្យនាងនូវការងារជាអ្នកហៅទូរស័ព្ទ ប៉ុន្តែវាបានក្លាយជាផ្នែកមួយនៃការបោកប្រាស់។ នៅពេលដែលនាងបដិសេធមិនទទួលយកការងារនោះ ស្ត្រីនោះត្រូវបាន John និងក្រុមពួកគេ គំរាមទារប្រាក់ចំនួន ២,៧៦,៥០០ Rs បើមិនដូចឆ្នោះទេ នាងនឹងត្រូវបានលក់ទៅបន្ត និងបង្ខំអោយធ្វើពេស្យាចារ។

ស្ត្រីរូបនេះត្រូវបានគេរាយការណ៍ថាត្រូវបានឃុំឃាំងនៅក្នុងបន្ទប់មួយ ហើយទទួលរងការធ្វើទារុណកម្មផ្លូវចិត្ត និងផ្លូវកាយ ហើយត្រូវបានគំរាមកំហែងថានាង និងគ្រួសាររបស់នាងនឹងមានគ្រោះថ្នាក់ ប្រសិនបើនាងទាក់ទងទៅស្ថានទូត ឬភ្នាក់ងារផ្លូវច្បាប់ណាមួយផ្សេងទៀត។ ប៉ូលិសបាននិយាយថា តាមប្រភពខ្លះស្ត្រីនោះបានរកមធ្យោបាយរត់គេចពីកន្លែងនោះត្រឡប់ទៅប្រទេសឥណ្ឌាវិញ ។ បន្ទាប់ពីនាងបានជួបអគ្គនាយក Puducherry និងបានដាក់ពាក្យបណ្តឹង ករណីមួយត្រូវបានចុះបញ្ជីដោយ CB-CID ដែលជាក្រុមពិសេសមួយត្រូវបានបង្កើតឡើង ហើយប៉ូលីសបានចាប់ខ្លួន Murugan ក្នុងរយៈពេល ២៤ម៉ោង។ ពេលនេះក្រុមការងរបានធ្វើដំណើរទៅក្រុង Chennai ដើម្បីចាប់ខ្លួនជនជាប់ចោទម្នាក់ទៀត ហើយនឹងចាប់ខ្លួនអ្នកផ្សេងទៀតដែលពាក់ព័ន្ធនឹងការងារឆបោកនេះ។ *The Indian Express*

# ជនរងគ្រោះម៉ាឡេស៊ី១១នាក់ទៀត ពីការឆបោកការងារនៅកម្ពុជាត្រូវបាននាំមកប្រទេសកំណើត

https://www.khmertimeskh.com/501152566//?p=1152566 Khmer Times September 17, 2022

ជនជាតិម៉ាឡេស៊ី ១១នាក់ទៀត ដែលធ្លាក់ខ្លួនជាជនរងគ្រោះដោយសារក្រុមបោកប្រាស់ការងារនៅកម្ពុជា បានមកដល់អាកាសយានដ្ឋានអន្តរជាតិគូឡាឡាំពួរទី២ ដោយសុវត្ថិភាពនៅម៉ោង ១១៖៥៥នាទីយប់ថ្ងៃព្រហស្បតិ៍ ពាក់កណ្តាលអធ្រាត្រ។ នៅក្នុងសេចក្តីថ្លែងការណ៍មួយកាលពីម្សិលមិញ ក្រសួងការបរទេសម៉ាឡេស៊ីបាននិយាយថា គិតត្រឹមម្សិលមិញ ជនរងគ្រោះសរុបចំនួន ១២៣ នាក់ក្នុងចំណោម ១៥៣ នាក់ត្រូវបានជួយសង្គ្រោះ។ "ក្រសួងសូមថ្លែងអំណរគុណ និងដឹងគុណចំពោះរដ្ឋាភិបាលកម្ពុជា តាមរយៈអាជ្ញាធររបស់ប្រទេស ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អដែលបានផ្តល់ឱ្យក្នុងការកំណត់ទីតាំង និងជួយសង្គ្រោះជនរងគ្រោះ។

ក្រសួងតាមរយៈស្ថានទូតម៉ាឡេស៊ីប្រចាំរាជធានីភ្នំពេញ នឹងបន្តសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរកម្ពុជាក្នុងការកំណត់ទីតាំង និងជួយសង្គ្រោះជនរងគ្រោះ ដើម្បីឲ្យពួកគេអាចត្រឡប់ទៅប្រទេសកំណើតវិញដោយ

សុវត្ថិភាព។ យោងតាមសេចក្តីថ្លែងការណ៍ បុគ្គល ឬសាច់ញាតិរបស់ពលរដ្ឋម៉ាឡេស៊ីដែលពាក់ព័ន្ធនឹងការបោកប្រាស់ការងារនៅក្រៅប្រទេសអាចទាក់ទងទៅក្រសួងដោយផ្ទាល់តាមរយៈអង្គភាពជំនួយកុងស៊ុលសម្រាប់ប្រជាជនម៉ាឡេស៊ីនៅក្រៅប្រទេសតាមរយៈអ៊ីមែល bkrm@kln.gov.my ។ លើសពីនេះ ក៏អាចទាក់ទងស្ថានទូតម៉ាឡេស៊ីប្រចាំទីក្រុងភ្នំពេញ តាមរយៈអ៊ីមែល mwphnompenh@kln.gov.my ។

## សាលាឧទ្ធរណ៍ តម្កល់ទោស ប្តីប្រពន្ធបង់ក្លាដេស និង ប្រពន្ធខ្មែរ ២នាក់ ជាប់គុក ក្នុងម្នាក់ៗ ៧ ឆ្នាំ ជាប់ពាក់ព័ន្ធការរត់ពន្ធមនុស្ស ឆ្លងដែនខុសច្បាប់

https://dap-news.com/national/2022/09/17/279683/ ByPH104Posted on September 17, 2022

**ភ្នំពេញៈ ប្តីប្រពន្ធបង់ក្លាដេស និងខ្មែរ ជាប់ចោទមួយគូ កាលពីថ្ងៃ ទី ១៦ ខែកញ្ញា ឆ្នាំ២០២២ ត្រូវបានសាលាឧទ្ធរណ៍ រាជធានីភ្នំពេញ ប្រកាសសាលក្រមដីកា តម្កល់ទោស ត្រូវជាប់ក្នុងពន្ធនាគារ ក្នុងម្នាក់ៗ កំណត់ ៧ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការរត់ពន្ធមនុស្សឆ្លងដែនខុសច្បាប់ ដោយធ្វើការ លួចនាំចូល នូវពលករជនជាតិ បង់ក្លាដេស ចំនួន ១៦ នាក់ មកធ្វើការក្នុងប្រទេសកម្ពុជាដោយមិនស្របច្បាប់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុង ឆ្នាំ២០២០ ។**

លោកស្រី ខៀវ សុខា ជាប្រធានចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ បានថ្លែងអោយដឹង នៅក្នុងអង្គសវនាការថា ជនជាប់ចោទ ទាំង២នាក់នេះ មាន ឈ្មោះ MOHAMMAD JAHNGIR ភេទប្រុស ភេទប្រុស អាយុ ៣៧ ឆ្នាំ ជនជាតិបង់ក្លាដេស មានមុខរបរមុនចាប់ខ្លួន ជានាយកក្រុមហ៊ុន CEB BIC CIES CO,Lld ។ និង ឈ្មោះ ឈ្មោះ ម៉មសុខុម ភេទ ស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ។ អ្នកទាំង២ នាក់ គឺ ត្រូវជាប្តីប្រពន្ធនឹងគ្នាមានទីលំនៅផ្ទះគ្មានលេខ ផ្លូវលំ ភូមិថ្មគោល២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ។ លោកស្រីចៅក្រម បានថ្លែងថាៈនៅក្នុងសំណុំរឿងក្តីនេះ ពួកគេទាំង២នាក់ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២១ កាត់ទោស ដាក់ពន្ធនាគារកំណត់ ក្នុង ម្នាក់ៗ កំណត់ ៧ ឆ្នាំ ពីបទ: នាំចេញដោយមិនស្របច្បាប់ និងជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច ។ តែពួកគេបានប្តឹងឧទ្ធរណ៍។ ពួកគេ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ៣០ខែ កក្កដា ឆ្នាំ ២០២១ នៅភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ ក្រោយការឃាត់ខ្លួនពួកគេ, សមត្ថកិច្ចនគរបាលប្រឆាំងការជួញដូរមនុស្ស ក្រសួងមហាផ្ទៃ ជួយសង្គ្រោះបានជនរងគ្រោះ ជនជាតិបង់ក្លដេស ចំនួន ១៦ នាក់ ក្នុងនោះ មានប្រុសចំនួន១៥នាក់ និង ស្រី ម្នាក់៕ ដោយ : លីហ្សា

## កងកម្លាំងការពារព្រំដែនគោកលេខ៤០៣ ៖ ទប់ស្កាត់បង្រ្កាបឱ្យបានទាន់ពេលវេលារាល់បទល្មើស ជួញដូរមនុស្ស រត់ពន្ធគ្រឿងញៀន និងការឆ្លងដែនចេញចូលខុសច្បាប់

http://nokorwatnews.com/archives/899425 17/09/2022

ខេត្តព្រះវិហារ ៖ លោកវរសេនីយ៍ឯក ជឹម សំអោ មេបញ្ជាការ កងការពារព្រំដែនគោកលេខ ៤០៣ នៅព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២ បានបន្តចាត់តាំងកម្លាំងដើរល្បាត ត្រួតពិនិត្យភូមិសាស្ត្រ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ភូមិសាស្ត្រដែលអង្គភាពទទួលខុសត្រូវ ដើម្បីតាមដាន និងក្តាប់ឱ្យជាប់នូវរាល់សភាពការណ៍ប្រែប្រួលតាមព្រំដែន ព្រមទាំងទប់ស្កាត់រាល់បទល្មើសផ្សេងៗដែលអាចកើតមានឡើង ជាលទ្ធផល សភាពការណ៍នៅលើខ្សែបន្ទាត់ព្រំដែន ដែលអង្គភាពទទួលខុសត្រូវគ្មានអ្វីប្រែប្រួលឡើយ ។ ក្នុងនោះដែរ លោកវរសេនីយ៍ឯក ជឹម សំអោ មេបញ្ជាការកងការពារព្រំដែនគោកលេខ ៤០៣ បានមានប្រសាសន៍ថា ក្រៅពីការងារស្នូល ដោយអនុវត្តតាមបទបញ្ជារបស់ ឯកឧត្តម មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៤ បានដាក់បទបញ្ជាដល់កងកម្លាំងទាំងអស់ មានភារកិច្ចត្រៀមបម្រុងកម្លាំងនៅហ្នឹងកន្លែង ទាំងមធ្យោបាយ គ្រឿងបំពាក់ និងសម្ភារៈប្រើប្រាស់

ផ្ទាល់ខ្លួន ត្រៀមសហការជាមួយកម្លាំងមានសមត្ថកិច្ចដែលអង្គភាពឈរជើង ដើម្បីការពារ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព នាឱកាសបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ បុណ្យអុំទូក អកអំបុក សំពះព្រះខែ និងបុណ្យឆ្លងឆ្នាំសកល ខាងមុខនេះ។

លោកវរសេនីយ៍ឯក ជឹម សំអោ បានគូសបញ្ជាក់ថា កម្លាំងទាំងអស់ ត្រូវបង្កើនការប្រុងប្រយ័ត្នតាមដានសភាពការណ៍ព្រំដែន ចាត់តាំងកម្លាំងត្រៀមប្រយុទ្ធ ធ្វើសកម្មភាពល្បាតត្រួតពិនិត្យតាមបណ្តោយព្រំដែន ដោះស្រាយទាន់ពេលវេលានូវយកថាហេតុកើតឡើង ការពាររឹងមាំបូរណភាពទឹកដី និងចំណុចឈរជើងរបស់ខ្លួន ទប់ស្កាត់បង្ក្រាបបានទាន់ពេលវេលារាល់បទល្មើស ជួញដូរមនុស្ស រត់ពន្ធគ្រឿងញៀន ការឆ្លងដែនចេញចូលខុសច្បាប់ ដើម្បីបង្ការជំងឺកូវីដ១៩ នៅតាមខ្សែបន្ទាត់ព្រំដែន ពិសេសត្រៀមកម្លាំង ជួយសង្គ្រោះប្រជាពលរដ្ឋដែលជួបគ្រោះមហន្តរាយធម្មជាតិ ក្នុងភូមិសាស្រ្តទទួលខុសត្រូវ និងត្រូវត្រៀមខ្លួន គ្រឿងបំពាក់ សម្ភារៈប្រើប្រាស់ និងមធ្យោបាយ ២៤ម៉ោងលើ២៤ម៉ោង រង់ចាំបទបញ្ជា៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/2022/09/16/-31/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅរសៀល ថ្ងៃសុក្រ ៦រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរង ផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ីមេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២លើក សរុបចំនួន២៨នាក់ ស្រី១១នាក់ ក្មេង១១នាក់ ក្មេងស្រី៤នាក់ ។

ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្ដែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/2022/09/16/-30/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង៦ និង០០នាទី ថ្ងៃសុក្រ ៦រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស . ២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹម សាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និង ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡេ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន២៨នាក់ ស្រី១៧នាក់ ។

ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើការពិនិត្យ និងស្ដែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២

### សម្តេចក្រឡាហោម ស ខេង អញ្ជើញដឹកនាំកិច្ចប្រជុំណែនាំ អំពីវិធានការប្រឆាំងការអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ

https://www.information.gov.kh/articles/86592 ចេញផ្សាយ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០២២

នៅទីស្តីការក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃចន្ទ ទី១៩ ខែកញ្ញា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំណែនាំ អំពីវិធានការប្រឆាំងការអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ ដោយមានការចូលរួមពី រដ្ឋលេខាធិការប្រចាំការ, រដ្ឋលេខាធិការ, អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ, អគ្គស្នងការដ្ឋាននគរបាលជាតិ, អភិបាលរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធជាច្រើនរូបទៀត។ នាឱកាសនោះដែរ សម្តេចក្រឡាហោម ស ខេង ក៏មានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ។ សម្តេចក្រឡាហោម បន្ថែមថា កន្លងមកសារព័ត៌មានអន្តរជាតិធំៗ និងបណ្តាញព័ត៌មានមួយចំនួនទៀតនៃប្រទេសក្នុងតំបន់ រួមទាំងប្រទេសជិតខាងកម្ពុជាផងដែរ បានផ្សព្វផ្សាយ ចោទប្រកាន់មកលើប្រទេសកម្ពុជា ជាបន្តបន្ទាប់ដែលធ្វើឱ្យប៉ះពាល់ដល់មុខមាត់កិត្តិយសរបស់ប្រទេសជាតិ និងបានបន្ទុចបង្អាក់ដល់លំហូរវិនិយោគិនបរទេស អ្នកទេសចរណ៍ ក៏ដូចជា៖ អ្នកជំនាញបច្ចេកទេសបរទេសមកកម្ពុជា។

សម្តេចក្រឡាហោម បន្តថា យោងតាមស្ថានភាពការណ៍ចាំបាច់នេះ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ កន្លងទៅនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញផែនការប្រតិបត្តិការ ប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ព្រមទាំងបានបង្កើត គណៈ

បញ្ជាការប្រតិបត្តិការដើម្បីអនុវត្តផែនការនេះ។ សម្តេច ថា គណៈបញ្ជាការប្រតិបត្តិការ ដែលដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ក៏បានរៀបចំផែនការអនុវត្ត នូវផែនការប្រតិបត្តិការ ដោយរៀបចំឱ្យមានក្រុមប្រតិបត្តិការផ្ទាល់ចំនួន ៥ បានផ្សព្វផ្សាយផែនការនេះ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២ កន្លងទៅ ដើម្បីចាប់ផ្តើមអនុវត្ត គឺចុះជួយគាំទ្រខេត្តព្រះសីហនុ។

លើសពីនេះ សម្តេចក្រឡាហោម ស ខេង បញ្ជាក់ថា នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ កន្លងទៅ ក្រសួងយុត្តិធម៌ ក៏បានចេញសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដើម្បីចូលរួមអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា ជាពិសេស ជួយពង្រឹងបន្ថែមចំពោះផ្នែកច្បាប់៕

## សម្តេច ស ខេង៖ ល្បែងខុសច្បាប់ក្លាយជាមែកធាងនៃការជួញដូរមនុស្សនៅកម្ពុជា

https://btv.com.kh/article/15422 2022/09/19 12:36:26 pm

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា បនល្បែងខុសច្បាប់គឺកំពុងក្លាយជាមហារីកនៅក្នុងសង្គមកម្ពុជា ខណៈដែលល្បែងស៊ីសងនេះហើយ ជាមែកធាងនៃការជួញដូរមនុស្សនៅកម្ពុជា។ ថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយពីបញ្ចប់នៃកិច្ចប្រជុំ ស្តីពីករណីបង្ក្រាបបទល្មើសជួញដូរមនុស្ស និងការបង្ក្រាបបទល្មើសល្បែងស៊ីសងខុសច្បាប់ នាក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ២០២២ នេះ សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា រាជរដ្ឋាភិបាលបានកំពុងយកចិត្តទុកដាក់បំផុត ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងបង្ក្រាបបនល្បែងខុសច្បាប់គ្រប់ប្រភេទ ដោយសារការជួញដូរមនុស្ស និងល្បែងអនឡាញខុសច្បាប់ទាំងនេះហើយ ធ្វើឲ្យកម្ពុជាកំពុងមានឈ្មោះមិនសូវល្អលើឆាកអន្តរជាតិ ជាពិសេសក្រោយដែលអាមេរិកបានដាក់កម្ពុជាក្នុងបញ្ជីខ្មៅ ជាប្រទេសទីបី ក្នុងការមិនយកចិត្តទុកដាក់ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្សនេះ។

យ៉ាងណាក៏ដោយសម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា រាជរដ្ឋាភិបាល បានកំពុងខិតយ៉ាងយកចិត្តទុកដាក់បំផុតក្នុងការពន្លត់ភ្លើងនៃមហារីកសង្គមនេះឲ្យអស់ ហើយប្រសិនបើមិនប្រញ៉ាប់ពន្លត់វាទេ វានឹងរីករាលដាលដល់បទល្មើសផ្សេងៗទៀតនៅក្នុងសង្គមកម្ពុជា រួមទាំងប៉ះពាល់ដល់ការពង្រឹង ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាផងដែរ។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី ក៏បានបញ្ជាក់ផងដែរថា គោលដៅសង្ស័យច្រើនជាងគេចំពោះជួញដូរមនុស្ស និងបនល្បែងខុសច្បាប់តាមអនឡាញនេះ គឺនៅខេត្តព្រះសីហនុ ហើយអាជ្ញាធរចម្រុះបានកំពុងធ្វើប្រតិបត្តិការយ៉ាងសកម្មផងដែរ ដោយបានចាប់ជនល្មើសយកទៅផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន និងបានជួយសង្គ្រោះជនរងគ្រោះឲ្យរួចផុតពីការជួញដូរ និងធ្វើទារុណកម្មបានយ៉ាងច្រើនផងដែរ៕ អត្ថបទ៖ បាន ចក់

## សម្តេចក្រឡាហោម ស ខេង នឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ និងកិច្ចបជុំពាក់ព័ន្ធ

https://www.information.gov.kh/articles/86598 ចេញផ្សាយ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០២២

ដោយបានការឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងនាមជាប្រធានប្តូរវេន នឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួល បន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ ( 16'h AMMTC and Its Related Meetings ) ចាប់ពីថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ។

កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ គឺជាវេទិកាសម្រាប់ រដ្ឋមន្ត្រីមកពីបណ្តារដ្ឋសមាជិកអាស៊ាន ផ្លាស់ប្តូរយោបល់ និងចែករំលែកបច្ចុប្បន្នភាពអំពីនិន្នាការនៃ ឧក្រិដ្ឋកម្មឆ្លងដែនក្នុងតំបន់ និងសកល ជាពិសេសលើប្រភេទនៃឧក្រិដ្ឋកម្មទាំង១០ ដែលបានកំណត់ ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរបស់អាស៊ាន ដូចជា៖ ការរត់ពន្ធអាវុធ អំពើភេរវកម្ម ការសម្អាតប្រាក់ អំពើប្លន់លើផ្ទៃសមុទ្រ ការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស បទល្មើសសេដ្ឋកិច្ចអន្តរជាតិ បទល្មើស បច្ចេកវិទ្យា ការជួញដូរគ្រឿងញៀនខុសច្បាប់ និងការជួញដូរសត្វព្រៃ និងឈើខុសច្បាប់។ ទន្ទឹមនេះ កិច្ចប្រជុំ ក៏នឹងពិនិត្យ ពិភាក្សាលើកម្មវិធីការងារ និងផែនការសកម្មភាពដែលបានដាក់ចេញកន្លងមក ដើម្បីឈានទៅកំណត់ទិសដៅអនុវត្តបន្ត។

សូមជម្រាបជូនដែរថា នៅក្នុងក្របខណ្ឌនៃកិច្ចប្រជុំ លើកទី១៦ នេះដែរ ក្រសួងមហាផ្ទៃ ក៏នឹងធ្វើជាប្រធានកិច្ចប្រជុំ ពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ជាមួយដៃគូសន្ទនា បូកបី ( ចិន, ជប៉ុន , សាធារណរដ្ឋកូរ៉េ ) លើកទី១២ ( 12º AMMTC + 3 Consultation ) ៕

## នគរបាលចុះបង្ក្រាបទីតាំងប្រព្រឹត្តិអំពើជួញដូរផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងកុមារ, ចាប់ជនសង្ស័យម្នាក់ និងសង្គ្រោះជនរងគ្រោះ៤នាក់

http://freshnewsasia.com/index.php/en/localnews/257666-2022-09-17-13-32-59.html 2022-09-17 08:32pm

**(ភ្នំពេញ)៖** កម្លាំងការិយាល័យប្រឆាំការជួញដូរមនុស្ស និងការពារអនីតិជន បានឃាត់ខ្លួនជនសង្ស័យម្នាក់ពាក់ព័ន្ធករណីបើកកន្លែងប្រព្រឹត្តិអំពើសញ្ចារកម្ម ជួញដូរផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងកុមារ និងសង្គ្រោះជនរងគ្រោះចំនួន០៤នាក់។ នេះបើតាមលោកវរសេនីយ៍ឯក សាន សុខសីហា អ្នកនាំពាក្យស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News នៅព្រលប់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២នេះ។

អ្នកនាំពាក្យរូបនេះ បានឱ្យដឹងថា ប្រតិបត្តិការបង្ក្រាបបទល្មើសនេះ បានធ្វើឡើងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ២១:០០នាទី ដឹកនាំដោយលោកឧត្តមសេនីយ៍ទោ ចាន់ កិត្តិឧម ស្នងការរង ទទួលដឹកនាំការងារការិយាល័យប្រឆាំការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះអនុវត្តចំណារអនុញ្ញាតឱ្យបង្ក្រាបដាក់ស្តែងលេខ ១៩៤ អ.យ.ក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ លោកវរសេនីយ៍ឯក សាន សុខសីហា បានបន្ថែមថា ក្នុងប្រតិបត្តិករនេះ កម្លាំងជំនាញបានឃាត់ខ្លួនជនសង្ស័យម្នាក់ និងសង្គ្រោះជនរងគ្រោះចំនួន០៤នាក់ ស្រី (អនីតិជន ០២នាក់) ពាក់ព័ន្ធករណីបើកកន្លែងប្រព្រឹត្តិអំពើសញ្ចារកម្ម ឃីហោ (សម្រស់ម្ទិះ) នៅផ្ទះលេខ235A ផ្លូវលំ សង្កាត់កន្ទោក ខណ្ឌកំបូលរាជធានីភ្នំពេញ មកកាន់ការិយាល័យ ដើម្បីធ្វើការសាកសួរ និងស្រាវជ្រាវ។

លោកបានបន្តថា ជនសង្ស័យឈ្មោះ សៀវ ប៊ុនជឿន ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ បើកហាងម៉ាស្សា។ **វត្ថុតាងដកហូត៖** ស្រោមអនាម័យប្រើប្រាស់រួច និងមិនទាន់ប្រើប្រាស់មួយចំនួន, ម៉ូតូ ០១គ្រឿង ម៉ាក់ Nex ពណ៌ស ផ្លាកលេខ កំពង់ធំ 1M. 2321។បច្ចុប្បន្នជនសង្ស័យ និងវត្ថុតាងខាងលើកម្លាំងជំនាញការិយាល័យ កំពុងកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់៕

## ជនជាតិវៀតណាមជាង៥០នាក់ រត់ចេញពីកាស៊ីណូក្នុងខេត្តស្វាយរៀងស្វែងរកការជួយសង្គ្រោះ

https://www.rfi.fr/km//20220918-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 18/09/2022 - 08:57ដោយ៖ជួប នរក្សា

យ៉ាងហោចណាស់ មានជនជាតិវៀតណាមជាង៥០នាក់ បាននាំគ្នារត់ចេញពីកាស៊ីណូមួយកន្លែងក្នុងក្រុងបាវិត ខេត្តស្វាយរៀង សំដៅទៅប្រទេសវៀតណាមវិញ។ ព្រឹត្តិការណ៍នេះបានកើតឡើងកាលពីម្សិលមិញ គឺស្របពេលដែលរដ្ឋាភិបាលកម្ពុជា បើកយុទ្ធនាការបង្ក្រាបកន្លែងលេងល្បែងស៊ីសងខុសច្បាប់ និងស្របពេលនឹងយុទ្ធនាការបង្ក្រាបការជួញដូរមនុស្សនៅកម្ពុជា។

បើតាមការចុះផ្សាយរបស់សារព័ត៌មាន VN Express គឺមានជនជាតិវៀតណាមចំនួន៥៦នាក់ បាននាំគ្នារត់ចេញពីទីតាំងកាស៊ីណូមួយកន្លែងក្នុងក្រុងបាវិត ខេត្តស្វាយរៀង សំដៅទៅរកច្រកព្រំដែនម៉ុកបៃ ប្រទេសវៀតណាមនៅថ្ងៃទី១៧កញ្ញា។ លោក Tran Ngoc Binh ដែលជាជនជាតិវៀតណាម បានរត់ចេញនោះ បានអះអាងថា រូបគេបានចាញ់បោកមកធ្វើការនៅកាស៊ីណូកាលពីខែបីខែមុន។ បើតាមការអះអាងគឺមានមនុស្សជាច្រើនត្រូវបានដាក់ឲ្យស្នាក់នៅអគារជាន់ទីប្រាំបី ដែលមានផ្លូវចេញតែមួយប៉ុណ្ណោះ។ បើតាមលោក Tran Ngoc Binh គឺជនជាតិវៀតណាមជាង៥០ ដែលនាំគ្នារត់ចេញរួមទាំងលោកផង បានគិតពីគម្រោងនេះតាំងពីប៉ុន្មានថ្ងៃមុន ដើម្បីស្វែងរកការសង្គ្រោះពីអ្នកខាងក្រៅ។ យ៉ាងណាជនជាតិវៀតណាមដែលរត់ចេញពីទីតាំងល្បែងកម្សាន្តក្នុងក្រុងបាវិត ត្រូវបានអាជ្ញាធរសមត្ថកិច្ចឃាត់ខ្លួន ដើម្បីស៊ើបអង្កេតបន្ត។ បើតាមការបញ្ជាក់ចុងក្រោយ ជនជាតិវៀតណាមទាំងនោះកំពុងស្ថិតការិយាល័យអន្តោប្រវេសន៍ក្រុងបាវិត។

វិទ្យុបារាំងអន្តរជាតិ មិនអាចសុំការបញ្ជាក់ពីលោក ពេជ្រ វីរៈ ស្នងការនគរបាលខេត្តស្វាយរៀង បាននៅឡើយទេនៅថ្ងៃអាទិត្យ។ យ៉ាងណាមិញ ការរត់ចេញរបស់ជនជាតិវៀតណាម កើតឡើងចំពេលដែលរដ្ឋាភិបាលកម្ពុជាបានប្រកាសពីការបើកការបង្ក្រាបបទល្មើសល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទនៅកម្ពុជា។ តាមរយៈសារជាសំឡេងជាង២០នាទី កាលពីថ្ងៃសៅរ៍ទី១៧កញ្ញា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញបទបញ្ជាដាច់ខាតមួយ ដោយឲ្យអាជ្ញាធរមូលដ្ឋានត្រូវបង្ក្រាបឲ្យអស់នូវកន្លែងលែងល្បែងស៊ីសងខុសច្បាប់។ តាមលោកនាយករដ្ឋមន្ត្រី គឺលោកមិនញញើតសោះឡើយ ក្នុងការដកតំណែងមន្ត្រីមូលដ្ឋាន រាប់ចាប់តាំងពីតំណែងអភិបាល ប្រសិនបើពួកគេគ្មានឆន្ទៈបង្ក្រាបល្បែងស៊ីសងដែលខុសច្បាប់៕

## សមត្ថកិច្ចរកឃើញជនបរទេស៤៩៥នាក់ និងកំណត់បទល្មើស៦ផ្សេងគ្នា ក្រោយត្រួតពិនិត្យអគារស៊ីងសានទីងនៅខេត្តព្រះសីហនុ

http://freshnewsasia.com/index.php/en/localnews/257729-2022-09-18-11-33-05.html 2022-09-18 06:33pm

**(ព្រះសីហនុ)៖** រដ្ឋបាលខេត្តព្រះសីហនុ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២នេះ បានចេញសេចក្តីប្រកាសព័ត៌មានអំពីលទ្ធផលប្រតិបត្តិការចុះត្រួតពិនិត្យរដ្ឋបាលទីតាំងឈ្មោះ ស៊ីង សាន ទីង (ហៅ ឆាងធឹង) ចាប់ពីថ្ងៃទី១៣ដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២ ដោយបានរកឃើញជនបរទេសសរុប៤៩៥នាក់ និងកំណត់បទល្មើស៦ផ្សេងគ្នា។ បន្ទាប់ពីមានការឯកភាពក្នុងកិច្ចប្រជុំរវាងគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តព្រះសីហនុ បានសហការជាមួយនាយកដ្ឋានកណ្តាលសន្តិសុខនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងស្ថាប័នជំនាញពាក់ព័ន្ធ ដោយមានការសម្របសម្រួលនីតិវិធីពីអយ្យការអមសាលាដំបូងខេត្តបានចុះត្រួតពិនិត្យរដ្ឋបាលទី

តាំងឈ្មោះ ស៊ីង សាន ទីង (ហៅឆាងធឹង) មានចំនួន៣អគារ (អគារ A, B និង C) ដោយពិនិត្យលើស្ថានភាពទីតាំងអាជ្ញាប័ណ្ណប្រកបអាជីវកម្ម ការស្នាក់នៅនិងការបម្រើការងាររបស់ជនបរទេស ព្រមទាំងស្រាវជ្រាវស៊ើបអង្កេតបទល្មើសបង្ខាំងមនុស្សដោយខុសច្បាប់ ការទារុណកម្ម និងបទល្មើសជួញដូរមនុស្ស ដោយប្រើប្រាស់កម្លាំងសរុប១៣៧រូប។ ទីតាំងឈ្មោះ ស៊ីង សាន ទីង ស្ថិតនៅដីឡូតិ៍ ក្រុម២៧ ភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

**ប្រតិបត្តិការបង្ក្រាបនេះទទួលបានលទ្ធផលដូចខាងក្រោម៖**

ទីតាំងឈ្មោះ ស៊ីង សាន ទីង (ហៅឆាងធឹង) មានចំនួន៣អគារ (អគារA មាន៣ជាន់, អគារB មាន២ជាន់ និងអគារC មាន៣ជាន់) មានបន្ទប់សរុប៣៣២បន្ទប់ បន្ទប់ស្នាក់នៅមានចំនួន២៦៧បន្ទប់ បន្ទប់ធ្វើការមានចំនួន៥១បន្ទប់ អាហារដ្ឋានមានចំនួន១១ហាង Mart ១ ហាងលក់ផ្លែឈើ១ ហាងអ៊ុតសក់១ និងកន្លែងលេងកម្សាន្ត១ មានជនបរទេសសរុប៤៩៥នាក់ (ស្រី៥១នាក់) មាន៤សញ្ជាតិ។ ក្នុងប្រតិបត្តិការរយៈពេល៥ថ្ងៃនេះ កម្លាំងចម្រុះដឹកនាំដោយគណៈបញ្ជាការឯកភាពខេត្តបានរកឃើញនូវជនបរទេសខុសច្បាប់អន្តោប្រវេសន៍ចំនួន១៤១នាក់ ស្រី៦នាក់ មាន២សញ្ជាតិ ក្នុងនោះមានជនជាតិចិនចំនួន១៣០នាក់ (ស្រី៣នាក់) និងជនជាតិវៀតណាមចំនួន១១នាក់ (ស្រី៣នាក់) ដោយបានបញ្ជូនទៅនាយកដ្ឋានស៊ើបអង្កេតនិងអនុវត្តនីតិវិធីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ដើម្បីបណ្តេញចេញពីកម្ពុជា។

ក្នុងនោះផងដែរមានជនបរទេសចំនួន២៦២នាក់ (ស្រី២៥នាក់) ត្រូវបានពិនិត្យឃើញថា បានបម្រើការងារដោយគ្មានបណ្ណការងារ ហើយត្រូវបានផាកពិន័យដោយជំនាញមកពីនាយកដ្ឋានជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ រួចទើបអនុញ្ញាតឱ្យស្នើសុំបណ្ណការងារពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត អង្គភាពទាំងពីរបានប្រមូលអាករចេញពីការផាកពិន័យ និងការផ្តល់បណ្ណការងារសរុបបានចំនួន១៣១,០០០,០០០រៀល និង៧៨,៨៤០ដុល្លារ។ បន្ថែមពីនេះមន្ទីរការងារបានផាកពិន័យចំពោះសហគ្រាសលើ៣ចំណុច ដូចជាគ្មានសេចក្តីប្រកាសស្តីពីបុគ្គលិក គ្មានលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស គ្មានបណ្ណការងារ ដែលសរុបជាទឹកប្រាក់បានចំនួន៦,៧២០,០០០រៀល។

សមត្ថកិច្ចជំនាញនៃនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៃអគ្គស្នងការដ្ឋាននគរបាលជាតិ រួមជាមួយសមត្ថកិច្ចជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងជំនាញនគរបាលព្រហ្មទណ្ឌនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានរកឃើញនិងកំណត់បានបទល្មើសចំនួន៦បទល្មើសផ្សេងគ្នា ដូចជា បទល្មើសល្បែងស៊ីសងខុសច្បាប់ បទល្មើសបង្ខាំងនិងធ្វើទារុណកម្មមនុស្សខុសច្បាប់ បទល្មើសកាន់កាប់ និងរក្សាទុកអាវុធខុសច្បាប់ បទល្មើសសញ្ចារកម្ម និងជួញដូរមនុស្ស ព្រមទាំងបើកការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ ស្របតាមសំអាងនៃបទល្មើសល្បែងស៊ីសងខុសច្បាប់ និងបទល្មើសសញ្ចារកម្ម និងជួញដូរមនុស្ស។

ជនបរទេសចំនួន២៧នាក់ត្រូវបាននាំខ្លួន និងបញ្ជូនទៅសាកសួរនៅស្នងការដ្ឋាននគរបាលខេត្ត (ជនសង្ស័យ១២នាក់ ជនរងគ្រោះ៥នាក់ និងនារីបម្រើសេវាផ្លូវភេទ១០នាក់) និងបានដកហូតនូវវត្ថុតាងមួយចំនួន ដូចជា អាវុធខ្លី៤ដើម ទូរស័ព្ទដៃសរុប៨,៧៧៦គ្រឿង កុំព្យូទ័រលើតុ៨០៤គ្រឿង កុំព្យូទ័រយួរដៃ១៦គ្រឿង លិខិតឆ្លងដែន៣៦ក្បាល ឧបករណ៍ផ្ទុកទិន្នន័យ១២គ្រឿង ខ្នោះដៃ៤គូ ដំបងឆក់៨ដើម ពិលឆក់២ដើម រួមទាំងសម្ភារៈ ឯកសារ និងប្រាក់មួយចំនួន។

**ដោយទទួលបានគោលការណ៍ពីសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជំនាញពាក់ព័ន្ធគណៈបញ្ជាការឯកភាពខេត្តព្រះសីហនុសម្រេចដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

១.ធ្វើកិច្ចសន្យាអប់រំដល់ជនបរទេសដែលស្របច្បាប់ និងជនបរទេសដែលបានផាកពិន័យ រួចឱ្យចាកចេញពីទីតាំងទៅរកកន្លែងថ្មីតាមការស្ម័គ្រចិត្ត។

២.បិទអាជីវកម្មទាំងអស់ដែលស្ថិតក្នុងបរិវេណទីតាំងឈ្មោះ ស៊ីង សានទីង (ហៅឆាងធឹង)។

៣.បិទអគារA អគារB និងអគារC ដើម្បីបន្តស៊ើបអង្កេតរហូតដល់កិច្ចស៊ើបអង្កេតត្រូវបានបញ្ចប់ទាំងស្រុង។

៤.បន្តការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ ស្របសំអាង នៃបទល្មើសល្បែងស៊ីសងខុសច្បាប់លើជនសង្ស័យចំនួន៤នាក់ និងក្រុមហ៊ុនចំនួន១។

៥. បន្តការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ ស្របសំអាងនៃបទល្មើសជួញដូរមនុស្ស និងបទល្មើសសញ្ជារកម្ម ជនសង្ស័យចំនួន២នាក់។

៦. បន្តការស៊ើបអង្កេតលើករណីរក្សាទុកអាវុធខុសច្បាប់ និងបទល្មើសពាក់ព័ន្ធ។

៧. បន្តការស្រាវជ្រាវ និងស្វែងរកចាប់ខ្លួនជនសង្ស័យចំនួន១នាក់ ដែលជាមេក្លោងក្នុងសំណុំរឿងខាងលើ។

រដ្ឋបាលខេត្តព្រះសីហនុនឹងបន្តធ្វើការត្រួតពិនិត្យរដ្ឋបាលនៅតាមបណ្តាទីតាំងអាជីវកម្ម ដែលសង្ស័យមិនមានច្បាប់អនុញ្ញាត ព្រមទាំងចាត់វិធានការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ចំពោះជនបរទេសដែលបានត្រួតពិនិត្យ និងមានកិច្ចសន្យាអប់រំរួចហើយនៅតែបន្តស្វែងរកការធ្វើដោយខុសច្បាប់ និងសូមអំពាវនាវដល់អាជីវករទាំងអស់ ដែលកំពុងសម្ងំលួចលាក់ធ្វើអាជីវកម្មដោយគ្មានច្បាប់អនុញ្ញាត បញ្ឈប់ជាបន្ទាន់នូវសកម្មភាពទាំងឡាយណាដែលច្បាប់ហាមឃាត់៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/2022/09/18/-32/ 18/09/2022 Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃសៅរ៍ ៧រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជាលោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃនិងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង ៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូនខេត្តបាត់ដំបង ចំនួន០៣លើក សរុបចំនួន៥១នាក់ ស្រី១៣នាក់ ក្មេង៥នាក់ ក្មេងស្រី៤នាក់ ។

ក្រោយពីទទួលបានកម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចប្រគល់បងប្អូន ចំនួន២នាក់ ស្រី១នាក់ ទៅឲ្យក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារអន្តរជាតិគីឡូ១៣ និងបងប្អូន ចំនួន៤៩នាក់ ស្រី១២នាក់ ក្មេង៥នាក់ ក្មេងស្រី៤នាក់ ទៅឲ្យក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើការត្រួតពិនិត្យប៉័ណ្ណចាក់វ៉ាក់សាំងជាលទ្ធផលត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## សមត្ថកិច្ចស្រាវជ្រាវ តាមបណ្តឹង Hotline រកឃើញជនរងគ្រោះ៩នាក់ និងឃាត់ជនសង្ស័យ ៧នាក់ ព្រមទាំងរកឃើញជនជាតិចិន៣៧នាក់ ស្នាក់នៅដោយខុសច្បាប់

https://freshnewsasia.com/index.php/en/localnews/257785-2022-09-19-05-44-51.html 2022-09-19 12:44pm

**(ភ្នំពេញ)៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញ បានចុះត្រួតពិនិត្យមកដល់ទីតាំងក្នុងសណ្ឋាគារ ថាមពលថ្មី នៅក្នុងខេត្តព្រះសីហនុ ដោយស្វែងរកឃើញជនរងគ្រោះជាជនជាតិចំនួន៩នាក់ និងឃាត់ខ្លួនជនសង្ស័យ៧នាក់ ព្រមទាំងបន្តស្វែងរកជនជាតិចិនចំនួន ៣៧នាក់ (ស្រី៥) សង្ស័យស្នាក់នៅដោយខុសច្បាប់ ក្នុងប្រទេសកម្ពុជា (លួចឆ្លងដែន)។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា ប្រតិបត្តិការចុះត្រួតពិនិត្យនេះ ធ្វើឡើងបន្ទាប់ពីមានបណ្តឹងតាម HotLine របស់ក្រុមការងារសម្តេចក្រឡាហោម ស ខេង ថា: មានបុរសជនជាតិចិន០៩នាក់ សង្ស័យថាត្រូវបានបង្ខាំងទុកដោយខុសច្បាប់ នៅក្នុងសណ្ឋាគារ ថាមពលថ្មី នៅក្នុងខេត្តព្រះសីហនុ។ **នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានបញ្ជាក់ថា នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១១៖៣០នាទី កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងបានសហការជាមួយកម្លាំងនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជនក្រសួងមហាផ្ទៃ បានចុះមកដល់ទីតាំងអគារ ថាមពលថ្មី ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ដើម្បីស្វែងរកបុរសជនជាតិចិន ០៩នាក់ សង្ស័យថា ត្រូវបានបង្ខាំងទុកដោយខុសច្បាប់៖**

**ទី១៖** ឈ្មោះ JIANG LINFENG

**ទី២៖** ឈ្មោះ CHEN WEI

**ទី៣៖** ឈ្មោះ SUN SHIHAO

**ទី៤៖** ឈ្មោះ LIU ZEHAO

**ទី៥៖** ឈ្មោះ LUO ZHENHUA

**ទី៦៖** ឈ្មោះ DU HAILUN

**ទី៧៖** ឈ្មោះ LIANG JIANQIANG

**ទី៨៖** ឈ្មោះ CHEN HANJIE

**និងទី៩៖** ឈ្មោះ CHEN RONGWEI

ជាមួយគ្នានេះដែរ នាយឧត្តមសេនីយ៍ បានបន្តថា ដោយមានការសហការពីម្ចាស់ទីតាំងកម្លាំងសមត្ថកិច្ចបានស្វែងរកឃើញជនរងគ្រោះទាំង ០៩នាក់ ជាជនជាតិចិន ភេទប្រុស និងធ្វើការឃាត់ខ្លួនបានជនសង្ស័យចំនួន ០៧នាក់ ភេទប្រុស ជនជាតិខ្មែរ ដែលនៅចាំយាមជនរងគ្រោះមិនឱ្យចេញពីបន្ទប់ស្នាក់នៅ។ ក្នុងកិច្ចប្រតិបត្តិការណ៍នេះ កម្លាំងសមត្ថកិច្ចបានស្រាវជ្រាវស្វែងរកឃើញ ជនជាតិចិនចំនួន ៣៧នាក់ (ស្រី៥) សង្ស័យស្នាក់នៅដោយខុសច្បាប់ ក្នុងប្រទេសកម្ពុជា (លួចឆ្លងដែន)។ ករណីនេះកម្លាំងសមត្ថកិច្ចបាននាំជនរងគ្រោះ និងជនសង្ស័យមកធ្វើការសាកសួរតាមនីតិវិធីជំនាញ នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ព្រមទាំងបាននាំយកជនជាតិចិនចំនួន ៣៧នាក់ (ស្រី៥) ស្នាក់នៅដោយខុសច្បាប់ ក្នុងប្រទេសកម្ពុជា (លួចឆ្លងដែន) ទៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដើម្បីចាត់ការតាមនីតិវិធីជំនាញ៕

## កាស៊ីណូនៅកម្ពុជាដោះលែងជនជាតិវៀតណាម ១១នាក់

https://www.khmertimeskh.com/501153574/ Khmer Times September 19, 2022

កាស៊ីណូមួយក្នុងប្រទេសកម្ពុជាបានប្រគល់ពលរដ្ឋវៀតណាមចំនួន ១១ នាក់ទៅអាជ្ញាធរមូលដ្ឋាន បន្ទាប់ពីមានបុគ្គលិកចំនួន ៥៦ នាក់បានរត់គេចពីកន្លែងនោះកាលពីថ្ងៃសៅរ៍។ ក្រសួងការបរទេសបាននិយាយថា បច្ចុប្បន្នវៀតណាមកំពុងសហការជាមួយអាជ្ញាធរកម្ពុជា ដើម្បីនាំពលរដ្ឋវៀតណាមត្រឡប់ទៅផ្ទះវិញឱ្យបានឆាប់

តាមដែលអាចធ្វើទៅបាន និងដើម្បីពិនិត្យមើលថាតើមានជនជាតិវៀតណាមណាផ្សេងទៀតដែលនៅសេសសល់នៅកន្លែងនេះដែរឬទេ។

លោក Nguyen Thanh Ngoc ប្រធានគណៈកម្មាធិការប្រជាជន Tay Ninh បាននិយាយកាលពីថ្ងៃសៅរ៍ថា ជនជាតិវៀតណាមចំនួន ៥៦ នាក់ដែលធ្វើការនៅក្នុងកាស៊ីណូមួយក្នុងក្រុងបាវិត ខេត្តស្វាយរៀង បានភៀសខ្លួនទៅកាន់ផ្លូវធំឆ្ពោះទៅច្រកព្រំដែន Moc Bai ដោយលើកឡើងពីលក្ខខណ្ឌការងារ។ លោក Ngoc បាននិយាយថា នគរបាលកម្ពុជាបានឃាត់ក្រុមនេះដើម្បីធ្វើការស៊ើបអង្កេត។

វីដេអូរយៈពេលមួយនាទីដែលបានថតដោយប្រជាជនក្នុងតំបន់បង្ហាញថាក្រុមនេះបានរត់ចេញពីកាស៊ីណូពេលមានភ្លៀងធ្លាក់ខ្លាំង។ វីដេអូបង្ហាញពីមនុស្សជាច្រើនក្នុងឯកសណ្ឋានពណ៌ខ្មៅដេញតាមពួកគេ។ ពេលមនុស្សមួយចំនួនរត់ចេញ ជនក្នុងឯកសណ្ឋានពណ៌ខ្មៅបានចាប់និងវាយដំពួកគេ។ ការរត់គេចខ្លួននេះគឺជាការប៉ុនប៉ងធំទីពីររបស់ពលករវៀតណាមនៅកម្ពុជា ដែលបានកើតឡើងក្នុងប៉ុន្មានសប្ដាហ៍ថ្មីៗនេះ។

កាលពីថ្ងៃទី១៨ ខែសីហា ជនជាតិវៀតណាម៤០នាក់បានហែលឆ្លងទន្លេ Binh Di ដើម្បីគេចចេញពីកាស៊ីណូ Phoenix ក្នុងប្រទេសកម្ពុជា ទៅកាន់ខេត្ត An Giang ប្រទេសវៀតណាម។ ម្នាក់ក្នុងចំណោម២នាក់ផ្សេងទៀត ដែលបានព្យាយាមរត់គេចខ្លួនផងដែរ គឺក្មេងប្រុសជំទង់ម្នាក់ បានលង់ទឹកទន្លេ ចំណែកម្នាក់ទៀតត្រូវមនុស្សរបស់កាស៊ីណូចាប់បានវិញ។ ជនជាតិវៀតណាមបាននិយាយថា ពួកគេត្រូវបានគេបង្ខាំងខ្លួននៅកាស៊ីណូប្រឆាំងនឹងឆន្ទៈរបស់ពួកគេ និងទទួលរងការធ្វើទារុណកម្ម។

ក្នុងឆមាសទី១ឆ្នាំនេះ ក្រសួងសន្តិសុខសាធារណៈបានបង្ក្រាបបណ្ដាញជាច្រើនដែលរត់ពន្ធមនុស្សមកកម្ពុជាដើម្បីធ្វើការខុសច្បាប់។ អាជ្ញាធរក៏បានជួយសង្គ្រោះពលរដ្ឋវៀតណាមរាប់រយនាក់ និងជួយរាប់ម៉ឺននាក់ផ្សេងទៀតនៅក្នុងប្រទេសកម្ពុជារៀបចំនីតិវិធីឲ្យត្រឡប់ទៅប្រទេសកំណើតវិញ។ *VnExpress*

# ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២

## ក្នុងរយៈពេល១ខែ ក្រសួង មហាផ្ទៃបានទទួលបណ្ដឹង សរុបចំនួន២៨៩ករណី ពីការជួញដូរមនុស្ស

https://www.information.gov.kh/articles/86624 វិទ្យុជាតិកម្ពុជា៖ លោកស្រី ធីណា ឌីណេ ១៩,០៩,២០២២

MC៖ សម្ដេចក្រឡាហោម បានឱ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយគិតចាប់ពីថ្ងៃទី ១៨ ខែសីហា ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ក្រសួងមហាផ្ទៃបានទទួលបណ្ដឹងសរុបចំនួន២៨៩ករណីពីសាមីជន សាច់ញាតិ ស្ថានទូត និងអង្គការអន្តរជាតិមួយចំនួន។ ថ្លែងក្នុងកិច្ចប្រជុំណែនាំការប្រឆាំងអំពើជួញដូរមនុស្ស នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ នៅទីស្ដីការក្រសួងមហាផ្ទៃ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឱ្យដឹងថាបណ្ដឹងដែលក្រសួងទទួលបានមាន ខេត្តព្រះសីហនុមាន២១២ករណី, ពោធិ៍សាត់មាន៤ករណី, ស្វាយរៀងមាន១៨ករណី, ខេត្តកោះកុងមាន៥ករណី, ប៉ៃលិនមាន១ ករណី, ឧត្តរមានជ័យមាន ១៤ករណី, កណ្ដាលមាន១៨ ករណី, សៀមរាបមាន១ ករណី, រាជធានីភ្នំពេញ១៤ ករណី និងខេត្តបន្ទាយមាន ជ័យមាន២ករណី ។ សម្ដេចបន្ថែមថា ពាក្យបណ្ដឹងទាំង នេះ ដំបូងឡើយយើងក៏មិនជឿទុកចិត្តទាំងស្រុងនោះដែរ ប៉ុន្តែឆ្លងកាត់ការអនុវត្តជាក់ ស្ដែងបន្តបន្ទាប់គឺប្រមាណ ៩៥ភាគរយជាការពិត។

សម្ដេចក្រឡាហោមបានបន្តថា ក្រុមប្រតិបត្តិការ ក៏បានស្រាវជ្រាវ និងស៊ើបអង្កេតបានករណីមួយចំនួនដែរ ដោយគិតចាប់ពីថ្ងៃទី១០ ខែសីហា ដល់ថ្ងៃទី១០ ខែកញ្ញា បានស្រាវជ្រាវនិងស៊ើបអង្កេតបានចំនួន៨៥ករណី រកឃើញមនុស្ស១៧៦នាក់ មាន៨ សញ្ជាតិ ក្នុងនោះខេត្តព្រះសីហនុច្រើនជាងគេ និងកត់សម្គាល់ថា ភាគច្រើននៃជនរងគ្រោះ គឺធ្វើការនៅ កន្លែងអាជីវកម្មល្បែងភ្នាល់អនឡាញខុសច្បាប់។ ដើម្បីជានាឱ្យកិច្ចប្រតិបត្តិការនៃការប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ សម្ដេចក្រឡាហោម ស ខេង បានណែនាំឱ្យប្រកាន់ជំហរឯកភាពគ្នាថា«ការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ គឺត្រូវប្រកាន់គោលការណ៍នីតិរដ្ឋ មិនមែនដោយផ្អែកលើល្បែង ស៊ីសងខុសច្បាប់នោះទេ»។

សម្ដេចបន្ថែមថា ទោះបីមាន ការប្រឈមខ្លះក៏ដោយ ប៉ុន្តែគ្រប់គ្នាត្រូវយល់ឱ្យបានត្រឹម ត្រូវថា អំពើជួញដូរមនុស្ស និងល្បែងអនឡាញខុសច្បាប់នេះ ជាអំពើល្មើសច្បាប់ បម្រើផលប្រយោជន៍តែបុគ្គល ឬក្រុមមនុស្សមួយចំនួនតូចប៉ុណ្ណោះ ពុំមែនបម្រើផលប្រ យោជន៍សាធារណៈ ឬផលប្រយោជន៍ប្រជាជនទូទៅឡើយ។ សម្ដេចបានចាត់ទុកបញ្ហាប្រឈមនេះថា ជាឱកាសឱ្យមន្ត្រីបញ្ចេញស្នាដៃ បង្ហាញឆន្ទៈ និងការប្ដេជ្ញាចិត្តក្នុងការបំពេញភារកិច្ចជូនរាជរដ្ឋាភិ បាល និងប្រជាពលរដ្ឋ ដ្បិតប្រសិនបើមានការរារែក មិនច្បាស់លាស់ នឹងមានន័យថាមន្ត្រីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្មានការប្ដេជ្ញាចិត្ត និងមិនអាចបញ្ចេញ ស្នាដៃទទួលខុសត្រូវនោះទេ៕

## សម្ដេចក្រឡាហោម ដាក់បទបញ្ជាឲ្យបង្ក្រាបអំពើជួញដូរមនុស្ស ល្បែងស៊ីសង ល្បែងអនឡាញខុសច្បាប់

https://cen.com.kh/archives/534479.html Posted ByPen Srey NeatSeptember 20, 2022

ភ្នំពេញ ៖ នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២នេះ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំណែនាំកិច្ចការប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ។ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ក្នុងនោះ គិតចាប់ពីថ្ងៃទី១៨ ខែសីហា ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ក្រសួងបានទទួលបណ្ដឹងសរុបចំនួន២៨៩ករណី ពីសាម៉ីជន សាច់ញាតិ ស្ថានទូត និងអង្គការអន្តរជាតិមួយចំនួន។ សម្ដេច ឱ្យដឹងថា ខេត្តព្រះសីហនុមាន២១២ករណី, ពោធិ៍សាត់មាន៤ករណី, ស្វាយរៀងមាន១៨ករណី, ខេត្តកោះកុងមាន៥ករណី, ប៉ៃលិនមាន១ករណី, ឧត្តរមានជ័យមាន១៤ករណី, កណ្ដាលមាន១៨ករណី, សៀមរាបមាន១ករណី, រាជធានីភ្នំពេញ១៤ករណី និងខេត្តបន្ទាយមានជ័យមាន២ករណី។ សម្ដេច បន្តថា«ពាក្យបណ្ដឹងទាំងឡាយនេះ ដំបូងឡើយយើងក៏មិនជឿទុកចិត្តទាំងស្រុងនោះដែរ ប៉ុន្តែឆ្លងកាត់ការអនុវត្តជាក់ស្ដែងបន្តបន្ទាប់គឺប្រមាណ៩៥ភាគរយជាការពិត»។

សម្ដេចក្រឡាហោម បានបន្តថាក្រុមប្រតិបត្តិការ ក៏បានស្រាវជ្រាវ និងស៊ើបអង្កេតបានករណីមួយចំនួនដែរ ដោយគិតចាប់ពីថ្ងៃទី១០ ខែសីហា ដល់ថ្ងៃទី១០ ខែកញ្ញា បានស្រាវជ្រាវ និងស៊ើបអង្កេតបានចំនួន៨៥ករណី រកឃើញមនុស្ស១៧៦នាក់ មាន៨សញ្ជាតិ ក្នុងនោះខេត្តព្រះសហនុច្រើនជាងគេ និងកត់សម្គាល់ថាភាគច្រើននៃជនរងគ្រោះគឺធ្វើការនៅកន្លែងអាជីវកម្មល្បែងភ្នាល់អនឡាញខុសច្បាប់។ ដើម្បីជានាឱ្យកិច្ចប្រតិបត្តិការនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួយដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ សម្ដេចក្រឡាហោម ស ខេង បានណែនាំឱ្យប្រកាន់ជំហរឯកភាពគ្នាថា«ការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ គឺដោយត្រូវប្រកាន់គោលការណ៍នីតិរដ្ឋ មិនមែនដោយផ្អែកលើល្បែងស៊ីសងខុសច្បាប់នោះទេ»។ សម្ដេច បន្ថែមថាទោះបីមានការប្រឈមខ្លះក៏ដោយ ប៉ុន្តែគ្រប់គ្នាត្រូវយល់ឱ្យបានត្រឹមត្រូវថាអំពើជួញដូរមនុស្ស និងល្បែងអនឡាញខុសច្បាប់នេះជាអំពើល្មើសច្បាប់ បម្រើផល

ប្រយោជន៍តែបុគ្គល ឬក្រុមមនុស្សមួយចំនួនតូចប៉ុណ្ណោះ ពុំមែនបម្រើផលប្រយោជន៍សាធារណៈ ឬផលបរយោជន៍ប្រជាជនទូទៅឡើយ។

សម្ដេច បានចាត់ទុកបញ្ហាប្រឈមនេះថាជាឱកាសឱ្យមន្ត្រីបញ្ចេញស្នាដៃ បង្ហាញឆន្ទៈ និងការប្ដេជ្ញាចិត្តក្នុងការបំពេញភារកិច្ចជូនរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋដែរ ដ្បិតប្រសិនបើមានការរារែក មិនច្បាស់លាស់ នឹងមានន័យថាមន្ត្រីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្មានការប្ដេជ្ញាចិត្ត និងមិនអាចបញ្ចេញស្នាដៃទទួលខុសត្រូវនោះទេ។ បើតាមសម្ដេច កិច្ចប្រតិបត្តិការនេះជាវិញ្ញាសារសំខាន់សម្រាប់វាស់វែងឧត្តមគិតិ ឆន្ទៈ សមត្ថភាពរបស់រដ្ឋបាលរាជធានីខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធ ពិសេសអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។ ពាក់ព័ន្ធនឹងល្បែងស៊ីសងខុសច្បាប់នេះដែរ សម្ដេចបានមានប្រសាសន៍ថា ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ គឺជាមេរោគហារីកសង្គមយ៉ាងកាចសាហាវបំផុត។ តាមរយៈបទល្មើសនេះ បទល្មើសផ្សេងៗនឹងកើតមានឡើងតាមនោះដែរ មានជាអាទិ៍ បទល្មើសជួញដូរមនុស្សគ្រប់ទម្រង់ បទល្មើសគ្រឿងញៀន ភេរវកម្ម លួចឆក់ប្លន់ បទល្មើសជម្រិតទារប្រាក់ បទល្មើសធ្វើទារុណកម្ម កាប់សម្លាប់ សងសឹក ប្រើប្រាស់អាវុធខុសច្បាប់ បទល្មើសអន្តោប្រវេសន៍ខុសច្បាប់ បទល្មើសសម្អាតប្រាក់ និងក៏ប៉ះពាល់ដល់ការកសាងយុត្តិធម៌សង្គម។

សម្ដេច បន្តសង្កត់ធ្ងន់ទៀតថា«ការបណ្ដែតបណ្ដោយឱ្យមានល្បែងស៊ីសងខុសច្បាប់អាចជំនួសឱ្យការវិនិយោគត្រឹមត្រូវតាមច្បាប់នោះបានទេ។ អាខុសច្បាប់ហ្នឹងមានពន្ធ មានចំណូលស្អីចូលរដ្ឋដូចគេវិនិយោគត្រឹមត្រូវ? វាថែមទាំងរារាំងការវិនិយោគត្រឹមត្រូវដែលគេមានទុនវិនិយោគច្រើនថែមទៀតផង។ ព្រោះធម្មតាមុននឹងគេយកប្រាក់មកវិនិយោគ គេមើលទាំងអស់។ ការមកច្រើននៃអ្នកមិនត្រឹមត្រូវនេះ វាក៏មិនអាចមកជំនួសអ្នកជំនាញល្អៗ និងទេសចរណ៍នោះបានដែរ ប៉ុន្តែវាថែមទាំងរារាំងអ្នកជំនាញ និងទេសចរណ៍ថែមទៀតផង»។ សម្ដេច បានទាញការចាប់អារម្មណ៍ថា រាជរដ្ឋាភិបាលបានចំណាយថវិកាប្រមាណជាង២០០លានដុល្លារ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងព្រះសីហនុ ហើយការវិនិយោគផ្លូវល្បឿនលឿនប្រមាណ២ពាន់លានដុល្លារ និងការកែលម្អផ្លូវជាតិលេខ៤នោះ មិនមែនដើម្បីបម្រើឱ្យឋានសួគ៌នៃល្បែងខុសច្បាប់នោះទេ។ គឺក្នុងបំណងទាក់ទាញការវិនិយោគត្រឹមត្រូវ អ្នកទេសចរណ៍ត្រឹមត្រូវដើម្បីបានចំណូលកសាងប្រទេសជាតិទាំងមូល គឺមិនមែនតែខេត្តព្រះសីហនុនោះទេ។

ម្ដេចបានណែនាំឱ្យយកចិត្តទុកដាក់សម្រេចគោលដៅអាទិភាព៤ រួមមានទី១. គឺសង្គ្រោះជនរងគ្រោះឱ្យបានទាន់ពេលវេលា, ទី២. ខិតខំស្រាវជ្រាវមេខ្លោងនិងអ្នកពាក់ព័ន្ធមកផ្ដន្ទាទោសឱ្យបានម៉ឺងម៉ាត់ និងដោយគ្មានការលើកលែង, ទី៣.ត្រួតពិនិត្យប្រមូលភស្តុតាងដើម្បីបិទទីតាំងប្រព្រឹត្តបទល្មើស និងទីតាំងខុសច្បាប់ និងទី៤. គឺត្រូវពន្លាតការស្រាវជ្រាវបន្ថែមទៀត ដើម្បីរកបទល្មើសសម្អាតប្រាក់ និងបទល្មើសផ្សេងៗទៀត។ សម្ដេច ក៏បានផ្ដល់ការណែនាំអំពីការសម្រេចបែងចែកការបង្ក្រាបល្បែងស៊ីសងខុសច្បាប់ នៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ឱ្យរដ្ឋបាលរាជធានី ខេត្ត ជាអ្នកទទួលខុសត្រូវ ដោយសារបទល្មើសនេះមិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សមនុស្ស។ ចំណែកក្រុមការងារដឹកនាំដោយឯកឧត្តម សន្តិបណ្ឌិត សុខ ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ជាអ្នកទទួលខុសត្រូវបង្ក្រាបបទល្មើសល្បែងអនឡាញខុសច្បាប់៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## ប្រទេសវៀតណាម ធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋដែលរត់គេចខ្លួនចេញពីកាស៊ីណូនៅកម្ពុជា

https://www.khmertimeskh.com/501154179//?p=1154179 Khmer Times September 20, 2022

ក្រសួងការបរទេសបាននិយាយថា យ៉ាងហោចណាស់មានជនជាតិវៀតណាមចំនួន៦៧នាក់ បានរត់គេចខ្លួនចេញពីទីតាំងអាជីវកម្មក្នុងក្រុងបាវិតប្រទេសកម្ពុជាកាលពីថ្ងៃសៅរ៍ដោយព្យាយាមត្រឡប់ទៅប្រទេសវៀតណាមវិញ។ ពួកគេតម្រង់ទៅកាន់ច្រកទ្វារព្រំដែនបាវិត ដោយសំដៅទៅកាន់ច្រកព្រំដែន Mộc Bài ក្នុងខេត្ត Tây Ninh ប្រទេសវៀតណាម។ កន្លែងអាជីវកម្មដែលពលរដ្ឋវៀតណាមរត់គេចនោះគឺនៅភូមិបាវិតកណ្តាល ក្នុងក្រុងបាវិត ខេត្តស្វាយរៀង។ ថ្នាក់ដឹកនាំខេត្ត Tây Ninh បាននិយាយថា ទីតាំងអាជីវកម្មនោះគឺជាកាស៊ីណូ។ ក្រសួងការបរទេសវៀតណាម បាននិយាយថា ខណៈពេលកំពុងរត់គេចខ្លួន ៤នាក់ត្រូវបានចាប់ខ្លួន ដោយក្រុមកាស៊ីណូ។

វៀតណាមបានទាក់ទងអាជ្ញាធរកម្ពុជាដើម្បីទទួលបានព័ត៌មានអំពីករណីនេះ និងផ្ទៀងផ្ទាត់អត្តសញ្ញាណប្រជាពលរដ្ឋ និងអនុវត្តនីតិវិធីធ្វើមាតុភូមិនិវត្តន៍។ វៀតណាមក៏បានស្នើដល់កម្ពុជាជួយសង្គ្រោះអ្នកដែលនៅសេសសល់។ គិតត្រឹមរសៀលថ្ងៃសៅរ៍ នគរបាលកម្ពុជាបានទាមទារឲ្យកន្លែងនោះប្រគល់ពលរដ្ឋវៀតណាម ១១នាក់បន្ថែមទៀតមកវិញ ដែលធ្វើឲ្យចំនួនអ្នកពាក់ព័ន្ធក្នុងករណីនេះកើនដល់ ៦៧នាក់។ ពួកគេទាំងនោះត្រូវបានការពារដោយនគរបាលកម្ពុជា។ ស្ថានទូតវៀតណាម និងឆ្មាំព្រំដែនកំពុងសម្របសម្រួលជាមួយនាយកដ្ឋានកុងស៊ុលក្រសួងការបរទេស និងអាជ្ញាធរកម្ពុជា ដើម្បីនាំពលរដ្ឋទៅផ្ទះវិញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ក្រសួងការបរទេសវៀតណាមក៏បានផ្តាំផ្ញើដល់ស្ថានទូតវៀតណាមប្រចាំកម្ពុជា ជួយមើលថែប្រជាពលរដ្ឋអោយបានត្រឹមត្រូវខណៈដែលពួកគេរង់ចាំត្រឡប់ទៅប្រទេសកំណើតវិញ។

ភ្នាក់ងារវៀតណាមនឹងបន្តសម្របសម្រួលជាមួយអាជ្ញាធរកម្ពុជា ដើម្បីពិនិត្យមើលថាតើនៅមានពលរដ្ឋវៀតណាមនៅកន្លែងអាជីវកម្មនោះដែរឬអត់ និងស្នើសុំការស៊ើបអង្កេតលើករណីនេះ និងការពារសិទ្ធិស្របច្បាប់របស់ពួកគេ។ ប្រជាពលរដ្ឋដែលត្រូវការជំនួយអាចទាក់ទងស្ថានទូតវៀតណាមប្រចាំកម្ពុជាតាមទូរស័ព្ទលេខ៖ +855-23726274 ស្ថានអគ្គកុងស៊ុលខេត្តព្រះសីហនុ ៖ +855-34934039 ឬខ្សែទូរស័ព្ទបន្ទាន់៖ +84-981 84 84 84។

ប្រធានក្រុមប្រឹក្សាខេត្ត Tây Ninh លោក Nguyễn Thanh Ngọc បានប្រាប់កាសែត Tuổi Trẻ ថា ដំបូងឡើយមនុស្សទាំងនោះមានជម្លោះជាមួយម្ចាស់អាជីវកម្ម ទើបពួកគេរត់គេចខ្លួន៕ *VNS*

## អ្នកនាំពាក្យក្រសួងមហាផ្ទៃ៖ ម្សិលមិញ សមត្ថកិច្ចកម្ពុជាទទួលបានបណ្តឹង ៥១ទៀត ដែលស្នើឱ្យអន្តរាគមន៍រកជនរងគ្រោះ

http://freshnewsasia.com/index.php/en/localnews/257905-2022-09-20-04-28-02.html 2022-09-20 11:28am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង៣៖០០នាទីថ្ងៃទី១៨ ដល់វេលាម៉ោង៣៖០០ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជា បានទទួលសំណើ៥១ករណី ដើម្បីស្វែងរកជនបរទេស ១២៦នាក់។ នេះបើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង៥១ករណីនេះ រួមមាន៖ ស្នើឱ្យស្វែងរកជនជាតិចិនចំនួន ៧៤នាក់, តៃវ៉ាន់ ១នាក់, វៀតណាម ៤៩នាក់, ម៉ាឡេស៊ី ៣នាក់, មីយ៉ាន់ម៉ា ១នាក់, បង់ក្លាដេស ១នាក់ និងខ្មែរ ១នាក់។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើស

គ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## សមត្ថកិច្ចបិទទីតាំង ១ នៅក្រុងព្រះសីហនុ ក្រោយរកឃើញជនបរទេសខុសច្បាប់ និងគ្មានបណ្ណការងារ ៤០៣ នាក់

https://www.postkhmer.com/national/2022-09-20-0929-241254.html វ៉ន ដារ៉ា and ហ៊ីន ព្រៀងា | Publication date 20 September 2022 | 09:29 ICT

**ព្រះសីហនុៈ** សមត្ថកិច្ចបានបិទទីតាំងឈ្មោះ ស៊ីង សានទីង ដែលមាន ៣ អគារ ស្ថិតនៅភូមិ ៣ សង្កាត់លេខ ៣ បន្ទាប់ពីបានចុះប្រតិបត្តិការត្រួតពិនិត្យរដ្ឋបាលទីតាំងនេះចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៧ ខែកញ្ញា ដោយបានឃាត់ខ្លួនជនបរទេសខុសច្បាប់អន្តោប្រវេសន៍ និងជនមកបម្រើការដោយគ្មានបណ្ណការងាររួមទាំងពាក់ព័ន្ធនឹងបទល្មើសមួយចំនួនសរុបចំនួន ៤០៣ នាក់ (ស្រី ៣១ នាក់)។ តាមសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រះសីហនុស្តីពីលទ្ធផលប្រតិបត្តិការចុះត្រួតពិនិត្យរដ្ឋបាល ទីតាំង ស៊ីង សានទីង កាលពីថ្ងៃទី ១៨ កញ្ញា បានឱ្យដឹងថា ទីតាំងនេះមាន ៣ អគារ (អគារ A មាន ៣ ជាន់, អគារ B មាន ២ ជាន់ និងអគារ C មាន ៣ ជាន់) មានបន្ទប់សរុប ៣៣២ បន្ទប់ និងមានជនបរទេសស្នាក់នៅ និងធ្វើការងារសរុប ៤៩៥ នាក់ (ស្រី ៥១ នាក់) មាន ៤ សញ្ជាតិគឺចិន ចិនតៃវ៉ាន់ ម៉ាឡេស៊ី និងវៀតណាម។ សេចក្តីប្រកាសបន្តថា «ក្នុងប្រតិបត្តិការរយៈពេល ៥ ថ្ងៃនេះ កម្លាំងសមត្ថកិច្ចចម្រុះបានរកឃើញជនបរទេសខុសច្បាប់អន្តោប្រវេសន៍ចំនួន ១៤១ នាក់ ស្រី ៦ នាក់ មាន ២ សញ្ជាតិក្នុងនោះមានជនជាតិចិន ១៣០ នាក់ (ស្រី ៣ នាក់ និងជនជាតិវៀតណាម ១១ នាក់ស្រី ៣ នាក់)។

បច្ចុប្បន្នសមត្ថកិច្ចបានបញ្ជូនជនបរទេសទាំងនេះ ទៅនាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីបណ្តេញចេញពីកម្ពុជា»។ ក្នុងនោះផងដែរ មានជនបរទេសចំនួន ២៦២ នាក់ (ស្រី ២៥ នាក់) ត្រូវបានពិនិត្យឃើញថា បានបម្រើការងារដោយគ្មានបណ្ណការងារ។ ពួកគេត្រូវបានផាកពិន័យដោយនាយកដ្ឋានអន្តោប្រវេសន៍ រួចទើបអនុញ្ញាតឱ្យស្នើសុំបណ្ណការងារពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ សមត្ថកិច្ចបានប្រមូលអាករចេញពីការផាកពិន័យ និងការផ្តល់បណ្ណការងារសរុបបានចំនួន ១៣១ ០០០ ០០០ រៀល និង ៧៨ ៨៤០ ដុល្លារ។ បន្ថែមពីនោះ មន្ទីរការងារខេត្តក៏បានធ្វើការផាកពិន័យចំពោះសហគ្រាសលើ ៣ ចំណុចដូចជាគ្មានសេចក្តីប្រកាសស្តីពីបុគ្គលិកគ្មានលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស និងប្រើប្រាស់ជនបរទេស គ្មានបណ្ណការងារដែលសរុបជាទឹកប្រាក់បានចំនួន ៦ ៧២០ ០០០ រៀល។ សេចក្តីប្រកាសព័ត៌មានបន្តថា៖ «សមត្ថកិច្ចជំនាញបានរកឃើញ និងកំណត់បានបទល្មើសចំនួន ៦ បទល្មើសផ្សេងគ្នាក្នុងប្រតិបត្តិការនេះ ដូចជាបទល្មើសល្បែងស៊ីសងខុសច្បាប់ បទល្មើសបង្ខាំង និងធ្វើទារុណកម្មមនុស្សខុសច្បាប់ បទល្មើសកាន់កាប់ និងរក្សាទុកអាវុធខុសច្បាប់ បទល្មើសសញ្ញារកម្ម និងជួញដូរមនុស្ស ព្រមទាំងបើកការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ សំអាងតាមបទល្មើសល្បែងស៊ីសងខុសច្បាប់ និងបទល្មើសសញ្ញារកម្ម និងជួញដូរមនុស្ស។

បើតាមរដ្ឋបាលខេត្តព្រះសីហនុក្នុងប្រតិបត្តិការនេះជនបរទេសចំនួន ២៧ នាក់ត្រូវបាននាំខ្លួន និងបញ្ជូនទៅសាកសួរនៅស្នងការដ្ឋាននគរបាលខេត្ត (ជនសង្ស័យ ១២ នាក់ ជនរងគ្រោះ ៥ នាក់ និងនារីបម្រើសេវាផ្លូវភេទ ១០ នាក់) និងបានដកហូតនូវវត្ថុតាងមួយចំនួនដូចជា អាវុធខ្លី ចំនួន ៤ ដើម ទូរស័ព្ទដៃសរុប ចំនួន ៨ ៧៧៦ គ្រឿង កុំព្យូទ័រលើតុ ៨០៤ គ្រឿង កុំព្យូទ័រយួរដៃ ១៦ គ្រឿង លិខិតឆ្លងដែន ៣៦ ក្បាល ឧបករណ៍ផ្ទុកទិន្នន័យចំនួន ១២ គ្រឿង ខ្នោះដៃ ៤ គូ ដំបងឆក់ ៨ ដើម ពិលឆក់ ២ ដើម រួមទាំងសម្ភារ ឯកសារ និងប្រាក់មួយចំនួន។

ដោយទទួលបានគោលការណ៍ពីឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង និងជំនាញពាក់ព័ន្ធ គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ សម្រេចដាក់ចេញនូវវិធានការមួយចំនួនក្នុងករណីបង្ក្រាបបទល្មើសនេះ ដោយឱ្យធ្វើកិច្ចសន្យាអប់រំដល់ជនបរទេសដែលស្របច្បាប់ និងជនបរទេសដែលបានផាកពិន័យរួចឱ្យចាកចេញពីទីតាំងទៅរកកន្លែងថ្មីតាមការស្ម័គ្រចិត្ត។ បិទអាជីវកម្មទាំងអស់ដែលស្ថិតក្នុងបរិវេណទីតាំងឈ្មោះ ស៊ឹងសានទីង ដើម្បីបន្តស៊ើបអង្កេតរហូតដល់កិច្ចស៊ើបអង្កេតត្រូវបានបញ្ចប់ទាំងស្រុង។ គណៈបញ្ជាឯកភាពខេត្តបានដាក់ចេញវិធានការឱ្យបន្តការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ស្របតាមសំអាង នៃបទល្មើសល្បែងស៊ីសងខុសច្បាប់លើជនសង្ស័យ ៤ នាក់ និងក្រុមហ៊ុនចំនួន ១ និង បន្តការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ស្របតាមសំអាងនៃបទល្មើសជួញដូរមនុស្ស និងបទល្មើស សញ្ជារកម្មលើជនសង្ស័យចំនួន ២ នាក់។

បន្តការស៊ើបអង្កេតលើករណីរក្សាទុកអាវុធខុសច្បាប់ និងបទល្មើសពាក់ព័ន្ធ និងបន្តការស្រាវជ្រាវ និងស្វែងរកចាប់ខ្លួនជនសង្ស័យចំនួន ១ នាក់ ដែលជាមេខ្លោងក្នុងសំណុំរឿងខាងលើ។ «រដ្ឋបាលខេត្តព្រះសីហនុនឹងបន្តធ្វើការត្រួតពិនិត្យរដ្ឋបាល នៅតាមបណ្តាទីតាំងអាជីវកម្មដែលសង្ស័យមិនមានច្បាប់អនុញ្ញាត ព្រមទាំងចាត់វិធានការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ ចំពោះជនបរទេសដែលបានត្រួតពិនិត្យ និងមានកិច្ចសន្យា អប់រំរួចហើយនៅតែបន្តធ្វើដោយខុសច្បាប់ និងសូមអំពាវនាវដល់អាជីវករទាំងអស់ ដែលកំពុងសំងំលួចលាក់ធ្វើអាជីវកម្មដោយគ្មានច្បាប់អនុញ្ញាតបញ្ឈប់ជាបន្ទាន់នូវសកម្មភាពទាំងឡាយណាដែលច្បាប់ហាមឃាត់»។

លោក អ៊ំ សំអាត នាយករងអង្គការលីកាដូបានសម្តែងការព្រួយបារម្ភចំពោះបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់នៅកម្ពុជានាពេលបច្ចុប្បន្ននេះដែលកើតឡើងតាមរូបភាព ជួញដូរមនុស្ស ជាពិសេសតាមប្រព័ន្ធអនឡាញធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ជាតិ លំហូរអ្នកវិនិយោគ មុខមាត់ប្រទេសជាតិ និងសន្តិសុខសុវត្ថិភាពរបស់ប្រជាពលរដ្ឋ។ «យើងមានការព្រួយបារម្ភខ្លាំងដែរ ទាក់ទងនឹងការជួញដូរគ្រប់ទម្រង់រូបភាព ជាពិសេសតាមប្រព័ន្ធអនឡាញ។ កន្លងមកយើងឃើញហើយតាមព័ត៌មានជាតិ និងស្ថាប័នអន្តរជាតិជាច្រើនបានចុះផ្សាយអំពីការជួញដូរ និងការរំលោភបំពាន ការបង្ខាំងមនុស្សនៅតាមបណ្តាបនល្បែងមួយចំនួននៅខេត្តព្រះសីហនុ និងបណ្តាខេត្តនៅជាប់ព្រំដែន»។

លោក ស ខេង ឧបនាយករដ្ឋមន្ត្រីបានថ្លែងថា រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ក្នុងនោះ គិតចាប់ពីថ្ងៃទី ១៨ ខែសីហា ដល់ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០២២ ក្រសួងបានទទួលបណ្តឹងសរុបចំនួន ២៨៩ ករណីពីសាមីជន សាច់ញាតិស្ថានទូត និងអង្គការអន្តរជាតិមួយចំនួន។ លោកថ្លែងថា៖ «ពាក្យបណ្តឹងទាំងឡាយនេះ ដំបូងឡើយយើងក៏មិនជឿទុកចិត្តទាំងស្រុងនោះដែរ ប៉ុន្តែឆ្លងកាត់ការអនុវត្តជាក់ស្តែងបន្តបន្ទាប់គឺប្រមាណ ៩៥ ភាគរយជាការពិត»។ លោកបានបន្តទៀតថា ក្រុមប្រតិបត្តិការក៏បានស្រាវជ្រាវ និងស៊ើបអង្កេតបានករណីមួយចំនួនដែរ ដោយគិតចាប់ពីថ្ងៃទី ១០ ខែសីហា ដល់ថ្ងៃទី ១០ ខែកញ្ញា បានស្រាវជ្រាវ និងស៊ើបអង្កេតបាន ៨៥ ករណី រកឃើញមនុស្ស ១៧៦ នាក់មាន ៨ សញ្ជាតិ ក្នុងនោះខេត្តព្រះសីហនុច្រើនជាងគេ និងកត់សម្គាល់ថា ភាគច្រើននៃជនរងគ្រោះគឺធ្វើការនៅកន្លែងអាជីវកម្មល្បែងភ្នាល់អនឡាញខុសច្បាប់។

គណៈបញ្ជាការប្រតិបត្តិការដែលដឹកនាំដោយ លោក នេត សាវឿន អគ្គស្នងការនគរបាលជាតិក៏បានរៀបចំផែនការអនុវត្តនូវផែនការប្រតិបត្តិការ ដោយរៀបចំឱ្យមានក្រុមប្រតិបត្តិការផ្ទាល់ចំនួន ៥ ក្រុម បានផ្សព្វផ្សាយផែនការនេះនៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ២០២២ ដើម្បីចាប់ផ្តើមអនុវត្តចុះជួយគាំទ្រខេត្តព្រះសីហនុ។ លើសពីនេះនៅថ្ងៃទី ៩ កញ្ញា ឆ្នាំ ២០២២ ក្រសួងយុត្តិធម៌ក៏បានចេញសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចប្រយុទ្ធ

ប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដើម្បីចូលរួមអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ជាពិសេសជួយពង្រឹងបន្ថែមចំពោះផ្នែកច្បាប់៕

## ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

### រដ្ឋាភិបាលទទួលស្គាល់ថា មានការជួញដូរ និងបង្ខាំងមនុស្សជាច្រើនករណី

https://khmer.voanews.com/a/government-acknowledges-presence-of-human-trafficking-and-confinement-cases/6755062.html 20 កញ្ញា 2022

ភ្នំពេញ៖ ក្រោយការចុះពិនិត្យ និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស ការបង្ខាំងមនុស្ស និងធ្វើទារុណកម្មលើមនុស្សខុសច្បាប់ជាដើមនោះ រដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា រឿងនេះពិតជាបានកើតឡើងមែន។ នេះបើតាមរបាយការណ៍ចុងក្រោយមួយរបស់ក្រសួងមហាផ្ទៃចេញផ្សាយកាលពីថ្ងៃចន្ទ។ របាយការណ៍ដែលត្រូវបានផ្សព្វផ្សាយតាមទំព័រហ្វេប៊ុករបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គឺលោក ស ខេងនោះ បានបង្ហាញថា ក្រសួងបានទទួលបណ្តឹងសរុបចំនួន២៨៩ករណីពីសាមីជន សាច់ញាតិ ស្ថានទូត និងអង្គការអន្តរជាតិ គិតចាប់ពីថ្ងៃទី១៨ ខែសីហា ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ដែលករណីបទល្មើសទាំងអស់នេះកើតឡើងនៅក្នុងទឹកដីកម្ពុជាជាច្រើនខេត្ត រួមមានខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង ខេត្តកោះកុង ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញ។

រដ្ឋមន្ត្រីនៃក្រសួងមហាផ្ទៃ លោកស ខេង បានបញ្ជាក់កាលពីថ្ងៃចន្ទនេះថា ក្រោយការចុះអនុវត្ត ការបង្ក្រាបជាក់ស្តែងជាបន្តបន្ទាប់តាមពាក្យបណ្តឹង ដែលអាជ្ញាធរទទួលបានចំនួន «ប្រមាណ៩៥ ភាគរយ គឺជាការពិត»។ ក្រោយកិច្ចប្រជុំណែនាំកិច្ចការប្រឆាំងអំពើជួញដូរមនុស្សកាលពីម្សិលមិញ លោក ស ខេង បានថ្លែងទៅកាន់អ្នកសារព័ត៌មានថា៖ «វិធីរបស់យើងមានតែប៉ុណ្ណឹងទេគឺថា ជាគោលការណ៍ធ្វើម៉េចសង្គ្រោះជនរងគ្រោះ បន្ទាប់មកទៀតគឺផ្តន្ទាទោសអ្នកពាក់ព័ន្ធ និងបិទអាជីវកម្មខុសច្បាប់»។ លោកបន្ថែមថា អ្នកមិនត្រឹមត្រូវ ឬខុសច្បាប់មកដល់ប្រទេសនេះច្រើនអាចនឹងរារាំងដល់វិនិយោគទុនបរទេសផ្សេងទៀតដែលត្រឹមត្រូវ។

នៅឆ្នាំ ២០២២ នេះ កម្ពុជាទទួលបានចំណាត់ថ្នាក់ទាបបំផុតក្នុងរបាយការណ៍របស់អាមេរិកស្តីពីការជួញដូរមនុស្ស ដែលរបាយការណ៍នេះចងក្រងព្រឹត្តិការណ៍ដែលបានកើតឡើងតាំងពីដើមខែមេសា ឆ្នាំ២០២១ រហូតដល់ចុងខែមីនា ឆ្នាំ២០២២។ នៅឆ្នាំ២០២២ដដែលនេះ អង្គការពិភពលោកឃ្លាំមើលការលាងលុយទុច្ចរិត (FATF) ដែលមានមូលដ្ឋាននៅទីក្រុងប៉ារីស បន្តដាក់កម្ពុជាឱ្យស្ថិតក្នុង «បញ្ជីប្រផេះ» នៃក្រុមប្រទេសដែលមានហានិភ័យនៃការលាងលុយកខ្វក់។ គណៈកម្មការអឺរ៉ុបធ្លាប់បានស្នើរំកិលចំណាត់ថ្នាក់កម្ពុជាទៅមួយកម្រិតទៀតទៅក្នុង«បញ្ជីខ្មៅ» នៃស្ថាប័ននេះ។

អ្នកនាំពាក្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលោក មាស សុខសេនសាន បានប្រាប់វីអូអេនៅថ្ងៃអង្គារនេះថា ក្រសួងមិនទាន់ឃើញប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ច និងវិនិយោគនៅកម្ពុជា ដែលផ្តើមចេញពីបញ្ហាបទល្មើសជួញដូរមនុស្ស ការបង្ខាំង និងធ្វើទារុណកម្មមនុស្សខុសច្បាប់ អស់ទាំងនេះនៅឡើយទេ ហើយក្រសួងនៅកំពុងបន្តតាមដានរបាយការណ៍ពាក់ព័ន្ធផ្សេងៗទៀតជាបន្តបន្ទាប់។ ក៏ប៉ុន្តែ លោកនិយាយយ៉ាងដូច្នេះថា៖ «ប៉ុន្តែយើងមានគណៈកម្មការនៅក្នុងការធ្វើយ៉ាងម៉េចដើម្បីបង្ក្រាប និងធ្វើយ៉ាងម៉េចដើម្បីរំដោះប្រទេសយើងហ្នឹងឱ្យចេញពីបញ្ជីប្រផេះនៅក្នុងការសម្អាតសាច់ប្រាក់»។ លោកបន្ថែមថា បើសិនជាប្រទេសមួយត្រូវបានដាក់ឱ្យស្ថិតក្នុងបញ្ជីខ្មៅនៃការលាងលុយកខ្វក់ នោះការប៉ះពាល់នឹងកើតឡើងលើចរាចរណ៍ហិរញ្ញប្បទាន និងចរាចរណ៍នៃហិរញ្ញវត្ថុអន្តរជាតិ ដែល

មានន័យថាជំនួញជួញដូរដែលប្រើប្រាស់ហិរញ្ញវត្ថុទាំងអស់នេះនឹងប្រឈមមុខនឹងហានិភ័យ។ លោកបន្ត៖ «អ៊ីចឹងដៃម្ខាង យើងខិតខំធ្វើកិច្ចការកែទម្រង់ និងរដ្ឋបាលដើម្បីធ្វើឱ្យអ្នកវិនិយោគពេញចិត្តពេញថ្លើមតាមរយៈគោលនយោបាយសារពើពន្ធ និងបង្កលក្ខណៈប្រកួតប្រជែង។ ចំណែកម្ខាងទៀត យើងខិតខំធ្វើជាមួយដែនសមត្ថកិច្ចក្រសួងដទៃទៀត ចាត់ចែងការបង្ក្រាបអីហ្នឹង វានឹងចូលរួមចំណែកកែលម្អក្នុងស្ថានភាពដែលមានការលំបាក»។

«វាច្បាស់ណាស់ថា រដ្ឋាភិបាលកម្ពុជាកំពុងឆ្លើយតបទៅនឹងសម្ពាធយ៉ាងច្រើនដែលពួកគេប្រឈមមុខពីរដ្ឋាភិបាលនៃប្រទេសផ្សេងៗទៀត ដែលរដ្ឋាភិបាលទាំងនោះព្រួយបារម្ភអំពីការជួញដូរពលរដ្ឋរបស់ពួកគេ»។ នេះជាការលើកឡើងរបស់នាយករងនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីលោក Phil Robertson ដែលបានប្រាប់វីអូអេតាមសារអេឡិចត្រូនិកអ៊ីមែល។ លោកថា ហេតុផលតែមួយគត់ដែលគេចាប់ផ្តើមឃើញមានសកម្មភាពបង្ក្រាបមួយចំនួននោះគឺមកពីផលប៉ះពាល់ដល់មុខមាត់កម្ពុជានៅលើឆាកអន្តរជាតិ ដែលបង្កដោយបទល្មើសឆបោកជួញដូរមនុស្សដ៏រីករាលដាលអស់ទាំងនេះមានទំហំធំធេង ធ្ងន់លើសពីផលប្រយោជន៍ដែលបានមកពីអំពើពុករលួយដែលមេដឹកនាំសំខាន់ៗក្នុងជួររដ្ឋាភិបាល យោធា និងប៉ូលិសមួយចំនួនកំពុងទទួលបានពីក្រុមប្រព្រឹត្តបទល្មើសទាំងនោះ។ ដូច្នេះលោកថា ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋាភិបាលកម្ពុជា ដែលជាប់ពាក់ព័ន្ធក្នុងការជួញដូរមនុស្ស និងការឆបោកតាមប្រព័ន្ធទូរគមនាគមន៍គួរតែប្រឈមមុខនឹងការដាក់ទណ្ឌកម្មអន្តរជាតិ ដែលរួមមានការហាមប្រាមការធ្វើដំណើរ និងការរឹបអូសទ្រព្យសម្បត្តិរបស់ពួកគេ គ្រប់ទីកន្លែងដែលពួកគេត្រូវបានរកឃើញ។ លោកបន្ថែមថា៖ «ប្រសិនបើមិនមានប្រព័ន្ធផ្សព្វផ្សាយផ្សេងៗលាតត្រដាងអំពីទុក្ខវេទនាកើតឡើងដោយសារការឆបោកអស់ទាំងនេះ ដែលញ៉ាំងឱ្យរដ្ឋាភិបាលប្រទេសផ្សេងៗនាំគ្នារកអន្តរាគមន៍ជួយពលរដ្ឋខ្លួននោះទេ អ្នកអាចភ្នាល់បានថា ក្រសួងមហាផ្ទៃនឹងនៅតែបន្តបដិសេធដោយថា មិនមានអ្វីខុសឆ្គងកើតឡើងនោះទេ»។

ទោះជាយ៉ាងណា អភិបាលរងខេត្តព្រះសីហនុលោក ឡុង ឌីម៉ង់ បាននិយាយថា រដ្ឋាភិបាលពុំដែលបានអះអាងបដិសេធថា ពុំមានករណីបទល្មើសទាំងនេះនៅកម្ពុជាទេ ហើយលោកថា ប្រតិបត្តិការបង្ក្រាបថ្មីៗនេះបានកំពុងតែលើកមុខមាត់កម្ពុជា។ លោកថ្លែងថា៖ «អ៊ីចឹងដូច្នេះវាអត់មានប៉ះពាល់ស្ថានភាពវិនិយោគរបស់យើងទេ។ ផ្ទុយទៅវិញ វាបានលើកឱ្យបានឃើញពីកិត្តិយស កិត្តិនាមរបស់កម្ពុជាឱ្យឃើញពីស្នាដៃ ការខិតខំប្រឹងប្រែងអំពីកងកម្លាំងប្រដាប់អាវុធ ដូចជាអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការទប់ស្កាត់បញ្ហាទាំងអស់នេះ»។ គិតមកដល់ត្រឹមព្រឹកថ្ងៃអង្គារនេះ លោកថា នៅក្រុងព្រះសីហនុ អាជ្ញាធរមានសមត្ថកិច្ចបានចុះត្រួតពិនិត្យចំនួន៤ទីតាំង ដែលរួមមាន ហ្គាឡាក់ស៊ីវើល ជីងឆាយ៥ ប៉ាវយ៉ុងតិចណូឡូជី និងស៊ីងសានទីង (ហៅ ផាំងធឹង)។ នៅក្នុងចំណោមនោះ នៅទីតាំងឈ្មោះ ស៊ីងសានទីង (ហៅ ផាំងធឹង) អាជ្ញាធរបានរកឃើញ និងកំណត់បទល្មើសចំនួន៦ប្រភេទ រួមមានបទល្មើសល្បែងស៊ីសងខុសច្បាប់ បទល្មើសបង្ខាំង និងធ្វើទារុណកម្មមនុស្សខុសច្បាប់ បទល្មើសកាន់កាប់ និងរក្សាទុកអាវុធខុសច្បាប់ បទល្មើសសញ្ញារកម្ម និងជួញដូរមនុស្ស ហើយពួកគេនឹងបន្តស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ និងបង្ហាញរបាយការណ៍ជាបន្តបន្ទាប់៕

## លោក កើត រិទ្ធ រំឭកមន្ត្រីតុលាការពង្រឹងគុណភាពការងារនៅចំពោះមុខអំពើជួញដូរមនុស្ស

https://www.postkhmer.com/national/2022-09-20-1517-241280.html អេង រាជនី | Publication date 20 September 2022 | 15:17 ICT

**ភ្នំពេញ៖** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លោក កើត រិទ្ធ ថ្មីៗនេះបានជំរុញទៅភាគីពាក់ព័ន្ធ ឱ្យពង្រឹងគុណភាពសាលាជម្រះក្តីឬតុលាការនៅចំពោះមុខរឿងហេតុមួយចំនួនដែលកំពុងតែកើតឡើងដូចជា អំពើជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទជាដើម។ ការណែនាំនេះធ្វើឡើងនៅថ្ងៃទី ១៦ ខែកញ្ញា ក្នុងកិច្ចប្រជុំស្តីពីចំណាត់ការលើសំណុំរឿងជួញដូរមនុស្ស សំណុំរឿងសម្អាតប្រាក់ និងសំណុំរឿងរំលោភសេពសន្ថវៈ ក្នុង

គោលបំណងបង្កើនប្រសិទ្ធភាព និងពន្លឿនចំណាត់ការនីតិវិធីពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌ។ ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លោក កើត រិទ្ធ បានប្រាប់ទៅកាន់ស្ថាប័នអយ្យការត្រូវផ្តល់កិច្ចសហការពេញលេញ និងគ្រប់ជ្រុងជ្រោយជាមួយមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ ក្នុងការអនុវត្តប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ។

លោកកើត រិទ្ធ ថ្លែងថា ស្ថាប័នអយ្យការត្រូវយកចិត្តទុកដាក់ផងដែរ ពន្លឿនការស្រាវជ្រាវពាក់ព័ន្ធនឹងបទល្មើសសម្អាតប្រាក់ឱ្យបានទាន់ពេលវេលា និងឱ្យមានប្រសិទ្ធភាព ហើយសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ត្រូវពន្លឿនចំណាត់ការឱ្យបានឆាប់រហ័ស។ រីឯចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ទាំងអស់ត្រូវយកចិត្តទុកដាក់ពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមទៀតលើជំនាញផ្នែកប្រយុទ្ធប្រឆាំងនឹងការសម្អាតប្រាក់ ជួញដូរមនុស្ស ជួញដូរពលកម្ម កេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ ដើម្បីជានាប្រសិទ្ធភាពការងារក្នុងការប្រយុទ្ធប្រឆាំងបទល្មើសទាំងនេះឆ្លើយតបទៅនឹងសភាការណ៍ជាក់ស្តែងនៃការវិវត្តផ្នែកសង្គម និងសេដ្ឋកិច្ច។

គួរកត់សម្គាល់ថា ការណែនាំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឱ្យពង្រឹងគុណភាពសាលាជម្រះក្តីឬតុលាការធ្វើឡើងស្របគ្នានឹងយុទ្ធនាការរបស់អាជ្ញាធរពាក់ព័ន្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បន្ទាប់ពីក្រសួងការបរទេសអាមេរិកចេញរបាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ ២០២២ ដោយដាក់កម្ពុជាក្នុងចំណាត់ថ្នាក់អាក្រក់បំផុតនៃអំពើជួញដូរមនុស្ស។

លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌បានឱ្យដឹងថា កិច្ចប្រជុំអំពីបញ្ហានេះមិនមែនទើបតែធ្វើនៅដំណាក់កាលនេះទេ ពោលគឺរដ្ឋមន្ត្រីតែងដឹកនាំកិច្ចប្រជុំរបៀបនេះជាប់ប្រចាំ។ លោកបន្ថែមថា៖ «កិច្ចប្រជុំនេះគឺដើម្បីពង្រឹងសមត្ថភាពបន្ថែម ពីព្រោះសំណុំរឿងព្រហ្មទណ្ឌ (ពាក់ព័ន្ធបញ្ហាជួញដូរមនុស្ស) មានចរិតពិសេស ដូច្នេះយើងជួបប្រជុំដើម្បីផ្លាស់ប្តូរបទពិសោធគ្នា ឈានទៅដោះស្រាយសំណុំរឿងប្រកបដោយប្រសិទ្ធភាពខ្ពស់ជាងមុន»។

លោក អំ សំអាត នាយកប្រតិបត្តិនៃអង្គការលីកាដូលើកឡើងថា តួនាទីរបស់ក្រសួងយុត្តិធម៌ដែលមានសិទ្ធិគ្រប់គ្រងលើមន្ត្រីតុលាការបានដើរតួនាទីសំខាន់ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពនៅក្នុងសង្គម ដើម្បីជានាយុត្តិធម៌ និងស្មើភាពគ្នានៅចំពោះមុខច្បាប់។ លោកថា៖ «ទាក់ទងបទល្មើសទាំងឡាយ ក្រសួងយុត្តិធម៌គឺដើរតួនាទីសំខាន់តាមរយៈប្រព័ន្ធតុលាការ ក្នុងការទប់ស្កាត់ បង្ក្រាប ជាពិសេសតុលាការផ្ទាល់ជាអ្នកអនុវត្តច្បាប់អ៊ីចឹងពាក់ព័ន្ធបទឧក្រិដ្ឋធំៗរួមទាំងការជួញដូរមនុស្ស គ្រឿងញៀនជាដើម គឺច្បាស់ណាស់ប្រព័ន្ធយុត្តិធម៌ដើរតួនាទីសំខាន់មែនទែន»។ មន្ត្រីសិទ្ធិមនុស្សរូបនេះបានធ្វើការកត់សម្គាល់ថា ក្រសួងយុត្តិធម៌ក្នុងអាណត្តិលោក កើត រិទ្ធ បានធ្វើការកែទម្រង់ក្នុងប្រព័ន្ធយុត្តិធម៌ ដូចជា យុទ្ធនាការពន្លឿនការកកស្ទះសំណុំរឿងដើម្បីឈានទៅកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ ការដាក់ចេញការដោះលែងអ្នកទោសដែលជិតផុតទោសឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយភ្ជាប់ជាមួយលក្ខខណ្ឌផ្សេងៗ។

លោក អំ សំអាត ថ្លែងថា៖ «យើងក៏ឧស្សាហ៍សង្កេតឃើញលោក កើត រិទ្ធ ធ្វើការក្រើនរំឭកទៅតុលាការឬព្រះរាជអាជ្ញា ហើយថ្មីៗនេះ រដ្ឋាភិបាលក៏ដូចជាក្រសួងយុត្តិធម៌បានបង្ហាញឆន្ទៈក្នុងការទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការបង្កើតគណៈកម្មការចំពោះកិច្ចដែលនេះក៏ជាផ្នែកមួយមានឥទ្ធិពលលើប្រព័ន្ធតុលាការដែរ ដែលត្រូវធ្វើការងារឱ្យបានត្រឹមត្រូវ និងស្មើភាពគ្នានៅចំពោះមុខច្បាប់»។

របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ ២០២២ របស់សហរដ្ឋអាមេរិក លើកឡើងថា រដ្ឋាភិបាលកម្ពុជាពុំបានគោរពតាមពេញលេញដើម្បីលុបបំបាត់នូវអំពើជួញដូរមនុស្ស និងពុំបានខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សឡើយ។ ស្ថិតក្នុងបញ្ជីខ្មៅ ឬកម្រិត ៣ កម្ពុជានឹងអាចប្រឈមការរឹតត្បិត

ជំនួយ ឬឈានទៅដល់ការផ្តាច់ជំនួយពីសហរដ្ឋអាមេរិក ពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស។ យ៉ាងណាមិញ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថា កម្ពុជានឹងមិនដកថយឡើយ ហើយខិតខំរកឱ្យឃើញចំណុចខ្សោយដើម្បីដោះស្រាយបញ្ហានេះ៕

## គ្រោះថ្នាក់ចរាចរណ៍មួយនៅខេត្តឈុនបុរី ប្រទេសថៃ បណ្តាលឱ្យ ពលករខ្មែរប្រុសស្រី១៣នាក់រងរបួសធ្ងន់ស្រាល

http://nokorwatnews.com/archives/900758?fbclid=IwAR00rvyCk80Vcqm31IW0bDjSi0SaPpgig_hrX8I3Ea9V8fP8qXLvvC6g55w 21/09/2022

ប្រទេសថៃ ៖ ពលករខ្មែរប្រុសស្រី១៣នាក់ រងរបួសធ្ងន់ស្រាល ដោយជួបហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ នៅថ្ងៃទី២០ខែកញ្ញាឆ្នាំ២០២២ នៅខេត្តឈុនបុរី ប្រទេសថៃ។ តាមសេចក្តីរាយការណ៍ពីពលករនៅប្រទេសថៃ ប្រាប់ថា មានរថយន្តទូរ១៣កៅអីមួយគ្រឿងដឹកពលករខ្មែរធ្វើដំណើរពីកន្លែងធ្វើការដោយពលករខ្មែរទាំងនោះមាន បំណងមកស្រុកកំណើត (ប្រទេសកម្ពុជាវិញ) នៅរដូវបុណ្យភ្ជុំបិណ្ឌខាងមុខតែចៃដន្យបានជួបគ្រោះថ្នាក់ចរាចរណ៍ តែម្តង។ សេចក្តីរាយការណ៍ខាងលើមិនបានបញ្ជាក់ពីករណីគ្រោះថ្នាក់ខាងលើអំពីឈ្មោះភូមិឃុំស្រុកកំណើតរបស់ អ្នករងរបួសនោះឡើយដោយគ្រាន់តែប្រាប់ថាមានពលករខ្មែរប្រុសស្រីចំនួន១៣នាក់ ជួបគ្រោះថ្នាក់ចរាចរណ៍នៅ កន្លែងកើតហេតុ ហើយពលករទាំងអស់នោះមានបំណងធ្វើដំណើរមកស្រុកកំណើតវិញនៅរដូវភ្ជុំតែប៉ុណ្ណោះ។ ក្រោយពីកើតហេតុគេឃើញមន្ត្រីជំនាញជនជាតិថៃ បាននាំពួកគាត់ទៅសង្គ្រោះនៅមន្ទីរពេទ្យក្នុងភូមិសាស្ត្រខាង លើ។បញ្ហានេះដែរអ្នកសារព័ត៌មានយើងមិនទាន់បានការបំភ្លឺពីមន្ត្រីកុងស៊ុលប្រចាំប្រទេសថៃនៅឡើយ ព្រោះគ្មាន លេខទំនាក់ទំនង ៕

## ក្នុង១ថ្ងៃនេះ សមត្ថកិច្ចកម្ពុជា ទទួលសំណើ និងសំណូមពរ ៧ទៀត ទាក់ទងនឹងការអន្តរាគមន៍ស្វែងរកជនបរទេស

http://freshnewsasia.com/index.php/en/localnews/258011-2022-09-20-15-09-39.html 2022-09-20 10:09pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង៣៖០០នាថ្ងៃទី១៩ ដល់ម៉ោង៣៖០០ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជា បានទទួលសំណើចំនួន០៧ករណី ដើម្បីស្វែងរកជនបរទេស ២៧នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង០៧ករណីនេះ រួមមាន៖ ជនជាតិចិនចំនួន៣នាក់ និងជនជាតិវៀតណាមចំនួន២នាក់, ជនជាតិឥណ្ឌា៤នាក់ និងជនជាតិឥណ្ឌូនេស៊ី១៨នាក់។ សម្រាប់ករណីនេះ សមត្ថកិច្ចកំពុងស្រាវជ្រាវកំណត់មុខសញ្ញា និងបន្តនីតិវិធី។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## ខេត្ត អាន យ៉ាង ទទួលជនចំណាកស្រុកខុសច្បាប់ចំនួន ៤៤ នាក់ពីកម្ពុជា

https://www.khmertimeskh.com/501154938//?p=1154938 September 21, 2022

កម្លាំងការពារព្រំដែន និងភ្នាក់ងារពាក់ព័ន្ធនៃខេត្ត អាន យ៉ាងនៃទំនាបទន្លេមេគង្គ កាលពីថ្ងៃទី២០ ខែកញ្ញា បានទទួលជនជាតិវៀតណាមចំនួន ៤៤នាក់ ដែលត្រូវបានកម្ពុជាប្រគល់ឲ្យ។ យោងតាមលោក Truong Quoc Hung អនុប្រធានប៉ុស្តិ៍ព្រំដែននៅច្រកព្រំដែន Tinh Bien បាននិយាយថា ស្ត្រី ៩ នាក់ និងបុរស ៣៥ នាក់បានចូលប្រទេសកម្ពុជាដោយខុសច្បាប់ដើម្បីធ្វើការនៅក្នុងកាស៊ីណូ។ ក្នុងចំណោមនោះ មានមនុស្សម្នាក់ត្រូវបាននគរបាលក្រុង Vinh Yen ខេត្ត Vinh Phuc ភាគខាងជើងចាប់ខ្លួន ហើយលោកបានបន្ថែមថា ប៉ុស្តិ៍ព្រំដែនកំពុងឃាត់ខ្លួនបុរសដែលគេតាមចាប់ខ្លួនប្រគល់ឲ្យនគរបាលខេត្ត Vinh Phuc។ ចំណែកមនុស្ស៤៣នាក់ទៀតត្រូវបានបញ្ជូនទៅកាន់ការិយាល័យអន្តោប្រវេសន៍ក្រោមមន្ទីរសន្តិសុខសាធារណៈខេត្ត ដើម្បីបំពេញនីតិវិធីពាក់ព័ន្ធ ។

កាលពីថ្ងៃទី១៨ ខែសីហា ជនជាតិវៀតណាមចំនួន ៤០នាក់ ត្រូវបានកម្លាំងការពារព្រំដែនខេត្តអានយ៉ាងឃាត់ខ្លួន បន្ទាប់ពីបានចូលមកប្រទេសវៀតណាមដោយខុសច្បាប់ពីកម្ពុជា។ ពួកគេបាននិយាយថា ពួកគេបានគៀសខ្លួនចេញពីការងារដោយបង្ខំនៅកាស៊ីណូមួយក្នុងឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ប្រទេសកម្ពុជា ហើយបានហែលឆ្លងទន្លេ Binh Ghi ដើម្បីត្រឡប់ទៅប្រទេសវៀតណាមវិញ។ ក្នុងការស៊ើបអង្កេតករណីនេះ នគរបាលខេត្តបានរកឃើញមុខសញ្ញាបណ្តាញជួញដូរមនុស្សចំនួន៤នាក់ ។ នគរបាលក៏បានចាប់ខ្លួនជនសង្ស័យពីរនាក់ពាក់ព័ន្ធនឹងករណីនេះ។ VNA

## ជនជាតិម៉ាឡេស៊ី៥អ្នកទៀតដែលរងគ្រោះដោយសារការឆបោកការងារ បានត្រឡប់មកពីកម្ពុជាវិញ

https://www.khmertimeskh.com/501155018//?p=1155018 Khmer Times September 21, 2022

ជនជាតិម៉ាឡេស៊ី៥អ្នកទៀត ដែលរងគ្រោះដោយសារការឆបោកការងារនៅកម្ពុជាបានត្រឡប់មកប្រទេសវិញហើយនៅថ្ងៃចន្ទ។ ក្រសួងការបរទេសបាននិយាយថា ជាមួយនឹងការត្រឡប់មកវិញរបស់ពួកគេ ជនរងគ្រោះនៃការឆបោកប្រាស់ការងារនៅកម្ពុជាចំនួន ១៤៨ នាក់ត្រូវបានជួយសង្គ្រោះក្នុងចំណោម ១៥៨ ករណីដែលត្រូវបានរាយការណ៍។ ក្រសួងបានបន្តថាស្ថានទូតម៉ាឡេស៊ីនៅទីក្រុងភ្នំពេញកំពុងបន្តកិច្ចប្រឹងប្រែងយ៉ាងសកម្មដើម្បីតាមរកអ្នកផ្សេងទៀត។ នៅក្នុងសេចក្តីថ្លែងការណ៍មួយ ក្រសួងក៏បាននិយាយផងដែរថា ខ្លួនកំពុងបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីជួយសង្គ្រោះប្រជាជនម៉ាឡេស៊ីដែលត្រូវបានបោកបញ្ឆោតដោយក្រុមផ្សេងទៀតនៅក្នុងប្រទេសថៃ ឡាវ និងមីយ៉ាន់ម៉ា តាមរយៈស្ថានទូតម៉ាឡេស៊ីនៅក្នុងប្រទេសទាំងនោះ។ មកទល់ពេលនេះ ជនជាតិម៉ាឡេស៊ី ១៦នាក់ត្រូវបានជួយសង្គ្រោះនៅប្រទេសថៃ ២៧នាក់នៅឡាវ និង ៩នាក់ទៀតនៅមីយ៉ាន់ម៉ា។ ជនរងគ្រោះ ១២ នាក់ផ្សេងទៀតកំពុងត្រូវបានតាមរកនៅប្រទេសថៃ ២៨ នាក់នៅឡាវ និង ៥៤ នាក់នៅមីយ៉ាន់ម៉ា។

ខ្មែរថាមស៍បានទទួលព័ត៌មានដ៏គួរអោយទុកចិត្តថា រហូតមកដល់ពេលនេះមានការបង្ក្រាបដ៏ធំណាមួយទៅលើអ្នកជ្រើសរើសពលករនៅប្រទេសម៉ាឡេស៊ីនោះទេ។ លំហូរជនជាតិម៉ាឡេស៊ីមកកម្ពុជានឹងបន្តទៅមុខទៀត ខណៈដែលមិនមានការឃ្លាំមើលជនជាតិម៉ាឡេស៊ីដែលចូលមកកម្ពុជា ដែលគេសន្មត់ថាមកធ្វើការ ប៉ុន្តែគ្មានឯកសារ ឬទិដ្ឋាការត្រឹមត្រូវដែលចេញដោយស្ថានទូតកម្ពុជានៅទីក្រុងគួឡាឡាំពួរ។ លើសពីនេះ ភាគច្រើននៃអ្នកដែលមកកម្ពុជា ឬមកតាម "ច្រកខុសច្បាប់" ឬតាមព្រំដែនគោកតាមប្រទេសថៃ ត្រូវបានទាក់ទាញដោយប្រាក់ដុល្លារអាមេរិកដោយសារអត្រាប្តូរប្រាក់ខ្ពស់ដែលពួកគេអាចទទួលបានសម្រាប់ប្តូរជារូបិយប័ណ្ណម៉ាឡេស៊ី។ មន្ត្រីការងារប្រចាំប្រទេសកម្ពុជាម្នាក់ដែលដឹងខ្លះពីរបៀបរបស់ក្រុមអ្នកបោកប្រាស់បានប្រាប់ខ្មែរថាមស៍ថា "និយាយជារួម ភាពលោភ

លន់ក៏ដើរតួយ៉ាងសំខាន់ក្នុងលំហូរចូលរបស់ពលរដ្ឋម៉ាឡេស៊ី ឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដែស និងនេប៉ាល់ ដោយសារអត្រាប្តូរប្រាក់ទាក់ទាញក្នុងពួកគេឱ្យព្រងើយកន្តើយនឹងហានិភ័យ”។ *Bernama/Khmer Times*

## កម្ពុជា ធ្វើជាម្ចាស់ផ្ទះ
## នៃកិច្ចប្រជុំថ្នាក់ រដ្ឋមន្ត្រីអាស៊ាន ទទួលបន្ទុក ឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦

https://dap-news.com/national/2022/09/21/280417/ ByPH104Posted on September 21, 2022

**ភ្នំពេញ ៖ នៅថ្ងៃពុធទី២១ ខែកញ្ញា ឆ្នាំ២០២២ សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី ក្នុងនាមជាប្រធាន ប្តូរវេន បានដឹកនាំកិច្ចប្រជុំថ្នាក់ រដ្ឋមន្ត្រីអាស៊ានទទួល បន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ (16th AMMTC and Its Related Meetings) តាមរយៈប្រព័ន្ធវីដេអូ។** កិច្ចប្រជុំនេះ ក៏មានការអញ្ជើញ ចូលរួមពី ប្រធានប្រតិភូទទួលបន្ទុក ឧក្រិដ្ឋឆ្លងដែន នៃប្រទេស សមាជិកអាស៊ាន, អគ្គលេខាធិការរងអាស៊ាន ទទួលបន្ទុកសហគមន៍សន្តិសុខ នយោបាយ និងភ្ញៀវកិត្តិយសជាតិ-អន្តរជាតិជាច្រើនរូបទៀត ។

សូមបញ្ជាក់ថា ក្រសួងមហាផ្ទៃកម្ពុជា ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ ចាប់ពីថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០២២ តាមប្រព័ន្ធវិដេអូ ។ កិច្ចប្រជុំនេះ គឺជាវេទិកាសម្រាប់ រដ្ឋមន្ត្រីមកពីបណ្ដាប្រទេស សមាជិកអាស៊ាន ផ្លាស់ប្តូរយោបល់ និងចែករំលែកបច្ចុប្បន្នភាព អំពីនិន្នាការនៃឧក្រិដ្ឋកម្មឆ្លងដែនក្នុងតំបន់ និងសកល ជាពិសេសលើប្រភេទ នៃឧក្រិដ្ឋកម្មទាំង១០ ដែលបានកំណត់ ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរបស់អាស៊ាន ដូចជា៖ ការរត់ពន្ធអាវុធ អំពើភេរវកម្ម ការសម្អាតប្រាក់ អំពើប្លន់លើផ្ទៃសមុទ្រ ការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស បទល្មើសសេដ្ឋកិច្ចអន្តរជាតិ បទល្មើស បច្ចេកវិទ្យា ការជួញដូរគ្រឿងញៀន ខុសច្បាប់ និងការជួញដូរសត្វព្រៃ និងឈើខុសច្បាប់ ។ ទន្ទឹមនេះ កិច្ចប្រជុំ ក៏នឹងពិនិត្យ ពិភាក្សាលើកម្មវិធីការងារ និងផែនការសកម្មភាព ដែលបានដាក់ចេញកន្លងមក ដើម្បីឈានទៅកំណត់ទិសដៅអនុវត្តបន្តផងដែរ ៕

## យុវជនឥណ្ឌា៦នាក់ជាប់គាំង
## ប្រទេសកម្ពុជាត្រូវបានសង្ស័យថាបានជាប់បង្ខាំងដោយក្រុមជនពាលតាមអ៊ីនធឺណិត

https://www.khmertimeskh.com/501155165//?p=1155165K hmer Times September 21, 2022

យុវជន ៦នាក់ មកពីស្រុក Karimnagar ក្រុង Telangana ប្រទេសឥណ្ឌា បានជាប់គាំងក្នុងប្រទេសកម្ពុជា ខណៈពួកគេត្រូវបានបង្ខាំងដោយក្រុមឆបោកតាមប្រព័ន្ធអ៊ីនធឺណិត។ ហេតុការណ៍នេះបានកើតឡើងនៅពេលដែលពួកគេបានផ្ញើសារជាវីដេអូនៅលើ Whatsapp ទៅកាន់ឪពុកម្តាយរបស់ពួកគេកាលពីថ្ងៃចន្ទ។ ភ្លាមៗនោះ ឪពុកម្តាយបានប្រញាប់ទៅដាក់ពាក្យបណ្តឹងនៅស្នងការនគរបាល Satyanarayana។

ឪពុកម្តាយបានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា ក្រុមហ៊ុនប្រឹក្សាឥណ្ឌូ-អារ៉ាប់មួយនៅទីក្រុង Karimnagar បានល្បួងយុវជនដែលគ្មានការងារធ្វើដោយផ្តល់ពួកគេនូវការងារជាប្រតិបត្តិករកុំព្យូទ័រនៅបរទេស។ បន្ទាប់ពីប្រមូលបាន ២ lakhក្នុងមនុស្សម្នាក់ ក្រុមហ៊ុននេះបានបញ្ជូនពួកគេមកកម្ពុជាក្នុងសប្តាហ៍ទីមួយនៃខែកញ្ញា។ បន្ទាប់ពីទៅដល់ទីនោះ ជំនួសឱ្យការបែងចែកពួកគេឱ្យធ្វើការងារកុំព្យូទ័រ ជាក់ស្តែងពួកគេត្រូវបានបង្ខំឲ្យប្រព្រឹត្តិឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ដូចជារូបិយប័ណ្ណគ្រីបតូ ការឆបោកកាតឥណទាន និងការឆបោកផ្សេងទៀត។ ឪពុកម្តាយនៅទីនេះបាននិយាយទៀតថា ក្រុមឆបោកតាមប្រព័ន្ធអ៊ីនធឺណេត ថែមទាំងបានគំរាមយុវជនទាំងនោះថា ពួកគេនឹងមិនបានលិខិតឆ្លងដែនរបស់ពួកគេវិញទេ ប្រសិនបើពួកគេបដិសេធមិនធ្វើនូវអ្វីដែលពួកគេត្រូវបានបញ្ជា ហើយនឹងត្រូវបញ្ជូនទៅពន្ធនាគារក្រោមការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត។

ក្រុមជនពាលទាំងនោះទាមទារឱ្យយុវជនម្នាក់ៗបង់ប្រាក់ចំនួន ២,៤lakh ដើម្បីបញ្ជូនពួកគេត្រឡប់ទៅប្រទេសឥណ្ឌាវិញ។ ពួកគេត្រូវបានក្រុមជនពាលធ្វើទារុណកម្មដោយវាយដំ ដូចដែលឪពុកម្ដាយបានចោទប្រកាន់។ មន្ត្រីអន្តោប្រវេសន៍ និងក្រុមការងារដែលពាក់ព័ន្ធក្នុងការបង្ក្រាបទូទាំងប្រទេសបានប្រាប់កាសែតខ្មែរថាមស៍ក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះថា ជនជាតិឥណ្ឌារហូតដល់ ៦០ នាក់ត្រូវបានជួយសង្គ្រោះពីតំបន់ផ្សេងៗនៃប្រទេសពីក្រុមឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ហើយបានបញ្ជូនពួកគេត្រឡប់ទៅផ្ទះវិញ។ គេជឿថាមានចំនួនជនជាតិឥណ្ឌារហូតដល់តួលេខបីខ្ទង់ដែលធ្វើការដោយស្ម័គ្រចិត្តឬបង្ខំដោយក្រុមទាំងនេះដែលភាគច្រើននៅក្នុងខេត្តព្រះសីហនុ៕ *Deccan Chronicle/ខ្មែរថាមស៍*

## ជនជាតិវៀតណាម ៧០នាក់ រត់ចេញពីកន្លែងខុសច្បាប់នៅកម្ពុជា

https://www.khmertimeskh.com/501155097//?p=1155097 Khmer Times September 21, 2022

ពលរដ្ឋវៀតណាមជិត ៧០នាក់ បានរត់គេចពីកន្លែងខុសច្បាប់ជាច្រើននៅកម្ពុជា ទទួលបានការជួយសង្គ្រោះពីអគ្គកុងស៊ុលវៀតណាមប្រចាំក្រុងព្រះសីហនុ។ តំណាងស្ថានកុងស៊ុលបាននិយាយថា ការរត់ចេញនេះបានកើតឡើងកាលពីយប់ថ្ងៃអាទិត្យ បន្ទាប់ពីបុគ្គលិកនៅស្ថានទូតវៀតណាមនៅភ្នំពេញបានទទួលសារពីមនុស្សម្នាក់ក្នុងក្រុម សុំការជួយ។ ក្រុមនេះកំពុងធ្វើការនៅកន្លែងមួយចំនួននៅទីតាំងដែលមានរឿងអាស្រូវក្នុងខេត្តព្រះសីហនុ ដែលមានការប្រមូលផ្តុំនៃសកម្មភាពទាំងនេះ។ រូបថតអេក្រង់នៃសាររវាងតំណាងនិងក្រុមជនជាតិវៀតណាមបង្ហាញថា ពួកគេបានឈានដល់ការជួយសង្គ្រោះ នៅម៉ោង ៦៖៥៦ ល្ងាច កាលពីថ្ងៃអាទិត្យមុន និងបានផ្តល់ទីតាំងរបស់ពួកគេ។

"ដោយវាយតម្លៃថា ស្ថានភាពមិនមានគ្រោះថ្នាក់ខ្លាំងពេក តំណាងស្ថានកុងស៊ុល ដែលចង់រក្សាភាពអនាមិក បានណែនាំក្រុមឱ្យគៀសខ្លួនដោយខ្លួនឯង។ លោកបានថ្លែងថា៖ «អាជ្ញាធរកម្ពុជាបាននិងកំពុងបង្ក្រាបយ៉ាងខ្លាំងលើគ្រឹះស្ថានដែលប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់ក្នុងក្រុងព្រះសីហនុ។ «ដោយសារក្រុមវៀតណាមមានច្រើន ហើយពួកគេទាំងអស់គ្នាស្នាក់នៅកន្លែងតែមួយ អ្នកដែលបើកកន្លែងទាំងនោះមិនហ៊ានធ្វើអ្វីទេ ព្រោះពួកគេមិនអាចប្រឈមមុខនឹងមនុស្សរាប់សិបនាក់ក្នុងពេលតែមួយ ជាពិសេសនៅពេលដែលមានជនជាតិវៀតណាមក្លាហានមួយចំនួននៅក្នុង ក្រុម។ ប្រហែលបីម៉ោងក្រោយមក ក្រុមនេះបានជូនដំណឹងទៅតំណាងថា ពួកគេជិត ៧០នាក់បានរត់គេចខ្លួនដោយជោគជ័យជាពីរក្រុម ប៉ុន្តែពួកគេមួយចំនួននៅតែជាប់នៅខាងក្នុង។ នៅវេលាម៉ោង ១០ និង១១នាទីយប់ ក្រុមនេះបាននិយាយថា ពួកគេទាំងអស់គ្នាមានសុវត្ថិភាព ហើយបានសុំជំនួយដើម្បីត្រលប់ទៅផ្ទះវិញ។

ស្ថានកុងស៊ុលបាននាំក្រុមទៅច្រកទ្វារព្រំដែនអន្តរជាតិ Moc Bai ក្នុងខេត្ត Tay Ninh ភាគខាងត្បូងវៀតណាម។ អ្នករត់គេចខ្លួនបានទៅដល់ប្រទេសវៀតណាមនៅយប់នោះ។ ពួកគេ ៥ នាក់បានខកខានរថយន្តក្រុងនៅយប់នោះ ហើយត្រូវបានបញ្ជូនទៅការិយាល័យកុងស៊ុលដើម្បីសម្រាកមួយយប់។ ពួកគេត្រូវបានគេបញ្ជូនត្រឡប់មកផ្ទះវិញនៅព្រឹកបន្ទាប់តាមច្រកព្រំដែនក្នុងខេត្តមួយទៀតរបស់វៀតណាមភាគខាងត្បូង គឺខេត្តKien Giang។ កាលពីថ្ងៃចន្ទ កម្លាំងការពារព្រំដែនខេត្តអានយ៉ាង ភាគខាងត្បូងជាប់ព្រំដែនកម្ពុជា បានទទួលពលរដ្ឋវៀតណាម ៤៤នាក់ ដែលត្រូវបានប្រគល់ជូនដោយអាជ្ញាធរកម្ពុជា។ ពួកគេភាគច្រើនជាកម្មករខុសច្បាប់នៅកាស៊ីណូក្នុងប្រទេសកម្ពុជា។ នេះជាលើកទីពហើយនៅឆ្នាំនេះដែលកម្លាំងការពារព្រំដែន ខេត្តអានយ៉ាងទទួលជនជាតិវៀតណាម ត្រឡប់ពីកាស៊ីណូកម្ពុជា។ រហូតមកដល់ពេលនេះ ជនជាតិវៀតណាមចំនួន ១១១នាក់ត្រូវបានជួយសង្គ្រោះពីកាស៊ីណូ។

យោងតាមប្រភពពីការិយាល័យអគ្គកុងស៊ុលវៀតណាមប្រចាំខេត្តព្រះសីហនុ បានឲ្យដឹងថា មានករណីជនជាតិវៀតណាមប្រមាណ ២០០ ទៅ ៣០០នាក់ ត្រូវបានអាជ្ញាធរកម្ពុជា ឃាត់ខ្លួន រង់ចាំការដោះស្រាយតាមនីតិវិធីដើម្បីត្រឡប់ទៅប្រទេសកំណើតវិញ។ មនុស្សទាំងនេះទើបតែត្រូវបានជួយសង្គ្រោះពីគ្រឹះស្ថានខុសច្បាប់។ កាលពីថ្ងៃទី១៨ ខែសីហា ជនជាតិវៀតណាម៤០នាក់បានហែលឆ្លងទន្លេ Binh Di ដើម្បីគេចចេញពីកាស៊ីណូ Phoenix ក្នុងប្រទេសកម្ពុជា ទៅកាន់ខេត្ត An Giang ប្រទេសវៀតណាម។ ម្នាក់ក្នុងចំណោមពីរនាក់ផ្សេងទៀត ដែលបានព្យាយាមរត់ចេញ គឺក្មេងប្រុសជំទង់ម្នាក់ បានលង់ទឹកទន្លេ ចំណែកម្នាក់ទៀតត្រូវបានមនុស្សកាស៊ីណូចាប់បាន។ ក្នុងករណីភាគច្រើន ជនជាតិវៀតណាមបាននិយាយថា ពួកគេត្រូវបានបង្ខាំង និងធ្វើការប្រឆាំងនឹងឆន្ទៈរបស់ពួកគេនៅក្នុងកន្លែងខុសច្បាប់ក្នុងប្រទេសកម្ពុជា ហើយត្រូវរងការធ្វើទារុណកម្ម។ អ្នកខ្លះនិយាយថាពួកគេត្រូវបានបោកនិងលក់។

ក្នុងឆមាសទី១ឆ្នាំនេះ ក្រសួងសន្តិសុខសាធារណៈបានបង្ក្រាបបណ្ដាញជាច្រើនដែលរត់ពន្ធមនុស្សមកកម្ពុជាដើម្បីធ្វើការខុសច្បាប់។ អាជ្ញាធរក៏បានជួយសង្គ្រោះពលរដ្ឋវៀតណាមរាប់រយនាក់ និងជួយរាប់ពាន់នាក់នៅក្នុងប្រទេសកម្ពុជាដើម្បីបំពេញនីតិវិធីឲ្យត្រឡប់ទៅប្រទេសកំណើតវិញ។ កាលពីរសៀលថ្ងៃសៅរ៍ កម្មករវៀតណាមជាង ៥០នាក់ បានរត់គេចពីកាស៊ីណូក្នុងខេត្តស្វាយរៀង របស់កម្ពុជា ក្បែរច្រកព្រំដែនម៉ុកបៃ ហើយត្រូវបានឃាត់ខ្លួនដោយអាជ្ញាធរកម្ពុជា៕ *VNExpress*

## ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២

### ម៉ាឡេស៊ីបង្កើនការប្រយុទ្ធប្រឆាំងនឹងការឆបោកការងារតាមអ៊ីនធឺណិត ដោយបង្កើតគណៈកម្មាធិការដើម្បីដោះស្រាយបញ្ហានេះ

https://www.khmertimeskh.com/501156042//?p=1156042 Khmer Times September 22, 2022

នាយករដ្ឋមន្ត្រីម៉ាឡេស៊ី Ismail Sabri Yaakob បានឯកភាពបង្កើតគណៈកម្មាធិការមួយ ដើម្បីដោះស្រាយបញ្ហាប្រជាជនម៉ាឡេស៊ីដែលធ្លាក់ខ្លួនជាជនរងគ្រោះដោយសារការឆបោកការងារនៅបរទេស។ នៅក្នុងសេចក្តីថ្លែងការណ៍មួយ ក្រសួងការបរទេសបាននិយាយថា រដ្ឋមន្ត្រីមុខងារពិសេស Abd Latiff Ahmad បានលើកឡើងពីបញ្ហានេះនៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី។ ក្រសួងបានបន្តថា៖ «ចំពោះបញ្ហានេះ លោកនាយករដ្ឋមន្ត្រីបានឯកភាពឱ្យមានគណៈកម្មការមួយ រួមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហានេះអោយកាន់តែមានប្រសិទ្ធភាព»។ ក្រសួងបន្ថែមថា គិតត្រឹមថ្ងៃនេះ មានរបាយការណ៍សរុបចំនួន ៣០១ ករណីនៃជនជាតិម៉ាឡេស៊ី ដែលត្រូវបានបោកបញ្ឆោត ដោយសន្យាផ្តល់ការងារនៅក្នុងប្រទេសឡាវ មីយ៉ាន់ម៉ា ថៃ និងកម្ពុជា។ ក្នុងចំណោមជនរងគ្រោះទាំង៣០១នាក់ មាន១៦៨នាក់ត្រូវបានគេជួយសង្គ្រោះ និងនាំត្រឡប់ទៅប្រទេសម៉ាឡេស៊ីវិញ ។ ជនរងគ្រោះ ៣៤ នាក់ផ្សេងទៀត ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ហើយ ៩៩ នាក់ទៀតកំពុងត្រូវបានតាមរកដោយអាជ្ញាធរតាមបណ្តាប្រទេសទាំងនោះ។ ក្រសួងក៏បានឲ្យដឹងដែរថា តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ស្ថានទូតម៉ាឡេស៊ីនៅរាជធានីភ្នំពេញ ជនរងគ្រោះចំនួន ១៥ នាក់ត្រូវបានជួយសង្គ្រោះពីកម្ពុជា។ ពួកគេបានមកដល់ទីក្រុងកូឡាឡាំពួរនៅម៉ោង១១និង៥០នាទីយប់ថ្ងៃទី២០ កញ្ញា។

Ismail បាននិយាយថា រដ្ឋាភិបាលកំពុងប្រើប្រាស់បណ្តាញដែលមានទាំងអស់ ដើម្បីជួយសង្គ្រោះប្រជាជនម៉ាឡេស៊ីដែលត្រូវបានបោកបញ្ឆោត និងកំពុងត្រូវបានឃុំខ្លួននៅបរទេស។ លោកបានបន្តថា Latiff បានជួបជាមួយអង្គការមនុស្សធម៌អន្តរជាតិម៉ាឡេស៊ី (MHO) សមាគមថៃទាំជនរងគ្រោះដោយសារឧក្រិដ្ឋកម្មម៉ាឡេស៊ី និង

សមាជិកគ្រួសារជនរងគ្រោះជុំវិញបញ្ហានេះ។ ក្រសួងការបរទេសម៉ាឡេស៊ីបាននិយាយថា ជនរងគ្រោះដោយសារការបោកប្រាស់ការងារនៅកម្ពុជាចំនួន១៤៨ នាក់ត្រូវបានជួយសង្គ្រោះក្នុងចំណោម ១៥៨ នាក់ដែលត្រូវបានរាយការណ៍ និងធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសម៉ាឡេស៊ី។

ខ្មែរថាមស៍ បានដឹងថា អាចមានជនជាតិម៉ាឡេស៊ីជាច្រើនទៀត ដែលសម្រេចចិត្តជ្រើសរើសលាក់ខ្លួន ខណៈដែលពួកគេមិនស្ថិតនៅក្រោមការបង្ខិតបង្ខំ ហើយត្រូវបានគេរាយការណ៍ថាអាចរកប្រាក់ចំណូលបានច្រើនពីការងាររបស់ពួកគេ ទោះបីជាវាខុសច្បាប់ក៏ដោយ។ "ដោយសារអត្រាប្តូរប្រាក់ដុល្លារមានតម្លៃខ្ពស់ជាងរីងហ្គីតម៉ាឡេស៊ី គឺនេះបានទាក់ទាញមនុស្សជាច្រើនអោយសំងំលាក់ខ្លួន និងសមត្ថភាពរបស់ពួកគេក្នុងការបំពេញតាមតម្រូវចាំបាច់ នេះមានន័យថាស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេកាន់តែមានភាពប្រសើរឡើង។ មន្ត្រីសន្តិសុខម្នាក់ដែលដឹងខ្លះពីប្រតិបត្តិការបោកប្រាស់បានប្រាប់ខ្មែរថាមស៍ ក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះដោយសារការបង្ក្រាបសកម្មភាពបែបនេះនៅកម្ពុជាកំពុងតែបន្ត ថា "បទល្មើសសន្តិសុខ (វិធានការពិសេស)ឆ្នាំ ២០១២ (SOSMA) វិធានការសន្តិសុខជាតិគួរតែត្រូវបានដាក់ប្រើប្រឆាំងនឹងជនបោកប្រាស់ ខណៈដែលមានជនជាតិម៉ាឡេស៊ីធ្វើដំណើរចូលមកកម្ពុជា ថៃ និងមីយ៉ាន់ម៉ា ដើម្បីធ្វើការនៅក្នុងមជ្ឈមណ្ឌលហៅទូរស័ព្ទបោកប្រាស់នេះ។ ហើយប្រសិនបើ ជនបោកប្រាស់មិនត្រូវបានបញ្ឈប់ទេ ប្រាក់ដុល្លារអាមេរិកនឹងបន្តទាក់ទាញប្រជាជនម៉ាឡេស៊ីឱ្យទទួលយកការងារបែបនេះ ទោះបីជាពួកគេប្រឈមនឹងគ្រោះថ្នាក់ក៏ដោយ"។

ច្បាប់ស្តីពីបទល្មើសសន្តិសុខ (វិធានការពិសេស) ឆ្នាំ២០១២ គឺជាច្បាប់មួយដែលត្រូវបានអនុម័ត "ដើម្បីផ្តល់វិធានការពិសេសទាក់ទងនឹងបទល្មើសសន្តិសុខ ក្នុងគោលបំណងរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ និងបញ្ហាពាក់ព័ន្ធផ្សេងៗ"។ ច្បាប់នេះគឺដើម្បីជំនួសច្បាប់សន្តិសុខផ្ទៃក្នុងឆ្នាំ១៩៦០ ដែលអនុញ្ញាតឱ្យមានការឃុំខ្លួនដោយគ្មានការជំនុំជម្រះរហូតដល់២ឆ្នាំ៕ *FMT/Khmer Times*

## ប៉ូលីសចិនចាប់ខ្លួនអ្នកឆ្លងដែនខុសច្បាប់២៩នាក់ដែលគ្រោងចូលខេត្តព្រះសីហនុ

http://kh.cc-times.com/posts/12576 06/09/2022 ហួ ឆេងស៊ីម

ចិន៖ ប៉ូលីសជើងទឹកទីក្រុង Wenzhou ខេត្ត Zhejiang ប្រទេសចិន បានបង្ក្រាបករណីលួចឆ្លងដែនខុសច្បាប់តាមសមុទ្រដ៏ធំមួយ ដែលមានគម្រោងចូលមកក្រុងព្រះសីហនុ នៃប្រទេសកម្ពុជា និង បានរឹបអូសបានកប៉ាល់ចំនួន ១គ្រឿង និងបានចាប់ខ្លួនជនលួចឆ្លងដែនខុសច្បាប់ចំនួន២៩នាក់ និង នាវិកចំនួន៤នាក់ ។ បច្ចុប្បន្ន មន្ត្រីពាក់ព័ន្ធបានប្រគល់ករណីនេះទៅឲ្យអង្គភាពសន្តិសុខសាធារណៈ ដើម្បីធ្វើការស៊ើបអង្កេតបន្ថែម។ នៅម៉ោង ១៥:២០ នាទី ថ្ងៃទី ៦ ខែកញ្ញា ប៉ូលីសជើងទឹកទីក្រុង Wenzhou បានទទួលសេចក្តីរាយការណ៍ពីស្នងការនគរបាលសន្តិសុខសាធារណៈទីក្រុង Ruian ថា មានក្រុមហ៊ុនឆបោកតាមប្រព័ន្ធទូរគមនាគមន៍ "Global" នៅក្រុងព្រះសីហនុ ប្រទេសកម្ពុជា បានឃុបឃិតជាមួយមេខ្យល់លួចឆ្លងដែនទៅក្រៅប្រទេសខុសច្បាប់ ដើម្បីជ្រើសរើសបុគ្គលិកជនជាតិចិនចំនួន ៣៥នាក់មកប្រទេសកម្ពុជា ដើម្បីបម្រើការងារឆបោកតាមប្រព័ន្ធទូរគមនាគមន៍។

បើតាមសេចក្តីរាយការណ៍ ក្រោយទទួលបានព័ត៌មាន ប៉ូលីសចិន បានចាប់ផ្តើមចេញសកម្មភាពផែនការសង្គ្រោះបន្ទាន់នៅដែនសមុទ្រភ្លាមៗ ដោយបានបង្កើតក្រុមកិច្ចការពិសេសដោយសហការជាមួយស្នងការនគរបាលសន្តិសុខសាធារណៈទីក្រុង Ruian ដោយចេញប្រតិបត្តិការចាប់ខ្លួនទាំងផ្លូវសមុទ្រ និង ផ្លូវគោក៕

## ឯកអគ្គរាជទូតម៉ាឡេស៊ី ថ្លែងអំណរគុណ រាជរដ្ឋាភិបាល កម្ពុជា ជួយសង្គ្រោះពលរដ្ឋរបស់ខ្លួន ពីការជួញដូរមនុស្ស

https://dap-news.com/national/2022/09/22/280962/ BySSP108Posted on September 22, 2022

ឯកអគ្គរាជទូតម៉ាឡេស៊ី ប្រចាំកម្ពុជា លោក Eldeen Husaini Mohd Hashim បានប្រកាសថ្លែងអំណរគុណ ចំពោះរាជរដ្ឋាភិបាល កម្ពុជា ជួយសង្គ្រោះពលរដ្ឋរបស់ខ្លួន ពីការជួញដូរមនុស្ស នៅក្នុងសន្និសីទកាសែត នាព្រឹកថ្ងៃព្រហស្បត្តិ៍នេះ នាសណ្ឋាគារណាហ្គាវើល១ នារាជធានីភ្នំពេញ។ លោកឯកអគ្គរាជទូត បានលើកឡើងថា ក្នុងយុទ្ធនាការជួយសង្គ្រោះរបស់អាជ្ញាធរកម្ពុជា គឺបានជួយសង្គ្រោះ ជនជាតិម៉ាឡេស៊ី ក្នុងចំណោមជនរងគ្រោះឯទៀត ប្រមាណ១៥៨នាក់។ បើតាមលោកទូត ជនរងគ្រោះ ប្រមាណ១៣៨នាក់ ត្រូវបានធ្វើមាតុភូមិនិវត្តន៍របស់ខ្លួនរួចរាល់អស់ហើយ នៅសល់ប៉ុន្មានទៀត នឹងត្រូវបញ្ជូន ឆាប់ៗខាងមុខនេះ។ លោក Eldeen បានលើកឡើង "ខ្ញុំសូមសម្តែងនូវការអរគុណដ៏ស្មោះអំពីខ្ញុំ ចំពោះសម្តេចប្រមុខ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាឯ.ក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា និងសម្តេចក្រឡាហោម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ"។

លោកប្រមុខការទូតរូបនេះ ក៏ពន្យល់ផងដែរថា ការដែលពលរដ្ឋម៉ាឡេស៊ី ចាញ់បោកមេខ្យល់មកធ្វើការ នៅកម្ពុជា នោះក៏ព្រោះតែ ប្រទេសទើបបើកឡើងវិញ ក្រោយពីកូវីដ១៩ អ្នកខ្លះអត់លុយ អត់មានការងារធ្វើ ពេលគេប្រកាសផ្តល់ប្រាក់ខែ ២ ០០០ ទៅ ៣ ០០០ដុល្លារ ទោះគ្មានជំនាញក៏ដោយ តែពេលមកដល់ក៏ត្រូវចាញ់បោកគេតែម្តងទៅ។ លោក Eldeen បានបន្តថា "ជាមួយនឹងការជួយពីរាជរដ្ឋាភិបាលកម្ពុជា ស្ថានទូតម៉ាឡេស៊ី បានចាត់ចែងជួយជនជាតិម៉ាឡេស៊ី ចំនួន ១៥៣នាក់ ដែលក្នុងនោះ ១៣៧នាក់ ត្រូវបានបញ្ជូនត្រឡប់ទៅកាន់ប្រទេសកំណើតវិញ, ហើយនៅសល់១៦នាក់ទៀត ដែលកំពុងស្នាក់នៅក្នុងមជ្ឈមណ្ឌលឃុំឃាំងអន្តោប្រវេសន៍, ទូរលេខនេះ អាចនិយាយបានថា ជាកំរិតនៃកិច្ចសហប្រតិបត្តិការ ដែលបានកើតឡើង រវាងយើងខ្ញុំ និងរដ្ឋាភិបាលកម្ពុជា"។ លោក ទូត បន្ថែមថា "យើងនឹងបន្តការធ្វើការជាមួយពួកគេ ដើម្បីធានាដោះស្រាយបញ្ហានៅក្នុងដៃ អោយរួចរាល់ទាំងអស់តែម្តង"។ យ៉ាងណាក៏ដោយ លោក ទូត ក៏បានស្នើ ឱ្យពលរដ្ឋម៉ាឡេស៊ី ទាំងអស់ដែលចង់មកធ្វើការនៅប្រទេសកម្ពុជា គឺត្រូវតែសាកសួរព័ត៌មានផ្លូវការ ពីក្រសួងការបរទេស ឬ ស្ថានទូតម៉ាឡេស៊ី ប្រចាំកម្ពុជា មុននឹងសម្រេចចិត្ត មកធ្វើការ៕ *ដោយ៖ សយ សុភា*

## ម៉ាឡេស៊ីជួយសង្គ្រោះមនុស្ស១៥នាក់ពីឧក្រិ.ដ្ឋកម្មតាមអ៊ីនធឺណេតនៅកម្ពុជា

https://kohsantepheapdaily.com.kh/article/1603062.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ២២ ខែ កញ្ញា ឆ្នាំ ២០២២ ម៉ោង ១៥:៤៩

ម៉ាឡេស៊ី ៖ អាជ្ញាធរម៉ាឡេស៊ីបានជួយជនរងគ្រោះចំនួន ១៥នាក់ពីឧក្រិ.ដ្ឋកម្មតាមអ៊ីនធឺណេតនៅក្នុងប្រទេសកម្ពុជា ខណៈរដ្ឋាភិបាលកំពុងបង្កើនកិច្ចប្រឹងប្រែងដើម្បីជួយពលរដ្ឋខ្លួនរាប់រយនាក់ទៀតដែលជាប់ក្នុងប្រតិបត្តិការស្រដៀងគ្នានៅទូទាំងអាស៊ីអាគ្នេយ៍។ ជនរងគ្រោះទាំង ១៥នាក់បានធ្វើដំណើរដល់ទីក្រុង Kuala Lumpur កាលពីថ្ងៃអង្គារ ទី ២០ កញ្ញា។ ការជួយសង្គ្រោះពួកគេកើតឡើងចំពេលមានការផ្ទក់ទូទាំងប្រទេសកម្ពុជានៅសប្តាហ៍នេះលើបរិវេណឧក្រិ.ដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណេត ដែលសង្ស័យថាបានជួញដូរមនុស្សចូលទៅកម្ពុជាដើម្បីធ្វើការក្នុងល្បែងស៊ីសងខុសច្បាប់ និងកន្លែងឆបោក។

នៅក្នុងសេចក្តីប្រកាសកាលពីថ្ងៃពុធ ទី ២១ កញ្ញា ក្រសួងការបរទេសម៉ាឡេស៊ីបាននិយាយថា ខ្លួនទទួលបានរបាយការណ៍ចំនួន ៣០១នៃមនុស្សដែលជាប់គាំងដោយសារបណ្តាញឆបោកនៅក្នុងប្រទេសកម្ពុជា ព្រមទាំងឡាវ ម៉ាឡេស៊ី និងថៃ។ ក្នុងចំណោមនោះ មនុស្ស ១៦៨នាក់ត្រូវបានជួយសង្គ្រោះ ៣៤នាក់កំពុងស្ថិតនៅកន្លែងឃុំឃាំងអន្តោប្រវេសន៍ និង៩៩នាក់ទៀតកំពុងត្រូវបានតាមដាន។

ជនរងគ្រោះនិយាយថា ពួកគេត្រូវបានបោកបញ្ឆោតឱ្យធ្វើដំណើរទៅប្រទេសកម្ពុជាតាមការសន្យាផ្តល់ការងារប្រាក់ខែខ្ពស់នៅកាស៊ីណូ និងសណ្ឋាគារ ប៉ុន្តែផ្ទុយទៅវិញ ពួកគេត្រូវបានបង្ខំឱ្យរស់នៅក្នុងបរិវេណ និងធ្វើការបោកប្រាស់អ្នកប្រើប្រាស់អ៊ីនធឺណែតតាមរយៈស្នេហា និងគម្រោងរូបិយប័ណ្ណឌីជីថល។

អាជ្ញាធរកម្ពុជាបាននិយាយថា ពួកគេបានរកឃើញភស្តុតាងល្បែងស៊ីសងខុសច្បាប់ ការបង្ខាំងមនុស្ស និងទារុណកម្ម ពេស្យាចារ ការកាន់កាប់អាវុធខុសច្បាប់ ការលាងលុយកខ្វក់ និងការជួញដូរមនុស្សនៅបរិវេណមួយ៕ (យោងតាមប្រភព៖ Reuters)

## កម្ពុជា-ម៉ាឡេស៊ីជួយសង្គ្រោះជនរងគ្រោះ១៥៣នាក់ពីកន្លែងធ្វើការបោកប្រាស

http://freshnewsasia.com/index.php/en/localnews/258245-2022-09-22-08-09-04.html 2022-09-22 03:09pm

**(ភ្នំពេញ)៖** ជនរងគ្រោះម៉ាឡេស៊ីចំនួន១៥៣នាក់ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាសហការជាមួយស្ថានទូតម៉ាឡេស៊ីនៅរាជធានីភ្នំពេញជួយសង្គ្រោះពីកន្លែងធ្វើការបោកប្រាស ក្នុងនោះ១៣៧នាក់ត្រូវបានបញ្ជូនទៅប្រទេសកំណើតវិញ ខណៈ១៦នាក់ទៀតកំពុងសម្រួលនីតិវិធីបញ្ជូនទៅតាមក្រោយ។ ដើម្បីបកស្រាយលម្អិតជុំវិញករណីនេះ ស្ថានទូតម៉ាឡេស៊ីប្រចាំកម្ពុជាបានធ្វើសន្និសីទសារព័ត៌មានមួយនៅអគារណាហ្គាវើលដ៍ នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ក្រោមការផ្តល់ព័ត៌មានដោយផ្ទាល់ពីសំណាក់ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក អ៊ែលដិន ហាសៃនី ម៉ូដហាស៊្រីម (Datuk Eldeen Husaini Mohd Hashim)។ លោក អ៊ែលដិន បានឱ្យដឹងថា ជនរងគ្រោះម៉ាឡេស៊ី១៥៣នាក់នេះគឺរងការឆបោកតាមអ៊ីនធើណេត ដែលជនទុច្ចរិតបានបោកប្រាសពួកគេទាក់ទាញឱ្យមកធ្វើការនៅកម្ពុជា ក្រោមការសន្យាថានឹងផ្តល់ប្រាក់ឈ្នួលពី២-៣ពាន់ដុល្លារក្នុងមួយខែ។

លោកបានបន្តថា មូលហេតុដែលជនរងគ្រោះទាំងនោះធ្លោយខ្លួនបាញ់បោកជនទុច្ចរិតនោះ គឺដោយសារវិបត្តិជំងឺកូវីដ១៩រំខានដល់ជីវភាពរបស់ពួកគេ នាំឱ្យសេដ្ឋកិច្ចគ្រួសារធ្លាក់ចុះ ចួនជាមានការឃោសនាពីជនទុច្ចរិតថាមកធ្វើការនៅប្រទេសកម្ពុជាទទួលបានប្រាក់ខែខ្ពស់ផងនោះ ពួកគេក៏ធ្វើដំណើរមកតាមការឃោសនានោះតែម្តង (ក្រោយប្រទេសទាំងពីរបើកជើងហោះហើរវិញ)។ នៅពេលមកដល់ ជនរងគ្រោះទាំងនោះក៏ត្រូវគេបង្ខាំងទុកមិនឱ្យទៅណា និងមិនផ្តល់ប្រាក់ខែឱ្យឡើយ។ ពួកគេភាគច្រើនត្រូវគេបង្ខាំងទុកទីតាំងអគារក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ លោកឯកអគ្គរាជទូតបានបន្តទៀតថា ការជួយសង្គ្រោះពលរដ្ឋម៉ាឡេស៊ីទាំង១៥៣នាក់នោះ គឺមានរយៈពេលត្រឹមតែ១ខែ ក្រោមកិច្ចសហការយ៉ាងយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ ក៏ដូចជាមន្ត្រីមានសមត្ថកិច្ច និងអាជ្ញាធររបស់កម្ពុជា ជាមួយស្ថានទូតម៉ាឡេស៊ីប្រចាំកម្ពុជា។

ចំពោះមធ្យោបាយដើម្បីនាំពួកគេចេញពីទីបង្ខាំង ការរៀបចំកន្លែងស្នាក់នៅនិងអាហារ និងកិច្ចសហការជាមួយភាគីកម្ពុជាដើម្បីបញ្ជូនពួកគេទៅមាតុភូមិវិញនោះ គឺជាការចំណាយរបស់ភាគីម៉ាឡេស៊ីទាំងស្រុង។ ជនរងគ្រោះទាំងនោះគឺត្រូវបាននាំពីខេត្តព្រះសីហនុមកស្នាក់នៅបណ្តោះអាសន្ននាសណ្ឋាគារមួយក្បែរវិហារវត្តស្លាម បឹងកក់ មុនបញ្ជូនទៅកាន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីធ្វើដំណើរត្រលប់ទៅប្រទេសកំណើតវិញ។ បើតាមលោកឯកអគ្គរាជទូត មកដល់ពេលនេះ មានជនរងគ្រោះ១៣៧នាក់ហើយដែលត្រូវបានបញ្ជូនទៅប្រទេសកំណើតវិញ ខណៈ១៦នាក់ទៀតកំពុងស្ថិតក្នុងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃកម្ពុជា ដើម្បីបំពេញនីតិវិធីមុនពេលអនុញ្ញាតឱ្យពួកគេត្រលប់ទៅប្រទេសកំណើតវិញ។

លោកឯកអគ្គរាជទូតម៉ាឡេស៊ីក៏បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសចំពោះសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានចេញបទបញ្ជាឱ្យមន្ត្រីមានសមត្ថកិច្ចចូលរួមលុបបំបាត់បទល្មើសឆបោកតាមអ៊ីនធើណេត ក៏ដូចជាតាមមធ្យោបាយផ្សេងទៀត។ លោកក៏បានថ្លែងអំណរគុណចំពោះលោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិដែលបានពង្រឹងទំនាក់ទំនងមិត្តភាពទ្វេភាគីដ៏រឹងមាំរវាងកម្ពុជានិងម៉ាឡេស៊ី។

គួររំឭកថា ក្នុងដំណើរទស្សនកិច្ចរបស់រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ីមកកាន់កម្ពុជានាពេលថ្មីៗនេះ រដ្ឋមន្ត្រីការបរទេសទាំងពីរបានសន្ទនាតាមទូរស័ព្ទ ដើម្បីពិភាក្សាឱ្យមានការសម្របសម្រួលគ្នាយ៉ាងរលូននៅក្នុងប្រតិបត្តិការជួយសង្គ្រោះប្រជាជនម៉ាឡេស៊ីកន្លងមកនេះ។ ទាំងនេះគឺជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា-ម៉ាឡេស៊ី។ ភាគីទាំងពីរនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយពួកគេ ដើម្បីធានាថាបញ្ហានេះនឹងត្រូវដោះស្រាយឱ្យចប់សព្វគ្រប់។ នេះបើតាមការអះអាងរបស់លោក អ៊ែលជិន ហាសៃនី ម៉ូដហាស្ស៊ីម។ ជាការកត់សម្គាល់ក្នុងពេលធ្វើសន្និសីទនោះ ទោះបីការងារនេះសម្រេចបានជិតរួចរាល់ក៏ពិតមែន ប៉ុន្តែឯកអគ្គរាជទូតម៉ាឡេស៊ីរូបនេះមិនបង្ហាញទឹកមុខញញឹមបន្តិចណាឡើយ។ មន្ត្រីស្ថានទូតម៉ាឡេស៊ីប្រចាំរាជធានីភ្នំពេញបាននិយាយថា លោក អ៊ែលជិន ព្យាយាមបំពេញកិច្ចការនេះយ៉ាងមមាញឹកដើម្បីសង្គ្រោះពលរដ្ឋរបស់ខ្លួន ទាំងការនាំពួកគេចេញពីទីបង្ខាំង ចាត់ចែងរៀបចំកន្លែងស្នាក់នៅនិងអាហារ និងការបញ្ជូនពួកគេទៅមាតុភូមិវិញ ម្យ៉ាងនៅសល់ពលរដ្ឋម៉ាឡេស៊ី១៦ ទៀតក៏មិនទាន់បញ្ជូនទៅវិញនៅឡើយ ដូច្នេះលោកមានការមមាញឹកយ៉ាងខ្លាំងជាមួយមន្ត្រីកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ីរបស់លោក៕

## ក្រសួងមហាផ្ទៃ បង្ហាញលទ្ធផល
## នៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន

https://dap-news.com/national/2022/09/22/281055/ BySS107Posted on September 22, 2022

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងនាមជាប្រធានប្តូរវេន និងជាម្ចាស់ផ្ទះ បានអញ្ជើញដឹកនាំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ (16th AMMTC and Its Related Meetings) ចាប់ពីថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ។ សម្តេចក្រឡាហោម ស ខេង រួមទាំងរដ្ឋមន្ត្រី និងប្រធានប្រតិភូនៃរដ្ឋសមាជិកអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន បានសម្តែងការកោតសរសើរ និងអបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ កងកម្លាំងអនុវត្តច្បាប់ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នាំដល់ការសម្រេចបានលទ្ធផលជាវិជ្ជមានក្នុងដំណើរការស្តារឡើងវិញសង្គម-សេដ្ឋកិច្ច ព្រមទាំងកិច្ចសហការជិតស្និទ្ធ ក្នុងការដោះស្រាយបញ្ហាដែលលេចឡើងថ្មីៗ នៅក្រោយវិបត្តិនៃជំងឺរាតត្បាតជាសកលនេះ ស្របទៅនឹងមូលបទអាស៊ានឆ្នាំ២០២២ «អាស៊ានរួមគ្នាធ្វើ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា»។

ទន្ទឹមនេះ កិច្ចប្រជុំក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់ស្ថាប័ន អនុវត្តច្បាប់ពាក់ព័ន្ធ ក្នុងកិច្ចសហប្រតិបត្តិការបង្ការ ទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ព្រមទាំងបានពិភាក្សាផ្លាស់ប្តូរយោបល់ និងចែករំលែកនូវបច្ចុប្បន្នភាពអំពីនិន្នាការនៃឧក្រិដ្ឋកម្មឆ្លងដែន នៅក្នុងតំបន់ ក្នុងនោះ ក៏បានកត់សម្គាល់ការវិវត្តកើនឡើងនូវបទល្មើសមួយចំនួន ដូចជា៖ អំពើភេរវកម្ម អំពើហិង្សាជ្រុលនិយម ការជួញដូរគ្រឿងញៀន អំពើជួញដូរមនុស្ស រត់ពន្ធមនុស្ស បទល្មើសពាក់ព័ន្ធនឹង បច្ចេកវិទ្យា បទល្មើសជួញដូរសត្វព្រៃ និងឈើខុសច្បាប់ បទល្មើសសម្អាតប្រាក់ និងបទល្មើសសេដ្ឋកិច្ចអន្តរជាតិជាដើម។

សូមបញ្ជាក់ថា ក្នុងស្មារតីបង្កើនការយកចិត្តទុកដាក់ឆ្លើយតបទៅនឹងនិន្នាការនៃបទល្មើសទាំងនេះ កិច្ចប្រជុំបានផ្លាស់ប្តូរយោបល់ និងលើកឡើងគំនិតផ្តួចផ្តើមសំខាន់ៗ ដើម្បីពង្រឹង និងពង្រីក ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ តាមរយៈយន្តការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងបទល្មើស ព្រមទាំង ចែករំលែកបទពិសោធន៍ និងជំនាញបច្ចេកទេស សំដៅលើកកម្ពស់សមត្ថភាពកងកម្លាំងអនុវត្តច្បាប់ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រែប្រួលនៃសភាពការណ៍សន្តិសុខក្នុងតំបន់ និងសកលលោក៕

## អ្នកនាំពាក្យក្រសួងមហាផ្ទៃ៖ ម្សិលមិញ
## សមត្ថកិច្ចកម្ពុជាទទួលបានបណ្តឹង ១៦ទៀត ដែលស្នើឲ្យសង្គ្រោះជនបរទេស

http://freshnewsasia.com/index.php/en/localnews/258297-2022-09-22-11-25-09.html 2022-09-22 06:25pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០នាថ្ងៃទី២០ ដល់វេលាម៉ោង ៣៖០០ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញ សមត្ថកិច្ចកម្ពុជា បានទទួលសំណើ ១៦ករណីទៀត ដែលស្នើឲ្យសង្គ្រោះជនបរទេស ៥២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង ១៦ករណីនេះ រួមមាន៖ ស្នើឲ្យសង្គ្រោះជនជាតិចិនចំនួន ២៨នាក់, ចិនតៃវ៉ាន់ ១នាក់, ឥណ្ឌា ៦នាក់, វៀតណាម ៦នាក់, ស៊ូដង់ ១នាក់ និងបង់ក្លាដេស ១១នាក់។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៣០៣ករណី មានមនុស្ស ៦៦៦នាក់ មាន ១១សញ្ជាតិ.

**២៖** ស្រាវជ្រាវអង្កេតបឋមបាន ១៣៦សំណើ នៅសល់ ១៦៧សំណើ (រកឃើញ ២៧០នាក់, ឃាត់ខ្លួន ៣០នាក់, បិទក្រុមហ៊ុន ១ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៣ទីតាំង)។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមានដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## មានករណីលិចទូកមួយគ្រឿង
## នៅកណ្តាលសមុទ្រកម្ពុជា បានបណ្តាលឲ្យមនុស្សជាង ២០នាក់បាត់ខ្លួន

https://www.btv.com.kh/article/15562 2022/09/22 09:42:35 pm

ខេត្តព្រះសីហនុ៖ មានករណីលិចទូកនៅកណ្តាលសមុទ្រកម្ពុជាមួយគ្រឿងត្រង់ចន្លោះពយសារី និងកោះតាង នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២នេះ ក្រោយកើតហេតុអាជ្ញាធរខ្មែរបានជួយសង្គ្រោះជនរងគ្រោះជាជនជាតិចិនបានចំនួន១៨នាក់ខណៈ២៣ទៀតកំពុងបាត់ខ្លួន។ នេះបើតាមការឲ្យដឹងពីសមត្ថកិច្ចខេត្តព្រះសីហនុ។ សមត្ថកិច្ចបានឲ្យដឹងថា មានទូកមួយគ្រឿងដែលមានមនុស្សរាប់សិបនាក់ជិះ ហើយមកដល់ត្រង់ចន្លោះពយសារី និងកោះតាងបានលិច បន្ទាប់ពីមានសេចក្តីរាយការណ៍ដល់នគរបាលព្រំដែនទឹកបានទៅជួយសង្គ្រោះជនរងគ្រោះចំនួន១៨នាក់ ខណៈអ្នកបាត់ខ្លួននគរបាលកំពុងស្វែងរកបន្ត។

បើតាមការបញ្ជាក់ ពីអ្នករួមដំណើរម្នាក់ ដែលមានឈ្មោះ CHEN Gui Sheng ជាជនជាតិចិន ភេទប្រុស បានប្រាប់សមត្ថកិច្ចថា អ្នករួមដំណើរនៅលើទូកនេះមានចំនួនជាង៤០នាក់ ហើយពេលនេះកំពុង បាត់ខ្លួនចំនួន ២៣នាក់ទៀត។ សាក្សីបានបញ្ជាក់ប្រាប់សមត្ថកិច្ចថា ទូកនេះបានធ្វើដំណើរចេញពីប្រទេសចិន (កំពង់ផែក្វាងចូវ) តាមកប៉ាល់លឿន ០១គ្រឿង នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២ រួចបានសាងមកទូកឈើ០១គ្រឿង នៅអំឡុងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២ នៅសមុទ្រអន្តរជាតិជាមួយតៃកុងទូកជនជាតិខ្មែរ ០២នាក់ និងបានបន្តនៅលើទូកឈើនោះ រហូតដល់ថ្ងៃទី២២ ខែកញ្ញាឆ្នាំ២០២២ ទូកឈើនោះខូចក៏ចាប់ផ្តើមលិចបន្តិចម្តងៗ ទើបមានទូកនេសាទ ១ គ្រឿង ប្រភេទទូកអូសពណ៌បៃតង មានមនុស្ស ០៦នាក់ បានមកទទួលយកតៃកុងខ្មែរ ០២នាក់នោះ ចេញទៅបាត់ ដោយទុកតែអ្នកធ្វើដំណើរនៅលើទូក ក្រោយមកទូកនេះក៏បានលិចបាត់នេះនៅកណ្តាលសមុទ្រ។ យ៉ាងណាក៏ដោយ ករណីនេះ សមត្ថកិច្ចកំពុងស្រាវជ្រាវបន្ត៕

## ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២

### អ្នកនាំពាក្យក្រសួងមហាផ្ទៃ៖ ម្សិលមិញ សមត្ថកិច្ចកម្ពុជាទទួលបានបណ្តឹង ១៣ទៀត ដែលស្នើឱ្យសង្គ្រោះជនបរទេស

http://freshnewsasia.com/index.php/en/localnews/258393-2022-09-23-06-25-57.html 2022-09-23 01:25pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០នាថ្ងៃទី២១ ដល់វេលាម៉ោង ៣៖០០ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញ សមត្ថកិច្ចកម្ពុជា បានទទួលសំណើ ១៣ករណីទៀត ដែលស្នើឱ្យសង្គ្រោះជនបរទេស ២៧នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង ១៣ករណីនេះ រួមមាន៖ ស្នើឱ្យសង្គ្រោះជនជាតិចិនចំនួន ៦នាក់, ជនជាតិឥណ្ឌា ១នាក់, ជនជាតិវៀតណាម ៤នាក់, ជនជាតិស្រីលង្កា ១ នាក់, ជនជាតិបង់ក្លាដេស ៧នាក់ ជានជាតិខ្មែរ ១នាក់ ជនជាតិម៉ាឡេស៊ី ៦នាក់ និងជនជាតិហ្វីលីពីន ១នាក់។

**បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៣០៣ករណី មានមនុស្ស ៦៦៦នាក់ មាន ១១សញ្ជាតិ។

**២៖** ស្រាវជ្រាវអង្កេតបឋមបាន ១៣៧សំណើ នៅសល់ ១៦៦សំណើ (រកឃើញ ២៧១នាក់, ឃាត់ខ្លួន ៤៩នាក់, បិទក្រុមហ៊ុន ១ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៥ទីតាំង)។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## ឥណ្ឌាស្វែងរកការជួយសង្គ្រោះយុវជន៦នាក់ដែលជាប់ក្នុងប្រទេសកម្ពុជា

https://www.khmertimeskh.com/501157127//?p=1157127 Khmer Times September 24, 2022

លោក Bandi Sanjay Kumar បានសរសេរលិខិតទៅកាន់ក្រសួងការបរទេស ដើម្បីសុំជួយសង្គ្រោះយុវជនចំនួន ៦ នាក់ ដែលជាប់ក្នុងប្រទេសកម្ពុជា បន្ទាប់ពីត្រូវបានល្បួងដោយក្រុមឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតមកពីប្រទេសចិន។ យុវជនទាំង៦នាក់ មកពីស្រុក Karimnagar បានទៅប្រទេសកម្ពុជា ដើម្បីស្វែងរកការងារ ដោយម្នាក់ៗបានបង់ប្រាក់ចំនួន ₹2 lakh ទៅក្រុមហ៊ុនមួយដែលមានមូលដ្ឋាននៅ Karimnagar ។ យុវជនទាំងនោះមានឈ្មោះ Nadeem, Siabaaz Khan, Saleem, Hajibaba, Sultan និង Sharukh Khan ត្រូវបានសម្យាផ្តល់ការងារជាប្រតិបត្តិករកុំព្យូទ័រ។ ប៉ុន្តែ ជាក់ស្តែងពួកគេត្រូវបានបង្ខំឱ្យចូលរួមក្នុងសកម្មភាពខុសច្បាប់។ នៅពេលដឹងអំពីស្ថានភាពរបស់ពួកគេ Sanjay ដែលជាសមាជិកសភាមកពី Karimnagar បានសរសេរទៅកាន់ក្រសួងការបរទេស ក៏ដូចជាស្ថានទូតឥណ្ឌា ដើម្បីសុំនាំពួកគេត្រឡប់ទៅប្រទេសឥណ្ឌាវិញ។ យុវជនទាំង៦នាក់នោះបានទៅប្រទេសកម្ពុជាតាមរយៈទិដ្ឋាការទេសចរណ៍។ ដើម្បីស្វែងរកការជួយសង្គ្រោះកូនៗ ឪពុកម្តាយរបស់យុវជនទាំងនោះក៏បានដាក់ពាក្យបណ្តឹងទៅស្នងការនគរបាល V. Satyanarayana កាលពីថ្ងៃទី១៩ ខែកញ្ញា។

នគរបាលបានកសាងសំណុំរឿងនិងកំពុងស៊ើបអង្កេត។ គេបានដឹងដែរថា ក្រុមហ៊ុនដែលមានមូលដ្ឋាននៅ Karimnagar បានបញ្ជូនយុវជន១៦ នាក់មកប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ។ នគរបាលកំពុងព្យាយាមស្វែងរកព័ត៌មានលម្អិតនៃយុវជនដែលនៅសេសសល់។ ខ្មែរថាមស៍ បានដឹងថា រហូតមកដល់ពេលនេះ ជនជាតិឥណ្ឌាជាង ៦០នាក់ ត្រូវបានជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ ត្រឡប់ទៅប្រទេសឥណ្ឌាវិញក្នុងរយៈពេលប៉ុន្មានសប្តាហ៍ថ្មីៗនេះ។ ប្រជាជនឥណ្ឌាត្រូវបានគេកំណត់គោលដៅដោយសារមានជំនាញ IT ឬភាសារបស់ពួកគេ ខណៈដែល Modus Operandi នៃប្រតិបត្តិករបោកប្រាស់បានផ្លាស់ប្តូរទិសដៅរបស់ពួកគេ។ លើសពីនេះ ក្រុមឆបោកកំពុងប្រមូលប្រាក់ជាមធ្យមចំនួន ៣,០០០ ដុល្លារសម្រាប់ជនជាតិឥណ្ឌាម្នាក់ៗដែលត្រូវបានជ្រើសរើសឲ្យធ្វើការងារដោយក្រុមបោកប្រាស់ទាំងនេះ។ ពួកគេថែមទាំងត្រូវបានផ្តល់សាច់ប្រាក់ចំនួន $១,០០០ ដើម្បីបង្ហាញជាភស្តុតាងដល់នាយកប្រតិបត្តិក្រុមហ៊ុនអាកាសចរណ៍មុនពេលឡើងយន្តហោះថាពួកគេមានប្រាក់គ្រប់គ្រាន់សម្រាប់ធ្វើដំណើរ។ ពេលមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សមាជិកក្រុមឆបោកកំណត់អត្តសញ្ញាណជនជាតិឥណ្ឌាបានយ៉ាងឆាប់រហ័ស ដែលជាធម្មតាពួកគេមកដល់ជាក្រុមមានគ្នាដល់ទៅ៦នាក់ លិខិតឆ្លងដែនរបស់ពួកគេត្រូវបានប្រមូល ហើយត្រូវបាននាំទៅកាន់គោលដៅផ្សេងៗ។

យោងតាមមន្ត្រីម្នាក់ដែលជាសមាជិកក្នុងការបង្ក្រាបទីតាំងខុសច្បាប់ទាំងនេះក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះ ជឿថាអាចមានជនជាតិឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដែស រហូតដល់ទៅ៤០០ នាក់ដែលស្ថិតនៅក្នុងកណ្តាប់ដៃក្រុមជនពាល ហើយពួកគេជាច្រើនក៏មានការស្ទាក់ស្ទើរក្នុងការចាកចេញពីកន្លែងទាំងនោះ ព្រោះពួកគេអាចរក

ប្រាក់ចំណូលបានច្រើនគួរសម ប្រសិនបើពួកគេអាចបំពេញតាមគោលដៅដែលបានដាក់អោយ ។ *Deccan Chronicle/Khmer Times*

## បច្ចុប្បន្នអ្នកបោកប្រាស់ស្វែងរកអ្នកដែលមានជំនាញភាសាអង់គ្លេស ខណៈដែលមានការផ្លាស់ប្តូរយ៉ាងរហ័សចំពោះគោលដៅសក្តានុពលដែលកំពុងកើតឡើង

https://www.khmertimeskh.com/501157140//?p=1157140 Kong Arey / Khmer Times September 24, 2022

កន្លងមក អ្នកដែលចេះភាសារអង់គ្លេសបានគួរសម ឬអ្នកដែលមិនអាចនិយាយភាសាអង់គ្លេសបាន ប៉ុន្តែអាចនិយាយគ្រាមភាសាចិនផ្សេងៗត្រូវបានគេកំណត់គោលដៅជ្រើសរើស ដោយក្រុមបោកប្រាស់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែ បច្ចុប្បន្នមានការផ្លាស់ប្តូរនៅក្នុងគំរូនៃការជ្រើសរើសជនទាំងនោះ។ ប្រភពដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតលើការងារខុសច្បាប់ទាំងនេះ បានប្រាប់ Khmer Times ក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះថា អ្នកនិយាយភាសាចិនដែលងាយស្រួលនឹងត្រូវបានគេបោក គឺជាគោលដៅដំបូងរបស់ក្រុមបោកប្រាស់ ដូចជា បន្លំទាក់ទងក្នុងន័យស្នេហា ការគំរាមកំហែង ការជួញដូរគ្រឿបតូ និងសកម្មភាពលេងល្បែងអនឡាញខុសច្បាប់។

មន្ត្រីម្នាក់បានប្រាប់ខ្មែរថាមស៍ថា ដូចនេះ អ្នកដែលត្រូវបានគេជ្រើសរើសគឺមានភាពស្ទាត់ជំនាញក្នុងភាសា។ ប៉ុន្តែឥឡូវនេះ គំរូបានផ្លាស់ប្តូរយ៉ាងខ្លាំង។ "គោលដៅសម្រាប់អ្នកបោកប្រាស់ឥឡូវនេះគឺពួកលោកខាងលិចជាពិសេសអ្នកចូលនិវត្តន៍នៅសហរដ្ឋអាមេរិក អឺរ៉ុប និងអូស្ត្រាលី។ សម្រាប់គោលបំណងនេះ ជនឆបោកទាំងនោះកំពុងត្រូវបានផ្តល់ការលើកទឹកចិត្តបន្ថែម ដើម្បីទាក់ទាញអ្នកដែលមានចំណេះដឹងភាសាអង់គ្លេស ឱ្យចូលរួមក្នុងប្រតិបត្តិការនេះ។ មន្ត្រីរូបនេះបាននិយាយថា "ដូច្នេះហើយអ្នកដែលត្រូវបានគេជ្រើសរើសមកពីប្រទេសសិង្ហបុរី ឥណ្ឌា ស្រីលង្កា ប៉ាគីស្ថាន និងបង់ក្លាដែស បានក្លាយជាគោលដៅ ព្រោះជាទូទៅពួកគេស្ទាត់ជំនាញភាសាអង់គ្លេស។ ក្នុងចំណោមក្រុមដែលត្រូវបានចាប់ខ្លួនដោយក្រុមការងារដែលជាប់ពាក់ព័ន្ធក្នុងប្រតិបត្តិការឆបោកនោះ ជនជាតិសិង្ហបុរីជាងមួយក្តាប់តូចក៏ត្រូវបានចាប់ខ្លួនផងដែរ ហើយកំពុងត្រូវបានដំណើរការនីតិវិធីសម្រាប់ការបញ្ជូនទៅវិញ។

លោកស្រីបានបន្ថែមថា រហូតមកដល់ពេលនេះ ជនជាតិឥណ្ឌាជាង ៦០នាក់ ត្រូវបានជួយសង្គ្រោះ ឬរត់គេចខ្លួន ដោយទទួលបានជំនួយពីបុគ្គលដែលត្រូវបាកគេបោកប្រាស់ផ្សេងទៀត ហើយមានជនជាតិជាច្រើនទៀតធ្លាក់ទៅក្នុងសកម្មភាពខុសច្បាប់ទាំងនេះ ដោយសារតែការទាក់ទាញរបស់ប្រាក់ដុល្លារ ធៀបទៅនឹងរូបិយប័ណ្ណនៅក្នុងប្រទេសពួកគេដែលមានតម្លៃទាបជាង។ លោកស្រីក៏បានពន្យល់ពីមូលហេតុដែលពួកលោកខាងលិចដែលបានចូលនិវត្តន៍ ត្រូវបានគេកំណត់គោលដៅ ខណៈដែលពួកគេជឿថាអ្នកទាំងនេះមិនសូវមានទំនោរក្នុងការរាយការណ៍អំពីការឆបោកនោះទេ ហើយដោយសារតែពួកគេខ្វះចំណេះដឹងផ្នែក IT ថែមទាំងរីករាយនឹងផ្តល់ព័ត៌មានលម្អិតហិរញ្ញវត្ថុផ្ទាល់ខ្លួនដល់ពួកបោកប្រាស់ រាប់ចាប់ពីប្រតិបត្តិករមជ្ឈមណ្ឌលហៅទូរសព្ទ រួមទាំងបន្លំធ្វើមន្ត្រីធនាគារ និងមន្ត្រី IRD ជាដើម។ លោកស្រីបានសង្កត់ធ្ងន់ថា "ពួកលោកខាងលិចដែលជិតចូលនិវត្តន៍ជាច្រើននាក់ក៏បានធ្លាក់ខ្លួនជាជនរងគ្រោះស្នេហាឆបោក និងការបន្លំរូបិយប័ណ្ណគ្រីបតូផងដែរ"៕

## ភាពព្រងើយកន្តើយ និងកង្វះភាពយកចិត្តទុកដាក់ក្នុងចំណោមស្ថានទូតមួយចំនួន បានរារាំងដល់ការសង្គ្រោះជនរងគ្រោះដែលត្រូវបានគេឆបោកនៅកម្ពុជា

https://www.khmertimeskh.com/501157222//?p=1157222 ខ្មែរថាមស៍ September 24, 2022

មន្ត្រីជាន់ខ្ពស់ ដែលពាក់ព័ន្ធនឹងការបង្ក្រាបទីតាំងឆបោកក្នុងប្រទេសកម្ពុជាបានបង្ហើបប្រាប់ខ្មែរថាមស៍ថា ស្ថានទូតបរទេសមួយចំនួននៅភ្នំពេញស្ទាក់ ស្ទើរក្នុងការផ្ដល់ព័ត៌មានដល់មន្ត្រី ដោយផ្អែកលើហេតុផលផ្សេងៗ។ មន្ត្រីរូបនេះបន្តថា ទាំងនេះរារាំងដល់ប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះ ដូចជានៅតាមទីតាំងជាក់លាក់ នៅពេលដែលការវាយឆ្មក់ត្រូវបានធ្វើឡើង ជាពិសេសការវាយឆ្មក់គោលដៅស្វែងរកជនជាតិដែលបានកំណត់ ទន្ទឹមនឹងនេះ ជនជាតិផ្សេងទៀតក៏ត្រូវបានរកឃើញដែរ ប៉ុន្តែពួកគេមិនព្រមចាកចេញ ដោយបានបង្ហាញកិច្ចសន្យាការងារ ឯកសារធ្វើដំណើរ និងការងារត្រឹមត្រូវ និង មានការតាំងចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការបន្តធ្វើការរបស់ពួកគេ ដែលត្រូវបានជួល។ មន្ត្រីរូបនេះបាននិយាយថា "សេចក្ដីថ្លែងការណ៍នាពេលថ្មីៗនេះរបស់ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីនៃការបង្កើតក្រុមការងារការទូតរួមគ្នា ដើម្បីធ្វើការចែករំលែកព័ត៌មាន និងផ្លាស់ប្ដូរព័ត៌មានបែបនេះ អាចជាដំណោះស្រាយចំពោះកាលទេសៈដែលយើងប្រឈម បន្ទាប់មកយើងនឹងមានស្ថានទូតគាំទ្រចំពោះសកម្មភាពរបស់យើង"។

លោកបានបន្ថែមថា ខណៈដែលការផ្ដល់យោបល់នេះ គឺជាការផ្លាស់ប្ដូរដ៏សំខាន់ក្នុងទិសដៅត្រឹមត្រូវ វាក៏មានសារៈសំខាន់ផងដែរសម្រាប់ស្ថានទូតនានាធ្វើការជាមួយយើង ជាពិសេសមន្ត្រីអនុវត្តច្បាប់ ព្រោះពួកគេអាចផ្ដល់មានព័ត៌មានជាក់លាក់បន្ថែមទៀត ជាពិសេសអំពីទីតាំង និង លេខទូរសព្ទ។ "ជាច្រើនដង យើងបានចេញបង្ក្រាបខុសទីតាំង និងកូអរដោនេ GPS ដែលទទួលបាន។ ទាំងនេះប៉ះពាល់ដល់ប្រតិបត្តិការរបស់យើង ដោយសារមានទិដ្ឋភាពជាច្រើនដែលត្រូវពិនិត្យមើល មុនពេលការវាយឆ្មក់ត្រូវបានចាប់ផ្ដើម។ លោកបានបន្ថែមថា "ដោយគ្រាន់តែផ្សព្វផ្សាយ និងជូនដំណឹងណែនាំដល់ជនជាតិខ្លួន ឱ្យមានការប្រយ័ត្នប្រយែងក្នុងការទទួលយកការងារពីក្រុមហ៊ុនដែលមិនមានប្រវត្តិត្រឹមត្រូវ គឺមិនគ្រប់គ្រាន់នោះទេក្នុងពេលបច្ចុប្បន្ននេះ ដើម្បីជៀសវាងការផ្សព្វផ្សាយអវិជ្ជមាន ពួកគេមិនបង្ហាញទីតាំង និងកូអរដោនេ GPS" ទេ។

បច្ចុប្បន្ននេះ លោកបានអះអាងថា ប្រតិបត្តិការរបស់ពួកគេត្រូវបានរារាំងដោយទទួលបានព័ត៌មានមិនពិត អាស្រ័យហេតុនេះ ជនពាលទាំងនោះបានចាកចេញទៅទីតាំងផ្សេងទៀតបាត់រួចទៅហើយ។ ទីតាំងមួយចំនួនដែលយើងដឹងច្បាស់ថាជាកន្លែងប្រតិបត្តិការល្បែងស៊ីសងតាមអ៊ីនធឺណិត ឬជាទីតាំងឆបោកត្រូវបានប្រែក្លាយយ៉ាងលឿនទៅកន្លែងកាត់ដេរ ឬខ្សែសង្វាក់ផលិតកម្មតូចៗផ្សេងទៀត ដែលមិនតម្រូវឱ្យមានគ្រឿងចក្រច្រើននោះទេ។ "ជនឆបោក និងប្រតិបត្តិករលេងល្បែងតាមអ៊ីនធឺណេត ជួនកាលមានផែនការលឿនជាងយើង ប៉ុន្តែយើងមានភាពវៃឆ្លាត និងកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើងពីស្ថានទូតមួយចំនួន ដូច្នេះហើយ អត្រាជោគជ័យមានកាន់តែច្រើន។ "ឧបសគ្គដ៏ធំបំផុតដែលយើងប្រឈមមុខគឺនៅពេលដែលយើងទៅដល់ទីតាំងត្រឹមត្រូវ កម្មករជាច្រើននៅក្នុងបរិវេណនោះបដិសេធយ៉ាងខ្លាំងក្នុងការធ្វើមាតុភូមិនិវត្តន៍ ដោយសារពួកគេមានឯកសារត្រឹមត្រូវដូចជា លិខិតឆ្លងដែន ប័ណ្ណការងារ ទិដ្ឋាការជាដើម យើងមិនអាចចាប់ខ្លួន ឬ ឃាត់ខ្លួនពួកគេដើម្បីបញ្ជូនទៅវិញនោះទេ»៕

## ជនជាតិខ្មែរ និងចិន ១៩នាក់ ត្រូវបានឃាត់ខ្លួនពាក់ព័ន្ធករណី បង្ខាំងមនុស្សខុសច្បាប់នៅខេត្តព្រះសីហនុ

https://thmeythmey.com/?page=detail&id=119510 25, Sep 2022 , 12:19 pm ដោយ: ឈុំ ចន្ថា

ភ្នំពេញ៖ ជនជាតិខ្មែរ និងចិនចំនួន១៩នាក់ ត្រូវបានឃាត់ខ្លួនពាក់ព័ន្ធនឹងករណីបង្ខាំងមនុស្សខុសច្បាប់នៅខេត្តព្រះសីហនុ។ ការឃាត់ខ្លួនមនុស្សទាំង១៩នាក់នេះ ត្រូវបានធ្វើឡើងក្រោយមានជនរងគ្រោះម្នាក់ប្ដឹងតាមទំព័រហ្វេសបុករបស់សម្ដេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រះសីហនុ នៅល្ងាចថ្ងៃទី២៤កញ្ញា ជនសង្ស័យចំនួន ១៩នាក់ ក្នុងនោះមានជនជាតិចិន១១នាក់ និងខ្មែរ៨នាក់ ត្រូវបានឃាត់ខ្លួនពាក់ព័ន្ធនឹងករណីបង្ខាំងមនុស្សខុសច្បាប់នៅក្នុងសណ្ឋាគារថាមពលថ្មី ស្ថិតក្នុងភូមិ១ សង្កាត់៣ ក្រុងព្រះសីហនុ។ ជាមួយគ្នានេះ អាជ្ញាធរខេត្តព្រះ

សីហនុ បានបន្តប្រតិបត្តិការពិនិត្យទីតាំងក្រុមហ៊ុន ហ្គាឡាក់ស៊ីវើល មួយទៀតស្ថិតក្នុងភូមិ៤ សង្កាត់លេខ៤ ដោយរកឃើញជនបរទេសសរុប៤១៤នាក់ ស្រី៤២នាក់ ក្នុងនោះជនជាតិចិនចំនួន៣៥១នាក់ ស្រីចំនួន៣០នាក់ ឡាវចំនួន២នាក់ ស្រីទាំង២នាក់ វៀតណាមចំនួន៤៦នាក់ ស្រី១០នាក់ ម៉ាឡេស៊ី ចំនួន១០នាក់ និងឥណ្ឌា៥នាក់។ ក្នុងចំណោមជនបរទេសទាំង៤១៤នាក់ មាន១៦៨នាក់ ត្រូវបានរកឃើញស្នាក់នៅនិងធ្វើការដោយ គ្មានឯកសារត្រឹមត្រូវ ខណៈជនបរទេសចំនួន២០៨នាក់ទៀត ត្រូវផាកពិន័យ ចំនួន១០៤លានរៀល។ ជនបរទេសដែលបានផាកពិន័យរួច គឺតម្រូវឱ្យស្នើបណ្ណការងារថ្មី ដែលប្រមូលបានអាករសរុប ៦០,៣១០ដុល្លារ។

ដោយឡែក ចំពោះនិយោជក ឬសហគ្រិន គ្មានលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មជនបរទេសខុសពីមាត្រា២៦៤នឹងត្រូវពិន័យតាមមាត្រា៣៦៩នៃច្បាប់ស្តីពីការងារគិតជាទឹកប្រាក់ពិន័យសរុប២,៥២០,០០០រៀល។ ក្នុងករណីប្រើប្រាស់ជនបរទេសគ្មានបណ្ណការងារ លើសពី០៥នាក់ គឺខុសនឹងមាត្រា៣៧២ និងត្រូវពិន័យតាមមាត្រា ៣៧២ នៃច្បាប់ស្តីពីការងារ មានទឹកប្រាក់ពិន័យសរុប ១២,៦០០,០០០រៀល។ ទូទាត់ប្រាក់ឈ្នួល ដែលនៅសល់ ជូនកម្មករ-និយោជិតសរុបចំនួន១០៤នាក់ មានទឹកប្រាក់សរុបចំនួន ២៧,៧៩៦ដុល្លារ គិតត្រឹមថ្ងៃទី២០ ខែកញ្ញា នឹងបន្តទទួលខុសត្រូវករណីមានបណ្តឹងបន្ថែមទៀត។

ពាក់ព័ន្ធបញ្ហានេះ អាជ្ញាធរខេត្តព្រះសីហនុ បានសម្រេចដាក់វិធានការមួយចំនួន ដោយតម្រូវឱ្យជនបរទេសដែលបានបំពេញនីតិវិធីគ្រប់លក្ខខណ្ឌ និងបានធ្វើកិច្ចសន្យារួចរាល់ ឱ្យចាកចេញពីក្នុងទីតាំងឱ្យអស់ត្រឹមថ្ងៃបញ្ចប់ប្រតិបត្តិការណ៍។ បិទទីតាំង និងសេវាកម្ម អាជីវកម្មទាំងអស់ក្នុងទីតាំងដី និងអគារក្រុមហ៊ុន ហ្គាឡាក់ស៊ីវើល លើកលែងតែអាហារដ្ឋាន។ អនុញ្ញាតឱ្យដំណើរការសេវាកម្មម្ហូបអាហារ រហូតដល់ជនបរទេសទាំងអស់ចាកចេញអស់ពីទីតាំង និងបញ្ចប់ប្រតិបត្តិការណ៍។ បិទអគារ A C និងE ដើម្បីបន្តការស៊ើបអង្កេតបទល្មើសផ្សេងៗ ដែលចាំបាច់រហូតដល់កិច្ច ស៊ើប អង្កេតត្រូវបានបញ្ចប់ទាំងស្រុង។ សេចក្តីជូនដំណឹងដដែល បញ្ជាក់ថា រដ្ឋបាលខេត្តព្រះសីហនុ នឹងបន្តត្រួតពិនិត្យរដ្ឋបាលតាមបណ្តាទីតាំងអាជីវកម្មដែល សង្ស័យមិនមានច្បាប់អនុញ្ញាត ព្រមទាំងចាត់វិធានការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ចំពោះម្ចាស់អាជីវកម្ម ក្នុងករណីរកឃើញ បទល្មើស រហូតដល់ភូមិសាស្ត្រខេត្តព្រះសីហនុទាំងមូលលែងមានបញ្ហាទាំងនេះ៕

## កម្លាំងសមត្ថកិច្ចខេត្តព្រះសីហនុ បើកប្រតិបត្តិការរដ្ឋបាលនៅទីតាំង «ជីងឆាយតិចណូឡូជី» រកឃើញពាក់ព័ន្ធបទល្មើសល្បែងអនឡាញខុសច្បាប់, ជួញដូរមនុស្ស និងសញ្ជារកម្ម

http://freshnewsasia.com/index.php/en/localnews/258546-2022-09-25-05-29-23.html 2022-09-25 12:29pm

**(ព្រះសីហនុ)៖** កម្លាំងគណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ បានបើកប្រតិបត្តិការរដ្ឋបាលរយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ នៅទីតាំងឈ្មោះ **«ជីងឆាយតិចណូឡូជី»** ចំនួន៨អគារ នៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ និងរកឃើញថាពាក់ព័ន្ធបទល្មើសល្បែងអនឡាញខុសច្បាប់, បទល្មើសជួញដូរមនុស្ស និងបទល្មើសសញ្ជារកម្ម។ ក្នុងសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រះសីហនុ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២នេះ បានបញ្ជាក់ថា ទីតាំងមានអគារចំនួន០៨ អគារ (អគារលេខ០៦ កំពស់១០ជាន់ អគារលេខ០៧ កំពស់០៩ជាន់ អគារលេខ០៨ កំពស់០៩ជាន់ អគារលេខ០៩ កំពស់០៥ជាន់ អគារលេខ១០ កំពស់០៨ជាន់ អគារលេខ១១ កំពស់០៩ជាន់ អគារលេខ១២ កំពស់១៧ជាន់ និងអគារលេខ១៣ កំពស់០៤ជាន់)។

ក្នុងប្រតិបត្តិការរយៈពេល៣ថ្ងៃនេះ កម្លាំងចម្រុះដឹកនាំដោយគណៈបញ្ជាការឯកភាពខេត្ត បានរកឃើញជនបរទេសសរុប ៤៦៩នាក់ ស្រី៧៥នាក់ មានចំនួន១០សញ្ជាតិ ជនជាតិចិន ចំនួន២៧៤នាក់ ស្រី៣៣នាក់, ជនជាតិ

ចិនតៃវ៉ាន់ ចំនួន០៦នាក់, ជនជាតិវៀតណាម ចំនួន១៥៨នាក់ ស្រី៣៤នាក់, ជនជាតិម៉ាឡេស៊ី ចំនួន១៥នាក់ ស្រី០២នាក់, ជនជាតិឥណ្ឌូនេស៊ី ចំនួន០៣នាក់ ស្រី០២នាក់, ជនជាតិឥណ្ឌា ចំនួន០៤នាក់ ជនជាតិថៃ ចំនួន០៣នាក់ ស្រី០១នាក់, ជនជាតិបង់ក្លាដេស ចំនួន០១នាក់, ជនជាតិមីយ៉ាន់ម៉ា ចំនួន០១នាក់ ស្រី០១នាក់ និងជនជាតិរុស្ស៊ី ចំនួន០២នាក់ ស្រី០២នាក់។ ជនបរទេសខុសច្បាប់អន្តោប្រវេសន៍ សរុបចំនួន២៣៦នាក់ ស្រី៣២នាក់ មាន០៨សញ្ញាតិ ក្នុងនោះជនជាតិចិន ចំនួន៩៩នាក់ ស្រី០៦នាក់ តៃវ៉ាន់ ចំនួន០២នាក់ វៀតណាម ចំនួន១២២នាក់ ស្រី២៤នាក់ ម៉ាឡេស៊ី ០៥នាក់ ថៃ០៣នាក់ ស្រី០១នាក់ បង់ក្លាដេស ០១នាក់ មីយ៉ាន់ម៉ា ០១នាក់ (ស្រី) ឥណ្ឌា ០៣នាក់។

**បន្ទាប់ពីសមត្ថកិច្ចជំនាញផ្នែកការងារ និងសមត្ថកិច្ចជំនាញផ្នែកអន្តោប្រវេសន៍ បានធ្វើការសាកសួរព័ត៌មាន និងពិនិត្យឯកសារពាក់ព័ន្ធនានា ដែលលើជនបរទេសសរុបចំនួន ៤១៤នាក់ មានជនបរទេស ជាស្រីចំនួន៤២នាក់ ឃើញថា៖**

* រកឃើញជនបរទេសបម្រើការងារមិនមានប័ណ្ណការងារមាន ចំនួន២៣៦នាក់ (ស្រី ៣៩នាក់) បានផាកពិន័យ ចំនួន២៣៦នាក់ (ស្រី៣៩នាក់) និងប្រមូលអាករពីការធ្វើប័ណ្ណការងារ បានថវិកាសរុប ចំនួន១១៨លានរៀល។

* មានប័ណ្ណការងារ ចំនួន៣៥នាក់ (ស្រី០៨នាក់) ជនបរទេសដែលមិនមានលិខិតឆ្លងដែន និងកំពុងស្នាក់នៅក្នុងទីតាំងហ្គាឡាក់ស៊ីវើល មានចំនួន១៦៨នាក់ ស្រីចំនួន ១៧នាក់ ក្នុងនោះមានសញ្ញាតិចិន ចំនួន១៣០នាក់ ស្រីចំនួន០៨នាក់ វៀតណាមចំនួន៣៣នាក់ ស្រីចំនួន០៧នាក់ ម៉ាឡេស៊ីចំនួន០៣នាក់ និងឡាវ០២នាក់ ស្រី០២នាក់។

**ជាលទ្ធផលក្នុងប្រតិបត្តិការត្រួតពិនិត្យរដ្ឋបាលទីតាំងខាងលើ កម្លាំងជំនាញកំណត់បានសញ្ញាណពាក់ព័ន្ធនឹងបទល្មើសចំនួន៣រួមមាន បទល្មើសល្បែងអនឡាញខុសច្បាប់ បទល្មើសជួញដូរមនុស្ស និងបទល្មើសសញ្ជារកម្ម។ ដោយទទួលបានគោលការណ៍ដ៏ខ្ពង់ខ្ពស់ពី សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងគោលការណ៍ឯកភាពគ្នាជារួមពីជំនាញពាក់ព័ន្ធ គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុសម្រេចដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

* ធ្វើកិច្ចសន្យាអប់រំដល់ជនបរទេសដែលស្របច្បាប់ និងជនបរទេស ដែលបានផាកពិន័យអន្តោប្រវេសន៍ និងផ្តល់ប័ណ្ណការងាររួចរាល់ អនុញ្ញាតអោយចាកចេញពីទីតាំងទៅរកកន្លែងថ្មី។

* បិទអាជីវកម្មទាំងអស់ ដែលស្ថិតក្នុងបរិវេណទីតាំងឈ្មោះជើង ឆាយ តិចណូឡូជី (ហៅ ជីងឆ្វាយ០៥) លើកលែងតែអាហារដ្ឋាន ដោយផ្តល់ការសម្រេចចិត្តពីម្ចាស់ទីតាំងអាជីវកម្មអាហារដ្ឋាន លើការចាកចេញ ឬបន្តអាជីវកម្ម។

* បិទជាបណ្តោះអាសន្ននូវអគារលេខ០៦ (ជាន់ទី៥,៧,៨,៩) អគារលេខ០៧ (ជាន់ទី៣,៨,៩) អគារលេខ០៨ (ជាន់ទី៣,៥, ៦,៨,៩,១០) អគារលេខ០៩ (បន្ទប់មេការខាវ៉ាអូខេ ០១បន្ទប់) អគារលេខ១០ (ជាន់ទី៧,៨,៩) និងអគារលេខ១១ (ជាន់ទី៥,៧,៨,៩,១០)

* ប្រគល់ជូនគណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ រក្សាទុកសម្ភារៈ ទ្រព្យសម្បត្តិដែលបានចាប់យកក្នុងពេលប្រតិបត្តិការ។

* ជំនាញ នៃនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម កសាងសំណុំរឿងពាក់ព័ន្ធល្បែងអនឡាញខុសច្បាប់ បញ្ជូនទៅតុលាការ និងបន្តស៊ើបអង្កេតបទល្មើសសម្អាតប្រាក់។

* ជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុកសាងសំណុំរឿងបទល្មើសជួញដូរមនុស្ស បទល្មើសញ្ញារកម្ម បញ្ជូនជនសង្ស័យ ចំនួន ០៥នាក់ទៅតុលាការ និងបន្តស៊ើបអង្កេតបទល្មើសសម្លាតប្រាក់៕

## ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២

### សម្តេច ស ខេង ស្នើទូតចិនប្រចាំកម្ពុជា បន្តគាំទ្រ ដល់ការបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ

https://www.kampucheathmey.com/local-news/382611 ថ្ងៃអង្គារ ២៧ កញ្ញា ២០២២ដោយ sopheak khoun

សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា បានស្នើឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា បន្តគាំទ្រដល់ការបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ហើយអាជ្ញាធរកម្ពុជានឹងបន្តខិតខំស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបពួកឧក្រិដ្ឋជនទាំងនោះ ដែលមាននៅក្នុងប្រទេសកម្ពុជា។ ការស្នើនេះ គ្រាដែលសម្តេចក្រឡាហោម ស ខេង បានអនុញ្ញាតឲ្យលោក វ៉ាង វិនធាន ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា ចូលជួបពិភាក្សាការងារនៅរសៀលថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០២២នេះ។ នៅក្នុងជំនួបនេះសម្តេចក្រឡាហោម ស ខេង បានជម្រាបជូនលោកឯកអគ្គរដ្ឋទូតចិន នូវលទ្ធផលកិច្ចសហប្រតិបត្តិការ បង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ នារយៈពេលចុងក្រោយ ដោយសម្តេចបន្ថែមថា រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងមហាផ្ទៃ មានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីមិត្ត ព្រមទាំងបណ្តាភាគីមិត្តក្នុងតំបន់ទាំងអស់ដែរ។ សម្តេចក្រឡាហោម បានបន្ថែមថា ដើម្បីជំរុញដល់ដំណើរការប្រតិបត្តិការនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានសម្រេចបង្កើតយន្តការសំខាន់ៗ រួមមាន៖ ការបង្កើតក្រុមការងារបង្ក្រាបល្បែងស៊ីសងខុសច្បាប់, ក្រុមការងារប្រតិបត្តិការអង្កេត និងស្រាវជ្រាវ, និងក្រុមការងារត្រួតពិនិត្យក្រុមពលករហត្ថពលម្នបរទេសនៅកម្ពុជា ផងដែរ។

សម្តេចក្រឡាហោម បានបញ្ជាក់ថា កម្ពុជា ក៏ជាប្រទេសរងគ្រោះដោយសារការឆ្លៀតឱកាសកេងប្រយោជន៍ពីចំណុចខ្វះខាតមួយចំនួន ពីសំណាក់ក្រុមជនទុច្ចរិត ដើម្បីប្រព្រឹត្តបទល្មើស។ សម្តេច ក៏អរគុណចំពោះកិច្ចសហប្រតិបត្តិការ ពិសេសការផ្តល់កិច្ចសហប្រតិបត្តិការឲ្យគ្នាទៅវិញទៅមក ក្នុងការបង្ការ និងបង្ក្រាបបទល្មើសប្រភេទនេះ នាពេលកន្លងមកជាមួយភាគីចិន។ សម្តេច ស ខេង ក៏បានស្នើភាគីចិនបន្តគាំទ្រការងារនេះ តាមរយៈការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបមេក្លោងនៅក្នុងប្រទេសសាមី ដែលពួកគេមានបណ្តាញទំនាក់ទំនងប្រព្រឹត្តបទល្មើសឆ្លងដែនខុសច្បាប់ ហើយកម្ពុជានឹងបន្តខិតខំស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបពួកឧក្រិដ្ឋជនទាំងនោះ ដែលមាននៅក្នុងប្រទេសកម្ពុជា។ សម្តេច បានរំលឹកទៀតថា កាលពីពេលថ្មីៗនេះ ដែលមានការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន សម្តេចក៏បានលើកឡើងបញ្ហានេះទៅកាន់អង្គប្រជុំ និងបានគូសបញ្ជាក់អំពីសារៈសំខាន់ នៃការរួមគ្នាឈានទៅកាត់ផ្តាច់បណ្តាញឧក្រិដ្ឋជន បង្ក្រាប ចាប់ខ្លួនជនល្មើសមកផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ជាការឆ្លើយតបលោកឯកអគ្គរដ្ឋទូតចិន បានថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ របស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងមហាផ្ទៃលើករណីនេះ និងបានអរគុណសម្តេចក្រឡាហោម ដែលបានបង្កើតក្រុមការងារ និងមធ្យោបាយនានា សម្រាប់ស្ថានទូត ឬអ្នកពាក់ព័ន្ធអាចផ្តល់នូវព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងករណីបទល្មើសឆ្លងដែនផ្សេងៗដើម្បីមានកិច្ចអន្តរាគមន៍។ លោក វ៉ាង វិនធាន ក៏បានជម្រាបជូនសម្តេចដែរថាស្ថា នទូតចិនបានធ្វើការងារនេះ ដោយបន្តជំរុញការផ្សព្វផ្សាយអំពីព័ត៌មានទាំងនេះ ទៅដល់បណ្តាញផ្សព្វផ្សាយ ក៏ដូចជាសាធារណជននានា

ឲ្យបានដឹងពីមធ្យោបាយ និងព័ត៌មានមកខាងអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា តាមរយៈគេហទំព័រហ្វេសប៊ុក ឬប្រព័ន្ធទូរសព្ទHot Line ដែលបានផ្សព្វផ្សាយកន្លងមក។ លោកក៏បានថ្លែងអំណរគុណការយកចិត្តទុកដាក់របស់អាជ្ញាធរកម្ពុជា ដែលបានធ្វើកិច្ចអន្តរាគមន៍ជួយសង្គ្រោះពលរដ្ឋចិនរងគ្រោះក្នុងករណីកន្លងមក និងសូមអរអបសាទរចំពោះលទ្ធផលជាវិជ្ជមាន នៃកិច្ចសហប្រតិបត្តិការដ៏មានសារៈសំខាន់នេះ។

លោកក៏ត្រៀមខ្លួនផ្តល់កិច្ចសហការ និងសំណូមពរផ្សេងៗរបស់ភាគីកម្ពុជា ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងបទល្មើស ក៏ដូចជាជនល្មើសដែលពាក់ព័ន្ធ។ សម្ដេចក្រឡាហោម បានថ្លែងអំណរគុណការប្តេជ្ញាចិត្តរបស់លោកឯកអគ្គរដ្ឋទូត និងរដ្ឋាភិបាលចិន នៅក្នុងការងារទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទនេះ ដោយចាត់ទុកថា ជាមូលដ្ឋានរឹងមាំ និងសំខាន់មិនអាចខ្វះបាន ដើម្បីរួមគ្នាក្នុងក្នុងបេសកកម្មនេះ ព្រមទាំងលុបបំបាត់ការផ្សព្វផ្សាយនានា ដែលខុសពីភាពជាក់ស្តែងនៅកម្ពុជា៕

## អ្នកនាំពាក្យក្រសួងមហាផ្ទៃ ម៉ៅ ចាន់ម៉ូ សមត្ថកិច្ចកម្ពុជាទទួលបានបណ្ដឹង ០២ទៀត ដែលស្នើឱ្យសង្គ្រោះជនបរទេស

http://freshnewsasia.com/index.php/en/localnews/258619-2022-09-26-13-27-42.html 2022-09-26 08:27pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០នាថ្ងៃទី២៤ ដល់វេលាម៉ោង ៣៖០០ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញ សមត្ថកិច្ចកម្ពុជា បានទទួលសំណើ ០២ករណីទៀត ដែលស្នើឱ្យសង្គ្រោះជនបរទេស ០៧នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង ០២ករណីនេះ រួមមាន៖ ស្នើឱ្យសង្គ្រោះជនជាតិវៀតណាមចំនួន ០៧នាក់។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២១ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៣៣៧ករណី មានមនុស្ស ៨០៥នាក់ មាន ១១សញ្ជាតិ។

២៖ ស្រាវជ្រាវអង្កេតបឋមបាន ១៣៧សំណើ នៅសល់ ១៧៥សំណើ (រកឃើញ ១៦២នាក់, ឃាត់ខ្លួន ៥៣នាក់, បិទក្រុមហ៊ុន ១ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៥ទីតាំង)។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## សង្គមស៊ីវិលថាពលករខ្មែរទៅធ្វើការនៅប្រទេសថៃ នៅតែប្រឈមនឹងចៅហ្វាយថៃកេងប្រវ័ញ្ចកម្លាំងពលកម្ម

https://www.rfa.org/khmer/news/human-rights/cambodia-migration-workers-09222022050006.html ដោយ អាស៊ីសេរី2022.09.22

សង្គមស៊ីវិលថាពលករខ្មែរធ្វើការនៅប្រទេសថៃ នៅតែប្រឈមនឹងថៅកែថៃកេងប្រវ័ញ្ចកម្លាំងពលកម្ម និងត្រូវអាជ្ញាធរថៃចាប់ខ្លួនដាក់ពន្ធនាគារដោយអយុត្តិធម៌។ មន្ត្រីសង្គមស៊ីវិលនិងពលករខ្មែរ មើលឃើញថា ទុក្ខលំបាករបស់ពលករនេះកើតឡើងដោយសារខ្វះការជួយអន្តរាគមន៍ពីរដ្ឋាភិបាលនិងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ។ មន្ត្រីសង្គមស៊ីវិលលើកឡើងថាពលរដ្ឋចំណាកស្រុកទៅធ្វើការនៅប្រទេសថៃមួយចំនួន តែងរងការរើសអើងធ្វើបាបគ្រោះថ្នាក់ចរាចរ ការចោទប្រកាន់ ការកេងប្រវ័ញ្ចកម្លាំងពលកម្មពីថៅកែ និងអាជ្ញាធរថៃចាប់ខ្លួនដាក់ពន្ធនាគារជាដើម។ សាច់ញាតិ និងក្រុមគ្រួសារពលករ តែងជួបទុក្ខលំបាកជីវភាព ក្រោយមេគ្រួសារ និងសមាជិកគ្រួសាររបស់ពួកគេត្រូវបានអាជ្ញាធរថៃ ឃុំខ្លួន ឬចាប់ខ្លួនដោយគ្មានការគាំពារពីអាជ្ញាធរខ្មែរឱ្យបានទាន់ពេលនោះ ឡើយ។

មន្ត្រីគម្រោងនៃអង្គការសង់ត្រាល់ប្រចាំប្រទេសថៃលោក លឹង សុផុន លើកឡើងថា លោកតែងចុះសាកសួរនៅពេលពលករជួបបញ្ហាផ្សេងៗនៅប្រទេសថៃនៅពេលលោកទទួលបានព័ត៌មានពីពលករ។ លោកបន្តថា ពលករខ្មែរប្រឈមបញ្ហាជាច្រើន រួមមានការកេងប្រវ័ញ្ចកម្លាំងពលកម្ម ពីសំណាក់ថៅកែថៃ ឱ្យធ្វើការលើសម៉ោង មិនបើកប្រាក់ឈ្នួល និងការចោទប្រកាន់ក្នុងរូបភាពផ្សេងៗគ្នា ហើយប្រឈមខ្លាំង គឺពលករដែលឆ្លងដែនទៅធ្វើការដោយខុសច្បាប់។ លោកបន្តទៀតថា ពលករតែងត្អូញត្អែរពីការធ្វើឯកសារការងារមានតម្លៃថ្លៃ ហើយកង្វះខាតការងារធ្វើមួយរយៈចុងក្រោយនេះ។ លោក លឹង សុផុន សង្កេតឃើញថា ការងារក្នុងប្រទេសថៃមានការថយចុះ ។

លោក លឹង សុផុន បញ្ជាក់ថា ពលករមួយចំនួនតែងរងការចោទប្រកាន់ និងត្រូវថៅកែថៃប្ដឹងចាប់ដាក់ពន្ធនាគារនៅប្រទេសថៃ។ លោកថា បញ្ហាទាំងនេះភាគច្រើនកើតឡើងដោយសារ ពលករគ្មានចំណេះដឹងផ្លូវច្បាប់ និងខ្វះការជួយអន្តរាគមន៍ពីរដ្ឋាភិបាលខ្មែរមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ «បន្ទាប់ពីបានសម្ភាសន៍សួរនាំគ្រួសារដែលគេយកប្ដីទៅចាប់ដាក់គុកទៅ ខ្ញុំក៏បានអោយគាត់ទៅឆែកមើលលេខឯកសារដែលគេចោទប្រកាន់ហ្នឹងហាស។ តាពិតពួកខ្ញុំទៅ ហើយនឹងក្រុមការងារទៅហ្នឹង តុលាការហ្នឹងបានសម្រេចកាត់ទោសអោយជាប់គុក១៨ខែ ។ ខាងស្ថាប័នរដ្ឋដូចជាខាងស្ថានទូត និងអនុព័ន្ធការងារអីក៏បានដឹងរឿងហ្នឹងដែរ ខ្ញុំបាននិយាយជាមួយគាត់ដែររឿងហ្នឹងដែរ តែមិនដឹងថា គាត់នឹងជួយរកវិធីដោះស្រាយជួយដល់បងប្អូនពលករយ៉ាងម៉េច ខ្ញុំអត់ទាន់ដឹងច្បាស់នៅឡើយ»។

ដោយឡែក ប្រពន្ធពលករជាប់ឃុំ លោក ជ័យ មុំ គឺលោកស្រី ម៉េត បូរី ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី២១ ខែកញ្ញា លោកស្រីថា មកធ្វើការនៅប្រទេសថៃ ៧ឆ្នាំហើយ ដោយប្ដីលោកស្រី ត្រូវបាន ថៅកែថៃប្ដឹងឱ្យប៉ូលិសថៃចាប់ដាក់ពន្ធនាគារ១៨ខែ ដោយអយុត្តិធម៌ ព្រោះលោកស្រីថា មិនបានប្រព្រឹត្តខុសច្បាប់ដូចការចោទប្រកាន់របស់ថៅកែថៃឡើយ ។ លោកស្រីបន្តថា ពេលប្ដីត្រូវចាប់ខ្លួនលោកស្រី ធ្លាប់បានទូរស័ព្ទទាក់ទងទៅមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃដែរ ប៉ុន្តែគ្មានអ្នកទទួលឡើយ និងគ្មានការទាក់ទងពីអាជ្ញាធរខ្មែរណាមួយឡើយ។ លោកស្រីបន្តទៀតថា ក្រោយប្ដីជាប់ឃុំ គ្រួសារជួបការលំបាកច្រើន ព្រោះលោកស្រីត្រូវរ៉ាប់រងគ្រួសារ ចិញ្ចឹមកូន២នាក់អោយរៀនសូត្រនៅប្រទេសថៃ។ លោកស្រីស្នើសុំឲ្យស្ថានទូតខ្មែរជួយអន្តរាគមន៍ទៅអាជ្ញាធរថៃឱ្យដោះលែងប្ដីលោកស្រី ដើម្បីបាន ជួបជុំគ្រួសារ ដើម្បីសម្រាលទុក្ខលំបាក និងបន្តរស់នៅចិញ្ចឹមកូនៗ៖ « មេការឆោណា ទូរស័ព្ទប្រាប់ថៅកែខ្ញុំថា ប្ដីខ្ញុំយកដូងប្រេង(ប៉ាម)ទៅលក់ ដល់ពេលទៅឆែកតាមជញ្ជីង អត់មានទេ មានតែឈ្មោះមេការ(ហ៊ួណា)អត់មានឈ្មោះប្ដីខ្ញុំទេ។ មារឯងដឹងស្រាប់ហើយស្រុកថៃ កូនខ្មែរលក់ប៉ាម(ដូងប្រេង)អត់បានទេ។ លក់ដូងប្រេងយើងហ្នឹង ថៃគេហៅប៉ាម។ ចោទថាប្ដីខ្ញុំយកប៉ាមទៅលក់ ប្ដីខ្ញុំថាមិនបានលក់ទេ កូនខ្មែរលក់ម៉េចបានប្រទេសថៃនោះ។ ចាសចោទប្រកាន់ដដែល ដាក់គុក១ឆ្នាំ៦ខែ ១៨ខែដាក់គុកប្ដីខ្ញុំនោះ»។

ជុំវិញរឿងនេះ ប្រធានសមាគមពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា (CIREA) លោក ឌិន ពុទ្ធី យល់ឃើញថា កត្តាកង្វះការងារនៅប្រទេសកម្ពុជា គ្មានទីផ្សារកសិផលច្បាស់លាស់ នាំអោយពលរដ្ឋសម្រេចចិត្តចំណាកស្រុកទាំងប្រថុយប្រថាន និងប្រឈមទុក្ខលំបាក។ លោកបន្តថា ពលករធុញទ្រាន់និងការទំនាក់ទំនងទៅកាន់ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ព្រោះពិបាកទាក់ទង ហើយគ្មានការទទួលត្រូវ ដោយមានការរត់ការឯកសារពេលពលរដ្ឋទៅបញ្ជាក់ឯកសារម្តងៗ។ លោក ឌិន ពុទ្ធី អំពាវនាវដល់រដ្ឋាភិបាលក្នុងការសម្រួលឯកសារស្របច្បាប់តម្លៃសមរម្យ និងឆាប់រហ័សជូនពលរដ្ឋ និងត្រួតពិនិត្យទៅលើមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ ពាក់ព័ន្ធការរត់ការឯកសារ៖ «ទៅដល់កន្លែងណាក៏មានឈ្មួញកណ្តាលគួកជេរ ធ្វើបាបពលករ ហើយពលករ(គ្នា)ធ្វើការហើយចំណាយលុយយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅលើឯកសារហ្នឹង ហើយយឺតយ៉ាវទៀត។ ដល់ពេលអ៊ីចឹងធុញមិនចង់ធ្វើទេឯកសារហ្នឹង។ ពិបាកស្មុគស្មាញគ្រប់សព្វបែបយ៉ាង អ៊ីចឹងសុខចិត្តខុសច្បាប់ទៅ ដល់ពេលខុសច្បាប់ពលករហ្នឹង គឺរងគ្រោះបន្តៗហ្នឹង។ គេបញ្ជូនទៅនេះទៅនោះអ៊ីចឹង ទៅតាមតែអំពើចិត្ត ឬក៏យើងទៅធ្វើការងារចុះទូកចុះអីអ៊ីចឹងទៅ គ្រោះថ្នាក់គេសម្លាប់ចោលអ៊ីចឹងទៅ វាបញ្ហាច្រើនណាស់។ ពេលពលករ កម្មករមានបញ្ហាទៅរកកុងស៊ុលហ្នឹងស្តីអោយយើងទៀតហាស អោយយើងរកភស្តុតាង អាយើងរងគ្រោះ គេគាបសង្កត់យកលុយ គេកេងប្រវ័ញ្ច គេធ្វើបាប អោយរកភស្តុតាងទៀត ហើយទៅរកភស្តុតាងឯណា បើនៅកន្លែងគេហ្នឹង គេអោយយើងថតអី គេទាត់យើង២ ៣ ជើងអ្នកណាទៅថតគេបាន»។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងសុំការអត្ថាធិប្បាយជុំវិញបញ្ហានេះពីស្ថានទូតខ្មែរ និងមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ លោក ផៃ លន បានទេ នៅថ្ងៃទី២១ ខែកញ្ញា ដោយទូរស័ព្ទហៅចូលតែពុំមានអ្នកទទួល។ ប៉ុន្តែ ហ្វេសប៊ុករបស់អនុព័ន្ធការងារអមស្ថានទូតកម្ពុជានៅប្រទេសថៃ បានចុះផ្សាយពីការជួយដល់ពលករខ្មែរមានអគ្គីភ័យឆាបឆេះកន្លែងស្នាក់នៅរបស់ពលករចំនួន៣៦បន្ទប់ ស្ថិតនៅប្រធាអូធិត៦៩ ដែលធ្វើអោយខូចខាតសម្ភារៈប្រើប្រាស់៨០-៩០ភាគរយ ចំនួន១៨គ្រួសារ កាលពីថ្ងៃទី១០ ខែកញ្ញា ។ ពលករតែងតែរងការគាបសង្កត់ និងរំលោភសិទ្ធិជួបគ្រោះថ្នាក់ចរាចរ និងការរើសអើងគ្រប់រូបភាពពីថៅកែមួយចំនួនក្នុងប្រទេសថៃ ពិសេសកម្មករខុសច្បាប់ ដែលរងផលប៉ះពាល់ខ្លាំង។ ពលករខ្លះធ្លាក់ខ្លួនឈឺ ប៉ុន្តែមិនហ៊ានទៅពេទ្យឡើយ ដោយសារពួកគេធ្វើការងារខុសច្បាប់ក៏សុខចិត្តដេកឈឺនៅកន្លែងធ្វើការ។

មន្ត្រីសង្គមស៊ីវិលលោក លឹង សុផុន បន្តថា ពលករខ្មែរធ្វើការនៅប្រទេសថៃ តែងតែត្រូវបានថៅកែនិងជនជាតិថៃប្ដឹងអាជ្ញាធរថៃចាប់ដាក់ពន្ធនាគារជាច្រើនករណី ហើយភាគច្រើនពួកគេបានចាញ់ក្ដី និងជាប់ពន្ធនាគារដោយអយុត្តិធម៌។ លោកមើលឃើញថា បញ្ហាទាំងនេះកើតឡើងដោយសារតែពលករទាំងនោះគ្មានមេធាវីការពារក្ដីក្នុងតុលាការ។ កាលពីខែធ្នូឆ្នាំ២០២០មានពលករខ្មែរមួយគ្រួសារមានគ្នាបីនាក់ប្ដីប្រពន្ធនិងកូន ក៏ត្រូវបានថៅកែជំឡូងមីជនជាតិថៃនៅប្រាជីនបុរី (Prachinbori) យកកាំភ្លើងខ្លីបាញ់គំរាមសម្លាប់ ដោយសារខឹងពួកគេសុំច្បាប់ទៅលេងកម្ពុជាដែរ។ ថៅកែថៃ បានចោទប្រកាន់ពលករខ្មែរមួយគ្រួសារនោះថា ជំពាក់ប្រាក់ថ្លៃធ្វើលិខិតឆ្លងដែនមិនទាន់សងគ្រប់នៅឡើយ។ ប៉ុន្តែពលករខ្មែរអះអាងថា មូលហេតុដែលពួកគេសុំទៅកម្ពុជាដោយសារពួកគេធ្វើឱ្យថៅកែរូបនេះជាច្រើនខែមកហើយមិនបានប្រាក់ឈ្នួលឱ្យពួកគេនោះទេ។ របាយការណ៍អង្គការសង់ត្រាល់បង្ហាញថា សព្វថ្ងៃមានពលករខ្មែររស់នៅ និងធ្វើការនៅប្រទេសថៃ ទាំងស្របច្បាប់ និងមិនស្របច្បាប់មានប្រមាណជាងពីរលាន (២.០០០.០០០)នាក់ ៕

## អ្នកនាំពាក្យក្រសួងមហាផ្ទៃ៖ ម្សិលមិញ សមត្ថកិច្ចកម្ពុជាទទួលបានបណ្ដឹង ០៥ទៀត ដែលស្នើឱ្យសង្គ្រោះជនបរទេស ២៤នាក់

http://freshnewsasia.com/index.php/en/localnews/258650-2022-09-27-04-53-34.html 2022-09-27 11:53am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០នាថ្ងៃទី២៥ ដល់វេលាម៉ោង ៣៖០០ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញ សមត្ថកិច្ចកម្ពុជា បានទទួលសំណើ ០៥ករណីទៀត ដែលស្នើឱ្យសង្គ្រោះជនបរទេស ២៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង ០៥ករណីនេះ រួមមាន៖ ស្នើឱ្យសង្គ្រោះជនជាតិវៀតណាមចំនួន ១១នាក់, ម៉ាឡេស៊ី ០៦នាក់, ឥណ្ឌា០៦នាក់ និងជនជាតិបង់ក្លាដេស ១នាក់។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៣៣៧ករណី មានមនុស្ស ៨០៥នាក់ មាន ១១សញ្ជាតិ។

**២៖** ស្រាវជ្រាវអង្កេតបឋមបាន ១៧៧សំណើ នៅសល់ ១៦០សំណើ (រកឃើញ ៣៥៨នាក់, ឃាត់ខ្លួន ៥៣នាក់, បិទក្រុមហ៊ុន ១ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៥ទីតាំង)។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្ដេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធ បន្តសហការផ្ដល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្រ្កាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្ដេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្ដល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## មានការកើនឡើងនូវការគំរាមកំហែងដែលធ្វើឡើងដោយក្រុមឆបោក ពាក់ព័ន្ធនឹងការចោទប្រកាន់"ការជួញដូរសរីរាង្គ"

https://www.khmertimeskh.com/501158015//?p=1158015 Kong Arey / Khmer Times September 27, 2022

ការចោទប្រកាន់ជាច្រើនអំពីការជួញដូរផ្នែករាងកាយរបស់ជនរងគ្រោះ ដោយការជួញដូរមនុស្សត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងរីករាលដាលពាសពេញតំបន់ ដែលបង្កការភ័យខ្លាច និងភាពមិនច្បាស់លាស់ដល់អ្នកដែលគ្រោងនឹងមកកម្សាន្តនៅកម្ពុជា។ រឿងរ៉ាវទាំងអស់នេះបានចាប់ផ្តើមជាមួយនឹងវីដេអូខ្លី ដែលបានបង្ហោះដែលត្រូវបានផ្សព្វផ្សាយនៅក្នុងប្លុក(blog) និងគេហទំព័រ ដោយបានចោទប្រកាន់ថា អ្នកដែលបដិសេធមិនធ្វើតាមការបញ្ជារបស់ក្រុមឆបោក នឹងត្រូវបានវះយកសរីរាង្គសំខាន់ៗរបស់ពួកគេទៅលក់ក្នុងទីផ្សារងងឹតតាមរយៈគេហទំព័រខុសច្បាប់។ ក៏មានការអះអាងថាជនបរទេស"រាប់ពាន់" នាក់ត្រូវបានចោទប្រកាន់ថាត្រូវបានជួញដូរ ដោយល្បួងឱ្យមកធ្វើការនៅក្នុងប្រទេសកម្ពុជា និងយ៉ាងហោចណាស់ប្រទេសអាស៊ីអាគ្នេយ៍ពីរផ្សេងទៀតជាមួយនឹងការ

សន្យាផ្តល់ការងារបានប្រាក់ខែខ្ពស់ជាប្រាក់ដុល្លារ ដែលមានតម្លៃខ្ពស់ជាងរូបិយប័ណ្ណក្នុងប្រទេសពួកគេ ហើយប្រទេសកម្ពុជាជាប្រទេសដែលមានសេដ្ឋកិច្ចប្រើប្រាក់ប្រាក់ដុល្លារ។

មន្ត្រីនគរបាលមកពីបណ្តាប្រទេសអាស៊ានមួយចំនួន បានប្រាប់កាសែតខ្មែរថាមស៍ ក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះថា ការចោទប្រកាន់នេះបានធ្វើឲ្យខូចខាតមុខមាត់យ៉ាងធំធេងដល់កម្ពុជា និងប្រទេសពីរផ្សេងទៀត ទោះបីជាករណីជួញដូរមនុស្សសម្រាប់ប្រតិបត្តិការល្បែងស៊ីសងខុសច្បាប់តាមប្រព័ន្ធអ៊ីនធឺណិត និងប្រតិបត្តិការឆបោកផ្សេងទៀតកំពុងកើតឡើង យ៉ាងហោចណាស់ពាក់កណ្តាលនៃប្រទេសសមាជិកអាស៊ានទាំង១០ក៏ដោយ។ « ការជួញដូរមនុស្ស ការលក់មនុស្សពីក្រុមមួយទៅឱ្យក្រុមមួយទៀត បន្ទាប់ពីពួកគេបានមកដល់ប្រទេសកម្ពុជាដោយស្ម័គ្រចិត្ត ហើយប្រទេសផ្សេងទៀតត្រូវបានលើកឡើងមកនិយាយដោយប្រព័ន្ធផ្សព្វផ្សាយជាច្រើន។ ប៉ុន្តែ មានតែកម្ពុជាប៉ុណ្ណោះត្រូវបានគេលើកមកនិយាយដោយអយុត្តិធម៌ ហើយចំពោះសកម្មភាពរបស់នគរបាលក្នុងការចាប់ខ្លួនក្រុមឆបោក ដែលរហូតមកដល់បច្ចុប្បន្ន ចាប់បានជនសង្ស័យរាប់រយនាក់ ទទួលបានការឆ្លើយតបតិចតួចបើប្រៀបធៀបទៅនឹងការចោទប្រកាន់។

កម្លាំងនគរបាលកម្ពុជាបាននិយាយថា "ការស៊ើបអង្កេតរបស់យើងបានបង្ហាញថាការចោទប្រកាន់នូវការជួញដូរអេវៈយវៈមនុស្សគ្រាន់តែជាការគំរាមកំហែងដែលប្រើដោយក្រុមឆបោកដើម្បីគម្រាមពលករទាំងនោះ ហើយមិនមានផ្នែករាងកាយពិតប្រាកដណាមួយត្រូវបានជួយដូរទេ ហើយក៏មិនមាននរណាម្នាក់ចេញមុខផ្តល់ភស្តុតាងណាមួយអំពីរឿងនេះ រួមជាមួយនឹងការជួញដូរឈាម ដែលជាការចោទប្រកាន់ដែលត្រូវបានច្រានចោលផងដែរ» ។ លោកបានបន្ថែមថា បញ្ហានោះគឺនៅក្នុងប្រទេសដែលជនរងគ្រោះដែលត្រូវបានគេចោទប្រកាន់ថាត្រូវបានជួញដូរ ខណៈដែលការចាប់ខ្លួនជនបោកប្រាស់នឹងជួយកាត់បន្ថយ និងលុបបំបាត់ក្រុមបោកប្រាស់ទាំងនេះដែលតែងតែល្បួងជនងាយរងគ្រោះ។ លោកបានបន្ថែមថា "ការថ្លែងនាពេលថ្មីៗនេះរបស់ឯកអគ្គរដ្ឋទូតម៉ាឡេស៊ី លោក Datuk Eldeen Husaini ថា ការសហការរួមគ្នារវាងអាស៊ានអាចជាដំណោះស្រាយ ខណៈដែលការចែករំលែកព័ត៌មាន និងការស៊ើបការណ៍សម្ងាត់ ការសម្របសម្រួល និងការវិភាគអាចដើរតួយ៉ាងសំខាន់ក្នុងការកំចាត់ក្រុមទាំងនេះ" ។

កាលពីខែកក្កដា សហរដ្ឋអាមេរិកបានទម្លាក់កម្ពុជាមកនៅចំណាត់ថ្នាក់ទី ៣ ដែលជាចំណាត់ថ្នាក់ទាបបំផុតលើសន្ទស្សន៍ការជួញដូរមនុស្សរបស់ខ្លួន បន្ទាប់ពីមិនបានដោះស្រាយបញ្ហានេះឲ្យមានប្រសិទ្ធភាព។

លោកឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃបាននិយាយថា « [រហូតដល់] ៩៩,៩ ភាគរយនៃមេខ្លោងឧក្រិដ្ឋកម្មមិនមែនជាជនជាតិខ្មែរទេ។ អ្នកដែលរៀបចំផែនការបញ្ជូនមនុស្សពីប្រទេសផ្សេងៗមកកម្ពុជាក៏មិនមែនជាជនជាតិខ្មែរដែរ»។ ក្នុងឆ្នាំ ២០១៧ ជនជាតិខ្មែរពីរនាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់នៅតុលាការពីបទជួញដូរអេវៈយវៈ ក្នុងករណី ដែលជនជាតិខ្មែរមួយចំនួនត្រូវបានគេបញ្ចុះបញ្ចូលឱ្យធ្វើដំណើរទៅប្រទេសឥណ្ឌាដើម្បីលក់ក្រលៀន ឬសរីរាង្គសំខាន់ៗផ្សេងទៀត។ នៅឆ្នាំ២០១៦ រដ្ឋសភាបានអនុម័តច្បាប់ហាមឃាត់ការជួញដូរសរីរាង្គក្នុងគោលបំណងទប់ស្កាត់ការជួញដូរនៅក្នុងទីផ្សារសរីរាង្គ(red market) ។

នគរបាលបាននិយាយថា វាជារឿងសំខាន់ក្នុងការកត់សម្គាល់ថា ការជួញដូរសរីរាង្គ និងការជួញដូរមនុស្សសម្រាប់ការយកសរីរាង្គគឺខុសគ្នា ដែលជារឿយៗត្រូវបានគេច្រលំគ្នា"។ ការជួញដូរមនុស្សដើម្បីយកសរីរាង្គ កើតឡើងនៅពេលដែលមនុស្សត្រូវបានគេបង្ខំ ឬបោកបញ្ឆោតឱ្យផ្តល់សរីរាង្គ នៅពេលដែលពួកគេយល់ព្រមលក់សរីរាង្គណាមួយ ប៉ុន្តែត្រូវបានគេបោកប្រាស់ ឬនៅពេលដែលពួកគេត្រូវបានចាប់ពង្រត់ និងត្រូវបានដាក់ថ្នាំ ហើយក្រោយមកត្រូវបានគេវះយកសរីរាង្គ។ មន្ត្រីក្រុមការងាររូបនេះបានលើកឡើងថា ចំណុចសំខាន់ដែលត្រូវបញ្ជាក់គឺមិនមានករណីបែបនេះក្នុងប្រទេសកម្ពុជាពាក់ព័ន្ធនឹងការជួញដូរសរីរាង្គមនុស្សដោយក្រុមអ្នកជួញដូរឡើយ៕

## ភាពប្រទាក់ក្រឡាគ្នារវាងល្បែងស៊ីសង និងការជួញដូរមនុស្សនៅកម្ពុជា

https://kohsantepheapdaily.com.kh/article/1604947.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ២៧ ខែ កញ្ញា ឆ្នាំ ២០២២ ម៉ោង ១៦:៤៤

ការជួញដូរមនុស្ស និងល្បែងស៊ីសងកំពុងធ្វើអោយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល និងសម្តេច ស ខេង ឈឺក្បាលខ្លាំងបន្ថែមពីលើការងារសំខាន់ៗផ្សេងៗទៀត ដែលត្រូវដោះស្រាយសម្រាប់ប្រទេសជាតិ។ ការជួញដូរមនុស្ស និងល្បែងស៊ីសងច្រើនកន្លែងហាក់ដូចជាមានភាពប្រទាក់ក្រឡាគ្នា ដោយជំរុញអោយរដ្ឋាភិបាលកម្ពុជាបើកយុទ្ធនាការស្ទើរជំណាលគ្នា ដើម្បីកំចាត់បញ្ហាទាំងពីរនេះ។ ដោយសារភាពធ្ងន់ធ្ងរ នៃបញ្ហាល្បែងស៊ីសង និងការជួញដូរមនុស្សមានផលប៉ះពាល់ខ្លាំង ចំពោះសង្គមសេដ្ឋកិច្ច និងមុខមាត់កម្ពុជាលើឆាកអន្តរជាតិ យើងមានក្តីសង្ឃឹមថា យើងអាចរកឃើញអ្នកដែលទទួលខុសត្រូវពិតប្រាកដនៅពីក្រោយបទល្មើសពាក់ព័ន្ធនឹងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ និងអ្នកនៅពីក្រោយខ្នងការជួញដូរមនុស្ស។ ពេល គឺយើងត្រូវចាប់អោយបានមេខ្លោងចំពោះបញ្ហាដ៏ធ្ងន់ធ្ងរទាំងពីរនេះ។

មកដល់ពេលនេះសមត្ថកិច្ចទើបតែអាចរកឃើញជនបរទេស ដែលពាក់ព័ន្ធហើយភាគច្រើន គឺជាជនរងគ្រោះនៅក្នុងឧក្រិដ្ឋកម្មនោះ ប្រមាណជាជាង១៥០នាក់ប៉ុណ្ណោះ ដោយពួកគេ ត្រូវបានរកឃើញនៅខេត្តកណ្តាល កោះកុង និងរាជធានីភ្នំពេញ ដោយនៅក្នុងនោះពួកគេជា ជនជាតិចិន ឥណ្ឌូនេស៊ី និងវៀតណាមជាដើម។ ក្រៅពីជនបរទេសទាំងនោះ សមត្ថកិច្ចបានចាត់វិធានការនៅតាមកន្លែងបញ្ចាំមួយចំនួន ហើយបានរឹបអូសម៉ូតូប្រមាណជាជាង ១០០០គ្រឿង ដោយមួយចំនួនបានប្រគល់ដល់ម្ចាស់ដើមវិញ។ បញ្ហាដែលចេញមកពីបញ្ហាល្បែងស៊ីសងនេះបានធ្វើឲ្យប្រទេសជាច្រើននៅក្នុងតំបន់ដាក់ការសង្ស័យរបស់ពួកគេមកលើកម្ពុជាថា ជាកន្លែងដែលមានអ្នកពាក់ព័ន្ធនឹងអំពើឆបោក និង បញ្ហាជួញដូរមនុស្ស ដោយនៅក្នុងនោះ មានប្រទេសវៀតណាម ម៉ាឡេស៊ី ហ្វីលីពិន ស្របពេលដែលអាមេរិក បានដាក់កម្ពុជាក្នុងចំណាត់ថ្នាក់ដ៏អាក្រក់បំផុតនៃអំពើជួញដូរ មនុស្សកាលពីខែ កក្កដា ឆ្នាំ ២០២២។ របាយការណ៍របស់ក្រសួងការបរទេសអាមេរិកបានលើកឡើងថា កម្ពុជាពុំបានគោរពតាមពេញលេញនូវស្តង់ដារអប្បបរមាដើម្បីលុបបំបាត់នូវអំពើជួញដូរមនុស្ស និងពុំបានខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សឡើយ ខណៈដែលអំពើពុករលួយក្នុងសង្គមកម្ពុជា នៅតែបន្តរារាំងដល់ការអនុវត្តច្បាប់ជារួម ដើម្បីនាំជនល្មើសនៃអំពើជួញដូរមនុស្សយកមកទទួលខុសត្រូវតាមផ្លូវច្បាប់ និងរារាំងដល់ការផ្តល់សេវាជូនជនរងគ្រោះ។

អាជ្ញាធរវៀតណាមវិញថ្វីត្បិតតែមិនចេញរបាយការណ៍ណាមួយក៏ពិតមែន ប៉ុន្តែបានស្នើឲ្យ កម្ពុជាបើកការស៊ើបអង្កេតខណៈដែលមានជនជាតិវៀតណាមប្រមាណជា ៤០នាក់ បានសម្រុក រត់ចេញពីកន្លែងលេងល្បែងស៊ីសងមួយកន្លែងនៅខេត្តកណ្តាលលោតចុះទឹក ហែលឆ្លងទៅវៀតណាម ហើយមានរបាយការណ៍ថា ម្នាក់នៅក្នុងចំណោមនោះ បានស្លា.ប់ថែមទៀត ។

ក្រៅពីនេះ ម៉ាឡេស៊ីវិញ គឺបានឈានដល់ការសម្រេចចិត្តបង្កើតគណកម្មការមួយ ដើម្បីទទួលបន្ទុកបញ្ហាជនជាតិម៉ាឡេស៊ីដែលរងគ្រោះដោយសារតែបញ្ហាបោកប្រាក់ការងារនៅ បរទេស ហើយរដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ីក៏បានទំនាក់ទំនងមករដ្ឋមន្ត្រី ការបរទេស កម្ពុជាផងដែរលើបញ្ហានេះ។

ក្រៅពីនេះ អាជ្ញាធរហ្វីលីពិនបានប្រកាសថា ការិយាល័យឥន្ទ្រប្រវេសន៍ហ្វីលីពិននឹងរិតបន្តឹងវិធានការផ្សេងៗលើរាល់អ្នកដំណើរទាំងអស់ ដែលមកពីកម្ពុជា និងវៀតណាម ដោយសារតែ បញ្ហារឿងអាស្រូវនេះ។ ទាំងនេះគឺជាស្ថានភាពត្រួសៗអំពីបញ្ហាដែលកើតមានឡើងជុំវិញបញ្ហាដែលគេជឿថា មានឫសគលចេញមកពីបណ្តាកន្លែងដែលបើកល្បែងស៊ីសងខុសច្បាប់ធំៗនៅកម្ពុជា ។ដោយសារតែភាពធ្ងន់ធ្ងរនៃបញ្ហាល្បែងស៊ីសង និងការជួញដូរមនុស្ស

ប៉ះពាល់ខ្លាំងដល់មុខមាត់ប្រទេសកម្ពុជា ប្រតិបត្តិការបង្ក្រាបលើបញ្ហាទាំងពីរនេះមិនត្រូវធ្វើលំៗឡើយ ហើយត្រូវធ្វើអោយមានប្រសិទ្ធភាពបំផុតតាមការចង់បានរបស់ប្រមុខរាជរដ្ឋាភិបាលគឺ សម្តេចតេ ជោហ៊ុនសែន ។

និយាយអោយត្រង់ជាងនេះ ការបង្ក្រាប គឺត្រូវធ្វើអោយ ដល់ឬសគល់ ពិតប្រាកដហើយត្រូវចាប់អោយបានមេខ្លោងនៅពីក្រោយបញ្ហាទាំងពីរនេះ។ បើសិនជាមិន អាចចាប់មេក្លោងបានទេ បញ្ហាទាំងពីរនេះនឹងបន្តញាំញីប្រទេសកម្ពុជា ហើយកម្ពុជាមិន អាចដោះ ស្រាយបញ្ហានេះបានជោគជ័យ១០០ភាគរយ ដូចការចង់បានរបស់ក្រសួងមហាផ្ទៃដែលដឹកនាំដោយសម្តេច ស ខេង និងរដ្ឋាភិបាលដែលដឹកនាំដោយ សម្តេចតេជោ ហ៊ុន សែន។ ដោយ ៖ ហេង ចេស្តារ

## អាជ្ញាធរបានរកឃើញជនបរទេសសរុបជិត ៩០០ នាក់ ក្នុងក្រុងព្រះសីហនុ ពាក់ព័ន្ធល្បែង និងរស់នៅខុសច្បាប់

https://www.postkhmer.com/national/2022-09-27-1603-241448.html ឡាយ សាមាន | Publication date 27 September 2022 | 16:03 ICT

**ព្រះសីហនុ:** ក្នុងប្រតិបត្តិការរយៈពេល ៣ ថ្ងៃ អាជ្ញាធរបានរកឃើញជនបរទេសសរុបជិត ៩០០ នាក់ នៅ ២ ទីតាំងផ្សេងគ្នាក្នុងក្រុងព្រះសីហនុ ដោយមានជនបរទេសមួយចំនួនរស់នៅខុសច្បាប់ និងបានកំណត់បទល្មើសពាក់ព័ន្ធបើកល្បែងអនឡាញខុសច្បាប់ បទល្មើសជួញដូរមនុស្ស និងបទល្មើសសញ្ញារកម្ម។

សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រះសីហនុចុះថ្ងៃទី ២៣ ខែកញ្ញា បានឱ្យដឹងថា គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តព្រះសីហនុ បានសហការជាមួយ នាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងស្ថាប័នជំនាញពាក់ព័ន្ធ ដោយមានការសម្របសម្រួលនីតិវិធីពីអយ្យការអមសាលាដំបូងខេត្ត បានចុះពិនិត្យរដ្ឋបាលទីតាំងឈ្មោះ ជីង ឆាយ តិចណូឡូជី (ហៅ ជើង ឆាយ០៥) មានចំនួន ៨ អគារ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ដើម្បីពិនិត្យលើស្ថានភាពទីតាំងអាជ្ញាប័ណ្ណ ប្រកបអាជីវកម្មការស្នាក់នៅរបស់ជនអន្តោប្រវេសន៍ និងករណីជួញដូរមនុស្ស សញ្ញារកម្ម និងល្បែងអនឡាញ ខុសច្បាប់។ សេចក្តីប្រកាសបន្តថា ក្នុងប្រតិបត្តិការរយៈពេល ៣ ថ្ងៃនេះ ចាប់ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០២២ កម្លាំងចម្រុះដឹកនាំដោយគណៈបញ្ជាការឯកភាពខេត្ត បានរកឃើញ ជនបរទេសសរុប ៤៦៩ នាក់ ស្រី ៧៥ នាក់ មានចំនួន ១០ សញ្ជាតិ។

ក្នុងនោះជនជាតិចិន ចំនួន ២៧៤ នាក់ (ស្រី ៣៣ នាក់) ជនជាតិចិនតៃវ៉ាន់ ចំនួន ៦ នាក់ ជនជាតិវៀតណាម ចំនួន ១៥៨ នាក់ (ស្រី ៣៤ នាក់) ជនជាតិម៉ាឡេស៊ី ចំនួន ១៥ នាក់ (ស្រី ២ នាក់) ជនជាតិឥណ្ឌូនេស៊ី ចំនួន ៣ នាក់ (ស្រី ២ នាក់) ជនជាតិឥណ្ឌា ចំនួន ៤ នាក់ ជនជាតិថៃ ចំនួន ៣ នាក់ (ស្រីម្នាក់) ជនជាតិបង់ក្លាដែស ១ នាក់ ជនជាតិមីយ៉ាន់ម៉ា ចំនួនស្រី ១ នាក់ និងជនជាតិរុស្ស៊ី ស្រី ២ នាក់។ ក្នុងចំណោម ៤៦៩ នាក់ មានជនបរទេសខុសច្បាប់អន្តោប្រវេសន៍ សរុបចំនួន ២៣៦ នាក់ ស្រី ៣២ នាក់ មាន ៨ សញ្ជាតិ ក្នុងនោះជនជាតិចិន ចំនួន ៩៩ នាក់ តៃវ៉ាន់ ចំនួន ២ នាក់ វៀតណាម ចំនួន ១២២ នាក់ ម៉ាឡេស៊ី ៥ នាក់ ថៃ ៣ នាក់ បង់ក្លាដែស ១ នាក់ មីយ៉ាន់ម៉ា ១ នាក់ និង ឥណ្ឌាចំនួន ៣ នាក់។ ប្រភពដដែលឱ្យដឹងថា បន្ទាប់ពីសមត្ថកិច្ចជំនាញផ្នែកការងារ និងសមត្ថកិច្ចជំនាញផ្នែកអន្តោប្រវេសន៍ បានធ្វើការសាកសួរព័ត៌មាន និងពិនិត្យឯកសារពាក់ព័ន្ធនានា លើជនបរទេសសរុបចំនួន ៤១៤ នាក់ ឃើញថា ជនបរទេសបម្រើការងារមិនមានបណ្ណការងារ មានចំនួន ២៣៦ នាក់ និងបានធ្វើការផាកពិន័យទាំងអស់ ព្រមទាំងប្រមូលអាករពីការធ្វើបណ្ណការងារ បានថវិកាសរុប ចំនួន ១១៨ លានរៀល។

ក្នុងនោះ មានបណ្ណការងារ ចំនួន ៣៥ នាក់ ខណៈជនបរទេសដែលមិនមានលិខិតឆ្លងដែន មានចំនួន ១៦៨ នាក់ ក្នុងនោះ ជនជាតិចិនចំនួន ១៣០ នាក់ វៀតណាមចំនួន៣៣នាក់ ម៉ាឡេស៊ីចំនួន ៣ នាក់ និងឡាវ ចំនួន ២ នាក់។ ជាលទ្ធផលក្នុងប្រតិបត្តិការត្រួតពិនិត្យរដ្ឋបាលទីតាំងខាងលើ កម្លាំងជំនាញកំណត់បទល្មើសចំនួន ៣ រួមមាន បទល្មើសល្បែងអនឡាញខុសច្បាប់ បទល្មើសជួញដូរមនុស្ស និងបទល្មើសសញ្ជារកម្ម។ ក្នុងប្រតិបត្តិការនេះ គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុសម្រេចដាក់ចេញនូវ វិធានការមួយចំនួនរួមមាន ធ្វើកិច្ចសន្យាអប់រំដល់ជនបរទេសដែលស្របច្បាប់ និងជនបរទេសដែលបានផាកពិន័យអន្តោប្រវេសន៍ និងផ្តល់បណ្ណការងាររួចរាល់ អនុញ្ញាតឱ្យចាកចេញពីទីតាំងទៅរកកន្លែងថ្មី។ សម្រេចបិទអាជីវកម្មទាំងអស់ ដែលស្ថិតក្នុងបរិវេណទីតាំងឈ្មោះ ជើង ឆាយ តិចណូឡូជី លើកលែងតែអាហារដ្ឋាន និងបិទជាបណ្តោះអាសន្ននូវអគារមួយចំនួន ដែលមានភាពអនាធិបតេយ្យ។ ជាមួយគ្នានេះដែរ គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ បានរក្សាទុកសម្ភារ ទ្រព្យសម្បត្តិដែលបានចាប់ យកក្នុងពេលប្រតិបត្តិការ។

ដោយឡែក ប្រតិបត្តិការចុះត្រួតពិនិត្យរដ្ឋបាលនៅទីតាំងក្រុមហ៊ុន ហ្គាឡាក់ស៊ីវើលដ៍ ស្ថិតនៅសង្កាត់លេខ ៤ ក្រុងព្រះសីហនុ រយៈពេល៣ថ្ងៃដូចគ្នា បានរកឃើញជនបរទេសសរុប ៤១៤ នាក់ ដែលមាន ៥ សញ្ជាតិ។ រដ្ឋបាលខេត្តព្រះសីហនុ ឱ្យដឹងថា ក្នុងប្រតិបត្តិការនេះទាំង២ទីតាំងរកឃើញជនបរទេសសរុបចំនួន ៨៨៣ នាក់ ដោយក្នុងនោះ រកឃើញករណីជនបរទេសរស់នៅខុសច្បាប់ ករណីបង្ខាំងមនុស្ស និងបានចាត់វិធានការតាមផ្លូវច្បាប់។ រដ្ឋបាលខេត្តព្រះសីហនុ ឱ្យដឹងថា ចំពោះករណីទាំងនេះ សមត្ថកិច្ចបានកំពុងធ្វើការទៅតាមជំនាញរៀងៗខ្លួន ក្នុងនោះ ជំនាញនៃនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម បានកសាងសំណុំរឿងពាក់ព័ន្ធល្បែងអនឡាញខុសច្បាប់បញ្ជូនទៅតុលាការ និងបន្តស៊ើបអង្កេតបទល្មើសសម្អាតប្រាក់។ ចំណែកជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ កសាងសំណុំរឿងបទល្មើសជួញដូរមនុស្ស បទល្មើសញ្ជារកម្ម បញ្ជូនជនសង្ស័យចំនួន ៥ នាក់ ទៅតុលាការ និងបន្តស៊ើបអង្កេតបទល្មើសសម្អាតប្រាក់។

លោក អំ សំអាត នាយករងទទួលបន្ទុកផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្សនៃអង្គការលីកាដូ ថ្លែងថា យុទ្ធនាការបង្ក្រាបទៅលើល្បែងស៊ីសងខុសច្បាប់ដែលមានលក្ខណៈទ្រង់ទ្រាយធំគឺជារឿងល្អ ប៉ុន្តែអ្វីដែលសំខាន់នោះ គឺការអនុវត្តច្បាប់តឹងរ៉ឹងចំពោះបុគ្គលគ្រប់រូប ទើបការងារនោះមានប្រសិទ្ធភាព។ លោកថា៖ «អ្វីដែលសំខាន់ការបង្ក្រាបលើល្បែងស៊ីសងទាំងអស់នេះ កុំចាំបាច់ទាល់មានបទបញ្ជាពីថ្នាក់ជាតិទើបថ្នាក់ក្រោមជាតិចាត់វិធានការ បើមិនដូច្នេះទេដូចវៃកចកអ៊ីចឹង ព្រោះច្បាប់យើងមានស្រាប់ អ៊ីចឹងត្រូវអនុវត្តច្បាប់ឱ្យល្អប្រសើរពិសេសគ្រប់មន្ត្រីទាំងអស់ត្រូវនៅឱ្យឆ្ងាយពីល្បែងស៊ីសង ដើម្បីឱ្យវិធានការទប់ស្កាត់ឬបង្ក្រាបនេះមានប្រសិទ្ធភាព»។

រដ្ឋបាលខេត្តព្រះសីហនុ បានគូសបញ្ជាក់ថា នឹងបន្តធ្វើការត្រួតពិនិត្យរដ្ឋបាលនៅតាមបណ្តាទីតាំងអាជីវកម្មដែល សង្ស័យមិនមានច្បាប់អនុញ្ញាត ព្រមទាំងចាត់វិធានការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ចំពោះម្ចាស់អាជីវកម្ម ក្នុងករណីរកឃើញ បទល្មើស រហូតដល់ភូមិសាស្ត្រខេត្តព្រះសីហនុ ទាំងមូលលែងមានបញ្ហាទាំងនេះ។ ការចុះប្រតិបត្តិការទ្រង់ទ្រាយធំ និងម៉ឺងម៉ាត់បែបនេះ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏ដូចជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង នៅ ក្នុងខែកញ្ញា បានចេញបញ្ជាឱ្យបង្ក្រាបទីតាំងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទនៅទូទាំងប្រទេស ដែលជាដើមចមនៃបទល្មើសនានា ដើម្បីរក្សាសណ្តាប់ធ្នាប់សង្គម និងធានាដល់គោលនយោបាយភូមិ ឃុំ សុវត្ថិភាព៕

## គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ដាក់វិធានការបន្តលុបបំបាត់ល្បែងស៊ីសងគ្រប់ប្រភេទ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នៅក្នុងរាជធានី

https://cen.com.kh/archives/538910.html Posted ByPen Srey NeatSeptember 27, 2022

ភ្នំពេញ៖ ការបង្ក្រាបបទល្មើសល្បែងស៊ីសងគ្រប់ប្រភេទនៅភ្នំពេញ នៅតែជាចំណុចក្ដៅរបស់ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ សំដៅធ្វើយ៉ាងណាលុបបំបាត់ឲ្យអស់ ទៅតាមអនុសាសន៍របស់ សម្ដេចអគ្គមហាសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ជាក់ស្ដែងនៅរសៀលថ្ងៃទី២៧ កញ្ញានេះ ឯកឧត្តមឃួង ស្រេង អភិបាលរាជធានីភ្នំពេញ និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ បានអញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីត្រួតពិនិត្យ និងដាក់វិធានការបន្ត ឈានដល់ការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់នៅរាជធានីភ្នំពេញ។ ក្នុងកិច្ចប្រជុំនេះ មានការចូលរួមពីលោកស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការរងកងរាជអាវុធហត្ថរាជធានី ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១៤ និងមន្ទីរពាក់ព័ន្ធមួយចំនួនទៀត៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

### សម្ដេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីប្រារព្ធ «វេទិកាអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៦»

http://freshnewsasia.com/index.php/en/localnews/258866-2022-09-28-11-07-25.html 2022-09-28 06:07pm

**(ភ្នំពេញ)៖** បន្ទាប់ពីខកខានអស់រយៈពេលពីរឆ្នាំ ដោយសារការរាតត្បាតជំងឺកូវីដ១៩នោះ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៩ ខែកញ្ញា ឆ្នាំ២០២២ស្អែកនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងរៀបចំ **«វេទិកាអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស»** ឡើងវិញ។ វេទិកានេះនឹងប្រារព្ធធ្វើឡើងក្រោមអធិបតីភាពរបស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ព្រមទាំងមានការអញ្ជើញចូលរួមពីមន្ត្រីពាក់ព័ន្ធជាច្រើនរូបផ្សេងទៀត។

គិតចាប់ពីឆ្នាំ២០១៧មក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន តែងតែបានសហការជាមួយអ្នកដឹកនាំសាសនាធំៗ ក្នុងប្រទេសកម្ពុជា រៀបចំកម្មវិធីវេទិកាអន្តរសាសនា ដើម្បីបួងសួងឱ្យប្រជាជនកម្ពុជា ក៏ដូចជាប្រជាជនលើសកលលោក ទទួលបានសេចក្ដីសុខ ចៀសផុតពីការរំលោភបំពាន និងអំពើជួញដូរមនុស្ស ដែលជាទាសភាសម័យទំនើប។ សារៈសំខាន់ នៃកម្មវិធីនេះ គឺជាការបង្ហាញនូវភាពសុខដុមរមនា នៃសាសនានៅកម្ពុជា ដែលតែងតែឯកភាព សហការ គាំទ្រគ្នាទៅវិញទៅមក ដោយភាពទន់ភ្លន់ មិនមានទំនាស់ មិនប្រទូស្ដរាយគ្នា មិនបង្កឱ្យមានការបែកបាក់ និងគ្រោះមហន្តរាយក្នុងសង្គម។ ផ្ទុយទៅវិញ ភាពសុខដុម នៃសាសនា បានដើរតួជាគន្លឹះក្នុងការកសាងនូវសន្តិភាពផ្លូវចិត្ត របស់បុគ្គល និងសន្តិសុខសង្គម ព្រមទាំងជួយពង្រឹងស្មារតី មនុស្សគ្រប់រូបឲ្យរឹងប៉ឹង រួមគ្នាតស៊ូ ជម្នះនឹងការញុះញង់ អូសទាញ ដែលជាល្បិចកលឧក្រិដ្ឋជនជួញដូរមនុស្ស។

កម្មវិធីវេទិកាអន្តរសាសនា តែងតែត្រូវបានរៀបចំជារបៀបមិទ្ទិញទ្រង់ទ្រាយធំ ដោយមានអ្នកដឹកនាំនិកាយសាសនាទាំងឡាយ ចូលរួមប្រារព្ធពិធីតាមបែបសាសនានីមួយៗ ក្នុងពេលតែមួយ ទីកន្លែងតែមួយ គោលដៅតែមួយ ដោយឯកភាពគ្នា និងដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការ យ៉ាងច្រើនកុះករ។ នៅឆ្នាំ២០២០-២០២១ គឺជាពេលវេលាដ៏លំបាក ដែលថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូពេទ្យ អាជ្ញាធរ ក៏ដូចជាប្រជាពលរដ្ឋ បាននិងកំពុងតស៊ូ ទប់ទល់នឹងបញ្ហាប្រឈម ដែលបង្កឡើងដោយការរាតត្បាត នៃជំងឺកូវីដ១៩ និងមេរោគបំប្លែងថ្មី ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មិនបានរៀបចំកម្មវិធីទ្រង់ទ្រាយធំឡើ

យ។ ក៏ប៉ុន្តែបានរៀបចំជាបទយកការណ៍ និងការផ្សព្វផ្សាយជាទម្រង់វីដេអូ ដែលទទួលបានការអញ្ជើញចូលរួមជាអធិបតី ពីសម្តេចតេជោ ហ៊ុន សែន ដើម្បីថ្លែងសុន្ទរកថាបើកកម្មវិធី យ៉ាងអធិកអធម និងផ្សព្វផ្សាយទូទាំងប្រទេស និងទៅលើពិភពលោក។ វេទិកាអន្តរសាសនាលើកទី៦ ឆ្នាំ២០២២ នឹងមានការចូលរួមពីថ្នាក់ដឹកនាំ ព្រះពុទ្ធសាសនា មូស្លីម កាតូលិក គ្រិស្តបរិស័ទបំណងល្អ ប្រូតេស្តង់ និងអ្នកជំនឿផ្សេងៗទៀត ព្រមទាំងតំណាងអង្គការជាតិ-អន្តរជាតិមួយចំនួន ដែលកំពុងបំពេញការងារពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ប្រមាណ ១,៥០០អង្គ/នាក់។

សូមបញ្ជាក់ថា ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ កម្ពុជា បាននឹងកំពុងបើកប្រតិបត្តិការយ៉ាងក្តៅគគុក បង្រ្កាបទីតាំជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម ជាពិសេសនៅតាមបណ្តាទីតាំងលេងល្បែងស៊ីសង។ ក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលដឹកនាំដោយសម្តេចក្រឡាហោម ស ខេង បានជំរុញកិច្ចសហប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងទម្រង់ថ្មីនេះយ៉ាងទូលំទូលាយ ដោយអនុញ្ញាតឱ្យជនរងគ្រោះដាក់បណ្តឹង ឬសេចក្តីរាយការណ៍ជាក់លាក់ពីជនរងគ្រោះ ទីតាំងបទល្មើស និងស្ថានភាពនៃបទល្មើស តាមបណ្តាញគេហទំព័រហ្វេសប៊ុក ផ្ទាល់របស់សម្តេចក្រឡាហោម និងតាមបណ្តាញដទៃទៀត របស់ក្រសួងមហាផ្ទៃ ដើម្បីបានធ្វើកិច្ចសហប្រតិបត្តិការបាន ឆាប់រហ័ស ទាន់ពេល ក្នុងគោលដៅស្វែងរក និងសង្គ្រោះជនរងគ្រោះ បង្រ្កាបបទល្មើសដែលលាក់បង្កប់ ក្នុងទីតាំងដែលគួរឲ្យសង្ស័យ និងនាំយកជនប្រព្រឹត្តបទល្មើស មកផ្តន្ទាទោសតាមច្បាប់ដោយឥតលើកលែង។

រយៈពេលចាប់ផ្តើមកិច្ចប្រតិបត្តិការ ក្នុងខែសីហា មកដល់ពេលនេះ សមត្ថកិច្ចបានរកឃើញបានជិត ៣០០ករណី និងសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុសស្ស ដែលបានទទួលរងនូវទណ្ឌកម្ម ការបិទសិទ្ធិសេរីភាព និងការកេងប្រវ័ញ្ចកម្លាំងពលកម្មរាប់រយនាក់ និងបានសង្គ្រោះមនុស្សចេញពីទីតាំងអាថ៌កំបាំងទាំងនោះជាច្រើននាក់បន្ថែមទៀត ព្រមទាំងមានវិធានការបិទទីតាំងប្រព្រឹត្តបទល្មើសជាច្រើនកន្លែង។ លទ្ធផលដែលទទួលបាននេះគឺជាការបង្ហាញឱ្យច្បាស់ពីស្មារតីរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការជួញដូរកម្លាំងពលកម្ម៕

## ក្រុមអ្នកឃ្លាំមើលសាទរចំណាត់ការរដ្ឋាភិបាលក្នុងការបង្ក្រាបករណីជួញដូរមនុស្ស ដើម្បីទាក់ទាញលំហូរវិនិយោគនិងភ្ញៀវទេសចរមកកម្ពុជា

https://www.postkhmer.com/national/2022-09-27-1817-241460.html សំបាន ច័ន្ទដារ៉ា | Publication date 27 September 2022 | 18:17 ICT

**ភ្នំពេញៈ** អ្នកជំនាញឃ្លាំមើលបញ្ហាសង្គមបានសាទរលើការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនាពេលកន្លងមក និងយល់ស្របឱ្យរដ្ឋាភិបាលកម្ពុជាអនុវត្តច្បាប់លើករណីជួញដូរមនុស្ស ជាពិសេសការរឹតបន្តឹងលំហូរចូលនូវជនបរទេស ពិនិត្យការអនុវត្តច្បាប់អន្តោប្រវេសន៍ និងវែកមុខអ្នកពាក់ព័ន្ធឃុបឃិតដើម្បីបង្ហាញទៅសហគមន៍អន្តរជាតិឱ្យមានទំនុកចិត្តលើកម្ពុជាឡើងវិញ។ ក្រុមអ្នកវិភាគបានលើកឡើងថា ប្រសិនបើបញ្ហាជួញដូរមនុស្សឬបោកបញ្ឆោតតាមអនឡាញនៅបន្តកើតមាន នោះនឹងប៉ះពាល់ដល់មុខមាត់ប្រទេសកម្ពុជាដែលអាចប្រឈមមុខនឹងទណ្ឌកម្មរបស់សហគមន៍អន្តរជាតិ ការស្រុតចុះនូវលំហូរវិនិយោគទុន ជំនួយមូលនិធិអភិវឌ្ឍន៍ប្រទេស និងធ្លាក់ចុះវិស័យទេសចរណ៍។ល។

លោក មាស នី អ្នកស្រាវជ្រាវការអភិវឌ្ឍសង្គមលើកឡើងថា បទល្មើសជួញដូរមនុស្សជាបញ្ហាធំរបស់ពិភពលោក ដែលគេកំពុងយកចិត្តទុកដាក់ឃ្លាំមើល និងត្រួតពិនិត្យ ជាពិសេសបណ្តាប្រទេសដែលមានប្រព័ន្ធច្បាប់ និងការអនុវត្តច្បាប់ធូររលុង។ លោកបានបន្តថា ការអនុវត្តច្បាប់អន្តោប្រវេសន៍នៅមានចន្លោះប្រហោងខ្លាំង ដែលបង្ក

ភាពងាយស្រួលដល់ឧក្រិដ្ឋជនយកកម្ពុជាជាទីតាំងប្រព្រឹត្តបទល្មើសជួញដូរមនុស្សបាន ដោយលោកសង្កត់ធ្ងន់ថា បើរដ្ឋាភិបាលមិនបានចាត់វិធានការឱ្យមានប្រសិទ្ធភាពទេនោះ អាចនឹងមានទណ្ឌកម្មពីសហគមន៍អន្តរជាតិនានាបន្ថែមទៀត ដែលនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចកម្ពុជា។ លោក មាស នី បានបញ្ជាក់ថា៖ «ការជួញដូរមនុស្សនេះ ជាការរំលោភសិទ្ធិមនុស្ស ហើយកាលណាចូលដល់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរហើយ យើងអាចនឹងទទួលរងទណ្ឌកម្មអន្តរជាតិ បើយើងមិនបានត្រួតពិនិត្យដើម្បីកាត់បន្ថយវា» ។ លោកបានបន្ថែមថា ប្រសិនបើរដ្ឋាភិបាលមិនបានដោះស្រាយករណីនេះឱ្យមានភាពប្រសិទ្ធទេនោះ ទីក្រុងព្រះសីហនុនឹងក្លាយជាទីក្រុងម៉ាហ្វីយ៉ាសម្រាប់ឧក្រិដ្ឋជន ដែលនឹងប៉ះពាល់ដល់វិស័យទេសចរណ៍នៅក្នុងស្រុក និងមុខមាត់កម្ពុជាលើឆាកអន្តរជាតិ។

កាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២២ កន្លងទៅ ក្រសួងការបរទេសអាមេរិកបានដាក់កម្ពុជាក្នុងបញ្ជីខ្មៅរបស់ខ្លួនលើផ្នែកជួញដូរមនុស្ស ដែលចាត់ថ្នាក់កម្ពុជាក្នុងលំដាប់ទី២ ក្នុងការតាមដាន ហើយសហរដ្ឋអាមេរិកអះអាងថា ការជួញដូរជនបរទេសចូលមកក្នុងប្រទេសកម្ពុជាកំពុងមានការកើនឡើងជាលំដាប់ ។

ចំពោះលោក គិន ភា ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជាបានថ្លែងថា ករណីជួញដូរមនុស្សនៅកម្ពុជា សហគមន៍អន្តរជាតិបានចាត់ទុកកម្ពុជាក្នុងស្ថានភាពដែលមានហានិភ័យខ្ពស់ដែលក្នុងរូបភាពបែបនេះ វាបានប៉ះពាល់ដល់មុខមាត់កម្ពុជាលើឆាកអន្តរជាតិ និងជាពិសេសលំហូរវិនិយោគទុនពីបរទេសដោយផ្ទាល់នៅក្នុងស្រុក ដែលអ្នកវិនិយោគទាំងនោះមានការខ្លាចរអាក្នុងការបោះទុនវិនិយោគនៅកម្ពុជា។ លោក គិន ភា បានគូសបញ្ជាក់ពីនយោបាយការបរទេសរបស់រដ្ឋាភិបាលកម្ពុជាក្នុងការលើកស្ទួយមុខមាត់ប្រទេសឡើងវិញ ដូច្នេះថា៖ «ជានយោបាយការបរទេស រដ្ឋាភិបាលកម្ពុជាបានបង្ហាញទៅកាន់អន្តរជាតិថា បញ្ហាជួញដូរមនុស្សនេះ កម្ពុជាមិនបានគាំទ្រឡើយ ហើយរដ្ឋាភិបាលក៏មានក្របខ័ណ្ឌនយោបាយប្រាកដប្រជាក្នុងការប្រយុទ្ធប្រឆាំងដែរ ព្រមទាំងសុច្ឆន្ទៈក៏ដូចជាការខិតខំប្រឹងប្រែងរួចហើយលើករណីជួញដូរមនុស្ស និងការបង្ក្រាបល្បែងអនឡាញជាដើមនេះ»។

លោក ស៊ឹង សែនករុណា អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុកវិញនៅតែបន្តព្រួយបារម្ភពីករណីជួញដូរមនុស្ស ក៏ដូចជា ការលាងលុយកខ្វក់ផងដែរ ដែលរឿង២នេះគឺមានចំណងពាក់ព័ន្ធគ្នា។ លោកថា បញ្ជីប្រផេះចំពោះការលាងលុយកខ្វក់ដែលវាធ្វើឱ្យអ្នកវិនិយោគភាគច្រើនមិនហ៊ានមករកស៊ីនៅកម្ពុជា ជាពិសេសអ្នកវិនិយោគក្នុងប្រទេសលោកសេរីដោយពួកគេមិនអាចរកស៊ីក្នុងប្រទេស ដែលមានចំណាត់ថ្នាក់អាក្រក់លើការរំលោភសិទ្ធិមនុស្ស និងស្រុតចុះប្រជាធិបតេយ្យបានឡើយនិងមួយវិញទៀតគឺពួកគេភ័យខ្លាចពីសុខសុវត្ថិភាពផង ។ ជាមួយគ្នានេះ លោកបានអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឱ្យបង្ហាញឆន្ទៈពិតប្រាកដលើការទប់ស្កាត់ករណីជួញដូរមនុស្សឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីបង្កើនទំនុកចិត្តពីសហគមន៍អន្តរជាតិ និងជាពិសេសការបើកលំហសេរីភាពនិងប្រជាធិបតេយ្យឡើងវិញ។

ចំពោះលោក អំ សំអាត នាយករងទទួលបន្ទុកផ្នែកសិទ្ធិមនុស្សអង្គការលីកាដូ (Licadho) វិញបានគូសបញ្ជាក់ថា រដ្ឋាភិបាលនៃបណ្ដាប្រទេសខ្លះបានអំពាវនាវឱ្យប្រជាជនខ្លួនប្រុងប្រយ័ត្នជាមួយកម្ពុជាផង ដែលវាជះឥទ្ធិពលអាក្រក់ដល់វិស័យទេសចរណ៍កម្ពុជា ការវិនិយោគ មិនតែប៉ុណ្ណោះ វាអាចប៉ះពាល់ជំនួយ និងមូលនិធិអភិវឌ្ឍន៍ប្រទេសផង។ ប៉ុន្តែលោកសង្កេតឃើញថា រដ្ឋាភិបាលបានដាក់ចេញនូវវិធានការបន្តបន្ទាប់រួចហើយ ហើយលោកសង្ឃឹមថា វិធានការទាំងអស់នោះនឹងមានប្រសិទ្ធភាពពិតប្រាកដ។

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា ធ្លាប់បានសម្តែងការព្រួយបារម្ភថា បើកម្ពុជារអិលធ្លាក់ក្នុងបញ្ជីខ្មៅនៃការលាងលុយកខ្វក់ កម្ពុជាអាចនឹងជួបវិបត្តិនានាមិនថាវិស័យនយោបាយ និងវិស័យធនាគារ ពាក់ព័ន្ធលើយន្តការផ្ទេរប្រាក់តាមយន្តការអន្តរជាតិជាដើម។ រាជរដ្ឋាភិបាលកម្ពុជាបានសង្គ្រោះជន ដែលត្រូវគេជួញដូររាប់

យេនាក់ក្នុងយុទ្ធនាការបង្ក្រាបការជួញដូរមនុស្សនៅទូទាំងប្រទេស។ ក្រសួងមហាផ្ទៃក៏បានប្រកាសលេខទូរស័ព្ទទទួលពាក្យបណ្តឹងបន្ទាន់ជុំវិញករណីជួញដូរមនុស្សនេះដែរ ដោយកាលពីខែកន្លងទៅក្រសួងជំនាញមួយនេះទទួលពាក្យបណ្តឹងប្រមាណជាង ២០០ ករណីពីជនរងគ្រោះ៕

## ក្រសួងការងារជូនដំណឹងឲ្យពលករខ្មែរជំនាញផ្នែកថែទាំ ប្រញាប់ដាក់ពាក្យធ្វើតេស្ត ដើម្បីបានទៅធ្វើការនៅជប៉ុន

https://www.kampucheathmey.com/local-news/383059 ថ្ងៃពុធ ២៨ កញ្ញា ២០២២ ដោយ sopheak khoun

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសឲ្យពលករខ្មែរជំនាញផ្នែកថែទាំទាំងអស់ប្រញាប់មកដាក់ពាក្យធ្វើតេស្តជំនាញ និងភាសា ដើម្បីបានទៅធ្វើការនៅប្រទេសជប៉ុន ទទួលបានបទពិសោធន៍ការងារល្អៗ និងទទួលបានប្រាក់ខែខ្ពស់។

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងនៅក្នុងសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី ២៨ ខែកញ្ញានេះថា អង្គភាពទទួលបន្ទុកការធ្វើតេស្តភាសាជប៉ុន និងតេស្តជំនាញថែទាំ នឹងរៀបចំការធ្វើតេស្តភាសា និងតេស្តជំនាញផ្នែកថែទាំ តាមរយៈប្រព័ន្ធកុំព្យូទ័រ។ លោករដ្ឋមន្ត្រី បានបន្តថា ការធ្វើតេស្តភាសាជប៉ុន និងតេស្តជំនាញនេះ នឹងប្រព្រឹត្តិទៅនៅសាកលវិទ្យាល័យអន្តរជាតិ បែលធីសាខាទួលស្លែង នៅថ្ងៃទី ១៥ និង ១៦ ខែធ្នូ ឆ្នាំ ២០២២ និងថ្ងៃទី ១០ និង ១១ ខែមករា ឆ្នាំ ២០២៣ ក្នុងតម្លៃ ២២ដុល្លារអាមេរិក។ លោករដ្ឋមន្ត្រី បានបន្តទៀតថា ជំនាញផ្នែកថែទាំ នឹងធ្វើតេស្តនៅថ្ងៃទី ១៨, ២៤, ២៥ ខែធ្នូ ឆ្នាំ២០២២ និងនៅថ្ងៃទី ៨ និងទី ១៥ ខែមករា ឆ្នាំ ២០២៣ នៅវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ ដែលមានអាសយដ្ឋាន នៅសង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ក្នុងតម្លៃធ្វើតេស្តចំនួន ១៨ដុល្លារអាមេរិក។

លោករដ្ឋមន្ត្រី បានបន្ថែមទៀតថា ចំពោះការចុះឈ្មោះធ្វើតេស្តភាសាជប៉ុន និងតេស្តជំនាញបេក្ខជនត្រូវមានអាយុចាប់ពី ១៧ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌ឡើយ និងត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា៖ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬប័ណ្ណបើកបរ។ លោករដ្ឋមន្ត្រី បានបញ្ជាក់ថា ការបរិច្ឆេទនៃការធ្វើតេស្តនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅលើស្ថានភាពជំងឺកូវីដ-១៩។ យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា បច្ចុប្បន្ននេះ មានពលករខ្មែរប្រមាណជាង ១លាន ២សែននាក់ កំពុងធ្វើការនៅក្រៅប្រទេស។ ក្នុងនោះ នៅប្រទេសជប៉ុន មានចំនួន ១១,៤៥៣នាក់៕ អត្ថបទ៖ សំអឿន

## ខេត្ត Dong Thap សហការជាមួយអាជ្ញាធរមូលដ្ឋានកម្ពុជា ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

https://www.khmertimeskh.com/501158559/-dong-thap-/?p=1158559 Khmer Times September 28, 2022

ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គឺជាវិស័យមួយ នៃកិច្ចសហប្រតិបត្តិការនៅក្នុងកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខារវាងសហភាពនារី នៃខេត្ត Dong Thap ភាគខាងត្បូង និងសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខេត្តព្រៃវែងកាលពីម្សិលមិញ។ កិច្ចព្រមព្រៀងឆ្នាំ២០២២-២០២៧ ត្រូវបានចុះហត្ថលេខានៅក្នុងសន្និសីទដែលរៀបចំឡើងដោយអង្គការស្ត្រីទាំងពីរនៅទីក្រុង Cao Lanh នៃខេត្ត Dong Thap ដើម្បីពិនិត្យការងាររួមរបស់ពួកគេក្នុងរយៈពេលពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២២។ ភាគីទាំងពីរក៏បានប្តេជ្ញាថា នឹងសហការគ្នា ដើម្បីតស៊ូមតិលើកកម្ពស់ស្ត្រី និងអភិវឌ្ឍវិស័យទេសចរណ៍។ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ អង្គការស្ត្រីទាំងពីរបានចែក

រំលែកបទពិសោធន៍ក្នុងការពង្រឹងអង្គភាពរបស់ពួកគេ ពង្រីកសមាជិកភាព និងបន្តខ្លឹមសារ និងវិធីសាស្ត្រនៃប្រតិបត្តិការ។ ជាពិសេស ការសហការគ្នាក្នុងការងារទំនាក់ទំនង ដើម្បីទប់ស្កាត់ និងបង្ការការជួញដូរស្ត្រី និងកុមារឆ្លងកាត់ព្រំដែន បានបង្ហាញឱ្យឃើញនូវប្រសិទ្ធភាព។ VNA

## អ្នកនាំពាក្យក្រសួងមហាផ្ទៃ៖ ម្សិលមិញ សមត្ថកិច្ចកម្ពុជាទទួលបានបណ្តឹង ៣៤ទៀត ដែលស្នើឱ្យសង្គ្រោះជនបរទេស ៩៤នាក់

http://freshnewsasia.com/index.php/en/localnews/258809-2022-09-28-07-30-04.html 2022-09-28 02:30pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០នាថ្ងៃទី២៦ ដល់វេលាម៉ោង ៣៖០០ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ម្សិលមិញ សមត្ថកិច្ចកម្ពុជា បានទទួលសំណើ ៣៤ករណីទៀត ដែលស្នើឱ្យសង្គ្រោះជនបរទេស ៩៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង ៣៤ករណីនេះ មានចំនួន ៦សញ្ជាតិរួមមាន៖ ស្នើឱ្យសង្គ្រោះជនជាតិវៀតណាមចំនួន ៣៨នាក់, ម៉ាឡេស៊ី ០៩នាក់, ឥណ្ឌា០៦នាក់, ជនជាតិបង់ក្លាដេស ១នាក់, ចិន៣៧នាក់ និងចិនតៃវ៉ាន់២នាក់។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៣៦៨ករណី មានមនុស្ស ៨៨៧នាក់ មាន ១១សញ្ជាតិ។

**២៖** ស្រាវជ្រាវអង្កេតបឋមបាន ១៧៨សំណើ នៅសល់ ១៩០សំណើ (រកឃើញ ៣៦១នាក់, ឃាត់ខ្លួន ៥៣នាក់, បិទក្រុមហ៊ុន ១ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាបន្តស្រាវជ្រាវក្រុមហ៊ុន ៥ទីតាំង)។

សូមបញ្ជាក់ថា ថ្មីៗនេះ សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

# ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២

## សម្តេចតេជោ៖ មិនអាចយកបញ្ហាជួញដូរមនុស្ស ឬការរៀបការ

## មកបង្ខំឲ្យកម្ពុជាអនុវត្តនូវនយោបាយចិនពីរ បានទេ

https://www.kampucheathmey.com/local-news/383889 ថ្ងៃព្រហស្បតិ៍ ២៩ កញ្ញា ២០២២

សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានគូសបញ្ជាក់ថា គេមិនអាចយកបញ្ហាការជួញដូរមនុស្ស ឬបញ្ហាការរៀបការក្ដី មកបង្ខំឲ្យកម្ពុជាអនុវត្តនូវនយោបាយចិនពីរបានទេ ហើយកម្ពុជាមិនទទួលឲ្យដាក់ស្ថានបេសកកម្មណាមួយ តំណាងតៃវ៉ាន់នៅកម្ពុជាឡើយ។ សម្ដេចតេជោ ហ៊ុន សែន បានថ្លែងក្នុង «វេទិកាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៦» ក្រោមប្រធានបទ "សូមកុំយកកម្ពុជា ធ្វើជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស" នាព្រឹកថ្ងៃទី ២៩ ខែកញ្ញានេះថា កន្លងមក មានអ្នកស្នើឲ្យសម្ដេចអនុញ្ញាតឲ្យមាន ស្ថានបេសកកម្មរបស់តៃវ៉ាន់ប្រចាំនៅកម្ពុជា ដើម្បីដោះស្រាយបញ្ហាស្ត្រីប្រមាណ ៥ពាន់នាក់ ដែលត្រូវរៀបការទៅតៃវ៉ាន់។ តែឯកសារដែលអ្នកស្នើនោះ យកមកឲ្យត្រូវសម្ដេចគ្រវ៉ាត់ចោល។

សម្ដេចតេជោ ហ៊ុន សែន បានថ្លែងបន្តថា គេមិនអាចយកបញ្ហាការជួញដូរមនុស្ស ឬបញ្ហាការរៀបការក្ដី មកបង្ខំឲ្យកម្ពុជាអនុវត្តនូវនយោបាយចិនពីរ បានទេ។ សម្ដេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងបញ្ជាក់ថា «មិនអាចយកបញ្ហាការជួញដូរមនុស្ស ការរៀបការដោយស្ម័គ្រចិត្តក្ដី ឬដោយបង្ខំក្ដី យកមកបង្ខំឲ្យកម្ពុជា អនុវត្តនូវគោលនយោបាយចិនពីរបាន ទេ....កម្ពុជាទទួលដាក់នូវស្ថានទំនាក់ទំនងការទូត តែជាមួយសាធារណរដ្ឋប្រជាមានិតចិនតែប៉ុណ្ណោះ»។ ប្រមុខរាជរដ្ឋាភិបាល បានបញ្ជាក់បន្ថែមថា «អ្នកកុំយកបញ្ហារឿងស្ត្រីប៉ុន្មានរយ ប៉ុន្មានពាន់នាក់ យកមកបង្ខំឲ្យខ្ញុំទទួលដាក់បេសកកម្ម ដើម្បីថា មកដោះស្រាយការបញ្ជាក់ចេញពីការិយាល័យរបស់គេ នៅទីក្រុងភ្នំពេញ ដើម្បីបង្កើតភាពស្របរស់នៅតៃវ៉ាន់»។ សម្ដេចតេជោ ហ៊ុន សែន បានបញ្ជាក់ទៀតថា កម្ពុជា មិនឲ្យមានតំណាងតៃវ៉ាន់ណាមួយនៅក្នុងប្រទេសកម្ពុជាទេ ដោយទទួលត្រឹមតែអ្នកវិនិយោគតៃវ៉ាន់តែប៉ុណ្ណោះ ដែលកម្ពុជាមិនទទួលឲ្យដាក់ស្ថានបេសកកម្មណាមួយតំណាងតៃវ៉ាន់នៅកម្ពុជា នោះទេ៕ អត្ថបទ៖ ឃួន សុភ័ក្រ

## សម្ដេចតេជោ៖ កម្ពុជាកំពុងរួមគ្នាប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ប៉ុន្តែបញ្ហានេះ មិនមែនមានតែកម្ពុជាទេ

https://www.btv.com.kh/article/15701 2022/09/29 08:53:48 am

ភ្នំពេញ៖ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានអញ្ជើញមានប្រសាសន៍ថា ទោះបីបច្ចុប្បន្នប្រទេសកម្ពុជា ត្រូវបានចាត់ក្នុងចំណោមប្រទេសគួរព្រួយបារម្ភហើយបាននិងកំពុងរួមគ្នាប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ប៉ុន្តែសម្ដេចក៏បានលើកឡើងដែរថា ការជួញដូរមនុស្ស គឺមិនមែនមានតែប្រទេសកម្ពុជាទេ ។ សម្ដេចតេជោ ហ៊ុន សែន ប្រមុខ នៃរាជរដ្ឋាភិបាលបានមានប្រសាសន៍យ៉ាងដូច្នេះ ខណៈអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បើកវេទិកាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស លើកទី៦ ក្រោមប្រធានបទ៖ «សូមកុំយកកម្ពុជា ជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស» ។

ក្នុងវេទិកានៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វានាព្រឹកថ្ងៃទី២៩កញ្ញានេះ សម្ដេចបានមានប្រសាសន៍ថា ឥឡូវនេះ រាជរដ្ឋាភិបាលក៏ត្រូវការចូលរួមពីគ្រប់សាសនា ដើម្បីចូលរួមប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ ប៉ុន្តែទោះជាយ៉ាងណា សម្ដេចបានវាយតម្លៃថា ប្រសិនបើគ្មានការបេកស្រាយច្បាស់លាស់ទេ ប្រទេសរបស់យើងគេអាចបកស្រាយអាក្រក់បំផុតនៅលើពិភពលោក។ សម្ដេចមានប្រសាសន៍ថា ស្ថានភាពនៃការជួញដូរមនុស្ស ឧក្រិដ្ឋកម្ម ឬចំណាកស្រុកគឺមិនមែនមានតែកម្ពុជា១ទេ យ៉ាងណាមិញ ដូចជាសហរដ្ឋអាមេរិកជាដើម កន្លងមកអតីតប្រធានាធិបតី សហរដ្ឋអាមេរិក ដូណាល់ត្រាំ រហូតចង់ធ្វើរបងខ័ណ្ឌរវាងអាមេរិក និងមិចស៊ិច មិនឱ្យមានការឆ្លងចូលពីមិចស៊ិច ចូលអាមេរិកជាដើមនោះ។

សម្តេចបានផ្តាំផ្ញើឱ្យគ្រប់តួអង្គទាំងអស់ធ្វើសកម្មភាពព្រមៗគ្នាទៅលើការបង្ក្រាបគ្រឿងញៀន ល្បែងស៊ីសងខុសច្បាស់ និងជនប្រព្រឹត្តិបទល្មើសដែលនាំទៅដល់ការជួញដូរមនុស្ស ហើយត្រូវស្រាវជ្រាវយកជនប្រព្រឹត្តិបទល្មើស នៃការជួញដូរមនុស្សមកផ្តន្ទាទោសតាមច្បាប់ ជាពិសេសត្រូវមានការត្រៀមបង្ការ ទប់ស្កាត់នូវរឿងអកុសលទាំងអស់នេះ តាមរយៈវិធានការអប់រំ វិធានការច្បាប់ ជាពិសេសកុំឱ្យកូនចៅរបស់យើងក្លាយជាអ្នករងគ្រោះដោយសារតែអំពើខុសច្បាប់ទាំងអស់នេះ និងកុំឱ្យប្រទេសរបស់យើងក្លាយជាជំរក នៃអំពើវេរកម្ម និងធ្វើការគ្រប់គ្រងអាវុធឱ្យត្រឹមត្រូវ៕

## សម្តេចតេជោ កំណត់យកថ្ងៃ២០ សីហា ជារៀងរាល់ឆ្នាំ ជាទិវាជាតិនៃវេទិកាអន្តរសាសនាថ្នាក់ជាតិ

https://dap-news.com/national/2022/09/29/281899/ ByTR110Posted on September 29, 2022

ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានកំណត់យកថ្ងៃ២០សីហា ជារៀងរាល់ឆ្នាំ ជាទិវាជាតិនៃវេទិកាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីជាការជួបជុំគ្នា នៅតាមបណ្តាខេត្ត-ស្រុក-ឃុំ-ភូមិ ជាមួយគ្រប់អ្នកកាន់សាសនាដូចជា សាសនាព្រះពុទ្ធ គ្រឹះ និងឥស្លាមជាដើម ៕

## សម្តេចតេជោ ៖ ការជួញដូរមនុស្ស មិនមែនមានតែនៅកម្ពុជាទេ គឺមានលើពិភពលោក

https://dap-news.com/national/2022/09/29/281902/ ByTR110Posted on September 29, 2022

**ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានលើកឡើងថា ការជួញដូរមនុស្ស មិនមែនកើតឡើងតែនៅកម្ពុជាមួយទេ គឺមាននៅគ្រប់ប្រទេសនៅទូទាំងពិភពលោក ដែលបាននិងកំពុងកើតឡើង ហើយអាជ្ញាធរត្រូវបន្តទប់ស្កាត់ឲ្យទាន់ពេលវេលា កុំឲ្យកម្ពុជាក្លាយជាគោលដៅសុវត្ថិភាពរត់ពន្ធមនុស្ស។**

ការលើកឡើងរបស់សម្តេចតេជោបែបនេះ ក្រោយមានការរត់ពន្ធមនុស្សចូលកម្ពុជា ឬរត់ពន្ធមនុស្សចេញពីកម្ពុជាទៅប្រទេសផ្សេងៗ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើនការស្រាវជ្រាវ បង្ក្រាប ហើយអនុវត្តច្បាប់ដោយស្មើភាព និងម៉ឺងម៉ាត់ ដោយគ្មានការលើកលែងចំពោះទីតាំង និងបុគ្គល ពាក់ព័ន្ធនឹងអំពើជួញដូរ និងរត់ពន្ធមនុស្សគ្រប់ទម្រង់ នៅកម្ពុជា។ នាឱកាសអញ្ជើញជាអធិបតីក្នុង «វេទិកាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៦» ក្រោមប្រធានបទ «សូមកុំយកកម្ពុជា ធ្វើជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស» នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ សម្តេចតេជោ មានប្រសាសន៍ថា កម្ពុជាមិនល្អឥតខ្ចោះនោះទេ តែក៏មិនអាក្រក់ ដូចជនអគតិ ឬបរទេសខ្លះចោទប្រកាន់ និងវាយតម្លៃនោះដែរ លើបញ្ហាទាំងឡាយដែលកម្ពុជាមានឆន្ទៈ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្ស។

សម្តេចតេជោមានប្រសាសន៍ថា «ខ្ញុំ វាយតម្លៃស្ថានភាពរួមលើពិភពលោក ទាក់ទងទៅនឹងបញ្ហាការជួញដូរមនុស្ស ឬក៏ឧក្រិដ្ឋដែលបានកើត ការធ្វើចំណាក់ស្រុក មិនមែនមានប្រទេសកម្ពុជាមួយទេ ដែលបាននិងកំពុងកើតឡើងបញ្ហាទាំងនេះ។ យើងក្រឡេកមើលសហរដ្ឋអាមេរិក និងតំបន់អាមេរិក រហូតដល់អតីតប្រធានាធិបតី ដូណាត្រាំ ចង់ធ្វើរបបរាំងសហរដ្ឋអាមេរិក និងម៉ិចស៊ិក សំដៅដោះស្រាយអ្វី? គឺដោះស្រាយកុំឲ្យមានមនុស្សរត់ពីបណ្តាប្រទេសអាមេរិកខាងជើង និងប្រទេសដ៏ទៃទៀតនៅតំបន់នោះទៅកាន់សហរដ្ឋអាមេរិក»។

សម្តេចតេជោបន្តថា ការរត់ពន្ធមនុស្សពីប្រទេសមួយ ទៅប្រទេសមួយ ក្លាយជារឿងអកុសលសម្រាប់ប្រជាជនក្រីក្រ ក៏ប៉ុន្តែក៏ជាឱកាសនៃពួកទុច្ចរិតដែលធ្វើការងារនេះ សំដៅបម្រើផលប្រយោជន៍របស់ពួកគេ។ សម្តេចថា ការរត់ពន្ធមនុស្សនៅកម្ពុជា បើប្រៀបធៀបជាមួយបណ្តាប្រទេសមួយចំនួន មិនទាន់ធំហួសឡើយ ប៉ុន្តែបើមិនទប់ស្កាត់ទេ នឹងក្លាយជាគោលដៅសុវត្ថិភាពពួកឧក្រិដ្ឋជន រត់ពន្ធមនុស្សចូលមកកម្ពុជា ឬរត់ពន្ធមនុស្សពីកម្ពុជា ទៅអាមេរិក ដូច្នេះរួមគ្នាបន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៕

# សម្តេចតេជោ ហ៊ុន សែន ៖ រាជរដ្ឋាភិបាល ត្រូវការចូលរួមពីគ្រប់សាសនា ដើម្បីចូលរួមប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស

https://cen.com.kh/archives/540321.html Posted ByPen Srey NeatSeptember 29, 2022

ភ្នំពេញ ៖ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៩ ខែកញ្ញា ឆ្នាំ២០២២ នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានអញ្ជើញជាអធិបតីប្រារព្ធក្នុង «វេទិកាអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៦» ក្រោមប្រធានបទ ″ សូមកុំយកកម្ពុជាធ្វើជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស″។ ពិធីនេះ បានប្រារព្ធធ្វើឡើងនៅមជ្ឈមណ្ឌលពាណិជ្ជកម្ម និងពិព័ណ៌ជ្រោយចង្វារ (OCIC)។

តាមរបាយការណ៍ របស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានឲ្យដឹងថា កម្មវិធីនេះ គឺជាការបង្ហាញនូវភាពសុខដុមរមនា នៃសាសនានៅកម្ពុជា ដែលតែងតែឯកភាព សហការ គាំទ្រគ្នាទៅវិញទៅមក ដោយភាពទន់ភ្លន់ មិនមានទំនាស់ មិនប្រទូស្តរាយគ្នា មិនបង្កឱ្យមានការបែកបាក់ និងគ្រោះមហន្តរាយក្នុងសង្គម។ភាពសុខុដុម នៃសាសនា បានដើរតួជាគន្លឹះក្នុងការកសាងនូវសន្តិភាពផ្លូវចិត្ត របស់បុគ្គល និងសន្តិសុខសង្គម ព្រមទាំងជួយពង្រឹងស្មារតី មនុស្សគ្រប់រូបឲ្យរឹងប៉ឹង រួមគ្នាតស៊ូ ជម្នះនឹងការញុះញង់ អូសទាញដែលជាល្បិចកលឧក្រិដ្ឋជនជួញដូរមនុស្ស។

កម្មវិធីវេទិកាអន្តរសាសនា តែងតែត្រូវបានរៀបចំជារបៀបមិទ្ទិញទ្រង់ទ្រាយធំ ដោយមានអ្នកដឹកនាំនិកាយសាសនាទាំងឡាយ ចូលរួមប្រារព្ធពិធីតាមបែបសាសនានីមួយៗ ក្នុងពេលតែមួយ ទីកន្លែងតែមួយ គោលដៅតែមួយ ដោយឯកភាពគ្នា និងដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការ យ៉ាងច្រើនកុះករ។ នៅឆ្នាំ២០២០-២០២១ គឺជាពេលវេលាដ៏លំបាក ដែលថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូពេទ្យ អាជ្ញាធរ ក៏ដូចជាប្រជាពលរដ្ឋ បាននិងកំពុងតស៊ូ ទប់ទល់នឹងបញ្ហាប្រឈម ដែលបង្កឡើងដោយការរាតត្បាត នៃជំងឺកូវីដ-១៩ និងមេរោគបំប្លែងថ្មី ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មិនបានរៀបចំកម្មវិធីទ្រង់ទ្រាយធំឡើយ។ វេទិកាអន្តរសាសនាលើកទី៦ ឆ្នាំ២០២២ នឹងមានការចូលរួមពីថ្នាក់ដឹកនាំ ព្រះពុទ្ធសាសនា មូស្លីម កាតូលិក គ្រិស្តបរិស័ទបំណងល្អ ប្រូតេស្តង់ និងអ្នកជំនឿផ្សេងៗទៀត ព្រមទាំងតំណាងអង្គការជាតិ-អន្តរជាតិមួយចំនួនដែលកំពុងបំពេញការងារពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ប្រមាណ ១,៥០០អង្គ/នាក់។

សម្តេចតេជោ ហ៊ុន សែន ពិតជារីករាយដែលបានអញ្ជើញចូលរួមក្នុងវេទិកាជាតិអន្តរសេសាសនាប្រឆាំងការជួញដូរមនុស្សលើកទី០៦ នេះ។ សម្តេចតេជោក៏បានវាយតម្លៃខ្ពស់ និងបានកោតសរសើរចំពោះសាសនាទាំងបីដែលបានចូលរួមនៅក្នុងវេទិកាដ៏មានសារៈសំខាន់នាថ្ងៃនេះផងដែរ។ នៅថ្ងៃនេះ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានប្រកាសយកថ្ងៃទី ២០ខែសីហា ជារៀងរាល់ឆ្នាំប្រារព្ធនៅទិវាជាតិអន្តរសេសាសនាប្រឆាំងការជួញដូរមនុស្ស។ សម្តេចតេជោបានមានប្រសាសន៍បញ្ជាក់ថា ទិវានេះមិនធ្វើតែមួយថ្ងៃ២០សីហានោះទេ គឺត្រូវធ្វើជារៀងរាល់ថ្ងៃតែម្តង ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំង ទប់ស្កាត់ការជួញដូរមនុស្សនៅកម្ពុជា។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ទោះបីបច្ចុប្បន្នប្រទេសកម្ពុជា ត្រូវបានចាត់ក្នុងចំណោមប្រទេសគួរព្រួយបារម្ភ ហើយបាន និងកំពុងរួមគ្នាប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ប៉ុន្តែសម្តេចក៏បានលើកឡើងដែរថា ការជួញដូរមនុស្ស គឺមិនមែនមានតែប្រទេសកម្ពុជាទេ។សម្តេចបានមានប្រសាសន៍ថា ឥឡូវនេះ រាជរដ្ឋាភិបាលក៏ត្រូវការចូលរួមពីគ្រប់សាសនា ដើម្បីចូលរួមប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ ប៉ុន្តែទោះជាយ៉ាងណា សម្តេចបានវាយតម្លៃថា ប្រសិនបើគ្មានការបកស្រាយច្បាស់លាស់ទេ ប្រទេសរបស់យើងគេអាចបកស្រាយអាក្រក់បំផុតនៅលើពិភពលោក។

នៅថ្ងៃនេះ សម្តេចតេជោបានផ្តាំផ្ញើឱ្យគ្រប់តួអង្គទាំងអស់ធ្វើសកម្មភាពព្រមៗគ្នាទៅលើការបង្ក្រាបគ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងជនប្រព្រឹត្តិបទល្មើសដែលនាំទៅដល់ការជួញដូរមនុស្ស ហើយត្រូវស្រាវជ្រាវ

យកជនប្រព្រឹត្តិបទល្មើស នៃការជួញដូរមនុស្សមកផ្តន្ទាទោសតាមច្បាប់ ជាពិសេសត្រូវមានការត្រៀមបង្ការ ទប់ស្កាត់នូវរឿងអកុសល ទាំងអស់នេះ តាមរយៈវិធានការអប់រំ វិធានការច្បាប់ ជាពិសេសកុំឱ្យកូនចៅរបស់យើងក្លាយជាអ្នករងគ្រោះដោយសារតែអំពើខុសច្បាប់ទាំងអស់នេះ និងកុំឱ្យប្រទេសរបស់យើងក្លាយជាជំរក នៃអំពើវេរកម្ម និងធ្វើការគ្រប់គ្រងអាវុធឱ្យត្រឹមត្រូវ។ សម្តេចតេជោបានមានប្រសាសន៍បញ្ជាក់ថា រឿងរ៉ាវការបង្ក្រាបល្បែងស៊ីសងកុំចាំបាច់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃស្រែក ឬនាយករដ្ឋមន្ត្រីស្រែកបានធ្វើនោះទេ គឺអាជ្ញាធរដូចជាថ្នាក់ក្រោមជាតិហ្នឹងត្រូវតែចុះធ្វើហើយត្រូវធ្វើដូចភ្លៀងរលឹម។

សម្តេចតេជោបានថ្លែងថា បើទោះបីកម្ពុជាមិនមែនជាគោលដៅវាយប្រហារភេរវកម្ម តែត្រូវរួមគ្នាទប់ស្កាត់កុំឱ្យកម្ពុជាទៅជាជម្រករបស់ភេរវកម្ម។ សម្តេចតេជោ ហ៊ុន សែន បានបង្ហាញការជឿជាក់ថា ការបង្ក្រាបល្បែង នឹងរួមចំណែកកាត់បន្ថយការជួញដូរមនុស្ស និងបង្កើនសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម។ នៅថ្ងៃនេះ សម្តេចតេជោ ហ៊ុន សែន នៅតែបន្តអំពាវនាវពលរដ្ឋបន្តទៅទទួលយកវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ កូវីដមិនទាន់ទៅណាឆ្ងាយពីយើងនោះទេ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## សម្តេចតេជោ ហ៊ុន សែន៖ ការជួញដូរមនុស្សជាបញ្ហាសកល ដែលទាមទារឱ្យមានការរួមគ្នាគ្រប់ប្រទេស ដើម្បីប្រយុទ្ធប្រឆាំង

https://freshnewsasia.com/index.php/en/localnews/258943-2022-09-29-04-49-00.html 2022-09-29 11:49am

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានលើកឡើងថា ការជួញដូរមនុស្ស បានក្លាយទៅជាបញ្ហាសកល ដែលទាមទារឱ្យមានការរួមគ្នាគ្រប់ប្រទេស ដើម្បីប្រយុទ្ធប្រឆាំង។ ការលើកឡើងរបស់សម្តេចតេជោ បានធ្វើឡើងស្របពេលដែលកម្ពុជា បើកយុទ្ធនាការយ៉ាងក្តៅគគុកប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស កម្លាំងពលកម្ម និងត្រួតពិនិត្យជនបរទេសដែលមករស់នៅ និងធ្វើការខុសច្បាប់ នៅក្នុងប្រទេស ដោយក្នុងនោះមានការរំដោះជនរងគ្រោះ និងឃាត់ខ្លួនជនល្មើសជាច្រើននាក់។ ថ្លែងក្នុងពិធីបើក **«វេទិកាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស» នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២នេះ សម្តេចតេជោ ហ៊ុន សែន បានលើកឡើងដូច្នេះថា៖ «ទាក់ទងនឹងការជួញដូរមនុស្ស វាក្លាយទៅជាបញ្ហាសកល ដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរួម ពីប្រទេសមួយទៅកាន់ប្រទេសមួយ ហើយក៏ស្ថិតនៅក្នុងក្របខណ្ឌនៃយន្តការសហប្រតិបត្តិការទូលំទូលាយក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិផង ក្រោមឆ័ត្រនៃអង្គការតំបន់ និងអង្គការក្រៅរដ្ឋាភិបាលផងដែរ»**។

សហរដ្ឋអាមេរិក កាលពីខែកក្កដា ឆ្នាំ២០២២ កន្លងទៅ បានទម្លាក់ចំណាត់ប្រទេសកម្ពុជា រួមជាមួយប្រទេសចិន ម៉ាកាវ វៀតណាម ម៉ាឡេស៊ី មីយ៉ាន់ម៉ា កូរ៉េខាងជើង ប្រ៊ុយណេ ស៊ីរី អាហ្វហ្គានីស្ថាន ស៊ូដង់ខាងត្បូង និងរដ្ឋចំនួន១២ផ្សេងទៀត ជាប្រទេសដែលស្ថិតនៅក្នុងចំណាត់ថ្នាក់លេខ៣ ផងដែរ ពាក់ព័ន្ធនឹងការជួញដូរមនុស្ស ដែលចំណាត់ថ្នាក់នេះ ដោយសហរដ្ឋអាមេរិក បានចោទថាប្រទេស កម្ពុជា និងប្រទេសទាំងនោះគ្មានឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាល បានអះអាងថា តាំងពីដើមមក ខ្លួនពុំបានបន្ធូរដៃនៅក្នុងការទប់ស្កាត់ និងបង្ក្រាប់ករណីជួញដូរនោះឡើយ ផ្ទុយទៅវិញរាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ។

កាលពីខែមុន សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជ.ប.ជ) បានចេញសេចក្តីអំពាវនាវឱ្យសាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសជាមិត្ត បន្តសហការផ្តល់ព័ត៌មាន ឬតម្រុយនានាពាក់ព័ន្ធអំពើជួញដូរមនុស្ស ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះ នៅក្នុងប្រទេសកម្ពុជា។

គិតត្រឹមថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជា បានទទួលសំណើសរុបជាង៣០០ករណីដែលបានទទួលរងនូវទណ្ឌកម្ម ការបិទសិទ្ធិសេរីភាព និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ក្នុងនោះក៏មានការបើកការស្រាវជ្រាវបឋមចំនួន១៨០ករណីផងដែរ និងរកឃើញជនរងគ្រោះ៣៧៨នាក់ ជាមួយនឹងការឃាត់ខ្លួនជនល្មើសជាង៥០នាក់ផងដែរ៕

## សម្តេចតេជោ ហ៊ុន សែន៖ ការបង្ក្រាបល្បែងស៊ីសង នឹងរួមចំណែកកាត់បន្ថយការជួញដូរមនុស្ស និងបង្កើនសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម

http://freshnewsasia.com/index.php/en/localnews/258937-2022-09-29-04-37-01.html 2022-09-29 11:37am

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានថ្លែងបង្ហាញការជឿជាក់ថា ការបង្ក្រាបល្បែងស៊ីសង នឹងអាចចូលរួមចំណែកក្នុងកាត់បន្ថយការជួញដូរ មនុស្សបង្កើនសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម ធ្វើឱ្យភូមិឃុំមានសុវត្ថិភាព និងជួយឱ្យប្រជាពលរដ្ឋសន្សំបានប្រាក់កាស និងរស់នៅប្រកបដោយសុខដុមរមនា ជាមួយគ្នា។ ការថ្លែងរបស់សម្តេចតេជោ ហ៊ុន សែន ធ្វើឡើងក្នុងឱកាសអញ្ជើញជាអធិបតីក្នុង **«វេទិកាអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៦»** នៅព្រឹកថ្ងៃព្រហស្បតិ៍ទី២៩ ខែកញ្ញា ឆ្នាំ២០២២នេះ។ សម្តេចតេជោ ហ៊ុន សែន បានថ្លែងដូចនេះថា **«ជាមួយនឹងយុទ្ធនាការមានគោលដៅជាក់លាក់ ដែលយើងបាននឹងកំពុងធ្វើរួមមកហើយនេះ និងបន្តធ្វើតទៅទៀត ខ្ញុំជឿជាក់ថាយុទ្ធនាការបង្ក្រាបល្បែងស៊ីសងនេះ វានឹងរួមចំណែកដើម្បីកាត់បន្ថយនូវការជួញដូរមនុស្ស និងបង្កើនសុវត្ថិភាព ភូមិឃុំមានសុវត្ថិភាព ព្រោះបើកាលណា ចាញ់ល្បែងហើយ វាចាប់ផ្តើមមានបញ្ហាហើយ»**។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងបញ្ជាក់ទៀតថា កាលណាចាញ់ល្បែងហើយ ដំបូងឡើយមានបញ្ហាអស់លុយ ហើយបញ្ហាជម្លោះក្នុងគ្រួសារកើតឡើង បើប្តីលេងឆ្នោត ប្រពន្ធលេងឡូតូស្មើដៃគ្នានោះ ថ្ងៃណាឈ្នះនឹងញញឹមរកគ្នា តែបើថ្ងៃណាចាញ់វិញនោះនឹងបោកចានបោកឆ្នាំងមុខគ្នា ដូចពាក្យខ្មែរតែងថា «ឈ្នះមុខខ្លាញ់ ចាញ់មុខសេះ។ សម្តេចតេជោ បានបន្ថែមទៀតថា ដើម្បីឱ្យភូមិឃុំមានសុវត្ថិភាព ដាច់ខាតត្រូវតែជំរុញការអនុវត្តន៍លុបបំបាត់ល្បែងស៊ីសងនៅតាមមូលដ្ឋាន ជំរុញបំបាត់ការជួញដូរ គ្រឿងញៀននៅតាមមូលដ្ឋាន ដែលនេះវាគឺជាធាតុផ្សំសម្រាប់ការទប់ស្កាត់ការជួញដូរមនុស្ស។ សម្តេចបានគុសបញ្ជាក់ទៀតថា បើអនុវត្តន៍បានយ៉ាងដូចនេះ ប្រជាពលរដ្ឋនឹងសន្សំបានប្រាក់កាស និងអាចរស់នៅជាមួយគ្នាប្រកបដោយសុខដុមរមនា។

សូមបញ្ជាក់ដែរថា ពាក់ព័ន្ធនឹងការបង្ក្រាបល្បែងស៊ីសងខុសច្បាប់នេះ សម្តេចតេជោ ហ៊ុន សែន កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២ បានចេញបញ្ជាយ៉ាងដាច់ណាត់ ឱ្យមន្ត្រីពាក់ព័ន្ធគ្រប់រូប ជាពិសេសមន្ត្រីថ្នាក់ក្រោមជាតិ ត្រូវបង្ក្រាបឱ្យអស់នូវល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ និងបានព្រមានដកអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រូបណាដែលមិនទទួលខុសត្រូវលើតួនាទីបណ្តោយឱ្យល្បែងស៊ីសងរីកសាយភាយក្នុងមូលដ្ឋានរបស់ខ្លួន។ សម្តេចតេជោ ហ៊ុន សែន បានគូសរំលេចថា ល្បែងស៊ីសងទាំងនេះមិនបានចំណេញដល់សេដ្ឋកិច្ចជាតិនោះទេ ផ្ទុយ

ទៅវិញបាននាំឱ្យប្រជាពលរដ្ឋ ដែលងប់ងុល នឹងល្បែងត្រូវលក់គោលក់ក្របី ផ្ទះសម្បែង ដោយសារតែល្បែងនេះផងដែរ៕

## សម្តេចតេជោះ ពីមុនជនជាតិខ្មែរ ត្រូវគេជួញដូរទៅបរទេស តែឥឡូវជនបរទេស ត្រូវគេជួញដូរមកស្រុកខ្មែរវិញម្តង

https://dap-news.com/national/2022/09/29/281942/ ByKD102Posted on September 29, 2022

**ភ្នំពេញ៖ ខណៈកំពុងបើកប្រតិបត្តិការ បង្ក្រាបករណីជួញដូរមនុស្សនៅកម្ពុជា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានលើកឡើងបែបហួសចិត្តថា កាលពីដើមឡើយមានប្រជាពលរដ្ឋខ្មែរ ត្រូវបានជួញដូរទៅបរទេស ប៉ុន្តែបច្ចុប្បន្នជនបរទេសត្រូវបាន គេធ្វើការជួញដូរមកស្រុកខ្មែរវិញម្តង។** ត្រង់ចំណុចនេះ សម្តេចបានលើកជាសំណួរថា តើបណ្តាលមកពីអ្វី? តែសម្តេចក៏បានផ្តល់ជាចំលើយមកវិញដែរ គឺទាក់ទិនទៅនឹងកម្ពុជាមានសន្តិភាព ព្រោះបើមិនដូច្នេះទេ គេមិនអាចមកកម្ពុជានោះទេ ។ នេះជាប្រសាសន៍របស់សម្តេចតេជោ ក្នុងវេទិកាជាតិអន្តរសាសនា ប្រឆាំងការជួញដូរមនុស្សលើកទី៦ នាថ្ងៃ២៩ កញ្ញា ។ សម្តេចសង្កត់ធ្ងន់ថា សភាពការណ៍មានការប្រែប្រួល គឺចាប់ពីពលរដ្ឋកម្ពុជាធ្វើការ នៅក្រៅប្រទេសត្រូវបាន ចាញ់បោកគេក្នុងការជួញដូរ តែបច្ចុប្បន្នបែរជាមានជនបរទេស ត្រូវគេជួញដូរមកស្រុកខ្មែរវិញម្តង ។ ដូច្នេះចំណុចនេះត្រូវតែមើលឃើញ ។

បន្ថែមពីលើករណីនេះទៀត សម្តេចគូសបញ្ជាក់ថា "ពីមុនមានជនជាតិខ្មែរ ត្រូវគេជួញដូរទៅបរទេស តែឥឡូវមានជនបរទេស ត្រូវគេជួញដូរមកស្រុកខ្មែរវិញម្តង តើចំណុចនេះផ្តើមចេញពីអ្វី? ចំណុចនេះគឺទាក់ទិន នឹងកម្ពុជាមានសន្តិភាព ។ បើមិនដូច្នេះទេ គេមិនអាចមកកម្ពុជានោះទេ។ ប៉ុន្តែក៏ផ្តើមចេញអំពីចំណុច ខ្សែយណាមួយដែលបង្កើត ឲ្យមានបញ្ហាដែលគេជ្រៀតចូល មកធ្វើអាជីវកម្មនៅកម្ពុជា ដូច្នេះវត្តមានដែលជនបរទេស ដែលគេជួញដូរនៅកម្ពុជា គឺផ្ទុយស្រឡះនូវអ្វីដែល បានកើតពីមុនដែលមានតែ គេជួញដូរតែខ្មែរទៅបរទេស ហើយការជួញដូរនេះ ខ្លះធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ"។ បើតាមសម្តេចតេជោបញ្ជាក់ ក្រោយទទួលរបាយការណ៍ពីសម្តេច ស ខេង ដែលជាប្រធានគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បន្ទាប់ពីបើកប្រតិបត្តិការ បង្ក្រាបទ្រង់ទ្រាយធំ កាលពីប៉ុន្មានខែមុននោះ បានរកឃើញជនបរទេស ជាច្រើនពាន់នាក់ និងមានសញ្ជាតិច្រើនកំពុងធ្វើការនៅកម្ពុជា ប៉ុន្តែចំពោះជនរងគ្រោះ ដែលគេជួញដូរនៅកម្ពុជា មានត្រឹមតែរយនាក់ប៉ុណ្ណោះ ហើយក៏បានជួយសង្គ្រោះ ពួកគេជាបន្តបន្ទាប់ផងដែរ។ បើសម្តេចដដែល ជនបរទេសមកធ្វើការកម្ពុជា ហើយរងគ្រោះមានឥណ្ឌូនេស៊ី និងម៉ាឡេស៊ីជាដើម ៕

## សម្តេចតេជោ ហ៊ុន សែន អំពាវនាវឱ្យប្រយុទ្ធប្រឆាំងទាំងអស់គ្នា ដើម្បីកុំឱ្យកម្ពុជាក្លាយទៅជាឋានសួគ៌នៃឧក្រិដ្ឋកម្ម ជាកន្លែងលាងលុយកខ្វក់ ជាកន្លែងជួញដូរមនុស្ស

http://freshnewsasia.com/index.php/en/localnews/258932-2022-09-29-04-13-37.html 2022-09-29 11:13am

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានអំពាវនាវទៅកាន់កម្លាំងសមត្ថកិច្ច អាជ្ញាធរទាំងថ្នាក់ជាតិនិងមូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធទាំងផ្នែកអាណាចក្រ និងសាសនាសូមរួមគ្នាប្រយុទ្ធប្រឆាំងនឹងអំពើទុច្ចរិតឱ្យបានព្រមៗគ្នា ដើម្បីកុំឱ្យកម្ពុជាក្លាយជាកន្លែងឧក្រិដ្ឋកម្ម កន្លែងលាងលុយ ជួញដូរមនុស្ស និងបទល្មើសផ្សេងៗ។ ការអំពាវនាវរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី គឺបានធ្វើឡើងក្នុងវេទិកាអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស នាព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២។ នាឱកាសនោះ សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា យោងតាមរបាយការណ៍បានរាយការណ៍ពីករណីល្បែងស៊ីសងនៅតាមមូលដ្ឋាន អំពើជួញដូរមនុស្ស ការលាងលុយ

កខ្វក់ និងការឆបោកពលករពីក្រៅប្រទេសឱ្យធ្វើការនៅកម្ពុជា ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាមិនអាចនៅស្ងៀមបានឡើយ ពោលគឺត្រូវតែរួមគ្នាប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងលុបបំបាត់ឱ្យបានខ្លាំងក្លាប្រកបដោយ ប្រសិទ្ធភាព។ សម្តេចតេជោក៏បានអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធទាំងផ្នែកអាណាចក្រ ពុទ្ធចក្រ និងសាសនាផ្សេងៗទៀតសូមរួមគ្នាប្រយុទ្ធប្រឆាំងនឹងអំពើទុច្ចរិតនៅក្នុងប្រទេស ដើម្បីកុំឱ្យកម្ពុជាក្លាយជាកន្លែងឧក្រិដ្ឋកម្ម កន្លែងលាងលុយ និងជួញដូរមនុស្ស។ សម្តេចបានថ្លែងយ៉ាងដូច្នេះថា «**កុំឱ្យកម្ពុជាក្លាយទៅជាឋានសួគ៌នៃឧក្រិដ្ឋកម្ម ជាកន្លែងលាងលុយកខ្វក់ ជាកន្លែងជួញដូរមនុស្ស**»។

សម្តេចតេជោ ហ៊ុន សែន ក៏បានទូលស្នើព្រះសង្ឃនៃព្រះពុទ្ធសាសនា ក៏ដូចជាសាសនាដទៃសូមបង្កើនការផ្សព្វផ្សាយធម៌ ឬស្មារតីអប់រំចិត្តល្អៗឱ្យបានច្រើនដល់ប្រជាជន ដើម្បីជួយដាស់តឿនអូសទាញពួកគេឱ្យចាកផុតពីអំពើអបាយមុខ អំពើទុច្ចរិត ឬក៏ការលេងល្បែងភ្នាល់ផ្សេងៗ ដោយសម្តេចតេជោជឿជាក់ថាមានតែប្រើប្រាស់វិធីអប់រំតាមបែបសាសនា និងការអប់រំតាមបែបរដ្ឋបាលនោះទេ ទើបអាចជួយបញ្ជៀសអំពើទុច្ចរិតទាំងឡាយ ជួយឱ្យប្រជាជនមានសុខដុមរមនា សល់ថវិកា និងបង្កើនកម្លាំងកសាងសង្គម។ ជាមួយគ្នានោះ សម្តេចប្រមុខរាជរដ្ឋាភិបាលក៏បានបញ្ជាទៅកាន់កងកម្លាំងសមត្ថកិច្ច និងមន្ត្រីពាក់ព័ន្ធទាំងអស់ត្រូវធ្វើសកម្មភាពបង្ក្រាប ទប់ស្កាត់ លុបបំបាត់ឱ្យបានព្រមៗគ្នា ទើបអាចជោគជ័យទៅបាន។ សម្តេចបានបន្តថា នេះជាយុទ្ធនាការដ៏ធំមួយមានគោលដៅជាក់លាក់ដែលរាជរដ្ឋាភិបាលបាននិងកំពុងធ្វើ និងបន្តធ្វើមិនឱ្យទន់ដៃនោះឡើយ។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានបន្តទៀតថា យុទ្ធនាការបង្ក្រាបល្បែងស៊ីសងនេះនឹងរួមចំណែកក្នុងការកាត់បន្ថយនូវការជួញដូរមនុស្ស និងបង្កើនប្រសិទ្ធភាពដល់ការអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព។ ការងារនេះក៏នឹងកាត់បន្ថយបញ្ហាចាញ់ល្បែង ការបង្ខំឱ្យធ្វើការងារសងបំណុល ហិង្សានិងជម្លោះក្នុងគ្រួសារ ព្រមទាំងការជួញដូរមនុស្សផងដែរ ពីព្រោះនេះជាធាតុផ្សំសម្រាប់ការទប់ស្កាត់អំពើជួញដូរមនុស្ស៕

## ពីថ្ងៃ១៨ សីហា ដល់បច្ចុប្បន្នហ្វេសប៊ុក សម្តេច ស ខេង ទទួលបណ្តឹង៣៦៨ករណី និងសង្គ្រោះជនរងគ្រោះ ៣៦១នាក់

https://dap-news.com/national/2022/09/29/281980/ ByPH104Posted on September 29, 2022

**ភ្នំពេញ ៖ សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឲ្យដឹងថា គិតចាប់តាំងពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រហូតដល់បច្ចុប្បន្ន ចំនួនបណ្តឹងទទួលបានតាមប្រព័ន្ធហ្វេសប៊ុកសម្តេច និងទូរស័ព្ទទាន់ហេតុការណ៍ប្រមាណ ៣៦៨ករណី និងសង្គ្រោះជនរងគ្រោះ៣៦១នាក់។**

ក្នុងវេទិកាអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៦ ឆ្នាំ២០២២ ក្រោមប្រធានបទ «សូមកុំយកកម្ពុជាធ្វើជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស» ក្រោមអធិបតីភាព សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ សម្តេច ស ខេង បានថ្លែងថា «គិតចាប់តាំង ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រហូតដល់បច្ចុប្បន្នចំនួនបណ្តឹង ដែលបានទទួលតាមប្រព័ន្ធហ្វេសប៊ុក និងប្រព័ន្ធទូរស័ព្ទ ទាន់ហេតុការណ៍ មានប្រមាណ ៣៦៨ករណី។ ក្នុងនោះ ជនល្មើស បានធ្វើសកម្មភាព ក្នុងខេត្តព្រះសីហនុ ច្រើនជាងគេ គឺរហូតដល់ ២៤៩ករណី»។

សម្តេចបន្តថា ក្រុមប្រតិបត្តិការ បានធ្វើសកម្មភាពរុករកជនល្មើស នៅតាមបណ្តាលពីតាំងសង្ស័យ ដោយបានសង្គ្រោះជនរងគ្រោះ ៣៦១នាក់។ ក្នុងនោះ រងគ្រោះដោយអំពើជួញដូរ ៩ករណី មានមនុស្ស ៥៤នាក់ មាន ៦ សញ្ជាតិ។ លើសពីនេះ សមត្ថកិច្ច ក៏បានធ្វើការឃាត់ខ្លួនជនសង្ស័យប្រព្រឹត្តិបទល្មើស ៤១នាក់ មាន៣សញ្ជាតិ បញ្ជូនទៅតុលាការ និងរឹបអូសភស្តុតាង និងបិទទីតាំងដើម្បីស៊ើបអង្កេត ប្រមូលភស្តុតាងបន្ថែមទៀត។

សម្តេចបន្ថែមថា ក្រៅពីនេះ ក៏មានជនរងគ្រោះ រាប់រាយនាក់ទៀត ដែលត្រូវបានសមត្ថកិច្ច រកឃើញ ទោះបីអ្នកទាំងនោះ មិនមែនជាជនរងគ្រោះ ដោយអំពើជួញដូរ មនុស្សក៏ដោយ ក៏ត្រូវបានសមត្ថកិច្ចរំដោះចេញពីតាំងគ្រោះថ្នាក់ នាំទៅកាន់ទីតាំងសុវត្ថិភាព ក្រោមកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលពីបណ្តាលស្ថានទូត នៃបណ្តាប្រទេសសាមី ដែលមានការពាក់ព័ន្ធ ដើម្បីវិលត្រឡប់ទៅកាន់មាតុភូមិ និងជួបជុំក្រុមគ្រួសារវិញ ដោយសុវត្ថិភាព ។

## ថ្ងៃនេះ ក្រសួងមហាផ្ទៃទទួល បានសំណើ៩ករណីទៀត ពាក់ព័ន្ធនឹង ការសុំអន្តរាគមន៍ឱ្យសង្គ្រោះជនបរទេស

http://freshnewsasia.com/index.php/en/localnews/258889-2022-09-28-13-45-59.html 2022-09-28 08:45pm

(ភ្នំពេញ)៖ គិតចាប់ពីម៉ោង៣រសៀល ថ្ងៃទី២៧ ដល់ម៉ោង៣រសៀល ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២នេះ សមត្ថកិច្ចកម្ពុជា បានទទួលសំណើចំនួន៩ករណីទៀត ពាក់ព័ន្ធនឹងការសុំអន្តរាគមន៍ឱ្យស្វែងរក និងសង្គ្រោះជនបរទេស ចំនួន១៧នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ ក្នុងចំណោមបណ្តឹងទាំងនោះមាន នៅខេត្តកណ្តាល៣ករណី ឧត្តរមានជ័យ១ករណី ព្រះសីហនុ២ករណី ស្វាយរៀង២ករណី និងរាជធានីភ្នំពេញ១ករណី។ គិតត្រឹមថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១នេះ សម្តេចក្រឡាហោម ស ខេង បានទទួលសំណើសរុបចំនួន៣៦៨ករណី ក្នុងនោះក៏មានការបើកការស្រាវជ្រាវបឋមចំនួន១៨០ករណីផងដែរ និងរកឃើញជនរងគ្រោះ៣៧៨នាក់ ជាមួយនឹងការឃាត់ខ្លួនជនល្មើសចំនួន៥៣នាក់៕

## ប្រទេសម៉ាឡេស៊ីនិយាយថាករណីឆបោកការងារនឹងមិនប៉ះពាល់ដល់ ការពិភាក្សានាំពលករពីកម្ពុជាទេ

https://www.khmertimeskh.com/501159327//?p=1159327 Khmer Times September 29, 2022

រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស លោក Datuk Seri M Saravanan មានប្រសាសន៍ថា ករណីពលករម៉ាឡេស៊ីជាជនរងគ្រោះនៃការបោកប្រាស់ការងារនៅកម្ពុជា ដូចដែលបានរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយនាពេលថ្មីៗនេះ នឹងមិនប៉ះពាល់ដល់កិច្ចពិភាក្សាដើម្បីនាំពលករពីកម្ពុជាទៅកាន់ប្រទេសម៉ាឡេស៊ីនោះទេ។ លោកថា ករណីបែបនេះក៏អាចកើតមានក្នុងប្រទេសផ្សេង មិនមែនតែក្នុងប្រទេសកម្ពុជាទេ ហើយក៏កើតមាននៅប្រទេសម៉ាឡេស៊ីដែរ។ លោកបានមានប្រសាសន៍ថា "វានឹងមិនប៉ះពាល់ដល់ការពិភាក្សារបស់យើងទេ ពីព្រោះទាំងនេះត្រូវបានចាត់ទុកថាជាករណីពិសេស ឬដាច់ដោយឡែក ហើយលើសពីការរំពឹងទុករបស់យើង ... ប៉ុន្តែយើងនឹងព្យាយាមស្វែងរកដំណោះស្រាយប្រកបដោយមិត្តភាព" ។

លោក Saravanan ដែលជាអនុប្រធានសភាឥណ្ឌាម៉ាឡេស៊ី (MIC) បានធ្វើអត្ថាធិប្បាយលើរបាយការណ៍កាលពីថ្ងៃទី៩ ខែកញ្ញា ដែលក្នុងនោះជនជាតិម៉ាឡេស៊ីចំនួន២៤ នាក់ដែលមានអាយុចន្លោះពី២០ ទៅ ៣០ឆ្នាំ ដែលបានធ្លាក់ខ្លួនរងគ្រោះដោយការបោកប្រាស់ការងារនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា ត្រូវបាននាំយកមកប្រទេសកំណើតវិញដោយជោគជ័យ។ កាលពីខែសីហាកន្លងទៅនេះ លោក Saravanan ត្រូវបានគេរាយការណ៍ថា ម៉ាឡេស៊ីត្រូវបានគេរំពឹងថានឹងចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពីការជ្រើសរើសពលករបម្រើការងារតាមផ្ទះនៅក្នុងខែកញ្ញា៕ *Bernama*

# ការបង្កើតរឿង«វះយកគ្រឿងក្នុង» គឺជាល្បិចបំភ័យរបស់ក្រុមជួញដូរមនុស្សនៅកម្ពុជា

https://www.khmertimeskh.com/501159135//?p=1159135 គង់ អារី និង ស៊ុត គឹមសឿន
September 29, 2022

ខណៈដែលមានករណីបង្ក្រាបការជួញដូរមនុស្ស និង កម្លាំងពលកម្មកំពុងបន្តធ្វើក្នុងប្រទេសកម្ពុជា ក្នុងនោះករណី ជួយសង្គ្រោះចុងក្រោយលើជនរងគ្រោះចំនួន៤៦៩នាក់ក្នុង ខេត្តព្រះសីហនុនោះ ក៏មានការអះអាងថាមានការជួញដូរសរីរាង្គមកលើជនបរទេស ដែលត្រូវបានមេខ្យល់ក្រុមជួញដូរបានធបោកក្រោមរូបភាពផ្តល់ការងារដែរ។ ការអះអាងដែលថាការជួញដូរសរីរាង្គត្រូវបានគេរាយការណ៍ថា ត្រូវបានលើកឡើងដោយ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានផ្សព្វផ្សាយទូលំទូលាយក្នុងតំបន់ និងបង្កឲ្យមានការភ័យខ្លាចនិងការរារែកក្នុងការធ្វើដំណើរមកកាន់កម្ពុជាក្នុងចំណោមជនបរទេស។ យ៉ាងណាក៏ដោយ លទ្ធផលនៃការស៊ើបអង្កេតបានបង្ហាញថា ការចោទប្រកាន់ទាំងអស់នោះគឺជាការគំរាមកំហែងដែលក្រុមជួញដូរមនុស្សប្រើ ដើម្បីដាក់គំនាបឱ្យជនរងគ្រោះស្តាប់តាមការបង្គាប់របស់ពួកគេ។ ពាក្យចចាមអារ៉ាមនេះបានលេចឡើងបន្ទាប់ពីមានការសាយភាយនៃឃ្លីបវីដេអូនៅក្នុងប្លុកនិងគេហទំព័រជាច្រើនទៀតដែលលើកឡើងពីករណីជួញដូរមនុស្ស ដែលជនរងគ្រោះជាជនបរទេសមកពីក្រៅស្រុកត្រូវបានទាក់ទាញឱ្យមកធ្វើការនៅកម្ពុជា និងប្រទេសពីរទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាថ្នូរនឹងប្រាក់ខែច្រើនគិតជាប្រាក់ដុល្លារ ឬអត្ថប្រយោជន៍គួរឱ្យទាក់ទាញជាច្រើន ប៉ុន្តែក្រោយមកបែរជាត្រូវបានគេជួញដូរឱ្យធ្វើការឱ្យក្រុមខុសច្បាប់ទៅវិញ។

មន្ត្រីប៉ូលិសនៅក្នុងប្រទេសអាស៊ានបានប្រាប់សារព័ត៌មានខ្មែរថាមស៍ក្នុងលក្ខខណ្ឌបញ្ចេញឈ្មោះថា ការចោទប្រកាន់ទាំងនោះបណ្តាលឲ្យប៉ះពាល់និងបំផ្លាញប្រទេសកម្ពុជា និងដល់ប្រទេសពីរផ្សេងទៀត ខណៈការករណីជួញដូរមនុស្សសម្រាប់ការងារល្បែងស៊ីសងតាមអនឡាញនិងការបោកបញ្ឆោតផ្សេងទៀត កំពុងកើតឡើងយ៉ាងហោចណាស់ក្នុងពាក់កណ្តាលនៃបណ្តាប្រទេសអាស៊ាន។ មន្ត្រីប៉ូលិសមួយរូបបាននិយាយថា៖ « ករណីជួញដូរមនុស្ស ទាំងនេះត្រូវបានគូសបញ្ជាក់ដោយបណ្តាប្រទេសដទៃទៀត ក៏ដូចជាបណ្តាប្រព ័ន្ធផ្សព្វផ្សាយ ។ ទោះជាយ៉ាងក៏ដោយកម្ពុជារងគ្រោះដោយអយុត្តិធម៌ និងនិន្នាភាពចំណាត់ការប៉ូលិសក្នុងការបង្ក្រាបករណីធបោកដែលបានបង្ក្រាបករណីជនសង្ស័យរាប់រយនាក់ដែលទទួលបានការឆ្លើយតបតិចតួចនៅពេលប្រៀបធៀបទៅនឹងការចោទប្រកាន់»។ មន្ត្រីប៉ូលិសរូបនោះបានឲ្យដឹងទៀតថា៖ « ការស៊ើបអង្កេតរបស់យើងបង្ហាញថា ការលើកឡើងពីការវះយកគ្រឿងក្នុងគឺជាការបំភិតបំភ័យដែលធ្វើឡើងដោយក្រុមជួញដូរដើម្បីឱ្យជនរងគ្រោះស្តាប់បង្គាប់របស់ពួកគេ ដោយគិតមកដល់ពេលនេះ ពុំទាន់មានភស្តុតាងណាមួយបង្ហាញពីការជួញដូរសរីរាង្គនោះឡើយ»។

លោកបានបន្ថែមថា ចំនុចសំខាន់គឺស្ថិតនៅត្រង់ខាងប្រទេសដើមរបស់ជនរងគ្រោះដែលត្រូវបានជួញដូរមនុស្ស ជាកន្លែងដែលពួកគេត្រូវបានជ្រើសរើសក្លាយជាជនរងគ្រោះ ដោយសង្កត់ធ្ងន់ទៅលើការកាត់បន្ថយនិងលុបបំបាត់ក្រុមជួញដូរខុសច្បាប់ទាំងនេះ។ លោកបានបន្តថា៖ « ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីលោក Datuk Eldeen Husaini Mohd Hashim ថ្លែងថា ក្រុមការងារអាស៊ានរួមគ្នាអាចជាចម្លើយ ខណៈការចែករំលែកព័ត៌មាន និងការស៊ើបការណ៍សម្ងាត់ ការសម្របសម្រួល និងការវិភាគអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការកម្ទេចក្រុម ទាំងនេះ»។

កាលពីខែកក្កដាកន្លងទៅ សហរដ្ឋអាមេរិកបានទម្លាក់កម្ពុជាមកនៅចំណាត់ថ្នាក់ទី ៣ ដែលជាចំណាត់ថ្នាក់ទាបបំផុតលើសន្ទស្សន៍ការជួញដូរមនុស្សរបស់ខ្លួន បន្ទាប់ពីចោទប្រកាន់កម្ពុជាថា បានបរាជ័យក្នុងការដោះស្រាយបញ្ហានេះឲ្យមានប្រសិទ្ធភាព។

ក៏ប៉ុន្តែ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ធ្លាប់បានលើកឡើងថា៖ « រហូតដល់ ៩៩.៩៥% នៃមេខ្លោងនៃឧក្រិដ្ឋកម្ម មិនមែនជាជនជាតិខ្មែរទេ។ អ្នកដែលរៀបចំផែនការបញ្ជូនមនុស្សពីប្រទេសផ្សេងមកកម្ពុជា

មិនមែនជាជនជាតិខ្មែរទេ»។ នៅឆ្នាំ ២០១៧ ជនជាតិខ្មែរពីរនាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់នៅតុលាការពីបទជួញដូរផ្នែករាងកាយ ក្នុងករណីដែលជនជាតិខ្មែរត្រូវបានបញ្ចុះបញ្ចូល និងសូកប៉ាន់ឱ្យធ្វើដំណើរទៅប្រទេសឥណ្ឌាដើម្បីលក់ក្រលៀន ឬសរីរាង្គសំខាន់ៗផ្សេងទៀត។ នៅឆ្នាំ ២០១៦ រដ្ឋសភាបានអនុម័តច្បាប់ហាមឃាត់ការប្តូរសរីរាង្គក្នុងគោលបំណងទប់ស្កាត់ការជួញដូរនៅក្នុងទម្រង់ពាណិជ្ជកម្មដែលគេហៅថា «ទីផ្សារក្រហម»។

ប៉ូលីសបាននិយាយថា វាជារឿងសំខាន់ក្នុងការកត់សម្គាល់ថា ការជួញដូរសរីរាង្គ និងការជួញដូរមនុស្សសម្រាប់ការយកចេញសរីរាង្គគឺខុសគ្នា ហើយ ករណីជាញឹកញាប់ត្រូវបានយល់ច្រឡំទាំងស្រុង។ ការជួញដូរមនុស្សដើម្បីយកសរីរាង្គចេញ កើតឡើងនៅពេលដែលមនុស្សត្រូវបានបង្ខំ ឬបោកបញ្ឆោតឱ្យបោះបង់ចោលសរីរាង្គណាមួយ នៅពេលដែលពួកគេយល់ព្រមលក់សរីរាង្គមួយ ប៉ុន្តែត្រូវបានគេបោកប្រាស់ ឬនៅពេលដែលមនុស្សត្រូវបានចាប់ពង្រត់ និងប្រើប្រាស់គ្រឿងញៀន ហើយក្រោយមកត្រូវដកសរីរាង្គរបស់ពួកគេចេញ។

មន្ត្រីក្រុមការងារបានលើកឡើងថា ចំណុចសំខាន់ដែលត្រូវបញ្ជាក់គឺថា មិនមានករណីបែបនេះនៅកម្ពុជាដែលពាក់ព័ន្ធនឹងការជួញដូរផ្នែកសរីរាង្គមនុស្សដោយក្រុមអ្នកជួញដូរមនុស្សឡើយ។ ជាមួយគ្នានេះ ក្នុងប្រតិបត្តិការបង្ក្រាបជាបន្តបន្ទាប់ទៀត អាជ្ញាធរខេត្តព្រះសីហនុ បានជួយសង្គ្រោះជនរងគ្រោះដោយសារការជួញដូរមនុស្ស ឬជួញដូរផ្លូវភេទចំនួន៤៦៩នាក់ ក្នុងអំឡុងការបង្ក្រាបនៅខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២២ ខែកញ្ញា។ ជនរងគ្រោះស្ថិតក្នុងចំណោមជនបរទេសចំនួន ១ ៤៨០ នាក់ (ស្រី ១៩៩ នាក់) ដែលត្រូវបានឃុំខ្លួនក្នុងកំឡុងប្រតិបត្តិការជួញដូរមនុស្ស ការឃុំខ្លួនខុសច្បាប់ ការជួញដូរផ្លូវភេទ និងល្បែងស៊ីសងតាមអ៊ីនធឺណិតខុសច្បាប់ផងដែរ។ ក្នុងចំណោមជនបរទេសទាំង ១ ៤៨០នាក់ មាន ៥៨៨នាក់ (ស្រី ៧០នាក់) បានស្នាក់នៅ និងធ្វើការក្នុងប្រទេសកម្ពុជា ដោយគ្មានលិខិតឆ្លងដែន ប័ណ្ណការងារ និងឯកសារផ្លូវច្បាប់ផ្សេងៗ។

អ្នកនាំពាក្យរដ្ឋបាលខេត្តព្រះសីហនុ លោក ឃាង ភារម្យ មានប្រសាសន៍កាលពីថ្ងៃអង្គារថា ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែកញ្ញា អាជ្ញាធរបានឆ្មក់ចូលអគារចំនួន៣នៃក្រុមហ៊ុន Pao Yong Technology ស្ថិតក្នុងភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ដើម្បីពិនិត្យមើលអាជ្ញាប័ណ្ណអាជីវកម្ម និងការងាររបស់ជនបរទេស ព្រមទាំងស៊ើបអង្កេតប្រសិនបើមានការឃាត់ខ្លួនដោយខុសច្បាប់ ការធ្វើទារុណកម្ម ការជួញដូរមនុស្ស និងល្បែងស៊ីសងខុសច្បាប់កំពុងត្រូវបានអនុវត្ត។ អាជ្ញាធរបានរកឃើញជនបរទេសចំនួន៥៩៧នាក់ ក្នុងនោះ១៨៤នាក់ (ស្រី២១នាក់) ជាជនអន្តោប្រវេសន៍ខុសច្បាប់មកពីប្រទេសចំនួន៣។ ជនជាតិចិនចំនួន ១០០នាក់ (ស្រី២នាក់) វៀតណាម ៧៩ នាក់ (ស្រី១៨នាក់)និងម៉ាឡេស៊ី ៥នាក់ (ស្រីម្នាក់) ត្រូវបានបញ្ជូនទៅនាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីនិរទេសចេញពីកម្ពុជា។ លោកបន្តថា ជនបរទេសចំនួន៣៥៧នាក់ទៀត (ស្រី៤៩នាក់) ត្រូវបានរកឃើញថា ធ្វើការដោយគ្មានប័ណ្ណការងារ ហើយត្រូវបាននគរបាលនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ធ្វើការផាកពិន័យ រួចអនុញ្ញាតឲ្យដាក់ពាក្យសុំប័ណ្ណការងារពីមន្ទីរការងារខេត្ត។ លោកបានបន្តថា ការស៊ើបអង្កេតរបស់នាយកដ្ឋានប្រឆាំងល្បែងស៊ីសងពាណិជ្ជកម្ម និងនាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិតនៃអគ្គស្នងការនគរបាលជាតិ មិនបានរកឃើញសញ្ញានៃការចាប់ឃុំឃាំង ការធ្វើទារុណកម្ម ការជួញដូរមនុស្ស និងល្បែងស៊ីសងតាមប្រព័អ៊ិនធឺណេតខុសច្បាប់នោះទេ ប៉ុន្តែពួកគេពាក់ព័ន្ធករណីផ្សេង ដូចជាការប្រើប្រាស់ពលកម្មបរទេសខុសច្បាប់។

ចាប់ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២១ ខែកញ្ញា អាជ្ញាធរបានឆ្មក់ចូលអគារចំនួន ៣ របស់ Galaxy World ស្ថិតក្នុងភូមិ ៤ សង្កាត់លេខ ៤ ក្រុងព្រះសីហនុផងដែរដោយគេបានរកឃើញជនបរទេសចំនួន ៤១៤ នាក់ (ស្រី ៤២ នាក់) នៃ ៥ សញ្ជាតិនៅកន្លែងនោះ។ ក្នុងនោះមានជនជាតិចិនចំនួន៣៥១នាក់ (ស្រី៣០នាក់) ឡាវ២នាក់ វៀតណាម៤៦នាក់ ម៉ាឡេស៊ី១០នាក់ និងឥណ្ឌា១០នាក់ (ស្រី៥នាក់)។ ក្នុងនោះ ១៦៨នាក់ (ស្រី១៧នាក់) ត្រូវបាន

រកឃើញរស់នៅ និងធ្វើការដោយគ្មានឯកសារត្រឹមត្រូវ និង២០៨នាក់ (ស្រី២៣នាក់) ត្រូវបានអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ពិន័យជាប្រាក់សរុបប្រមាណ ២ម៉ឺនដុល្លារ ដោយសារមិនមានប័ណ្ណការងារ។ ចាប់ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២២ ខែកញ្ញា អាជ្ញាធរបានឆ្មក់ចូលអគារចំនួន ៨ របស់ក្រុមហ៊ុន Jing Chhay Technology ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ។ អាជ្ញាធរបានជួយសង្គ្រោះជនបរទេសចំនួន ៤៦៩ នាក់(ស្រី ៧៥ នាក់) ដែលជាជនរងគ្រោះនៃការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទដែលពាក់ព័ន្ធនឹងក្រុមល្បែងអនឡាញ។ ជនរងគ្រោះមានជនជាតិចិន ២៧៤នាក់ (ស្រី៣៣នាក់) តៃវ៉ាន់៦នាក់ វៀតណាម ១៥៨នាក់ (ស្រី៣៤នាក់) ម៉ាឡេស៊ី ១៥នាក់ (ស្រី២នាក់) ឥណ្ឌូណេស៊ី ៣នាក់ (ស្រី២នាក់)ឥណ្ឌា៤នាក់ ថៃ៣នាក់ (ស្រី១នាក់) បង់ក្លាដែស ១នាក់ និងមីយ៉ាន់ម៉ាម្នាក់ និងស្ត្រីជនជាតិរុស្ស៊ីពីរនាក់។ លោក ភារម្យ បាននិយាយថា នគរបាលប្រឆាំងការជួញដូរមនុស្សខេត្តកំពុងស៊ើបអង្កេតករណីជួញដូរមនុស្ស និងពេស្យាចារ បានបញ្ជូនជនសង្ស័យ៥នាក់ទៅតុលាការ ហើយកំពុងបន្តស៊ើបអង្កេតលើករណីលាងលុយកខ្វក់ផងដែរ។

ស្នងការនគរបាលខេត្តព្រះសីហនុ លោកឧត្តមសេនីយ៍ទោ ជួន ណារិទ្ធ បានមានប្រសាសន៍ថា អាជ្ញាធរនឹងបន្តចុះត្រួតពិនិត្យទីតាំងអាជីវកម្មដែលសង្ស័យគ្មានច្បាប់អនុញ្ញាត។ លោកមានប្រសាសន៍ថា វិធានការច្បាប់តឹងរ៉ឹងចំពោះម្ចាស់អាជីវកម្មក្នុងករណីបទល្មើស នឹងត្រូវចាត់វិធានការរហូតដល់ខេត្តព្រះសីហនុទាំងមូលលែងមានបញ្ហាបែបនេះតទៅទៀត។ នៅពេលចោទសួរថា តើមានការអះអាងពីការប្រមូលផលសរីរាង្គក្នុងពេលសាកសួរជនរងគ្រោះឬអត់នោះ លោកឧត្តមសេនីយ៍ ណារិន បដិសេធមិនធ្វើអត្ថាធិប្បាយទេ។ លោកឧត្តមសេនីយ៍ ណារិន មានប្រសាសន៍ថា៖ « ខ្ញុំមិនអាចផ្តល់ព័ត៌មានលម្អិតអំពីជនសង្ស័យដែលត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងការបង្រ្កាបបានទេ ព្រោះការស៊ើបអង្កេតកំពុងបន្ត»។ លោកមានប្រសាសន៍ថា៖ « ខ្ញុំក៏មិនអាចផ្តល់ព័ត៌មានលម្អិតអំពីជនរងគ្រោះដែរ ហើយគ្រាន់តែអាចបង្ហាញពីការបង្រ្កាបប៉ុណ្ណោះ»៕